# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ទុតិយភាគ

## ៨

ព. ស. ២៥៥៧

# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ទុតិយភាគ

## ៨


រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្ដើមប្រែរៀបរៀងដោយខ្ញុំព្រះករុណា ខ្ញុំបាទ សុន្ទរ៍-សារមៀន



ព. ស. ២៥៥៧ គ. ស. ២០១៣

សម្មោហ

វិនោទនី

អដ្ឋកថា

ព្រះអភិធម្ម

បិដក

ទុតិយភាគ

៨

ព. ស.

២៥៥៧

# សេចក្ដីបញ្ជាក់

*គម្ពីរ* **អដ្ឋកថាព្រះអភិធម្ម** *ជាពាក្យអធិប្បាយសេចក្ដីក្នុងព្រះអភិ-ធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគ គឺ*

**១.បឋមភាគ** *ឈ្មោះ* **អដ្ឋសាលិនី** *អធិប្បាយគម្ពីរ* ***ធម្មសង្គណី***

**២.ទុតិយភាគ** *ឈ្មោះ* **សម្មោហវិនោទនី** *អធិប្បាយគម្ពីរ* ***វិភង្គ***

**៣.តតិយភាគ** *ឈ្មោះ* **បរមត្ថទីបនី** *អធិប្បាយគម្ពីរ* ***បញ្ចបករណ៍*** *តាំងពី* ***ធាតុកថា*** *រហូតដល់ចប់គម្ពីរ* ***បដ្ឋាន*** *ទាំងអស់ ។*

*បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ។ ឯសៀវភៅដែលលោកអ្នកកំពុងអាននេះ ជាគម្ពីរអដ្ឋ-កថា* ***អភិធម្មបិដក ទុតិយភាគ ៨*** *កើតឡើងដោយស្នាព្រះហស្តនៃ* ***ព្រះពុទ្ធឃោសាចារ្យ*** *ជាជនជាតិឥណ្ឌា បានរចនានៅឯប្រទេសសិរីលង្កាក្រោយការបរិនិព្វានរបស់ព្រះពុទ្ធជាង ៩០០ឆ្នាំ ។ ឯរូបខ្ញុំផ្ទាល់វិញគ្រាន់តែជាអ្នកផ្ដើមប្រែសម្រួលរៀបរៀង ជាបណ្ដោះអាសន្ន សម្រាប់អ្នកដែលត្រូវការសិក្សារៀនសូត្រតែប៉ុណ្ណោះ ព្រោះហេតុដូច្នេះ ខ្ញុំ* ***សូមបញ្ជាក់*** *និងសូមទោសជាមុន ចំពោះអ្នកអាន និងអ្នកសិក្សាជាទីគោរពថាខ្ញុំពុំមានសមត្ថភាពនៃការចេះដឹងគ្រប់គ្រាន់ ដូចសេចក្ដីនៃធម៌ដែលមាននៅ*

ក្នុងសៀវភៅនេះទេ ថែមទាំងសមត្ថភាពនៃការប្រែសម្រួល និងរៀបរៀង នេះទៀត មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ ការខុសឆ្គាំឆ្គង ទាំងនុ៎ះ មានដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ តែខ្ញុំយល់ ឃើញថា **មានប្រសើរជាងគ្មាន** ព្រោះសៀវភៅដែលរងនូវព្រះអភិធម្ម បិដកបែបនេះ មិនទាន់ដែលមានគ្រប់គ្រាន់ក្នុងប្រទេសយើងទេ ដូច្នេះ យើងក៏អាចឧទាហរណ៍បានថា ៖

* សម័យណា ដែលមានភាពអន្ធការ សូម្បីតែពន្លឺអំពិលអំពែក ក៏ អាចភ្លឺបានដែរ ។

* សម័យណា គ្មានដើមឈើ គេក៏អាចយកដើមល្ហុង ធ្វើជាដើម ឈើបានដែរ ។ ល ។ (ស្រីហិតោបទេស) ។

ព្រោះហេតុដូច្នេះ ខ្ញុំសូមផ្ញើនូវគម្ពីរនេះ ដល់លោកអ្នកសិក្សា និង វិញ្ញូជនទាំងឡាយ ជួយកែសម្រួល សម្រាប់សិក្សាតរៀងទៅ ។ ដើម្បី សម្រួលដល់ការបូកសរុបមតិកែតម្រូវ ក្នុងអត្ថបទនេះ សូមមេត្តា ជ្រាបដូចតទៅ ៖

១-សូមសរសេរឈ្មោះ ទីកន្លែង និងថ្ងៃ ខែ ឆ្នាំ ដែលកែ សម្រេចនៅលើក្រដាសដែលផ្ញើមក ។

២-ចុះលេខទំព័រ បន្ទាត់ ក្នុងតារាងលេខ ១ និងលេខ ២ ។ ចំពោះសេចក្តី ពាក្យ ឃ្លា ឬអក្ខរាវិរុទ្ធត្រង់ណា ដែលយល់ថា មិនទាន់ត្រឹមត្រូវ សូមសរសេរចុះក្នុងតារាងលេខ ៣ ។ ចំណែកពាក្យដែលយល់ថា គួរកែមកជាយ៉ាងណាវិញនោះ សូមសរសេរចុះក្នុងតារាងលេខ ៤ ។

៣-ប្រសិនបើ ការកែតម្រូវនោះ មានឯកសារបញ្ជាក់ សូមចុះឈ្មោះឯកសារនោះ ក្នុងតារាងលេខ ៥ ។

៤-នៅក្នុងតារាងលេខ ៦ សម្រាប់បញ្ជាក់បន្ថែម ចំពោះករណីពិសេសណា ដែលប្រាថ្នាចង់បញ្ជាក់បន្ថែម ។

៥-សូមផ្ញើកំណែមកខ្ញុំ ដោយការទាក់ទង តាមទូរសព្ទដែលមាននៅក្នុងសៀវភៅនេះស្រាប់ ។

* ប្រសិនបើ នៅក្នុងសៀវភៅនេះ មានការខុសទំព័រលេខរៀង អក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣

ខ្ញុំព្រះករុណា ខ្ញុំបាទ ***សុន្ទរ៍ សាមៀន***

សូមអរព្រះគុណ និងអរគុណ

# តារាងកែតម្រូវ "ឮ"

## នាមឈ្មោះអ្នកជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួល

## អដ្ឋកថាឧត្តិយភាគ ៨ នេះ មាន ៖

-ភិក្ខុសាមណេរជាពហូសូតក្នុងវត្តធុតង្គ ( ចំការដូង) មាន ៦ រូប

-ភិក្ខុសាមណេរជាពហូសូតក្នុងវត្តនិគ្រោធវ័ន ( គល់ទទឹង) មាន ៦ រូប

-ភិក្ខុខន្តិជាតិកោ **ថៃ គិរម្យ**

-ភិក្ខុវិនយប្បញ្ញោ **សឹម រតនះ**

-ភិក្ខុធម្មរក្ខិតោ **គង់ វន**

-ឧបាសក **សៀរង វ័ណ្ណា**

-ឧបាសក **រឿង សិរីសុគន្ធ**

-អ្នកគ្រូ **ធី សុធី**

-ឧបាសក **ងួន សុខុម** ៕

## អ្នកមានឧបការៈក្នុងការរៀបចំធម្មទាននេះ

*-លោកបញ្ញាបទីបោ* ***ព្រឿង ប៊ុនធឿន***

*-លោកខន្តិជាតិកោ* ***ថៃ គិរក្ស***

*-ឧបាសិកា* ***លី ស៊ីវង្ស*** *ជាដើម*

*-ឧបាសិកា* ***ងុន ស៊ូគី*** *ជាដើម*

*-ភិក្ខុសាមណេរ* ***វត្តគីរីរម្យចាស់*** *ជាដើម*

- ឧបាសិកា **អ៊ឹ សរុន** ជាដើម
- លោក **ហេង សុវណ្ណារ៉ា**
- ឧបាសក **ស្រុង ចាន់ណា** និងក្រុមគ្រួសារ
- ឧបាសក **ម៉ៅ ផុន ហៅ ពុយ** និងសហការី ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនា ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសន្ដានចិត្តដ៏ល្អរបស់គុណម្ចាស់ ញាតិញោមជាពុទ្ធបរិស័ទទាំងក្នុង និងក្រៅប្រទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយពិនិត្យកែសម្រួល ព្រមទាំងចំណាយរូបិយវត្ថុជាដើម ដើម្បីជំរុញឲ្យអត្ថបទនៃគម្ពីរនេះ ចេញជារូបរាងឡើង ។

បន្ទាប់ពីទុតិយភាគ ៨ នេះទៅ ខ្ញុំនឹងដំណើរការបោះពុម្ពនូវតតិយភាគ ៩ ជាបន្តទៀត ។

អាស្រ័យហេតុនេះ បើព្រះគុណម្ចាស់ ញាតិញោមត្រូវការចូលប្រាក់ដើម្បីថតចម្លងជាធម្មទាន ឬយកផ្ទាល់ខ្លួន ឬក៏យកទៅតម្កល់តាមវត្តនានា សូមមេត្តាទាក់ទងតាមរយៈទូរសព្ទដូចខាងក្រោមនេះ ៖

០៩២ ៩០ ៨២ ៦៥

០៩៧ ២៣ ៣០ ២១៥

០១៦ ៨៦ ៥២ ៣៨

# ឧទ្ទិសកថា

ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង ទាំងក្រៅប្រទេស, ***អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន*** រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ ***ហ៊ុន សែន*** ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស ទាំងក្រៅប្រទេស មានលោកគ្រូអគ្គបណ្ឌិត ***ប៊ុត សាវង្ស*** ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូមទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះ គ្រប់ៗ រូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។

***ដោយអំណាចនៃមហាកុសលផលធម្មទាននេះ សូមឱ្យ ៖***

*-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ*

*-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា*

*-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ*

*-សត្វទាំងឡាយ រក្សានូវខ្លួន ឱ្យបានជាសុខតរៀងទៅ ។*

..........................................................................................................................................................................................

**តារាងកែតម្រូវ**

**អដ្ឋកថានុត្តិយភាគ ៨**

សម្រាប់បោះពុម្ពលើកទី ៣

ថ្ងៃទី ....... ខែ ..... ឆ្នាំ ...

ឈ្មោះ .........................

អាសយដ្ឋាន .................

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ឯកសារយោង | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |

# សម្មោហវិនោទនី
# អដ្ឋកថាព្រះអភិធម្មបិដក
## ទុតិយភាគ ៨

**មាតិកាធម៌** **ទំព័រ**

### ១៦-អដ្ឋកថាញាណវិភង្គ


អធិប្បាយបទមាតិកា ..... ..... ..... .... ..... ..... ..... ..... ..... ..... ..... ១
សម្ដែងអំពីកម្លាំងកាយរបស់ព្រះតថាគត ..... ..... ..... ...... .... .... .... ៤
សម្ដែងអំពីកម្លាំងញាណរបស់ព្រះតថាគត ..... ..... ..... ..... .... ...... ៦
សម្ដែងអំពីកម្លាំង ១0 របស់ព្រះតថាគត ..... ..... ..... ..... .... ..... ១៤
សម្ដែងអំពីកម្លាំងរបស់ព្រះតថាគតទី ១ .... .... .... .... .... ..... ..... ១៥
” ” ២ .... .... .... .... .... ..... .... ១៦
” ” ៣ .... .... .... .... .... ..... ..... ១៦
” ” ៤ ..... ..... ..... ..... ..... ..... ១៧
” ” ៥ .... .... .... .... .... ..... .... ១៧
” ” ៦ .... .... .... .... .... ..... ..... ១៧
” ” ៧ .... .... .... .... ..... ..... ..... ១៨

## អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**


សម្ដែងអំពីកម្លាំងរបស់ព្រះតថាគតទី ៨-១០ ..... ...... ..... ..... ១៩

អដ្ឋកថាឯកកនិទ្ទេស

អធិប្បាយញាណវត្ថុពួក ១ .... .... .... .... ...... .... ..... ..... ..... ២១

ហេតុនៃការយល់សប្តិ ៤ .... .... .... .... .... ...... ..... ..... ....... ៣១

អដ្ឋកថាទុកនិទ្ទេស

អធិប្បាយញាណវត្ថុពួក ២ .... .... .... .... ...... ...... ..... ..... ..... ៣៧

ន័យរបស់អដ្ឋកថាដែលជាបាលីមុត្តកៈ ម្យ៉ាងទៀត .... ..... .... ៣៨-៣៩

អដ្ឋកថាតិកនិទ្ទេស

អធិប្បាយញាណវត្ថុពួក ៣ }
ចិន្តាមយបញ្ញា } ..... ..... ..... ..... ...... .... .... .... ៤១

ន័យរបស់ហីនកម្ម .... .... .... .... .... ..... .... ..... .... .... .... ..... ៤២

ន័យរបស់ឧក្កដ្ឋកម្ម .... .... .... .... .... ..... .... ..... .... .... .... ..... ៤៣

ន័យរបស់សិប្បៈទាំង ២ យ៉ាង .... .... ...... .... .... ..... ..... ..... ៤៣

អធិប្បាយសុតាមយបញ្ញា .... .... .... .... .... ..... .... .... .... ...... ៤៧

” ភាវនាមយបញ្ញា .... .... .... .... .... ..... .... ..... ..... .... ៤៧

” ទានមយបញ្ញា .... .... ..... .... .... ..... .... ..... ..... ..... ៤៧

” សីលមយបញ្ញា .... .... .... ...... ..... .... ..... .... ....... ៤៨

” អធិសីលបញ្ញាជាដើម .... ..... .... .... .... ..... ..... ...... ៤៩

## សម្ពោហវិនោទនី

មាតិកាធម៌ ទំព័រ


” អាយកោសល្លជាដើម .... .... .... .... .... ..... .... ........ ៥២

**អដ្ឋកថាចតុក្កនិទ្ទេស**

អធិប្បាយញាណវត្ថុពួក ៤ ..... ..... ..... ..... ..... ..... ..... ..... ..... ៥៤

” មគ្គសមង្គិញ្ញាណ ..... ..... ..... ..... ..... ..... ..... ..... ..... ៥៦

” ធម្មញ្ញាណជាដើម ..... ..... ..... ..... ..... ..... ..... ....... ៥៦

” ហានគាមិនីបញ្ញាជាដើម ..... ..... ..... ..... ..... ..... ..... ៦២

” បដិបទានៃបញ្ញា ៤ ..... ..... ..... ..... ..... ..... ..... ..... ៦៥

” អារម្មណ៍នៃបញ្ញា ៤ ..... ..... ..... ..... ..... ..... ..... ៦៦

” មគ្គសមង្គិញ្ញាណជាដើម ..... ..... ..... .. ..... ..... ..... ៦៧

**អដ្ឋកថាបញ្ចកនិទ្ទេស**

អធិប្បាយញាណវត្ថុពួក ៥ ..... ..... ..... ..... ..... ..... ..... ..... ..... ៦៧

” សម្មាសមាធិមានឈាន ៥ ..... ..... ..... ..... ..... ..... ..... ៦៨

**អដ្ឋកថាឆក្កនិទ្ទេស**

អធិប្បាយញាណវត្ថុពួក ៦ ..... ..... ..... ..... ..... .... ..... ..... ..... ៧០

**អដ្ឋកថាសត្តកនិទ្ទេស**

អធិប្បាយញាណវត្ថុពួក ៧ ..... ..... ..... ..... ..... ..... ..... ..... .... ៧២

**អដ្ឋកថាអដ្ឋកនិទ្ទេស**

អធិប្បាយញាណវត្ថុពួក ៨ ..... ..... ..... ..... ...... ..... ..... ..... ... ៧៥

## អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**


**អដ្ឋកថានវកនិទ្ទេស**

អធិប្បាយញាណវត្ថុពួក ៩ ..... ..... ..... ...... ..... ..... ..... ..... ៧៥

**អដ្ឋកថាទសកនិទ្ទេស**

អធិប្បាយញាណវត្ថុពួក ១០
” កម្លាំងទី ១ របស់ព្រះតថាគត } ..... ..... ...... ..... ៧៦

វិនិច្ឆ័យអំពីកម្ម ..... ..... ..... ..... ..... ..... ..... ..... ..... ..... ...... ៨៣

” ទ្វារ ..... ..... ..... ..... ..... ..... ..... ...... ..... ...... ៨៧

” ការតាំងនៅរហូតកប្ប ..... ..... ...... ..... ..... ..... ...... ៨៨

” បាកៈ គឺផលរបស់កម្ម ..... ..... ..... .... ..... ..... ....... ៨៨

” សាធារណៈជាដើម ..... ..... ..... .. ..... ..... ..... ..... ៨៩

អធិប្បាយលោកធាតុពុទ្ធក្ខេត្ត ..... ..... ..... ..... ..... ..... ..... ..... ៩៣

អន្តរធាន ៣ យ៉ាង ..... ..... ..... ..... ..... ..... ..... ..... ..... ....... ៩៥

បរិនិព្វាន ៣ យ៉ាង ..... ..... ..... ..... ..... ..... ..... ..... ..... ....... ៩៨

មិលិន្ទបញ្ហា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ......... ១០១

អធិប្បាយការកើតឡើងនៃស្តេចចក្រពត្តិ ..... ..... ..... ..... ........ ១០៩

” ស្ត្រីជាព្រះអរហន្តសម្មាសម្ពុទ្ធជាដើមមិនបាន ..... ... ..... ១១០

” កាយទុច្ចរិតជាដើមមិនកើតផលគួរប្រាថ្នាជាដើម ....... ១១៣

” បុគ្គលដែលដល់ព្រមដោយកាយទុច្ចរិតជាដើម ........ ... ១១៤

## សម្ពោហវិនោទនី

**មាតិកាធម៌** **ទំព័រ**


អធិប្បាយកម្លាំងទី ២ របស់ព្រះតថាគត សម្ដែងអំពីកម្មសមាទានជាបាប ..... ..... ..... ..... ..... ១១៧

" " ជាកុសល ..... ..... ..... ..... ..... ...... .... ១២៥

រឿងព្រះបាទទីបរាជ ..... ..... ..... ..... .... ..... ..... ..... ..... ..... ១២៦

រឿងព្រះថេរៈ ឈ្មោះថា មហាសោណៈ ..... ....... ..... ..... ..... ១៣០

រឿងវត្តពុកនិគ្រោធត្ថេរ ..... ..... ..... .. ..... ..... ..... ..... ....... ១៣៨

រឿងព្រះបាទកូដកណ្ណរាជ ..... ..... ..... ..... ........ ..... ...... ...... ១៤៣

ឧបមាដោយអាមាត្យ ..... ..... ........ ..... ..... ..... ..... ..... ..... ១៤៥

កម្មក្នុងបដិសម្ភិទាមគ្គ ..... ..... ..... ....... ..... ..... ..... ...... ...... ១៤៧

អធិប្បាយញាណជាកម្លាំងទី ៣ ..... ..... .. ..... ..... ..... ..... ..... ១៤៩

" " ទី ៤ ....... ..... ..... ..... ..... ..... ..... ១៥៣

" " ទី ៥ ..... ..... ..... .. ..... ..... ..... ..... ១៥៥

" " ទី ៦ ..... ..... ........ ..... ..... ..... ..... ១៥៨

សម្ដែងអំពីអាសយៈរបស់សត្វដែលមិនអាស្រ័យវដ្តៈ .... ..... ....... ១៦០

ពាក្យរបស់អាចារ្យទាំងឡាយ ..... ..... ..... ..... ..... ..... ..... ......១៦១

សម្ដែងអំពីនិទ្ទេសនៃអនុស័យ ..... ..... ..... ..... .... ..... ..... ១៦៣

" " ចរិតជាដើម ..... ..... ...... ..... ..... ..... ...... ១៦៤

" " ភព្វបុគ្គល និងអភព្វបុគ្គលជាដើម ....... ..... ១៦៦

## អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**


អធិប្បាយញាណជាកម្លាំងទី ៧ ..... ...... ....... ..... ..... ..... ..... ១៦៧

សម្តែងអំពីសមាធិ ៣ ..... ..... ..... ..... ..... ..... ..... ..... .... ..... ១៧០

អធិប្បាយញាណជាកម្លាំងទី ៨ ..... ..... ........ ..... ..... ..... ..... ១៧១

” ” ទី ៩ .... ..... ..... .... ...... ..... ..... ១៧១

” ” ទី ១០ .... .... ....... ..... ..... ..... .... ១៧២


## ១៧. អដ្ឋកថាខុទ្ទកវត្ថុវិភង្គ


ការកំណត់បទមាតិកា ..... ..... ..... ..... ..... ..... . ..... ..... ...... ១៧៥


**អដ្ឋកថាឯកកនិទ្ទេស**


អធិប្បាយមាតិកាពួកមួយ ..... ..... ..... ..... ..... ..... ..... ...... ១៧៦

សម្តែងអំពីការស្រវឹងក្នុងជាតិជាដើម ..... ..... ..... ..... ..... ..... ១៧៦

សម្តែងអំពីការស្រវឹងក្នុងភាពមិនមានរោគជាដើម ..... ........ ..... ១៧៧

” ” ក្នុងភាពជាកំលោះក្រមុំ ..... ..... .. ..... ...... ១៧៨

” ” ក្នុងជីវិត ..... ..... ..... ..... ....... ..... ...... ១៧៨

” ” ក្នុងលាភ ..... ..... ..... ..... ..... ....... ...... ១៧៨

” ” ក្នុងសក្ការៈ ..... ..... ..... ...... ..... ..... ..... ១៧៩

” ” ក្នុងការធ្វើសេចក្តីគោរព ..... ..... .... ..... .....១៧៩

## សម្មោហវិនោទនី

**មាតិកាចម៌** **ទំព័រ**


សម្តែងអំពីការស្រវឹងក្នុងភាពជាមេដឹកនាំ ..... .... ..... ...... ..... ១៧៩

” ” ក្នុងបរិវារ ..... ..... ........ ..... ..... ..... ..... ១៨០

” ” ក្នុងភោគសម្បត្តិ ..... ....... ..... ..... ..... .... ១៨០

” ” ក្នុងពណ៌សម្បុរ ..... ...... ..... ..... ..... ..... ១៨១

” ” ក្នុងការសិក្សា ..... ........ ..... ..... ..... ..... ១៨១

” ” ក្នុងបដិភាណ ..... ...... ..... ..... ..... ..... ១៨១

” ” ក្នុងរត្តញ្ញូ ..... ....... ..... ..... ..... ..... ...... ១៨២

” ” ក្នុងការកាន់បិណ្ឌបាតជាវត្ត ..... ... ..... ....... ១៨២

” ” ដោយមិនមាននរណាមើលងាយ ... ..... ...... ១៨២

” ” ក្នុងឥរិយាបថ ..... ..... ..... ..... ..... ...... ១៨៣

” ” ក្នុងឫទ្ធិ ..... ..... ..... ..... ....... ..... ...... ១៨៣

” ” ក្នុងយសស័ក្តិ ..... ..... ......... ..... ..... ..... ១៨៣

” ” ក្នុងសីល ..... ..... ..... ..... .... ..... ..... ...... ១៨៤

” ” ក្នុងសមាធិ ..... ..... ..... ... ..... ..... .... .... ១៨៤

” ” ក្នុងសិប្បៈ ..... ..... ..... ..... ..... ..... ..... ១៨៤

” ” ក្នុងភាពជាអ្នកមានកម្ពស់ ....... ..... ..... .... ១៨៥

” ” ” ទំហំ ..... .. ..... ..... ..... ១៨៥

” ” ” ទ្រង់ទ្រាយ ......... ..... .. ១៨៥

## អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**


សម្ដែងអំពីការស្រវឹងក្នុងរាងកាយដែលបរិបូណ៌ ..... ...... ..... .....១៨៦

**បមាទនិទ្ទេស**

អធិប្បាយពាក្យថា សេចក្ដីប្រមាទ ..... ..... ..... ..... .... ..... ...... ១៨៦

**ថម្ភនិទ្ទេស**

អធិប្បាយការរឹងត្អឹង ..... ..... ..... ..... ..... ..... ..... ..... ..... ......១៨៨

**សារម្ភនិទ្ទេស**

អធិប្បាយការប្រណាំងប្រជែង ..... ..... ..... ..... ..... ..... ..... .... ១៨៩

**អត្រិច្ឆតានិទ្ទេស**

អធិប្បាយការចង់បានហួសប្រមាណ ..... ..... ........ ..... ..... .... ១៩០

រឿងអ្នកចង់បានហួសប្រមាណ ..... ..... .. ...... ..... ..... ..... ..... ១៩២

រឿងបុត្រនៃសេដ្ឋី ..... ..... ..... ..... .... ..... ..... ..... ..... ..... ១៩៣

រឿងអាមាត្យ ..... ..... ..... ..... ..... ..... .. ..... ..... ..... ..... ..... ១៩៦

**មហិច្ឆតានិទ្ទេស**

អធិប្បាយការប្រាថ្នាច្រើន ឬការស្រេកឃ្លាន ..... ..... ..... ..... ១៩៦

រឿងភិក្ខុកំលោះ ..... ..... ..... ..... ..... ..... . ..... ..... ..... ...... ១៩៨

**បាបិច្ឆតានិទ្ទេស**

អធិប្បាយការប្រាថ្នាលាមក ..... ..... ..... ....... ..... ..... ..... .... ១៩៩

រឿងចាដិអរហន្ត ( អរហន្តពាងទឹក) ..... ..... ....... ..... ..... ..... ២០៤

## សម្មោហវិនោទនី

**មាតិកាធម៌** **ទំព័រ**


រឿងបារោហអរហន្ត ( អរហន្តពួរជ្រៃ) ..... ..... ........ ..... ..... ... ២០៥

**សិង្គនិទ្ទេស**

អធិប្បាយការនិយាយចាក់ដោត ..... ..... ........ ..... ..... ..... ..... ២០៦

**តិន្តិណនិទ្ទេស**

អធិប្បាយការនិយាយរារាំង ..... ..... .. ..... ..... ..... ..... ..... ..... ២០៧

**ចាបល្យនិទ្ទេស**

អធិប្បាយការពេញចិត្តតុបតែង ..... ..... ........ ..... ..... ..... ..... ២០៨

**អសភាគវុត្តិនិទ្ទេស**

អធិប្បាយការប្រព្រឹត្តិមិនសមគួរ ..... ..... ...... ..... ..... ..... ..... ២០៩

**អរតិនិទ្ទេស**

អធិប្បាយការមិនត្រេកអរ .... ..... ..... ....... ..... ..... ..... ..... ២០១០

**តន្ទីនិទ្ទេស**

អធិប្បាយការងោកងុយ ..... ..... ..... ..... ..... . ..... ..... ..... ... ២១១

**វិជម្ភិតានិទ្ទេស**

អធិប្បាយការពត់កាយ ..... ..... ..... ..... ..... ....... ..... ..... ..... ២១១

**ភត្តសម្មទនិទ្ទេស**

អធិប្បាយការស្រវឹងអាហារ ..... ..... ....... ..... ..... ..... ..... .... ២១២

**កុហនានិទ្ទេស**

## អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**


អធិប្បាយការបោកបញ្ឆោត ..... ..... ..... . ..... ..... ..... ..... .... ២១៣

លបនានិទ្ទេស

អធិប្បាយការនិយាយរាក់ទាក់ ..... ..... ..... .... ..... ...... ..... .... ២១៩

នេមិត្តិកតានិទ្ទេស

អធិប្បាយការធ្វើនិមិត្ត ..... ..... .... ..... ..... ..... .. ..... ..... ..... ២២២

និប្បេសិកតានិទ្ទេស

អធិប្បាយការនិយាយតិះដៀល ..... ..... ..... .... ..... .... .... ២២៤

លាភេន លាភំ និជិគីសនតានិទ្ទេស

អធិប្បាយការទាក់លាភ ដោយលាភ ..... ..... ..... ..... ..... ..... ២២៦

សេយ្យមាននិទ្ទេស

អធិប្បាយការសម្គាល់ថា ខ្លួនលើសគេ ..... ..... ..... ..... ..... .... ២២៧

សទិសមាននិទ្ទេស

អធិប្បាយការសម្គាល់ថា ខ្លួនស្មើគេ ..... ..... ..... ...... ..... ...... ២២៧

ហីនមាននិទ្ទេស

អធិប្បាយការសម្គាល់ថា ខ្លួនអន់ជាងគេ ..... ..... .... ..... ..... .... ២២៨

មានាតិមាននិទ្ទេស

អធិប្បាយការប្រកាន់ខ្លួន និងការឆ្មើងឆ្មៃ ..... ..... ...... ..... ..... ២៣២

អធិមាននិទ្ទេស

## សម្មោហវិនោទនី

**មាតិកាធម៌** **ទំព័រ**


អធិប្បាយការសម្គាល់ថា បានពន្លុះធម៌វិសេស ..... ...... ..... ..... ២៣៣

រឿងព្រះមហានាគត្ថេរ ..... ..... ..... ..... ..... ..... ...... ..... ..... ២៣៥

**អស្មិមាននិទ្ទេស**

អធិប្បាយការសម្គាល់ថា មានអត្តា ..... ..... ..... ..... ..... ...... ២៣៧

**មិច្ឆាមាននិទ្ទេស**

អធិប្បាយការប្រកាន់ខ្លួនខុស ..... ..... ..... ..... ..... ....... ..... ... ២៣៨

**អជ្ឈកថាទុកនិទ្ទេស**

អធិប្បាយមាតិកា ២ ប្រភេទ ..... ..... ..... ..... ..... ..... ..... ..... ២៤២

**មាយានិទ្ទេស**

អធិប្បាយការបោកប្រាស់ ..... ..... ..... ........ ..... ..... ..... ......២៤៥

**សាថេយ្យនិទ្ទេស**

អធិប្បាយការអួតអាង ..... ..... ..... ..... ..... ...... ...... ..... ...... ២៤៧

**អនជ្ជវនិទ្ទេស**

អធិប្បាយការមិនស្មោះត្រង់ ..... ..... ..... ..... ....... ..... ..... ..... ២៤៨

**អមទ្ទវនិទ្ទេស**

អធិប្បាយការមិនទន់ភ្លន់ ..... ..... ..... ..... ..... ... ..... ..... ....... ២៤៨

**សព្ភោជននិទ្ទេស**

អធិប្បាយកិលេសជាគ្រឿងចងទុក ..... ..... ..... ..... .... ..... ...... ២៤៩

# អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**


**អដ្ឋកថាតិកនិទ្ទេស**

អធិប្បាយមាតិកាពួក ៣ .... ..... ..... ..... ..... ..... ..... ..... ...... ២៥១

**ទុច្ចរិតនិទ្ទេស**

អធិប្បាយទុច្ចរិត ..... ..... ..... ..... ..... ..... ..... ....... ..... ..... ២៥១

**ឯសនានិទ្ទេស**

អធិប្បាយការស្វែងរក ..... ..... ..... ..... ..... ..... ....... ..... ..... ២៥១

**វិធានិទ្ទេស**

អធិប្បាយវិធា គឺការប្រកាន់ខ្លួន ..... ..... ..... ..... .. ..... ..... ..... ២៥៣

**ភយនិទ្ទេស**

អធិប្បាយភយៈ គឺការខ្លាច ..... ..... ..... ..... ..... .... ..... ..... .... ២៥៤

**តមនិទ្ទេស**

អធិប្បាយតមៈ គឺអវិជ្ជា ..... ..... ..... ..... ..... ..... ..... ...... ...... ២៥៥

**និគណ្ឋសម័យ** លទ្ធិនៃនិគ្រន្ថ ឬជីអាក្រាត ..... ..... ..... .... ..... ២៥៧

**ព្រាហ្មណសម័យ** លទ្ធិនៃព្រាហ្មណ៍ ..... ..... ..... ..... ...... ...... ២៥៨

**អាជីវកសម័យ** លទ្ធិនៃអាជីវក ..... ..... ..... ..... ....... ..... ..... ២៥៩

**វិសមនិទ្ទេស**

អធិប្បាយការធ្វើមិនឱ្យស្មើ គឺកិលេស ..... ...... ...... ..... ..... .... ២៦១

**អគ្គិនិទ្ទេស**

## សម្មោហវិនោទនី

**មាតិកាធម៌** **ទំព័រ**


អធិប្បាយអគ្គិ គឺភ្លើង ..... ..... ..... ..... ..... .... .... ..... ..... ..... ២៦១

រឿងការដុតបំផ្លាញរបស់ភ្លើង គឺរាគះ ..... ....... ..... ..... ..... ..... ២៦១

**កោសជ្ជនិទ្ទេស**

អធិប្បាយការខ្ជិល ..... ..... ..... ..... ..... ..... ...... ..... ..... ..... ២៦៤

**អនាទរិយនិទ្ទេស**

អធិប្បាយការមិនអើពើ ..... ..... ..... ..... .. ..... ..... ..... ..... .... ២៦៤

**ឧម្មគ្គសេវនានិទ្ទេស**

អធិប្បាយការសេពផ្លូវខុស ..... ..... ..... ..... .. ..... ..... ..... ..... ២៦៨

**អដ្ឋកថាចតុក្កនិទ្ទេស**

អធិប្បាយមាតិកាពួក ៤ ..... ..... ..... ..... ..... ..... ..... ..... ..... ២៦៨

**អគតិគមនៈ** = លំអៀង ..... ..... ..... ..... ..... ..... ..... ..... ..... ២៦៩

**វិបរិយេសៈ** = ការយល់ខុស ..... ..... ..... ..... ..... ....... ..... .... ២៧១

អនរិយវោហារ .... ..... ..... ..... ..... ..... ..... ........ ..... ..... ... ២៧២

**អដ្ឋកថាបញ្ចក្កនិទ្ទេស**

អធិប្បាយមាតិកាពួក ៥ ..... ..... ..... ..... ......... ..... ..... ..... ២៧៥

ទោសនៃការមិនអត់ធន់ ៥ ..... ..... ..... ..... ..... . ..... ..... ..... ២៨០

**អដ្ឋកថាឆក្កនិទ្ទេស**

អធិប្បាយមាតិកាពួក ៦ ..... ..... ..... ..... ..... ..... ..... ..... ..... ២៨៣

**ឆន្ទរាគនិទ្ទេស**

## អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**


អធិប្បាយឆន្ទភាគៈ ..... ..... ..... ..... ..... ....... ..... ..... ..... ..... ២៨៤

ទិដ្ឋិ ៦ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៨៧

**អដ្ឋកថាសត្តកនិទ្ទេស**

អធិប្បាយមាតិកាពួក ៧ ..... ..... ..... ..... ........ ..... ..... ..... ... ២៩០

**ទិដ្ឋិនិទ្ទេស** ..... ..... ..... ..... ..... ...... ........ ...... ...... ..... ..... ២៩១

**អដ្ឋកថាអដ្ឋកនិទ្ទេស**

អធិប្បាយមាតិកាពួក ៨ ..... ..... ..... ..... ..... ..... ..... ..... ...... ២៩២

ចិត្តបដិឃាតក្នុងលោកធម៌ ..... ..... ..... ..... ..... ..... . ..... ..... ២៩៣

**អដ្ឋកថានវកនិទ្ទេស**

អធិប្បាយមាតិកាពួក ៩ ..... ..... ..... ..... ..... ..... ...... ..... ..... ២៩៨

តណ្ហាមូលកធម៌ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៩៨

**អដ្ឋកថាទសកនិទ្ទេស**

អធិប្បាយមាតិកាពួក ១០ ..... ..... ..... ..... ....... ..... ...... ...... ៣០២

**អដ្ឋកថាតណ្ហាវិចរិតនិទ្ទេស**

អធិប្បាយតណ្ហាវិចរិត ..... ..... ..... ..... ..... ....... ..... ..... ..... ៣០២

**ទិដ្ឋិគតនិទ្ទេស** ..... ..... ..... ..... ..... ..... . ..... ..... ..... ..... ... ៣១០


## ១៨. អដ្ឋកថាធម្មហទយវិភង្គ


អធិប្បាយសព្វសង្គាហិកវារៈទី ១ ..... ..... ..... ..... .. ..... ..... ... ៣១២

## សម្ពោហវិនោទនី

**មាតិកាធម៌** **ទំព័រ**


អធិប្បាយឧប្បត្តានុប្បត្តិទស្សនវារៈទី ២ ..... ..... ..... .. .... ..... ៣១៣

” បរិយាបន្នាបរិយាបន្នទស្សនវារៈទី ៣ ...... ..... ..... ....៣១៤

” វិជ្ជមានាវិជ្ជមានធម្មទស្សនវារៈទី ៤ ..... ....... ..... ..... ៣១៤

” ទស្សនវារៈទី ៥ ..... ..... ..... ..... ..... ....... ...... ..... ៣១៥

” ឧប្បាទកម្មាយុប្បមាណទស្សនវារៈទី ៦ ..... ..... .. .... ៣១៥

គហបតីមហាសាល ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣១៦

ព្រាហ្មណមហាសាល ..... ..... ..... ..... ..... ..... ....... ..... ....... ៣១៦

ខត្តិយមហាសាល ..... ..... ..... ..... ..... ..... ..... ........ ..... ..... ៣១៧

អធិប្បាយអាយុរបស់មនុស្ស និងទេវតា ..... ..... ..... ..... ..... ..... ៣១៨

” អភិញ្ញេយ្យាទិវារៈទី ៧ ..... ..... ..... ....... ..... ..... ... ៣២៤

” សារម្មណានារម្មណាទិវារៈទី ៨ ..... ...... ...... ..... ..... ៣២៥

**និគមគាថា** ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... .. ៣២៧

# អក្សរសង្ខេប
## ដែលប្រើក្នុងអដ្ឋកថាទុតិយភាគ ៨ នេះ

អភិ. = អភិធម្មបិដក

អំ. ឯក. = អង្គុត្តរនិកាយ ឯកនិបាត

អំ. ចតុក្ក. = អង្គុត្តរនិកាយ ចតុក្កនិបាត

អំ. តិក. = អង្គុត្តរនិកាយ តិកនិបាត

អំ. ទសក. = អង្គុត្តរនិកាយ ទសកនិបាត

ខុ. ជា. = ខុទ្ទកនិកាយ ជាតក

ខុ. ថេរ. = ខុទ្ទកនិកាយ ថេរគាថា

ខុ. ធ. = ខុទ្ទកនិកាយ ធម្មបទ

ខុ. បដិ. = ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

ខុ. ពុទ្ធ. = ខុទ្ទកនិកាយ ពុទ្ធវង្ស

ខុ. មហា. = ខុទ្ទកនិកាយ មហាវគ្គ

ខុ. សុ. = ខុទ្ទកនិកាយ សុត្តនិបាត

ទី. បា. = ទីឃនិកាយ បាដិកវគ្គ

ទី. ម. = ទីឃនិកាយ មហាវគ្គ

# អក្សរសង្ខេប

## ដែលប្រើក្នុងអដ្ឋកថាទុតិយភាគ ៨ នេះ

ទី. សី. = ទីឃនិកាយ សីលក្ខន្ធវគ្គ

សារត្ថ. = សារត្ថទីបនី

សំ. និ. = សំយុត្តនិកាយ និទានវគ្គ

សំ. ស. = សំយុត្តនិកាយ សឡាយតនវគ្គ

ប. សុ. = បទានវគ្គ សុត្តនិបាត

ម. មូ. = មជ្ឈិមនិកាយ មូលបណ្ណាសកៈ

ម. ឧ. = មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ

វិនយ. = វិនយបិដក ៕

# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ វិភង្គបករណ៍

## ទុតិយភាគ ៨

ព. ស. ២៥៥៧

# សម្មោហវិនោទនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ វិភង្គបករណ៍

## ទុតិយភាគ ៨

## ១៦_អដ្ឋកថាញាណវិភង្គ

### អធិប្បាយបទមាតិកា

ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់តាំងមាតិកា (មេបទ) ទុកក្នុងញាណវិភង្គ ជាលំដាប់នៃបដិសម្ភិទាវិភង្គនោះ ដោយបរិច្ឆេទទាំង ១០ ដែលមានមេបទពួក ១ ជាខាងដើម មានមេបទពួក ១០ ជាបរិយោសានមុន ដោយន័យមានពាក្យជាដើមថា **“ឯកវិធេន ញាណវត្ថុ** = ញាណវត្ថុពួកមួយ” ហើយធ្វើអធិប្បាយដោយលំដាប់នៃបទទាំងឡាយ ដែលព្រះអង្គទ្រង់តាំងទុក ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **“ឯកវិធេន”** បានដល់ ដោយប្រការមួយ ឬដោយចំណែកមួយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ញាណវត្ថុ** នេះ ឈ្មោះថា ញាណវត្ថុ ព្រោះអត្ថថា ញាណនោះផង វត្ថុនោះផង មានដល់សម្បត្តិទាំងឡាយមានប្រការផ្សេងៗ ។ សូម្បីពាក្យថា ឈ្មោះថា **វត្ថុនៃញាណ** ព្រោះអត្ថថា ជាការប្រាកដ (ឱកាសដ្ឋេន) ដូច្នេះ ក៏ឈ្មោះថា **ញាណវត្ថុ** ។ តែក្នុងទីនេះ គប្បីជ្រាបថា ឈ្មោះថា **ញាណវត្ថុ** ព្រោះអត្ថដែលមានន័យដូចមុនប៉ុណ្ណោះ ។ ដោយហេតុនោះ

ឯង ក្នុងទីបំផុតនៃការកំណត់ញាណវត្ថុពួកមួយ ទើបព្រះមានព្រះភាគត្រាស់ថា **“យាថាវកវត្ថុវិភាវនា បញ្ញា; ឯវំ ឯកវិធេន ញាណវត្ថុ** = បញ្ញាដែលសម្តែងរឿងរបស់វិញ្ញាណ ៥ តាមសេចក្តីពិតដូចពោលមកនេះ ញាណវត្ថុពួក ១ រមែងមានដោយប្រការដូច្នេះ” ។

ពាក្យថា **បញ្ច វិញ្ញាណា** បានដល់ វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម ។ បណ្ឌិតគប្បីជ្រាបពាក្យទាំងឡាយ មានពាក្យថា **“ន ហេតុ”** ជាដើម (ពាក្យថា **“ន ហេតុ** = មិនឈ្មោះថា ហេតុ” ដោយន័យដែលពោលហើយ ក្នុងអដ្ឋកថាធម្មសង្គហៈ ក្នុងពេលមុននោះឯង ។ តែមានពាក្យដោយសង្ខេបហើយ ពាក្យណាដែលនឹងគប្បីពោលក្នុងទីនេះ ពាក្យនោះនឹងប្រាកដច្បាស់ក្នុងវារៈនៃនិទ្ទេស ។

ម្យ៉ាងទៀត ក្នុងមេបទញាណវត្ថុពួកមួយនេះ យ៉ាងណា, សូម្បីក្នុងបទនៃទុកមាតិកាជាដើម ក៏ដូច្នោះដែរ, គឺថា ពាក្យណាដែលខ្ញុំនឹងគប្បីពោល, ពាក្យនោះក៏នឹងច្បាស់លាស់ក្នុងនិទ្ទេសវារៈនោះឯង ។ ក៏បណ្ឌិតគប្បីជ្រាបពាក្យយ៉ាងនេះ ក្នុងមេបទនៃញាណវិភង្គនេះ ត្រឹមតែថាជាគ្រឿងកំណត់នូវបទតាំង ។ ពិតមែន ក្នុងញាណវិភង្គនេះ ព្រះមានព្រះភាគទ្រង់តាំងមាតិកា (មេបទ) នៃធម៌ពួកទីមួយមាន ៧៨ បទ ដោយញែកចេញជា ២ ដោយសង្ខេប គឺដោយអំណាចនៃធម្មសង្គហមាតិកា មានពាក្យថា “(វិញ្ញាណ ៥) ជានហេតុ ជាអហេតុ” ជាដើមសិន, និងដោយអំណាចនៃធម៌មិនមែនមេបទ មានពាក្យថា “(វិញ្ញាណ ៥) ជាអនិច្ចៈ ជាជរាភិភូតៈ” ជាដើម ។

សម្រាប់ **ទុកមាតិកា** ទ្រង់តាំងទុកមួយពួក១ ២ ដោយទុកៈមាន ៣៥ ពួក

ដែលសមគួរដល់ធម៌ពួក ២ ។

**តិកមាតិកា** ទ្រង់តាំងទុកមួយពួកៗ ៣ មាន ៨៨ ពួក គឺពាហិរតិកៈ ៤ ពួក មានពាក្យថា **"ចិន្តាមយា បញ្ញា"** ជាដើម ដែលសមគួរដល់ធម៌ពួក ៣ **មាតិកាតិកៈ ១៤ ពួក** ដែលត្រាស់ទុកដោយអំណាចនៃ **អនិយមិតបញ្ញា** (បញ្ញាដែលមិនប្រាកដ) មានពាក្យថា **ទិដ្ឋកា បញ្ញា** ជាដើម ដោយបទ ១៣ បទ ដែលត្រាស់ទុកដោយអំណាចនៃ **និយមិតបញ្ញា** (បញ្ញាដែលប្រាកដ) ដែលជាបទទី ១ ក្នុងវិតក្កតិកៈ, ដោយបទ ៧ បទ ដែលត្រាស់ទុកដោយអំណាចនៃបញ្ញាដែលប្រាកដជាបទទី ២, ដោយបទ ១២ បទ ដែលត្រាស់ទុកដោយអំណាចនៃបញ្ញាដែលប្រាកដជាបទទី ៣, ដោយបទ ១៣ បទ ដែលត្រាស់ទុកដោយអំណាចនៃបញ្ញាដែលប្រាកដជាបទទី ១ ក្នុងបីតិត្តិកៈ, ដោយ បទ ១២ បទ ដែលត្រាស់ទុកដោយអំណាចនៃបញ្ញាដែលប្រាកដ ដែលជាបទទី ២ និង ទី ៣ ក្នុងបីតិត្តិកៈនុ៎ះឯង ។

ក៏ **ចតុក្កមាតិកា** ទ្រង់តាំងទុកដោយពួក ៤ មាន ២១ បទ មានពាក្យថា **"កម្មស្សកតញ្ញាណំ"** ជាដើម ។

**បញ្ចកមាតិកា** ទ្រង់តាំងទុកមួយពួកៗ ៥ មាន ២ ពួក ។

**ឆក្កមាតិកា** ទ្រង់តាំងទុកមួយពួកៗ ៦ មាន ១ ពួក ។

**សត្តកមាតិកា** ទ្រង់តាំងទុកមួយពួកៗ ៧ មាន ១១ ពួក ដែលត្រាស់ទុកដោយសង្ខេបយ៉ាងនេះថា **"សត្តសត្តតិ ញាណវត្ថុ** = ញាណវត្ថុ ៧៧" ។

**អដ្ឋមាតិកា** ទ្រង់តាំងទុកមួយពួកៗ ៨ មាន ១ ពួក ។

**នវកមាតិកា** ទ្រង់តាំងទុកមួយពួកៗ ៩ មាន ១ ពួក ។

**ទសកមាតិកា** ព្រះមានព្រះភាគទ្រង់តាំងទុកមួយពួកៗ ១០ មានត្រឹមតែមួយពួកប៉ុណ្ណោះ មានពាក្យថា "**ទស តថាគតស្ស តថាគតពលានិ**" ជាដើម ។

បណ្ដាពាក្យទាំងនោះ ពាក្យថា "**១០**" ជាពាក្យកំណត់ចំនួន ។

ពាក្យថា "**តថាគតស្ស** = របស់ព្រះតថាគត" បានដល់ ឥសីទាំងឡាយក្នុងកាលមុន មានព្រះពុទ្ធទ្រង់ព្រះនាមថា **វិបស្សី** ជាដើម យាងមកហើយ យ៉ាងណា, ព្រះតថាគតអង្គនេះ ក៏យាងមកហើយ យ៉ាងនោះដែរ; ម្យ៉ាងទៀត ព្រះពុទ្ធជាម្ចាស់ទាំងនោះ យាងទៅហើយយ៉ាងណា, ព្រះតថាគតអង្គនេះ ក៏យាងទៅហើយយ៉ាងនោះដែរ ។

ពាក្យថា "**តថាគតពលានិ**" បានដល់ កម្លាំងរបស់ព្រះតថាគតនោះ មិនបានទូទៅដល់ជនពួកដទៃៗ ទេ; ម្យ៉ាងទៀត អធិប្បាយថា កម្លាំងទាំងឡាយរបស់ព្រះពុទ្ធ ក្នុងកាលមុន យាងមកហើយដោយឧបនិស្សយសម្បត្តិ គឺបុណ្យយ៉ាងណា សូម្បីកម្លាំងនៃព្រះតថាគតអង្គនេះ យាងមកហើយ ក៏យ៉ាងនោះដែរ ។ សូម្បីកម្លាំងរបស់ព្រះតថាគត ក្នុងទីនោះ មាន ២ យ៉ាង គឺ **កម្លាំងរបស់កាយម្យ៉ាង, កម្លាំងរបស់ញាណម្យ៉ាង** ។ ក្នុងកម្លាំង ២ យ៉ាងនោះ បណ្ឌិតគប្បីជ្រាបកម្លាំងកាយរបស់ព្រះតថាគតបាន ដោយទំនងនៃត្រកូលដំរីតែម្យ៉ាង ៕

## សម្ដែងអំពីកម្លាំងកាយរបស់ព្រះតថាគត

**កាឡាវកញ្ច គង្គេយ្យំ បណ្ឌរំ តម្ពបិង្គលំ**
**គន្ធំ មង្គលហេមញ្ច ឧបោសថំ ឆទ្ទន្តិមេ**

**ទសាតិ ឥមានិ ហិ ទស ហត្ថិកុលានិ ។**

សមពិតដូចបុរាណាចារ្យ ពោលទុកថា ៖

ត្រកូលនៃដំរីទាំងឡាយ ១០ ត្រកូលនេះ គឺ

១.ត្រកូលនៃដំរីឈ្មោះថា **កាឡាវក:** (កាយពណ៌ខ្មៅ)

២.ត្រកូលនៃដំរីឈ្មោះថា **គង្គេយ្យ:** (ពណ៌ទឹកហូរ)

៣.ត្រកូលនៃដំរីឈ្មោះថា **បណ្ឌរ:** (ពណ៌សដូចភ្នំកៃឡាស)

៤.ត្រកូលនៃដំរីឈ្មោះថា **តម្ព:** (ពណ៌ទង់ដែង)

៥.ត្រកូលនៃដំរីឈ្មោះថា **បិង្គល:** (ពណ៌លឿងខ្ចី)

៦.ត្រកូលនៃដំរីឈ្មោះថា **គន្ធ:** (ពណ៌ឈើក្រស្នា មានក្លិនខ្លួនក្រអូប)

៧.ត្រកូលនៃដំរីឈ្មោះថា **មង្គល:** (ពណ៌ខៀវដូចផ្កាអញ្ចែន មានកិរិយាល្អ)

៨.ត្រកូលនៃដំរីឈ្មោះថា **ហេម:** (ពណ៌លឿង)

៩.ត្រកូលនៃដំរីឈ្មោះថា **ឧបោសថ:** (ពណ៌មាស)

១០.ត្រកូលនៃដំរីឈ្មោះថា **ឆទ្ទន្ត:** (ពណ៌សបរិសុទ្ធ ដូចពណ៌ប្រាក់ រង្វង់មាត់ និងជើងក្រហម) ។

បណ្តាត្រកូលដំរីទាំងនោះ ពាក្យថា **"ត្រកូលនៃដំរី ឈ្មោះថា កាឡាវក:"** បណ្ឌិតគប្បីជ្រាបថា ជាត្រកូលដំរីធម្មតា; គប្បីប្រៀបធៀបកម្លាំង ដូច្នេះ ៖

-កម្លាំងបុរស ១០ នាក់ ប៉ុននឹងកម្លាំងដំរីកាឡាវក: ១

-កម្លាំងដំរីកាឡាវក: ១០ ប៉ុននឹងកម្លាំងដំរីគង្គេយ្យ: ១

-កម្លាំងដំរីគង្គេយ្យ: ១០ ប៉ុននឹងកម្លាំងដំរីបណ្ឌរ: ១

| | | |
|---|---|---|
| -កម្លាំងដំរីបណ្ឌរៈ | ១០ | ប៉ុននឹងកម្លាំងដំរីតម្ពៈ ១ |
| -កម្លាំងដំរីតម្ពៈ | ១០ | ប៉ុននឹងកម្លាំងដំរីបិង្គលៈ ១ |
| -កម្លាំងដំរីបិង្គលៈ | ១០ | ប៉ុននឹងកម្លាំងដំរីគន្ធៈ ១ |
| -កម្លាំងដំរីគន្ធៈ | ១០ | ប៉ុននឹងកម្លាំងដំរីមង្គលៈ ១ |
| -កម្លាំងដំរីមង្គលៈ | ១០ | ប៉ុននឹងកម្លាំងដំរីហេមៈ ១ |
| -កម្លាំងដំរីហេមៈ | ១០ | ប៉ុននឹងកម្លាំងដំរីឧបោសថៈ ១ |
| -កម្លាំងដំរីឧបោសថៈ | ១០ | ប៉ុននឹងកម្លាំងដំរីឆទ្ទន្ត ១ |
| -កម្លាំងដំរីឆទ្ទន្ត | ១០ | ប៉ុននឹងកម្លាំងកាយរបស់ព្រះតថាគត ១ ។ |

នេះឯងលោកហៅថា "កម្លាំងកាយរបស់ព្រះពោធិសត្វ ព្រះនាមថា នារាយណ៍ [*] " ។ កម្លាំងកាយរបស់ព្រះតថាគតនោះ ប៉ុននឹងកម្លាំងរបស់ដំរីត្រកូលកាឡាវកៈ **មួយពាន់កោដិត្រកូល** និងប៉ុនកម្លាំងរបស់បុរស ១០ ពាន់កោដិនាក់ ។

**នេះចំពោះកម្លាំងកាយរបស់ព្រះតថាគត ៕**

## សម្ដែងអំពីកម្លាំងញាណរបស់ព្រះតថាគត

ក៏កម្លាំង គឺព្រះញាណរបស់ព្រះតថាគតនេះ ទសពលញ្ញាណដែលមកហើយ

---

[*] ក្នុងបរមត្ថទីបនី ឧទានវណ្ណនា ពោលថា កម្លាំងកាយរបស់ដំរីត្រកូលឆទ្ទន្ត ៦០ ក្បាល ប៉ុននឹងកម្លាំងកាយរបស់ព្រះពោធិសត្វក្នុងបច្ឆិមភព ( ព្រះពោធិសត្វ នឹងមកត្រាស់ដឹងជាព្រះពុទ្ធ ១០ អង្គ គឺ ព្រះសិអារ្យមេត្រិយ, ព្រះរាម, ព្រះបាទបសេនទិកោសល, មារាធិរាជ, អសុរិន្ទរាហូ, សោណព្រាហ្មណ៍, តោទេយ្យព្រាហ្មណ៍, ដំរីនាឡាគីរី, ដំរីបាលិលេយ្យកៈ និងព្រះសុភូតិ) ។

ក្នុងព្រះបាលី (បិដក) នោះឯង ក៏ពាន់នៃព្រះញាណ សូម្បីដទៃទៀតមិនមែនតិច គឺ

**-ទសពលញ្ញាណ** (ញាណដែលជាកម្លាំង ១០) **ក្នុងមហាសីហនាទសូត្រ**[១]

**-វេសារជ្ជញ្ញាណ ៤**

**-អកម្បនញ្ញាណ** (ញាណដែលមិនកម្រើកញាប់ញ័រ) **ក្នុងបរិស័ទ ៨**

**-ញាណដែលកំណត់ដឹងនូវកំណើត ៤**

**-ញាណដែលកំណត់ដឹងនូវគតិ ៥**

**-ញាណ ៧៣ ដែលមកហើយក្នុងសំយុត្តកៈ**[២]

**-ញាណទាំងឡាយមាន ៧៧** យ៉ាងនេះ ដោយប្រការដូច្នេះ ។

នេះឈ្មោះថា **ញាណពលៈ** (គឺកម្លាំងព្រះញាណ) ។ **ញាណពលៈប៉ុណ្ណោះ** លោកប្រាថ្នាយកក្នុងទីនេះ ។ ពិតមែន **ញាណ** ព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅថា **កម្លាំង** ព្រោះអត្ថថា ជាសភាវៈដែលមិនញាប់ញ័រ និងព្រោះអត្ថថា ជាការឧបត្ថម្ភ ។

ពាក្យថា “**យេហិ ពលេហិ សមន្នាគតោ** = ព្រះតថាគតប្រកបដោយកម្លាំងទាំងឡាយឯណា” បានដល់ ព្រះតថាគតនោះ ទ្រង់ចូលដល់ហើយ ចូលដល់ហើយដោយល្អ ដោយកម្លាំងព្រះញាណ ១០ ពួកណា ។

ពាក្យថា “**អាសភណ្ឌានំ**” បានដល់ ស្ថានទីដ៏ប្រសើរ ឋានដែលខ្ពង់ខ្ពស់

---

[១] ម. មូ.។

[២] សំ. និ.។

បំផុត ។ម្យ៉ាងទៀត អធិប្បាយថា ព្រះពុទ្ធជាម្ចាស់ក្នុងកាលមុនព្រះអង្គជាអ្នកធំក្រៃលែង, (ព្រះតថាគត) ទ្រង់ចូលដល់ឋានដូចព្រះពុទ្ធទាំងនោះ ។ ម្យ៉ាងវិញទៀត ប្រៀបដូចគោឧសភៈ (គោជាប្រធានក្នុងហ្វូង) ដែលចម្រើនបំផុតក្នុងចំនួនគោ ១០០ ក្បាល, គោវសភៈ ដែលចម្រើនបំផុតក្នុងចំនួនគោ ១.០០០ ក្បាល; ឬថាគោឧសភៈដែលចម្រើនបំផុត ក្នុងចំនួនគោរយលានក្បាល ឬក៏គោវសភៈដែលចម្រើនបំផុត ក្នុងចំនួនគោ ១.០០០ លានក្បាល; គោនិសភៈជាគោអត់ធន់ចំពោះអន្តរាយទាំងពួង មានពណ៌គួរស្រឡាញ់ នាំភារៈទៅបានច្រើន មិនញាប់ញ័រ សូម្បីដោយសំឡេងអសនីបាត (រន្ទះបាញ់) ទាំង ១០០ ដង ជាមេហ្វូងរបស់គោទាំងអស់; ក្នុងទីនេះប្រាថ្នាយកគោឧសភៈ (គោស) នោះ ។

ពិតមែនហើយ សូម្បីពាក្យថា "គោឧសភៈ" នេះ ក៏ជាពាក្យប្រៀបធៀបឋានដ៏ប្រសើរនោះ; ឈ្មោះថា អាសភៈ (ប្រសើរ) ព្រោះអត្ថថា ពាក្យនេះជាឈ្មោះរបស់គោឧសភៈនោះ; ពាក្យថា "ឋាន" បានដល់ ឋានដែលមិនកម្រើករបស់គោឧសភៈ ដែលប្រើជើងទាំង ៤ ជាន់លើផែនដី; ម្យ៉ាងទៀត ឈ្មោះថា អាសភៈ (ខ្ពស់បំផុត) ព្រោះអត្ថថា ឋាននេះ ហាក់ដូចជាការតាំងនៅរបស់គោដែលជាប្រធាន; ដូចយ៉ាងថា គោឧសភៈ គឺគោនិសភៈប្រកបដោយកម្លាំងរបស់គោឧសភៈ ប្រើជើងទាំង ៤ ជាន់លើផែនដី រមែងឈរមាំទាំមិនកម្រើក យ៉ាងណា, សូម្បីព្រះតថាគតក៏ដូច្នោះដែរ ប្រកបដោយកម្លាំងរបស់ព្រះតថាគត ១០ (ទសពលញ្ញាណ) ប្រើព្រះបាទ គឺវេសារជ្ជញ្ញាណ ៤ (ញាណដែលធ្វើសេចក្តីក្លៀវក្លា) ជាន់លើផែនដី គឺបរិស័ទ ៨ ទ្រង់ជាអ្នកមិនកម្រើក ញាប់ញ័រដោយបច្ចាមិត្រ ដែលមានការរាំងស្ទះនូវប្រ-

យោជន៍អ្វីៗ ក្នុងលោកនេះ ទាំងទេវលោក, ឈ្មោះថា ទ្រង់តាំងនៅក្នុងឋានដែលមិនញាប់ញ័រ; ក៏កាលបើទ្រង់តាំងនៅយ៉ាងនេះ ទើបទ្រង់បដិញ្ញាណ គឺទ្រង់ចូលដល់ឋានដែលជាអ្នកប្រសើរលើសនោះ រមែងមិនពោលឱ្យឃ្លាតចាកសេចក្ដីពិត និងទ្រង់លើកឋានដ៏ប្រសើរលើសនោះ ទុកក្នុងព្រះអង្គ; ដោយហេតុនោះ ទើបព្រះភគវាត្រាស់ថា **"អាសភណ្ឋានំ បដិជានាតិ** = ទ្រង់បដិញ្ញាណឋានដ៏ប្រសើរលើស" ។

ពាក្យថា **"បរិសាសុ"** បានដល់ ក្នុងបរិស័ទ ៨ * ។

ពាក្យថា **"សីហនាទំ នទតិ"** បានដល់ ទ្រង់បន្លឺ គឺទ្រង់បញ្ចេញព្រះសូរសៀងដ៏អង់អាច (សម្គាល់សេចក្ដីថា ទ្រង់បញ្ចេញព្រះសូរសៀងដ៏ប្រសើរ គឺមិនភ័យខ្លាច), ម្យ៉ាងទៀត ទ្រង់បញ្ចេញព្រះសូរសៀង ដូចសីហនាទ (គឺដូចការបន្លឺរបស់សីហរាជ); សេចក្ដីនេះ បណ្ឌិតគប្បីសម្ដែងដោយព្រះសូត្រ ឈ្មោះថា **សីហនាទសូត្រ**; ម្យ៉ាងវិញទៀត **សីហៈ** ព្រះមានព្រះភាគត្រាស់ហៅថា **សីហៈ** ព្រោះអត់ធន់ និងព្រោះការសម្លាប់ យ៉ាងណា, ព្រះតថាគតក៏ដូច្នោះដែរ ទ្រង់ព្រះនាមថា **សីហៈ** ព្រោះអត់ធន់ចំពោះ លោកធម៌ទាំងឡាយបាន និងព្រោះការសម្លាប់លទ្ធិដទៃៗ បាន; **ការគ្រហឹម គឺការបន្លឺរបស់សីហៈដែលពោលហើយ ដោយអាការយ៉ាងនេះ ឈ្មោះថា សីហនាទ**; ក្នុងទីនេះ សីហៈដែលប្រកបហើយដោយ

---

* បរិស័ទ ៨ គឺ ខត្តិយបរិស័ទ, ព្រាហ្មណបរិស័ទ, គហបតីបរិស័ទ, សមណបរិស័ទ, ចាតុម្មហារាជិកាបរិស័ទ, តាវត្តិង្សបរិស័ទ, មារបរិស័ទ និងព្រហ្មបរិស័ទ (ចាកមហាបរិនិព្វានសូត្រ) ។

កម្លាំងរបស់សីហៈ ជាអ្នកក្លៀវក្លាក្នុងទីទាំងពួង ជាអ្នកមានរោមបះទៅប្រាសហើយ រមែងបន្លឺសីហនាទ យ៉ាងណា, **សូម្បីសីហៈ គឺព្រះតថាគត** ក៏ដូច្នោះដែរ ប្រកបហើយដោយកម្លាំងរបស់តថាគត ជាអ្នកក្លៀវក្លាក្នុងបរិស័ទ ៨ មិនជាអ្នកមានរោមបះ; រមែងទ្រង់បន្លឺនូវសីហនាទដែលដល់ព្រមហើយ ដោយសេចក្ដីល្អរបស់ទេសនាមានវិធីផ្សេងៗ ដោយន័យមានពាក្យថា **"ឥតិ រូបំ"** ជាដើម; ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា **"បរិសាសុ សីហនាទំ នទតិ** = ទ្រង់បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ" ។

ពាក្យថា **"ព្រហ្មំ"** ក្នុងខថា **"ព្រហ្មចក្កំ បវត្តេតិ"** នេះ បានដល់ ប្រសើរខ្ពង់ខ្ពស់ គឺបរិសុទ្ធហើយ ។

ក៏ឯសព្ទថា **ចក្កំ** (ចក្កសព្ទ) នេះ រមែងប្រាកដក្នុងអត្ថថា **សម្បត្តិ ក្នុងលក្ខណៈ ក្នុងចំណែកនៃរថ គឺកង់ ក្នុងឥរិយាបថ ក្នុងទាន ក្នុងរតនៈ ក្នុងធម្មៈ និងក្នុងចក្រដ៏មុតស្រួច** ជាដើម ក្នុងទីនេះបណ្ឌិតគប្បីជ្រាបសព្ទថា **ធម្មចក្ក** (កង់រថ គឺព្រះធម៌) ហើយគប្បីញ៉ាំងពាក្យថា ធម្មចក្កនោះ ឱ្យជាក់ច្បាស់ ដោយញែកចេញជាពីរចំណែកដូច្នេះ ៖

ចក្កសព្ទនេះរមែងប្រាកដក្នុងអត្ថថា **សម្បត្តិ** (ការដល់ព្រម) ដែលមកហើយក្នុងពាក្យថា **"ចត្តារិមានិ ភិក្ខវេ ចក្កានិ យេហិ សមន្នាគតានំ ទេវ-**

**មនុស្សានំ** = ម្នាលភិក្ខុទាំងឡាយ ចក្ក ៤ [៣] ទាំងនេះ រមែងប្រព្រឹត្តទៅដល់ទេវតា និងមនុស្សទាំងឡាយ អ្នកប្រកបព្រមហើយ... រមែងដល់សេចក្ដីបរិបូណ៌ដ៏ធំក្នុងភោគៈ [៤] ទាំងឡាយ” [៤] ជាដើម, ចក្កសព្ទ រមែងប្រាកដក្នុងអត្ថថា **លក្ខណៈ** ដែលមកក្នុងពាក្យថា “**ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ** = ចក្កទាំងឡាយ រមែងកើតឡើងត្រង់ផ្ទៃព្រះបាទទាំងពីរនេះ” [៥] ។ ចក្កសព្ទ រមែងប្រាកដក្នុងអត្ថថា **ចំណែកនៃរថ គឺកង់** (កង់រថ) ដែលមកក្នុងពាក្យថា “**ចក្កំវ វហតោ បទំ** = ដូចជាកង់វិលទៅតាមស្នាមជើងនៃគោពលិពទ្ទ” [៦] ។ ចក្កសព្ទនេះ រមែងប្រាកដក្នុង**ឥរិយាបថ** ដែលមកហើយក្នុងពាក្យថា “**ចតុចក្កំ នវទ្វារំ** = យន្ត គឺសរីរៈដែលមានកង់ ៤ មានទ្វារ ៩” [៧] នេះ ។ ចក្កសព្ទរមែងប្រាកដក្នុងអត្ថថា **ទានដែល**

---

[៣] ចក្ក ៤ គឺ ១. **បដិរូបទេស** នៅក្នុងប្រទេសដ៏សមគួរ, ២. **សប្បុរិសូបស្សយៈ** សេពគប់សប្បុរស, ៣. **អត្តសម្មាបណិធិ** តម្កល់ខ្លួនទុកដោយប្រពៃ, ៤. **បុព្វេកតបុញ្ញតា** ភាពជាអ្នកបានធ្វើសេចក្ដីល្អទុកក្នុងកាលមុន; ធម៌ ៤ នេះ ដូចកង់រថនាំទៅកាន់សេចក្ដីចម្រើន ។

[៤] ភោគៈទាំងឡាយ សំដៅដល់មនុស្សសម្បត្តិ សួគ៌សម្បត្តិ និងនិព្វានសម្បត្តិ ។

[៤] អំ. ចតុក្ក.។

[៥] ទី. ម.។

[៦] ខុ. ធ. ។

[៧] សំ. ស.។

មកហើយក្នុងពាក្យថា **“ខាទ ភុញ្ជ មា ច បមាទោ, ចក្កំ វត្តស្ស សព្វបាណិនំ** = លោកចូរទំពា ចូរបរិភោគ ក៏ចូរកុំប្រមាទ, ញ៉ាំងចក្ក (គឺទាន) ឱ្យប្រព្រឹត្តទៅដល់សត្វទាំងអស់” [៨] នេះ ។ ចក្កសព្ទ រមែងប្រាកដក្នុងអត្ថថា **ចក្ករតនៈ** (រតនៈ គឺចក្រ) ដែលមកហើយក្នុងពាក្យថា **“ទិព្វចក្ករតនំ បាតុរហោសិ** = រតនៈ គឺចក្រដែលជាទិព្វប្រាកដហើយ” [៩] នេះ ។ ចក្កសព្ទ រមែងប្រាកដក្នុងអត្ថថា **ធម្មចក្ក** (ចក្ក គឺព្រះធម៌) ដែលមកហើយក្នុងពាក្យថា **“មយា បវត្តិតំ ចក្កំ** = ចក្កៈ គឺព្រះធម៌ដែលតថាគតឱ្យប្រព្រឹត្តទៅហើយ” [១០] នេះ ។ ចក្កសព្ទ រមែងប្រាកដក្នុងអត្ថថា **ចក្រមុតស្រួច**ដែលមកហើយក្នុងពាក្យថា **“ឥច្ឆាហតស្ស បោសស្ស, ចក្កំ ភមតិ មត្ថកេ** = ចក្ររមែងវិលទៅលើក្បាល របស់បុរសអ្នកត្រូវសេចក្ដីប្រាថ្នានាំមកហើយ” [១១] នេះ ។ រមែងប្រាកដក្នុងអត្ថថា **ចក្កៈ** (គ្រឿងប្រហារ) ក្នុងពាក្យថា **“ខុរបរិយន្តេន ចេបិ ចក្កេន** = ដោយចក្រមានមុខមុតស្រួចដោយជុំវិញ” [១២]; រមែងប្រាកដក្នុងអត្ថថា **អសនិមណ្ឌល** (បរិវេណខ្សែរន្ទះ) ក្នុងពាក្យថា **“អសនិវិ**

---

[៨] ខុ. ជា. ។

[៩] ទី. ម. ។

[១០] ខុ. សុ. ។

[១១] ខុ. ជា. ។

[១២] ទី. សី. ។

**ចក្ខុំ** = ភ្លើងរន្ទះ”[១៣] នេះ ។

តែក្នុងទីនេះ **ចក្កសព្ទ** បណ្ឌិតជ្រាបហើយថាចក្រ គឺព្រះធម៌ទាំងឡាយ ។ ក៏ចក្រ គឺព្រះធម៌នោះ មានពីរយ៉ាង គឺ

**១. បដិវេធញ្ញាណ** ញាណក្នុងការចាក់ធ្លុះ

**២. ទេសនាញាណ** ញាណក្នុងការសម្ដែង ។

ក្នុងពីរយ៉ាងនោះ **បដិវេធញ្ញាណ** នាំមកនូវអរិយផលរបស់ខ្លួន ដែលបញ្ញាអប់រំហើយ, **ទេសនាញាណ** នាំមកនូវអរិយផលរបស់សាវ័កទាំងឡាយ ដែលបំពេញគ្រប់ហើយដោយករុណា ។

បណ្ដាញាណទាំងនោះ បដិវេធញ្ញាណមាន ២ យ៉ាង គឺ

**១. ឧប្បជ្ជមានៈ** បដិវេធញ្ញាណដែលកំពុងកើតឡើង

**២. ឧប្បន្នៈ** បដិវេធញ្ញាណដែលកើតឡើងហើយ ។

ពិតមែន បដិវេធញ្ញាណដែលកំពុងកើតឡើង រាប់ចាប់ផ្ដើមតាំងពីការចេញមហាភិនេស្រ្កមរបស់ព្រះពុទ្ធជាម្ចាស់ ដរាបដល់អរហត្តមគ្គ, ក្នុងខណៈនៃផល ឈ្មោះថា បដិវេធញ្ញាណដែលកើតឡើងហើយ ។ ម្យ៉ាងទៀត **បដិវេធញ្ញាណ** ឈ្មោះថាកំពុងកើត រាប់ចាប់ពីស្ដេចនៅភពតុសិត ដរាបដល់អរហត្តមគ្គ ត្រង់មហាពោធិ-បល្ល័ង្ក, ក្នុងខណៈនៃផល បដិវេធញ្ញាណ ឈ្មោះថា កើតឡើងហើយ ។ ម្យ៉ាងវិញ-

---

[១៣] ទី. បា., សំ. និ.។

ទៀត រាប់ចាប់តាំងពីការព្យាករណ៍របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមថា **ទីបង្ករ** ដរាបដល់អរហត្តមគ្គ **បដិវេធញ្ញាណ** ឈ្មោះថា កំពុងកើតឡើង, ក្នុងខណៈនៃផល **បដិវេធញ្ញាណ** ឈ្មោះថា កើតឡើងហើយ ។

សូម្បីទេសនាញាណ ក៏មានពីរយ៉ាង គឺ

**១. បវត្តមានៈ** ទេសនាដែលកំពុងប្រព្រឹត្តទៅ

**២. បវត្តៈ** ទេសនាដែលប្រព្រឹត្តទៅហើយ ។

ពិតមែន បដិវេធញ្ញាណនោះ ឈ្មោះថា កំពុងប្រព្រឹត្តទៅ រាប់ចាប់ផ្ដើមពីសោតាបត្តិមគ្គរបស់ព្រះអញ្ញាកោណ្ឌញ្ញៈ, ក្នុងខណៈនៃផល ទេសនាញាណ ឈ្មោះថា ប្រព្រឹត្តទៅហើយ ។

**ក្នុងទេសនាញាណទាំងនោះ បដិវេធញ្ញាណជាលោកុត្តរ, ទេសនាញាណ ជាលោកិយ ។**

ក៏សូម្បីញាណទាំងពីរនោះ ជាឱរសញ្ញាណ (ញាណដែលកើតឡើងក្នុងព្រះឧរៈ = ទ្រូង = បេះដូង) របស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ មិនទូទៅដល់ជនពួកដទៃឡើយ ៕

## សម្ដែងអំពីកម្លាំង ១០ របស់ព្រះតថាគត

ឥឡូវនេះ ដើម្បីទ្រង់សម្ដែងកម្លាំងនៃព្រះតថាគត ដែលទ្រង់តាំងទុកថា

**"យេហិ ទសហិ ពលេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិ-ជានាតិ, យានិ អាទិតោវ ទស តថាគតស្ស តថាគតពលានិ** = ព្រះតថាគត ប្រកបដោយកម្លាំង ១០ ឯណា ទើបទ្រង់បដិញ្ញាណនូវឋានដ៏ប្រសើរ និងកម្លាំងពួកណា ឈ្មោះថា កម្លាំង ១០ របស់ព្រះតថាគតចាប់ផ្តើមពីដើម" ដោយពិស្តារ, ទើបត្រាស់ពាក្យថា **"កតមានិ ទស ឥធ តថាគតោ ឋានញ្ច ឋានតោ** = កម្លាំង ១០ របស់ព្រះតថាគត តើដូចម្តេច ? គឺព្រះតថាគតក្នុងលោកនេះ រមែងទ្រង់ជ្រាបធម៌ដែលជាឋាន ដោយសេចក្តីជាឋាន" ជាដើម ៕

## សម្តែងអំពីកម្លាំងរបស់ព្រះតថាគតទី ១

បណ្តាពាក្យទាំងនោះ ពាក្យថា **"ឋានញ្ច ឋានតោ"** បានដល់ ទ្រង់ជ្រាបធម៌ដែលជាហេតុ ដោយសេចក្តីជាហេតុ ។ ក៏**ហេតុ** រមែងឱ្យផលតាំងឡើងក្នុងទីនោះ គឺរមែងកើតឡើងផង រមែងប្រព្រឹត្តទៅផង ព្រោះការចូលទៅអាស្រ័យ និងការប្រព្រឹត្តទៅក្នុងកាលនោះ, ព្រោះហេតុដូច្នោះ ទើបលោកហៅថា **ឋាន**, អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាបនូវឋាននោះ ដោយសេចក្តីជាឋាន និងអដ្ឋានដោយសេចក្តីជាអដ្ឋាន គឺរមែងទ្រង់ជ្រាបតាមសេចក្តីពិតយ៉ាងនេះថា **ធម៌ពួកណាៗ ជាហេតុ ជាបច្ច័យ ដល់ធម៌ពួកណាៗ ព្រោះអាស្រ័យនូវធម៌នោះៗ ដែលជាឋាន** និងទ្រង់ជ្រាបថា **ធម៌ពួកណាៗ មិនមែនហេតុ មិនមែនបច្ច័យ របស់ធម៌ពួកណាៗ ព្រោះចូលទៅអាស្រ័យនូវធម៌ពួកនោះៗ ដែលមិនមែន**

ឋាន ។

ពាក្យថា **"យម្បិ** = សូម្បីណា" បានដល់ ដោយញាណណា ។

ពាក្យថា **"ឥទម្បិ តថាគតស្ស** = សូម្បីខនេះ ក៏ជាកម្លាំងរបស់ព្រះតថា-គត" អធិប្បាយថា សូម្បីឋានាឋានញ្ញាណរបស់ព្រះតថាគតនេះ ឈ្មោះថា ជាកម្លាំងរបស់ព្រះតថាគត ។ បណ្ឌិតគប្បីជ្រាបការប្រកបក្នុងបទទាំងពួងយ៉ាងនេះ ៕

## សម្តែងអំពីកម្លាំងរបស់ព្រះតថាគតទី ២

ពាក្យថា **"កម្មស្ស សមាទានានំ"** បានដល់ កម្មជាកុសល និងអកុសល ដែលតាំងចិត្តធ្វើហើយ ។ ម្យ៉ាងទៀត កម្មនុ៎ះឯង ឈ្មោះថា **កម្មស្សសមាទាន** ។ ពាក្យថា **"ឋានសោ ហេតុសោ** = ដោយឋាន ដោយហេតុ" បានដល់ ដោយបច្ច័យ និងដោយហេតុ ។ ក្នុងពាក្យទាំងនោះ គតិ ឧបធិ កាល និងបយោគ ឈ្មោះថា ឋានរបស់វិបាក, កម្ម ឈ្មោះថា ហេតុ ៕

## សម្តែងអំពីកម្លាំងរបស់ព្រះតថាគតទី ៣

ពាក្យថា **"សព្វត្ថគាមិនី** = ទៅកាន់ភូមិទាំងពួង" បានដល់ ទៅកាន់គតិទាំងពួង និងទៅកាន់អគតិ ។ ពាក្យថា **"បដិបទំ"** បានដល់ ផ្លូវ (គឺមគ្គ) ។ ពាក្យថា **"យថាភូតំ បជានាតិ"** បានដល់ រមែងទ្រង់ជ្រាបសភាវៈនៃការបដិបត្តិ ពោលគឺចេតនាដែលជាកុសល និងអកុសល ដោយមិនវិបរិត (មិនខុស) សូម្បីក្នុងវត្ថុមួយ ដោយន័យនេះថា "គ្រាកាលមនុស្សទាំងឡាយ សូម្បីមានចំនួនច្រើន

សម្លាប់នូវសត្វមួយនុ៎ះឯង ចេតនារបស់គេនោះ នឹងទៅកាន់និរយៈ ។ ឯចេតនារបស់អ្នកនេះនឹងដល់កំណើតក្នុងសត្វតិរច្ឆាន” ៕

## សម្តែងអំពីកម្លាំងរបស់ព្រះតថាគតទី ៤

ពាក្យថា “**អនេកធាតុំ**” បានដល់ ទ្រង់ជ្រាបធាតុច្រើនៗ មានចក្ខុធាតុជាដើម ឬកាមធាតុជាដើម ។ ពាក្យថា “**នានាធាតុំ**” បានដល់ ធាតុនានប្បការ (មានប្រការផ្សេងៗ) ព្រោះសេចក្តីដែលធាតុទាំងនោះនុ៎ះឯង មានលក្ខណៈផ្សេងគ្នា ។ ពាក្យថា “**លោកំ**” បានដល់ លោក គឺខន្ធ អាយតនៈ និងធាតុ ។ ពាក្យថា “**យថាភូតំ បជានាតិ**” បានដល់ ទ្រង់ចាក់ធ្លុះនូវធាតុនោះៗ ដោយមិនវិបរិត ។

## សម្តែងអំពីកម្លាំងរបស់ព្រះតថាគតទី ៥

ពាក្យថា “**នានាធិមុត្តិកតំ** = មានអធ្យាស្រ័យផ្សេងៗ គ្នា” បានដល់ ទ្រង់ជ្រាបសេចក្តីដែលសត្វទាំងឡាយ ជាអ្នកមានអធ្យាស្រ័យផ្សេងៗ គ្នា គឺមានអធ្យាស្រ័យដែលអាក្រក់ជាដើម ៕

## សម្តែងអំពីកម្លាំងរបស់ព្រះតថាគតទី ៦

ពាក្យថា “**បរសត្តានំ** = របស់សត្វពួកដទៃ” បានដល់ របស់សត្វអ្នកជាធំ ។ ពាក្យថា “**បរបុគ្គលានំ** = របស់បុគ្គលពួកដទៃ” បានដល់ សត្វថោកទាបជាងសត្វដទៃ អំពីសត្វទាំងនោះ។ ម្យ៉ាងទៀត បទទាំងពីរដែលពោលមកនេះ មានអត្ថ

តែម្យ៉ាងដូចគ្នា, កាលដែលព្រះមានព្រះភាគត្រាស់ទុកពីរយ៉ាង ដោយអំណាចនៃវេនេយ្យសត្វ គឺសត្វដែលគួរណែនាំ ។ ពាក្យថា **“ឥន្ទ្រិយបរោបរិយត្តំ** = សេចក្តីចាស់ក្លា និងមិនចាស់ក្លានៃឥន្ទ្រិយ” អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាបនូវការប្រព្រឹត្តទៅនៃសត្វដទៃៗ និងទ្រង់ជ្រាបសេចក្តីសាបសូន្យនៃឥន្ទ្រិយទាំង-ឡាយ មានសទ្ធាជាដើម ៕

## សម្តែងអំពីកម្លាំងរបស់ព្រះតថាគតទី ៧

ពាក្យថា **“ឈានវិមោក្ខសមាធិសមាបត្តីនំ** = នៃឈាន វិមោក្ខ សមាធិ សមាបត្តិ” បានដល់ ទ្រង់ជ្រាបសេចក្តីសៅហ្មង សេចក្តីផូរផង់ សេចក្តីចេញនៃឈាន ៤ មានបឋមជ្ឈានជាដើម... នៃវិមោក្ខ ៨ មានពាក្យថា **“រូបរូបានិ** * **បស្សតិ”** ជាដើម... នៃសមាធិ ៣ ដែលប្រព្រឹត្តទៅជាមួយវិតក្កៈ និងវិចារៈជាដើម... នៃអនុបុព្វសមាបត្តិ ៩ មានបឋមជ្ឈានសមាបត្តិជាដើម ។ ពាក្យថា **“សង្កិលេសំ** = សេចក្តីសៅហ្មង” បានដល់ ធម៌ជាចំណែកនៃសេចក្តីសាបសូន្យ ។ ពាក្យថា **“វោ-ទានំ** = សេចក្តីផូរផង់” បានដល់ ធម៌ដែលជាចំណែកវិសេស គឺផ្នែកល្អ ។ ពាក្យថា **“វុដ្ឋានំ** = ការចេញ” បានដល់ រមែងចេញចាកឈានជាដើម ដោយហេតុណា, រមែងជ្រាបនូវហេតុនោះ ៕

* ច្បាប់ភូមាថា *រូបីរូបានិ* ។

## សម្តែងអំពីកម្លាំងព្រះតថាគតទី ៨-១០

ពាក្យថា **“បុព្វេនិវាសានុស្សតិ៍** = រឭកជាតិវិលថយក្រោយ” បានដល់ ទ្រង់រឭកខន្ធដែលធ្លាប់អាស្រ័យហើយ ក្នុងកាលមុន ។ **ការចុតិ និងការឧប្បត្តិ** ឈ្មោះថា **ចុតូបបាតៈ** ព្រះអង្គទ្រង់ជ្រាបទាំងការស្លាប់ និងការកើតឡើងនៃសត្វទាំងឡាយ ។

ពាក្យថា **“អាសវានំ ខយំ** = ការអស់អាសវៈ” បានដល់ ព្រះនិព្វានដែលរលត់នូវអាសវៈ ពោលគឺការអស់ទៅនៃកាមាសវៈជាដើម ។ ពាក្យថា **“ឥមានិ** = កម្លាំងទាំងនេះ” បានដល់ ញាណទាំង ១០ ណា ដែលពោលទុកក្នុងកាលមុនថា “ជាកម្លាំងរបស់ព្រះតថាគតទាំង ១០ នេះ ក៏គឺញាណទាំង ១០ នេះឯង ។

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបការពណ៌នាបទ មកដោយលំដាប់ក្នុងមាតិកានេះ យ៉ាងនេះហើយ គប្បីជ្រាបទៀតថា ព្រះតថាគតរមែងទ្រង់ឃើញនូវវេនេយ្យសត្វទាំងឡាយ អ្នកមាន **កិលេសាវរណៈ** (គឺមានកិលេសជាគ្រឿងរារាំង) ដែលជាឋាន និងអដ្ឋាន របស់សត្វអ្នកនឹងសម្រេច និងមិនសម្រេចនូវការអស់ទៅនៃអាសវៈ ដោយឋានាឋានញ្ញាណមុន, ព្រោះឃើញឋាន គឺលោកិយសម្មាទិដ្ឋិ និងទ្រង់ឃើញនូវសេចក្តីមិនមានឋាន **គឺនិយតមិច្ឆាទិដ្ឋិ** ។ តពីនោះ ក៏ទ្រង់ឃើញនូវសេចក្តីដែលសត្វទាំងឡាយនោះ មានវិបាកជាគ្រឿងការពារ មិនឱ្យសម្រេចគុណវិសេស ដោយ **កម្មវិបាកញ្ញាណ** (គឺញាណ ដឹងផលរបស់កម្ម), ព្រោះទ្រង់ឃើញសត្វអ្នកបដិសន្ធិដោយតិហេតុកៈ ។ រមែងទ្រង់ឃើញនូវសេចក្តីដែលសត្វទាំងឡាយ មានកម្មជាគ្រឿងការពារ ដោយ**សព្វត្ថគាមិនីបដិបទាញាណ** (គឺញាណដឹងផ្លូវទៅកាន់ភូមិ

ទាំងពួង), ព្រោះទ្រង់ឃើញសេចក្ដីមិនមាននៃអនន្តរិយកម្ម ។ ទ្រង់ឃើញគុណ-វិសេសនៃការប្រព្រឹត្តទៅ ដើម្បីសម្ដែងធម៌អនុគ្រោះដល់សត្វអ្នកមិនមានកម្មជាគ្រឿងការពារយ៉ាងនេះ ដោយ**អនេកធាតុនានាធាតុញ្ញាណ** (ញាណដឹងលោកដែលជាអនេកធាតុ និងនានាធាតុ), ព្រោះទ្រង់ឃើញសេចក្ដីផ្សេងគ្នានៃធាតុ ។ លំដាប់នោះ ទ្រង់ឃើញនូវ**អធិមុត្តិ** (គឺអធ្យាស្រ័យរបស់សត្វទាំងនោះ) បានដោយ**នានាធិមុត្តិកញ្ញាណ** (ញាណដឹងអធ្យាស្រ័យផ្សេងៗ គ្នា) ទើបទ្រង់មិនបានកាន់យកពិធីការដើម្បីសម្ដែងធម៌ ដោយអំណាចនៃអធ្យាស្រ័យ។ តពីនោះ ទ្រង់ឃើញសេចក្ដីខ្វះខាត និងក្រៃលែងនៃឥន្ទ្រិយ ដើម្បីសម្ដែងធម៌តាមសតិ តាមកម្លាំង នៃសត្វអ្នកមានអធ្យាស្រ័យដែលដឹងបានដោយ **ឥន្ទ្រិយបរោបរិយត្តិញ្ញាណ**, ព្រោះទ្រង់ឃើញសភាពនៃសទ្ធាជាដើម ជាធម៌ចាស់ក្លា និងទន់ខ្សោយ ។ ក៏បើថា សេចក្ដីក្រៃលែង និងខ្វះខាតនៃឥន្ទ្រិយដែលសត្វគប្បីដឹងបានយ៉ាងនេះ ជាធម្មជាតិចាស់ក្លាសោត ឥន្ទ្រិយទាំងនោះរមែងចូលដល់បានរហ័ស ដោយគុណវិសេសនៃឫទ្ធិ ព្រោះភាវៈនៃខ្លួនជាអ្នកជំនាញហើយក្នុងឈានជាដើម ដោយញាណក្នុងឈានជាដើម ។ ក៏ឯគ្រាចូលដល់ហើយ ទើបទ្រង់សម្ដែងធម៌ដល់សត្វទាំងនោះ ជាអ្នកមានអធ្យា-ស្រ័យដែលកើតក្នុងកាលមុន ដោយ**បុព្វេនិវាសានុស្សតិញ្ញាណ**, ព្រោះអានុភាពនៃទិព្វចក្ខុ ទ្រង់ឃើញនូវសេចក្ដីវិសេសនៃចិត្ត ដែលដល់ព្រមដោយ**ចេតោបរិយ-ញ្ញាណ** ដោយអានុភាពនៃ **អាសវក្ខយញ្ញាណ** ទើបទ្រង់សម្ដែងធម៌ដើម្បីការអស់ទៅនៃអាសវៈ ព្រោះសត្វទាំងនោះ មានសេចក្ដីវង្វេងទៅប្រាសហើយ ដោយផ្លូវដែលឱ្យដល់អាសវក្ខយញ្ញាណ; ព្រោះហេតុដូច្នោះ ក្នុងលំដាប់នេះ បណ្ឌិតគប្បី

ជ្រាបថា ព្រះមានព្រះភាគត្រាស់ញាណទាំង ១០ នេះថា ជាកម្លាំង ។

**នេះជាការពណ៌នាសេចក្ដីក្នុងមាតិកាជាមុនសិន ៕**

## ១. អដ្ឋកថាឯកកនិទ្ទេស អធិប្បាយញាណវត្ថុពួក ១

ឥឡូវនេះ ជាការសម្ដែងបដិសេធសាធារណហេតុ ក្នុងពាក្យថា ជា **ន ហេតុ**ប៉ុណ្ណោះ; ក្នុងនិទ្ទេសវារៈ ព្រះមានព្រះភាគទ្រង់ផ្ដើមទុក ក្នុងមាតិកាតាមដែលទ្រង់តាំងទុកថា **"បញ្ចវិញ្ញាណា ន ហេតុមេវ"** ជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យណាដែលគប្បីពោលដោយន័យថា **"ចតុព្វិធោ ហេតុ** = មានហេតុ ៤ យ៉ាង" គឺ

**១. ហេតុហេតុ** **២. បច្ចយហេតុ**

**៣. ឧត្តមហេតុ** **៤. សាធារណហេតុ** ។

ពាក្យទាំងអស់នោះ ខ្ញុំពោលទុកហើយ ក្នុងការពណ៌នាសេចក្ដីនៃពាក្យទាំងឡាយ ក្នុងរូបកណ្ឌថា **"សព្វំ រូបំ ន ហេតុមេវ** = រូបទាំងអស់ជានហេតុមែនពិត" ជាដើមនោះឯង ។

ក្នុងពាក្យថា **"អហេតុកមេវ"** ជាដើម បណ្ឌិតគប្បីជ្រាប **ម**អក្សរដោយអំណាចនៃព្យញ្ជនសន្ធិ, គឺជា **អហេតុកាឯវ** = ជាអហេតុកៈប៉ុណ្ណោះ; សូម្បីក្នុងបទដែលនៅសល់ ក៏ន័យនេះដែរ ។ ម្យ៉ាងទៀត ក្នុងប្រភេទនៃធម៌មានពាក្យថា **"ហេតូ ធម្មា ន ហេតូ ធម្មា** = វិញ្ញាណ ៥ ជាហេតុធម៌ ឬមិនជាហេតុធម៌" ជាដើម ។ បណ្ឌិតគប្បីជ្រាបសេចក្ដីរបស់បទទាំងពួងក្នុងទីនេះ ដោយចំណែកមួយ

ថា "**កិរិញ្ញាណ ៥ ជានហេតុប៉ុណ្ណោះ ជាអហេតុកៈប៉ុណ្ណោះ**" ។

ពាក្យថា "**អព្យាកតមេទ** = ជាអព្យាកតៈប៉ុណ្ណោះ" នេះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចនៃវិបាកាព្យាកតៈ ។

បទថា "**សារម្មណមេទ**" នេះ ត្រាស់ដោយអំណាចនៃអារម្មណ៍ជាគ្រឿងយឹតយូរ (ឱលុព្ភារម្មណវសេន) ។ ពិតមែន អារម្មណ៍មាន ២ យ៉ាង គឺ **បច្ចយា-រម្មណ៍** បានដល់ អារម្មណ៍ដែលជាបច្ច័យ, **ឱលុព្ភារម្មណ៍** បានដល់ អារម្មណ៍ដែលជាគ្រឿងយឹតយូរ ។ តែក្នុងទីនេះ ជានាទីរបស់ឱលុព្ភារម្មណ៍នោះឯង ។ សូម្បីបច្ចយារម្មណ៍ ក៏រមែងបានដូចគ្នា ។

បទថា "**អចេតសិកមេទ** = ធម៌ដែលមិនប្រកបដោយចិត្ត" ។ ក្នុងអចេ-តសិកធម៌ (ធម៌ដែលមិនមែនចេតសិក) ៣ យ៉ាង គឺ ចិត្ត រូប និងព្រះនិព្វាន ព្រះ-មានព្រះភាគត្រាស់សំដៅយកចិត្តប៉ុណ្ណោះ ។ បទថា "**នោ អបរិយាបន្នមេទ**" បានដល់ ធម៌ដែលរាប់បញ្ចូលហើយ ដោយសេចក្ដីជាធម៌ដែលរាប់ភ្ជាប់ដោយគតិ ចុតិ និងភពក្នុងសង្សារវដ្ដ ឈ្មោះថា **នោអបរិយាបន្នៈ**; សភាវធម៌ណា មិនចេញចាកលោក គឺវដ្ដៈ ព្រោះហេតុនោះ សភាវៈនោះ ទើបឈ្មោះថា **ជាអនិយ្យានិកៈ** ។ ពាក្យថា "**ឧប្បន្នំ មនោវិញ្ញាណវិញ្ញេយ្យមេទ**" នេះ ព្រះមានព្រះភាគត្រាស់ទុកក្នុងរូបកណ្ឌថា ធម៌ដែលកើតឡើងហើយ ដែលវិញ្ញាណ ៦ គប្បីដឹងបាន ព្រោះធ្វើសូម្បីមនោវិញ្ញាណដែលជាវិស័យនៃអតីតៈជាដើម ព្រោះប្រារព្ធរូបជាដើមដែលកំពុងកើតឡើង ឱ្យប្រព្រឹត្តទៅដល់ចក្ខុវិញ្ញាណជាដើម ។ ក៏វិញ្ញាណ ៥ សូម្បីកំពុងកើតឡើង រមែងមិនជាអារម្មណ៍ដល់វិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណ

ជាដើម តែជាអារម្មណ៍ដល់មនោវិញ្ញាណប៉ុណ្ណោះ, ព្រោះហេតុដូច្នោះ ទើបព្រះ-មានព្រះភាគត្រាស់ថា **“មនោវិញ្ញាណវិញ្ញេយ្យា** = វិញ្ញាណ ៥ ជាធម៌ដែលដឹងបាន ដោយមនោវិញ្ញាណ” ។

ពាក្យថា **“អនិច្ចមេវ”** បានដល់ វិញ្ញាណ ៥ ឈ្មោះថា ជាអនិច្ចៈប៉ុណ្ណោះ ព្រោះអត្ថថា មានហើយរកមានមិនបាន (កើតឡើងហើយ ក៏រលត់ទៅវិញ) ។

ពាក្យថា **“ជរាភិភូតមេវ”** បានដល់ វិញ្ញាណ ៥ ឈ្មោះថា ជរាភិភូត ព្រោះដែលជរាគ្របសង្កត់ហើយ ។

ពាក្យថា **“ឧប្បន្នវត្ថុកា ឧប្បន្នារម្មណា** = វិញ្ញាណ ៥ មានវត្ថុដែលកើតហើយ មានអារម្មណ៍ដែលកើតឡើងហើយ” បណ្ឌិតគប្បីជ្រាបថា លោកបដិសេធអនាគត ។ ពិតមែន វិញ្ញាណ ៥ នោះ រមែងមិនកើតឡើងព្រោះអារម្មណ៍ និងវត្ថុដែលជាអនាគតទាំងឡាយ ។ ពាក្យថា **“បុរេជាតវត្ថុកា, បុរេជាតារម្មណា** = វិញ្ញាណ ៥ មានវត្ថុកើតមុន, មានអារម្មណ៍កើតមុន” បានដល់ ជាការបដិសេធសេចក្តីកើតឡើងព្រមគ្នា ។ ពិតណាស់ វិញ្ញាណ ៥ នោះរមែងមិនកើតឡើង ព្រោះអាស្រ័យវត្ថុ ឬអារម្មណ៍ ដែលកើតឡើងព្រមគ្នា, ក៏វិញ្ញាណ ៥ នោះ ជាធម្មជាតិកើតក្រោយ រមែងកើតឡើង ព្រោះវត្ថុ និងអារម្មណ៍ដែលកើតមុន ។

ពាក្យថា **“អជ្ឈត្តិកវត្ថុកា** = វិញ្ញាណ ៥ មានវត្ថុជាខាងក្នុង” នេះ ព្រះ-មានព្រះភាគត្រាស់ដោយអំណាចនៃវត្ថុខាងក្នុង ដែលជារបស់ខ្លួន ។ ពិតមែន វិញ្ញាណ ៥ នោះរមែងកើតឡើង ព្រោះ**ធ្វើបសាទរូប ៥** ដែលជាខាងក្នុង ឱ្យជាវត្ថុទីអាស្រ័យហើយកើត ។ ពាក្យថា **“ពាហិរារម្មណា** = មានអារម្មណ៍ខាងក្រៅ”

បានដល់ មានអារម្មណ៍ គឺរូបារម្មណ៍ជាដើម ខាងក្រៅជាអារម្មណ៍ ។ ក្នុងសេចក្តីនេះ បណ្ឌិតគប្បីជ្រាបធម៌ពួក ៤ ។ ពិតមែន វិញ្ញាណ ៥ នោះ ឈ្មោះថា ជាខាងក្នុង មានវត្ថុជាខាងក្នុង ព្រោះធ្វើបសាទ ឱ្យជាវត្ថុទីអាស្រ័យហើយកើត ។

មនោវិញ្ញាណ ឈ្មោះថា ជាខាងក្នុង មានវត្ថុខាងក្រៅ ព្រោះវេលាកើតឡើង ធ្វើហទយរូបឱ្យជាវត្ថុទីអាស្រ័យហើយកើត ។ ខន្ធ ៣ ដែលសម្បយុត្តដោយវិញ្ញាណ ៥ ជាខាងក្រៅ មានវត្ថុជាខាងក្នុង, ខន្ធ ៣ ដែលសម្បយុត្តដោយមនោ-វិញ្ញាណជាខាងក្រៅ មានវត្ថុជាខាងក្រៅ ព្រោះវេលាកើតឡើងធ្វើហទយរូប ឱ្យជាទីអាស្រ័យ; ពាក្យថា **“អសម្ភិន្នវត្ថុកា”** បានដល់ មានវត្ថុដែលនៅមិនទាន់បែកធ្លាយ ។ ពិតមែន វិញ្ញាណ ៥ ទាំងនោះរមែងមិនកើតឡើង ព្រោះអាស្រ័យវត្ថុជាអតីតៈដែលរលត់ទៅហើយ ។ សូម្បីវិញ្ញាណ ៥ ដែលមានអារម្មណ៍នៅមិនទាន់បែកធ្លាយ ក៏ន័យនេះដែរ ។

ក្នុងពាក្យថា **“អញ្ញំ ចក្ខុវិញ្ញាណស្ស វត្ថុ ច អារម្មណញ្ច”** ជាដើម ក៏វត្ថុ និងអារម្មណ៍ របស់ចក្ខុវិញ្ញាណម្យ៉ាង របស់សោតវិញ្ញាណជាដើម ក៏ម្យ៉ាង ។ ចក្ខុវិញ្ញាណសូម្បីដល់ការសម្រេចហើយ រមែងមិនកើតតអំពីការសម្រេចដោយធ្វើវត្ថុយ៉ាងណាមួយ **ក្នុងសោតបសាទ**ជាដើម ឱ្យជាវត្ថុ ឬធ្វើរូបយ៉ាងណាមួយ **ក្នុងសំឡេង**ជាដើម ឱ្យជាអារម្មណ៍ ។ តែចក្ខុវិញ្ញាណរមែងកើតឡើង ព្រោះធ្វើចក្ខុ-បសាទប៉ុណ្ណោះ ឱ្យជាវត្ថុ និងធ្វើរូបឱ្យជាអារម្មណ៍ ។ វត្ថុក្តី ទ្វារក្តី អារម្មណ៍ក្តី របស់ចក្ខុវិញ្ញាណ រមែងមិនឈានទៅកាន់វត្ថុដទៃ ឬទៅកាន់ទ្វារដទៃ ឬក៏អារម្មណ៍ដទៃដែលជាប់តគ្នា ដោយប្រការយ៉ាងនេះ ។

ចក្ខុវិញ្ញាណមានវត្ថុដែលជាប់តគ្នា មានទ្វារដែលជាប់តគ្នា មានអា-រម្មណ៍ដែលជាប់តគ្នាប៉ុណ្ណោះ ទើបកើតឡើង ។ សូម្បីក្នុងសោតវិញ្ញាណជាដើម ក៏ន័យនេះដែរ ។

ក្នុងពាក្យថា **"ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចានុភោន្តិ** = វិញ្ញាណ ៥ រមែងមិនសោយអារម្មណ៍របស់គ្នានឹងគ្នា" នេះ អធិប្បាយថា វិញ្ញាណទាំងនោះ រមែងមិនសោយអារម្មណ៍ ត្រឹមតែម្យ៉ាង របស់គ្នានឹងគ្នាយ៉ាងនេះ គឺចក្ខុវិញ្ញាណ រមែងមិនសោយអារម្មណ៍របស់សោតវិញ្ញាណ ឬថាសោតវិញ្ញាណ ក៏រមែងមិនសោយអារម្មណ៍របស់ចក្ខុវិញ្ញាណជាដើម ។

ពិតមែន បើចក្ខុវិញ្ញាណប្រមូលមកនូវពណ៌ ដែលផ្សេងដោយពណ៌ខៀវជាដើម ជាអារម្មណ៍ហើយ គប្បីបង្អោនឱ្យដល់សោតិន្ទ្រិយថា "សូមលោកចូរកំណត់ពណ៌នោះ ចូរបង្ហាញថា 'អារម្មណ៍នោះឈ្មោះអ្វី" , សូម្បីវៀរចក្ខុវិញ្ញាណចេញហើយ គប្បីពោលតាមធម្មតារបស់ខ្លួនចំពោះមុខ យ៉ាងនេះថា "នែជនអន្ធពាល លោកស្វែងរកអស់មួយរយឆ្នាំ ក៏ដោយ អស់មួយពាន់ឆ្នាំក៏ដោយ វៀរចាកយើង (ចក្ខុវិញ្ញាណ) ហើយ លោក (សោតវិញ្ញាណ) នឹងជ្រាបពណ៌នោះបានអំពីទីណា, លោកចូរនាំពណ៌នោះមក ចូរបង្អោនទៅត្រង់ចក្ខុបសាទ, យើងនឹងដឹងនូវអារម្មណ៍នោះ ទោះជាពណ៌ខៀវ ឬពណ៌លឿងក៏ដោយ; ក៏ព្រោះថា នុ៎ះមិនមែនជាវិស័យរបស់ធម៌ដទៃទេ, នុ៎ះជាវិស័យរបស់យើងប៉ុណ្ណោះ"; សូម្បីក្នុងវិញ្ញាណដែលនៅសល់ ក៏ន័យនេះដែរ ។ ដោយអាការយ៉ាងនេះ វិញ្ញាណ ៥ ទើបឈ្មោះថា រមែងមិនសោយអារម្មណ៍របស់គ្នានឹងគ្នា ។

ពាក្យថា **“សមន្នាហរន្តស្ស”** បានដល់ កាលនាំអាវជ្ជនៈមកហើយនោះឯង បញ្ចវិញ្ញាណទើបកើតឡើង ។ ពាក្យថា **“មនសិករោន្តស្ស”** បានដល់ កាលធ្វើទុកក្នុងចិត្តដោយការនឹកដល់នោះឯង បញ្ចវិញ្ញាណទើបកើត ។ ពិតមែន ចិត្តទាំងនេះ (បញ្ចវិញ្ញាណ) រមែងកើតឡើងក្នុងវេលានឹកដល់ ឬក្នុងវេលាធ្វើទុកក្នុងចិត្តដោយអាវជ្ជនៈ ។

ពាក្យថា **“ន អញ្ញោភិណ្ណា** = មិនច្រឡំគ្នាក៏មិនមែន” បានដល់ មិនត្រូវជ្រែកដោយវិញ្ញាណដទៃ រមែងកើតជាប់តគ្នាទៅក៏មិនមែន ។ សូម្បីការកើតរួមគ្នានឹងចិត្តទាំងពួង ព្រះមានព្រះភាគទ្រង់បដិសេធដោយបទថា **ន អបុព្វំ អចរិមំ** នេះ; និងទ្រង់បដិសេធការកើតឡើងដោយលំដាប់នៃគ្នានឹងគ្នា ដោយបទថា **ន អញ្ញមញ្ញស្ស សមនន្តរា** នេះ; ឈ្មោះទាំងឡាយរបស់អាវជ្ជនៈមាន ៤ ប៉ុណ្ណោះ ដែលមានពាក្យថា **អាវដ្ដនា** = ការនឹករាវរក; ពិតមែន ព្រះមានព្រះភាគត្រាស់ហៅអាវជ្ជនៈ នោះថា **អាវដ្ដនា** ព្រោះការត្រឡប់ដូរផ្លាស់ទៅនៃភវង្គ, ត្រាស់ហៅថា **អាភោគៈ** (ការរំពឹង) ព្រោះសេចក្ដីរំពឹងរបស់ចិត្តនោះនុ៎ះឯង, ត្រាស់ហៅថា **សមន្នាហរណៈ** ព្រោះប្រមូលមកនូវរូបជាដើម, ត្រាស់ហៅថា **មនសិការ** ព្រោះការធ្វើទុកក្នុងចិត្តរបស់ចិត្តទាំងនោះឯង ។ ការដែលអាចដើម្បីធ្វើនាទី (កិច្ច) នៃអាវដ្ដនា (ការនឹក) ព្រះមានព្រះភាគទ្រង់តាំងទុកក្នុងឋាន នៃអាវជ្ជនៈរបស់វិញ្ញាណ ៥ ដោយសង្ខេបក្នុងទីនេះ និងទ្រង់បដិសេធចិត្តតែមួយដួង១ ដែលកើតរួមគ្នាដោយអាការយ៉ាងនេះ ។

ពាក្យថា **“ន កិញ្ចិ ធម្មំ បដិជានាតិ** = បុគ្គលរមែងមិនដឹងច្បាស់នូវធម៌

អ្វីៗ ដោយវិញ្ញាណ ៥” អធិប្បាយថា បុគ្គលរមែងមិនដឹងច្បាស់នូវកុសល ឬអកុសលធម៌ សូម្បីត្រឹមតែមួយ ដែលព្រះមានព្រះភាគត្រាស់ទុកហើយ យ៉ាងនេះថា **“ធម៌ទាំងឡាយ មានចិត្តជាប្រធាន”** [១៤] ជាដើម ។

ពាក្យថា **“អញ្ញត្រ អភិនិបាតមត្តា** = ត្រឹមតែថា ជាទីធ្លាក់ទៅនៃអារម្មណ៍ឯណានីមួយ” អធិប្បាយថា វិញ្ញាណ ៥ ត្រឹមតែថា ជាទីធ្លាក់ទៅ ដោយវៀររូបជាដើម ហើយរមែងមិនដឹងអ្វីៗ; សេចក្ដីនេះ ព្រះមានព្រះភាគទ្រង់អធិប្បាយទុកថា ៖

“សូម្បីបុរសជាអ្នកឈ្លាសហើយ ក៏រមែងមិនដឹងធម៌ដទៃសូម្បីតែមួយ ក្នុងបណ្ដាកុសល និងអកុសលធម៌ ដោយវិញ្ញាណ ៥ វៀររូបដែលមកកាន់គន្លង” ។ ម្យ៉ាងទៀត ចក្ខុវិញ្ញាណក្នុងទីនេះ គ្រាន់តែជាការឃើញប៉ុណ្ណោះ ។ សូម្បីសោតវិញ្ញាណជាដើម ក៏ត្រឹមតែជាការស្ដាប់... ការធុំ... ការស្រូបរស... និងការប៉ះខ្ទប់ប៉ុណ្ណោះ ។ ក៏ការទទួលដឹងអារម្មណ៍ដោយត្រឹមតែការឃើញជាដើម ឈ្មោះថា ការរាយការណ៍ (ឬការពោលប្រាប់) នូវធម៌ទាំងនោះយ៉ាងដទៃ មានកុសលជាដើម មិនមែនទេ ។

ពាក្យថា **“មនោធាតុយាបិ** = សូម្បីដោយមនោធាតុ” បានដល់ សូម្បីដោយមនោធាតុ **គឺសម្បដិច្ឆន្នចិត្ត** ។ ម្យ៉ាងទៀត ក្នុងពាក្យថា **“មនោធាតុយាបិ”** នេះ **បិ**អក្សរជាការប្រមូលមកនូវសេចក្ដី; ព្រោះហេតុដូច្នោះ បណ្ឌិតគប្បី

---

[១៤] ខុ. ធ. (ធម្មបទ. ភាគ ១) ។

ជ្រាបសេចក្ដីក្នុងទីនេះ យ៉ាងនេះថា បុគ្គលរមែងមិនដឹងច្បាស់នូវធម៌អ្វី១ ដែលជាកុសលបាន ដោយវិញ្ញាណដែលប្រព្រឹត្តទៅតាមផ្លូវទ្វារ ៥ សូម្បីទាំងអស់ គឺសូម្បីដោយមនោធាតុ សូម្បីដោយមនោវិញ្ញាណធាតុដែលតអំពីមនោធាតុនោះ ។

សូម្បីក្នុងពាក្យថា **“ន កិញ្ចិ ឥរិយាបថំ កប្បេតិ** = បុគ្គលរមែងមិនសម្រេចឥរិយាបថយ៉ាងណាមួយ ដោយវិញ្ញាណ ៥” ជាដើម ក៏ន័យនេះដែរ ។ ពិតមែន បុគ្គលរមែងមិនសម្រេចឥរិយាបថណា១ ក្នុងការដើរជាដើមបាន ដោយវិញ្ញាណដែលប្រព្រឹត្តទៅតាមផ្លូវទ្វារ ៥ ។

បុគ្គលរមែងមិនតាំងកាយកម្ម មិនតាំងវចីកម្ម ដោយវិញ្ញាណ ៥ រមែងមិនសមាទានធម៌ដែលជាកុសលាកុសល ដោយវិញ្ញាណ ៥ រមែងមិនចូលសមាធិ (សមាបត្តិ) ដែលជាលោកិយ ឬលោកុត្តរ រមែងមិនចេញពីសមាធិដែលជាលោកិយ ឬលោកុត្តរ ដោយវិញ្ញាណ ៥ រមែងមិនចុតិ (ឃ្លាត) ចាកភព រមែងមិនកើតឡើងក្នុងភពដោយវិញ្ញាណ ៥ ។ **ពិតមែន កិច្ច (នាទីរបស់ចិត្ត) មានការដឹងច្បាស់នូវធម៌ដែលជាកុសល និងអកុសលជាដើម មានការចុតិជាបរិយោសានសូម្បីទាំងអស់ រមែងមានដោយចិត្តតាមផ្លូវមនោទ្វារប៉ុណ្ណោះ, រមែងមិនមាន ដោយចិត្តដែលប្រព្រឹត្តទៅតាមទ្វារ ៥,** ព្រោះហេតុដូច្នោះ សូម្បីវីថិចិត្តទាំងពួងដែលប្រព្រឹត្តទៅដោយជវនៈ ព្រោះការធ្វើនូវកិច្ចនេះ ទើបព្រះមានព្រះភាគទ្រង់បដិសេធហើយក្នុងវិញ្ញាណ ៥ នេះ ។ម្យ៉ាងទៀត កិច្ចទាំងឡាយដែលពោលហើយនេះ រមែងមានដល់ចិត្តដែលប្រកបដោយវិញ្ញាណ ៥ នេះ យ៉ាងណា, សូម្បីការឈានចុះកាន់និយាមធម៌ ក៏ដូច្នោះដែរ ។ គឺថាបុគ្គលរមែងមិនចុះកាន់

**មិច្ឆត្តនិយាម**[១៥] **ឬសម្មត្តនិយាម**[១៦] បានដោយវិញ្ញាណ ៥ ឡើយ ។

**ពិតមែន ជវនៈ** (**របស់បញ្ចទ្វារ**) **រមែងមិនស្ទុះទៅ** (**សេពអារម្មណ៍**) ព្រោះប្រារព្ធនាម និងគោត្រ, រមែងមិនត្រាច់ទៅ ព្រោះប្រារព្ធបញ្ញត្តិដែលមានកសិណជាដើម; រមែងមិនប្រព្រឹត្តទៅដោយអំណាចនៃវិបស្សនា ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍ រមែងមិនប្រព្រឹត្តទៅដោយអំណាចនៃវិបស្សនា ដែលមានកម្លាំង គឺវុដ្ឋានគាមិនី រមែងមិនត្រាច់ទៅព្រោះប្រារព្ធរូប និងអរូបធម៌ រមែងមិនត្រាច់ទៅកាន់ព្រះនិព្វាន ។ ម្យ៉ាងទៀត **បដិសម្ភិទាញាណ រមែងមិនកើតដោយជវ័ន** (**ក្នុងបញ្ចទ្វារ**) **នោះ, អភិញ្ញាញាណ, សាវកបារមីញាណ, បច្ចេកពោធិញ្ញាណ, សព្វញ្ញុតញ្ញាណ ក៏រមែងមិនកើតដោយជវនៈនោះ ។ ក៏ប៉ុន្តែថា ធម៌មានប្រភេទផ្សេងៗ សូម្បីទាំងអស់ រមែងមានក្នុងជវនមនោទ្វារប៉ុណ្ណោះ ។**

ពាក្យថា **"ន សុបតិ, ន បដិពុជ្ឈតិ, ន សុបិនំ បស្សតិ** = បុគ្គលរមែងមិនលក់, មិនភ្ញាក់, មិនសុបិន ដោយវិញ្ញាណ ៥" អធិប្បាយថា ព្រះមានព្រះភាគទ្រង់បដិសេធវីថិចិត្តព្រមដោយជវនៈ ក្នុងឋានទាំង ៣ នេះថា បុគ្គលរមែងមិនឈានចុះកាន់ សេចក្តីលក់, រមែងមិនលក់, រមែងមិនភ្ញាក់, រមែងមិនសុបិន (យល់សប្តិ) អ្វីៗ ដោយចិត្តដែលប្រព្រឹត្តទៅតាមបញ្ចទ្វារសូម្បីទាំងអស់ ។

---

[១៥] បានដល់ អនន្តរិយកម្ម ៥ និងនិយតមិច្ឆាទិដ្ឋិ ។

[១៦] បានដល់ លោកុត្តរ ៤។

ពិតមែន កាលបុគ្គលកំពុងលក់ស៊ប់ ដល់ញុំាងប្រឆេះទៀនធំឱ្យឆេះសន្ធោ-សន្ធៅ ហើយបញ្ជូនពន្លឺនោះចូលទៅជិតភ្នែករបស់បុគ្គលនោះ **បឋមភវង្គ** រមែង មិនត្រឡប់ទៅ (នៅមិនផ្លាស់ទៅ) កាន់អាវជ្ជនៈដែលប្រព្រឹត្តទៅតាមផ្លូវចក្ខុទ្វារ មុន ។

ក៏ចិត្តដែលប្រកបដោយមនោទ្វារប៉ុណ្ណោះ រមែងវិលទៅ; លំដាប់នោះ ជវនចិត្តសេពអារម្មណ៍ហើយ ក៏ធ្លាក់ចុះកាន់ភវង្គ ។

**ក្នុងវារៈទី ២** ភវង្គចិត្តរមែងត្រឡប់ទៅកាន់អាវជ្ជនចិត្តដែលជាចក្ខុទ្វារ, តពីនោះ ចក្ខុវិញ្ញាណជាដើម មានជវនៈជាបរិយោសាន រមែងប្រព្រឹត្តទៅ, លំដាប់ នោះ ភវង្គចិត្ត ទើបប្រព្រឹត្តទៅទៀត ។

**ក្នុងវារៈទី ៣** កាលភវង្គត្រឡប់ទៅកាន់អាវជ្ជនៈដែលជាមនោទ្វារហើយ ជវនៈ ដែលជាមនោទ្វារវីថិទើបត្រាច់ទៅ ។ លោកពោលថា ព្រោះដឹងដោយចិត្ត (ជវនចិត្តមនោទ្វារ) នោះ បុគ្គលក្រឡេកមើល ទើបជ្រាបអ្វីៗ បានក្នុងទីនេះ ។

ដោយទំនងដូចគ្នា កាលបុគ្គលកំពុងលក់ស្និទ្ធ អ្នកណាៗ ប្រគំតន្ត្រីជិតត្រចៀក ឬបង្ហោនផ្កាឈើដែលមានក្លិនក្រអូបក៏ដោយ ស្អុយក៏ដោយ ទៅជិតច្រមុះ ឬដាក់ ទឹកដោះថ្លា ឬក៏ដាក់ទឹកអំពៅចូលទៅក្នុងមាត់ ឬថាយកបាតដៃ ប្រហារត្រង់ខ្នង ក៏ដោយ បឋមភវង្គ ក៏នៅមិនត្រឡប់ទៅកាន់អាវជ្ជនៈ ដែលប្រព្រឹត្តទៅតាម សោតទ្វារជាដើមឡើយ ។

**ចិត្តដែលជាមនោទ្វារប៉ុណ្ណោះ រមែងត្រឡប់ទៅ; លំដាប់នោះ ជវនៈ សេពអារម្មណ៍ហើយ ក៏ធ្លាក់ចុះកាន់ភវង្គ ។**

**ក្នុងវារៈទី ២** ភវង្គទើបត្រឡប់ទៅកាន់អាវជ្ជនៈទាំងឡាយ ដែលប្រព្រឹត្តទៅតាមសោតទ្វារជាដើម, តពីនោះ សោតៈ ឃានៈ ជិវ្ហា និងកាយវិញ្ញាណជាដើម មានជវ័នជាបរិយោសាន រមែងប្រព្រឹត្តទៅ, តពីនោះ ភវង្គក៏ប្រព្រឹត្តទៅទៀត ។

**ក្នុងវារៈទី ៣** គ្រាកាលភវង្គត្រឡប់ទៅកាន់អាវជ្ជនៈ ដែលជាមនោទ្វារ ហើយ ជវ័នដែលជាមនោទ្វារ ក៏ត្រាច់ទៅ ។ ព្រោះដឹងដោយចិត្ត (ជវនចិត្តដែលជាមនោទ្វារវីថិ) នោះ ទើបបុគ្គលដឹងថា "សំឡេងអ្វីក្នុងទីនេះ ? នេះជាសំឡេងស័ង្ខ នេះជាសំឡេងស្គរ" , ឬដឹងថា "ក្លិនអ្វីក្នុងទីនេះ ? នេះជាក្លិនកើតពីឫស នេះជាក្លិនកើតពីខ្លឹម" ឬក៏ដឹងថា "រសអ្វីដែលគេដាក់ចូលទៅក្នុងមាត់របស់ខ្លួន ? នេះជាទឹកដោះថ្លា នេះជាទឹកអំពៅ" ឬមួយដឹងថា "ការប្រហារនេះអ្នកណាវាយ អ្នកណាខ្ទប់ អ្នកណាប្រហារខ្នង" ។ បុគ្គលទើបឈ្មោះថា រមែងភ្ញាក់ដោយជវនចិត្តដែលប្រព្រឹត្តទៅតាមមនោទ្វារប៉ុណ្ណោះ, ដោយអាការយ៉ាងនេះ ទើបបុគ្គលមិនបានភ្ញាក់ឡើង ដោយចិត្តដែលប្រព្រឹត្តទៅតាមបញ្ចទ្វារ ។

បុគ្គលរមែងឃើញសូម្បីសុបិន (យល់សប្តិ) ដោយជវនចិត្តផ្លូវមនោទ្វារនោះនុ៎ះឯង, មិនបានយល់សប្តិដោយចិត្តដែលប្រព្រឹត្តទៅតាមបញ្ចទ្វារឡើយ ៕

## ហេតុនៃការយល់សប្តិ ៤

ក៏ឯបុគ្គលកាលឃើញសុបិន (យល់សប្តិ) នោះៗ រមែងយល់សប្តិឃើញដោយហេតុ ៤ ប្រការ គឺ

**១.ធាតុក្ខោភតោ** ដោយធាតុកម្រើក

**-អនុភូតបុព្វតោ** ដោយធ្លាប់ប្រសព្វមកក្នុងកាលមុន
**-ទេវតោបសំហារតោ** ដោយទេវតាបណ្ដាលចិត្ត
**-បុព្វនិមិត្តតោ** ដោយបុព្វនិមិត្ត ។

ក្នុង ៤ យ៉ាងនោះ បុគ្គលមានធាតុកម្រើក ព្រោះប្រកបដោយបច្ច័យធ្វើឱ្យខុសប្រក្រតីរបស់ទឹកប្រមាត់ជាដើម ទើបឈ្មោះថា រមែងយល់សប្ដិ **ព្រោះធាតុកម្រើក** ។ ពិតមែន ការយល់សប្ដិទៅផ្សេងៗ ដូចជាកំពុងធ្លាក់ទៅពីភ្នំ ដូចជាកំពុងដើរទៅតាមអាកាស និងដូចជាត្រូវម្រឹគកាច ដំរីកាច និងចោរជាដើម ដេញតាម ។

**ពោលអំពីធ្លាប់ប្រសព្វមកក្នុងកាលមុន** បុគ្គលកាលយល់សប្ដិ រមែងយល់សប្ដិឃើញអារម្មណ៍ដែលខ្លួនធ្លាប់ប្រសព្វមកហើយក្នុងកាលមុន ។

**ពោលអំពីទេវតាបណ្ដាលចិត្ត** ទេវតារមែងបង្អោនអារម្មណ៍យ៉ាងផ្សេងៗចូលទៅ ព្រោះភាវៈជាអ្នកប្រាថ្នានឹងឱ្យប្រយោជន៍ ឬព្រោះការប្រាថ្នានឹងឱ្យកើតសេចក្ដីសាបសូន្យ ឬថាដើម្បីឱ្យកើតសេចក្ដីចម្រើន ឬក៏ដើម្បីឱ្យកើតសេចក្ដីវិនាសដល់បុគ្គលអ្នកយល់សប្ដិនោះ ។ បុគ្គលនោះ រមែងយល់សប្ដិឃើញអារម្មណ៍ទាំង-នោះ ដោយអានុភាពនៃទេវតាទាំងឡាយនោះ ។

**ពោលអំពីបុព្វនិមិត្ត** បុគ្គលកាលយល់សប្ដិឃើញ រមែងយល់សប្ដិឃើញសុបិនដែលជាបុព្វនិមិត្ត (គ្រាដែលប្រាប់ហេតុកើតឡើងមុន) នៃសេចក្ដីចម្រើន ឬសេចក្ដីវិនាស ដោយអំណាចនៃបុណ្យ និងបាប ដូចជាមាតាព្រះពោធិសត្វ សុបិន-និមិត្តក្នុងការបានចំពោះនូវព្រះរាជបុត្រ, ដូចព្រះពោធិសត្វទ្រង់មហាសុបិននិមិត្ត ៥

យ៉ាង [១៧] និងដូចព្រះបាទបសេនទិកោសលទ្រង់សុបិននិមិត្ត ១៦ យ៉ាង [១៨] ។

ក្នុងហេតុទាំង ៤ នោះ បុគ្គលរមែងយល់សប្តិឃើញវត្ថុណាដោយធាតុកម្រើក និងដោយការធ្លាប់ប្រសព្វមក វត្ថុនោះមិនមែនជាសេចក្តីពិត ។ បុគ្គលរមែងយល់សប្តិឃើញវត្ថុណាដែលទេវតាបណ្តាលចិត្ត, វត្ថុនោះពិតក៏បាន មិនពិតក៏បាន; ព្រោះថា ទេវតាក្រោធហើយ ប្រាថ្នាឱ្យដល់សេចក្តីវិនាសដោយឧបាយរបស់ខ្លួន ទើបធ្វើការបណ្តាលចិត្ត សម្តែងវត្ថុនោះឱ្យវិបរិតទៅក៏បាន ។

នេះជារឿងរ៉ាវក្នុងការយល់សប្តិនោះ ៖

បានឮថា ក្នុងមហាវិហារដ៏ប្រសើរ ក្នុងនគររោហណៈ ព្រះមហាថេរមិនសុំអនុញ្ញាតព្រះភិក្ខុសង្ឃ បញ្ជាឱ្យកាត់ដើមឈើធំមួយ; ទេវតាអ្នកឋិតនៅត្រង់ដើមឈើ ក្រោធខឹងព្រះថេរៈហើយ; គ្រាដំបូងនុ៎ះឯងធ្វើប្រឡោមលោម (រីករាយ) នឹងព្រះថេរៈ, ខាងក្រោយមកប្រាប់សុបិននិមិត្តថា “ព្រះរាជាអ្នកជាឧបដ្ឋាករបស់លោកនឹងសុគតខាងក្នុង ៧ ថ្ងៃ រាប់ពីថ្ងៃនេះទៅ” ។ ព្រះថេរៈនាំរឿងនោះ ទៅប្រាប់ដល់នាងស្នំរបស់ព្រះរាជា ។ ទេវតានោះ ក៏ក្លែងស្រែកសំឡេងហាក់ដូចជាត្រូវគេប្រហារមួយគ្រា ។ ព្រះរាជាទ្រង់សួរថា “នោះជាអ្វីទៅ ?” ; ទេវតានោះទូលថា “ព្រះថេរៈពោលយ៉ាងនេះ” ។ ព្រះរាជាឱ្យរាជបុរសរាប់ចំនួនថ្ងៃ កាលព្រះជន្មរបស់ព្រះ

---

[១៧] បានដល់ លោកុត្តរ ៤ ។

[១៨] ខុ. ជា., សារត្ថ. ២ ។

អង្គុលើស ៧ ថ្ងៃហើយ ទ្រង់ក្រោធឱ្យរាជបុរសកាត់ដៃ និងជើងរបស់ព្រះថេរៈចេញ ។

ក៏បុគ្គលរមែងឃើញវត្ថុណា ដោយបុព្វនិមិត្ត, វត្ថុនោះរមែងពិត ដោយចំណែកតែម្យ៉ាង; ឯប្រភេទនៃការយល់សប្តិ រមែងមានព្រោះតែសេចក្តី ផ្សេងគ្នា ទៅតាមការជាប់ទាក់ទងដោយមូលហេតុទាំង ៤ នេះមែនពិត ។

ម្យ៉ាងទៀត ព្រះសេក្ខៈ និងបុថុជ្ជនប៉ុណ្ណោះ រមែងយល់សប្តិសុបិន និមិត្ត សូម្បីទាំង ៤ យ៉ាង ព្រោះសេចក្តីដែលខ្លួននៅមិនទាន់បានលះ វិបល្លាស ៤ ។

សម្រាប់ព្រះអសេក្ខបុគ្គល រមែងមិនយល់សប្តិ ព្រោះលោកមាន វិបល្លាសដែលលះបានហើយ ។

សួរថា ក៏បុគ្គលកាលយល់សប្តិ លក់ហើយរមែងយល់សប្តិ, ឬភ្ញាក់ហើយ រមែងយល់សប្តិ, ឬថា ទាំងមិនមែនលក់ហើយ ទាំងមិនមែនភ្ញាក់ហើយ រមែង យល់សប្តិ ?

ឆ្លើយថា ក្នុងទីនេះ ការយល់សប្តិនឹងជាយ៉ាងណា គប្បីជ្រាបដូច្នេះ ៖

បើថា បុគ្គលលក់ហើយយល់សប្តិនោះ, សេចក្តីនេះ រមែងមិនត្រូវ តាមព្រះអភិធម្ម; ព្រោះថា (ក្នុងព្រះអភិធម្ម) បុគ្គលរមែងលក់ដោយភវង្គ ចិត្ត ឯភវង្គចិត្តដែលមានរូបនិមិត្តជាដើម ជាអារម្មណ៍នោះ មិនបានសម្ប យុត្តដោយកិលេស មានរាគៈជាដើម ។ ចំណែកបុគ្គលយល់សប្តិ ចិត្តទាំង ឡាយបែបនេះ (គឺចិត្តដែលសម្បយុត្តដោយកិលេសមានរាគៈជាដើម) រមែង កើតបាន ។

បើបុគ្គលភ្ញាក់ហើយ រមែងយល់សប្តិបាន, សេចក្តីនេះ ក៏មិនត្រូវតាមព្រះ

វិន័យ; ព្រោះថា បុគ្គលភ្ញាក់ហើយរមែងយល់សប្តិឃើញវត្ថុណា, វត្ថុនោះរមែងឃើញដោយចិត្តដែលប្រព្រឹត្តទៅជាមួយនឹងអព្វោហារិក (គឺវត្ថុដែលពោលអាងមិនបាន), ព្រោះថា ឈ្មោះថា អនាបត្តិ ព្រោះការប្រព្រឹត្តិកន្លងព្រះបញ្ញត្តិដែលភិក្ខុធ្វើហើយ ដោយចិត្តដែលប្រព្រឹត្តទៅជាមួយនឹងវត្ថុដែលពោលអាងមិនបាន មិនមាន ។ ម្យ៉ាងទៀត កាលបុគ្គលធ្វើកម្មដោយចិត្តដែលកំពុងយល់សប្តិ ដែលជាការកន្លងព្រះបញ្ញត្តិ រមែងជាអនាបត្តិមែនពិត ។

បើបុគ្គលមិនលក់ មិនភ្ញាក់ រមែងយល់សប្តិបាន, គេរមែងនឹងបានឈ្មោះថា មិនយល់សប្តិឃើញនូវសុបិន (ក្នុងទីនេះ); ក៏កាលបើមានសេចក្តីជាយ៉ាងនោះ ការមិនមាននៃសុបិននុ៎ះឯង រមែងប្រាកដ; ការមាននៃសុបិន ក៏រមែងមិនប្រាកដ; សេចក្តីនេះមាន ព្រោះហេតុអ្វី ? ព្រោះបុគ្គលមានសេចក្តីងងុយងោកងក់ទៅប្រាសហើយដូចស្វា រមែងយល់សប្តិ ។ សមពិតដូចដែលពោលទុកថា "បពិត្រមហារាជ បុគ្គលមានសេចក្តីងងុយងោកងក់ទៅប្រាសហើយដូចស្វា រមែងយល់សប្តិ" ។ ពាក្យថា **កបិមិទ្ធបរេតោ** លោកប្រកបទុកដោយការដេករបស់ស្វា ។ ដូចយ៉ាងថា ការដេកលក់របស់ស្វារមែងប្រព្រឹត្តទៅរហ័សយ៉ាងណា, ឈ្មោះថា ការដេកលក់របស់បុគ្គល ព្រោះសេចក្តីឃ្លៀងឃ្លាតហើយ ដោយកុសលចិត្តជាដើម ដែលប្រព្រឹត្តទៅយ៉ាងលឿនរហ័សញយៗ ក៏ដូច្នោះដែរ, ការកន្លងទៅចាកភវង្គញយៗ ព្រោះសេចក្តីប្រព្រឹត្តទៅនៃការលក់យ៉ាងណា, ការប្រកបដោយការលក់នោះ រមែងឃើញសុបិន; ព្រោះហេតុនោះ ការយល់សប្តិនេះ រមែងជាកុសលខ្លះ អកុសលខ្លះ និងជាអព្យាក្រឹតខ្លះ ។ ក្នុងការយល់សប្តិទាំងនោះ កាលបុគ្គលយល់សប្តិឃើញថា ថ្វាយបង្គំចេតិយ ស្តាប់ធម៌ និងសម្តែងធម៌ជាដើម រមែងជាកុសល, កាលយល់សប្តិថា ធ្វើ

បាណាតិបាតជាដើម រមែងជាអកុសល, ក្រៅពីចិត្តទាំងពីរនេះ ក្នុងខណៈអាវជ្ជនៈ និងតទាលម្ពណៈ គប្បីជ្រាបថាជាអព្យាក្រឹត។ សូម្បីក្នុងវេលាដែលពោលថា “វត្ថុនេះយើងឃើញ[*] , វត្ថុនេះយើងឮ វត្ថុដែលប្រាកដហើយនោះឯង ក៏ជាអព្យាក្រឹតដែរ។

**សួរថា** កុសលធម៌ និងអកុសលធម៌ ដែលបុគ្គលធ្វើហើយ ក្នុងខណៈយល់សប្តិជាធម៌មានវិបាកឬទេ ?

ឆ្លើយថា **មានវិបាក, តែកម្មដែលធ្វើក្នុងខណៈយល់សប្តិនោះ មិនអាចឱ្យបដិសន្ធិបាន ព្រោះវិបាកនោះមានកម្លាំងខ្សោយ ។ តែគ្រាកាលបដិសន្ធិប្រព្រឹត្តទៅហើយ (ក្នុងបវត្តិកាល) ដោយកម្មយ៉ាងដទៃ ឱ្យផលហើយ (កម្មដែលធ្វើក្នុងវេលាយល់សប្តិ) រមែងឱ្យផល ។**

ពាក្យថា “**ឯវំ យាថាវកវត្ថុវិភាវនា បញ្ញា** = ការដឹងរឿងវិញ្ញាណ ៥ ដូចពោលមកនេះ ឈ្មោះថា បញ្ញា” បណ្ឌិតគប្បីជ្រាបថា មិនមែនជាការអធិប្បាយដល់ហេតុរបស់វិញ្ញាណ ៥ តែជាការអធិប្បាយសេចក្តីពិតរបស់វិញ្ញាណ ៥ ប៉ុណ្ណោះ ។

ពាក្យថា “**តំ យាថាវវត្ថុំ វិភាវេតិ**” បានដល់ ជាការចង្អុលពន្យល់ដល់រឿងវិញ្ញាណ ៥ តាមសេចក្តីពិត ។ បណ្ឌិតគប្បីជ្រាប ពាក្យអធិប្បាយសេចក្តីដឹងរឿងវិញ្ញាណ ៥ តាមសេចក្តីពិតយ៉ាងនោះ ឈ្មោះថា ព្រះមានព្រះភាគទ្រង់តាំងទុកក្នុងមាតិកាថា “ការដឹងរឿងវិញ្ញាណ ៥ តាមសេចក្តីពិត យ៉ាងណា ឈ្មោះថា

---

[*] បាលីប្រើ **ទិដ្ឋំ វិយ មេ, សុត្តំ វិយ មេ** ដូចគ្នានឹងពាក្យថា រូបដែលយើងឃើញហើយ សំឡេងដែលយើងឮហើយ ដែលចាត់ជាអព្យាក្រឹត ព្រោះជារូប ។

បញ្ញា” ក្នុងកាលមុន ដូចពណ៌នាមកដូច្នេះ ។ គប្បីជ្រាបថា ការរាប់ញាណដោយអំណាចនៃធម៌ពួកមួយ ឬការរាប់ដោយអាការម្យ៉ាង យ៉ាងនេះថា “**ឯកវិធេន ញាណវត្ថុ**” ដូចពណ៌នាមកដូច្នេះ ៕

ចប់ញាណវត្ថុពួក ១

## ២. អដ្ឋកថាទុកនិទ្ទេស អធិប្បាយញាណវត្ថុពួក ២

ពាក្យថា “**ចតូសុ ភូមីសុ កុសលេ** = កុសលធម៌ក្នុងភូមិ ៤” បានដល់បញ្ញាជាកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ របស់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ គប្បីជ្រាបវិនិច្ឆ័យក្នុងទីនេះថា បញ្ញាណារមែងញ៉ាំងប្រយោជន៍ ពោលគឺវិបាកដែលរាប់បញ្ចូលហើយ ដោយភូមិរបស់ខ្លួនឱ្យកើតឡើង ឱ្យផល គឺឱ្យប្រព្រឹត្តទូទៅក្នុងប្រយោជន៍ ៥ * ដូចដែលព្រះមានព្រះភាគត្រាស់ទុក ក្នុងបដិសម្ភិទាវិភង្គ ព្រោះហេតុនោះ ទើបបញ្ញានោះ ឈ្មោះថា **អត្ថជាបិកា** ។ ពាក្យថា “**អរហតោ អភិញ្ញំ ឧប្បាទេន្តស្ស សមាបត្តឹ ឧប្បាទេន្តស្ស កិរិយាព្យាកតេ** = បញ្ញាដែលជាកិរិយាព្យាកតៈរបស់ព្រះអរហន្ត អ្នកកំពុងញ៉ាំងអភិញ្ញាឱ្យកើតឡើង អ្នកកំពុងញ៉ាំងសមាបត្តិឱ្យកើតឡើង” បានដល់ បញ្ញាដែលជាកិរិយាក្នុងកាមាវចរ ក្នុងវេលាធ្វើបរិកម្មនៃអភិញ្ញា និងសមាបត្តិ ។ ពិតមែន បញ្ញានោះរមែងញ៉ាំងប្រយោជន៍ ពោល

---

* គឺ ១-សច្ចវារៈ, ២-ហេតុវារៈ, ៣-ធម្មវារៈ, ៤-បច្ចយាការវារៈ, ៥-បរិយត្តិធម្មវារៈ ។

គឺកិរិយាដែលផ្សេងដោយអភិញ្ញា និងសមាបត្តិ ឱ្យកើត ឱ្យផល ឱ្យប្រព្រឹត្តទូទៅ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា **អត្ថជាបិកបញ្ញា** ៕

**ន័យរបស់អដ្ឋកថាដែលជាបាលីមុត្តកៈ ម្យ៉ាងទៀត** ៖

ក៏សូម្បីបញ្ញាណាជាកាមាវចរកិរិយា ដែលកើតឡើងមុន រមែងជាបច្ច័យដល់កាមាវចរកិរិយាដែលកើតឡើងខាងក្រោយ ដោយអំណាចនៃអនន្តរប្បច្ច័យ, សូម្បីបញ្ញានោះ ឈ្មោះថា **អត្ថជាបិកបញ្ញា** ព្រោះរមែងញ៉ាំងប្រយោជន៍ ពោលគឺកិរិយានោះ ឱ្យកើតឡើង ។ សូម្បីបញ្ញាក្នុងរូបាវចរទាំងឡាយ ក៏ន័យនេះដែរ ។ គប្បីជ្រាបក្នុងនិទ្ទេសនៃបទទី ២ មានពាក្យថា "**ចតូសុ ភូមីសុ វិបាកេ** = វិបាកធម៌ក្នុងភូមិ ៤" បានដល់ បញ្ញាក្នុងកាមាវចរវិបាក ឈ្មោះថា **ជាបិតត្ថា** ព្រោះញ៉ាំងប្រយោជន៍ក្នុងកាមាវចរវិបាក ឱ្យកើតឡើង ហើយតាំងនៅ ដោយអំណាចនៃបច្ច័យ មានសហជាតប្បច្ច័យជាដើម ។ សូម្បីបញ្ញាក្នុងវិបាកមានរូបាវចរបញ្ញាជាដើម ក៏ន័យនេះដែរ ។

ម្យ៉ាងទៀត សូម្បីបញ្ញាទាំងអស់នេះ ឈ្មោះថា **ជាបិតត្ថា** ព្រោះឱ្យកើត ឱ្យផល ឱ្យប្រព្រឹត្តទូទៅ ដោយហេតុទាំងឡាយរបស់ខ្លួនៗ និងសូម្បីដោយខ្លួនឯងក៏ជាប្រយោជន៍ដូច្នេះខ្លះ ។ សូម្បីក្នុងបញ្ញាដែលជាកិរិយាដែលព្រះមានព្រះភាគត្រាស់ទុកថា "បញ្ញារបស់ព្រះអរហន្ត ខណៈដែលអភិញ្ញាកើតហើយ ខណៈដែលសមាបត្តិកើតហើយ" ក៏ន័យនេះដែរ ៕

**ន័យរបស់អដ្ឋកថាដែលជាបាលីមុត្តកៈ ម្យ៉ាងទៀត** ៖

ក៏សូម្បីបញ្ញាក្នុងកិរិយាដែលជាកាមាវចរ ឈ្មោះថា **ជាមិតត្តា** ព្រោះញ៉ាំងប្រយោជន៍ ពោលគឺកាមាវចរកិរិយា ឱ្យកើតហើយតាំងនៅដោយអំណាចនៃសហ-ជាតប្បច្ច័យជាដើម ។ សូម្បីក្នុងបញ្ញាដែលជាកិរិយា ក្នុងរូបាវចរ និងអរូបាវចរ ក៏ន័យនេះដែរ ។

ម្យ៉ាងវិញទៀត សូម្បីបញ្ញាទាំងអស់នេះ ឈ្មោះថា **ជាមិតត្តា** ព្រោះឱ្យកើតឱ្យផល ឱ្យមានទូទៅ ដោយហេតុទាំងឡាយរបស់ខ្លួនៗ និងសូម្បីខ្លួនឯង ក៏ជាប្រយោជន៍ដូច្នេះខ្លះ ។ ពាក្យដែលនៅសល់ទាំងអស់ក្នុងទីនេះ ប្រាកដច្បាស់ហើយមែនពិត ព្រោះដូចដែលពោលហើយ ក្នុងអដ្ឋកថានៃធម្មសង្គហៈដូច្នោះឯង ៕

**ចប់ញាណវត្ថុពួក ២**

# ៣. អដ្ឋកថាតិកនិទ្ទេស

## អធិប្បាយញាណវត្ថុពួក ៣ ចិន្តាមយបញ្ញា

បញ្ញា ដែលព្រះមានព្រះភាគ ត្រាស់ហៅថា **យោគៈ** ក្នុងពាក្យថា **“យោគវិហិតេសុ”** នេះ មានអធិប្បាយថា ក្នុងការចាត់ចែង ដោយបញ្ញា ឈ្មោះថា បង្អោននាំទៅដោយបញ្ញា ។ អាយតនៈ គឺអណ្តូងកើតនៃការងារ ក្នុងពាក្យថា **“កម្មាយតនេសុ”** នេះ ឈ្មោះថា ការងារនោះឯង ។ ម្យ៉ាងទៀត សូម្បីតែពាក្យថា “ការងារនោះផង អាយតនៈនោះផង មានដល់បុគ្គលអ្នកមានអាជីវៈជាដើម” ក៏ឈ្មោះថា **អណ្តូងកើតនៃការងារ** ។ សូម្បីក្នុងពាក្យថា **សិប្បាយតនេសុ** ក៏ន័យនេះដែរ ។

ក្នុងពាក្យទាំងនោះ ការងារមាន ២ យ៉ាង គឺ **ហីនកម្ម និងឧក្កដ្ឋកម្ម** (ប្រភេទអាក្រក់ និងល្អ) ។ ក្នុងពីរយ៉ាងនោះ ការងាររបស់ជាងឈើ ការងាររបស់អ្នកក្រងផ្កាឈើជាដើម ឈ្មោះថា **ហីនកម្ម** (ប្រភេទអាក្រក់) កសិកម្ម ពាណិជ្ជកម្ម គោរក្ខកម្មជាដើម ឈ្មោះថា **ឧក្កដ្ឋកម្ម** (ប្រភេទល្អ) ។

**សូម្បីសិប្បៈ ក៏មាន ២ យ៉ាង គឺ ប្រភេទល្អ និងអាក្រក់ ។**

ក្នុងពីរយ៉ាងនោះ សិប្បៈរបស់ជាងត្បាញឫស្សី សិប្បៈរបស់ជាងកន្ទេល សិប្បៈរបស់ជាងឆ្នាំង សិប្បៈរបស់ជាងស្បែក និងរបស់ជាងកាត់សក់ជាដើម ឈ្មោះថា ប្រភេទអាក្រក់ ។ សិប្បៈដែលប្រើបញ្ញា (មុទ្ទា) សិប្បៈការរាប់ចំនួន (គណនា) សិប្បៈគូស សរសេរ (លេខ) ជាដើម ឈ្មោះថា ប្រភេទល្អ ។ ឋាននៃវិជ្ជា ឈ្មោះថា វិជ្ជាពិតមែន ។ ឋាននៃវិជ្ជានោះត្រូវប្រកបដោយធម៌ ទើបលោកកាន់យក ។ ឯ

ពេទ្យ ឈ្មួញ ដែលមានវិជ្ជាដូចនឹងមន្តគ្រឿងគ្រប់គ្រង គឺធ្វើឱ្យនាគវង្វេងដូចនឹងមន្ត របស់បុគ្គលអ្នកផ្លុំខ្លុយត្រឹមត្រូវ ចក្ខុវិទ្យា សល្យកម្មជាដើម លោកមិនកាន់យក ព្រោះភាពជាសិប្បៈដែលព្រះភគវាត្រាស់ទុកនោះ មិនចូលទៅរួមនៅក្នុងសិប្បៈ ដែលមានពាក្យថា "បពិត្រលោកអាចារ្យ ខ្ញុំប្រាថ្នាដើម្បីសិក្សាសិប្បៈ" [១៦] ៕

## ន័យរបស់ហីនកម្ម

គប្បីជ្រាបក្នុងសេចក្តីនេះថា បុរសអ្នកឈ្លាសម្នាក់ សាងផ្ទះ ប្រាសាទ យាន និងទូកជាដើម ដោយធម្មតារបស់ខ្លួនឯង ដើម្បីត្រូវការរស់នៅជាសុខ របស់មនុស្ស ទាំងឡាយ; ព្រោះថា បុរសអ្នកឈ្លាសនោះ តាំងនៅដោយការធ្វើប្រយោជន៍ដ៏ សមគួរ ដោយគិតថា "មនុស្សទាំងនេះជាទុក្ខ ព្រោះមិនមានទីនៅអាស្រ័យ" ទើបសាងផ្ទះដែលផ្សេងដោយផ្ទះមានខ្នងរំរែង និងបួនជ្រុងជាដើមឡើង នឹងដើម្បី ការពារសេចក្តីរងា និងក្តៅ កសាងប្រាសាទដែលផ្សេងដោយប្រាសាទ មានជាន់ តែមួយ និងជាន់ពីរជាដើម; កាលយានពាហនៈមិនមាន ក៏គិតថា "ឈ្មោះថា ការ សញ្ចរទៅមកជាទុក្ខ" ដើម្បីត្រូវការបន្ទោបង់សេចក្តីឈឺចុកចាប់នឿយហត់ស្មង ជាដើម កសាងពាហនៈជាគ្រឿងនាំទៅ មានរទេះ និងរថជាដើម; កាលទូកមិន មាន ក៏គិតថា "ឈ្មោះថា គ្រឿងសញ្ចរទៅក្នុងសមុទ្រជាដើម មិនមាន" ទើបសាង ទូកមានប្រការផ្សេងៗ ។ បុរសអ្នកឈ្លាសនោះ រមែងមិនឃើញវត្ថុទាំងឡាយនោះ ទាំងអស់ដែលបុគ្គលដទៃធ្វើ; មិនបានរើសយករបស់បុគ្គលដទៃធ្វើហើយមក, រមែង

---

[១៦] វិនយ. ។

មិនបានស្តាប់ពីអ្នកដទៃ, ក៏ប៉ុន្តែថា គេរមែងនឹកធ្វើតាមធម្មតារបស់ខ្លួន ។

ពិតមែន ការងារដែលបុគ្គលអ្នកមានបញ្ញា សូម្បីធ្វើតាមធម្មតារបស់ខ្លួន រមែងដូចនឹងការងារទាំងឡាយ ដែលជនពួកដទៃរៀនមកធ្វើឱ្យសម្រេចនុ៎ះឯង ។ នេះជាន័យក្នុងហីនកម្ម (ការងារដែលទាប) សិន ៕

## នំយរបស់ឧក្កដ្ឋកម្ម

សូម្បីក្នុងឧក្កដ្ឋកម្ម (ការងារដែលខ្ពស់) បណ្ឌិតម្នាក់គិតថា "កាលកសិកម្ម មិនមានជីវិតរបស់មនុស្សទាំងឡាយ រមែងមិនប្រព្រឹត្តទៅ" ដើម្បីត្រូវការឱ្យនៅជាសុខរបស់មនុស្សទាំងឡាយ ទើបសាងឧបករណ៍ធ្វើស្រែ មាននង្គ័ល និងនឹមជាដើម ។ ដោយទំនងនោះ គេរមែងសាងពាណិជ្ជកម្ម និងគោរក្ខកម្មឡើង ។ គេរមែងមិនឃើញការងារទាំងអស់នោះ ដែលបុគ្គលដទៃធ្វើ ។ ល ។ រមែងដូចនឹងការងារដែលបុគ្គលដទៃរៀនមក ធ្វើសម្រេចនោះឯង ។ នេះជាន័យក្នុងឧក្កដ្ឋកម្ម (ការងារដែលខ្ពស់) ៕

## នំយរបស់សិប្បៈនាំង ២ យ៉ាង

ក្នុងអណ្តូងកើតនៃសិប្បៈ សូម្បីទាំងពីរ បណ្ឌិតម្នាក់ប្រាថ្នានឹងឱ្យមនុស្សទាំងឡាយ មានសេចក្តីសុខសប្បាយ ទើបចាត់សាងហីនសិប្បៈ មានសិប្បៈរបស់ ជាងត្បាញឫស្សីជាដើមឡើង និងសាងសិប្បៈខ្ពស់ ពោលគឺដើម្បីឱ្យបានចំនួនខ្ពស់បំផុតនៃហត្ថកម្ម សាងឧបករណ៍រាប់ចំនួន ពោលគឺដើម្បីមិនឱ្យដាច់បរិមាណ សាងគ្រឿងគូសសរសេរ ដែលជាបែបយ៉ាង

ផ្សេងៗ មានប្រឡាយជាដើម ។ បណ្ឌិតនោះ មិនបានឃើញវត្ថុទាំងនោះ សូម្បីទាំងអស់ដែលបុគ្គលដទៃធ្វើ ។ ល ។ រមែងដូចនឹងសិប្បៈដែលបុគ្គលដទៃរៀនមក ហើយធ្វើឱ្យសម្រេចនោះឯង ។ សេចក្តីនេះ ជាន័យក្នុងអណ្តូងកើតនៃសិប្បៈ ។

ម្យ៉ាងទៀត បុគ្គលពួកខ្លះ ញុំាងឋាននៃវិជ្ជាទាំងឡាយ មានមន្តដែលញុំាងនាគឱ្យវង្វេង (ឱ្យវិលទៅ) ជាដើម ឱ្យកើតឡើង ដើម្បីត្រូវការព្យាបាលរោគមនុស្សទាំងឡាយ អ្នកចូលទៅលេង និងអមនុស្សមានពស់ជាដើម ។ បណ្ឌិតនោះរមែងមិនឃើញឋាននៃវិជ្ជាទាំងនោះ ដែលបុគ្គលដទៃធ្វើ មិនបានរៀនឋាននៃវិជ្ជាដែលបុគ្គលដទៃធ្វើហើយ, ទាំងមិនបានស្តាប់ចំពោះបុគ្គលដទៃ, តែថា គេរមែងធ្វើដោយការគិតតាមធម្មតារបស់ខ្លួន ។ ពិតមែន ឋាននៃវិជ្ជានោះ ដែលបុគ្គលអ្នកមានបញ្ញាសូម្បីធ្វើតាមធម្មតារបស់ខ្លួន ក៏រមែងដូចជាបុគ្គលដទៃដែលរៀនមក ធ្វើឱ្យសម្រេចនោះឯង ។

ពាក្យថា “**កម្មស្សកតំ ញាណំ** = កម្មស្សកតាញាណ” បានដល់ ញាណ គឺការដឹងយ៉ាងនេះថា “នេះជាកម្មរបស់សត្វទាំងឡាយ, នេះជាកម្មរបស់ខ្លួន នេះមិនមែនកម្មរបស់ខ្លួន” ។

ពាក្យថា “**សច្ចានុលោមិកំ ញាណំ** = សច្ចានុលោមិកញ្ញាណ” បានដល់ វិបស្សនាញាណ ។

ពិតមែន វិបស្សនាញាណនោះ ព្រះមានព្រះភាគត្រាស់ហៅថា សច្ចានុលោមិកញ្ញាណ ក៏ព្រោះអនុលោមតាមសច្ចៈ ៤ ។

ឥឡូវនេះ ដើម្បីសម្តែងនូវអាការ គឺសេចក្តីប្រព្រឹត្តទៅនៃសច្ចានុលោមិក-

ញ្ញាណ ដែលព្រះមានព្រះភាគត្រាស់ថា **“រូបំ អនិច្ចន្តិ ខោ** = រូបមិនទៀង” ជាដើម នោះ ។ ក៏រូបមានសេចក្ដីមិនទៀងជាលក្ខណៈនោះឯង មកហើយក្នុងពាក្យថា **“រូបំ អនិច្ចំ”** នេះ, មិនមែនមានទុក្ខជាលក្ខណៈ ឬមានអនត្តាជាលក្ខណៈទេ ។ តែគប្បីជ្រាបថា កាលពោលដោយអំណាចនៃអត្ថ (សេចក្ដី) ហើយ សភាវៈទាំងនោះ គប្បីជាយ៉ាងតែមួយ ព្រោះព្រះមានព្រះភាគត្រាស់ថា **“យញ្ហិ អនិច្ចំ, តំ ទុក្ខំ, យំ ទុក្ខំ, តំ អនត្តា** = មែនពិត វត្ថុណាមិនទៀង, វត្ថុនោះជាទុក្ខ; វត្ថុណាជាទុក្ខ, វត្ថុនោះជាអនត្តា” ។

ពាក្យថា **“យំ ឯវរូបី** = យ៉ាងណាដែលមានលក្ខណៈយ៉ាងនោះ” បានដល់ញាណណា ជាសភាវៈដែលព្រះមានព្រះភាគទ្រង់អធិប្បាយទុកផ្នែកមុន (ក្រោយ) យ៉ាងនេះ ញាណនោះ ឈ្មោះថា **អនុលោមិកញ្ញាណ** ។

ពាក្យថា **“ខន្តី”** [១៧] ជាដើម ជាវេវចនៈរបស់បញ្ញានោះឯង ។ ពិតមែនបញ្ញានោះ ឈ្មោះថា **អនុលោមិកៈ** ព្រោះអត្ថថា រមែងអនុលោម (គឺបណ្ដោយតាម) ហេតុដែលជាការធ្វើ ៥ យ៉ាង មានអណ្ដូងកើតនៃការងារជាដើមដែលព្រះមានព្រះភាគត្រាស់ទុកក្នុងកាលមុន ដោយការឃើញនូវធម៌ដែលមិនជាសត្រូវដូច្នេះ ។ មួយវិញទៀត បញ្ញា ឈ្មោះថា **អនុលោមិកៈ** ព្រោះអត្ថថា រមែងអនុលោមតាមប្រយោជន៍នៃសត្វទាំងឡាយដូច្នេះផង, រមែងអនុលោមតាមមគ្គសច្ចដូច្នេះផង, រមែងអនុលោមតាម ព្រោះការអនុលោមតាមព្រះនិព្វានដែលជាបរមត្ថសច្ចដូច្នេះក៏បាន ។

---

[១៧] គឺខន្តិញ្ញាណ ទិដ្ឋិញ្ញាណ រុចិញ្ញាណ មុតិញ្ញាណ បេក្ខញ្ញាណ និងធម្មនិជ្ឈានខន្តិញ្ញាណ ។

ញាណណា រមែងអត់ធន់ រមែងអាចដើម្បីឃើញនូវហេតុជាទីធ្វើ (ការណៈ)[១៨] សូម្បីទាំងអស់នោះ, ព្រោះហេតុនោះ ញាណនោះ ទើបឈ្មោះថា **ខន្តិ** ។ ពាក្យថា **"បស្សតិ"** បានដល់ ទិដ្ឋិញ្ញាណ។ ពាក្យថា **"រោចេតិ"** បានដល់ **រុចិញ្ញាណ**។ ពាក្យថា **"មុច្ចតិ"** បានដល់ **មុតិញ្ញាណ** ។ ព្រះបាលីថា **មុទតីតិ មុទីតិ** ឈ្មោះថា មុទិញ្ញាណដូច្នេះក៏មាន ។ ពាក្យថា **"បេក្ខតិ"** ឈ្មោះថា **បេក្ខញ្ញាណ** ។ ធម៌ទាំង-ឡាយ មានអណ្តូងកើតនៃការងារជាដើម សូម្បីទាំងអស់នោះ រមែងចូលទៅប្រចក្សច្បាស់ដល់ញាណនោះ ទើបឈ្មោះថា **ធម្មនិជ្ឈានខន្តិញ្ញាណ** ។ ម្យ៉ាងទៀត កាលពោលដោយពិសេស ធម៌ទាំងឡាយ ពោលគឺខន្ធ ៥ កាលចូលទៅសម្លឹងពិចារណា រមែងឱ្យប្រចក្សច្បាស់ ដោយអំណាចនៃភាវៈជាវត្ថុ មិនទៀង ជាទុក្ខ ជាអនត្តាញយ។ ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា **ធម្មនិជ្ឈានខន្តិញ្ញាណ** ។

ពាក្យថា **"បរតោ អស្សុត្វា បដិលភតិ** = បុគ្គលមិនបានស្តាប់ពីអ្នកដទៃរមែងបាន...[*]" បានដល់ មិនបានស្តាប់ពាក្យណែនាំរបស់អ្នកដទៃ កាលគិតដោយខ្លួនឯងនោះ រមែងបាន... ។

ពាក្យថា **"អយំ វុច្ចតិ** = នេះ ហៅថា" បានដល់ បញ្ញានេះ ព្រះមាន-ព្រះភាគត្រាស់ហៅថា **ចិន្តាមយបញ្ញា**។

**ក៏ចិន្តាមយបញ្ញានោះ រមែងមិនកើតដល់បុគ្គលពួកណាមួយ, រមែងកើតដល់ព្រះមហាពោធិសត្វទាំងឡាយ អ្នកដឹងក្រៃលែងម្យ៉ាងប៉ុណ្ណោះ;**

---

[១៨] **ការណៈ** គឺកម្ម សិប្បៈ វិជ្ជា កម្មស្សកតាញាណ និងសច្ចានុលោមិកញ្ញាណ ។

[*] ចូរអានក្នុងអភិធម្មបិដកផង ទើបអាចយល់បាន ។

សច្ចានុលោមិកញ្ញាណ សូម្បីក្នុងទីនេះ ក៏រមែងកើតដល់ព្រះពោធិសត្វទាំងពីរ (**ទ្វិន្នំយេវ ពោធិសត្តានំ**) ប៉ុណ្ណោះ ។

បញ្ញាដែលនៅសល់ បណ្ឌិតគប្បីជ្រាបថា រមែងកើតដល់បុគ្គលអ្នកមានបញ្ញាច្រើន សូម្បីទាំងអស់ ដែលមានបារមីពេញហើយ ៕

## អធិប្បាយសុតាមយបញ្ញា

ក្នុងពាក្យថា “**បរតោ សុត្វា បដិលភតិ**” នេះ បណ្ឌិតគប្បីជ្រាបថា បញ្ញាទាំងអស់ដែលបុគ្គលបានហើយ ព្រោះឃើញអណ្តូងកើតនៃការងារជាដើម ដែលបុគ្គលដទៃកំពុងធ្វើ ឬធ្វើស្រេចហើយក្តី ស្តាប់ពាក្យរបស់អ្នកណាៗ អ្នកប្រាប់ក្តី រៀនយកក្នុងសំណាក់អាចារ្យក្តី ឈ្មោះថា បុគ្គលស្តាប់ពីអ្នកដទៃហើយនោះឯង ៕

## អធិប្បាយភាវនាមយបញ្ញា

ពាក្យថា “**សមាបន្នស្ស** = ជាអ្នកចូលសមាបត្តិ” អធិប្បាយថា បញ្ញាក្នុងសមាបត្តិ របស់បុគ្គលអ្នកដល់ព្រមដោយសមាបត្តិ ឈ្មោះថា **ភាវនាមយបញ្ញា** ៕

## អធិប្បាយទានមយបញ្ញា

ពាក្យថា “**ទានំ អារព្ភ** = ប្រារព្ធទាន” បានដល់ អាស្រ័យទាន, អធិប្បាយថា មានចេតនាក្នុងទានជាបច្ច័យ ។ ពាក្យថា “**ទានាធិគច្ឆ** = បុគ្គលអ្នកឱ្យទាន” អធិប្បាយថា បុគ្គលកំពុងបង្អោនចូលទៅឱ្យនូវទាន ឈ្មោះថា អ្នកឱ្យទាន ។ ពាក្យ

ថា **“យា ឧប្បជ្ជតិ** = រមែងកើតឡើង” បានដល់ បញ្ញាណា ដែលសម្បយុត្តដោយចេតនាក្នុងទាន រមែងកើតឡើងយ៉ាងនេះ, បញ្ញានេះ ឈ្មោះថា **ទានមយបញ្ញា** ។ ក៏កាលបុគ្គលគិតថា “យើងនឹងឱ្យទាន” , ក៏ឱ្យទាន, គ្រាឱ្យទានហើយ ក៏ពិចារណានូវទាននោះ ។

**ទានមយបញ្ញានោះ រមែងកើតឡើងដោយអាការ ៣ យ៉ាង គឺ**

**១-បុព្វចេតនា** ចេតនាខាងដើម

**២-មុញ្ចនចេតនា** ចេតនាកំពុងឱ្យ

**៣-អបរចេតនា** ចេតនាខាងក្រោយ ៕

## អធិប្បាយសីលមយបញ្ញា

ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកបញ្ញា ដែលសម្បយុត្តដោយចេតនាក្នុងសីល សូម្បីក្នុងពាក្យថា **“សីលំ អារព្ភ សីលាធិគច្ឆ”** នេះថា **ជាសីលមយបញ្ញា** ។ ក៏កាលគិតថា “យើងនឹងញុំាងសីលឱ្យបរិបូណ៌” ដូច្នេះ ហើយក៏ញុំាងសីលនោះឱ្យបរិបូណ៌ គ្រាញុំាងសីលឱ្យបរិបូណ៌ហើយ ក៏ពិចារណាសីលនោះ សីលមយៈនេះទើបកើតឡើងដោយអាការ ៣ យ៉ាង គឺ បុព្វចេតនា មុញ្ចនចេតនា និងអបរចេតនា ។ សម្រាប់ភាវនាមយបញ្ញា ខ្ញុំពេលទុកហើយក្នុងកាលមុននោះឯង ៕

## អធិប្បាយអធិសីលបញ្ញាជាដើម

ក្នុងអធិសីលបញ្ញាជាដើម បណ្ឌិតគប្បីជ្រាបសីលជាដើម ដោយការប្រព្រឹត្តទៅម្យ៉ាងៗ ២ គឺ សីល, អធិសីល; ចិត្ត, អធិចិត្ត; បញ្ញា និងអធិបញ្ញា ។ ក្នុងពាក្យទាំងនោះ សីល ៥ ក្តី សីល ១០ ក្តី ឈ្មោះថា **សីល** ដោយអំណាចនៃការសង្គ្រោះចូលក្នុងបែបផែននេះថា "ការឧប្បត្តិឡើងនៃព្រះតថាគតទាំងឡាយ ឬមិនទ្រង់ឧប្បត្តិឡើងក៏ដោយ ធាតុ និងធម្មដ្ឋិតិ ធម្មនិយាមទាំងនោះ ក៏តាំងនៅហើយមែនពិត"[១៩] ។ ពិតមែនកាលព្រះតថាគតទ្រង់ឧប្បត្តិឡើងក្តី នៅមិនទ្រង់ឧប្បត្តិឡើងក្តី សីលនោះក៏មាន ។

*សួរថា* កាលព្រះតថាគតទ្រង់មិនទាន់បានឧប្បត្តិឡើង អ្នកណារមែងបញ្ញត្តសីល (គឺរមែងប្រកាសឱ្យដឹង) ? ។

ឆ្លើយថា តាបស បរិព្វាជក សព្វញ្ញូពោធិសត្វ និងព្រះបាទចក្រពត្តិ រមែងបញ្ញត្ត (ប្រកាស) សីល ។

**កាលបើព្រះសម្មាសម្ពុទ្ធទ្រង់ឧប្បត្តិឡើងហើយ ភិក្ខុសង្ឃ ភិក្ខុនីសង្ឃ ឧបាសក និងឧបាសិកា រមែងប្រកាសឱ្យដឹងនូវសីលនោះ ។ ម្យ៉ាងទៀត កាលព្រះតថាគត ទ្រង់ឧប្បត្តិឡើងហើយនុ៎ះឯង បាតិមោក្ខសំវរសីល ដែលជាសីល ក្រៃលែងជាងសីលទាំងអស់ ទើបប្រាកដឡើង, កាលព្រះតថាគតនៅមិនទាន់បានទ្រង់ឧប្បត្តិឡើង បាតិមោក្ខសំវរសីលនោះ ក៏មិនបានប្រាកដ ព្រោះថា ព្រះសព្វញ្ញូពុទ្ធជាម្ចាស់ទាំងឡាយប៉ុណ្ណោះ រមែង**

---

[១៩] សំ. និ., អំ. តិក. ។

បញ្ញត្តថា “ឈ្មោះថា សីលខនេះ រមែងមានព្រោះប្រព្រឹត្តកន្លងក្នុងរឿងនេះ” ។ នេះជាវិស័យរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយប៉ុណ្ណោះ, និងជាកម្លាំងរបស់ព្រះពុទ្ធទាំងឡាយ ដោយប្រការដូច្នេះ ។ បាតិមោក្ខសំវរសីលនេះ ជាអធិសីល ដោយហេតុណា, ព្រោះហេតុនោះ ដើម្បីទ្រង់សម្តែងអធិសីលបញ្ញា ទើបព្រះមានព្រះភាគត្រាស់ថា “**បាតិមោក្ខសំវរំ សំវរន្តស្ស** = បញ្ញាកើតដល់អ្នកសង្រួមដោយបាតិមោក្ខសំវរសីល” ជាដើម។

ម្យ៉ាងវិញទៀត សមាបត្តិ ៨ ដែលជាគ្រឿងដំណើរទៅក្នុងវដ្តៈ ឈ្មោះថាចិត្ត ដោយអំណាចនៃការសង្គ្រោះទុកដោយបែបផែន ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងកាលមុនន៎ុះឯង ។ ពិតមែន ចិត្តដែលប្រព្រឹត្តទៅក្នុងសមាបត្តិទាំង ៨ នោះ កាលព្រះតថាគតទ្រង់ឧប្បត្តិឡើងក៏ដោយ មិនទ្រង់ឧប្បត្តិឡើងក៏ដោយ ចិត្តដូច្នេះ រមែងកើតឡើងបាន ។

*សួរថា* កាលព្រះតថាគត នៅមិនទាន់បានទ្រង់ឧប្បត្តិឡើង អ្នកណាទៅរមែងញ៉ាំងចិត្តដែលប្រព្រឹត្តទៅក្នុងសមាបត្តិទាំងនោះ ឱ្យកើតឡើង ?

ឆ្លើយថា តាបស បរិព្វាជក ព្រះសព្វញ្ញូពោធិសត្វ និងស្តេចចក្រពត្តិរាជ ។

ក៏កាលបើព្រះមានព្រះភាគទ្រង់ឧប្បត្តិឡើងហើយ ជនទាំងឡាយអ្នកប្រាថ្នាគុណវិសេស សូម្បីមានភិក្ខុជាដើម រមែងញ៉ាំងចិត្តដូច្នោះ ឱ្យកើតឡើងបាន ។ តែថា សមាបត្តិ ៨ ដែលជាបាទឱ្យវិបស្សនាដែលក្រៃលែងជាងចិត្តទាំងឡាយ ដែលកើតឡើងនោះ, កាលព្រះតថាគតទ្រង់ឧប្បត្តិហើយប៉ុណ្ណោះទើបមាន, នៅមិនបានទ្រង់ឧប្បត្តិឡើង ចិត្តដូច្នោះមិនបានមានទេ។ ព្រះសព្វញ្ញូពុទ្ធទាំងឡាយប៉ុណ្ណោះ រមែងទ្រង់បញ្ញត្តប្រកាសចិត្តដែលប្រព្រឹត្ត

ទៅក្នុងសមាបត្តិ ៨ ដែលជាបាទនៃវិបស្សនាទាំងនោះទុក; ដោយប្រការដូច្នេះ សមាបត្តិ ៨ ជាអធិចិត្តបាន ព្រោះហេតុណា, ព្រោះហេតុនោះ ដើម្បីនឹងសម្តែងបញ្ញាដែលសម្រេចជាអធិចិត្តនោះ ទើបព្រះមានព្រះភាគត្រាស់ថា **"រូបាវចរារូបាវចរសមាបត្តី សមាបជ្ជន្តស្ស** = បញ្ញាណា... យ៉ាងណា កើតឡើងដល់យោគាវចរបុគ្គល អ្នកចូលរូបាវចរសមាបត្តិ និងអរូបាវចរសមាបត្តិ" ជាដើម ។

ក៏កម្មស្សកតាញាណ ឈ្មោះថា **បញ្ញា** ដោយអំណាចនៃការសង្គ្រោះទុកក្នុងបែបផែនដែលព្រះមានព្រះភាគត្រាស់ហើយ ក្នុងកាលមុននោះឯង ។ ពិតមែនកាលព្រះតថាគតទ្រង់ឧប្បត្តិឡើងហើយក្តី នៅមិនទ្រង់ឧប្បត្តិឡើងក្តី កម្មស្សកតាញាណនោះ ក៏មានបាន; គឺកាលព្រះតថាគតនៅមិនទ្រង់ឧប្បត្តិឡើង កម្មស្សកតាញាណនោះ រមែងកើតឡើង ដោយអំណាចនៃការឱ្យទានរបស់វេលាមព្រាហ្មណ៍ និងរបស់វេស្សន្តរជាដើម ។ កាលព្រះតថាគតទ្រង់ឧប្បត្តិឡើងហើយ ប្រមាណបុគ្គលអ្នកញ៉ាំងមហាទាន ឱ្យប្រព្រឹត្តទៅដោយញាណនោះមិនបានទេ ។

បញ្ញាក្នុងមគ្គ និងផល ជាសភាវៈក្រៃលែងជាងបញ្ញាទាំងអស់, កាលព្រះតថាគតទ្រង់ឧប្បត្តិឡើងហើយប៉ុណ្ណោះ ទើបជាសភាវៈផ្សាយចេញទៅ, កាលនៅមិនបានទ្រង់ឧប្បត្តិឡើង មិនជាដូច្នោះទេ ។ ដោយប្រការដូច្នេះ បញ្ញាក្នុងមគ្គ និងផល ឈ្មោះថា អធិបញ្ញា ព្រោះហេតុណា, ព្រោះហេតុនោះ ដើម្បីសម្តែងនូវបញ្ញាដោយអធិបញ្ញា ទើបត្រាស់ពាក្យថា **"ចតូសុ មគ្គេសុ"** ជាដើម ។

*សួរថា* ក្នុងចំណែកទាំង ៦ នេះ គឺ (សីល, អធិសីល; ចិត្ត, អធិចិត្ត; បញ្ញា,

អធិបញ្ញា) គប្បីមានសោត **វិបស្សនាបញ្ញាអាស្រ័យធម៌អ្វី** ទើបប្រព្រឹត្តទៅ ?

ឆ្លើយថា **អាស្រ័យអធិបញ្ញា** ។

ក្នុងសេចក្ដីនេះ ប្រៀបដូចបុគ្គលហៅអធិឆត្រ និងអធិធ័ជ (ទង់) ដែលមានប្រមាណច្រើន ព្រោះអាស្រ័យឆត្រ ឬធ័ជ (ទង់) ដែលមានប្រមាណតិចយ៉ាងណា, សូម្បីសេចក្ដីនេះ ក៏ដូច្នោះដែរ ឈ្មោះថា **បាតិមោក្ខសំវរសីលដែលជាអធិសីល ក៏ព្រោះអាស្រ័យសីល ៥ និង សីល ១០ ដែលជាខាងដើម** ។

**សមាបត្តិ ៨ ដែលជាបាទឱ្យវិបស្សនាកើតឡើង ឈ្មោះថា អធិចិត្ត ព្រោះអាស្រ័យសមាបត្តិ ៨ ដែលប្រព្រឹត្តទៅក្នុងវដ្តៈ។**

និងគប្បីជ្រាបថា វិបស្សនាបញ្ញា និងបញ្ញាក្នុងមគ្គផល ឈ្មោះថា អធិបញ្ញា ក៏ព្រោះអាស្រ័យកម្មស្សកតាបញ្ញា ៕

## អធិប្បាយអាយកោសល្លជាដើម

ក្នុង **និទ្ទេសនៃអាយកោសល្ល** ជាដើម ពាក្យថា “**អាយោ**” បានដល់ សេចក្ដីចម្រើន, អាយៈ គឺសេចក្ដីចម្រើននោះ មាន ២ យ៉ាង គឺ **អនត្ថហានិ** = ការលះសេចក្ដីវិនាស គឺអកុសលធម៌ និង **អត្ថុប្បត្តិ** ការញ៉ាំងប្រយោជន៍គឺកុសលធម៌ឱ្យ កើតឡើង ។ ពាក្យថា “**អបាយោ**” បានដល់ សេចក្ដីមិនចម្រើន, សូម្បីសេចក្ដីមិន ចម្រើននោះ ក៏មាន ២ យ៉ាង គឺ **អត្ថហានិ** = ការលះវត្ថុដែលជាប្រយោជន៍ គឺកុសលធម៌ និង **អនត្ថុប្បត្តិ** = ការញ៉ាំងវត្ថុមិនជាប្រយោជន៍ គឺអកុសលធម៌ឱ្យកើតឡើង ព្រោះហេតុណា; ព្រោះហេតុនោះ ដើម្បីសម្ដែងនូវសេចក្ដីចម្រើន និងសេចក្ដីមិនចម្រើននោះ ទើបព្រះមានព្រះភាគត្រាស់ថា “**ឥមេ**

**ធម្មេ មនសិករោតោ”** ជាដើម ។

ពាក្យថា **“ឥទំ វុច្ចតិ”** អធិប្បាយថា បញ្ញាយ៉ាងណា ដែលព្រះមានព្រះ-ភាគ ត្រាស់ហៅឈ្មោះថា **អាយកោសល្ល** ក៏ព្រោះប្រព្រឹត្តទៅក្នុងការលះ គឺមិនឱ្យអកុសលធម៌ទាំងនេះកើតឡើង និងព្រោះការតាំងនៅក្នុងការកើតឡើងនៃកុសលធម៌ទាំងឡាយ ក៏ឯបញ្ញានេះឯង ដែលព្រះមានព្រះភាគត្រាស់ថា “នេះ ឈ្មោះថា **អាបាយកោសល្ល”** បញ្ញានោះកាលពិចារណា រមែងដឹងក្នុងការនៅមិនកើតឡើង និងការរលត់ទៅនៃកុសលធម៌ទាំងឡាយ រមែងដឹងក្នុងការកើតឡើង និងការតាំងនៅនៃអកុសលធម៌ទាំងឡាយ ។

***សួរថា*** ភាពជាអ្នកឈ្លាសក្នុង **អាយៈ** គឺសេចក្ដីចម្រើននោះ ចូរលើកទុកសិន, ភាពជាអ្នកឈ្លាសក្នុង **អបាយៈ** គឺសេចក្ដីមិនចម្រើន ឈ្មោះថា បញ្ញានោះកើតឡើងបានយ៉ាងណា ?

ឆ្លើយថា ព្រោះថា កាលបុគ្គលពិចារណាដោយបញ្ញារបស់ខ្លួនយ៉ាងនេះ រមែងដឹងច្បាស់ថា “កុសលធម៌ទាំងឡាយដែលនៅមិនកើតឡើង រមែងមិនកើត, កុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ រមែងរលត់ទៅ; និងរមែងដឹងថា អកុសលធម៌ទាំងឡាយ ដែលនៅមិនទាន់កើតឡើង រមែងកើតឡើង, អកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ រមែងចម្រើន”; បុគ្គលនោះ កាលជ្រាបយ៉ាង-នេះហើយ រមែងមិនឱ្យដើម្បីការកើតឡើងនៃអកុសលធម៌ទាំងឡាយ ដែលនៅមិនកើតឡើង, រមែងលះអកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ; និងរមែងញុំាងកុសលធម៌ដែលនៅមិនកើតឡើង ឱ្យកើតឡើង, រមែងញុំាងកុសលធម៌ដែល

កើតឡើងហើយ ឱ្យដល់សេចក្ដីបរិបូណ៌ ដោយការចម្រើនបញ្ញា ។ សូម្បីភាពជាអ្នកឈ្លាសក្នុងអបាយ ដោយអាការយ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា ជាបញ្ញា ដូចពណ៌នាមកដូច្នេះ ។

ក៏ក្នុងពាក្យថា "**សព្វាបិ តត្រុបាយា បញ្ញា ឧបាយកោសល្លំ** = សូម្បីបញ្ញាទាំងអស់ ដែលជាឧបាយដោះស្រាយក្នុងកិច្ចប្រញាប់ប្រញាល់ ឬភ័យដែលកើតឡើងហើយនោះ ឈ្មោះថា ឧបាយកោសល្ល" នេះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃការដឹងដល់ហេតុក្នុងការកើតឡើងនៃឋាន ដើម្បីដោះស្រាយក្នុងកិច្ចការដែលប្រញាប់ប្រញាល់ ឬភ័យដែលកើតឡើងហើយនោះឯង ។ ពាក្យដែលនៅសល់ក្នុងទីទាំងពួង មានអត្ថងាយស្រួលទាំងអស់នុ៎ះឯង ៕

ចប់ញាណវត្ថុពួក ៣

## ៤. អដ្ឋកថាចតុក្កនិទ្ទេស អធិប្បាយញាណវត្ថុពួក ៤

ក្នុងពាក្យថា "**អត្ថិ ទិន្នំ** = ទានដែលឱ្យហើយមានផល" ជាដើម បណ្ឌិតគប្បីជ្រាបសេចក្ដីដោយឧបាយយ៉ាងនេះថា "**ផលមានព្រោះទានដែលខ្លួនធ្វើហើយជាបច្ច័យ**" ។

ពាក្យថា "**ឥទំ វុច្ចតិ** = នេះហៅថា កម្មស្សកតាញាណ" អធិប្បាយថា "ញាណណារមែងដឹងថា 'នេះជាកម្មរបស់ខ្លួន នេះមិនមែនជាកម្មរបស់ខ្លួន", ញាណនេះ ទើបព្រះមានព្រះភាគត្រាស់ហៅឈ្មោះថា កម្មស្សកតាញាណ ។

បណ្ដាកម្មទាំងពីរ (គឺទាំងរបស់ខ្លួន និងទាំងមិនមែនរបស់ខ្លួន) ÷

**កម្ម គឺកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ មនោទុច្ចរិត ៣ ទាំងនេះ មិនឈ្មោះថា ជាកម្មរបស់ខ្លួន ។**

**សូម្បីសុចរិតកម្មទាំង ១០ យ៉ាង ក្នុងទ្វារទាំង ៣ ឈ្មោះថា ជាកម្មរបស់ខ្លួន ។**

**សូម្បីអកុសលទាំងអស់ នឹងជារបស់ខ្លួន ឬរបស់បុគ្គលដទៃក៏ដោយ មិនឈ្មោះថា ជាកម្មរបស់ខ្លួន ។**

**សួរថា** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះការទម្លាយវត្ថុដែលជាប្រយោជន៍ និងព្រោះមិនឱ្យប្រយោជន៍កើតឡើង ។

គ្រាកាលកុសលអាចដើម្បីញ៉ាំងប្រយោជន៍ (សេចក្តីចម្រើន) ឱ្យកើតឡើងយ៉ាងនេះ ការកំណត់ចំនួនបុគ្គលអ្នកតាំងនៅក្នុងកម្មស្សកតាញាណនោះថា ៖

**កម្មស្សកតាញាណនេះ គឺអ្នកឱ្យទានច្រើនហើយ ញ៉ាំងសីលឱ្យបរិបូណ៌ សមាទានឧបោសថហើយ សោយសេចក្តីសុខ ដោយសេចក្តីសុខ សោយសម្បត្តិ ដោយសម្បត្តិហើយ សម្រេចព្រះនិព្វាន រកប្រមាណមិនបាន ។**

ដូចយ៉ាងថា បុរសមានទ្រព្យញ៉ាំងបុគ្គលឱ្យលើកវត្ថុទាំងឡាយ មានទឹកដោះថ្លា ទឹកឃ្មុំ ទឹកអំពៅជាដើម និងអំបិល ល្ង អង្ករជាដើម ដាក់រទេះ ៥ ធ្វើដំណើរទៅកាន់ផ្លូវកន្តារ (ត្រាច់ទៅក្នុងវដ្ដៈ) កាលសេចក្តីត្រូវការដោយកិច្ច យ៉ាងណាមួយ កើតឡើង គេរមែងមិនគិត, គឺមិនតក់ស្លុត, រមែងធ្វើដំណើរទៅ ដរាបដល់ទីដ៏

ក្បេមនោះ ព្រោះសេចក្ដីដែលឧបករណ៍ទាំងអស់ ជារបស់ដែលគេគ្រប់គ្រងហើយ យ៉ាងណា, សូម្បីបុគ្គលដែលតាំងនៅក្នុងកម្មស្សកតាញ្ញាណនេះ ឱ្យទានយ៉ាងច្រើន ។ល ។ រមែងដំណើរទៅដរាបដល់ព្រះនិព្វាន នឹងរាប់ប្រមាណមិនបានឡើយ ។

ពាក្យថា **“ឋបេត្វា សច្ចានុលោមិកំ ញាណំ** = វៀរសច្ចានុលោមិក-ញ្ញាណ” អធិប្បាយថា វៀរលែងវិបស្សនាញាណដែលមានឈ្មោះថា សច្ចានុលោ-មិកញ្ញាណ ព្រោះការអនុលោមតាមមគ្គសច្ចៈ និងបរមត្ថសច្ចហើយ កុសលបញ្ញា ដែលនៅសល់ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ឈ្មោះថា កម្មស្សកតាញ្ញាណនោះឯង ៕

## អធិប្បាយមគ្គសមង្គិញ្ញាណ

ក្នុងពាក្យថា **“មគ្គសមង្គិស្ស ញាណំ ទុក្ខេបេតំ ញាណំ** = មគ្គសមង្គិ-ញ្ញាណ គឺសេចក្ដីដឹងក្នុងទុក្ខនេះ” បានដល់ មគ្គសច្ចមួយប៉ុណ្ណោះ ដែលព្រះមាន-ព្រះភាគទ្រង់កាន់យកក្នុងឋាន ៤ ដោយអំណាចនៃការចាក់ធ្លុះសច្ចៈមួយ ក្នុង សច្ចៈទាំង ៤ ៕

## អធិប្បាយធម្មញ្ញាណ

ពាក្យថា **“ធម្មេ ញាណំ** = ធម្មញ្ញាណ” នេះ បញ្ញាក្នុងមគ្គ ឈ្មោះថា **ធម្មញ្ញាណ** ដោយអំណាចនៃការចាក់ធ្លុះសច្ចៈមួយ ក្នុងសច្ចៈទាំង ៤ ចូរលើកទុក សិនចុះ, បញ្ញាក្នុងផល ឈ្មោះថា ធម្មញ្ញាណ តើដូចម្ដេច ? បញ្ញាក្នុងផល ឈ្មោះថា ធម្មញ្ញាណបានដោយអំណាចនៃនិរោធសច្ច ។

ពិតមែន សូម្បីបញ្ញាទាំងពីរនោះ (គឺក្នុងមគ្គ និងផល) គប្បីជ្រាបថា ឈ្មោះថា **ធម្មញ្ញាណ** ព្រោះសភាវៈនៃញាណនោះ ប្រព្រឹត្តទៅក្នុងធម៌ គឺអរិយសច្ច ៤ ជាបច្ច័យដទៃទៀត ដែលញ៉ាំងអត្ថឱ្យជាក់ច្បាស់ ដោយកិច្ច និងដោយអារម្មណ៍ ។

ក្នុងពាក្យថា **"សោ ឥមិនា ធម្មេន"** នេះ ព្រះមានព្រះភាគត្រាស់ហៅថា **ធម៌** ដោយវោហារពោលថា ជាគោចរ ព្រោះសភាពនៃមគ្គញ្ញាណទាំងឡាយជាធម្មគោចរ, ម្យ៉ាងទៀត ពាក្យនេះជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ, អធិប្បាយថា ព្រះមានព្រះភាគទ្រង់ដឹងនូវធម៌នេះ, និងទ្រង់អធិប្បាយថា មគ្គញ្ញាណដែលដឹងនូវសច្ចធម៌ ៤ ហើយតាំងនៅ ។

ពាក្យថា **"ទិដ្ឋេន** = ទ្រង់ឃើញហើយ" អធិប្បាយថា ទ្រង់ឃើញ, គឺទ្រង់ឃើញធម៌ ហើយតាំងនៅ ។

ពាក្យថា **"បត្តេន** = ទ្រង់សម្រេចហើយ" គឺសម្រេចនូវធម៌ ព្រោះព្រះអង្គទ្រង់សម្រេចសច្ចៈ ៤ ហើយតាំងនៅ ។

ពាក្យថា **"វិទិតេន** = ទ្រង់ដឹងច្បាស់ហើយ" បានដល់ សច្ចៈ ៤ ជាធម៌ដែលព្រះអង្គដឹងច្បាស់ហើយ ទើបធ្វើឱ្យប្រាកដដោយមគ្គញ្ញាណ, ព្រោះហេតុដូច្នោះ អរិយសច្ច ៤ នោះ ទើបឈ្មោះថា ជាធម៌ដែលព្រះមានព្រះភាគទ្រង់ដឹងច្បាស់ហើយ, ដោយហេតុនោះ ទើបឈ្មោះថា មានធម៌ដែលទ្រង់ដឹងច្បាស់ហើយ ។

ពាក្យថា **"បរិយោគាឡ្ហា** = ទ្រង់ធ្លាក់ដល់ហើយ" បានដល់ ទ្រង់ធ្លាក់ចុះកាន់សច្ចៈទាំង ៤ ហើយតាំងនៅ ។

ពាក្យថា **“នយំ នេតិ** = បញ្ជូនន័យទៅ” បានដល់ ទ្រង់បង្អោនទៅ ទ្រង់នាំទៅ ឈ្មោះថា ទ្រង់បញ្ជូនន័យទៅក្នុងអតីតៈ និងអនាគត ។ម្យ៉ាងទៀត ក្នុងទីនេះជាកិច្ច (នាទី) របស់បច្ចវេក្ខណញ្ញាណ មិនមែនជាកិច្ចរបស់មគ្គញ្ញាណទេ ។ ក៏ន័យ គឺមគ្គញ្ញាណដែលព្រះសាស្តាធ្វើហើយ ឱ្យដូចជាការបង្អោនទៅក្នុងអតីតៈ និងអនាគត ។ ព្រោះហេតុអ្វី ? ព្រោះបច្ចវេក្ខណៈនោះ មានមគ្គជាហេតុ ។ ពិតមែន បច្ចវេក្ខណៈនោះ រមែងមានដល់ព្រះមានព្រះភាគដែលមានមគ្គចម្រើនហើយ; ព្រោះហេតុដូច្នោះ ទើបព្រះសាស្តាទ្រង់ធ្វើន័យ គឺមគ្គញ្ញាណនោះឯង ឱ្យដូចជាការបង្អោនទៅ ។ ន័យម្យ៉ាងវិញទៀត គប្បីជ្រាបអធិប្បាយក្នុងសេចក្តីនេះ យ៉ាងនេះថា ៖

មគ្គញ្ញាណនេះឯង ដែលមានសច្ចៈ ៤ ជាគោចរ ដែលទ្រង់ដឹងហើយ, ព្រោះញាណនេះឯងជាហេតុ ទើបព្រះអង្គទ្រង់បង្អោនទៅនូវន័យ ពោលគឺបច្ចវេក្ខណ-ញ្ញាណក្នុងអតីតៈ និងអនាគត ។

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់បង្អោនទៅនូវន័យដោយញាណនោះ ដោយប្រការណា, ដើម្បីសម្តែងនូវអាការនោះ ទើបត្រាស់ពាក្យថា **“យេហិ កេចិ អតីតមទ្ធានំ”** ជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យថា **“អព្ភញ្ញំសុ** = បានដឹងហើយ” បានដល់ សមណព្រាហ្មណ៍ពួកណាមួយ ចាក់ធ្លុះហើយក្នុងសេចក្តីដឹងទាំង-ឡាយ ។ ពាក្យថា **“ឥមំយេវ** = នេះឯង” បានដល់ សមណព្រាហ្មណ៍ពួកណាមួយ បានដឹងទុក្ខណាក្នុងអតីតៈ និងមិនដឹងច្បាស់ទុក្ខនេះនោះឯង មិនបានមានឡើយ, ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់អធិប្បាយទុកដូច្នេះ ក៏ព្រោះតែអត្ថដូចគ្នា ។ ពិតមែន ព្រះមានព្រះភាគត្រាស់ហើយ សូម្បីក្នុងអតីតៈថា វេរតណ្ហា

ចេញ សមណព្រាហ្មណ៍ទាំងឡាយ ដឹងហើយនូវខន្ធដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នុ៎ះឯង ជាទុក្ខសច្ច, ដឹងហើយនូវសមុទ័យ គឺតណ្ហានុ៎ះឯង, ដឹងហើយនូវនិរោធសច្ច គឺព្រះនិព្វាននុ៎ះឯង, ដឹងហើយនូវមគ្គសច្ច គឺអរិយមគ្គនុ៎ះឯង, សូម្បីក្នុងអនាគត ក៏នឹងចាក់ធ្លុះយ៉ាងនេះមែនពិត, សូម្បីក្នុងបច្ចុប្បន្ន ក៏នឹងចាក់ធ្លុះយ៉ាងនេះឯង ។ ឈ្មោះថា ន័យទាំងឡាយដទៃ ក៏ត្រាស់ទុកហើយដោយអត្ថដូចគ្នាទាំងអស់នោះឯង ។

ពាក្យថា "**ឥទំ វុច្ចតិ អន្វយេ ញាណំ** = នេះហៅថា អន្វញ្ញាណ" នេះ រមែងត្រាស់ថា "នេះញាណជាគ្រឿងនាំទៅ នេះញាណជាគ្រឿងបង្អោនទៅ នេះញាណជាហេតុ" ។

ពាក្យថា "**បរិច្ឆេទញ្ញាណំ**" បានដល់ ញាណជាគ្រឿងកំណត់ចិត្ត ។

ពាក្យថា "**បរសត្តានំ** = របស់សត្វដទៃ" បានដល់ សត្វដ៏សេស វៀរខ្លួនឯងចេញ ។

ពាក្យថា "**បរសត្តានំ**" នេះ ជាវេវចនៈរបស់ពាក្យថា សត្វដែលនៅសល់ ។

ពាក្យថា "**ចេតសា ចេតោ បរិច្ចបជានាតិ** = កំណត់ដឹងចិត្តរបស់សត្វដទៃដោយចិត្ត" អធិប្បាយថា កំណត់ចិត្តរបស់សត្វទាំងឡាយនោះ ដោយចិត្តរបស់ខ្លួន ហើយដឹងដោយប្រការផ្សេងៗ ដោយអំណាចនៃចិត្តមានរាគៈជាដើម ។ ពាក្យណាដែលគប្បីពោលក្នុងបណ្តាពាក្យទាំងនោះថា "ចិត្តមានរាគៈ" ជាដើម, ពាក្យនោះខ្ញុំពោលទុកហើយក្នុងសតិបដ្ឋានវិភង្គ ក្នុងកាលមុនឯណោះ ។

នេះជាសេចក្តីពិសេស ៖

ក្នុងបរិច្ឆញ្ញាណនេះ សូម្បីលោកុត្តរចិត្ត ក៏រមែងបានក្នុងពាក្យថា "**អនុត្តរំ**

**ទរា ចិត្តំ ទិមុត្តំ ទរា ចិត្តំ** = ចិត្តជាអនុត្តរៈ ឬចិត្តរួចផុត” នេះ ។ ពិតមែន ចិត្តរបស់អ្នកដទៃ សូម្បីបញ្ញាមិនបានចូលទៅឃើញ ក៏ឈ្មោះថា ជាវិស័យរបស់ញាណនោះដែរ ។

ពាក្យថា “**អទសេសា បញ្ញា** = បញ្ញាដែលនៅសល់” បានដល់ វៀរបញ្ញា ៣ យ៉ាង មានធម្មញ្ញាណជាដើម (គឺវៀរធម្មញ្ញាណ អន្វយញ្ញាណ និងបរិច្ចញ្ញាណ) ដែលនៅសល់ សូម្បីទាំងអស់ ឈ្មោះថា **ញាណ**, ព្រោះហេតុនោះ ញាណនោះទើបព្រះមានព្រះភាគត្រាស់ហៅថា **សម្មតិញ្ញាណ** ។ ម្យ៉ាងទៀត គប្បីជ្រាបវិចនត្ថៈថា ឈ្មោះថា សម្មតិញ្ញាណ ព្រោះអត្ថថា ដឹងក្នុងសម្មតិ ។

ពាក្យថា “**កាមាវចរកុសលេ បញ្ញា** = បញ្ញាក្នុងកាមាវចរកុសល” អធិប្បាយថា បញ្ញានេះរមែងសន្សំនូវចុតិ និងបដិសន្ធិ ក្នុងវដ្តៈដោយចំណែកតែ-ម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ ទើបបញ្ញានោះ ឈ្មោះថា **អាចយនោ អាចយបញ្ញា** ព្រោះសន្សំដែលរកទីបំផុតមិនបាន ។ តែបញ្ញាក្នុងលោកុត្តរមគ្គ មិនសន្សំនូវចុតិ និងបដិសន្ធិទេ, ដោយហេតុនេះ ទើបត្រាស់ហៅថា “**អបចយនោ អាចយ-បញ្ញា**” ។ បញ្ញាក្នុងរូបាវចរ និងអរូបាវចរ រមែងសន្សំនូវចុតិ និងបដិសន្ធិ, រមែងទម្លាយនូវកិលេសទាំងឡាយ និងធម៌ទាំងឡាយ ដែលមានកិលេសជាមូលផងដោយអំណាចនៃការគ្របសង្កត់ទុក, ដោយហេតុនោះ ទើបពោលទុកថា “**អាចយ-អបចយបញ្ញា** = បញ្ញាដើម្បីសន្សំផង និងដើម្បីមិនសន្សំផង” ។ បញ្ញាដែលនៅសល់ រមែងសន្សំនូវចុតិ និងបដិសន្ធិក៏មិនមែន មិនសន្សំក៏មិនមែន, ដោយហេតុនោះ ទើបត្រាស់ហៅថា “**នេវាចយនោ អបចយបញ្ញា**” ដូច្នេះ ។

ពាក្យថា **“ន ច អភិញ្ញាយោ បដិវិជ្ឈតិ** = តែមិនបានចាក់ធ្លុះអភិញ្ញា” នេះ ត្រាស់សំដៅយកបញ្ញាក្នុងបឋមជ្ឈាន ។ ពិតមែន បញ្ញានោះរមែងប្រព្រឹត្តទៅព្រម ដើម្បីសេចក្ដីនឿយណាយចំពោះកិលេស ព្រោះបឋមជ្ឈាននោះ ជាធម៌ដែលព្រះយោគាវចរ គប្បីពន្លះដោយការស្ងាត់ចាកកាម, ក៏បុគ្គលអ្នកមានរាគៈទៅប្រាសហើយក្នុងកាមទាំងឡាយ រមែងមានដោយបញ្ញាក្នុងបឋមជ្ឈាននោះ, ម្យ៉ាងទៀត បុគ្គលអ្នកប្រាសចាកសេចក្ដីត្រេកអរ ព្រោះមិនមានបឋមជ្ឈាននោះ ឈ្មោះថា ចាក់ធ្លុះនូវអភិញ្ញាទាំង ៥ * ព្រោះមិនបានសម្រេចឈានដែលជាបាទនៃអភិញ្ញា និងឈ្មោះថា មិនចាក់ធ្លុះនូវសច្ចៈទាំងឡាយ ព្រោះបឋមជ្ឈាននោះ មាននិមិត្តជាអារម្មណ៍, ដោយអាការយ៉ាងនេះ បញ្ញានោះ ទើបឈ្មោះថា **រមែងមានដើម្បីសេចក្ដីនឿយណាយចំពោះកិលេសតែម្យ៉ាង រមែងមិនមានដើម្បីការចាក់ធ្លុះសច្ចៈទាំងឡាយ** ។

ពាក្យថា **“សេ្វាទ** = បុគ្គលនោះ... នុ៎ះឯង” បានដល់ បុគ្គលអ្នកសម្រេចបឋមជ្ឈានហើយតាំងនៅ ។ ពាក្យថា **“កាមេសុ វីតរាគោ សមានោ** = អ្នកប្រាសចាកសេចក្ដីត្រេកអរក្នុងកាមទាំងឡាយ” បានដល់ អ្នកមានរាគៈទៅប្រាសហើយ ដោយអំណាចនៃកាមទាំងឡាយ ដែលខ្លួនគ្របសង្កត់ទុកហើយ យ៉ាងនោះនុ៎ះឯង ។ ពាក្យថា **“អភិញ្ញាយោ បដិវិជ្ឈតិ** = ចាក់ធ្លុះអភិញ្ញា” នេះ ព្រះមានព្រះភាគត្រាស់សំដៅយកបញ្ញាក្នុងចតុត្ថជ្ឈាន; ពិតមែន បញ្ញាក្នុងចតុត្ថជ្ឈានរមែង

---

* **អភិញ្ញាទាំង ៥** គឺ ១. ឥទ្ធិវិធិញ្ញាណ, ២. ទិព្វសោតធាតុញ្ញាណ, ៣. ចេតោបរិយញ្ញាណ, ៤. បុព្វេនិវាសានុស្សតិញ្ញាណ, ៥. ចុតូបបាតញ្ញាណ ។

ចាក់ធ្លុះអភិញ្ញា ៥; ព្រោះជាបាទនៃអភិញ្ញាខ្លះ, រមែងចាក់ធ្លុះយ៉ាងនោះឯង ព្រោះសម្រេចអភិញ្ញាខ្លះ, ព្រោះហេតុដូច្នោះ បញ្ញានោះរមែងមានដើម្បីការចាក់ធ្លុះ, តែមិនមានដើម្បីសេចក្ដីនឿយណាយ ក៏ព្រោះបញ្ញាក្នុងបឋមជ្ឈានប៉ុណ្ណោះ ជាធម៌ដើម្បីសេចក្ដីនឿយណាយ សូម្បីក្នុងកិលេសទាំងឡាយ ។

សួរថា បញ្ញាក្នុងទុតិយជ្ឈាន និងតតិយជ្ឈានឯណា, បញ្ញានោះឯង រមែងសេពចំណែកណា (សំដៅសេចក្ដីថា បញ្ញាក្នុងឈានទាំងពីរនោះ ព្រះមានព្រះភាគមិនបានត្រាស់ទុក, កាលបើដូច្នេះ នឹងសង្គ្រោះក្នុងឈានទី ១ ឬទី ៤) ?

ឆ្លើយថា បញ្ញាក្នុងទុតិយជ្ឈាន និងតតិយជ្ឈាន រមែងសេព (គឺចាត់ចូលក្នុងប្រភេទបឋមជ្ឈាន) ដោយអំណាចនៃសោមនស្ស ក៏បាន, និងរមែងសេពចតុត្ថជ្ឈានដោយអំណាចនៃការមិនមានវិតក្កៈ ក៏បាន; បញ្ញាក្នុងទុតិយជ្ឈាន និងតតិយជ្ឈាននោះ បណ្ឌិតគប្បីធ្វើអធិប្បាយឱ្យជាបញ្ញា ព្រោះអាស្រ័យបឋមជ្ឈាន ឬថា អាស្រ័យចតុត្ថជ្ឈាន ដោយអាការយ៉ាងនេះ ។

ពាក្យថា **“និព្វិទាយ ចេវ បដិវេធាយ ច** = ព្រោះសេចក្ដីនឿយណាយនិងព្រោះការចាក់ធ្លុះ” បានដល់ មគ្គបញ្ញារមែងកើតការនឿយណាយ ព្រោះសេចក្ដីនឿយណាយក្នុងវដ្ដៈសូម្បីទាំងអស់ និងដោយការចាក់ធ្លុះ ព្រោះការចាក់ធ្លុះនូវអភិញ្ញា ៦ ៕

## អធិប្បាយហានភាគិនីបញ្ញាជាដើម

ក្នុងពាក្យថា **“បឋមស្ស ឈានស្ស លាភី** = ព្រះយោគាវចរអ្នកបាន

បឋមជ្ឈាន” ជាដើម អធិប្បាយថា បុគ្គលនេះណា បានបឋមជ្ឈានដែលមានគុណដ៏តិច, សញ្ញាមនសិការជាធម៌សហគតៈដោយអំណាចនៃអារម្មណ៍ រមែងប្រាកដ រមែងជំទាស់ រមែងរុកកួន (បៀតបៀន) ព្រះយោគាវចរ ឱ្យសាបសូន្យចាកឈាននោះ; ព្រោះហេតុនោះ បញ្ញាក្នុងបឋមជ្ឈាននោះ ទើបសាបសូន្យជុំវិញដោយអំណាចនៃសញ្ញាមនសិការ បង្អោនចូលទៅសំឡឹងនូវកាមរបស់បុគ្គលនោះ; ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់បញ្ញានោះថា **“ហានភាគិនី”** ។

ពាក្យថា **“តទនុធម្មតា** = សមគួរដល់ធម៌នោះ” បានដល់ ជាសភាវៈសមគួរដល់បញ្ញានោះ ។ ពាក្យថា **“សតិ សន្តិដ្ឋតិ** = សតិ... រមែងតាំងមាំ” នេះ ព្រះមានព្រះភាគត្រាស់សំដៅយកមិច្ឆាសតិ, មិនបានសំដៅយកសម្មាសតិ ។ ពិតមែន សភាពអនុរូបនៃបឋមជ្ឈានដែលមិនគួរត្រេកអរ ក៏ត្រេកអរ ព្រោះឃើញបឋមជ្ឈានដោយជាធម៌ស្ងប់ហើយ ប្រណីតហើយ, សេចក្តីប្រាថ្នា (តណ្ហា) រមែងកើតឡើងដល់បុគ្គលណា, បញ្ញាក្នុងបឋមជ្ឈានរបស់បុគ្គលនោះ រមែងមិនសាបសូន្យ, និងរមែងមិនចម្រើនដោយអំណាចនៃសេចក្តីប្រាថ្នា (និកន្តិ), រមែងជាបញ្ញាដែលមានចំណែកនៃការតាំងនៅ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ហៅបញ្ញានោះថា **“ឋិតិភាគិនី”** ។

ពាក្យថា **“អវិតក្កសហគតា** = សហគតៈដោយឈានដែលមិនមានវិតក្កៈ” បានដល់ ឈ្មោះថា សហគតៈដោយឈាន ដែលមិនមានវិតក្កៈ ព្រោះមនសិការទុតិយជ្ឈានដែលមិនមានវិតក្កៈ ដោយអំណាចនៃអារម្មណ៍ ដែលស្ងប់ប្រណីត ។ ពាក្យថា **“សមុទាចរន្តិ”** បានដល់ រមែងរុកកួន រមែងដាស់តឿននូវព្រះ

យោគាវចរ អ្នកចេញចាកបឋមជ្ឈានដែលស្ទាត់នោះ ដើម្បីត្រូវការសម្រេចទុតិយ-ជ្ឈាន, អធិប្បាយថា បញ្ញាក្នុងបឋមជ្ឈាននោះ ព្រះមានព្រះភាគត្រាស់ហៅថា **វិសេសភាគិនី** ព្រោះជាឋាន គឺការកើតឡើងនៃទុតិយជ្ឈានដែលជារបស់វិសេស ដោយអំណាចនៃសញ្ញាមនសិការទាំងឡាយ ដែលចូលទៅសំឡឹងនូវទុតិយជ្ឈាន ដែលមានក្នុងខាងលើនៃបឋមជ្ឈាននោះ ។

ពាក្យថា **"និព្វិទាសហគតា** = សហគតៈដោយនិព្វិទាញាណ" បានដល់ បុគ្គលអ្នកបានបឋមជ្ឈាននោះ ចេញចាកឈានហើយ សហគតៈដោយវិបស្សនា-ញាណ ពោលគឺនិព្វិទា; ពិតមែន គ្រាកាលបែកធ្លាយទៅនៃអង្គរបស់ឈានដែលកំពុងប្រព្រឹត្តទៅ វិបស្សនាញាណរមែងនឿយណាយ រមែងធុញទ្រាន់; ព្រោះហេតុដូច្នោះ ទើបត្រាស់ហៅថា "និព្វិទាញាណ" ។ ពាក្យថា **"សមុទាចរន្តិ"** បានដល់ រមែងក្តៅក្រហាយ រមែងរុករកួន ដើម្បីសេចក្តីត្រូវការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ពាក្យថា **"វិរាគូបសញ្ហិតា** = ប្រកបដោយវិរាគៈ" បានដល់ ប្រ-កបដោយព្រះនិព្វាន ពោលគឺវិរាគៈ; ពិតមែន វិបស្សនាញាណដែលមគ្គនេះ អាចធ្វើឱ្យច្បាស់នូវព្រះនិព្វាន គឺវិរាគៈ ព្រោះហេតុដូច្នោះ ទើបត្រាស់ហៅថា "ប្រកបដោយវិរាគៈ" ព្រោះប្រព្រឹត្តទៅ ។ សូម្បីសញ្ញាមនសិការដែលសម្បយុត្តដោយវិរាគៈនោះ ក៏ឈ្មោះថា ប្រកបដោយវិរាគៈនុ៎ះឯង ដោយអំណាចនៃសញ្ញាមនសិការទាំងឡាយរបស់វិបស្សនានោះ បឋមជ្ឈានបញ្ញានុ៎ះ ព្រះមានព្រះភាគត្រាស់ហៅថា **និព្វេធភាគិនី** ព្រោះជាបទដ្ឋាន (គឺជាហេតុកើតឡើង) នៃការចាក់ធ្លុះនូវអរិយ-សច្ច; បឋមជ្ឈានបញ្ញានុ៎ះឯង ព្រះមានបុណ្យត្រាស់ហើយក្នុងឋានទាំង ៤ ដោយ

ប្រការដូច្នេះ ។ សូម្បីបញ្ញាក្នុងទុតិយជ្ឈានជាដើម បណ្ឌិតគប្បីជ្រាបសេចក្ដីដោយន័យនេះឯង ៕

## អធិប្បាយបដិបទានៃបញ្ញា ៤

ពាក្យថា **“កិច្ឆេន កសិរេន សមាធឹ ឧប្បាទេន្តស្ស** = អ្នកញុំាងសមាធិឱ្យកើតឡើងដោយលំបាកលំបិន” បានដល់ អ្នកញុំាងលោកុត្តរសមាធិឱ្យកើតឡើងដោយលំបាកលំបិន ដោយសម្បយោគដែលប្រព្រឹត្តទៅជាមួយនឹងសង្ខារ យ៉ាងយ៉ាប់លំបាក ជាទុក្ខ គឺថា គ្របសង្កត់កិលេសទាំងឡាយហើយមកដល់បានដោយយ៉ាប់លំបាកជាទុក្ខ ក្នុងកាលដែលចូលដល់បុព្វភាគ ។ ពាក្យថា **“ទន្ធំ តណ្ឋានំ អភិជានន្តស្ស** = ដឹងឋាននោះក៏យូរ” អធិប្បាយថា ក្នុងការអាស្រ័យវិបស្សនាក្នុងកិលេសទាំងឡាយ ដែលខ្លួនគ្របសង្កត់ទុកហើយអស់កាលយូរ ទើបដឹង ទើបសម្រេចដល់ឋាន ពោលគឺលោកុត្តរសមាធិនោះយូរប្រព្រឹត្តទៅបន្តិចៗ ។ ពាក្យថា **“អយំ វុច្ចតិ** = នេះហៅថា” បានដល់ បញ្ញានេះឯង រមែងកើតឡើងដោយអាការយ៉ាងនេះ, គឺបញ្ញានេះ សូម្បីកើតឡើងហើយក្នុងខណៈនៃចិត្តមួយដួង ក្នុងកាលនៃមគ្គ ព្រោះបដិបទាដែលគ្របសង្កត់កិលេសបានដោយលំបាក និងព្រោះបញ្ញាដែលអាស្រ័យនៅក្នុងវិបស្សនាដំណើរទៅយូរ ទើបព្រះមានព្រះភាគត្រាស់ហៅថា **“ទុក្ខាបដិបទា ទន្ធាភិញ្ញា** = បដិបត្តិលំបាក ត្រាស់ដឹងបានយឺត (ដោយអំណាចនៃការសម្រេច)” ; សូម្បីក្នុងបទទាំងបីខាងមុខ បណ្ឌិតគប្បីជ្រាបសេចក្ដីដោយន័យនេះចុះ ៕

## អធិប្បាយអារម្មណ៍នៃបញ្ញា ៤

ពាក្យថា "**សមាធិស្ស ន និកាមលាភិស្ស** = ព្រះយោគាវចរដែលបានសមាធិមិនស្ទាត់ជំនាញ" បានដល់ ព្រះយោគាវចរណា មិនបានសមាធិតាមសេចក្ដីត្រូវការ, ព្រះយោគាវចរនោះ ឈ្មោះថា បានសមាធិនោះ នៅមិនស្ទាត់ជំនាញ ។ អធិប្បាយថា សមាធិរបស់បុគ្គលណា មិនជាបច្ច័យដើម្បីសេចក្ដីព្យាយាម គឺដើម្បីប្រយោជន៍ក្នុងការចូលសមាធិខាងលើៗ, សមាធិរបស់បុគ្គលនោះ មានប្រក្រតីក្នុងឈានដែលមានគុណតិច ។ ពាក្យថា "**អារម្មណំ ថោកំ ផរន្តស្ស** = ផ្សាយអារម្មណ៍ទៅបន្តិចបន្តួច" អធិប្បាយថា អារម្មណ៍នោះ ឈ្មោះថា មិនចម្រើនហើយ ព្រោះធ្វើបរិកម្មក្នុងបរិត្តារម្មណ៍ មានប្រមាណប៉ុនចង្អេរ ឬថាស ជាប្រមាណ (សំដៅដល់និមិត្ត) ហើយសម្រេច អប្បនាក្នុងអារម្មណ៍នោះៗ ឯង ទើបឈ្មោះថា ផ្សាយអារម្មណ៍ទៅបន្តិចបន្តួច ។ ក្នុងបទទាំងឡាយដែលនៅសល់ ក៏ន័យនេះដែរ ។ ពិតមែន ព្រះយោគាវចរអ្នកបានឈានដែលស្ទាត់ជំនាញ ព្រះភគវាត្រាស់ថា ឈ្មោះថា អ្នកបានសមាធិដែលស្ទាត់ជំនាញហើយ ព្រោះជាបដិបក្ខចំពោះបុគ្គលអ្នកបានសមាធិដែលមិនស្ទាត់ជំនាញ។ ក៏ពាក្យថា "ផ្សាយអារម្មណ៍ទៅរកប្រមាណមិនបាន" ព្រះសយម្ភូត្រាស់ទុកដោយឋាន ជាបដិបក្ខចំពោះការផ្សាយអារម្មណ៍បន្តិចបន្តួច ។ ពាក្យដែលនៅសល់ មានន័យដូចដែលពោលហើយនុ៎ះដែរ ៕

## អធិប្បាយមគ្គសមង្គិញ្ញាណជាដើម

ពាក្យថា "**ជរាមរណេ បេតំ ញាណំ** = ញាណសូម្បីក្នុងជរា និងមរណៈ

នេះ” ព្រះភគវាត្រាស់ទុកដោយអំណាចនៃការចាក់ធ្លុះនូវសច្ចៈទាំង ៤ តែម្យ៉ាង ព្រោះធ្វើព្រះនិព្វាននោះឯង ឱ្យជាអារម្មណ៍ ។ ក៏ពាក្យថា **“ជរាមរណំ អារព្ភ** = ប្រារព្ធជរា និងមរណៈ” ជាដើម ព្រះសម្ពុទ្ធត្រាស់ដោយអំណាចនៃការកំណត់សច្ចៈក្នុងបុព្វភាគ ក្នុងវេលាដែលប្រារព្ធវត្ថុ (វត្ថុសច្ចៈ) មួយៗ ហើយប្រព្រឹត្តទៅ ។ ពាក្យដែលនៅសល់ក្នុងបទទាំងពួង មានអត្ថងាយស្រួលទាំងអស់ ៕

**ចប់ញាណវត្ថុពួក ៤**

## ៥. អដ្ឋកថាបញ្ចកនិទ្ទេស អធិប្បាយញាណវត្ថុពួក ៥

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា “បញ្ញាដែលផ្សាយបីតិទៅ” ជាដើម ៖

បញ្ញាណាកើតឡើង ផ្សាយទៅនូវបីតិ ព្រោះហេតុនោះ បញ្ញាក្នុងឈានទាំងពីរនោះ ទើបឈ្មោះថា ផ្សាយបីតិទៅ; បញ្ញាណាកើតឡើង ផ្សាយទៅនូវសេចក្ដីសុខ ព្រោះហេតុនោះ បញ្ញាក្នុងឈានទាំង ៣ នោះ ទើបឈ្មោះថា ផ្សាយទៅនូវសេចក្ដីសុខ ។ បញ្ញាណាកើតឡើង ផ្សាយចិត្តទៅកាន់បុគ្គលដទៃ ព្រោះហេតុនោះ បញ្ញាកំណត់ចិត្ត បុគ្គលដទៃនោះ ទើបឈ្មោះថា ផ្សាយទៅនូវចិត្ត ។ បញ្ញាណាកើតឡើង ផ្សាយទៅនូវអាលោក គឺពន្លឺ ព្រោះហេតុនោះ បញ្ញាដែលជាទិព្វចក្ខុនោះ ទើបឈ្មោះថា ផ្សាយពន្លឺទៅ ។ បច្ចវេក្ខណញ្ញាណ ឈ្មោះថា បច្ចវេក្ខណនិមិត្ត ។ ពាក្យថា **“បញ្ញា បីតិ ផរណតា”** ជាដើម ក្នុងឈានទាំង ២ ព្រះមានព្រះភាគត្រាស់ទុកដោយពាក្យដូចដែលពោលហើយនេះដែរ ។

ក៏ក្នុងពាក្យទាំងនោះ ការផ្សាយបីតិទៅ ការផ្សាយសេចក្ដីសុខទៅ ដូចជា

ជើងទាំងពីរ, ការផ្សាយចិត្តទៅ ការផ្សាយអាលោក គឺពន្លឺទៅ ដូចជាដៃទាំងពីរ, ឈានដែលជាបាទនៃអភិញ្ញា ដូចជាកាយត្រង់កណ្ដាល, បច្ចវេក្ខណនិមិត្ត ដូចក្បាល, ព្រោះហេតុនោះ ទើបព្រះភគវាទ្រង់សម្ដែងសម្មាសមាធិមានអង្គ ៥ ដូចបុរសអ្នកដល់ព្រមហើយ ដោយចំណែកប្រកបនៃរាងកាយ (គឺអវយវៈតូចធំ) ដោយប្រការ-ដូច្នេះ ។ ពាក្យថា "**អយំ បញ្ចង្គិកោ សម្មាសមាធិ** = នេះហៅថា សម្មាសមាធិមានអង្គ ៥" អធិប្បាយថា ព្រះមានព្រះភាគត្រាស់សម្មាសមាធិ នៃឈានដែលជាបាទថា "ព្រះយោគាវចរនេះ ប្រកបហើយដោយអង្គ ៥ ដូចជាដៃ ជើង និងក្បាលថា ជាសម្មាសមាធិ" ៕

## អធិប្បាយសម្មាសមាធិមានឈាន ៥

សមាធិក្នុងអរហត្តផល ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុងពាក្យថា "**អយំ សមាធិ បច្ចុប្បន្នសុខោ ចេវ** = សមាធិនេះ មានសុខក្នុងបច្ចុប្បន្នផង" ជាដើម; ក៏សមាធិនោះ ឈ្មោះថា មានសុខជាបច្ចុប្បន្ន ព្រោះជាសុខក្នុងខណៈនៃសមាធិនោះ ពិតប្រាកដហើយៗ; សមាធិដែលកើតឡើងមុនៗ ជាបច្ច័យដល់សមាធិដែលកើតឡើងក្រោយៗ ទើបឈ្មោះថា មានសុខជាវិបាកតទៅ ព្រោះសុខនោះជាបច្ច័យ ។ សមាធិនោះ រមែងញ៉ាំងផលចិត្តដ៏ស្ងប់ ដ៏សុខុម ដ៏ប្រណីត ដែលជាមធុរូប (រូបដែលល្អ) ឱ្យតាំងឡើង ។

ពិតមែន កាលបុគ្គលចេញចាកផលសមាបត្តិហើយ កាយវិញ្ញាណដែលសហគតៈដោយសេចក្ដីសុខ អាស្រ័យផោដ្ឋព្វៈ មានសមុដ្ឋានជាសុខ ដែលចូលដល់

កាយទាំងពួង រមែងកើតឡើង ឈ្មោះថា មានសុខជាវិបាកតទៅ សូម្បីដោយបរិ-យាយនេះ ។ សមាធិនេះ ឈ្មោះថា អរិយៈ (ឆ្ងាយ) ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ។ ឈ្មោះថា រកអាមិសមិនបាន ព្រោះមិនមាននិមិត្ត គឺកាមាមិស វដ្ដាមិស និងលោកាមិស ។ ឈ្មោះថា បុរសអ្នកមានបញ្ញាទន់ខ្សោយសេពមិន បាន ព្រោះមហាបុរសទាំងឡាយមានព្រះពុទ្ធជាម្ចាស់ជាដើម សេពហើយ ។ ឈ្មោះ ថា ស្ងប់ហើយ ព្រោះស្ងប់ចាកអង្គ (គឺចំណែកប្រកប ឬហេតុ) ព្រោះស្ងប់ចាកអារម្មណ៍ ព្រោះស្ងប់ហើយចាកសេចក្ដីក្រវល់ក្រវាយចាកកិលេសទាំងពួង; ឈ្មោះថា ប្រណីត ព្រោះអត្ថថា មិនក្ដៅក្រហាយ ។ ឈ្មោះថា បានសេចក្ដីស្ងប់រម្ងាប់ ព្រោះបានការស្ងប់កិលេស ឬថា ព្រោះភាវៈ គឺការស្ងប់រម្ងាប់ចាកកិលេសដែលខ្លួនបានហើយ ។ ពិតមែន ពាក្យថា "សេចក្ដីស្ងប់រម្ងាប់ ឈ្មោះថា **បដិបស្សទ្ធិ**" នេះ រមែងបានឈ្មោះថា ជាធម៌ឯកដោយអត្ថ ។ម្យ៉ាងទៀត ឈ្មោះថា បានសេចក្ដីស្ងប់រម្ងាប់ សូម្បីព្រោះភាពជាព្រះអរហន្តដែលខ្លួនបានហើយ និងព្រោះកិលេសស្ងប់រម្ងាប់ទៅហើយ ។ ឈ្មោះថា សម្រេចហើយដោយធម៌ឯកផុសឡើង ព្រោះខ្លួនសម្រេចហើយ ដោយសេចក្ដីជាធម៌ពិតប្រាកដ ឬព្រោះការសម្រេចហើយនូវភាពជាសមាធិ ។ ឈ្មោះថា មិនបានសម្រេចដោយការគ្របសង្កត់នីវរណៈ ហាមកិលេសដែលជាសសង្ខារិក ព្រោះសមាធិនោះ មិនបានគ្របសង្កត់នូវបច្ចនីកធម៌ (ធម៌ដែលជាសត្រូវ) ហើយទើបសម្រេច ដូចសមាធិដែលប្រព្រឹត្តទៅជាមួយនឹងអាសវៈដែលមានគុណដ៏តិច ។ ក៏កាលព្រះយោគាវចរចូលសមាធិនោះ (សម្មា-សមាធិ) ឬថា ចេញចាកសមាធិនោះ រមែងជាអ្នកមានសតិចូលសមាធិ និងមាន

សតិចេញចាកសមាធិ ។ ម្យ៉ាងទៀត មានសតិរមែងចូលសមាធិ និងមានសតិរមែងចេញចាកសមាធិ ដោយអំណាចនៃកាលតាមដែលកំណត់ទុកបាន; ព្រោះហេតុដូច្នោះ ក្នុងសេចក្ដីនេះ ញាណណាដែលមិនមានវត្ថុដទៃជារបស់ចំពោះខ្លួនប៉ុណ្ណោះ រមែងកើតដល់អ្នកពិចារណាយ៉ាងនេះថា "សមាធិនេះ មានសេចក្ដីសុខក្នុងបច្ចុប្បន្នផង មានសេចក្ដីសុខជាវិបាកតទៅទៀតផង" , នេះជាអង្គ ១ (ក្នុងបណ្ដាអង្គទាំង ៥); សូម្បីក្នុងអង្គដែលនៅសល់ ក៏មានន័យដូចគ្នានេះដែរ ។ សមាធិនេះឈ្មោះថា សម្មាសមាធិ ប្រកបដោយឈាន ៥ ដែលព្រះមានជោគត្រាស់ហើយដោយបច្ចវេក្ខណញ្ញាណទាំង ៥ នេះ ដោយប្រការដូច្នេះឯង ៕

**ចប់ញាណវត្ថុពួក ៥**

## ៦. អដ្ឋកថាឆក្កនិទ្ទេស អធិប្បាយញាណវត្ថុពួក ៦

ពាក្យថា "**ឥទ្ធិវិធេ ញាណំ** = ឥទ្ធិវិធិញ្ញាណ" បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា ញាណក្នុងការសម្ដែងឫទ្ធិ ដែលប្រព្រឹត្តទៅដោយន័យថា "សូម្បីបុគ្គលតែម្នាក់ ធ្វើឱ្យទៅជាបុគ្គលច្រើននាក់បាន"[២០] ដូច្នេះជាដើម ។ រូបាវចរទាំងឡាយ ដែលសហគតៈដោយឧបេក្ខាដែលមិនមានវិតក្កៈ និងវិចារៈ ជាបញ្ញាក្នុងអប្បនាដែលមានខណៈនៃចិត្តមួយដួង ដែលសម្រេចនូវភាពជាបុគ្គលច្រើននោះឯង ព្រះមានព្រះភាគត្រាស់ទុកដោយព្រះតម្រាស់ថា "**ឥទ្ធិវិធេ ញាណំ**" ។

---

[២០] ទី. សី., ខុ. បដិ. ។

ពាក្យថា **"សោតធាតុវិសុទ្ធិយា ញាណំ** = សោតធាតុវិសុទ្ធិញ្ញាណ" បានដល់ ញាណក្នុងទិព្វសោតធាតុ ដែលមានសំឡេងឆ្ងាយ និងជិតជាអារម្មណ៍; អធិប្បាយថា រូបាវចរដែលសហគតៈដោយឧបេក្ខា មិនមានវិតក្កៈ និងវិចារៈ ចាត់ជាបញ្ញាតែម្តង ដែលមានខណៈនៃចិត្តមួយ សូម្បីមានសំឡេងកន្លងវិស័យនៃសោត-ធាតុធម្មតាជាអារម្មណ៍ ព្រះភគវាត្រាស់ទុកដោយព្រះតម្រាស់ថា **"សោតធាតុ-វិសុទ្ធិយា ញាណំ"** ។

ពាក្យថា **"បរចិត្តេ ញាណំ** = បរចិត្តញ្ញាណ" បានដល់ ញាណក្នុងការកំណត់ចិត្តរបស់សត្វដទៃ; អធិប្បាយថា បញ្ញាក្នុងអប្បនាតែម្យ៉ាង ដែលជាខណៈនៃចិត្តមួយ មានចិត្តប្រកបដោយរាគៈជាដើម របស់សត្វដទៃជាអារម្មណ៍ មានប្រការតាមដែលពោលហើយ ព្រះមានជោគត្រាស់ទុក សូម្បីដោយព្រះតម្រាស់នេះថា **"បរចិត្តេ ញាណំ"** ។

ពាក្យថា **"បុព្វេនិវាសានុស្សតិញ្ញាណំ"** បានដល់ ញាណដែលសម្បយុត្តដោយការតាមរឭកដល់ខន្ធដែលធ្លាប់អាស្រ័យក្នុងកាលមុន; អធិប្បាយថា បញ្ញាក្នុងអប្បនាតែម្យ៉ាង ដែលជាខណៈនៃចិត្តមួយដួង សម្បយុត្តដោយសតិជាគ្រឿងតាមរឭកដល់ខន្ធដែលធ្លាប់អាស្រ័យហើយក្នុងកាលមុន មានប្រការតាមដែលពោលហើយ ។ ព្រះសម្ពុទ្ធត្រាស់ទុក សូម្បីដោយព្រះតម្រាស់នេះថា **"បុព្វេនិវាសា-នុស្សតិញ្ញាណំ"** ។

ពាក្យថា **"សត្តានំ ចុតូបបាតេ ញាណំ"** បានដល់ ញាណក្នុងកាលចុតិ

និងក្នុងកាលឧប្បត្តិរបស់សត្វទាំងឡាយ; អធិប្បាយថា បញ្ញាក្នុងអប្បនាតែម្យ៉ាង ដែលជាខណៈនៃចិត្តមួយ មានវណ្ណធាតុរបស់សត្វទាំងឡាយ ដែលស្លាប់ និងកើត ជាអារម្មណ៍ មានប្រការតាមដែលពោលហើយ; ព្រះមានព្រះភាគត្រាស់ទុក សូម្បី

ដោយព្រះតម្រាស់នេះថា **"សត្តានំ ចុតូបបាតេ ញាណំ"** ។

ពាក្យថា **"អាសវានំ ខយេ ញាណំ** = អាសវក្ខយញ្ញាណ" បានដល់ ញាណ ជាគ្រឿងកំណត់ដឹងសច្ចៈ; ក៏ញាណនេះប៉ុណ្ណោះជាលោកុត្តរ, ញាណទាំង ៥ ដែលនៅសល់ ជាលោកិយប៉ុណ្ណោះ ៕

**ចប់ញាណវត្ថុពួក ៦**

## ៧. អដ្ឋកថាសត្តកនិទ្ទេស អធិប្បាយញាណវត្ថុពួក ៧

ព្រះសាស្តាត្រាស់នូវបច្ចវេក្ខណញ្ញាណ ដែលផ្សេងដោយកាល ៣ ក្នុងអង្គ នៃបដិច្ចសមុប្បាទ ១១ ទុកតែអង្គមួយ ដោយអំណាចនៃសេចក្តីប្រព្រឹត្តទៅ និង មិនប្រព្រឹត្តទៅ ដោយន័យថា **"ជាតិប្បច្ចយា ជរាមរណំ"** ជាដើម ហើយក៏ត្រាស់ ញាណយ៉ាងណានោះ ដោយសង្ខេបយ៉ាងនេះថា "ការដឹងថា ធម្មដ្ឋិតិញ្ញាណរបស់ បុគ្គលនោះ" ដូច្នេះទៀត ដោយប្រការទាំងឡាយ មានការអស់ទៅជាធម្មតាជា ដើម ។ បណ្តាញាណទាំងនោះ ញាណ ២ ពួក គឺ ជរា និងមរណៈកើត ព្រោះជាតិ ជាបច្ច័យ, កាលជាតិមិនមាន ជរា និងមរណៈ ក៏មិនមាន ដូច្នេះ ត្រាស់ទុកដោយ

អំណាចនៃបច្ចុប្បន្នកាលដ៏យូរអង្វែង * ញាណទាំង ៦ នេះ គឺញាណ ២ ពួក ក្នុងអតីតៈ និងញាណ ២ ពួកទៀត ក្នុងអនាគត យ៉ាងនេះថា អតីតកាលដ៏យូរអង្វែងក្តី អនាគតកាលដ៏យូរអង្វែងក្តី (រួមបច្ចុប្បន្ន ២ ទៀត) រួមនឹងធម្មដ្ឋិតិញ្ញាណ ១ ផង ត្រូវជា ៧ ។ បណ្តាពាក្យទាំងនោះ ពាក្យថា "**ធម្មដ្ឋិតិញ្ញាណំ** = បញ្ញាក្នុងការកំណត់បច្ច័យ" បានដល់ ញាណក្នុងបច្ចយាការក្នុងការកំណត់បច្ច័យ; ពិតមែន បច្ចយាការ (គឺធម៌ដែលអាស្រ័យគ្នាហើយកើតឡើង) ព្រះសុគតត្រាស់ហៅថា "**ធម្មដ្ឋិតិ**" ព្រោះសភាវៈនៃធម៌ទាំងឡាយនោះ ជាហេតុនៃការប្រព្រឹត្តទៅ និងតាំងនៅ ។ ធម្មដ្ឋិតិញ្ញាណនេះ ជាឈ្មោះរបស់ញាណទាំង ៦ នោះឯង ។ ព្រោះធ្វើញាណទាំងនេះក្នុងអង្គមួយៗ ឱ្យជាមួយពួកៗ ៧ ក្នុងអង្គទាំង ១១ (បច្ចយាការ ១១) ទើបរួមជាញាណ ៧៧ យ៉ាង ដោយប្រការដូច្នេះ ។

បណ្តាពាក្យទាំងនោះ ពាក្យថា "**ខយធម្មំ** = មានការអស់ទៅជាធម្មតា" បានដល់ សភាវៈដែលដល់នូវការអស់ទៅ ។ ពាក្យថា "**វយធម្មំ** = មានការសូន្យទៅជាធម្មតា" បានដល់ សភាវៈដែលដល់នូវការសូន្យទៅ។ ពាក្យថា "**វិរាគធម្មំ** = មានការប្រាសទៅ ជាធម្មតា" បានដល់ សភាវៈដែលមិនគួរត្រេកអរ ។ ពាក្យថា "**និរោធធម្មំ** = មានការរលត់ទៅជាធម្មតា" បានដល់ សភាវៈដែលបាត់ទៅ ។

សួរថា មានប្រយោជន៍អ្វី ដែលព្រះលោកនាថត្រាស់ទុកដោយព្រះតម្រាស់

---

* បច្ចុប្បន្ន ៤ គឺ បច្ចុប្បន្នខណៈ បច្ចុប្បន្នសន្តតិ បច្ចុប្បន្នសម័យ និងបច្ចុប្បន្នអទ្ធា។ អតីតៈ និងអនាគត ក៏មានម្យ៉ាងៗ ៤ ដូចគ្នាដែរ ។

ដែលត្រាស់មកនេះ ?

ឆ្លើយថា ដើម្បីវិបស្សនាក្នុងវេលាដទៃទៀត (គឺក្នុងអនាគតកាល) ទើបព្រះលោកនាថត្រាស់ឱ្យពិចារណាដោយវិបស្សនា ក្នុងធម៌ដែលមានមកជាមុន ។

សួរថា ដោយព្រះតម្រាស់នោះ ព្រះលោកនាថទ្រង់ត្រាស់ដើម្បីវិបស្សនាតើដូចម្ដេច ?

ឆ្លើយថា ត្រាស់វិបស្សនា និងបដិវិបស្សនា អស់ ៧ ដង ។

ពិតមែន ញាណ (វិបស្សនា) នោះ រមែងគួរដើម្បីការឃើញដោយញាណ (វិបស្សនាញាណ) ទី ២ ព្រោះឃើញការមិនទៀង ជាទុក្ខ ជាអនត្តា ក្នុងសង្ខារទាំងពួង ដោយញាណ (វិបស្សនាញាណ) ទី ១ ។ ញាណ (វិបស្សនាញាណ) ទី ២ រមែងគួរដើម្បីការឃើញនូវសភាវៈទាំងនោះ ដោយញាណ (វិបស្សនាញាណ) ទី ៣ ។ ញាណ (វិបស្សនា ញាណ) ទី ៣ សមគួរដើម្បីការឃើញនូវសភាវៈទាំងនោះ ដោយញាណ (វិបស្សនាញាណ) ទី ៤ ។ ញាណ (វិបស្សនាញាណ) ទី ៤ រមែងសមគួរដើម្បីការឃើញនូវសភាវៈទាំងនោះ ដោយញាណ (វិបស្សនាញាណ) ទី ៥ ។ ញាណ (វិបស្សនាញាណ) ទី ៥ រមែងសមគួរដើម្បីការឃើញនូវសភាវៈទាំងនោះ ដោយញាណ (វិបស្សនាញាណ) ទី ៦ ។ ញាណ (វិបស្សនាញាណ) ទី ៦ រមែងសមគួរដើម្បីការឃើញនូវសភាវៈទាំងនោះ ដោយញាណ (វិបស្សនាញាណ) ទី ៧ ទៀត ។ ដោយប្រការដូច្នេះ ទើបព្រះលោកនាថត្រាស់វិបស្សនា និងបដិវិបស្សនាទុកអស់ ៧ ដង ដូច្នេះឯង ៕

**ចប់ញាណវត្ថុពួក ៧**

## ៨. អដ្ឋកថាអដ្ឋកនិទ្ទេស អធិប្បាយញាណវត្ថុពួក ៨

ពាក្យថា **"សោតាបត្តិមគ្គេ បញ្ញា"** បានដល់ បញ្ញាក្នុងសោតាបត្តិមគ្គ; អធិប្បាយថា បញ្ញាដែលសម្បយុត្តដោយសោតាបត្តិមគ្គនោះឯង ។ ព្រះលោកវិទូត្រាស់ទុកដោយព្រះតម្រាស់នេះថា **"សោតាបត្តិមគ្គេ បញ្ញា"** នេះ ។ សូម្បីក្នុងបទដែលនៅសល់ ក៏មានន័យដូចគ្នានេះដែរ ៕

ចប់ញាណវត្ថុពួក ៨

## ៩. អដ្ឋកថានវកនិទ្ទេស អធិប្បាយញាណវត្ថុពួក ៩

ពាក្យថា **"អនុបុព្វវិហារសមាបត្តីសុ"** បានដល់ សមាបត្តិទាំងឡាយពោលគឺធម៌ជាគ្រឿងនៅដោយលំដាប់ (អនុបុព្វវិហារ) ។ បញ្ញាទាំងនោះ ឈ្មោះថា អនុបុព្វវិហារ ព្រោះអត្ថថា ដែលព្រះយោគាវចរគប្បីចូលទៅនៅក្នុងក្បួន ដោយលំដាប់, គប្បីជ្រាបបញ្ញាទាំងនោះ ឈ្មោះថា សមាបត្តិ (ការចូលឈាន) ព្រោះអត្ថថា ជាធម៌ដែលព្រះយោគាវចរគប្បីដល់ព្រម ។ ក្នុងបញ្ញាទាំងនោះ គប្បីជ្រាបសម្បយុត្តបញ្ញា ៨ យ៉ាង មានពាក្យថា "បញ្ញាក្នុងបឋមជ្ឈានសមាបត្តិ" ជាដើមយ៉ាងនេះ ។ បញ្ញាក្នុងបច្ចវេក្ខណៈ (ការពិចារណា) ជាបញ្ញាខទី ៩ ។ ពិតមែនបញ្ញាក្នុងបច្ចវេក្ខណៈនោះ រមែងប្រព្រឹត្តទៅដល់ព្រះយោគាវចរអ្នកពិចារណាដោយស្ងប់ ដោយប្រណីត ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "បច្ចវេក្ខណញ្ញាណរបស់ព្រះយោគាវចរបុគ្គល អ្នកចេញចាកសញ្ញាវេទយិតនិរោធ-សមាបត្តិ" ៕

ចប់ញាណវត្ថុពួក ៩

## ១០. អដ្ឋកថាឧសកនិទ្ទេស អធិប្បាយញាណវត្ថុពួក ១០

## អធិប្បាយកម្លាំងទី ១ របស់ព្រះតថាគត

ពាក្យថា “**អដ្ឋានំ** = មិនមែនឋានៈ” បានដល់ បដិសេធហេតុ ។ ពាក្យថា “**អនវកាសោ** = មិនមែនឱកាស” បានដល់ បដិសេធបច្ច័យ ។ សូម្បីដោយពាក្យទាំងពីរ ក៏បដិសេធការណៈ (គឺហេតុនុ៎ះឯង) ។ ពិតមែន ការណៈ ព្រះមានព្រះ-ភាគត្រាស់ហៅថា ឋានៈ និងអវកាស (គឺឱកាស) ព្រោះការណៈនោះ ជាទីអា-ស្រ័យឱ្យប្រព្រឹត្តទៅដល់ផលរបស់ខ្លួន ។

ពាក្យថា “**យំ** = ណា” បានដល់ ដោយហេតុណា ។

ពាក្យថា “**ទិដ្ឋិសម្បន្នោ**” បានដល់ ព្រះអរិយសាវ័កអ្នកជាសោតាបន្នដល់ព្រមហើយដោយមគ្គទិដ្ឋិ ។ ពាក្យថា “**កិញ្ចិ សង្ខារំ** = សង្ខារណានីមួយ” បានដល់ សូម្បីសង្ខារណានីមួយត្រឹមតែម្យ៉ាង ក្នុងសង្ខារទាំងឡាយដែលបច្ច័យប្រជុំតាក់តែងហើយ ប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ពាក្យថា “**និច្ចតោ ឧបគច្ឆេយ្យ** = គប្បីកាន់យកដោយសេចក្ដីជារបស់ទៀង” បានដល់ គប្បីកាន់យកថាជារបស់ទៀង ។ ពាក្យថា “**នេតំ ឋានំ វិជ្ជតិ** = មិនមែនឋានៈដែលនៅមាន” បានដល់ ហេតុនោះមិនមាននៅ គឺស្ទង់ឃើញ (ដោយបញ្ញា) មិនបាន ។ ពាក្យថា “**យំ បុថុជ្ជនោ**” បានដល់ បុថុជ្ជន... គប្បីប្រកាន់យកដោយហេតុណា ។ ពាក្យថា “**ឋានមេតំ វិជ្ជតិ**” បានដល់ ហេតុនោះមាន, អធិប្បាយថា ក៏បុថុជ្ជននោះ គប្បីកាន់យកនូវសង្ខារអ្វីៗក្នុងបណ្ដាសង្ខារទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ថា ជារបស់ទៀង ដោយ

សស្សតទិដ្ឋិ ។ * ក៏សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៤ រមែងមិនជាអារម្មណ៍របស់ទិដ្ឋិ ឬថា របស់អកុសលទាំងឡាយដទៃ ដូចដុំដែកដែលក្រហមរងាលរហូតអស់មួយថ្ងៃ រមែងមិនជាអារម្មណ៍របស់សត្វរុយទាំងឡាយ ព្រោះជារបស់ពិតប្រាកដដោយភ្លើង ។ គប្បីជ្រាបអធិប្បាយសូម្បីក្នុងពាក្យថា **"កិញ្ចិ សង្ខារំ សុខតោ"** ដោយន័យនេះ ។ ពាក្យថា **"សុខតោ ឧបគច្ឆេយ្យ"** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកការប្រកាន់ថាជាសុខ ដោយអំណាចនៃអត្តទិដ្ឋិ យ៉ាងនេះថា "ខ្លួនមានសេចក្តីសុខដោយចំណែកមួយ ខាងមុខអំពីការស្លាប់ ក៏មិនមានរោគ" [២១] ជាដើម ។

ក៏ព្រះអរិយសាវ័កអ្នកគ្របសង្កត់នូវសេចក្តីក្តៅក្រហាយហើយ ដោយចិត្តដែលជាទិដ្ឋិវិប្បយុត្ត, ដូចនាយហត្ថាចារ្យអ្នកញ៉ាំងដំរីចុះប្រេង ឱ្យភ័យខ្លាច ដើម្បីត្រូវការឱ្យសេចក្តីក្តៅក្រហាយស្ងប់រម្ងាប់ ដូចបោក្ខរព្រាហ្មណ៍អ្នកប្រាថ្នាចំពោះភាពស្អាត រមែងមិនប្រកាន់សង្ខារអ្វីៗ ដូចលាមកថាជាសេចក្តីសុខ ។ ក្នុងអត្តវាទ (ក្នុងលទ្ធិថាខ្លួនមាន) ព្រះមានព្រះភាគមិនត្រាស់ថា **"សង្ខារោ"** ដើម្បីសង្គ្រោះបញ្ញត្តិមានកសិណបញ្ញត្តិជាដើម ទើបត្រាស់ពាក្យថា "ធម៌អ្វីៗ" ។ បណ្ឌិតគប្បីជ្រាបការកំណត់សូម្បីក្នុងញាណនេះ ដោយអំណាចនៃភូមិ ៤ របស់ព្រះអរិយសាវ័ក និងដោយអំណាចនៃភូមិ ៣ របស់បុថុជ្ជន ។ ម្យ៉ាងទៀត ការកំណត់ក្នុងវារៈទាំងពួង

---

* ក្នុងទីនេះ ប្រែតាមបាលីអដ្ឋកថាដែលថា **ចតុភូមិសង្ខារោ** តែដោយសភាវបរមត្ថ គួរនឹងជាសង្ខារ ក្នុងភូមិទី ៤ គឺលោកុត្តរធម៌ ទើបត្រឹមត្រូវ ដែលមិនជាអារម្មណ៍របស់ទិដ្ឋិ និងអកុសលទាំងឡាយ ។

[២១] ម. ឧ.។

ដោយអំណាចនៃភូមិ ៣ នោះឯង រមែងគួរសូម្បីដល់ព្រះអរិយសាវ័ក ។ ក៏បុថុជ្ជន រមែងប្រកាន់នូវវត្ថុណា១, ព្រះអរិយសាវ័ក រមែងប្រកាន់សង្ខារណា១ ថា “ជារបស់ទៀង ជាសុខ ជាអត្តា” , ព្រះអរិយសាវ័កកាលកំណត់សង្ខារនោះ១ ថា “ជាវត្ថុមិនទៀង ជាទុក្ខ ជាអនត្តា” ឈ្មោះថា កម្ចាត់នូវសេចក្ដីប្រកាន់ ។

ក្នុងពាក្យថា “**មាតរំ** = មាតា” ជាដើម មាតា គឺអ្នកបង្កើត ។ បិតា ក៏គឺអ្នកឱ្យកើត ។ ព្រះខីណាស្រពដែលជាមនុស្សប៉ុណ្ណោះ ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុងពាក្យថា សម្លាប់ព្រះអរហន្ត ។

កាលមានពាក្យសួរថា “ព្រះអរិយសាវ័កគប្បីផ្ដាច់បង់សត្វ ឱ្យចុះចាកជីវិត (សម្លាប់សត្វ) ឬ ?” ក៏ត្រូវឆ្លើយថា “សូម្បីសេចក្ដីនេះ ក៏ជាអឋានៈ” ។ សូម្បីបើថា នរណា១ គប្បីពោលនឹងព្រះអរិយសាវ័កអ្នកលះភពក្ដី និងសូម្បីបុគ្គលអ្នកមិនដឹងខ្លួនជាព្រះអរិយសាវ័កក្ដី ថា “លោកចូរដាក់ចុះនូវស្រមោចតូច១ មួយនេះ ចុះចាកជីវិតទៅ ហើយក៏នឹងដល់នូវភាពជាស្ដេចចក្រពត្តិក្នុងផ្ទៃ (ភព) នៃចក្រវាលទាំងអស់” ។ ព្រះអរិយសាវ័កនោះ នឹងមិនគប្បីផ្ដាច់សត្វនោះ ចុះចាកជីវិតពិតប្រាកដ ។ ម្យ៉ាងទៀត ជនទាំងឡាយគប្បីពោលនឹងព្រះអរិយសាវ័កនោះ យ៉ាងនេះថា “បើលោកនឹងមិនសម្លាប់នូវសត្វនេះ ចុះចាកជីវិតទេ, ពួកយើងកាត់សិរសារបស់លោក” , ជនទាំងនោះ ក៏នឹងគប្បីកាត់សិរសារបស់ព្រះអរិយសាវ័កនោះពិតប្រាកដ, ព្រោះលោកមិនគប្បីសម្លាប់សត្វនោះឡើយ ។ ក៏ពាក្យនេះពោលទុកដើម្បីសម្ដែងដល់ភាពជាបុថុជ្ជនមានទោសច្រើន និងដើម្បីសម្ដែងនូវកម្លាំងរបស់

ព្រះអរិយសាវ័ក ។ ពិតមែន ក្នុងញាណនេះ គប្បីជ្រាបអធិប្បាយដូច្នេះ ៖

បុថុជ្ជននឹងធ្វើអនន្តរិយកម្ម មានការសម្លាប់មាតាជាដើមឯណា ឈ្មោះថា ភាពជាបុថុជ្ជនអ្នកប្រព្រឹត្តទៅជាមួយនឹងទោស នឹងធ្វើសូម្បីនូវអនន្តរិយកម្មនោះបាន ។ ព្រះអរិយសាវ័កឈ្មោះថា "អ្នកមានកម្លាំងច្រើនពិត, ព្រោះលោកមិនធ្វើកម្មទាំងនេះ" ។

ពាក្យថា "**បទុដ្ឋេន ចិត្តេន** = អ្នកមានចិត្តប្រទូសរ៉ាយ" បានដល់ មានចិត្តសម្លាប់ដែលសម្បយុត្តដោយទោសៈ ។

ពាក្យថា "**លោហិតំ ឧប្បាទេយ្យ** = ញ៉ាំងព្រះលោហិតរបស់ព្រះពុទ្ធឱ្យពុះពងឡើង" បានដល់ ញ៉ាំងព្រះលោហិតក្នុងសរីរៈរបស់ព្រះពុទ្ធ ដែលទ្រង់ព្រះជន្មនៅ សូម្បីមានប្រមាណត្រឹមតែការក្រេបផឹករបស់សត្វរុយតូចៗ ឱ្យពុះពងឡើង ។

ពាក្យថា "**សង្ឃំ ភិន្ទេយ្យ** = គប្បីញ៉ាំងសង្ឃឱ្យបែកចាកគ្នា" បានដល់ ញ៉ាំងសង្ឃអ្នកមានសង្វាសស្មើគ្នា ដែលតាំងនៅក្នុងសីមាជាមួយគ្នា ឱ្យបែកទៅដោយហេតុ ៥ ប្រការ ។

សមពិតដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

"ម្នាលឧបាលិ សង្ឃរមែងបែកចាកគ្នា ដោយអាការ ៥ ប្រការ គឺ ដោយកម្ម ឧទ្ទេស ការពោលញែកគ្នា (វោហារ) អនុសាវនា និងការចាប់ស្លាក" [២២] ។

បណ្ដាពាក្យទាំងនោះ ពាក្យថា ដោយកម្ម បានដល់ ក្នុងកម្ម ៤ យ៉ាង មាន

[២២] វិនយ. ។

អបលោកនកម្ម[២៣] ជាដើម កម្មយ៉ាងណាមួយ ។ ពាក្យថា **ឧទ្ទេស** បានដល់ ការសម្តែងបាតិមោក្ខុទ្ទេស ៥ យ៉ាង ដោយការសម្តែងបាតិមោក្ខុទ្ទេសយ៉ាងណានីមួយ ។ ពាក្យថា ការពោលញែកគ្នា បានដល់ ការពោល, គឺសម្តែងនូវភេទករវត្ថុ (រឿងវិវាទ) ១៨[២៤] យ៉ាង មានពាក្យថា **"អធម្មំ ធម្មោ** = វត្ថុដែលមិនមែនធម៌ ពោល

[២៣] កម្ម ៤ គឺ អបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១ និងញត្តិចតុត្ថកម្ម ១ ។

[២៤] ភេទករវត្ថុ ១៨ យ៉ាង គឺ

១. វត្ថុមិនមែនធម៌ ពោលថា ជាធម៌

២. វត្ថុដែលជាធម៌ ពោលថា មិនមែនធម៌

៣. វត្ថុដែលមិនមែនវិន័យ ពោលថា ជាវិន័យ

៤. វត្ថុដែលជាវិន័យ ពោលថា មិនមែនវិន័យ

៥. វត្ថុដែលព្រះមានព្រះភាគត្រាស់ទុក ពោលថា មិនបានត្រាស់ទុក

៦. វត្ថុដែលព្រះមានព្រះភាគមិនបានត្រាស់ទុក ពោលថា បានត្រាស់ទុក

៧. វត្ថុដែលព្រះមានព្រះភាគធ្លាប់នាំមក ពោលថា មិនធ្លាប់នាំមក

៨. វត្ថុដែលព្រះមានព្រះភាគមិនធ្លាប់នាំមក ពោលថា ធ្លាប់នាំមក

៩. សិក្ខាបទដែលទ្រង់បញ្ញត្តទុក ពោលថា ទ្រង់មិនបានបញ្ញត្តទុក

១០. សិក្ខាបទដែលទ្រង់មិនបញ្ញត្តទុក ពោលថា ទ្រង់បញ្ញត្តទុក

១១. វត្ថុជាអាបត្តិ ពោលថា មិនជាអាបត្តិ

១២. វត្ថុមិនជាអាបត្តិ ពោលថា ជាអាបត្តិ

១៣. អាបត្តិស្រាល ពោលថា អាបត្តិធ្ងន់

១៤. អាបត្តិធ្ងន់ ពោលថា អាបត្តិស្រាល

ថា ជាធម៌” ជាដើម ដោយរឿងវិវាទគ្នាទាំងនោះៗ ដែលកើតឡើង ។ ពាក្យថា អនុសាវនា បានដល់ ដោយការពោលប្រកាស ព្រោះបញ្ចេញវាចាជិតត្រចៀក ដោយន័យថា “លោកទាំងឡាយ រមែងជ្រាបនូវភាពនៃយើងជាអ្នកបួសហើយ ចាកត្រកូលខ្ពស់ ឯយើងក៏ជាពហុស្សូត្រ, បុគ្គលដូចជាយើង គប្បីកាន់យកនូវពាក្យទូន្មានរបស់ព្រះពុទ្ធដែលយល់ខុសចាកធម៌ ចាកវិន័យ ឬសូម្បីតែការគិត លោកទាំងឡាយក៏មិនគួរព្យាយាមឱ្យកើតឡើង, ប្រយោជន៍អ្វីរបស់យើង យើងរមែងមិនខ្លាចអ្វីៗ ចាកអបាយ អវីចីនរក ជាធម្មជាតិស្ងប់ ដូចជាព្រៃនៃផ្កាឧប្បលខៀវជាដើម ។

ពាក្យថា ដោយការចាប់ស្លាក ឈ្មោះថា ការចាប់ស្លាក ព្រោះថា ពេលប្រកាសយ៉ាងនោះហើយ ទើបឧបត្ថម្ភចិត្តរបស់បុគ្គលទាំងនោះឱ្យកម្រើក ហើយក៏ពោលថា “លោកទាំងឡាយចូរកាន់យកស្លាកទាំងនេះ ចូរកាន់យកស្លាកនេះ” (សំដៅដល់ ការសរសេរស្លាកឱ្យចាប់ដើម្បីឱ្យជាពួករបស់ខ្លួនច្រើន) ។

ម្យ៉ាងទៀត ក្នុងសេចក្តីនេះ កម្ម (ការចាត់ចែង) នុ៎ះឯង ជាឧទ្ទេស ឬជាប្រមាណ (គ្រឿងកំណត់), ក៏ការកាន់យកស្លាកព្រោះពោលជំទាស់គ្នា និងការប្រ-

---

១៥. អាបត្តិដែលកែខៃបាន ពោលថា កែខៃមិនបាន

១៦. អាបត្តិដែលកែខៃមិនបាន ពោលថា កែខៃបាន

១៧. អាបត្តិដែលគ្រោតគ្រាត ពោលថា ជាអាបត្តិមិនគ្រោតគ្រាត

១៨. អាបត្តិដែលមិនគ្រោតគ្រាត ពោលថា ជាអាបត្តិគ្រោតគ្រាត ។

កាស ចាត់ជាបុព្វភាគ (ខាងដើម); ពិតមែន សង្ឃនៅមិនបែកគ្នា ព្រោះសូម្បីបុគ្គលអ្នកពោលជំទាស់នឹងគ្នា ដោយអំណាចនៃការសម្តែងវត្ថុ (រឿងវិវាទ) ១៨ ខ ព្រោះការប្រកាសសេចក្តីត្រូវការឱ្យកើតការយល់ឃើញចូលចិត្តក្នុងទីនោះ ហើយកាន់យកស្លាក (អ្នកគង់នឹងដល់ការទទួលលទ្ធផលថា អ្នកណាមានសេចក្តីយល់ឃើញផ្លូវណាឱ្យបែកគ្នា) ។ តែថា កាលណាសង្ឃកាន់យកស្លាក ៤ រូប ឬលើសជាង ដោយអាការដែលពោលមកហើយ ក៏ធ្វើកម្ម ឬឧទ្ទេស, សង្ឃបែកចេញទៅជាពីរពួកក្នុងកាលនោះ ទើបឈ្មោះថា បែកគ្នាហើយ ។

ពាក្យថា "បុគ្គលអ្នកដល់ព្រមដោយទិដ្ឋិ (មគ្គទិដ្ឋិ) ដោយអាការយ៉ាងនេះគប្បីទម្លាយសង្ឃ" នេះ មិនមែនឋានៈ ។ ព្រះភគវាត្រាស់ដល់អនន្តរិយកម្ម ៥ មានការសម្លាប់មាតា និងបិតាជាដើម ទុកដោយពាក្យមានប្រមាណប៉ុណ្ណេះថា បុថុជ្ជនតែងធ្វើនូវអនន្តរិយកម្មណា, ព្រះអរិយសាវ័ក រមែងមិនធ្វើនូវអនន្តរិយកម្មនោះទេ។

ដើម្បីសេចក្តីជាក់ច្បាស់នៃកម្មទាំងនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ គឺ ៖

**កម្មតោ** ដោយកម្ម

**ទ្វារតោ** ដោយទ្វារ

**កប្បដ្ឋិតិយតោ** ដោយការតាំងនៅរហូតកប្ប

**បាកតោ** ដោយផលនៃកម្ម

**សាធារណាទីហិ** ដោយសាធារណៈជាដើម ៕

## វិនិច្ឆ័យអំពីកម្ម

ក្នុងពាក្យទាំងនោះ ពោលអំពីកម្ម ជាមុនសិន ៖

ពិតមែន ក្នុងអនន្តរិយកម្មនេះ កាលជាមនុស្សនោះឯង ក្លែងសម្លាប់មាតា ឬបិតាដែលជាមនុស្សមានភេទមិនផ្លាស់ប្តូរ[២៥] (សម្លាប់មាតាបិតា) អនន្តរិយកម្ម រមែងមានដល់គេ ។ មនុស្សអ្នកធ្វើកម្មនោះ គិតថា "យើងនឹងហាមវិបាករបស់អនន្តរិយកម្មនោះ" ទើបញ៉ាំងចក្រវាលទាំងអស់ ឱ្យពេញដោយស្តូប (សថូបចេតិយ) ដែលសម្រេចហើយ ដោយមាសមានប្រមាណប៉ុនមហាចេតិយ, ញ៉ាំងភិក្ខុសង្ឃដែលអង្គុយរហូតចក្រវាល ហើយថ្វាយមហាទានក្តី, ចាប់ជាយសំពត់សង្ឃាដីរបស់ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងហើយធ្វើដំណើរទៅក្តី, ក៏រមែងកើតក្នុងនរកនោះឯង ព្រោះកាយបែកធ្លាយ ។ តែថា អ្នកណា ជាមនុស្សក្លែងសម្លាប់ជីវិតមាតាឬបិតាដែលជាមនុស្ស ឬសត្វតិរច្ឆាននោះឯង សម្លាប់ជីវិតមាតាបិតាអ្នកជាសត្វឱ្យស្លាប់ទៅ, កម្មរបស់អ្នកនោះ មិនជាអនន្តរិយកម្ម, តែកម្ម ជាអំពើធ្ងន់, រមែងហាក់ដូចជាអនន្តរិយកម្មនោះឯង ។ បញ្ហានេះ ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃសត្វដែលកើតជាមនុស្ស (មនុស្សជាតិ) ។

ក្នុងសេចក្តីនេះ បណ្ឌិតគប្បីពោលដល់ប្រភេទ ៤ នៃការសម្លាប់ពពែ ៤ ប្រភេទនៃការធ្វើសង្គ្រាម និង ៤ ប្រភេទ នៃការសម្លាប់ចោរ ដូច្នេះគឺ ៖

មនុស្សអ្នកញ៉ាំងមាតា ឬបិតា ជាមនុស្សដែលឈរនៅទីជិតពពែឱ្យស្លាប់

---

[២៥] សម្គាល់សេចក្តីថា ភេទរបស់មាតា ឬបិតា តាំងនៅដោយប្រក្រតី គឺមិនបានផ្លាស់ប្តូរទៅជាសត្វតិរច្ឆានជាដើម ។

សូម្បីដោយការប្រាថ្នាថា "យើងនឹងសម្លាប់ពពែ" ដូច្នេះ រមែងបានទទួលអនន្តរិយកម្ម ។ ក៏នេះជាចេតនាសម្លាប់ពពែ [២៦] , ពពែនោះស្លាប់ក្តី, ចេតនាសម្លាប់មាតាបិតា [២៧] តែពពែស្លាប់ក្តី, រមែងមិនបានទទួលអនន្តរិយកម្ម ។ ចេតនាសម្លាប់មាតាបិតា ញុំាងមាតាបិតាឱ្យស្លាប់ រមែងបានទទួលអនន្តរិយកម្មពិតប្រាកដ ។ ក្នុងកម្មទាំងពីរប្រភេទដ៏សេស ក្រៅអំពីនេះ ក៏ន័យនេះដែរ ។

ក៏ក្នុងមាតាបិតាជាដើមយ៉ាងណា, សូម្បីការសម្លាប់ព្រះអរហន្ត ក៏ដូច្នោះដែរ ។ បណ្ឌិតគប្បីជ្រាប ៤ ប្រភេទ នៃការសម្លាប់ព្រះអរហន្ត ដូចតទៅ ៖

ក៏បុគ្គលញុំាងព្រះអរហន្តដែលជាមនុស្សប៉ុណ្ណោះឱ្យស្លាប់ រមែងជាអនន្តរិយកម្ម, ញុំាងព្រះអរហន្តដែលជាយក្សឱ្យស្លាប់ រមែងមិនជាអនន្តរិយកម្ម តែជាកម្មដែលធ្ងន់ដូចនឹងអនន្តរិយកម្មនោះដែរ ។ ម្យ៉ាងទៀត កាលបុគ្គលប្រហារដោយសស្ត្រា ឬសូម្បីតែឱ្យថ្នាំពិស ក្នុងកាលដែលលោកនៅជាមនុស្សបុថុជ្ជននោះឯង បើថា លោកពន្លុះព្រះអរហន្តហើយបរិញ្វាន ដោយហេតុនោះឯង, រមែងជាអរហន្តឃាតដោយពិត ។ តែទានដែលបុគ្គលថ្វាយក្នុងកាលដែលលោកនៅជាបុថុជ្ជន កាលលោកពន្លុះព្រះអរហន្តហើយ ទើបឆាន់អាហារនោះ, អាហារដែលថ្វាយហើយក្នុងកាលនោះ រមែងឈ្មោះថា ថ្វាយដល់បុថុជ្ជនប៉ុណ្ណោះ; កាលបុគ្គលសម្លាប់ព្រះអរិយៈដ៏សេស (មានព្រះឥន្ទជាដើម) រមែងមិនចាត់ជាអនន្តរិយកម្ម, តែក៏ជាកម្មដែលធ្ងន់ដូចនឹងអនន្តរិយកម្មដែរ ។

---

[២៦] ចេតនាសម្លាប់ពពែដោយសម្គាល់ថា ជាមាតាបិតា ។

[២៧] ចេតនាសម្លាប់មាតាបិតាដោយសម្គាល់ថា ជាពពែ ។

ក្នុងលោហិតុប្បាទ ឈ្មោះថា ការហូរចេញនៃព្រះលោហិត ព្រោះការកាត់ស្បែក (រូបធម៌) ដោយការរុករានរបស់សឹកសត្រូវ ដោយការធ្វើឱ្យបែកកាយ នៃព្រះតថាគត រមែងមិនមាន, តែបើនឹងមាន ក៏ត្រឹមតែលោហិតក្នុងទីមួយកន្លែងប្រជុំ (រួមគ្នា) ខាងក្នុងនៃសរីរៈប៉ុណ្ណោះ ។ សូម្បីស្បែកដែលរលាត់ទៅហើយ ព្រោះថ្មដែលទេវទត្តប្រមៀលទៅប្រហារ ត្រង់ទីបំផុតចុងព្រះបាទរបស់ព្រះតថាគត, ព្រះបាទមានត្រឹមតែព្រះលោហិតពុះពង (ច្រាល) ឡើងខាងក្នុងប៉ុណ្ណោះ ការធ្វើនោះដូចជាបុគ្គលប្រហារហើយដោយពូថៅ ។ កាលទេវទត្តធ្វើដូច្នោះ អនន្តរិយកម្មក៏បានមានហើយដល់លោក ។

ចំណែកហ្ម (ពេទ្យ) ជីវកធ្វើការវះកាត់ព្រះឆវី (ស្បែក) របស់ព្រះតថាគត ដោយកាំបិតតាមពេញចិត្ត ហើយធ្វើព្រះលោហិតដែលទោសប្រទូសរ៉ាយ ចេញចាកទីនោះ បានធ្វើឱ្យផាសុក (ស្រួល) ។ កាលហ្មអាជីវកធ្វើយ៉ាងនោះ បុញ្ញកម្មប៉ុណ្ណោះរមែងកើតឡើង ។

ម្យ៉ាងទៀត កាលព្រះតថាគតបរិនិព្វានហើយ ជនពួកណារមែងទម្លាយព្រះចេតិយ កាត់ដើមព្រះមហាពោធិព្រឹក្ស, បៀតបៀនព្រះធាតុ, កម្មអ្វីរមែងមានដល់ជនទាំងនោះ ? កម្មដែលធ្ងន់ដូចនឹងអនន្តរិយកម្ម រមែងកើតដល់គេ ។ ក៏បុគ្គលរមែងគួរ ដើម្បីកាត់មែកមហាពោធិ ដែលបៀតបៀនព្រះសថូបបញ្ចុះព្រះធាតុ ព្រះរូបបដិមា (ពុទ្ធរូប); ឬសូម្បីបើពួកសត្វបក្សីទាំងឡាយ រស់នៅត្រង់ដើមមហា-ពោធិ៍នោះ រមែងបន្ទោបង់វច្ចៈ (ឧច្ចារៈ) ធ្លាក់ចុះត្រង់ព្រះចេតិយ ទើបសមគួរដើម្បីកាត់មែកមហាពោធិនោះមែនពិត ។ ព្រោះថា សរីរចេតិយ (ចេតិយបញ្ចុះ

ព្រះធាតុ) ធំជាងបរិភោគចេតិយ (ចេតិយបញ្ចុះបរិក្ខារប្រើប្រាស់របស់ព្រះពុទ្ធ); ការកាត់សូម្បីត្រង់គល់ពោធិដែលទម្លាយចេតិយនាំចេញទៅ ក៏គួរ ។ ក៏មែកនៃដើមមហាពោធិណា រមែងបៀតបៀតផ្ទះពោធិ មិនគួរកាត់មែកពោធិដើម្បីប្រយោជន៍ដល់ផ្ទះ ។ ពិតមែន ផ្ទះដើម្បីប្រយោជន៍ដល់ដើមពោធិមាន មិនគួរកាត់ដើម្បីប្រយោជន៍ដល់ផ្ទះ; សូម្បីក្នុងផ្ទះ អាសនៈ (ដែលរក្សាព្រះធាតុ) ក៏ន័យនេះដែរ ។ តែព្រះធាតុដែលបុគ្គលរក្សាទុកត្រង់ផ្ទះ អាសនៈណា, ដើម្បីត្រូវការផ្ទះអាសនៈនោះ គួរដើម្បីកាត់មែកពោធិ ។ និងដើម្បីត្រូវការរក្សាដើមពោធិទុក សមគួរកាត់មែកដែលនាំរសជាតិចេញទៅ ឬទីស្អុយរលួយ (ដែលខូច) នោះឯង, សូម្បីបុណ្យ ក៏រមែងកើតឡើងដល់បុគ្គលនោះ ដូចការបដិបត្តិព្រះសរីរៈដែរ ។

ក្នុងសង្ឃភេទ កាលសង្ឃនៅក្នុងសីមាមិនប្រជុំគ្នាហើយ ការបែកនៃសង្ឃផង អនន្តរិយកម្មផង រមែងមានដល់បុគ្គលអ្នកពោលប្រកាសឱ្យចាប់ស្លាកធ្វើហើយ ព្រោះកាន់យកបរិស័ទផ្សេង១ ហើយ នឹងធ្វើនូវកម្ម ឬសូធ្យនូវឧទ្ទេស ។ ក៏កាលធ្វើកម្ម ឬសូធ្យឧទ្ទេស ដោយសេចក្តីសំគាល់ថា មានការព្រមព្រៀងគ្នា ទើបគួរធ្វើ ។ ពិតមែន កាលធ្វើដោយសញ្ញានៃសេចក្តីព្រមព្រៀងគ្នា ការបែកនៃសង្ឃ និងអនន្តរិយកម្ម រមែងមិនមាន ។ ដោយទំនងដូចគ្នា ធ្វើកម្មដោយស្តារបរិស័ទឡើងថ្មី ក៏សមគួរ ។ បណ្តាជន អ្នកថ្មី កំណត់ក្រោមបំផុតតិចជាងមនុស្ស (អ្នកមិនដឹង), មនុស្សណារមែងទម្លាយសង្ឃ អនន្តរិយកម្មរមែងកើតដល់គេ ។ កម្មដែលមានទោសច្រើន រមែងកើតដល់អធម្មវាទី ទាំងឡាយអ្នកជាសត្រូវនឹងសង្ឃ ។ កម្មដែលមិនមានទោស រមែងកើតដល់ធម្មវាទី ។

ក៏ក្នុងសេចក្ដីនេះ សូត្រក្នុងសង្ឃភេទរបស់អ្នកថ្មីនោះឯង ដូច្នេះ ៖

"ម្នាលឧបាលិ ភិក្ខុអ្នកចាប់ស្លាក ៤ រូប, មួយពួក ៤ រូប, មួយពួកទៀត ភិក្ខុដែលថ្មី រមែងប្រកាសឱ្យកាន់យកស្លាកថា 'នេះជាធម៌, នេះជាវិន័យ, នេះជាសត្ថុសាសនា, លោកទាំងឡាយចូរកាន់យកស្លាកនេះ, ចូរពេញចិត្តពាក្យនេះ,' ដោយអាការយ៉ាងនេះឯង; ម្នាលឧបាលិ ការប្រេះឆានៃសង្ឃ និងការបែកបាក់នៃសង្ឃ រមែងមាន; ម្នាលឧបាលិ ការប្រេះឆានៃសង្ឃក្ដី ការបែកបាក់នៃសង្ឃក្ដី រមែងមានដល់អ្នកថ្មី ឬអ្នកថ្មីក្រៃលែង" [២៨] ។ ក៏បណ្ដាអនន្តរិយកម្ម ៥ យ៉ាង សង្ឃភេទប៉ុណ្ណោះជាវចីកម្ម, កម្មដ៏សេសផ្សេងទៀត ជាកាយកម្ម ។ គប្បីជ្រាបវិនិច្ឆ័យ ការពោលអំពីកម្ម ដោយប្រការដូច្នេះ ៕

## វិនិច្ឆ័យអំពីទ្វារ

ពាក្យថា ដោយទ្វារ ក៏កម្មទាំងអស់នេះ រមែងតាំងឡើងអំពីកាយទ្វារខ្លះ អំពីវចីទ្វារខ្លះ; តែក្នុងអនន្តរិយកម្មទាំង ៥ យ៉ាងនោះ អនន្តរិយកម្ម ៤ ខាងដើម (វៀរសង្ឃភេទ) សូម្បីតាំងឡើងហើយអំពីវចីទ្វារ ដោយអំណាចនៃប្រយោគដែលសម្រេចដោយវិជ្ជា ព្រោះប្រើឱ្យធ្វើ ក៏រមែងញ៉ាំងកាយទ្វារនោះឯង ឱ្យពេញដោយសង្ឃភេទដែរ; កាលបុគ្គលធ្វើការបំបែកសង្ឃ ដោយការចង្អុលបង្ហាញដោយដៃ សូម្បីនឹងតាំងឡើងពីកាយទ្វារ ក៏ឈ្មោះថា ញ៉ាំងវចីទ្វារនោះឯង ឱ្យពេញដែរ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្ដីនេះ សូម្បីដោយទ្វារ មានប្រការដូច្នេះ ៕

---

[២៨] វិនយ. ។

## វិនិច្ឆ័យអំពីការតាំងនៅរហូតកប្ប

ពាក្យថា ដោយការតាំងនៅរហូតកប្ប ក៏ក្នុងអនន្តរិយកម្មទាំង ៥ នេះ សង្ឃភេទប៉ុណ្ណោះជាកម្មតាំងនៅរហូតកប្ប ។ ពិតមែន កាលកប្បកំពុងប្រព្រឹត្តទៅ (ខាងដើមកប្ប) ឬកណ្ដាលនៃកប្បកំពុងប្រព្រឹត្តទៅ អ្នកធ្វើសង្ឃភេទរមែងរួចផុតពីការឱ្យផលរបស់កម្ម ក្នុងកាលដែលកប្បវិនាសទៅតែប៉ុណ្ណោះ ។ សូម្បីថាកប្បនឹងវិនាសទៅក្នុងថ្ងៃព្រឹកនេះសោត បុគ្គលធ្វើសង្ឃភេទ ក្នុងថ្ងៃនេះ គេក៏នឹងផុតពីអបាយក្នុងថ្ងៃព្រឹកនេះឯង, គឺគេត្រូវឆេះក្នុងនរកអស់មួយថ្ងៃប៉ុណ្ណោះ, តែថាការធ្វើកម្មដូចពោលមកនេះ មិនមានទេ ។ អនន្តរិយកម្ម ៤ ដ៏សេស ជាអនន្តរិយ-កម្មដូចគ្នា, តែមិនតាំងនៅរហូតកប្ប គប្បីជ្រាបវិនិច្ឆ័យក្នុងអនន្តរិយកម្មនេះ សូម្បីពោលដោយការតាំងនៅរហូតកប្ប ដូចពណ៌នាមកដូច្នេះ ៕

## វិនិច្ឆ័យអំពីបាកៈ* គឺផលរបស់កម្ម

ពាក្យថា "ដោយបាកៈ" ក៏អនន្តរិយកម្មទាំង ៥ យ៉ាង ដែលបុគ្គលណាធ្វើហើយ, សង្ឃភេទប៉ុណ្ណោះ រមែងឱ្យផលដល់គេដោយអំណាចនៃបដិសន្ធិ, កម្មដែលសេសសល់រាប់ថា ជាអហោសិកម្ម គឺកម្មនោះមិនឱ្យផល ។ កាលមិនធ្វើសង្ឃភេទ លោហិតុប្បាទ រមែងឱ្យផលដោយអំណាចនាំឱ្យបដិសន្ធិ ។ ព្រោះសេចក្ដីមិនមាននៃកម្មទាំងពីរដែលពោលហើយ អរហន្តឃាត រមែងឱ្យផល ។ បើអរហន្តឃាត

---

* ពាក្យពេញថា **វិបាកៈ** តែដែលយកពាក្យបាកៈមកប្រើក្នុងទីនេះ ព្រោះតម្រូវទៅតាមសេចក្ដីនៃគាថា ដែលមានមកហើយក្នុងខាងដើម ។

មិនមាន, បិតាជាអ្នកមានសីល មាតាជាអ្នកទ្រុស្តសីល ឬមានសីលទាបជាងបិតា, បិតុឃាត រមែងឱ្យផល ដោយអំណាចនាំឱ្យបដិសន្ធិ; បើមាតាមានសីលខ្ពស់ជាង មាតុឃាត រមែងឱ្យផល ។ បើមាតា និងបិតាមានសីល ឬមិនមានសីលស្មើគ្នា មាតុឃាតប៉ុណ្ណោះ រមែងឱ្យផល ដោយអំណាចនៃការនាំឱ្យបដិសន្ធិ; ព្រោះថា មាតាជាអ្នកធ្វើនូវការងារដែលបិតា ធ្វើបានដោយលំបាក និងព្រោះមានឧបការច្រើនដល់បុត្រ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្ដីនេះ សូម្បីពោលដោយការឱ្យផល មានប្រការដូច្នេះ ៕

## វិនិច្ឆ័យអំពីសាធារណៈជាដើម

ពាក្យថា "ពោលដោយសាធារណៈជាដើម" អនន្តរិយកម្ម ៥ (វៀរសង្ឃភេទ) នេះចេញ ទូទៅដល់គ្រហស្ថ និងបព្វជិតទាំងឡាយ; ចំណែកសង្ឃភេទជាអនន្តរិយកម្មដល់ភិក្ខុ មានប្រការតាមដែលពោលហើយ, មិនជាអនន្តរិយកម្មដល់បុគ្គលដទៃ ព្រោះព្រះបាលីថា " **ន ខោ ឧបាលិ ភិក្ខុនី សង្ឃំ ភិន្ទតិ, ន សិក្ខមានា, ន សាមណេរោ, ន សាមណេរី, ន ឧបាសកោ, ន ឧបាសិកា សង្ឃំ ភិន្ទតិ, ភិក្ខុ ខោ ឧបាលិ បកតត្តោ សមានសំវាសកោ សមាន~សីមាយំ ឋិតោ សង្ឃំ ភិន្ទតិ** = ម្នាលឧបាលិ ភិក្ខុនីរមែងទម្លាយសង្ឃមិនបាន, សិក្ខមានា ..., សាមណេរ ..., សាមណេរី ..., ឧបាសក និងឧបាសិកា រមែងទម្លាយសង្ឃឱ្យបែកគ្នាមិនបាន, ម្នាលឧបាលិ ភិក្ខុ និងអ្នកមានសង្វាសស្មើគ្នាជាបកតត្តៈ

(ប្រក្រតី) តាំងនៅក្នុងសីមាជាមួយគ្នា រមែងទម្លាយសង្ឃ” [២៩] ដូច្នេះ; ព្រោះហេតុដូច្នោះ សង្ឃភេទនេះ ទើបមិនទូទៅដល់បុគ្គលដទៃ ។ សូម្បីអនន្តរិយកម្មទាំងអស់នេះ សហគតៈដោយទុក្ខវេទនា សម្បយុត្តដោយទោសៈ និងមោហៈ លោកពោលសង្គ្រោះដោយអាទិសព្ទដូច្នេះឯង ។

ពាក្យថា “**អញ្ញំ សត្ថារំ** = សាស្តាដទៃ” អធិប្បាយថា ព្រះសោតាបន្ន នឹងគប្បីបូជាចំពោះលទ្ធិដទៃ យ៉ាងនេះថា “អ្នកនេះជាសាស្តារបស់យើង, យើងអាចដើម្បីធ្វើកិច្ចរបស់សាស្តាបាន” ដូច្នេះ សូម្បីក្នុងចន្លោះភព នឹងគប្បីប្រកាន់ខ្ជាប់ថា “អ្នកនេះ ជាសាស្តារបស់យើង”; ចំណុចនេះ មិនមែនឋានដែលនឹងមានឡើយ ។

ពាក្យថា “**អដ្ឋមំ ភវំ និព្វត្តេយ្យ** = កើតក្នុងភពទី ៨” អធិប្បាយថា ព្រះសោតាបន្ន សូម្បីមានបញ្ញាតិចជាងព្រះអរិយបុគ្គលទាំងអស់ ឈានកន្លងភពទី ៧ ហើយ គប្បីកើតក្នុងភពទី ៨, សេចក្តីនេះឯង មិនមែនឋានៈដែលមានទេ ។ ព្រោះថា ព្រះមានព្រះភាគសំដៅយកភពទី ៧ ដោយកំណត់ខ្ពស់បំផុត ទើបត្រាស់ថា “ជាអ្នកទៀងចំពោះការត្រាស់ដឹងខាងមុខ” ដូច្នេះ ។

សួរថា អ្វីទៅ រមែងកំណត់ភពនោះ, អ្វីទៅ កំណត់បុព្វហេតុ, មគ្គដែលលោកបានចំពោះហើយកំណត់, ឬថាមគ្គ ៣ ខាងលើ រមែងកំណត់ ?

ឆ្លើយថា សេចក្តីនេះ ត្រឹមតែជាឈ្មោះដែលព្រះសម្ពុទ្ធកាន់យកហើយ ។ ក៏បុគ្គលឈ្មោះថា ទៀង រមែងមិនមាន, ព្រោះថា អ្នកណា១ កាលពោលថា “បុព្វ-ហេតុរមែងកំណត់” ដូច្នេះ ក៏នឹងពោលដល់ឧបនិស្ស័យនៃមគ្គ ៣ ខាងលើ, រមែង

---

[២៩] វិនយ. ។

ដល់សេចក្ដីមិនមានឧបនិស្ស័យនៃបឋមមគ្គ; ព្រោះហេតុនោះ បឋមមគ្គនោះ ទើបមិនមែនហេតុ មិនមែនបច្ច័យឱ្យដល់ការកើត ។ កាលមានអ្នកពោលថា "មគ្គដែលបានហើយ រមែងកំណត់" ដូច្នេះ មគ្គខាងលើ ៣ ក៏មិនមានកិច្ច (គឺមិនមានមុខនាទី), បឋមមគ្គប៉ុណ្ណោះមានមុខនាទី, មគ្គខាងលើ ៣ មានមុខនាទី, ព្រោះមគ្គខាងលើ ៣ មិនបានញ៉ាំងបឋមមគ្គឱ្យកើត ហើយទើបកើតឡើង, ក៏កិលេសទាំងឡាយគប្បីអស់ទៅមិនកើតឡើង ដោយបឋមមគ្គប៉ុណ្ណោះ; ព្រោះហេតុដូច្នោះ ធម៌ណាៗ ដទៃរមែងកំណត់ភពនោះ, វិបស្សនារបស់មគ្គ ៣ ខាងលើនោះឯង រមែងកំណត់ ។ ពិតមែន បើវិបស្សនារបស់សោតាបន្នបុគ្គលទាំងនោះ ជាធម៌មានបញ្ញាជ្រាលជ្រៅក្លៀវក្លានាំទៅ, បុគ្គលនោះញ៉ាំងភពមួយប៉ុណ្ណោះឱ្យកើតឡើង ហើយក៏ពន្លុះព្រះអរហត្ត បរិនិព្វាន ។ បើមានបញ្ញាអន់ជាងនោះ ក៏ញ៉ាំងភពទី ២-៣-៤-៥-៦ ឱ្យកើតហើយ ពន្លុះអរហត្តបរិនិព្វាន ។ អ្នកមានបញ្ញាអន់ជាងបុគ្គលទាំងអស់ ញ៉ាំងភពទី ៧ ឱ្យកើតឡើងហើយពន្លុះព្រះអរហត្ត, បដិសន្ធិក្នុងភពទី ៨ របស់លោក ទើបមិនមាន ។ ដោយប្រការដូច្នេះ ការកំណត់នេះ ទើបត្រឹមតែជាឈ្មោះដែលព្រះសម្មាសម្ពុទ្ធទ្រង់កាន់យកហើយ ។

ពិតមែន ព្រះសាស្ដាទ្រង់ពិចារណាហើយ ដោយការពិចារណារបស់ព្រះពុទ្ធជាម្ចាស់ ទើបទ្រង់កំណត់ទុកដោយព្រះសព្វញ្ញុតញ្ញាណថា "បុគ្គលនេះមានបញ្ញាច្រើនជាង ជនទាំងពួង មានវិបស្សនាជ្រាលជ្រៅ និងញ៉ាំងភពទីមួយប៉ុណ្ណោះឱ្យកើតហើយកាន់យកព្រះអរហត្ត" ដូច្នេះ ទើបបានទ្រង់ធ្វើ ឈ្មោះថា **ឯកពីជី**; បុគ្គល

នេះ ញុំាងភពទី ២ ទី ៣ ទី ៤ ទី ៥ និងទី ៦ ឱ្យកើតហើយកាន់យកព្រះអរហត្ត និងទ្រង់ធ្វើ ឈ្មោះថា **កោលង្កោលៈ** និងបុគ្គលនេះ ញុំាងភពទី ៧ ឱ្យកើតឡើង នឹងកាន់យកព្រះអរហត្ត និងទ្រង់ធ្វើ ឈ្មោះថា **សត្តក្ខត្តុបរមៈ** ។ ក៏បុគ្គលណា១ ឈ្មោះថា ទៀង រមែងមិនមានដល់ភពទាំង ៧, តែព្រះអរិយសាវ័កអ្នកមានបញ្ញាតិចជាង ដោយអាការសូម្បីយ៉ាងណាមួយ លោកក៏មិនដល់ភពទី ៨ រមែងបរិនិព្វាន ក្នុងចន្លោះភពនោះឯង ។ ពិតមែន ព្រះសោតាបន្នអ្នកត្រេកអរក្រៃលែងក្នុងភព សូម្បីដូចនឹងស្ដេចសក្កៈរមែងទៅកាន់ភពទី ៧ ប៉ុណ្ណោះ, សូម្បីប្រក្រតីនៅដោយសេចក្ដីប្រមាទដោយអាការទាំងពួង, វិបស្សនាញាណរបស់លោក ក៏រមែងដល់សេចក្ដីចាស់ក្លាជុំវិញក្នុងភពទី ៧ ។ ព្រោះកាលលោកធុញទ្រាន់ក្នុងអារម្មណ៍ សូម្បីមានប្រមាណតិច រមែងពន្លះហើយបរិនិព្វានបាន ។ ក៏សូម្បីកាលបើលោកឈានចុះកាន់ការបិទភ្នែក ឬកំពុងដើរទៅមានអ្នកណា១ ដែលនឹងប្រទូសរ៉ាយឈរនៅក្នុងទីកំបាំងខាងក្រោយ គប្បីញុំាងសីរៈរបស់លោកឱ្យធ្លាក់ទៅដោយដាវដ៏មុត, ឬគប្បីចាប់លោកសង្កត់ចុះក្នុងទឹកឱ្យស្លាប់, ឬក៏ផ្ទេកបន្ទោរ (រន្ទះបាញ់) គប្បីសង្កត់លើសីសៈឱ្យធ្លាក់ចុះសូម្បីក្នុងវេលាដូច្នេះ ឈ្មោះថា ធ្វើកាលៈមានបដិសន្ធិក្នុងភពទី ៨ ទៀត រមែងមិនមាន, រមែងនឹងពន្លុះព្រះអរហត្តនោះឯងហើយបរិនិព្វាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា "ព្រះសោតាបន្នគប្បីញុំាងភពទី ៧ ឱ្យកើត មិនមែនឋានៈដែលមានបានឡើយ" ៕

## អធិប្បាយលោកធាតុពុទ្ធក្ខេត្ត

ពាក្យថា "**ឯកិស្សា លោកធាតុយា** = ក្នុងលោកធាតុជាមួយគ្នា" បានដល់ លោកធាតុមានចំនួនមួយម៉ឺន ។ ពិតមែន វិហារអ្នកកាន់ព្រះពុទ្ធសាសនា (ខេត្តានិ) មាន ៣ គឺ **ជាតិក្ខេត្តំ** (ជាតិខេត្ត) **អាណាខេត្តំ** (អាណាខេត្ត) **វិសយក្ខេត្តំ** (វិស័យខេត្ត) ។

បណ្តាខេត្តទាំងនោះ លោកធាតុមានចំនួនមួយម៉ឺន ឈ្មោះថា ជាតិខេត្ត (កំណត់ដោយជាតិ); ពិតមែន ម៉ឺនលោកធាតុនោះរមែងញាប់ញ័រ ក្នុងកាលដែលព្រះតថាគត ស្តេចចុះកាន់គភ៌របស់ព្រះមាតា, ក្នុងកាលដែលស្តេចចេញមហាភិនេស្រ្កម, ក្នុងកាលដែលស្តេចត្រាស់ដឹងព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ, ក្នុងកាលញ៉ាំងព្រះធម្មចក្រឱ្យប្រព្រឹត្តទៅ, ក្នុងកាលដាក់ព្រះជន្មាយុសង្ខារ និងក្នុងកាលទ្រង់បរិនិព្វាន ។

ក៏ចក្រវាលចំនួនសែនកោដិចក្រវាល ឈ្មោះថា អាណាខេត្ត (កំណត់ដោយអំណាច); ពិតមែន អាណា (អំណាច) នៃអាដានាដិយបរិត្ត មោរបរិត្ត ធជគ្គបរិត្ត និងរតនបរិត្តជាដើម រមែងប្រព្រឹត្ត (លាតត្រដាង) ទៅ ក្នុងសែនកោដិចក្រវាលនេះ ។

តែថា ការកំណត់នូវវិស័យខេត្តរមែងមិនមាន; ពិតមែន ព្រោះបាលីថា "ញាណរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ មានប្រមាណប៉ុនណា, ធម៌ដែលព្រះអង្គគប្បីបង្ហោនទៅ (មានសេចក្តីប្រាថ្នានឹងដឹង) ក៏មានប្រមាណប៉ុណ្ណោះ, ធម៌ដែល

ព្រះអង្គគប្បីបង្អោនទៅ មានប្រមាណប៉ុនណា; ញាណក៏មានប្រមាណប៉ុណ្ណោះ, ធម៌ដែលគប្បីបង្អោនទៅ មានទីបំផុតដោយព្រះញាណ, ញាណក៏មានទីបំផុតដោយធម៌ដែលគប្បីបង្អោនទៅ”[៣០] ដូច្នេះ ឈ្មោះថា ដូចវិស័យព្រះពុទ្ធជាម្ចាស់ទាំងឡាយរមែងមិនមាន ។

ក៏ពុទ្ធក្ខេត្តទាំង ៣ នោះ ពាក្យថា “វៀរចក្រវាលនេះ ព្រះពុទ្ធជាម្ចាស់ទាំង-ឡាយ រមែងត្រាស់ដឹងឡើងក្នុងចក្រវាលដទៃ” ដូច្នេះ ជាសូត្រ (ពាក្យដែលត្រាស់ទុក) មិនមាន ។ តែពាក្យថា “ព្រះពុទ្ធជាម្ចាស់ទាំងឡាយរមែងមិនទ្រង់ឧប្បត្តិឡើង” ដូច្នេះ ជាសូត្រនៅមាន ។ ពាក្យថា “បិដក ៣ គឺ វិនយបិដក សុត្តន្តបិដក និងអភិធម្មបិដក” ដូច្នេះ និងពាក្យថា “សង្គីតិ ៣ គឺ សង្គីតិរបស់ព្រះមហាកស្ស-បត្ថេរ, របស់ព្រះមហាយសត្ថេរ និងរបស់ព្រះមហាមោគ្គលីបុត្តតិស្សត្ថេរ” ដូច្នេះមាន ។ ពាក្យថា “ក្រៅអំពីចក្រវាលនេះ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ រមែងទ្រង់ឧប្បត្តិឡើងក្នុងចក្រវាលដទៃ” ដូច្នេះ មិនមានសូត្រក្នុងព្រះត្រៃបិដក គឺពុទ្ធវចនៈដែលព្រះសង្គីតិកាចារ្យទាំងឡាយ លើកឡើងកាន់សង្គីតិទាំង ៣ លើកនេះ ។ តែពាក្យថា “ព្រះពុទ្ធជាម្ចាស់ទាំងឡាយ រមែងមិនទ្រង់ឧប្បត្តិឡើង” ដូច្នេះ ជាសូត្រនៅមាន ។

ពាក្យថា **“អបុព្វំ អចរិមំ”** បានដល់ ទ្រង់មិនឧប្បត្តិឡើងព្រមគ្នា គឺមិនមុន មិនក្រោយគ្នា ។ ព្រះមានព្រះភាគទ្រង់អធិប្បាយទុកថា “ព្រះពុទ្ធទាំងឡាយ

---

[៣០] ខុ. បដិ.។

រមែងទ្រង់ឧប្បត្តិឡើងមុន ឬក្រោយគ្នា (មិនមែនព្រមគ្នា) ” ដូច្នេះ មាន ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា “មុន ឬក្រោយ” ដូច្នេះ ៖

រាប់ចាប់ផ្ដើមអំពីការចុះកាន់បដិសន្ធិក្នុងគភ៌របស់មាតា រហូតដល់យាង ប្រថាប់គង់ត្រង់កន្លែងពោធិបល្លង្ក ទ្រង់តាំងព្រះទ័យយ៉ាងមាំថា “បើយើងនៅមិន ពន្លុះព្រះពោធិញ្ញាណទេ នឹងមិនក្រោកឡើងឡើយ” , សេចក្ដីនេះមិនគប្បីជ្រាបថា “ជាកាលមុន” ; ពិតមែន ការកំណត់ជាតិខេត្តក្នុងការកាន់យកបដិសន្ធិរបស់ព្រះ ពោធិសត្វ លោកធ្វើអធិប្បាយទុកថា ដោយការកម្រើកញាប់ញ័រនៃចក្រវាលមួយ ម៉ឺន ។ ក្នុងចន្លោះនេះ ការកើតឡើងនៃព្រះពុទ្ធជាម្ចាស់អង្គដទៃ ជាសភាពដែល លោកហាមទុកហើយ និងចាប់ផ្ដើមអំពីការបរិនិព្វាន ព្រះធាតុសូម្បីមានប្រមាណ ប៉ុនគ្រាប់ស្ពៃ ដរាបណាឋិតនៅ, ដរាបនោះ បណ្ឌិតមិនគប្បីជ្រាបថា ជាកាល ក្រោយឡើយ ។ ពិតមែន កាលព្រះបរមធាតុទាំងឡាយនៅតាំងនៅ (ឈ្មោះថា) នៅស្ថិតនៅនោះឯង; ព្រោះហេតុដូច្នោះ ក្នុងចន្លោះនៃព្រះពុទ្ធអង្គដទៃ រមែងជា សភាវៈដែលលោកហាមទុកហើយមែនពិត ។ ក៏កាលព្រះធាតុបរិនិព្វានហើយ ការ កើតឡើងនៃព្រះពុទ្ធអង្គដទៃដែលអ្វីៗ មិនបានហាមឃាត់សោះឡើយ ៕

## អន្តរធាន ៣ យ៉ាង

ពិតមែន ឈ្មោះថា **អន្តរធាន** (សេចក្ដីវិនាស) មាន ៣ យ៉ាង គឺ

**១. បរិយត្តិអន្តរធាន** វិនាសទៅនៃការរៀនព្រះត្រៃបិដក

**២. បដិបត្តិអន្តរធាន** វិនាសទៅនៃការបដិបត្តិ

**៣. បដិវេធអន្តរធាន** វិនាសទៅនៃការចាក់ធ្លុះមគ្គផល ។

ក្នុងបណ្តាអន្តរធាន ៣ យ៉ាងនោះ ព្រះត្រៃបិដក ឈ្មោះថា **បរិយត្តិ**; ការចាក់ធ្លុះនូវសច្ចៈ ឈ្មោះថា **បដិវេធ**; បដិបទា ឈ្មោះថា **បដិបត្តិ** ។ ក្នុងពាក្យទាំងនោះ បដិវេធ និងបដិបត្តិ មាននៅខ្លះ មិនមាននៅខ្លះ; ពិតមែន ភិក្ខុជាពហុស្សូតអ្នកធ្វើនូវបដិវេធ មាននៅក្នុងកាលម្តងម្កាល, ដែលបណ្ឌិតគប្បីលាម្រាមដៃចេញសម្តែងថា "អ្នកនេះមិនមែនជាភិក្ខុបុថុជ្ជន" ដូច្នេះ ក្នុងកាលនោះនៅមាន ។ បានឮថា ក្នុងកោះនេះឯង ក្នុងគ្រាមួយ ក៏ឈ្មោះថា ភិក្ខុដែលនៅជាបុថុជ្ជន មិនបានមានហើយ ។ សូម្បីភិក្ខុអ្នកបំពេញបដិបត្តិក្នុងកាលខ្លះ ក៏មានច្រើន, គ្រាខ្លះ ក៏មានតិច ។ ដោយប្រការដូច្នេះ បដិវេធ និងបដិបត្តិ ទើបឈ្មោះថា នៅមានខ្លះ មិននៅមានខ្លះ ក៏បរិយត្តិ ឈ្មោះថា ជាប្រមាណក្នុងកាលតាំងនៅនៃព្រះសាសនា ។ ពិតមែន បណ្ឌិតស្តាប់ព្រះត្រៃបិដកហើយ ក៏រមែងញ៉ាំងបដិបត្តិ និងបដិវេធ សូម្បីទាំងពីរឱ្យពេញ ។ ដូចព្រះពោធិសត្វរបស់យើង ទាំងឡាយញ៉ាំងអភិញ្ញា ៥ (វេវរអាសវក្ខយញ្ញាណទី ៦) និងសមាបត្តិ ៧ ឱ្យកើតឡើងក្នុងសំណាក់អាឡារតាបសហើយ ទើបសួរបរិកម្ម ក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិ, តាបសនោះប្រាប់ថា "យើងមិនជ្រាប" ; ទើបយាងទៅកាន់សំណាក់របស់ ឧទកតាបសរាមបុត្រ ទ្រង់ប្រៀបធៀបគុណវិសេស ដែលព្រះអង្គពន្លុះហើយ ទ្រង់សួរបរិកម្មក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិ; ឧទកតាបសរាមបុត្រនោះប្រាប់ហើយ, ព្រះមហាសត្វទ្រង់ញ៉ាំងសមាបត្តិនោះ ឱ្យដល់ព្រមហើយ ក្នុងលំដាប់នៃពាក្យរបស់តាបសនោះៗ ឯង ។

ភិក្ខុអ្នកមានបញ្ញាក៏ដូច្នោះដែរ ស្តាប់ព្រះបរិយត្តិហើយ រមែងញ៉ាំងបដិបត្តិ និងបដិវេធសូម្បីទាំងពីរ ឱ្យពេញ ។ ដោយហេតុនោះ ទើបព្រះសាសនា ឈ្មោះថា "តាំងនៅហើយ ព្រោះការតាំងនៅមាំនៃព្រះបរិយត្តិ" ។

ក្នុងកាលណា បរិយត្តិនោះអន្តរធានទៅ, ក្នុងកាលនោះព្រះអភិធម្មបិដករមែងវិនាសទៅមុន; ក្នុងព្រះអភិធម្មនោះ គម្ពីរបដ្ឋានរមែងអន្តរធានទៅមុនគម្ពីរទាំងអស់, រមែងអន្តរធានតមកដោយលំដាប់, ធម្មសង្គហៈរមែងអន្តរធានទៅខាងក្រោយ, កាលព្រះអភិធម្មបិដកនោះអន្តរធានទៅអស់ហើយ បិដកទាំងពីរក្រៅនេះសូម្បីតាំងនៅហើយ ព្រះសាសនា ក៏ឈ្មោះថា ស្ថិតនៅដែរ ។

បណ្តាបិដក ២ ដ៏សេសនោះ កាលព្រះសុត្តន្តបិដកនឹងអន្តរធានទៅ អង្គុត្តរ-និកាយទាំងឡាយ (ព្រះសូត្រដែលចែកធម៌ចេញទៅជាពួក១) រមែងអន្តរធានតាំងអំពីឯកាទសកនិបាត ចុះមកដល់ឯកនិបាតមុន, ក្នុងលំដាប់នោះ សំយុត្តនិកាយទាំងឡាយ (ព្រះសូត្រសម្តែងរឿងបុគ្គលជាប្រភេទ១) រមែងអន្តរធានតាំងអំពីចលក្កបេយ្យាលសូត្រចុះ មកដល់ឱឃតរណសូត្រ, ក្នុងលំដាប់នោះមជ្ឈិមនិកាយទាំងឡាយ (ព្រះសូត្ររឿងវែងល្មម) រមែងអន្តរធានតាំងអំពីឥន្ទ្រិយភាវនាសូត្រចុះមកដល់មូលបរិយាយសូត្រ, លំដាប់នោះ ទីឃនិកាយ (ព្រះសូត្ររឿងវែង) រមែងអន្តរធានតាំងអំពីទសុត្តរសូត្រ ចុះមកដល់ព្រហ្មជាលសូត្រ ។ ពាក្យបុច្ឆានៃគាថាមួយក្តី ពីរក្តី រមែងប្រព្រឹត្តទៅយូរ, តែពាក្យបុច្ឆានោះ រមែងមិនអាចដើម្បីញ៉ាំងព្រះសាសនាឱ្យស្ថិតនៅ ដូចសភិយបុច្ឆា និងអាឡវកបុច្ឆា; បានឮថា ពាក្យសួរទាំងពីរនេះ ចន្លោះកាលនៃព្រះពុទ្ធព្រះនាមថា **កស្សបៈ** ក៏មិនអាចញ៉ាំងសាសនា

ឱ្យតាំងនៅបាន ។

ក៏កាលបិដកទាំងពីរ សូម្បីអន្តរធានទៅហើយ **តែកាលព្រះវិនយបិដកនៅតាំងនៅ ព្រះសាសនា ក៏ឈ្មោះថា ស្ថិតនៅ** ។ កាលបរិវារៈ និងខន្ធកៈទាំងឡាយ អន្តរធានទៅហើយ តែឧភតោវិភង្គ* ស្ថិតនៅ ព្រះសាសនា ក៏ឈ្មោះថា ស្ថិតនៅនោះឯង ។ កាលឧភតោវិភង្គអន្តរធានទៅហើយ តែមាតិកាសូម្បីស្ថិតនៅ ព្រះ សាសនា ក៏នៅតែស្ថិតនៅនោះឯង; កាលមាតិកាអន្តរធានទៅហើយ តែព្រះបាតិមោក្ខ ការបព្វជ្ជា និងឧបសម្បទាស្ថិតនៅ ព្រះសាសនាក៏រមែងស្ថិតនៅ ។ លិង្គ (ភេទ) រមែងដំណើរទៅ អស់កាលយូរ ។ ក៏វង្សនៃសមណៈអ្នកស្លៀកសំពត់ស (សេតវត្ថសមណវំសោ) មិនអាចដើម្បីទ្រទ្រង់ព្រះសាសនាទុក ចាប់ផ្តើមអំពីកាលនៃព្រះពុទ្ធព្រះនាមថា កស្សបៈ ។ រាប់តាំងអំពីការចាក់ធ្លុះសច្ចៈរបស់ជន អ្នកកើតខាងក្រោយតាំងតែអំពីសីលភេទ គឺការបែកទៅនៃសីលរបស់បុគ្គលអ្នកកើតខាងក្រោយ (នៃពុទ្ធកាលហើយ) អំពីនោះមក ព្រះសាសនា ឈ្មោះថា រមែងថយចុះ ។ ចាប់ផ្តើមអំពីនោះមក ការកើតឡើងនៃព្រះពុទ្ធជាម្ចាស់អង្គដទៃ ដែលអ្វីៗ មិនបានហាមទុកឡើយ ៕

## បរិនិព្វាន ៣ យ៉ាង

ឈ្មោះថា បរិនិព្វាន មាន ៣ គឺ ៖

---

* វិភង្គមានពីរ គឺ ភិក្ខុវិភង្គ និងភិក្ខុនីវិភង្គ ។

- **កិលេសបរិនិព្វាន** អស់កិលេស
- **ខន្ធបរិនិព្វាន** អស់ខន្ធ
- **ធាតុបរិនិព្វាន** អស់ធាតុ ។

បណ្ដានិព្វានទាំងនោះ **កិលេសបរិនិព្វាន** (ការរំលត់នៃកិលេស) បានមានហើយ ត្រង់ពោធិបល្ល័ង្ក ។

**ខន្ធបរិនិព្វាន** (ការរំលត់នៃខន្ធ) បានមានហើយត្រង់នគរកុសិនារា។

**ធាតុបរិនិព្វាន** (ការរំលត់នៃព្រះធាតុ) នឹងមានក្នុងអនាគតកាល ។

បានឮថា ក្នុងកាលនៃព្រះសាសនាសាបសូន្យ ព្រះធាតុទាំងឡាយត្រង់តម្ពបណ្ណិទ្វីប (កោះលង្កា) នេះ * នឹងប្រជុំគ្នាហើយយាងទៅកាន់មហាចេតិយ, ចេញអំពីនោះ នឹងយាងទៅកាន់រាជាយតនចេតិយក្នុងនាគទ្វីប, តអំពីនោះនឹងទៅកាន់មហាពោធិបល្ល័ង្ក, ព្រះធាតុទាំងឡាយពីពិភពនាគក្ដី ពីទេវលោកក្ដី ពីព្រហ្មលោកក្ដី នឹងយាងទៅកាន់ដើមមហាពោធិបល្លង្កប៉ុណ្ណោះ ។ ព្រះធាតុសូម្បីមានប្រមាណប៉ុនគ្រាប់ស្ពៃ នឹងមិនបាត់បង់ទៅក្នុងចន្លោះផ្លូវឡើយ ។ ព្រះធាតុទាំងអស់ នឹងប្រជុំរួមគ្នា ដូចជាដុំមាសដែលគរទុកត្រង់មហាពោធិបល្ល័ង្ក ហើយបញ្ចេញនូវពន្លឺឆព្វណ្ណរង្សី (រស្មីមានពណ៌ ៦), ឆព្វណ្ណរង្សីនោះ នឹងលាតត្រដាង (ផ្សាយ) រហូតម៉ឺនលោកធាតុ ។ លំដាប់នោះ ទេវតាក្នុងម៉ឺនចក្រវាលនឹងមកប្រជុំគ្នា និងធ្វើសេចក្ដីករុណាដ៏ធំក្រៃលែង ជាងថ្ងៃដែលព្រះទសពលបរិនិព្វាន ហើយនឹងពោលថា "ថ្ងៃនេះ ព្រះសាស្ដានឹងបរិនិព្វាន, ថ្ងៃនេះព្រះសាសនានឹងសាបសូន្យ, ឥឡូវនេះ

---

* បានជាលោកប្រើពាក្យដូច្នេះ ព្រោះគម្ពីរនេះ លោក (ព្រះពុទ្ធឃោសាចារ្យ) រចនានៅកោះលង្កា ។

ការឃើញរបស់យើងនេះ ជាការឃើញចុងក្រោយ” ដូច្នេះ, បុគ្គលដ៏សេសទាំងអស់ វៀវព្រះអនាគាមី និងព្រះខីណាស្រពហើយ នឹងមិនអាចដើម្បីទ្រទ្រង់ទុកនូវភារៈរបស់ខ្លួនបានឡើយ ។ លំដាប់នោះ តេជោធាតុក្នុងព្រះធាតុទាំងឡាយ នឹងតាំងឡើងហើយ បញ្ចេញពន្លឺទៅដល់ព្រហ្មលោក, កាលព្រះធាតុ សូម្បីមានប្រមាណប៉ុនគ្រាប់ស្ពៃ នៅមានអណ្តាតអគ្គីមួយនឹងមាន, គ្រាព្រះធាតុទាំងឡាយ ដល់ការអស់ហើយ អណ្តាតភ្លើងនោះក៏រលត់ ។ លុះព្រះធាតុទាំងឡាយ សម្តែងអានុភាពដ៏ធំ ដោយប្រការដូច្នេះហើយ ក៏អន្តរធានអស់ទៅ ព្រះសាសនា ឈ្មោះថាអន្តរធានអស់ហើយ ។ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ គប្បីឧប្បត្តិឡើងព្រមគ្នាទាំងពីរព្រះអង្គ សេចក្តីនេះឯង មិនជាឋានៈដែលមានបាន ដោយប្រការដូច្នេះ ។

សួរថា ព្រោះហេតុអ្វីព្រះពុទ្ធជាម្ចាស់ទាំងឡាយ មិនឧប្បត្តិឡើងព្រមគ្នា ?

ឆ្លើយថា ព្រោះមិនមានសេចក្តីអស្ចារ្យ ។

ពិតមែន ព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គសុទ្ធតែជាមនុស្សអស្ចារ្យ ។ ដូចយ៉ាងដែលបានត្រាស់ទុកថា ៖

**“ម្នាលភិក្ខុទាំងឡាយ បុគ្គលម្នាក់ កាលកើតឡើងក្នុងលោក រមែងកើតឡើងជាមនុស្សអស្ចារ្យ, បុគ្គលមួយជាយ៉ាងណា, ម្នាលភិក្ខុទាំងឡាយ បុគ្គលមួយនោះ គឺព្រះតថាគតដែលជាអរហន្តសម្មាសម្ពុទ្ធជាម្ចាស់”** [៣១] ។

ម្យ៉ាងទៀត បើព្រះពុទ្ធជាម្ចាស់ ២ ព្រះអង្គ ឬ ៣-៤-៨ ឬ ១៦ ព្រះអង្គ គប្បីកើតឡើងព្រមគ្នាសោត, សេចក្តីអស្ចារ្យទាំងឡាយ ក៏មិនគប្បីមាន ។ ព្រោះ

---

[៣១] អំ. ឯកក. ។

ថា សូម្បីលាភសក្ការៈនៃចេតិយពីរក្នុងវិហារតែមួយ មិនមានឱឡារៈ (ធំ) សូម្បីតែភិក្ខុទាំងឡាយ ក៏មិនអស្ចារ្យ, ព្រោះហេតុនោះ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទើបទ្រង់មិនឧប្បត្តិឡើងព្រមគ្នា ដោយប្រការដូច្នេះ និងព្រោះធម្មទេសនា ក៏ជាសភាវៈមិនប្លែកគ្នាឡើយ ។ ពិតមែន ព្រះពុទ្ធជាម្ចាស់មួយព្រះអង្គ រមែងសម្ដែងធម៌ មានសតិបដ្ឋានជាដើម, ព្រះធម៌នោះឯង ដែលព្រះពុទ្ធជាម្ចាស់អង្គដទៃ ក៏សម្ដែងបាន; ភាពអស្ចារ្យ ក៏មិនគប្បីមាន, តែកាលព្រះពុទ្ធជាម្ចាស់មួយអង្គសម្ដែងធម៌ សូម្បីទេសនាក៏ជាធម៌អស្ចារ្យ; និងព្រោះមិនកើតសេចក្ដីទាស់ទែងផង; ព្រោះថា កាលបើព្រះពុទ្ធច្រើនព្រះអង្គ ទ្រង់ឧប្បត្តិឡើងព្រមគ្នាហើយ សាវ័កទាំងឡាយក៏នឹងគប្បីពោលទាស់ទែងគ្នានឹងគ្នាថា "ព្រះពុទ្ធជាម្ចាស់របស់ពួកយើង ជាអ្នកគួរជ្រះថ្លា, ព្រះពុទ្ធជាម្ចាស់របស់ពួកយើង មានសំឡេងពីរោះ មានលាភ និងមានបុណ្យ" ដូច្នេះ, ដូចអន្តេវាសិករបស់អាចារ្យច្រើននាក់ ពោលជំទាស់ដណ្ដើមគ្នា ។ ព្រោះហេតុនោះឯង ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទើបមិនកើតឡើងព្រមគ្នា ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ដោយហេតុនេះ ព្រះនាគសេនត្ថេរ ដែលព្រះបាទមិលិន្ទទ្រង់សួរហើយ ទើបឱ្យពិស្ដារហើយមែនពិត ។

ក៏ក្នុងរឿងនោះ លោកពោលទុកដូច្នេះ ៖

**មិលិន្ទបញ្ហា**

**"ទ្វិន្នំ ពុទ្ធានំ លោកេ នុប្បជ្ជនបញ្ហា**

បញ្ហាដោយការមិនឧប្បត្តិឡើងនៃព្រះពុទ្ធ ២ ព្រះអង្គក្នុងលោក"

**ព្រះបាទមិលិន្ទត្រាស់សួរថា** បពិត្រព្រះនាគសេន សូម្បីព្រះពុទ្ធវចនៈនេះ ព្រះមានព្រះភាគជ្រាបហើយត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តសម្មាសម្ពុទ្ធទាំង ២ ព្រះអង្គ គប្បីកើតឡើងមិនមុនមិនក្រោយព្រមគ្នា ក្នុងលោកធាតុតែមួយ ដោយហេតុណា, ព្រោះហេតុនោះ មិនមែនជាឋានៈដែលមានបាន”[៣២] ដូច្នេះ ព្រោះហេតុអ្វី ?

ព្រះនាគសេនថេរទូលថា “សូមថ្វាយព្រះពរមហាបពិត្រ ព្រះតថាគត សូម្បីទាំងអស់ កាលទ្រង់សម្តែងធម៌ រមែងទ្រង់សម្តែងធម៌ទាំងឡាយ ដែលជាចំណែកនៃបញ្ញាគ្រឿងត្រាស់ដឹង ៣៧ ប្រការប៉ុណ្ណោះ ( ពោធិបក្ខិយធម៌ ៣៧ ប្រការ) , ក៏កាលនឹងត្រាស់ រមែងត្រាស់អរិយសច្ចទាំង ៤, ក៏កាលនឹងឱ្យសិក្សា រមែងឱ្យសិក្សាក្នុងសិក្ខាទាំង ៣, ក៏កាលបង្រៀន រមែងបង្រៀនក្នុងការបដិបត្តិ ដើម្បីសេចក្តីមិនប្រមាទ” ។

ព្រះរាជាត្រាស់សួរថា “បពិត្រលោកនាគសេន បើថា ទេសនារបស់ព្រះតថាគត សូម្បីទាំងអស់ដូចគ្នា កថាក៏ដូចគ្នា សិក្ខាក៏ដូចគ្នា និងការបង្រៀន ក៏ដូចគ្នា, ព្រោះហេតុអ្វី ព្រះតថាគត ២ ព្រះអង្គ ទើបមិនកើតឡើងក្នុងពេលតែមួយទៅ ?; ម្យ៉ាងទៀត លោកនេះមានពន្លឺកើតឡើង ដោយការកើតឡើងនៃព្រះពុទ្ធ សូម្បីមួយអង្គមុន ។

បើថា ព្រះពុទ្ធអង្គទី ២ គប្បីកើតឡើងសោត, លោកនេះ នឹងគប្បីមានពន្លឺកើតឡើងលើសប្រមាណដោយពន្លឺនៃព្រះពុទ្ធជាម្ចាស់ទាំង ២ ព្រះអង្គ មិនមែនឬ ?

---

[៣២] ម. ឧ., អំ. ឯកក. ។

ក៏ព្រះតថាគតទាំង ២ កាលនឹងឱ្យឱវាទ ក៏គប្បីឱ្យឱវាទងាយស្រួល, កាលនឹងបង្រៀន គប្បីបង្រៀនងាយស្រួល មិនមែនឬ ?, សូមលោកម្ចាស់សម្តែងហេតុក្នុងសេចក្តីនោះ ដល់ខ្ញុំព្រះករុណា១ នឹងគប្បីអស់សេចក្តីសង្ស័យយ៉ាងណា ។

ព្រះថេរៈទូលថា "សូមថ្វាយព្រះពរមហាបពិត្រ មួយម៉ឺនលោកធាតុនេះទ្រព្រះពុទ្ធជាម្ចាស់បានត្រឹមតែមួយព្រះអង្គ, រមែងទ្រគុណរបស់ព្រះតថាគតបានមួយព្រះអង្គប៉ុណ្ណោះ, បើថាព្រះពុទ្ធជាម្ចាស់អង្គទីពីរ គប្បីកើតសោត, សូម្បីមួយម៉ឺនលោកធាតុនេះ ក៏នឹងគប្បីទ្រទុកមិនបាន, គប្បីកម្រើក ញាប់ញ័រ បង្អោនទៅស្រុតចុះ គ្រវីគ្រវាត់ (ឃ្លេងឃ្លោង) រប៉ាត់រប៉ាយ ខ្ចាត់ខ្ចាយ និងចូលដល់ការតាំងនៅមិនបាន ។

សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចទូកដែលនាំឆ្លងកាត់ច្រាំងទៅបានតែមនុស្សម្នាក់, កាលបុរសម្នាក់ឡើងហើយ ទូកនោះ ក៏គប្បីឱ្យដល់ច្រាំងបាន, បើថា បុរសអ្នកទីពីរ គប្បីមកសោត ហើយគេក៏ជាមនុស្សដូចគ្នា ដោយអាយុដោយវណ្ណៈ ដោយវ័យជាប្រមាណ និងដោយអវយវៈតូចធំ ស្គម ឬធាត់ (ខ្នាតដូចគ្នា), បុរសអ្នកទីពីរនោះ គប្បីឡើងកាន់ទូកនោះ, បពិត្រមហារាជ ទូកនោះគប្បីទ្របុរសទាំងពីរទុកបានឬ ?" ។

ព្រះរាជាត្រាស់ថា "មិនបានទេ ព្រះគុណម្ចាស់ដ៏ចម្រើន, ទូកនោះគប្បីកម្រើក ឃ្លេងឃ្លោង គប្បីផ្អៀងទៅ គប្បីពេញព្រៀប គប្បីគ្រវីគ្រវាត់ គប្បីវិនាសទៅ គប្បីខ្ចាត់ខ្ចាយ, គប្បីចូលដល់សេចក្តីទ្រនៅមិនបាន, គប្បីលិចចុះក្នុងទឹក"។

ព្រះថេរៈពោលថា "សូមថ្វាយព្រះពរ ទូកនោះគប្បីទ្របុរសពីរនាក់មិនបាន

រមែងលិចចុះក្នុងទឹកយ៉ាងណា; មួយម៉ឺនលោកធាតុនេះ ទ្រព្រះពុទ្ធជាម្ចាស់ទុកបាន ត្រឹមតែមួយព្រះអង្គ, ទ្រគុណរបស់ព្រះតថាគតបានត្រឹមតែមួយព្រះអង្គ, បើថា ព្រះពុទ្ធជាម្ចាស់អង្គទីពីរ គប្បីឧប្បត្តិឡើង, មួយម៉ឺនលោកធាតុគប្បីទ្រទុកមិនបាន, គប្បីកម្រើក ញាប់ញ័រ ផ្អៀងចុះ ស្រុតចុះ គ្រវីគ្រវាត់ របាត់របាយ ខ្ចាត់ខ្ចាយ និង គប្បីចូលដល់ការតាំងនៅមិនបាន ក៏យ៉ាងនោះដែរ ។

បពិត្រមហារាជ ម្យ៉ាងទៀត ប្រៀបដូចបុរសគប្បីបរិភោគអាហារតាម ត្រូវការ គេញ៉ាំងអាហារដែលពេញចិត្តឱ្យពេញដល់កន្ត្រែតហើយ, បរិបូណ៌ហើយ មិនមានប្រហោងចន្លោះ ដែលដល់ភាវៈជាអ្នកខ្ជិលច្រអូស ដូចជាកំណាត់ឈើនោះ មិនលិចចុះ ហើយគប្បីបរិភោគអាហារទៀតនោះឯង, បពិត្រមហារាជ បុរសនោះ គប្បីមានសេចក្តីសុខខ្លះឬ ?" ។

ព្រះរាជាត្រាស់ថា "បពិត្រព្រះគុណម្ចាស់ មិនបានទេ, បុរសនោះគប្បី បរិភោគមួយគ្រានោះឯង ហើយក៏នឹងស្លាប់ទៅ" ដូច្នេះ ។

ព្រះថេរៈ : "សូមថ្វាយព្រះពរ សេចក្តីនេះយ៉ាងណា, មួយម៉ឺនលោកធាតុ នេះ ក៏យ៉ាងនោះដែរ ទ្រព្រះពុទ្ធជាម្ចាស់បានត្រឹមតែមួយព្រះអង្គ ទ្រគុណរបស់ ព្រះតថាគត ទុកបានត្រឹមតែមួយព្រះអង្គ បើថាព្រះពុទ្ធជាម្ចាស់អង្គទីពីរ គប្បីកើត ឡើងសោត មួយម៉ឺនលោកធាតុទ្រមិនបាន គប្បីកម្រើក រំកិល ផ្អៀងចុះ ស្រុតចុះ គ្រវីគ្រវាត់ របាត់របាយ ខ្ចាត់ខ្ចាយ និងគប្បីចូលដល់ការតាំងនៅមិនបានទេ ។

ព្រះរាជា : "បពិត្រលោកនាគសេន ផែនដីរមែងកម្រើក រំកិល ដោយ ទម្ងន់ធម៌ដ៏លើសឬ ?" ។

ព្រះថេរៈ : "សូមថ្វាយព្រះពរ ក្នុងសេចក្ដីនេះ រទេះ ២ ដឹក ពេញដោយរតនៈ រហូតស្មើមាត់, បុគ្គលគប្បីជញ្ជូនយករតនៈអំពីរទេះ ១ ដាក់ក្នុងរទេះក្រៅ ១, បពិត្រមហារាជ រទេះនោះគប្បីទ្រទ្រង់រតនៈនៃរទេះ សូម្បីទាំងពីរបានឬ ?" ។

ព្រះរាជា : "មិនបានទេ ព្រះគុណម្ចាស់, សូម្បីដុំរបស់រទេះ ក៏គប្បីពៀកទៅ, សូម្បីកាំរទេះនោះ ក៏គប្បីបាក់បែកទៅ, សូម្បីកង់របស់រទេះនោះ ក៏គប្បីបែកទៅ, សូម្បីភ្លៅរបស់រទេះនោះ ក៏គប្បីទម្លាយទៅ" ដូច្នេះ ។

ព្រះថេរៈ : "សូមថ្វាយព្រះពរ រទេះរមែងត្រូវទម្លាយទៅដោយទម្ងន់រតនៈដ៏លើសទៅឬ ?" ។

ព្រះរាជា : "យ៉ាងនោះឯង ព្រះគុណម្ចាស់" ។

ព្រះថេរៈ : "សូមថ្វាយព្រះពរ រទេះត្រូវទម្លាយទៅដោយទម្ងន់លើសយ៉ាងណា, ផែនដីក៏យ៉ាងនោះដែរ រមែងកម្រើកញ័រញាក់ដោយទម្ងន់រតនៈ គឺធម៌ដ៏លើសទៅ; ម្យ៉ាងទៀត មហាបពិត្រ អាត្មានឹងពន្យល់នូវហេតុសូម្បីដទៃ ដែលជាការសមល្មមក្នុងសេចក្ដីនេះទៀត សូមថ្វាយព្រះពរ ព្រះសម្មាសម្ពុទ្ធទាំងពីរព្រះអង្គ រមែងមិនកើតឡើងក្នុងខណៈជាមួយគ្នាដោយហេតុណា សូមមហាបពិត្រ ចូរស្ដាប់ហេតុនោះ" ដូច្នេះ ៖

បពិត្រមហារាជ បើថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ពីរព្រះអង្គ គប្បីកើតឡើងក្នុងខណៈជាមួយគ្នាសោត, សេចក្ដីវិវាទគប្បីកើតឡើងដល់បរិស័ទ, បរិស័ទនឹងគប្បីបែកពៀកចេញជាពីរចំណែក ដោយពាក្យថា "ព្រះពុទ្ធរបស់ពួកលោក, ព្រះពុទ្ធរបស់ពួកយើង" ដូច្នេះ; បពិត្រមហារាជ ប្រៀបដូចសេចក្ដីវិវាទ រមែងកើតដល់

បរិស័ទរបស់អាមាត្យអ្នកមានកម្លាំងទាំងពីរនាក់ រមែងកើតការបែកញែកថា “នេះអាមាត្យរបស់ពួកលោក, នេះអាមាត្យរបស់ពួកយើង” យ៉ាងណា, សូមថ្វាយព្រះ-ពរ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ពីរព្រះអង្គ បើថា គប្បីកើតឡើងក្នុងខណៈជាមួយគ្នាក៏យ៉ាងនោះដែរ, សេចក្តីវិវាទទាំងឡាយ គប្បីកើតឡើងដល់បរិស័ទរបស់ព្រះពុទ្ធជាម្ចាស់ទាំងពីរព្រះអង្គថា “ព្រះពុទ្ធរបស់ពួកលោក, ព្រះពុទ្ធរបស់ពួកយើង” ដូច្នេះ; បរិស័ទគប្បីកើតបែកញែកចេញជាពីរចំណែក នេះជាហេតុទីមួយ ។

ព្រះសម្មាសម្ពុទ្ធពីរព្រះអង្គ រមែងមិនទ្រង់ឧប្បត្តិឡើងក្នុងខណៈជាមួយគ្នាដោយហេតុណា, សូមមហាបពិត្រ ចូរស្តាប់នូវហេតុនោះ សូម្បីដទៃទៀត ឱ្យក្រៃលែងឡើងទៅចុះ ៖

បពិត្រមហារាជ បើថា ព្រះសម្មាសម្ពុទ្ធពីរព្រះអង្គ គប្បីកើតឡើងក្នុងខណៈជាមួយគ្នាសោត ពាក្យដែលថា “**ព្រះពុទ្ធជាអ្នកលើស**” នោះ ក៏គប្បីជាពាក្យខុស, ពាក្យដែលថា “**ព្រះពុទ្ធជាអ្នកប្រសើរ**” នោះ ក៏គប្បីជាពាក្យខុស, ពាក្យដែលថា “**ព្រះពុទ្ធជាអ្នកវិសេស**” នោះ ក៏គប្បីជាពាក្យខុស, ពាក្យដែលថា “**ព្រះពុទ្ធជាអ្នកខ្ពង់ខ្ពស់**” នោះ ក៏គប្បីជាពាក្យខុស, ពាក្យដែលថា “**ព្រះពុទ្ធជាអ្នកបវរ**” នោះ ក៏គប្បីជាពាក្យខុស, ពាក្យដែលថា “**ព្រះពុទ្ធជាម្ចាស់ មិនមានអ្នកណាស្មើ**” នោះ ក៏គប្បីជាពាក្យខុស, ពាក្យដែលថា “**ព្រះពុទ្ធជាម្ចាស់ព្រះអង្គស្មើដោយបុគ្គល មិនមានអ្នកស្មើ**” នោះក៏ខុស, ពាក្យដែលថា “**ព្រះពុទ្ធជាម្ចាស់មិនមានអ្នកប្រៀប**” នោះ គប្បីជាពាក្យខុស, ពាក្យដែលថា “**ព្រះពុទ្ធជាម្ចាស់មិនមានចំណែកប្រៀប**” ដូច្នេះ នោះក៏គប្បីជាពាក្យខុស, ពាក្យដែល

ថា "ព្រះពុទ្ធជាម្ចាស់រកបុគ្គលប្រៀបមិនបាន" ដូច្នេះ នោះក៏គប្បីជាពាក្យខុស; បពិត្រមហារាជ ព្រះអង្គចូរទទួលហេតុសូម្បីនេះឯង ដោយសេចក្តីពិតចុះ ។

ម្យ៉ាងទៀត មហាបពិត្រ ព្រះពុទ្ធជាម្ចាស់ ២ ព្រះអង្គមិនកើតឡើងក្នុងខណៈតែមួយដោយហេតុណា, សូមមហាបពិត្រ ចូរជ្រាបហេតុយ៉ាងនេះថា "ការឧប្បត្តិឡើងនៃព្រះពុទ្ធជាម្ចាស់ រមែងឧប្បត្តិឡើងក្នុងលោក ចំពោះព្រះអង្គតែមួយ, នេះជាប្រក្រតី ដោយសភាពរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ; ព្រោះហេតុអ្វី ? ព្រោះសេចក្តីដែលគុណរបស់ព្រះពុទ្ធជាម្ចាស់ អ្នកត្រាស់ហើយ អ្នកជាសព្វញ្ញូ ជារបស់ធំ ។

សូមថ្វាយព្រះពរ សូម្បីវត្ថុដទៃណាដែលជារបស់ធំក្នុងលោក, វត្ថុនោះក៏ជារបស់មានតែម្យ៉ាងប៉ុណ្ណោះ; ផែនដីណាដែលធំ, ផែនដីនោះមានតែមួយគត់; សាគរណាជារបស់ធំ, សាគរនោះ ក៏មានតែមួយប៉ុណ្ណោះ ។ ភ្នំសិនេរុណា ជារបស់ធំ, ភ្នំសិនេរុនោះ ក៏ជាភ្នំតែម្យ៉ាងប៉ុណ្ណោះ; អាកាសណាជារបស់ធំ, អាកាសនោះ ក៏ជាអាកាសតែមួយប៉ុណ្ណោះ; ស្តេចសក្កៈណាជាធំ, ស្តេចសក្កៈនោះ ក៏មានតែមួយអង្គប៉ុណ្ណោះ ។ មារណាជាធំ, មារនោះ ក៏មានតែម្នាក់ប៉ុណ្ណោះ; ព្រហ្មណាជាធំ, មហាព្រហ្មនោះ ក៏មានតែម្នាក់ប៉ុណ្ណោះ; ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ក៏ជាធំត្រឹមតែមួយព្រះអង្គប៉ុណ្ណោះក្នុងលោក ។ ផែនដីជាដើម រមែងមិនកើតឡើងក្នុងទីណា, ការប្រាកដរបស់ផែនដីជាដើម រមែងមិនមានក្នុងទីនោះ; ព្រោះហេតុដូច្នោះ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធតែមួយប៉ុណ្ណោះ ទើបឧប្បត្តិឡើងក្នុងលោក"ដូច្នេះ ។

ព្រះរាជា : "បពិត្រលោកម្ចាស់នាគសេន បញ្ហាលោកម្ចាស់ដោះស្រាយល្អហើយ ដោយហេតុទាំងឡាយដែលជាគ្រឿងឧបមា" ៕

# អធិប្បាយ

## ការកើតឡើងនៃព្រះបាទចក្រពត្តិ

ពាក្យថា **“ឯកិស្សា លោកធាតុយា”** បានដល់ ចក្រវាលមួយ ។ អធិប្បាយថា លោកកាន់យកហ្មឺនចក្រវាល ដោយបទថា **“ឯកិស្សា លោក-ធាតុយា”** ដូច្នេះនេះ ក្នុងកាលមុននុ៎ះឯង ។ សូម្បីការកំណត់ហ្មឺន ចក្រវាលទាំងនោះ ដោយចក្រវាលមួយនោះឯង ក៏គួរ ។ ព្រោះថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយកាលកើតរមែងកើតក្នុងចក្រវាលនេះប៉ុណ្ណោះ, ក៏កាលឋាន គឺការកើតឡើងដែលលោកហាមហើយ ក៏ឈ្មោះថា ហាមទុកហើយ ព្រោះព្រះពុទ្ធទាំងឡាយ រមែងមិនទ្រង់កើតក្នុងចក្រវាលដទៃៗ ក្រៅពីចក្រវាលនេះឡើយ ។ ក្នុងពាក្យថា **“អបុព្វំ** = មិនមុន, **អចរិមំ** មិនក្រោយ” បានដល់ ឈ្មោះថា មុន (បុព្វំ) ព្រោះមុនពីកាលដែលប្រាកដរបស់ចក្ករតនៈ ។ ឈ្មោះថា ក្រោយ (ចរិមំ) ព្រោះក្រោយអំពីចក្ករតនៈនោះនុ៎ះឯង អន្តរធានទៅហើយ ។ ក្នុងពាក្យនោះ ការអន្តរធាននៃចក្ករតនៈ មាន ២ គឺ ព្រោះការសុគតរបស់ព្រះបាទចក្រពត្តិ ឬថា ការបព្វជ្ជា; ម្យ៉ាង-ទៀត ចក្ករតនៈនោះកាលនឹងអន្តរធានរមែងអន្តរធានក្នុងថ្ងៃទី ៧ រាប់ពីការសុគត ឬបព្វជ្ជា ។ ខាងមុខពីនោះ សេចក្តីប្រាកដនៃព្រះបាទចក្រពត្តិអង្គដទៃ គឺលោកមិនបានហាមទុកឡើយ ។ ក៏ព្រោះហេតុអ្វី ព្រះបាទចក្រពត្តិពីរអង្គ ទ្រង់មិនបានឧប្បត្តិឡើងព្រមគ្នាក្នុងចក្រវាលតែមួយជាមួយគ្នា ? ព្រោះធ្វើឱ្យកើតការវិវាទ ព្រោះមិនជាវត្ថុអស្ចារ្យ និងព្រោះមានអានុភាពច្រើននៃចក្ករតនៈ ។ ពិតមែន កាលមានព្រះបាទចក្រពត្តិពីរអង្គ សេចក្តីវិវាទគប្បីកើតឡើងថា “ព្រះរាជារបស់ពួកយើងធំ, ព្រះរាជារបស់ពួកយើងធំ” ដូច្នេះ ។ ម្យ៉ាងវិញទៀត ការមិនមានភាព

អស្ចារ្យ គប្បីកើតឡើងថា “ក្នុងទ្វីបមួយមានព្រះបាទចក្រពត្តិ និងក្នុងទ្វីបមួយឯណោះ ក៏មាន ព្រះបាទចក្រពត្តិ” ដូច្នេះ; ក៏អ្នកណានេះ អាចថែមឱ្យចក្ករតនៈដើម្បីភាពជាធំក្នុងទ្វីបធំទាំង ៤ ដែលមានទ្វីបទាំងពីរពាន់ជាបរិវារ អានុភាពធំនៃចក្ករតនៈនោះ គប្បីសាបសូន្យទៅ; ព្រោះហេតុនោះ ព្រះបាទចក្រពត្តិពីរអង្គ ទើបឈ្មោះថា មិនកើតឡើងក្នុងចក្រវាលតែមួយ ព្រោះចូលទៅកាន់សេចក្តីវិវាទ ព្រោះសេចក្តីមិនអស្ចារ្យ និងព្រោះសេចក្តីមិនមានអានុភាពច្រើន (មានច្រើនកន្លែង) របស់ចក្ករតនៈ ៕

## អធិប្បាយស្ត្រីជាព្រះអរហន្តសម្មាសម្ពុទ្ធជាដើមមិនបាន

ក្នុងពាក្យថា **“យំ ឥត្ថី អរហំ អស្ស សម្មាសម្ពុទ្ធោ** = ស្ត្រីនឹងគប្បីជាព្រះសម្មាសម្ពុទ្ធជាម្ចាស់” នេះ អធិប្បាយថា ភាពជាព្រះពុទ្ធជាម្ចាស់ ព្រះអង្គអាចចម្លងលោក ព្រោះញុំាងគុណ គឺសព្វញ្ញូឱ្យកើតឡើងនោះ ចូរលើកទុកសិន, សូម្បីត្រឹមតែការតាំងបណិធាន (ការតាំងសេចក្តីប្រាថ្នា) ក៏រមែងមិនសម្រេចដល់ស្ត្រី ។

**មនុស្សត្តំ លិង្គសម្បត្តិ ហេតុ សត្ថារទស្សនំ**
**បព្វជ្ជា គុណសម្បត្តិ អធិការោ ច ឆន្ទតា**
**អដ្ឋធម្មសមោធានា អភិនីហារោ សមិជ្ឈតិ**

ពិតមែន ហេតុដែលជាបណិធានសម្បត្តិទាំងនេះ គឺអភិនីហារ (ការប្រាថ្នាតាំងចិត្តពិត) រមែងសម្រេចព្រមព្រោះធម្មសមោធាន (ការប្រជុំនៃធម៌) ៨ ប្រការ គឺ :

**១. មនុស្សត្តំ** ការតាំងសេចក្តីប្រាថ្នា ត្រូវតែជាកំណើតមនុស្ស

**២. លិង្គសម្បត្តិ** លិង្គសម្បត្តិ គឺភេទប្រុស

**៣. ហេតុ** មានហេតុ គឺសន្សំកុសលច្រើន សមគួរនឹងជាព្រះអរហន្តបាន ។

**៤. សត្ថារទស្សនំ** ជួបព្រះពុទ្ធ និងបានទទួលពុទ្ធព្យាករណ៍

**៥. បព្វជ្ជា** បួសជាភិក្ខុសាមណេរ ឬតសីអ្នកជាកម្មវាទី

**៦. គុណសម្បត្តិ** បរិបូណ៌ដោយគុណ គឺឈាន សមាបត្តិ និងអភិញ្ញា

**៧. អធិការោ** ការធ្វើកុសលដ៏ធំក្រៃលែង

**៨. ឆន្ទតា** ពេញចិត្តក្នុងពោធិញ្ញាណ[៤០] ។

សេចក្តីតាំងបណិធាន ប្រាថ្នាដើម្បីឱ្យដល់ភាពជាព្រះសម្មាសម្ពុទ្ធបាន ដោយអាការយ៉ាងនេះ ភាពជាព្រះពុទ្ធរបស់ស្ត្រី មិនអាចនឹងមានពីណា ព្រោះហេតុដូច្នោះទើបព្រះមានព្រះភាគត្រាស់ថា “សេចក្តីដែលស្ត្រីនឹងគប្បីជាព្រះអរហន្តសម្មាសម្ពុទ្ធ, នោះមិនមែនឋានៈ មិនមែនឱកាស” ដូច្នេះ ។ មួយ៉ាងទៀត ធម៌ជាគ្រឿងអាស្រ័យគឺបុណ្យរមែងបរិបូណ៌ដោយអាការទាំងពួង រមែងញ៉ាំងអត្តភាពដែលពេញដោយអាការទាំងពួងនុ៎ះឯងឱ្យកើតឡើង ព្រោះហេតុដូច្នោះ បុរសប៉ុណ្ណោះ រមែងជាអរហន្តសម្មាសម្ពុទ្ធបាន, មិនមែនស្ត្រីទេ ។

សូម្បីក្នុងពាក្យថា **“យំ ឥត្ថី រាជា អស្ស ចក្កវត្តិ** = ខដែលថា ស្ត្រីនឹងគប្បីជាព្រះបាទចក្រពត្តិ” ជាដើម អធិប្បាយថា លក្ខណៈទាំងឡាយ មហាបុរិសលក្ខណៈ ៣២ ប្រការរបស់ស្ត្រី ឈ្មោះថា រមែងមិនបរិបូណ៌ ព្រោះសេចក្តីមិនមាននូវលក្ខណៈ

---

[៤០] ខុ. ពុទ្ធ. ។

ទាំងឡាយ មានគុយ្ហ (លិង្គ) ដែលកំបាំងនៅក្នុងស្រោម ដូចគុយ្ហនៃគោ និងដំរី ជាដើម, និងឈ្មោះថា អ្នកមិនព្រមព្រៀងដោយរតនៈ ៧ ព្រោះមិនមានឥត្ថីរតនៈ (នាងកែវ)ម្យ៉ាងទៀត អត្តភាពដែលក្រៃលែងជាងមនុស្សទាំងពួង ក៏មិនមាន ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា "សេចក្តីដែលស្ត្រីគប្បីជាព្រះបាទចក្កពត្តិនោះ មិនមែនឋានៈ មិនមែនឱកាស" ដូច្នេះ ។ សូម្បីភាពជាស្តេចសក្កៈ ជាដើម (ព្រះឥន្ទ្រ ស្តេចមារ និងមហាព្រហ្ម) ទាំង ៣ ជាតំណែងខ្ពស់, តែភេទស្ត្រី ជាភេទថោកទាប ព្រោះហេតុណា, ព្រោះហេតុនោះ សូម្បីភាពនៃស្ត្រីនោះ ជាស្តេចសក្កៈជាដើម ទើបព្រះមានព្រះភាគ ទ្រង់បដិសេធហើយ ។

***សួរថា*** ភេទស្ត្រីមិនមានក្នុងព្រហ្មលោកយ៉ាងណា, សូម្បីភេទប្រុស ក៏ដូច្នោះ មិនមែនឬ ? ព្រោះហេតុដូច្នោះ បុរសគប្បីធ្វើភាពជាព្រហ្មដោយហេតុណា ហេតុនោះ ក៏មិនគប្បីពោលថា "សូម្បីឋាននោះ (គឺភេទប្រុស) មាន" ដូច្នេះ ។

ឆ្លើយថា មិនគប្បីពោល មិនបាន ។

***សួរថា*** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះភាវៈជាបុរសក្នុងលោកនេះ កើតឡើងក្នុងព្រហ្មលោកមាន ។ ពិតមែន ការកើតជាព្រហ្ម ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុងពាក្យថា **ព្រហ្មត្តំ** = ភាពជាព្រហ្ម ។ ចំណែកស្ត្រីចម្រើនឈានក្នុងលោកនេះ ធ្វើកាលៈហើយ រមែងចូលដល់ភាពជាសម្លាញ់របស់ព្រហ្មបរិសជ្ជាទាំងឡាយ (សំដៅដល់ព្រហ្មដែលជាបរិស័ទរបស់មហាព្រហ្ម), មិនមែនកើតជាមហាព្រហ្ម ។ គ្រាភាវៈនៃភេទទាំងពីរ សូម្បីមានក្នុងព្រហ្មលោកនោះ ស្ត្រីនោះ ក៏ឈ្មោះថា ជាព្រហ្ម ព្រោះតាំងនៅក្នុងភាពជា

ប្រុស, មិនតាំងនៅក្នុងភាពជាស្រី; ព្រោះហេតុដូច្នោះ ពាក្យនោះទើបជាពាក្យដែលព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកល្អហើយមែនពិត ៕

## អធិប្បាយ

## កាយទុច្ចរិតជាដើម មិនកើតផលគួរប្រាថ្នាជាដើម

គប្បីជ្រាបក្នុងពាក្យថា **កាយទុច្ចរិតស្ស** ជាដើម; ពូជទាំងឡាយមានពូជរបស់ស្ដៅ និងននោងព្រៃជាដើម រមែងមិនឱ្យផលមានរសផ្អែម, រមែងឱ្យកើតផលដែលមិនពេញចិត្ត ដែលមិនមានរសផ្អែមនុ៎ះឯង យ៉ាងណា; កាយទុច្ចរិតជាដើមក៏ដូច្នោះ រមែងមិនឱ្យកើតវិបាកដែលគួរប្រាថ្នា រមែងបង្កើតវិបាកដែលមិនគួរពេញចិត្ត ។ ដូចយ៉ាងថា ពូជអំពៅ និងពូជស្រូវសាលីជាដើម រមែងញ៉ាំងផលដែលគួរពេញចិត្ត ដែលមានរសល្អប៉ុណ្ណោះ ឱ្យកើតឡើង, រមែងមិនញ៉ាំងផលដែលគួរត្រេកអរ ដែលហឹរយ៉ាងណា, កាយសុចរិតជាដើម រមែងឱ្យវិបាកដែលគួរប្រាថ្នាគួរពេញចិត្ត ឱ្យកើតឡើង, រមែងមិនញ៉ាំងវិបាក ដែលមិនគួរប្រាថ្នាឱ្យកើតឡើងដូច្នោះ ។

សមពិត ដូចដែលត្រាស់ទុកថា ៖

**“យាទិសំ វបតេ ពីជំ តាទិសំ លភតេ ផលំ**
**កល្យាណការី កល្យាណំ បាបការី ច បាបកំ**

បុគ្គលសាបព្រោះពូជ យ៉ាងណា, រមែងបាន
ផល យ៉ាងនោះ; អ្នកធ្វើល្អ បានផលល្អ, អ្នកធ្វើ

អាក្រក់ បានផលអាក្រក់”[៤១] ។

ព្រោះហេតុដូច្នោះ ទើបព្រះភគវាត្រាស់ថា “ការដែលកាយទុច្ចរិតជាដើម នឹងគប្បីឱ្យផលដែលគួរប្រាថ្នា គួរត្រូវការ គួរពេញចិត្តនោះ មិនមែនឋានៈ និង មិនមែនឱកាស” ជាដើម ៕

## អធិប្បាយបុគ្គលដែលដល់ព្រមដោយកាយទុច្ចរិតជាដើម

ពាក្យថា “បុគ្គលអ្នកដល់ព្រម” ក្នុងពាក្យថា “**អ្នកដល់ព្រមដោយកាយទុច្ចរិត**” ជាដើម បានដល់ សេចក្តីដល់ព្រម ៥ យ៉ាង គឺ :

- **អាយូហនសមង្គិតា** សេចក្តីដល់ព្រមដោយកម្មជាគ្រឿងប្រមូលមក
- **ចេតនាសមង្គិតា** សេចក្តីដល់ព្រមដោយចេតនា
- **កម្មសមង្គិតា** សេចក្តីដល់ព្រមដោយកម្ម
- **វិបាកសមង្គិតា** សេចក្តីដល់ព្រមដោយវិបាក
- **ឧបដ្ឋានសមង្គិតា** សេចក្តីដល់ព្រមដោយអាការប្រាកដ ។

ក្នុងសេចក្តីដល់ព្រមទាំងនោះ ក្នុងខណៈនៃការប្រមូលមកនូវកុសលកម្ម និង អកុសលកម្ម ហៅថា **អាយូហនសមង្គិតា, ចេតនាសមង្គិតា** ក៏ដូចគ្នា ។ ក៏សត្វសូម្បីទាំងអស់ នៅមិនសម្រេចអរហន្តដរាបណា, ដរាបនោះ ព្រះមានព្រះភាគត្រាស់ហៅថា អ្នកមានសេចក្តីដល់ព្រមដោយកម្ម ព្រោះសំដៅយកកម្មដែលសមគួរនឹងវិបាកដែលសន្សំទុកក្នុងកាលមុនដូច្នោះ, ខនេះទើបឈ្មោះថា **កម្មសមង្គិតា** ។

---

[៤១] សំ. ស.។

តែ **វិបាកសមង្គិតា** គប្បីជ្រាបក្នុងខណៈនៃការឱ្យផលនោះឯង ។

ក៏ដរាបណាសត្វទាំងឡាយ នៅមិនទាន់សម្រេចអរហន្ត, និមិត្តនៃការកើតឡើង រមែងប្រាកដយ៉ាងនេះ គឺកាលសត្វទាំងនោះត្រាច់ទៅពីទីនោះៗ កាលនឹងចូលដល់នរក នរករមែងប្រាកដដោយអាការតាំងឡើង មានអណ្ដាតភ្លើងក្នុងលោហកុម្ភីជាដើម, កាលសត្វទាំងឡាយនឹងចូលដល់ភាពជាគព្ភសេយ្យកៈ (កំណើតក្នុងគភ៌) ផ្ទៃរបស់មាតា រមែងប្រាកដ, កាលនឹងកើតក្នុងទេវលោក ទេវលោករមែងប្រាកដដោយ អាការទាំងឡាយ មានដើមកប្បព្រឹក្ស (ដើមឈើដែលតាំងនៅអស់កប្ប) និងវិមានជាដើម, ព្រោះហេតុដូច្នេះ ដោយអាការយ៉ាងនេះ ឈ្មោះថា **ឧបដ្ឋានសមង្គិតា** ព្រោះសត្វទាំងនោះ មិនផុតពីការប្រាកដនៃនិមិត្តដែលការកើតដូចពោលមកនេះ ។

**ឧបដ្ឋានសមង្គិតា** នុ៎ះឯង រមែងឃ្លាត (មិនគង់មួយកន្លែង), ដែលនៅសល់ មិនឃ្លាត; ពិតមែន កាលនរកសូម្បីប្រាកដហើយ ទេវលោករមែងប្រាកដក៏បាន, កាលទេវលោក សូម្បីប្រាកដហើយ នរករមែងប្រាកដក៏បាន, កាលមនុស្សលោកសូម្បីប្រាកដហើយ កំណើតសត្វតិរច្ឆានរមែងប្រាកដក៏បាន, និងកាលកំណើតនៃសត្វតិរច្ឆាន សូម្បីប្រាកដហើយ មនុស្សលោករមែងប្រាកដក៏បាន, ប្រព្រឹត្តទៅបាន ទាំងអស់; ក្នុងសេចក្ដីនោះ មានរឿងជាឧទាហរណ៍ដូច្នេះ ៖

បានឮថា ត្រង់ជើងភ្នំសោណៈ មានព្រះធម្មកថិកមួយរូប ឈ្មោះថា **សោណត្ថេរ** នៅក្នុងបិប្ផលិវិហារ, បិតារបស់លោកជានាយព្រាន ឈ្មោះថា **សុនក្ខវាជិកៈ** ព្រះថេរៈសូម្បីហាមបិតាយ៉ាងណាៗ ក៏មិនអាចដើម្បីឱ្យតាំងនៅក្នុង

សេចក្តីសង្រួម ទើបគិតថា "បិតាអ្នកគួរឱ្យអាណិត ចូរកុំវិនាសឡើយ" ដូច្នេះ ទើបឱ្យបិតា អ្នកមិនប្រាថ្នានឹងបួស បានបួសហើយក្នុងវេលាជាអ្នកចាស់; កាលបិតាដេកលើទីដេករបស់មនុស្សឈឺ (សំដៅដល់កំពុងឈឺ) នរកបានប្រាកដហើយ (អារម្មណ៍របស់នរក), គឺពួកសុនខធំៗ មកពីជើងភ្នំសោណៈហើយ ក៏ហែហាមដូចនឹងត្រូវការទំពាស៊ី; បិតារបស់ព្រះថេរៈខ្លាចចំពោះភ័យដ៏ធំ ទើបហៅព្រះថេរៈថា "កូនសោណៈ ចូរហាម, កូនសោណៈ ចូរហាម" ដូច្នេះ ទើបព្រះថេរៈសួរថា "ថី ?" , បិតារបស់លោកពោលថា "កូនមិនឃើញឬ ?" ហើយប្រាប់ហេតុដែលប្រព្រឹត្តទៅនោះ ។

ព្រះថេរៈត្រិះរិះថា "បិតារបស់អ្នកដូចនឹងយើង ក៏ឈ្មោះថា នឹងកើតក្នុងនរកបានយ៉ាងណា, យើងនឹងជាទីពឹងឱ្យដល់បិតា" ដូច្នេះ ហើយឱ្យសាមណេរទាំងឡាយនាំផ្កាឈើផ្សេងៗ មកឱ្យ ហើយធ្វើការបូជាបាចដោយផ្កាឈើ និងបូជា លើតាំងត្រង់លានព្រះចេតិយ និងទីលានពោធិ៍ទាំងឡាយ ហើយនាំបិតាមកកាន់ទីលានរបស់ព្រះចេតិយ ដោយគ្រែ (សែងមកដោយគ្រែ) ឱ្យដេកលើគ្រែហើយ ពោលនឹងបិតាថា "បពិត្រមហាថេរៈ (ញោម) ការបូជារបស់ខ្ញុំករុណានេះ ធ្វើដើម្បីប្រយោជន៍ដល់លោក, លោកចូរពោលថា 'បពិត្រព្រះមានព្រះភាគ នេះជាបណ្ណាការរបស់ខ្ញុំអ្នកទុគ្គត" ដូច្នេះហើយ ចូរថ្វាយបង្គំព្រះមានព្រះភាគ (ព្រះចេតិយ) ហើយពោលថា "សូមចូរញុំាងចិត្តឱ្យជ្រះថ្លា" ដូច្នេះ ។

មហាថេរ (បិតា) នោះឃើញការបូជាហើយ កាលនឹងធ្វើយ៉ាងនោះ ញុំាងចិត្តឱ្យជ្រះថ្លាហើយ, ខណៈនោះឯង ទេវលោកប្រាកដ (កម្មនិមិត្តារម្មណ៍) ដល់

មហាថេរនោះ គឺនន្ទវ័ន ចិត្រលតា មិស្សកវ័ន បារុសកវ័ន វិមាន និងការច្រៀងរាំ របស់ទេពអប្សរទាំងឡាយ បានមានហើយ ហាក់ដូចជាមកឈរហែហម; ទើបមហាថេរនោះ ពោលថា “សោណៈ (ព្រះថេរៈជាកូនប្រុស) ចូរជៀសចេញទៅ, សោណៈចូរជៀសចេញទៅ” ដូច្នេះ ។ ព្រះថេរៈពោលថា “នេះអ្វីមហាថេរ?” ។ មហាថេរពោលថា “ស្រីទាំងនេះនឹងមកជាមាតារបស់លោក” ដូច្នេះ ។ ព្រះថេរៈគិតថា “ស្គតិប្រាកដឡើងដល់មហាថេរហើយ” ។

**បណ្ឌិតគប្បីជ្រាបថា ឧបដ្ឋានសមង្គិតា រមែងគង់នៅមួយកន្លែង ដោយប្រការដូច្នេះ ។**

ក្នុងការដល់ព្រម (សមង្គិតា) ទាំងនោះ ពាក្យថា **“សេចក្តីដល់ព្រមដោយកាយទុច្ចរិតជាដើម”** ព្រះមានព្រះភាគត្រាស់ហើយក្នុងទីនេះ ដោយអំណាចនៃការដល់ព្រមដោយអាយូហនៈ ចេតនា និងកម្មដូច្នេះ ។ ពាក្យដែលនៅសល់ក្នុងទីទាំងពួង មានអត្ថងាយមែនពិត ៕

**ចប់ការអធិប្បាយកម្លាំងទី ១ របស់ព្រះតថាគត**

## អធិប្បាយកម្លាំងទី ២ របស់ព្រះតថាគត
## សម្តែងអំពីកម្មសមាទានជាបាប

ពាក្យថា **“គតិសម្បត្តិបដិពាឡ្ហានិ** = ដែលគតិសម្បត្តិហាមទុក” អធិប្បាយថា កម្មសមាទានជាបាបដែលគតិសម្បត្តិហាមទុក ការពារទុក និងបដិសេធហើយ ។ សូម្បីក្នុងបទដែលនៅសល់ ក៏ន័យនេះដែរ ។

ម្យ៉ាងទៀត ក្នុងពាក្យថា **"គតិសម្បត្តិ** * **"** នេះ បានដល់ គតិដែលសម្បូណ៌ គឺទេវលោក និងមនុស្សលោក ។

ពាក្យថា **"គតិវិបត្តិ"** បានដល់ គតិអាក្រក់ គឺអបាយភូមិ ៤ ។

សេចក្តីសម្រេចដោយល្អក្នុងអត្តភាព ឈ្មោះថា **ឧបធិសម្បត្តិ** ។

កាលដែលមានអត្តភាពអាក្រក់ ឈ្មោះថា **ឧបធិវិបត្តិ** ។

កាលដែលសម្បូណ៌ ពោលគឺជាកាលដែលចម្រើនរបស់ព្រះរាជាអ្នកទ្រទ្រង់ធម៌ និងជនអ្នកមានចិត្តល្អ ឈ្មោះថា **កាលសម្បត្តិ** ។

កាលដែលវិបត្តិ ពោលគឺកាលដែលមានព្រះរាជាអាក្រក់ និងបុគ្គលអ្នកមានចិត្តថោកទាប ឈ្មោះថា **កាលវិបត្តិ** ។

ការប្រកបដោយប្រពៃ ឈ្មោះថា **បយោគសម្បត្តិ** ។

ការប្រកបក្នុងផ្លូវដែលខុស ឈ្មោះថា **បយោគវិបត្តិ** ។

ក្នុងបណ្តាពាក្យទាំងនោះ បាបកម្មមានចំនួនច្រើន រមែងមានដល់បុគ្គលខ្លះ។ បាបកម្មនោះ គប្បីឱ្យផលដល់អ្នកតាំងនៅក្នុងគតិវិបត្តិ ។ តែបុគ្គលកើតឡើងក្នុងគតិសម្បត្តិ គឺក្នុងទេវតាទាំងឡាយ ឬមនុស្ស ដោយកល្យាណកម្មម្យ៉ាង, វារៈរបស់អកុសលរមែងមិនកើតឡើងក្នុងឋានដូច្នោះ, វារៈរបស់កុសលដោយចំណែកតែមួយប៉ុណ្ណោះ រមែងកើតឡើង ។

---

* **សម្បត្តិ ៤** គឺ គតិសម្បត្តិ, ឧបធិសម្បត្តិ, កាលសម្បត្តិ និងបយោគសម្បត្តិ; **វិបត្តិ ៤** គឺ គតិ-វិបត្តិ, ឧបធិវិបត្តិ, កាលវិបត្តិ និងបយោគវិបត្តិ ។

ព្រះមានព្រះភាគរមែងទ្រង់ជ្រាបថា **កម្មទាំងនេះ** (បាបកម្ម) **ដែលគតិ-សម្បត្តិហាមទុក ទើបមិនឱ្យផលដល់បុគ្គលនោះ** ដោយប្រការដូច្នេះ ។

សូម្បីបុគ្គលដទៃទៀត ដែលមានបាបកម្មច្រើន, បាបកម្មទាំងនោះ ក៏គប្បីឱ្យផលដល់បុគ្គលអ្នកតាំងនៅក្នុងឧបធិវិបត្តិ ។ ម្យ៉ាងទៀត បុគ្គលនោះតាំងនៅក្នុងឧបធិសម្បត្តិដែលមានសណ្ឋាន និងអវយវៈតូចធំ តាំងនៅល្អហើយ មានរូបល្អគួរពេញចិត្ត ដូចនឹងបុត្ររបស់ព្រហ្ម ដោយកល្យាណកម្មម្យ៉ាង; សូម្បីតែកើតជាទាសៈក្នុងផ្ទៃរបស់ទាសី; អត្តភាពដែលមានសភាពយ៉ាងនេះ ជាសភាពមិនសមគួរដល់ការងារដែលសៅហ្មង ព្រោះហេតុដូច្នោះ កល្យាណកម្មនោះរមែងមិនញុំាងបុគ្គលនោះ ឱ្យធ្វើការងារថោកទាប មានការចងជើងដំរី ពាំពៃ សេះ និងចិញ្ចឹមគោជាដើម រមែងឱ្យស្លៀកដណ្តប់សំពត់សាច់ល្អិត រមែងតាំងទុកក្នុងតំណែងអ្នករក្សាឃ្លាំង (ភណ្ឌាគារិក) ជាដើម; បើជាស្រី, កល្យាណកម្មនោះរមែងមិនឱ្យធ្វើការងារថោកទាប មានការឱ្យអាហារដំរីជាដើម, តែនឹងឱ្យសំពត់ និងគ្រឿងប្រដាប់ ឬធ្វើស្រីនោះឱ្យដេកក្នុងទីដេកដ៏ស្អាត, រមែងតាំងនៅក្នុងតំណែងរាជវល្លភ (តំណែងជាមនុស្សស្និទ្ធស្នាល*) ដូចជា **ព្រះសោមទេវី** ។

បានឮថា ក្នុងកាលនៃ **ព្រះបាទភាតិករាជ** ពួកអាមាត្យទាំងឡាយ ចាប់ជនទាំងឡាយចំនួនច្រើន អ្នកអាស្រ័យសាច់គោហើយរស់នៅ សម្តែងចំពោះព្រះរាជា; ត្រូវព្រះរាជាសួរថា "ពួកអ្នករមែងអាចដើម្បីឱ្យតម្លៃពិន័យឬ ?" ក្រាបទូលថា

* តំណែងជាអគ្គមហេសី (សម្មោ. អដ្ឋ.) ។

“ពួកខ្ញុំព្រះអង្គមិនអាច” ដូច្នេះ ។ លំដាប់នោះ ទើបឱ្យជនទាំងនោះធ្វើសេចក្តីសម្អាតត្រង់ព្រះលានស្តេច; ធីតាម្នាក់របស់ជនទាំងនោះ មានរូបស្អាត គួរមើល គួរពេញចិត្តមករកជនទាំងនោះ, ព្រះរាជាទ្រង់ទតព្រះនេត្រឃើញធីតានោះ ទើបទ្រង់ឱ្យនាំមកតាំងទុកក្នុងតំណែងរាជវល្លភ ខាងក្នុងព្រះរាជមណ្ឌប ។ សូម្បីញាតិទាំងឡាយដែលនៅសល់ ក៏មានជីវិតរស់នៅ ជាសុខដោយអានុភាពរបស់ស្រីនោះ ។ ពិតមែន ក្នុងអត្តភាពដូច្នេះ សូម្បី បាបកម្មទាំងឡាយ ក៏រមែងមិនអាចដើម្បីឱ្យផល ។

**ព្រះមានព្រះភាគទ្រង់ជ្រាបថា “បាបកម្មទាំងឡាយដែលឧបធិសម្បត្តិហាមទុក ទើបមិនឱ្យផល”** ដោយប្រការដូច្នេះ ។

បាបកម្មទាំងឡាយចំនួនច្រើន រមែងឱ្យផលសូម្បីដល់បុគ្គលពួកខ្លះ, បាបកម្មទាំងនោះ គប្បីឱ្យផលដល់បុគ្គលអ្នកតាំងនៅក្នុងកាលវិបត្តិ ។ ម្យ៉ាងទៀត បុគ្គលនោះ កើតឡើងហើយ ដោយកល្យាណកម្មម្យ៉ាង ក្នុងកាលនៃព្រះរាជាអ្នកទ្រទ្រង់ធម៌ និងមនុស្សអ្នកចិត្តល្អ ដូចក្នុងសម័យជាទីកើតឡើងនៃជនអ្នកកើតនៅក្នុងបឋមកប្ប ឬព្រះបាទចក្រពត្តិ ឬថា ព្រះពុទ្ធទាំងឡាយ, ក៏កាលបុគ្គលទាំងនោះ កើតឡើងហើយក្នុងកាលដូច្នោះ ឱកាសដើម្បីឱ្យវិបាករបស់អកុសល រមែងមិនមាន, ឱកាសរបស់កុសលតែម្យ៉ាងប៉ុណ្ណោះ រមែងមាន ។

**ព្រះសាស្តា រមែងទ្រង់ជ្រាបថា “បាបកម្មទាំងឡាយ ដែលកាលសម្បត្តិហាមទុក ទើបមិនឱ្យផល”** ដោយប្រការដូច្នេះ ។ សូម្បីបុគ្គលដទៃទៀតដែលមានបាបកម្មច្រើន; បាបកម្មទាំងនោះ គប្បីឱ្យផលដល់បុគ្គលអ្នកតាំងនៅក្នុងបយោគវិបត្តិ ។ តែថា បុគ្គលនោះតាំងនៅក្នុងបយោគសម្បត្តិ ដោយកល្យាណ

កម្មតែម្យ៉ាង គឺជាអ្នកវៀរចាកបាណាតិបាតជាដើមហើយ រមែងញ៉ាំងកាយសុចរិត និងមនោសុចរិតទាំងឡាយឱ្យពេញ; ក្នុងឋានដូច្នោះ ឱកាសនៃការឱ្យផលរបស់អកុសល រមែងមិនមាន, មានតែឱកាសរបស់កុសលតែម្យ៉ាងប៉ុណ្ណោះ ។

**ព្រះមានជោគ រមែងទ្រង់ជ្រាបថា "បាបកម្មទាំងនោះ ដែលបយោគសម្បត្តិហាមទុក ទើបមិនឱ្យផល"** ដោយប្រការដូច្នេះ ។

សូម្បីបុគ្គលដទៃទៀត មានបាបកម្មច្រើន, បាបកម្មទាំងនោះ មិនគប្បីឱ្យផលដល់បុគ្គលអ្នកតាំងនៅក្នុងគតិសម្បត្តិ ។ តែបុគ្គលនោះ កើតក្នុងគតិវិបត្តិ ដោយបាបកម្មតែម្យ៉ាងនុ៎ះឯង; បាបកម្មទាំងនោះ គប្បីចូលដល់បុគ្គលនោះ ក្នុងទីនោះហើយ រមែងឱ្យផលគ្រប់ៗ គ្រា, រមែងឱ្យកើតក្នុងនរក តាមកាលដ៏សមគួរ, កើតក្នុងកំណើតតិរច្ឆាន...; ក្នុងប្រេតវិស័យ...; ក្នុងអសុរកាយ តាមកាលដ៏សមគួរ; រមែងមិនឱ្យដើម្បីងើបក្បាលឡើងពីអបាយ សូម្បីអស់កាលយូរអង្វែង ។

**ព្រះសម្ពុទ្ធរមែងទ្រង់ជ្រាបថា "បាបកម្មទាំងឡាយ រមែងមិនអាចដើម្បីឱ្យផល ព្រោះសភាពនៃបាបកម្មទាំងនោះ ដែលគតិសម្បត្តិហាមទុក តែរមែងឱ្យផល ព្រោះអាស្រ័យគតិវិបត្តិ"** ដោយប្រការដូច្នេះ ។

សូម្បីបុគ្គលដទៃ ដែលមានបាបកម្មច្រើន, បាបកម្មទាំងនោះ មិនគប្បីឱ្យផលដល់បុគ្គលអ្នកតាំងនៅក្នុងកាលសម្បត្តិ ។ តែថា បុគ្គលនោះតាំងនៅក្នុងឧបធិវិបត្តិ ដោយកម្មមួយនុ៎ះឯង ឱ្យជាអ្នកមានពណ៌សម្បុរអាក្រក់ មានរូបអាក្រក់ មានសណ្ឋានមិនល្អ គួរខ្ពើមដូចបិសាច ។ បើថា គេកើតជាទាសៈក្នុងផ្ទៃរបស់នាងទាសី, បាបកម្មទាំងនោះរមែងសមគួរដល់បុគ្គលនោះ ព្រោះហេតុនោះ បាបកម្ម

ទាំងឡាយ រមែងញ៉ាំងបុគ្គលនោះឱ្យធ្វើការងារដែលសៅហ្មង ដោយហោចទៅ រមែងឱ្យចូលទៅអាស្រ័យការងាររបស់មនុស្សអ្នកចាក់ផ្កាឈើ ។ បើគេកើតជាស្រី, បាបកម្មទាំងនេះ សមគួរដល់ភាពជាស្រី គឺរមែងឱ្យស្រីនោះធ្វើការងារដែលសៅហ្មង មានការឱ្យអាហារដរីជាដើម ។ ស្រីនោះសូម្បីតែកើតក្នុងផ្ទះមានត្រកូល ក៏នឹងដូចជាស្រីម្ចាស់ផ្ទះរបស់មហាកុដុម្ពិកៈ ក្នុងភូមិ **កោតលវាបី** ដែលត្រូវរាជបុរសចាប់ទៅដោយសម្គាល់ថា ជានាងទាសី ។

ព្រះភគវារមែងទ្រង់ជ្រាបថា "បាបកម្មទាំងឡាយរមែងមិនអាចឱ្យផល ព្រោះសភាពនៃបាបកម្មនោះ ដែលឧបធិសម្បត្តិហាមទុក តែរមែងឱ្យផលព្រោះអាស្រ័យឧបធិវិបត្តិ" ដោយប្រការដូច្នេះ ។

សូម្បីបុគ្គលដទៃទៀត ដែលមានបាបកម្មច្រើន, បាបកម្មទាំងនោះ មិនគប្បីឱ្យផលដល់បុគ្គលអ្នកតាំងនៅក្នុងកាលសម្បត្តិ ។ តែថាបុគ្គលនោះកើតក្នុងកាល-វិបត្តិ ដោយបាបកម្មមួយ គឺក្នុងកាលដែលព្រះរាជាមិនតាំងនៅក្នុងធម៌ មនុស្សចិត្តអាក្រក់ ឬក្នុងកាលនៃសត្វមានអាយុក្ស័យ ១០ ឆ្នាំ ដែលជាកាលលាមកឥតតម្លៃ, ក្នុងកាលដូច្នោះ សូម្បីបញ្ចគោរស រមែងសាបសូន្យទៅជាចំនួនច្រើន, ស្មៅគែលលករាប់ថាជាអាហារដ៏ប្រសើរ ។ សូម្បីបុគ្គលនោះ កើតក្នុងមនុស្សលោកក៏ពិតមែន, ប៉ុន្តែ គេក៏មានការរស់នៅដូចនឹងម្រឹគ ឬសត្វដែលគេចិញ្ចឹមទុកជាអាហារ; ក្នុងកាលដូច្នេះ ឱកាសនៃការឱ្យផលរបស់កុសល រមែងមិនមាន, មានតែឱកាសរបស់អកុសលតែចំណែកមួយប៉ុណ្ណោះ ។

ព្រះមានព្រះភាគទ្រង់ជ្រាបថា "បាបកម្មចំនួនច្រើន រមែងមិនអាចឱ្យផល

ព្រោះកាលសម្បត្តិហាមទុក, តែរមែងឱ្យផលបាន ព្រោះអាស្រ័យកាលវិបត្តិ” ដោយប្រការដូច្នេះ ។

សូម្បីបុគ្គលដទៃផ្សេងទៀត ដែលមានបាបកម្មច្រើន, បាបកម្មនោះមិនគប្បីឱ្យផលដល់បុគ្គលអ្នកតាំងនៅក្នុងបយោគសម្បត្តិ, តែថា បុគ្គលនោះតាំងនៅក្នុងកាលវិបត្តិហើយ រមែងធ្វើអកុសលកម្ម ១០ មានបាណាតិបាតជាដើម, រាជបុរសទាំងឡាយចាប់ អ្នកធ្វើកម្មដែលអាក្រក់នោះនុ៎ះឯង សម្ដែងចំពោះព្រះរាជា; ព្រះរាជាទ្រង់ដាក់កម្មករណ៍ (ការទូន្មានផ្លូវកាយ) ជាច្រើន ហើយក៏ឱ្យសម្លាប់ចោល ។

ព្រះមានជោគរមែងទ្រង់ជ្រាបថា “បាបកម្មទាំងឡាយច្រើន រមែងមិនអាចឱ្យផល ព្រោះសេចក្ដីដែលបយោគសម្បត្តិហាមទុក តែរមែងឱ្យផលបាន ព្រោះអាស្រ័យបយោគវិបត្តិ” ដោយប្រការដូច្នេះ ។

**បាបកម្មដែលសម្បត្តិទាំង ៤ (គឺគតិសម្បត្តិ ឧបធិសម្បត្តិ កាលសម្បត្តិ និងបយោគសម្បត្តិ) ហាមទុក ទើបមិនឱ្យផល តែរមែងឱ្យផល ព្រោះអាស្រ័យវិបត្តិ ៤ (មានគតិវិបត្តិជាដើម)** ដោយប្រការដូច្នេះ ។

ដូចយ៉ាងថា បុរសខ្លះនុ៎ះឯង គប្បីឱ្យព្រះរាជាពេញព្រះទ័យ ដោយការងារយ៉ាងណាមួយ, ពេលនោះព្រះរាជាគប្បីឱ្យឋានន្តរៈ ហើយក៏ឱ្យជនបទ (ភូមិស្រុក) ដល់គេ, បុរសនោះ មិនអាចដើម្បីប្រើប្រាស់ជនបទនោះដោយប្រពៃ គប្បីធ្វើឱ្យវិនាសទៅ ដូចភាជនៈដាក់ភត្តដែលពានរ (ស្វា) រត់កាន់ដណ្ដើមទៅហើយ ។ បុរសនោះ ឃើញវត្ថុដែលពេញចិត្តយ៉ាងណា គឺយាន ឬពាហនៈ ទាសៈ ឬទាសី ទីសួន ឬទីស្រែ របស់បុគ្គលណា គប្បីកាន់យករបស់ទាំងនោះ ដោយពលក្ការ (ការគំរាម

កំហែង), ពួកមនុស្សមិនអាចនឹងពោលអ្វីៗ ដោយសម្គាល់ថា "អ្នកនេះជារាជវល្លភ" ដូច្នេះ ទាំងគេនោះ ក៏គប្បីធ្វើការប្រទូសរ៉ាយបុគ្គលអ្នកជិតស្និទ្ធនឹងព្រះរាជា ឬធ្វើការប្រទូសរ៉ាយមហាមាត្យរបស់ព្រះរាជា មហាមាត្យនោះ ចាប់បុរសនោះឱ្យវ៉ាយហើយៗ ក៏ចាប់ចងដៃអូសទៅគាល់ព្រះរាជា ក្រាបទូលឱ្យទ្រង់ជ្រាបថា "បពិត្រព្រះសម្មតិទេព បុរសឈ្មោះឯណោះ ទម្លាយជនបទរបស់ព្រះអង្គ" ដូច្នេះ ព្រះរាជាបញ្ជាឱ្យឃុំឃាំងក្នុងគុកហើយ ក៏ឱ្យរាជបុរសវ៉ាយស្គរប្រកាសក្នុងនគរថា "បុរសឈ្មោះឯណោះ លួចរបស់អ្វី របស់អ្នកណា ?" ដូច្នេះ, ពួកមនុស្សមកហើយគប្បីបញ្ចេញសំឡេងទ្រហឹងអឺងកងថា "វត្ថុនេះរបស់យើង ដែលបុរសនោះ កាន់យកហើយ, វត្ថុនេះរបស់យើង ដែលបុរសនោះ កាន់យកហើយ " ដូច្នេះ ។ ព្រះរាជាទ្រង់ក្រោធដោយហេតុត្រឹមតែពាក្យនោះ ទើបធ្វើបុរសនោះ ឱ្យលំបាកក្នុងគុកដោយប្រការផ្សេងៗ ហើយក៏ឱ្យប្រហារចោល ដោយត្រាស់ថា "ពួកអ្នកចូរទៅ, ចូរអូសបុរសនោះទៅចោលក្នុងព្រៃខ្មោច ឱ្យសមនឹងកំហុស" ។ ពាក្យឧបមាជាគ្រឿងញ៉ាំងឧបមេយ្យឱ្យដល់ព្រមនោះ បណ្ឌិតគប្បីជ្រាបសេចក្ដីយ៉ាងនេះ ។

**ក៏ក្នុងកាលនៃបុថុជ្ជន សូម្បីកើតក្នុងសួគ៌ដោយបុញ្ញកម្មយ៉ាងណាមួយនុ៎ះឯង ប្រៀបដូចក្នុងកាលដែលបុរសនោះ ធ្វើការងារយ៉ាងណាមួយ ឱ្យព្រះរាជាទ្រង់ពេញព្រះទ័យ ហើយទើបបានឋានន្តរៈ ។ កាលអកុសលកម្មមិនបានឱកាសឱ្យផល ក៏ព្រោះតែបុគ្គលនេះកើតក្នុងសួគ៌នេះ ប្រៀបដូចកាលដែលអ្នកណាៗ មិនអាចពោលពាក្យអ្វីៗ ក្នុងកាលបុរសនោះ ទម្លាយជនបទនោះ និង កាន់យករបស់របរផ្សេងៗ របស់មនុស្សទាំងឡាយ ។**

ក្នុងកាលដែលបុរសនេះឃ្លាតចាកសួគ៌ ហើយកើតក្នុងនរក ប្រៀបដូចកាល

ដែលបុរសនោះប្រទូសរ៉ាយរាជវល្លភម្នាក់ អស់ថ្ងៃមួយ ហើយត្រូវរាជបុរសវាយ រួចក្រាបទូលចំពោះព្រះរាជា។ ព្រោះទ្រង់ក្រេវក្រោធទើបឱ្យឃុំឃាំងក្នុងគុក ។ កាលដែលបុរសនោះកើតក្នុងនរក ហើយទទួលអកុសលកម្មទាំងពួង ដែលមកប្រជុំគ្នានោះ ប្រៀបដូចការស្រែកទ្រហឹងអឺងកងរបស់មនុស្សទាំងឡាយថា "វត្ថុនេះជារបស់យើង ដែលបុរសនេះ កាន់យកហើយ; វត្ថុនេះ ជារបស់យើង ដែលបុរសនោះកាន់យកហើយ" ដូច្នេះ ។ ការដែលគេត្រូវឆេះក្នុងនរករហូតដល់អស់កប្បមិនអាចងើបក្បាលឡើងពីនរកបាន ដោយវិបាកកម្មនេះ។ ដរាបដល់ច្រើនជាងកម្មមួយ។ នឹងអស់ទៅ ប្រៀបដូចកាលនាំបុរស នោះមកចងទុកក្នុងព្រៃខ្មោច (ស្មសាន) ដែលសមគួរដល់កម្មរបស់ខ្លួន ។ ពិតមែន សត្វដែលត្រូវឆេះអស់មួយកប្ប ព្រោះធ្វើកម្មដែលឱ្យតាំងនៅ ដរាបដល់កប្ប មិនមែនតែម្នាក់, មិនមែនពីរនាក់, មិនមែនមួយពាន់នាក់ ។ បានឮថា សត្វទាំងឡាយ ដែលត្រូវឆេះដោយអាការយ៉ាងនេះ នៅសល់ប្រមាណរាប់មិនបាន ៕

## សម្ដែងអំពីកម្មសមាទានជាកុសល

សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា "កម្មសមាទានជាកុសលពួកខ្លះមាន, កម្មសមាទាននោះដែលគតិវិបត្តិហាមទុក រមែងមិនឱ្យផល" ជាដើម បណ្ឌិតគប្បីប្រកបសេចក្ដីយ៉ាងនេះ ៖

កល្យាណកម្មចំនួនច្រើន មានដល់បុគ្គលខ្លះក្នុងលោកនេះ, កម្មនោះគប្បីឱ្យផល ដល់អ្នកតាំងនៅក្នុងគតិសម្បត្តិ ។ តែថា អ្នកនោះទៅកើតក្នុងគតិវិបត្តិ គឺក្នុង

នរក ឬក្នុងអសុរកាយ ដោយបាបកម្មម្យ៉ាង, ក្នុងឋានដូច្នេះ កុសលរមែងមិនអាចដើម្បីឱ្យផល, អកុសលប៉ុណ្ណោះ រមែងឱ្យផលដោយចំណែកមួយ ។

ព្រះសាស្តារមែងទ្រង់ជ្រាបថា "កុសលកម្មទាំងនោះ របស់បុគ្គលនោះដែលគតិវិបត្តិហាមទុក ទើបមិនឱ្យផល" ដោយប្រការដូច្នេះ ។

កល្យាណកម្មចំនួនច្រើន រមែងមានសូម្បីដល់បុគ្គលដទៃទៀត; កម្មនោះគប្បីឱ្យផលដល់អ្នកតាំងនៅក្នុងឧបធិសម្បត្តិ ។ តែថា គេតាំងនៅក្នុងឧបធិវិបត្តិដោយបាបកម្មមួយ គឺជាអ្នកមានពណ៌សម្បុរអាក្រក់ ដូចនឹងបិសាច; សូម្បីគេកើតក្នុងរាជត្រកូល, ដោយកាលដែលកន្លងទៅនៃព្រះបិតា រមែងមិនបានរាជសម្បត្តិព្រោះពាក្យថា "អ្វី១ ដោយរាជសម្បត្តិរបស់អ្នកនេះ រកសិរីមិនបាន" , សូម្បីកើតក្នុងផ្ទះសេនាបតីជាដើម ក៏រមែងមិនបានតំណែងជាសេនាបតី ឬតំណែងសេដ្ឋីជាដើម ។ ក៏ដើម្បីជាក់ច្បាស់សេចក្តីនេះ គប្បីជ្រាបរឿងព្រះបាទទីបរាជ ដូចតទៅ ៖

## រឿងព្រះបាទទីបរាជ

បានឮថា ព្រះរាជាកាលព្រះរាជបុត្រប្រសូតហើយ ទ្រង់ជ្រះថ្លាក្នុងព្រះទេវីទើបបានទ្រង់ប្រទានពរ; ព្រះទេវីនោះទទួលពរហើយទ្រង់ផ្អាកទុក ។ តមក ព្រះរាជកុមារមានព្រះជន្មាយុ ៧ វស្សា បានឱ្យរាជបុរសនាំមាន់មកឱ្យជល់គ្នា ត្រង់ព្រះលានស្តេច...; មាន់មួយហើរឡើងទៅ ហើយទម្លាយព្រះនេត្រព្រះកុមារ; ព្រះទេវីជាព្រះមាតារបស់ព្រះកុមារ ទ្រង់តម្រិះថា "យើងនឹងសុំទទួលរាជសម្បត្តិ ក្នុងវេលាដែលឱរសមានវស្សា ១៥ ឬ ១៦" ដូច្នេះ ទើបយាងទៅគាល់ព្រះរាជា ទូលថា

“បពិត្រសម្មតិទេព ក្នុងវេលាដែលព្រះរាជកុមារប្រសូតហើយ ព្រះអង្គទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់ៗ ទទួលពរនោះ ហើយរង់ចាំដល់វេលា; ឥឡូវនេះ ខ្ញុំម្ចាស់នឹងទទួលយកពរនោះ” ដូច្នេះ ។ ព្រះរាជាត្រាស់ថា “ល្អហើយទេវី នាងចូរទទួលយកចុះ” ដូច្នេះ ។ ព្រះទេវីទូលថា “បពិត្រសម្មតិទេព វត្ថុអ្វីៗ ឈ្មោះថា ខ្ញុំម្ចាស់មិនបានហើយអំពីសំណាក់របស់ព្រះអង្គ មិនបានមាន, តែឥឡូវនេះ ខ្ញុំម្ចាស់ សូមទូលសុំរាជសម្បត្តិដើម្បីព្រះឱរសរបស់ខ្ញុំម្ចាស់” ដូច្នេះ ។ ព្រះរាជាទូលថា “ម្នាលទេវី បុត្ររបស់នាងមានអវយវៈមិនសមប្រកប (ពិការ), យើងមិនអាចដើម្បីនឹងឱ្យរាជសម្បត្តិ ដល់បុត្ររបស់នាងទេ” ដូច្នេះ ។ ព្រះទេវីទូលថា “ព្រះអង្គកាលមិនអាចដើម្បីប្រទានពរ ដែលល្មមព្រះទ័យដល់ខ្ញុំម្ចាស់ ព្រោះហេតុអ្វីទើបបានប្រទានពរដល់ខ្ញុំម្ចាស់ ក្នុងគ្រានោះ (ពេលមុន) ?” ដូច្នេះ; ព្រះរាជាកាលត្រូវព្រះទេវីគាបសង្កត់យ៉ាងក្រៃលែង ក៏មិនអាចដើម្បីឱ្យរាជសម្បត្តិ ក្នុងកាលក្រោយទាំងអស់ដល់ឱរសរបស់ព្រះអង្គ ទើបទ្រង់បញ្ជូនទៅកាន់នាគទីប (កោះតូច) ដោយព្រះតម្រាស់ថា “ចូរឱ្យរាជបុរសលើកឆ័ត្រឡើងត្រង់កោះតូច ហើយនៅចុះ” ដូច្នេះ, ព្រះរាជបុត្រនោះ ទើបបានទ្រង់ព្រះនាមថា **ព្រះបាទទីបរាជ** ។ បើថា ភាពពិការនៃចក្ខុនឹងមិនបានមានហើយសោត ក៏នឹងបានរាជសម្បត្តិដែលនៅជុំវិញ ដោយសម្បត្តិទាំងពួង ទាំងអស់ដែលមាន ១៥០ យោជន៏ ជាប្រមាណ ។ ព្រះមានព្រះភាគរមែងទ្រង់ជ្រាបថា “កល្យាណកម្មទាំងឡាយ ដែលឧបធិវិបត្តិហាមទុក ទើបមិនឱ្យផល” ដោយប្រការយ៉ាងនេះ ។ កល្យាណកម្មចំនួនច្រើន មានដល់បុគ្គលសូម្បីដទៃទៀត, កម្មនោះគួរឱ្យដល់បុគ្គលអ្នកតាំងនៅក្នុងកាល; តែថា បុគ្គលនោះ

តាំងនៅក្នុងកាលវិបត្តិ គឺក្នុងកាលនៃព្រះរាជាមិនតាំងនៅក្នុងធម៌ និងមនុស្សចិត្តអាក្រក់ ជាកាលលាមកឥតតម្លៃ មានអាយុតិចបំផុតនៃការដំណើរទៅ; ក៏ក្នុងកាលដូច្នោះ កល្យាណកម្មរមែងមិនអាចដើម្បីឱ្យផល ។ ព្រះភគវា រមែងទ្រង់ជ្រាបថា "កល្យាណកម្មទាំងឡាយ ដែលកាលវិបត្តិហាមទុក រមែងមិនឱ្យផល" ដោយប្រការដូច្នេះ ។ កល្យាណកម្មទាំងឡាយច្រើន សូម្បីមានដល់បុគ្គលដទៃទៀត កម្មទាំងនោះ ទើបឱ្យផលដល់អ្នកតាំងនៅក្នុងបយោគសម្បត្តិ ។ តែថា បុគ្គលនេះតាំងនៅក្នុងបយោគវិបត្តិ គឺរមែងសម្លាប់សត្វ ។ ល ។ រមែងញ៉ាំងភាពជាអ្នកទ្រុស្តសីលទាំងពួងឱ្យពេញ; ដោយទំនងនេះ ត្រកូលទាំងឡាយ ទោះបីមានជាតិស្មើគ្នាក៏រមែងមិនធ្វើអាវាហវិវាហមង្គល ជាមួយត្រកូលអ្នកទ្រុស្តសីលនោះ, បុរសដូចនេះជាអ្នកលាមក គឺជាអ្នកលេងស្រី លេងសុរា និងលេងល្បែងភ្នាល់, ព្រោះហេតុដូច្នោះ អ្នកប្រាថ្នាប្រយោជន៍ត្រូវវៀរឱ្យឆ្ងាយ ។ ព្រោះកល្យាណកម្មទាំងឡាយរមែងមិនអាចដើម្បីឱ្យផល ។ ព្រះមានព្រះភាគ រមែងទ្រង់ជ្រាបថា "កល្យាណកម្មទាំងនេះ ដែលបយោគវិបត្តិហាមទុក ទើបមិនឱ្យផល" ដោយប្រការដូច្នេះ ។ កល្យាណកម្មដែលនឹងឱ្យនូវផល ព្រោះអាស្រ័យសម្បត្តិ ៤ តែរមែងមិនឱ្យផល ព្រោះកល្យាណកម្មនោះ ដែលវិបត្តិ ៤ ហាមទុក ទើបមិនឱ្យផល ដោយប្រការដូច្នេះ ។ កល្យាណកម្មចំនួនច្រើនមានដល់បុគ្គលសូម្បីដទៃទៀត, កម្មនោះ មិនគប្បីឱ្យផលដល់បុគ្គលអ្នកតាំងនៅហើយក្នុងគតិវិបត្តិ ។ តែថាបុគ្គលនោះ កើតក្នុងគតិ-សម្បត្តិ ដោយកល្យាណកម្មមួយនោះឯង; កម្មដូច្នេះ ចូលដល់អ្នកនោះហើយទើបឱ្យផលក្នុងទីនោះៗ គឺឱ្យកើតក្នុងមនុស្សលោក តាមកាលដែលគួរ, ឱ្យកើតក្នុង

ទេវលោក តាមកាលដែលគួរ ។

ព្រះមានជោគរមែងទ្រង់ជ្រាបថា "កល្យាណកម្មទាំងនេះ មិនអាចឱ្យផល ព្រោះគតិវិបត្តិហាមទុក តែរមែងឱ្យផល ព្រោះអាស្រ័យគតិសម្បត្តិ" ដោយប្រការដូច្នេះ ។

កល្យាណកម្មចំនួនច្រើន សូម្បីមានដល់បុគ្គលដទៃទៀត, កម្មទាំងនោះមិនគប្បីឱ្យផលដល់អ្នកតាំងនៅក្នុងឧបធិវិបត្តិ; តែថា បុគ្គលនោះតាំងនៅក្នុងឧបធិ-សម្បត្តិ ដោយកល្យាណកម្មតែម្យ៉ាងប៉ុណ្ណោះ គឺមានរូបស្អាតគួរមើល គួរជ្រះថ្លា ដូចនឹងសិរសាព្រហ្ម ។ កល្យាណកម្មទាំងនោះ ឈ្មោះថា រមែងឱ្យផល ព្រោះភាវៈនៃបុគ្គលនោះ តាំងនៅក្នុងឧបធិសម្បត្តិ; ប្រសិនបើកម្មនោះ ឱ្យកើតក្នុងរាជ-សំណាក់, ថែមទាំងព្រះជេដ្ឋាទាំងពួង ក៏នៅមានដែរ អត្តភាពរបស់អ្នកដែលកម្មឱ្យកើតឡើងហើយនេះ រមែងជារបស់សម្រេចហើយដោយល្អ, រាជបុរសទាំងឡាយរមែងអភិសេកអ្នកទាំងនោះឯង ក្នុងរាជសម្បត្តិ ដោយសេចក្ដីសង្ឃឹមថា "កាលយើងលើកស្វេតច្ឆត្រឡើងដល់អ្នកនេះហើយ សេចក្ដីសុខសាន្ត នឹងមានដល់ពួកលោក" ដូច្នេះ; អ្នកកើតក្នុងផ្ទះរបស់ឧបរាជជាដើម រមែងបានភាពជាឧបរាជដោយកាលកន្លងទៅនៃបិតា ដែលជាតំណែងសេនាបតី តំណែងនាម៉ឺន ឬតំណែងសេដ្ឋី ។ **ព្រះមានព្រះភាគទ្រង់ជ្រាបថា "កល្យាណកម្មទាំងនេះ មិនអាចឱ្យផល ព្រោះឧបធិវិបត្តិហាមទុក តែរមែងឱ្យផល ព្រោះអាស្រ័យឧបធិសម្បត្តិ"** ដោយប្រការយ៉ាងនេះ ។ កល្យាណកម្មចំនួនច្រើន សូម្បីនៅមានដល់បុគ្គលដទៃទៀត, កម្មទាំងនេះ មិនគប្បីឱ្យផលដល់អ្នកតាំងនៅក្នុងកាលវិបត្តិ ។

តែថា បុគ្គលនោះ កើតក្នុងកាលសម្បត្តិ ដោយកល្យាណកម្មយ៉ាង គឺក្នុងកាលដែលព្រះរាជាទ្រង់ធម៌ និងមនុស្សអ្នកមានចិត្តល្អ, កល្យាណកម្មរមែងឱ្យផលដល់បុគ្គលអ្នកកើតនោះ ព្រោះការសម្រេចនៃកាលដូច្នោះ; ក្នុងសេចក្តីនេះ គប្បីជ្រាបរឿងរបស់ព្រះថេរៈ ឈ្មោះថា **មហាសោណៈ** ជាឧទាហរណ៍ ដូចតទៅ ៖

## រឿងព្រះថេរៈ ឈ្មោះថា មហាសោណៈ

បានឮមកថា ភិក្ខុមានចំនួន ១២.០០០ រូប អាស្រ័យនៅក្នុងចិត្តលបព៌តដែលមានភ័យពីព្រាហ្មណ៍ (អ្នកជាចោរ) ឈ្មោះថា **តិស្សៈ**; ក្នុងតិស្សមហាវិហារក៏ដូចគ្នាដែរ; សូម្បីក្នុងមហាវិហារទាំងពីរ ពួកកណ្តុរធំទាំងឡាយ នាំគ្នាមកខាំសំពត់ក្នុងវេលារាត្រីអស់ ៣ ឆ្នាំ ហើយនាំទៅទុកត្រង់គំនរអង្កាម; ភិក្ខុសង្ឃនៅត្រង់ចិត្តលបព៌តគិតថា “យើងនឹងអាស្រ័យសំពត់ ក្នុងតិស្សមហាវិហារ” , ទើបចេញអំពីវិហារដោយប្រាថ្នាថា “យើងទៅហើយ នឹងអាស្រ័យនៅក្នុងទីនោះ” ដូច្នេះ ។ ចំណែកភិក្ខុសង្ឃ សូម្បីក្នុងតិស្សមហាវិហារ ក៏គិតថា “យើងនឹងអាស្រ័យសំពត់ ក្នុងចិត្តលបព៌ត” , ចេញអំពីវិហារ ដោយប្រាថ្នាថា “យើងទៅហើយ នឹងអាស្រ័យនៅក្នុងទីនោះ” ដូច្នេះ; សូម្បីភិក្ខុទាំងពីរពួក ក៏មកជួបគ្នាត្រង់ច្រាំងនៃជ្រលងភ្នំមួយកន្លែង ទើបសួរនូវគ្នានឹងគ្នា សូម្បីជ្រាបហើយនូវសេចក្តីដែលសំពត់ជារបស់អស់ទៅភិក្ខុទាំងអស់ ២៤.០០០ រូប បានប្រឹក្សាគ្នាថា “ពួកយើងនឹងធ្វើយ៉ាងណា” ដូច្នេះ ។ ភិក្ខុពួកខ្លះ ក៏ចូលទៅកាន់ព្រៃជាជ្រលងភ្នំ គង់ហើយបរិនិព្វានដោយនិព្វានធាតុ ដែលជាអនុបាទិសេសៈ ដោយកិរិយាដែលអង្គុយនោះឯង ។ ខាងក្រោយកាលភ័យស្ងប់

ហើយ ភិក្ខុសង្ឃអាស្រ័យសក្កទេវរាជ ទើបរួបរួមព្រះធាតុទាំងឡាយ ធ្វើជាចេតិយ; សូម្បីចោរព្រាហ្មណ៍ ឈ្មោះថា តិស្សៈ ក៏រំលាយជនបទដែរ ។ សង្ឃប្រជុំពិភាក្សាគ្នាហើយ ទើបបញ្ជូនព្រះថេរៈ ៨ រូប ទៅកាន់សំណាក់របស់សក្កៈថា "សូមព្រះអង្គហាមចោរ" ដូច្នេះ ។ សក្កទេវរាជត្រាស់ថា "បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ចោរកើតឡើងហើយ ញោមមិនអាចដើម្បីនឹងហាម, សូមព្រះសង្ឃទៅផ្លូវសមុទ្រខាងមុខ, ញោមនឹងធ្វើការរក្សាសមុទ្រ" ។ ព្រះសង្ឃទៅកាន់នាគទីបពីទិសទាំងពួង ឱ្យចងក្បូនធំ ៣ ជាន់ ត្រង់កំពង់ឈ្មោះ **ជម្ពុកោលៈ** ។ ក្បូនមួយលិចចុះក្នុងទឹក, ភិក្ខុសង្ឃអង្គុយមួយជាន់ទៀត តាំងបាត្រ និងចីវរទុកមួយជាន់ទៀត ។ ព្រះថេរៈទាំង ៣ រូប អ្នកជាប្រធាននៃបរិស័ទទាំងនោះ គឺ**ព្រះចូឡសិវត្ថេរ** អ្នកជំនាញសំយុត្តនិកាយ, **ឥសិទត្តត្ថេរ និងមហាសោណត្ថេរ** ។ បណ្តាព្រះថេរៈទាំងនោះ ព្រះថេរៈពីររូប ពោលនិមន្តព្រះសោណត្ថេរថា "បពិត្រលោកមហាសោណៈមានអាយុ លោកចូរឈានឡើងក្បូនធំចុះ" ដូច្នេះ ។ ព្រះសោណត្ថេរពោលថា "បពិត្រលោកដ៏ចម្រើន ចុះលោកវិញ" ។ ព្រះថេរៈទាំងពីរពោលថា "អ្នកមានអាយុ សេចក្តីស្លាប់ក្នុងទឹកក្តី សេចក្តីស្លាប់លើគោកក្តី ក៏ដូចតែគ្នា, ពួកយើងនឹងមិនទៅ, តែលោកអាស្រ័យក្បូននោះ ហើយនឹងបន្តព្រះសាសនាក្នុងអនាគត, អ្នកមានអាយុ លោកចូរទៅចុះ" ដូច្នេះ ។

ព្រះមហាសោណត្ថេរ សូម្បីពោលដល់ ៣ ដងថា "បពិត្រលោកដ៏ចម្រើន កាលលោកទាំងពីរមិនទៅ ខ្ញុំនឹងមិនទៅដែរ" កាលព្រះថេរៈទាំងពីរ មិនអាចញ៉ាំងព្រះថេរៈឱ្យឡើងកាន់ក្បូន ទើបនាំគ្នាត្រឡប់ទៅវិញ ។

លំដាប់នោះ **ព្រះចូឡសិវត្ថេរ** ពោលនឹង **ព្រះឥសិទត្តត្ថេរ** ថា “អ្នកមានអាយុ **ឥសិទត្តៈ** លោកអាស្រ័យព្រះមហាសោណៈហើយ ការបន្តនៃព្រះសាសនានឹងតាំងនៅក្នុងអនាគត, លោកចូរកុំពន្លែងដៃពីព្រះសោណៈ (បានសេចក្តីថា ឱ្យណែនាំទូន្មាន)” ; ព្រះឥសិទត្តត្ថេរពោលនឹងព្រះចូឡសិវត្ថេរថា “ករុណាលោកម្ចាស់” ដូច្នេះ, ព្រះចូឡសិវត្ថេរពោលថា “ខ្ញុំនឹងទៅថ្វាយបង្គំមហាចេតិយ” ដូច្នេះ ។ ព្រះចូឡសិវត្ថេរពោលទូន្មានព្រះថេរៈទាំងពីរហើយ ក៏ត្រាច់ចារិកទៅដោយលំដាប់ដរាបដល់ព្រះមហាវិហារ ។ ក្នុងសម័យនោះ មហាវិហារមិនមានភិក្ខុសង្ឃឡើយ, ដើមល្ហុងដុះឡើងត្រង់លានព្រះចេតិយ, ព្រះចេតិយមានគុម្ពឈើទាំងឡាយឡោមព័ទ្ធ, មានស្លែព័ន្ធព័ទ្ធហើយ ។ ព្រះថេរៈថ្វាយបង្គំមហាចេតិយ ដូចនឹងសម្តែងការនមស្ការចំពោះព្រះមានព្រះភាគ ដែលនៅមានព្រះជន្ម ហើយចូលទៅកាន់សាលាតាមទិសបច្ចិម (ខាងលិច) កាលក្រឡេកមើល អង្គុយត្រិះរិះថា “ទីបញ្ចុះព្រះសារីរិកធាតុរបស់ព្រះសាស្តា ដែលដល់ហើយនូវភាពធំក្រៃលែងដោយលាភសក្ការៈដោយយសដ៏ធំក្រៃលែងមានសភាពដូច្នេះ មិនមានទីពឹងហើយហ្ន៎” ។

លំដាប់នោះ ទេវតាអ្នកឋិតនៅត្រង់ដើមឈើដែលមិនឆ្ងាយពីទីនោះ កាន់យកនាឡិអង្ករ និងស្ករអំពៅ ទៅកាន់សំណាក់របស់ព្រះថេរៈ មានសភាពជារបស់មនុស្សដោយឫទ្ធិ ហើយសួរព្រះថេរៈថា “បពិត្រលោកដ៏ចម្រើន លោកនឹងនិមន្តទៅទីណា ?” ។

**ព្រះថេរៈពោលថា** “ម្នាលឧបាសក អាត្មានឹងទៅកាន់ទិសទក្សិណ ។

**ទេវតាពោលថា** “បពិត្រលោកដ៏ចម្រើន សូម្បីខ្ញុំក៏ប្រាថ្នានឹងទៅទីនោះ

ដែរ, តោះយើងនឹងទៅជាមួយគ្នា” ។

**ព្រះថេរៈពោលថា** “អាត្មាមានកម្លាំងខ្សោយ មិនអាចនឹងទៅតាមអធ្យាស្រ័យរបស់អ្នកបានទេ អ្នកចូរទៅមុនចុះឧបាសក” ។

**ទេវតាពោលថា** “សូម្បីខ្ញុំក៏នឹងទៅតាមអធ្យាស្រ័យរបស់លោកម្ចាស់” ដូច្នេះ ហើយបានទទួលយកបាត្រ និងចីវររបស់ព្រះថេរៈមកកាន់ទុក ។

ក៏ក្នុងកាលជាទីឡើងទៅកាន់ទំនប់រក្សាទឹក ឈ្មោះថា **តិស្សៈ** ព្រះថេរៈឱ្យនាំបាត្រមកហើយធ្វើទឹកផឹក ទេវតាក៏បានធ្វើទឹកផឹកថ្វាយ, ល្មមព្រះថេរៈមានកម្លាំង តាំងនៅត្រឹមហេតុដែលថា ការផឹកទឹកហើយនុ៎ះឯង; ទេវតាបង្រួញផែនដីឱ្យដល់វិហារមួយខ្នង ក្នុងទីជិត **វេណុនទី** ហើយបោសសម្អាតស្ថានទីថ្វាយចំពោះព្រះថេរៈ ។ ថ្ងៃស្អែកឡើងគ្រាន់តែព្រះថេរៈលាងមុខស្រេច ទេវតាក៏បបរយាគូថ្វាយ, កាលព្រះថេរៈឆាន់យាគូហើយ, ទេវតាក៏ដាំបាយបង្អោនចូលទៅ ។ ព្រះថេរៈពោលថា “ឧបាសក អ្នកចូរតាំងទុកដើម្បីអ្នកចុះ ហើយយកដៃបិទបាត្រ”។ ទេវតាពោលថា “ខ្ញុំនឹងមិនទៅឆ្ងាយ” ហើយទើបយកភត្តដាក់ក្នុងបាត្ររបស់ព្រះថេរៈទៀត កាលព្រះថេរៈធ្វើភត្តកិច្ចស្រេចហើយ ទេវតាក៏កាន់យកបាត្រ និងចីវរដើម្បីធ្វើដំណើរទៅកាន់ផ្លូវដែលនឹងទៅ បង្រួញផែនដី នាំទៅកាន់សំណាក់នៃជជ្ជរនទី ហើយពោលថា “បពិត្រលោកដ៏ចម្រើន នុ៎ះជាទីសម្រាប់នៅរបស់ពួកមនុស្សអ្នកអាស្រ័យនូវស្លឹកឈើ ហើយរស់នៅ, ដើមឈើរមែងប្រាកដ ខ្ញុំនឹងទៅខាងមុខ” ដូច្នេះ សំពះព្រះថេរៈហើយទៅកាន់ភពរបស់ខ្លួន ។ ព្រះថេរៈអាស្រ័យពួកមនុស្សអ្នកអាស្រ័យស្លឹកឈើ ហើយរស់នៅរហូតអស់កាលនៃភ័យសូម្បីទាំងពួង ។

សូម្បី **ព្រះឥសិទត្តត្ថេរ** កាលចារិកទៅដោយលំដាប់ ក៏សម្រេចដល់អឡ-ជនបទ ។ ពួកមនុស្សក្នុងជនបទនោះពុះផ្លែស្រគំ ដែលនៅមិនទាន់ទុំពេក កាន់យកគ្រាប់ក្នុងផ្លែ ហើយចោលសំបកទើបទៅ ។ ព្រះថេរៈពោលនឹងព្រះមហាសោណត្ថេរថា "ម្នាលលោកមហាសោណៈ ភិក្ខាហាររមែងប្រាកដដល់យើង" ដូច្នេះ ហើយឱ្យព្រះមហាសោណៈនាំបាត្រ និងចីវរមកដណ្តប់ បាននាំបាត្រចេញទៅឈរនៅហើយ ។ កញ្ញាម្នាក់ ឃើញព្រះថេរៈឈរ ទើបគិតថា "ប្រយោជន៍អ្វីៗ នឹងមានដោយផ្លែស្រគំនេះ ទើបនាំផ្លែស្រគំ និងសាច់ស្រគំមកដាក់ក្នុងបាត្រ ហើយប្រគេន ។ ព្រះ-ថេរៈទាំងពីរឆាន់; អាហារនោះឯង បានប្រព្រឹត្តទៅរហូតដល់អស់ ៧ ថ្ងៃ ។ លំដាប់នោះ ជនទាំងឡាយ បញ្ជូនដំណឹងរឿងចោរមកដោយលំដាប់ ។ មនុស្សទាំងឡាយអ្នកភ័យខ្លាច ដែលកាន់យកផ្កាកុមុទ (ផ្កាឈូកក្រហម) ទាំងឡាយ បានចោលផ្កាកុមុទទាំងឡាយ ហើយជៀសចេញទៅ ។ ព្រះថេរៈពោលថា "ម្នាលលោកមហា-សោណៈ ភិក្ខាហាររមែងប្រាកដដល់យើង" ដូច្នេះ ហើយក៏ឱ្យនាំបាត្រ និងចីវរមកដណ្តប់ចីវរហើយ ក៏នាំបាត្រចេញមកឈរ ។ ក្មេងស្រីជំទង់ក្នុងភូមិម្នាក់ សម្អាតទងកុមុទហើយដាក់ក្នុងបាត្រប្រគេន ។ ព្រះថេរៈទាំងពីរឆាន់ទងកុមុទ * ។ អាហារនោះ បានគ្រាន់តែញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅបាន ៧ ថ្ងៃ ។ ព្រះថេរៈកាលត្រាច់ទៅដោយលំដាប់ បានដល់ទ្វារផ្ទះឃ្លាំងមួយ ក្នុងទីនៅនៃមនុស្សអ្នករស់នៅដោយអាស្រ័យស្លឹកឈើ ។ មាតា និងបិតារបស់ក្មេងស្រីជំទង់ ក្នុងភូមិនោះ កាលទៅព្រៃបានប្រាប់ថា "នែនាង បើលោកម្ចាស់ណាៗ មកទីនេះឯង ចូរកុំឱ្យលោកនិមន្តទៅ

---

* ក្រអៅឈូកទេដឹង ? ។

ទីណា ៗ, ចូរប្រាប់ទីជាទីនៅដល់លោកម្ចាស់” ដូច្នេះ ។ ទារិកានោះ ឃើញព្រះថេរៈទាំងពីរឈរហើយ ទើបទទួលបាត្រ និងនិមន្តឱ្យគង់ ។

ក៏ឈ្មោះថា ធញ្ញជាតិក្នុងផ្ទះមិនមាន, ក្មេងស្រីនោះទើបកាន់យកកាំបិតទៅស្មោះសំបកដើមទំពាំងបាយជូរ និងដើមចេកព្រៃ ព្រមនឹងត្រយូង និងបន្លែមករួមគ្នា ធ្វើឱ្យជា ៣ ដុំ ដាក់មួយដុំចុះក្នុងបាត្ររបស់ **ព្រះឥសិទត្តត្ថេរ**, ដាក់មួយដុំចុះក្នុងបាត្រ **ព្រះមហាសោណត្ថេរ** ដកដៃចេញទៅដោយប្រាថ្នាថា យើងនឹងដាក់ដុំដែលលើសចុះ ក្នុងបាត្ររបស់ព្រះឥសិទត្តត្ថេរ តែដៃបែរត្រឡប់ទៅដាក់ចុះក្នុងបាត្ររបស់ព្រះសោណត្ថេរ ព្រះឥសិទត្តពោលថា “កម្មដែលឱ្យនូវផល ព្រោះដុំទំពាំងបាយជូរ និងចេកព្រៃ ក្នុងសម័យមានភ័យពីព្រាហ្មណ៍ ឈ្មោះថា តិស្សៈ នឹងប្រាកដផលមានប្រមាណប៉ុនណា ព្រោះកាលដល់ព្រមនៃទេសកាល” ដូច្នេះ ហើយព្រះថេរៈទាំងពីរ ក៏ឆាន់ដុំទាំងនោះជាមួយគ្នា ហើយបានទៅកាន់ទីនៅ ។ សូម្បីក្មេងស្រីនោះ ក៏ប្រាប់មាតា និងបិតាដែលមកពីព្រៃថា “ព្រះថេរៈទាំងពីរមកហើយ, ឯទីនៅដើម្បីព្រះថេរៈទាំងពីរនោះ ខ្ញុំក៏ប្រាប់ហើយ” ដូច្នេះ ។ សូម្បីមាតា និងបិតាទាំងពីរនោះ ទៅកាន់សំណាក់របស់ព្រះថេរៈទាំងពីរ ថ្វាយបង្គំហើយទទួលបដិញ្ញាណ (ឱ្យសញ្ញា) ដោយពាក្យថា “បពិត្រលោកដ៏ចម្រើន ពួកញោមរមែងបានវត្ថុណាមក, ញោមនឹងបម្រុងព្រះគុណម្ចាស់ទាំងពីរ ដោយវត្ថុនោះ, សូមលោកម្ចាស់គង់នៅក្នុងទីនេះចុះ” ដូច្នេះ ។ សូម្បីព្រះថេរៈទាំងឡាយ ក៏អាស្រ័យជនទាំងនោះហើយនៅរហូតដល់អស់កាលនៃភ័យទាំងពួង ។

កាលចោរ ឈ្មោះថា តិស្សៈ អ្នកជាព្រាហ្មណ៍ស្លាប់ហើយ បិតាមហារាជ

ក៏ញ៉ាំងរាជបុរសឱ្យលើកស្វេតច្ឆត្រឡើង ។ ភិក្ខុសង្ឃមកពីច្រាំងសមុទ្រឯណោះ ស្តាប់ឮថា “ភ័យស្ងប់ហើយ ជនបទសម្បូណ៌ហើយ” ដូច្នេះ ក៏ឆ្លងមកដោយទូកដល់កំពង់ឈ្មោះថា មហាតិត្ថ: និងបានសួររក **ព្រះមហាសោណត្ថេរ** ថា “ព្រះ មហាសោណត្ថេរនៅទីណា” ដូច្នេះ ហើយបានទៅកាន់សំណាក់ព្រះថេរៈ ។ ព្រះថេរៈ (មហាសោណត្ថេរ) មានភិក្ខុសង្ឃប្រាំរយជាបរិវារ សម្រេចដល់វិហារឈ្មោះ **មណ្ឌលារាម** ក្នុងភូមិ **កាលកៈ** ។ ក្នុងស្រុកកាលកៈ មានត្រកូលអាស្រ័យនៅក្នុងភូមិកាលកៈ ៧០០ ត្រកូល, ក្នុងវេលាយប់ ទេវតាទាំងឡាយត្រាច់ទៅប្រាប់ដល់ពួកមនុស្សទាំងឡាយថា “ព្រះមហាសោណត្ថេរ អ្នកមានភិក្ខុជាបរិវារប្រាំរយមកដល់មណ្ឌលារាមហើយ សូមជនអ្នកផ្ទះមួយៗ ប្រគេនអាហារបិណ្ឌបាត ដែលជារបស់មានតម្លៃគួរដល់កហាបណៈមួយៗ ព្រមដោយសំពត់សាដកថ្មីៗ” ដូច្នេះ ។ ក៏ក្នុងថ្ងៃស្អែកឡើង ព្រះថេរៈទាំងឡាយចូលទៅកាន់ភូមិ ឈ្មោះកាលកៈ ដើម្បីបិណ្ឌបាត ។ មនុស្សទាំងឡាយនិមន្តឱ្យគង់ហើយ បានប្រគេនយាគូ ។ ព្រះថេរៈ ឈ្មោះថា **តិស្សភូត** ជាសង្ឃត្ថេរ ក៏គង់នៅក្នុងមណ្ឌលារាមដែរ ។

មហាឧបាសកម្នាក់ ថ្វាយបង្គំព្រះសង្ឃត្ថេរហើយសួរថា “ព្រះគុណម្ចាស់ដ៏ចម្រើន អង្គណា ឈ្មោះថា មហាសោណៈ” ដូច្នេះ សម័យនោះ ព្រះមហាសោណត្ថេរជាភិក្ខុថ្មីជាង ទើបអង្គុយក្នុងទីបំផុត, ទើបព្រះសង្ឃត្ថេរចង្អុលដៃទៅហើយពោលថា “ម្នាលឧបាសក នុ៎ះឈ្មោះថា មហាសោណៈ” ដូច្នេះ, ឧបាសកថ្វាយបង្គំព្រះមហាសោណត្ថេរនោះ ហើយសូមទទួលបាត្រអំពីលោក, ព្រះមហាសោណត្ថេរ មិនឱ្យព្រះតិស្សភូតត្ថេរពោលថា “អ្នកមានអាយុសោណៈ រមែងមិន

ជ្រាប ដោយអាការយ៉ាងណា, សូម្បីយើងក៏មិនជ្រាប ដោយអាការយ៉ាងនោះដែរ; ទេវតាទាំងឡាយ រមែងឱ្យចម្អិនភត្តដើម្បីអ្នកមានបុណ្យទាំងឡាយ, អ្នកចូរបញ្ចេញ (ឱ្យ) បាត្រ, ចូរធ្វើការសង្គ្រោះសព្រហ្មចារីទាំងឡាយ" ដូច្នេះ; ព្រះសោណត្ថេរក៏បានឱ្យបាត្រ; មហាឧបាសកកាន់យកបាត្រទៅ ដាក់ឱ្យពេញដោយអាហារបិណ្ឌ-បាត ដែលមានតម្លៃគួរដល់មួយកហាបណៈ និងធ្វើសំពត់សាដកថ្មី ហើយទ្របាត្រនាំមកដាក់ទុកលើដៃរបស់ព្រះថេរៈ ។ សូម្បីឧបាសកដទៃទៀត ក៏តាំងអាហារបិណ្ឌបាត និងសំពត់សាដក, រួមសំពត់សាដក និងអាហារបិណ្ឌបាតមួយៗ ៧០០ បានប្រគេនដល់ព្រះមហាសោណត្ថេរប៉ុណ្ណោះ ។

ព្រះមហាសោណត្ថេរ ធ្វើការបែងចែកវត្ថុទាំងនោះដល់ភិក្ខុសង្ឃរៀបរយហើយ ក៏ទៅកាន់មហាវិហារដោយលំដាប់ គ្រាខ្ចុរមាត់លាងមុខហើយ ក៏ថ្វាយបង្គំព្រះមហាពោធិ៍ និងព្រះមហាចេតិយ ហើយឈរនៅត្រង់ថូបារាម ដណ្តប់ចីវរ មានភិក្ខុជាបរិវារ ចូលទៅកាន់ព្រះនគរ តាមទ្វារទិសទក្សិណ (ខាងត្បូង) បានអាហារបិណ្ឌបាត ដែលមានតម្លៃគួរដល់ថ្លៃ ៦០ កហាបណៈ ក្នុងចន្លោះនោះ រហូតដល់ផ្លូវទៅកាន់សាលា ។ ចាប់ផ្តើមអំពីកាលនោះមក ប្រមាណនៃគ្រឿងសក្ការៈរាប់មិនបាន ។

ក៏ក្នុង **កាលវិបត្តិ** ដែលមានភិក្ខារកបានដោយលំបាក សូម្បីផ្លែ និងសម្បកស្រគំ និងទងផ្កាកុមុទ ក៏រកបានដោយលំបាក, តែក្នុង **កាលសម្បត្តិ** មានលាភច្រើនហូរហៀរ កើតឡើងហើយ ដោយប្រការដូច្នេះ ៕

## រឿងវត្តពុកនិគ្រោធត្ថេរ*

ក៏ភ័យអំពីចោរ ឈ្មោះថា តិស្សៈ អ្នកជាព្រាហ្មណ៍ កើតឡើងក្នុងកាលសូម្បីនៃ **វត្តពុកនិគ្រោធត្ថេរ** នៅជាសាមណេរ, សាមណេរ និងឧបជ្ឈាយ៍របស់សាមណេរ មិនបានទៅកាន់សមុទ្រត្រើយខាងណោះ, តែបានឆ្ពោះមុខទៅប្រទេសជាយដែន ដោយគិតថា **“ពួកយើងនឹងចូលទៅអាស្រ័យមនុស្ស ដែលមានស្លឹកឈើរស់នៅ”** ដូច្នេះ; សាមណេរជាអ្នកមិនមានអាហារប្រមាណ ៧ ថ្ងៃ ឃើញផ្លែត្នោតទុំនៅក្នុងទីជិតស្រុកមួយកន្លែង ទើបប្រាប់ព្រះថេរៈថា “សូមលោកម្ចាស់រង់ចាំមួយភ្លែត, ខ្ញុំករុណានឹងឱ្យផ្លែត្នោតធ្លាក់ចុះមក” ដូច្នេះ ។ ព្រះឧបជ្ឈាយ៍ (ព្រះថេរៈ) ពោលថា “សាមណេរ អ្នកមានកម្លាំងខ្សោយ កុំឡើងឡើយ” ដូច្នេះ ។ សាមណេរប្រាប់ថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណានឹងឡើង” ដូច្នេះ ហើយកាន់កាំបិតតូចឡើងដើមត្នោត ដើម្បីកាត់ធ្លាយត្នោត កាំបិតក៏របូតធ្លាក់ចុះមកដី ។

ព្រះថេរៈគិតថា “សាមណេរនេះ កំពុងលំបាកឡើងដើមត្នោត ហើយកាំបិតក៏របូតធ្លាក់ចុះមក, ឥឡូវនេះ គេនឹងធ្វើយ៉ាងណា ?” ដូច្នេះ ។ សាមណេរហែកស្លឹកត្នោត, លុះហែកហើយ ចងដងកាំបិតបោះចុះមក ឱ្យធ្លាក់ចុះមកលើផ្ទៃដី ហើយប្រាប់ព្រះថេរៈថា “លោកម្ចាស់ សូមទទួលឱ្យបានស្រួលបួលផង, បើថាផ្លែកាំបិតនៅក្នុងទីនោះ សូមលោកបញ្ជូនកាំបិតឱ្យខ្ញុំករុណាផង” ដូច្នេះ ។

ព្រះថេរៈគិតថា “សាមណេរជាអ្នកឈ្លាសក្នុងឧបាយ” ហើយបានបញ្ជូនកាំបិតឱ្យ ។ សាមណេរនោះ ក៏ប្រើកាំបិតកាត់ផ្លែត្នោតទាំងឡាយឱ្យធ្លាក់ចុះ;

---

* ជនទាំងឡាយហៅលោកថា អ្នកនឹងធឹង ដូចដើមនិគ្រោធ ។

សាមណេរបោះកាំបិតហើយទម្លាយផ្លែ ឱ្យរមៀលទៅហើយ កំពុងនឹងចោះផ្លែត្នោត ព្រះថេរៈពោលថា "សាមណេរ លោកមានកម្លាំងខ្សោយ, ចូរឆាន់ផ្លែត្នោតនេះមុនចុះ" ដូច្នេះ ។ សាមណេរប្រាប់ថា "លោកម្ចាស់ កាលលោកនៅមិនឆាន់ផ្លែត្នោតនេះ ខ្ញុំករុណាក៏នឹងមិនឆាន់" ដូច្នេះ ហើយទើបចាប់កាំបិតចោះផ្លែត្នោត នាំបាត្រចេញមកដាក់កំពឹងត្នោត ថ្វាយដល់ព្រះថេរៈហើយ ខ្លួនឯងទើបឆាន់ ។ ផ្លែត្នោតនៅមានទាំងពីរនោះ ក៏នៅក្នុងទីនោះៗ ឯង កាលផ្លែត្នោតអស់ហើយ ទើបទៅកាន់វិហារមួយ ដែលគេលះបង់ចោល ក្នុងទីនៅរបស់មនុស្សអ្នកអាស្រ័យស្លឹកឈើ ។

សាមណេរបោសសម្អាតទីសម្រាប់នៅដើម្បីព្រះថេរៈ ។ ព្រះថេរៈបានឱ្យឱវាទដល់សាមណេរ ហើយក៏ចូលទៅកាន់វិហារ ។ សាមណេរគិតថា "កំណត់ប្រមាណអត្តភាពទាំងឡាយ ដែលវិនាសហើយ ព្រោះវត្ថុដែលមិនគួរ (សេចក្តីលំបាក) រាប់មិនបាន, យើងនឹងធ្វើការបម្រើព្រះពុទ្ធជាម្ចាស់ ទើបទៅកាន់លានព្រះចេតិយ ធ្វើការដកស្មៅចេញហើយៗ, សាមណេរនោះ ញាប់ញ័រ (ម្ដេបៗ) ព្រោះខ្លួនមិនមានអាហារមក ៧ ថ្ងៃ ទើបដួលចុះទៅ ដេកនៅទីនោះ ហើយក៏នៅបោចស្មៅ ។

ក៏មនុស្សមួយពួក ត្រាច់ទៅក្នុងព្រៃ បានសម្បុកឃ្មុំហើយ ក៏កាន់យកឧសទាំងឡាយផង ស្លឹកបន្លែទាំងឡាយផង ទៅក្នុងទីជិតនៃសាមណេរ ដោយគិតថា "អេ! នុំះម្រឹគឬហ្ន៎" ។ គ្រាឃើញហើយទើបសួរថា "បពិត្រសាមណេរ លោកធ្វើអ្វី" ។ សាមណេរឆ្លើយថា "ម្នាលឧបាសក អាត្មាបោចស្មៅ" ។ ពួកមនុស្ស

ពោលថា “សាមណេរ នរណា១ សូម្បីដទៃទៀត មាននៅក្នុងទីនេះឬ ?”។ សាមណេរពោលថា “ម្នាលឧបាសកទាំងឡាយ មានព្រះឧបជ្ឈាយ៍របស់យើងនៅក្នុងបន្ទប់” ដូច្នេះ ឧបាសកពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកប្រគេនវត្ថុនេះដល់ព្រះមហាថេរ ហើយគប្បីឆាន់ចុះ” ។ ហើយក៏ប្រគេនសម្បុកឃ្មុំដល់សាមណេរ និងប្រាប់កន្លែងដែលជាទីនៅរបស់ពួកខ្លួន ហើយពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកយើងកាលធ្វើការកាច់មែកឈើស្រេចហើយ ក៏នឹងត្រឡប់ទៅវិញ, សូមសាមណេរនាំព្រះថេរៈមកដោយនិមិត្តសញ្ញានេះ” ដូច្នេះ ហើយនាំគ្នាត្រឡប់ទៅ ។

សាមណេរទទួលសម្បុកឃ្មុំ ហើយទៅកាន់ទីនៅរបស់ព្រះថេរៈ ឈរនៅខាងក្រៅប្រាប់ថា “លោកម្ចាស់ ខ្ញុំករុណាសូមនមស្ការ” ដូច្នេះ ។

ព្រះថេរៈបានជាអ្នកនៅស្ងៀម ដោយគិតថា “សាមណេរនឹងជាអ្នកដែលសេចក្តីស្រេកឃ្លានដុតរោលហើយមក ទើបសាមណេរប្រាប់ទៀតថា “លោកម្ចាស់ខ្ញុំករុណាសូមនមស្ការ” ។ ព្រះថេរៈពោលថា “សាមណេរ អ្នកមិនឱ្យភិក្ខុចាស់ដេកបានតាមសប្បាយ ព្រោះហេតុអ្វី ?”។ សាមណេរពោលថា “គួរបើកទ្វារលោកម្ចាស់” ។ ព្រះថេរៈទើបក្រោកឡើងបើកទ្វារ ហើយសួរថា “សាមណេរ អ្នកបានអ្វីមក ?” ដូច្នេះ ។ សាមណេរពោលថា “សម្បុកឃ្មុំ លោកគួរទំពាឆាន់សម្បុកឃ្មុំដែលមនុស្សទាំងឡាយប្រគេនមក” ។ ព្រះថេរៈពោលថា “សាមណេរ យើងលំបាកដើម្បីនឹងឆាន់យ៉ាងនេះ, នឹងធ្វើឱ្យជារបស់គួរផឹកហើយទើបផឹក”, សាមណេរធ្វើឱ្យជារបស់គួរផឹក ហើយថ្វាយដល់ព្រះថេរៈ ។

លំដាប់នោះ ព្រះថេរៈពោលថា “សាមណេរ លោកសួរដល់ទីនៅរបស់មនុស្សឬ ?” ។ សាមណេរប្រាប់ថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកមនុស្សសូមនិមន្តលោកម្ចាស់” ។ ព្រះថេរៈពោលថា “សាមណេរ កាលយើងទៅពេលព្រឹកនឹងលំបាក, យើងនឹងទៅថ្ងៃនេះតែម្តង” ហើយឱ្យសាមណេរកាន់បាត្រ និងចីវរចេញទៅ ។ (បព្វជិត) ទាំងពីរនោះទៅហើយ អាស្រ័យនៅទីដែលមិនឆ្ងាយអំពីទីជាទីនៅរបស់ពួកមនុស្ស ។ ក្នុងវេលានៃរាត្រី សាមណេរគិតថា “ចាប់ផ្តើមអំពីយើងបួសហើយ ឈ្មោះថា អរុណខាងក្នុងស្រុក (ក្នុងទីមួយកន្លែងនឹងព្រះថេរៈ) យើងមិនធ្លាប់ឱ្យរះឡើងឡើយ” , ទើបកាន់យកបាត្រចេញទៅកាន់ព្រៃ ។ ព្រះមហាថេរៈ កាលមិនឃើញសាមណេរក្នុងទីដេក ទើបគិតថា “សាមណេរនឹងជាអ្នកដែលមនុស្សចាប់ទៅ ហើយស៊ី” ដូច្នេះ ។ សាមណេរញ៉ាំងអរុណឱ្យរះឡើងក្នុងព្រៃ ហើយកាន់យកទឹក និងឈើស្ទន់ដោយបាត្រត្រឡប់មក ។ ព្រះថេរៈសួរថា “សាមណេរ អ្នកទៅណា, ធ្វើឱ្យកើតវិតក្កៈដល់យើង, អ្នកគួរដល់ទណ្ឌកម្ម (ការទទួលទណ្ឌកម្ម)” ។ សាមណេរឆ្លើយថា “ខ្ញុំករុណានឹង ទទួលទណ្ឌកម្ម (នឹងដល់ការប្រព្រឹត្តយ៉ាងណាមួយ ជាការដាក់ទោសខ្លួនឯង)” ។ ព្រះថេរៈលាងមុខហើយដណ្តប់ចីវរ ។ សូម្បីលោកទាំងពីរ ក៏បាននាំគ្នាទៅកាន់ទីនៅនៃមនុស្សទាំងឡាយ ។ សូម្បីមនុស្សទាំងឡាយ ក៏បានប្រគេនអាហារ មានត្រាវ ផ្លែឈើ និងស្លឹកឈើ ដែលជាគ្រឿងបរិភោគរបស់ខ្លួន ។ សូម្បីព្រះថេរៈឆាន់ស្រេចហើយ ក៏ទៅកាន់វិហារ ។ សាមណេរនាំទឹកមក ហើយពោលថា “លោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណានឹង លាងជើងរបស់លោកម្ចាស់ (ជាការធ្វើទណ្ឌកម្ម)” ដូច្នេះ ។ ព្រះថេរៈ

ពោលថា "ម្នាលសាមណេរ អ្នកទៅណាក្នុងពេលកណ្ដាលអាធ្រាត, ធ្វើឱ្យយើងមានវិតក្កៈកើតឡើង" ដូច្នេះ; សាមណេរប្រាប់ថា "លោកម្ចាស់ ខ្ញុំករុណាមិនធ្លាប់ឱ្យអរុណរះឡើងក្នុងស្រុកជាមួយនឹងលោកម្ចាស់ ដោយហេតុនេះ ទើបទៅកាន់ព្រៃដើម្បីត្រូវការឱ្យអរុណរះឡើង" ដូច្នេះ ។ ព្រះថេរៈពោលថា "សាមណេរ ទណ្ឌកម្មមិនសមគួរដល់អ្នក, សមគួរដល់យើង" ដូច្នេះ ហើយនៅក្នុងទីនោះៗ ឯង។ ម្យ៉ាងទៀត ព្រះថេរៈបានឱ្យនូវសេចក្ដី សម្គាល់ដល់សាមណេរថា "យើងជាមនុស្សចាស់ ឈ្មោះថា វត្ថុ (សេចក្ដីស្លាប់) នេះ នឹងមានមុន, ព្រោះហេតុដូច្នោះ សេចក្ដីស្លាប់នោះ អ្នកណាៗ មិនអាចដើម្បីនឹងដឹង, អ្នកចូររក្សាខ្លួនចុះ" ដូច្នេះ ។ បានឮថា ព្រះថេរៈជាអនាគាមី, ក្នុងកាលដទៃទៀត ពួកមនុស្សដែលស៊ីមនុស្ស បានចាប់ព្រះថេរៈស៊ីជាអាហារ ។ សាមណេររក្សាខ្លួនបាន ពេលភ័យស្ងប់ហើយ ក៏កាន់យកព្រះឧបជ្ឈាយ៍ក្នុងទីនោះ រួចឧបសម្ប័ទ ហើយរៀននូវព្រះពុទ្ធវចនៈ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ទើបមហាជនហៅលោកថា វត្តព្ភកនិគ្រោធត្ថេរ (ព្រះថេរៈអ្នកផុតភ័យដូចដើមនិគ្រោធ) កើតឡើងហើយ ។ **បិតុមហារាជ** ទ្រង់គ្រងរាជសម្បត្តិហើយ ។ ភិក្ខុទាំងឡាយអ្នកមកហើយៗ អំពីត្រើយសមុទ្រឯណោះ សួរថា "ព្រះថេរៈ ឈ្មោះថា **វត្តព្ភកនិគ្រោធ** ទៅណា ?" ដូច្នេះ ហើយក៏ទៅកាន់សំណាក់របស់វត្តព្ភកនិគ្រោធនោះ; ពួកនៃភិក្ខុថ្មីជាច្រើន ព័ទ្ធជុំវិញនូវព្រះថេរៈ; ព្រះថេរៈនោះមានភិក្ខុសង្ឃជាច្រើនចោមរោម ហើយទៅកាន់មហាវិហារ ថ្វាយបង្គំមហាពោធិ៍ ថ្វាយបង្គំព្រះចេតិយ និងថូបារាមដោយលំដាប់, ហើយចូលទៅកាន់ព្រះនគរ; ត្រៃចីវរក្នុងទីទាំងបី កើតឡើងដល់ព្រះថេរៈដែលកំពុងដើរទៅនោះឯង ដរាបដល់ទ្វារ

ទិសទក្សិណ ចាប់តាំងអំពីព្រះថេរៈចូលទៅដល់ទីក្រុងហើយ លាភសក្ការៈជាច្រើនក៏កើតឡើង ។

ក្នុងកាលវិបត្តិមានភិក្ខាហាររកបានដោយលំបាក សូម្បីតែផ្លែត្នោត ត្រាវដំឡូង និងស្លឹកឈើ, តែក្នុង **កាលសម្បត្តិ** មហាលាភមានសភាពដូច្នេះ កើតឡើងហើយ ដោយប្រការដូច្នេះ ។

**ព្រះមានព្រះភាគរមែងទ្រង់ជ្រាបថា "កល្យាណកម្មទាំងឡាយ មិនអាចដើម្បីនឹងឱ្យផល ព្រោះកាលវិបត្តិហាមទុកយ៉ាងនេះ តែរមែងឱ្យផលព្រោះអាស្រ័យកាលសម្បត្តិ"** ដូច្នេះ ។

កល្យាណកម្មចំនួនច្រើន សូម្បីមានដល់បុគ្គលដទៃទៀត, កម្មនោះមិនគប្បីឱ្យផលដល់បុគ្គលអ្នកតាំងនៅក្នុងបយោគវិបត្តិ ។ តែបុគ្គលនោះតាំងនៅចំពោះក្នុងសម្មាបយោគ (សេចក្ដីព្យាយាមដោយប្រពៃ) ដោយកល្យាណកម្មម្យ៉ាង ហើយរមែងបំពេញសុចរិត ៣, រមែងរក្សាសីល ៥ និងសីល ១០ ។ កាលបុគ្គលកើតក្នុងកាលសម្បត្តិ ព្រះរាជាទាំងឡាយអ្នកប្រកបដោយគ្រឿងប្រដាប់ទាំងពួង កម្មនោះរមែងបញ្ជូនរាជកញ្ញាទាំងឡាយ ដែលសមគួរដល់ព្រះរាជានោះ, រមែងបញ្ជូនទូវបណ្ណាការនោះៗ ដែលផ្សេងដោយវត្ថុមានតម្លៃ មានយាន ពាហនៈ កែវមណី មាស និងប្រាក់ជាដើម ដែលសមគួរដល់ព្រះរាជានោះ ។ សូម្បីគេដល់ការបព្វជ្ជា រមែងមានយសធំ មានអានុភាពច្រើន; ក្នុងសេចក្ដីនេះ មានរឿងនេះជាឧទាហរណ៍ ៖

## រឿងព្រះបាទកូដកណ្ណរាជ

បានឮថា ព្រះកូដកណ្ណរាជ ទ្រង់ស្រឡាញ់រាប់អាន ព្រះចូឡសុធម្មត្ថេរ

អ្នកអាស្រ័យនៅក្នុង **កណ្ណគ្រាម** ក្បែរភ្នំ, ព្រះរាជានោះ កាលប្រថាប់នៅក្បែរត្រពាំងទឹក មានផ្កាឧប្បល (ក្នុងឧប្បលវាបី) ទ្រង់បញ្ជាឱ្យនិមន្តព្រះថេរៈមក ។ ព្រះថេរៈមកហើយ អាស្រ័យនៅក្នុងវិហារឈ្មោះថា **មាលាវាម** ។ ព្រះរាជាត្រាស់សួរមាតារបស់ព្រះថេរៈថា "ព្រះថេរៈរមែងពេញចិត្តក្នុងអាហារប្រភេទណា ?" ដូច្នេះ ។ មាតារបស់ព្រះថេរៈទូលថា "បពិត្រមហារាជ ព្រះថេរៈពេញចិត្តត្រាវ" ដូច្នេះ ។ ព្រះរាជាបញ្ជាឱ្យរាជបុរសកាន់ត្រាវទៅកាន់វិហារ កាលប្រគេន មិនបានទតមើលមុខរបស់ព្រះថេរៈ, គ្រាយាងចេញអំពីវិហារហើយ ត្រាស់សួរព្រះទេវីខាងក្រៅបរិវេណវិហារថា "ព្រះថេរៈ ដូចជាអ្វី ?" ដូច្នេះ ។ ព្រះទេវីទូលថា "ព្រះអង្គជាបុរសមិនអាចដើម្បីនឹងទតបាន, ខ្ញុំម្ចាស់នឹងអាចដឹងយ៉ាងណា ?, ទាំងខ្ញុំម្ចាស់ក៏មិនជ្រាបថា 'លោកជាអ្វីដែរ" ដូច្នេះ ។ ព្រះរាជាមិនអាចដើម្បីនឹងទតឃើញសូម្បីតែបុត្ររបស់គហបតីអ្នកថ្វាយគ្រឿងសែនព្រេន (តង្វាយ) ក្នុងស្រុកតំបន់រស់នៅរបស់ព្រះអង្គ, ការកាន់សាសនារបស់ព្រះអង្គ, ត្រឹមតែផ្ទាត់ព្រះហស្ត ត្រាស់ថា "លោកម្ចាស់ដ៏ចម្រើនទាំងឡាយ ឈ្មោះថា ព្រះសាសនាជារបស់ធំហ្ន៎" ដូច្នេះ ។ ព្រះរាជាទ្រង់ពេញព្រះទ័យ សូម្បីនូវព្រះថេរៈ ឈ្មោះថា ចូឡនាគដែលជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ។

គ្រាតមក បូសតាំងឡើងត្រង់ម្រាមដៃរបស់ព្រះថេរៈនោះ; ព្រះរាជាស្តេចយាងទៅកាន់វិហារដោយតាំងព្រះទ័យថា "យើងនឹងសួរសុខទុក្ខព្រះថេរៈ" ដូច្នេះ ។ ដោយសេចក្តីស្រឡាញ់ដ៏មានកម្លាំង ទើបប្រើព្រះឱស្ឋបីតក្បាលបូសត្រង់ម្រាមដៃរបស់ព្រះថេរៈ, បូសបែកហើយក្នុងព្រះឱស្ឋនោះឯង, ទ្រង់មិនស្តោះខ្ទុះលោហិត

(ទឹកឈាម និងខ្ទុះ) ចេញ, ទ្រង់លេបចូលទៅហើយ ហាក់ដូចជាទឹកអម្រឹត ដោយសេចក្ដីស្រឡាញ់ចំពោះព្រះថេរៈ ។ ក្នុងកាលផ្សេងទៀត ព្រះថេរៈនោះៗ ឯងអាពាធធ្ងន់សិងលើគ្រែសម្រាប់មរណៈ; ព្រះរាជាយាងទៅហើយ ទ្រង់យកសីសៈជ្រប់មុខត្រង់គ្រែមរណៈដែលមិនស្អាត ទ្រង់បរិទេវនាការ (យំត្អូញត្អែរ) ថា "ភ្លៅរទេះ គឺព្រះធម៌រមែងបែក" ដូច្នេះ ហើយស្ដេចយាងទៅ ។

ឈ្មោះថា ការយកសីសៈជ្រប់ចុះត្រង់គ្រែដែលមិនស្អាត ហើយត្អូញត្អែរយំទៅតាមផ្លូវ ផ្លូវនោះនឹងជាផ្លូវរបស់អ្នកណា ? ឆ្លើយថា ជាផ្លូវទៅរបស់អ្នកប្រកបដោយល្អ ។

**ព្រះភគវារមែងទ្រង់ជ្រាបថា "កល្យាណកម្ម មិនអាចដើម្បីឱ្យផលដោយអាការយ៉ាងនេះទេ ព្រោះបយោគវិបត្តិហាមទុក តែរមែងឱ្យផលព្រោះអាស្រ័យបយោគសម្បត្តិ" ដូច្នេះ ។**

កល្យាណកម្មដែលវិបត្តិ ៤ ហាមទុក មិនឱ្យផល តែរមែងឱ្យផល ព្រោះអាស្រ័យសម្បត្តិ ៤ យ៉ាង ដោយប្រការដូច្នេះ; ក្នុងសេចក្ដីនេះ បណ្ឌិតគប្បីធ្វើឧបមាឱ្យជាក់ច្បាស់ ក្នុងរឿងមានតទៅនេះ ៖

## ឧបមាដោយអាមាត្យ

បានឮថា មហារាជមួយព្រះអង្គ ទ្រង់ខ្ញាល់ខ្ញាយនឹងអាមាត្យមួយ ដោយហេតុយ៉ាងណានីមួយ មានប្រមាណតិចតួច ទើបឱ្យចងអាមាត្យនោះ ក្នុងផ្ទះគុក, ញាតិទាំងឡាយរបស់អាមាត្យនោះ ដឹងសេចក្ដីដែលព្រះរាជាទ្រង់ពិរោធហើយ ពួក

គេមិនពោលពាក្យអ្វីៗ ទេ; គ្រាព្រះរាជាទ្រង់ប្រាសចាកសេចក្ដីពិរោធហើយ ទើបសូមឱ្យព្រះរាជាទ្រង់ជ្រាបសេចក្ដីដែលអាមាត្យនោះ មិនមានកំហុស ។ ព្រះរាជាទ្រង់ឱ្យដោះលែងហើយ ទាំងឱ្យព្រះរាជទានតំណែងដល់អាមាត្យនោះ ឱ្យត្រឡប់ជាប្រក្រតី ។ លំដាប់នោះ ប្រមាណនៃគ្រឿងបណ្ណាការទាំងឡាយ ក៏មកកាន់អាមាត្យនោះ រាប់មិនបាន រហូតដល់មិនអាចដើម្បីនឹងទទួលបាន ។

ក្នុងរឿងនេះ កាលដែលបុថុជ្ជនកើតក្នុងនរក គប្បីជ្រាបថា ប្រៀបដូចកាលដែលអាមាត្យនោះ ត្រូវព្រះរាជាទ្រង់ខ្វល់ខ្វាយដោយហេតុតិចតួច ហើយ ឱ្យចងក្នុងផ្ទះគុក ។ តមក កាលដែលបុថុជ្ជននោះកើតឡើងក្នុងសួគ៌ គប្បីជ្រាបថា ប្រៀបដូចកាលដែលញាតិទាំងឡាយរបស់អាមាត្យនោះ ឱ្យព្រះរាជាទ្រង់ជ្រាបសេចក្ដីដែលអាមាត្យនោះ មិនមានកំហុស ឱ្យដោះលែងចេញអំពីផ្ទះគុក និងប្រទានឋានន្តរៈឱ្យត្រឡប់ជាប្រក្រតីវិញ ។ ការដែលកល្យាណកម្មទាំងឡាយ អាស្រ័យសម្បត្តិ ៤ ហើយ ឱ្យផលជាសុខ សូម្បីទាំងសែននៃកប្ប ដែលនាំទៅកាន់ទីជាសុខអំពីទីនេះ ទៅកាន់ទីនោះ គឺនាំមកកាន់មនុស្សលោក អំពីទេវលោក ហើយឱ្យដល់ព្រះនិព្វាន បណ្ឌិតគប្បីជ្រាបថា ប្រៀបដូចកាលដែលអាមាត្យនោះ មិនអាចដើម្បីនឹងទទួលគ្រឿងបណ្ណាការដ៏ច្រើនបាន ៕

## កម្មក្ខយបដិសម្ភិទាមគ្គ

បណ្ឌិតលុះសម្ដែងកម្លាំងទី ២ ដោយអំណាចនៃព្រះបាលីមានអាការយ៉ាងនេះជាមុនហើយ គប្បីសម្ដែងដោយន័យនៃបដិសម្ភិទាមគ្គនេះថា **“អហោសិ**

**កម្មំ អហោសិ កម្មវិបាកោ"** ដូច្នេះ ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **"អហោសិ កម្មំ** = កម្មបានមានហើយ" បានដល់ កម្មដែលសន្សំហើយក្នុងអតីតៈ ក៏បានមានហើយក្នុងអតីតៈនោះឯង; ឯពាក្យថា **"អហោសិ កម្មវិបាកោ** = កម្មវិបាក គឺផលរបស់កម្មបានមានហើយ" នេះ លោកពោលទុកសំដៅយកវិបាកដែលឱ្យផលហើយក្នុងអតីតៈនោះ ។ ក៏បណ្ដាកម្មទាំងឡាយសូម្បីដ៏ច្រើន មានទិដ្ឋធម្មវេទនីយកម្មជាដើម (កម្មឱ្យផលក្នុងបច្ចុប្បន្ន) កម្មម្យ៉ាង ឱ្យផលក្នុងភពបច្ចុប្បន្នហើយ, កម្មដ៏សេសរមែងមិនឱ្យផលទេ ។ កម្មម្យ៉ាង ឱ្យផលជាឧបបជ្ជវេទនីយក្នុងបដិសន្ធិហើយ, កម្មទាំងឡាយដ៏សេសរមែងមិនឱ្យផលទេ ។ កម្មម្យ៉ាង ឱ្យកើតក្នុងនរកដោយអនន្តរិយកម្មមួយហើយ, កម្មទាំងឡាយដ៏សេស រមែងមិនឱ្យផលឡើយ ។ បណ្ដាសមាបត្តិ ៨ សមាបត្តិមួយ ឱ្យផលកើតក្នុងព្រហ្មលោក, កម្មដ៏សេសរមែងមិនឱ្យផល ។ ដោយហេតុនេះ ទើបលោកពោលថា **"កម្មវិបាកមិនបានមានហើយ"** ព្រោះសំដៅយកពាក្យដូចពោលមកនេះ ។

ម្យ៉ាងទៀត បុគ្គលណាធ្វើកម្ម ដែលជាកុសល និងអកុសល សូម្បីច្រើន អាស្រ័យកល្យាណមិត្តហើយ រមែងពន្លះព្រះអរហត្តបាន, ព្រោះហេតុដូច្នោះ ទើបកម្មវិបាកនោះ ឈ្មោះថា មិនបានមានហើយដល់ព្រះអរហន្តនោះទេ ។ កម្មណាដែលសន្សំហើយក្នុងអតីតៈ រមែងឱ្យផលក្នុងភពនេះ, កម្មនោះ ឈ្មោះថា **មិនបានមានហើយ** តែឈ្មោះថា **កម្មវិបាកនៅមាន** ។ កម្មណារមែងដល់សេចក្ដីជាអវិបាក (គឺមិនឱ្យផល) ដោយន័យមុននោះឯង, **កម្មនោះបានមានហើយ ឈ្មោះថា កម្មវិបាករមែងមិនមាន** ។ កម្មណាដែលសន្សំប្រមូលផ្ដុំហើយក្នុង

អតីតៈ នឹងឱ្យផល ក្នុងអនាគត កម្មនោះបានមានហើយ ឈ្មោះថា **កម្មវិបាកនឹងមាន** ។ កម្មណានឹងប្រាកដជាអវិបាក ដោយន័យមុននោះឯង, កម្មនោះបានមានហើយ ឈ្មោះថា **កម្មវិបាកនឹងមិនមាន** ។ កម្មណាដែលប្រមូលផ្ដុំក្នុងភពនេះនឹងឱ្យផលក្នុងភពនេះ ឯង, កម្មនោះ រមែងមាន ឈ្មោះថា **កម្មវិបាក ក៏នៅមាន**; កម្មណា រមែងប្រាកដ ជាអវិបាកដោយន័យមុននោះឯង, កម្មនោះនៅមាន ឈ្មោះថា **កម្មវិបាករមែងមិនមាន** ។ កម្មណាដែលប្រមូលផ្ដុំហើយក្នុងភពនេះ នឹងឱ្យផលក្នុងអនាគត, កម្មនោះនៅមាន ឈ្មោះថា **កម្មវិបាកនឹងមាន**; កម្មណា ដែលដល់សេចក្ដីជាអវិបាក ដោយន័យមុននោះឯង, កម្មនោះមាន ឈ្មោះថា **កម្មវិបាកនឹងមិនមាន** ។ សូម្បីកម្មណាខ្លួនឯងជាអនាគត, សូម្បីវិបាករបស់កម្មនោះ ក៏ជាអនាគត, កម្មនោះនឹងមាន ឈ្មោះថា **កម្មវិបាកក៏នឹងមាន** ។ កម្មណាខ្លួនឯងមាននឹងដល់ភាពជាអវិបាក (មិនឱ្យផល) ដោយន័យមុននោះឯង, កម្មនោះនឹងមាន ឈ្មោះថា **កម្មវិបាកនឹងមិនមាន** ។

ពាក្យថា “**ឥទំ តថាគតស្ស** = នេះជាកម្លាំងរបស់ព្រះតថាគត” នេះ បណ្ឌិតគប្បីជ្រាបញាណជាគ្រឿងកំណត់ដឹងសេចក្ដីផ្សេងនៃកម្ម និងវិបាក របស់ព្រះតថាគត សូម្បីដោយអាការទាំងពួងនេះ គប្បីជ្រាបថា “ជាកម្លាំងទី ២ ព្រោះអត្ថថា **អកម្បិយដ្ឋេន** = មិនញញើតញញើម” ដូច្នេះ ៕

**ចប់និទ្ទេសនៃកម្លាំងទី ២**

## អធិប្បាយញាណជាកម្លាំងទី ៣

ពាក្យថា **“មគ្គោ, បដិបទា** = ផ្លូវ” នេះ ជាឈ្មោះរបស់កម្មនោះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **“និរយគាមិនី** = ទៅកាន់នរក” ជាដើម ឈ្មោះថា **នរក** ព្រោះអត្ថថា **និរស្សាទដ្ឋេន** = ដែលជាទីមិនពេញចិត្ត និងព្រោះអត្ថថា **និរតិអដ្ឋេន** = ជាទីរកសេចក្ដីត្រេកអរមិនបាន ។ ឈ្មោះថា **តិរច្ឆាន** ព្រោះអត្ថថា ឃ្លាតចាកអត្តភាព ទៅតាមខាងលើ មិនសណ្ដូកត្រង់ឡើងទៅ (ទៅទទឹង) ។ តិរច្ឆាននោះឯង ឈ្មោះថា **កំណើតសត្វតិរច្ឆាន** ។ ឈ្មោះថា **បិត្តិ** (ប្រេត) ព្រោះភាពជាអ្នកលះទៅហើយ អធិប្បាយថា ព្រោះសេចក្ដីដែលខ្លួនលះលោកនេះទៅហើយ ។ ប្រេតនោះឯង ឈ្មោះថា **ប្រេតវិស័យ** ។

ឈ្មោះថា **មនុស្ស** ព្រោះជាអ្នកមានចិត្តខ្ពង់ខ្ពស់ = **មនស្ស ឧស្សន្នតាយ > មនុស្សា**, មនុស្សនោះឯង ឈ្មោះថា **មនុស្សលោក**; ឈ្មោះថា **ទេវៈ** (ទេព) ព្រោះអត្ថថា រមែងរីករាយមានប្រមាណច្រើនដោយបញ្ចកាមគុណ ឬថា ដោយសម្បត្តិជាហេតុ, ទេវៈនោះឯង ឈ្មោះថា **ទេវលោក** ។ តណ្ហា ព្រះមានព្រះភាគត្រាស់ហៅថា **វានៈ** (គ្រឿងចងរឹត), វានៈនោះរមែងមិនមានក្នុងទីនោះ ព្រោះហេតុនោះ ទីនោះ ទើបឈ្មោះថា **និព្វាន** ។ ឈ្មោះថា (ផ្លូវ) **ទៅកាន់នរក** ព្រោះអត្ថថា រមែងទៅកាន់នរក ។ ព្រះភគវាទ្រង់ត្រាស់សំដៅយកផ្លូវនេះ ។ម្យ៉ាងទៀត បដិបទាក៏ឈ្មោះថា ផ្លូវទៅកាន់នរកដែរ; សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដែរ ។

**ព្រះតថាគតរមែងទ្រង់ជ្រាបសូម្បីបដិបទាទាំងពួងនេះ; តើយ៉ាងណា?**

ក៏កាលជនទាំងឡាយសូម្បីនៅក្នុងស្រុកទាំងអស់ រួមគ្នាសម្លាប់ជ្រូកមួយ ឬ

ម្រឹគមួយចាកជីវិត សូម្បីចេតនារបស់ជនទាំងអស់ រមែងមានជីវិតិន្ទ្រិយរបស់សត្វដទៃ ជាអារម្មណ៍គ្រប់ៗ គ្នា, តែថាកម្មនោះរបស់បុគ្គលទាំងនោះរមែងផ្សេងគ្នា ព្រោះសេចក្ដីព្យាយាមនោះឯង ។ ព្រោះថា ក្នុងជនទាំងនោះ មនុស្សមួយមានសេចក្ដីពេញចិត្តកើតឡើង រមែងធ្វើការសម្លាប់ដោយសេចក្ដីអើពើ, មនុស្សមួយរមែងធ្វើព្រោះត្រូវអ្នកដទៃ បង្ខំដោយពាក្យថា "លោកចូរមក, លោកចូរធ្វើការសម្លាប់" , មនុស្សមួយមិនឃាត់ឃាំងការសម្លាប់ ត្រាច់ទៅហាក់ដូចជាថា មានសេចក្ដីពេញចិត្តផង (ស្មើគ្នា) ។ ក្នុងជនទាំងនោះ មនុស្សមួយរមែងកើតក្នុងនរកដោយកម្មនោះៗឯង, មនុស្សមួយរមែងកើត ក្នុងកំណើតសត្វតិរច្ឆាន, មនុស្សមួយរមែងកើតក្នុងបេតវិស័យ (កំណើតប្រេត) ។

ព្រះតថាគត រមែងទ្រង់ជ្រាបថា "អ្នកនេះនឹងកើតក្នុងនរក, អ្នកនេះនឹងកើតក្នុងកំណើតសត្វតិរច្ឆាន, អ្នកនេះនឹងកើតក្នុងបេតវិស័យ ព្រោះសេចក្ដីដែលបុគ្គលនោះ ព្យាយាមហើយដោយកិរិយាអាការនេះ ក្នុងខណៈនៃសេចក្ដីព្យាយាមនោះឯង" ដូច្នេះ ។ រមែងទ្រង់ជ្រាបថា "បណ្ដាបុគ្គលទាំងឡាយសូម្បីកាលនឹងកើតក្នុងនរក អ្នកនេះនឹងកើតក្នុងមហានរក ៨ រណ្ដៅ, អ្នកនោះនឹងកើតក្នុងឧស្សទ (នរកដែលប្រជ្រៀតចូលប្រទាក់ប្រទើស) ១៦ រណ្ដៅ" ដូច្នេះ; រមែងទ្រង់ជ្រាបថា "សូម្បីអ្នកណានឹងទៅកើតក្នុងកំណើតសត្វតិរច្ឆានអ្នកនោះ នឹងជាសត្វមិនមានជើង, អ្នកនោះនឹងជាសត្វជើង ២, អ្នកនេះនឹងជាសត្វជើង ៤, អ្នកនេះនឹងជាសត្វមានជើងច្រើន" ដូច្នេះ; រមែងទ្រង់ជ្រាបថា "សូម្បីអ្នកនេះ រមែងទៅកើតក្នុងបេតវិស័យ អ្នកនេះនឹងជានិជ្ឈាមតណ្ហិកប្រេត (ប្រេតអ្នកត្រូវសេចក្ដីលំបាកដុតបំផ្លាញ), អ្នកនេះនឹង

ជាខុប្បិបាសិកប្រេត (ប្រេតអ្នកស្រេកឃ្លាន), អ្នកនេះនឹងជាបរទត្តូបជីវិកប្រេត (ប្រេតអ្នកអាស្រ័យទានរបស់អ្នកដទៃចិញ្ចឹមជីវិត)” ដូច្នេះ; រមែងទ្រង់ជ្រាបថា “បណ្តាកម្មទាំងនោះ កម្មនេះ នឹងមិនអាចអូសទាញមកនូវបដិសន្ធិ (គឺឱ្យបដិសន្ធិ), កម្មនេះមានកម្លាំងខ្សោយ នឹងមានផលចងព័ន្ធព្រោះបដិសន្ធិដែលកម្មដទៃឱ្យហើយ” ដូច្នេះ ។

ម្យ៉ាងទៀត បណ្តាជនទាំងឡាយ អ្នកនៅក្នុងស្រុកទាំងអស់ រួមគ្នាប្រគេនអាហារបិណ្ឌបាត ក៏ហាក់ដូចគ្នា គឺថា សូម្បីចេតនារបស់ជនទាំងអស់នោះ រមែងមានអាហារបិណ្ឌបាតជាអារម្មណ៍មែនពិត ។ តែថា កម្មនោះ របស់បុគ្គលទាំងនោះ រមែងចែកផ្សេងគ្នាដោយន័យមុននោះឯង ក្នុងខណៈនៃសេចក្តីព្យាយាម។ ក្នុងជនទាំងនោះមនុស្សពួកខ្លះ រមែងកើតក្នុងទេវលោក, មនុស្សខ្លះកើតក្នុងមនុស្សលោក ។

ព្រះតថាគតរមែងទ្រង់ជ្រាបថា “បុគ្គលនេះនឹងកើតក្នុងមនុស្សលោក, អ្នកនេះ នឹងកើតក្នុងទេវលោក ព្រោះអ្នកនោះព្យាយាមហើយ ដោយកិរិយានេះ ក្នុងខណៈនៃសេចក្តីព្យាយាមនោះឯង” ដូច្នេះ ។

រមែងទ្រង់ជ្រាបថា “សូម្បីក្នុងបណ្តាអ្នកដែលនឹងកើតក្នុងទេវលោក អ្នកនេះ នឹងកើតក្នុងបរនិម្មិតវសវត្តីទាំងឡាយ (ជាន់ទី ៦), អ្នកនេះនឹងកើតក្នុងនិម្មានរតីទាំងឡាយ (ជាន់ទី ៥), អ្នកនេះនឹងកើតក្នុងតុសិតទាំងឡាយ (ជាន់ទី ៤), អ្នកនេះនឹងកើតក្នុងយាមាទាំងឡាយ (ជាន់ទី ៣), អ្នកនេះនឹងកើតក្នុងតាវត្តិង្សទាំងឡាយ (ជាន់ទី ២), អ្នកនេះនឹងកើតក្នុងចាតុម្មហារាជិកាទាំងឡាយ (ជាន់ទី ១), អ្នកនេះនឹងកើតក្នុងភូមិទេពទាំងឡាយ” ,

រមែងទ្រង់ជ្រាបថា អ្នកនេះ នឹងកើតជាទេវរាជដែលប្រសើរបំផុត, អ្នកនេះ នឹងកើតជាអ្នកទទួលបម្រើ មានតំណែងទី ២ ទី ៣ របស់ទេវរាជនោះ” ។

រមែងទ្រង់ជ្រាបថា “សូម្បីបណ្ដាអ្នកដែលនឹងកើតក្នុងមនុស្សទាំង-ឡាយ អ្នកនេះនឹងកើតក្នុងខត្តិយត្រកូល, អ្នកនេះនឹងកើតក្នុងត្រកូលព្រា-ហ្មណ៍..., ក្នុងត្រកូលឈ្មួញ (វេស្សៈ)..., ក្នុងត្រកូលសូទ្រៈ” ។

ទ្រង់ជ្រាបថា “ក៏បណ្ដាមនុស្សទាំងឡាយ អ្នកនេះនឹងកើតជាព្រះរាជា, អ្នកនេះនឹងកើតជាអ្នកបម្រើព្រះរាជាដែលមានតំណែងទី ២ ឬទី ៣” ។

រមែងទ្រង់ជ្រាបថា “បណ្ដាកម្មទាំងនោះ កម្មនេះនឹងមិនអាចដើម្បីទាញមកនូវបដិសន្ធិ (ឱ្យកើត), កម្មនេះមានកម្លាំងខ្សោយ នឹងឱ្យផលចងព័ន្ធ ព្រោះបដិសន្ធិដែលកម្មដទៃឱ្យហើយ” ។

ម្យ៉ាងទៀត កាលបើបុគ្គលទាំងនោះ ផ្ដើមតាំងវិបស្សនាហើយទុំះឯង នឹងមានវិបស្សនាដែលប្រារព្ធហើយ ដោយកិរិយាអាការ យ៉ាងណា, ព្រះភគវារមែងទ្រង់ជ្រាបថា “អ្នកនេះនឹងសម្រេចព្រះអរហត្ត, អ្នកនេះនឹងមិនអាចដើម្បីពន្លុះព្រះអរហត្ត, អ្នកនេះនឹងជាព្រះសោតាបន្នប៉ុណ្ណោះ, ក៏បុគ្គលនេះ នឹងមិនអាចដើម្បីធ្វើឱ្យជាក់ច្បាស់នូវមគ្គផល, អ្នកនេះនឹងតាំងនៅក្នុងវិបស្សនាដែលមានត្រឹមតែលក្ខណៈ ជាអារម្មណ៍, អ្នកនេះនឹងតាំងនៅក្នុងបច្ចយបរិគ្គហញាណ (ញាណដែលកំណត់ដឹងនូវបច្ច័យ) ប៉ុណ្ណោះ, អ្នកនេះនឹងតាំងនៅក្នុងនាមរូបបរិគ្គហញាណ (ញាណដែលកំណត់ដឹងនាមនិងរូប) ប៉ុណ្ណោះ, អ្នកនេះ នឹងតាំងនៅក្នុងអរូបបរិគ្គហញាណ (ញាណដែលកំណត់ដឹងអរូប) ប៉ុណ្ណោះ, អ្នកនេះនឹងតាំងនៅក្នុងរូបបរិគ្គហញាណប៉ុណ្ណោះ, អ្នកនេះនឹង

កំណត់ដឹងបានត្រឹមតែមហាភូតប៉ុណ្ណោះ, អ្នកនេះមិនអាចដើម្បីកំណត់ដឹងអ្វីៗ បានឡើយ" ដូច្នេះ ។

សូម្បីកាលព្រះយោគាវចរទាំងឡាយ កំពុងធ្វើកសិណបរិកម្ម ព្រះមានជោគ រមែងទ្រង់ជ្រាបថា "កសិណបរិកម្មរបស់អ្នកនេះ នឹងប្រព្រឹត្តទៅត្រឹមតែបរិកម្មប៉ុណ្ណោះ, នឹងមិនអាចដើម្បីឱ្យនិមិត្តកើតឡើងបាន, អ្នកនេះនឹងអាចដើម្បីឱ្យនិមិត្តកើតឡើង, ក៏នឹងមិនអាចដើម្បីឱ្យអប្បនាកើតឡើងបាន, អ្នកនេះ នឹងដល់អប្បនា ហើយធ្វើឈានឱ្យជាបាទ ផ្ដើមតាំងវិបស្សនា ទើបនឹងកាន់យកព្រះអរហត្តបាន" ដូច្នេះ ៕

ចប់និទ្ទេសនៃកម្លាំងទី ៣

## អធិប្បាយញាណជាកម្លាំងទី ៤

ពាក្យថា "**ខន្ធនានត្តំ** = ជាសេចក្ដីផ្សេងគ្នានៃខន្ធ" អធិប្បាយថា ព្រះភគវារមែងទ្រង់ជ្រាបហេតុផ្សេងៗ នៃខន្ធទាំង ៥ យ៉ាងនេះថា "នេះឈ្មោះថា រូបក្ខន្ធ ។ល ។ នេះ ឈ្មោះថា វិញ្ញាណក្ខន្ធ" ដូច្នេះ ។ សូម្បីក្នុងបណ្ដាខន្ធទាំងនោះ ព្រះមានព្រះភាគ រមែងទ្រង់ជ្រាបសេចក្ដីដែលខន្ធនីមួយៗ បែកផ្សេងគ្នាយ៉ាងនេះ "គឺរូបក្ខន្ធមានមួយយ៉ាង ។ល ។ រូបក្ខន្ធមានច្រើនយ៉ាង; វេទនាខន្ធមានមួយយ៉ាង ។ល ។ វេទនាខន្ធមានច្រើនយ៉ាង; សញ្ញាខន្ធមានមួយយ៉ាង ។ល ។ សញ្ញាខន្ធមានច្រើនយ៉ាង; សង្ខារក្ខន្ធមានមួយយ៉ាង ។ល ។ សង្ខារក្ខន្ធមានច្រើនយ៉ាង; វិញ្ញាណក្ខន្ធមានមួយយ៉ាង ។ល ។ វិញ្ញាណក្ខន្ធមានច្រើនយ៉ាង" ដូច្នេះ ។

ពាក្យថា "**អាយតននានត្តំ** = សេចក្ដីផ្សេងៗ នៃអាយតនៈ" នេះ ព្រះ

សាស្តារមែងទ្រង់ជ្រាបសេចក្តីប្លែកផ្សេងគ្នានៃអាយតនៈ យ៉ាងនេះថា “នេះឈ្មោះថា ចក្ខាយតនៈ ។ ល ។ នេះឈ្មោះថា ធម្មាយតនៈ; ក្នុងអាយតនៈទាំងនោះ កាមាវចរមាន ១០ អាយតនៈ, អាយតនៈដែលប្រព្រឹត្តទៅក្នុងភូមិ ៤ មាន ២ អាយតនៈ” ដូច្នេះ ។

ពាក្យថា “**ធាតុនានត្តំ** = សេចក្តីផ្សេងគ្នានៃធាតុ” អធិប្បាយថា ព្រះភគវាទ្រង់ជ្រាបសេចក្តីផ្សេងគ្នានៃធាតុ យ៉ាងនេះថា “នេះឈ្មោះថា ចក្ខុធាតុ ។ ល ។ នេះ ឈ្មោះថា មនោវិញ្ញាណធាតុ ។ ក្នុងធាតុទាំងនោះ កាមាវចរធាតុមាន ១៦ ។ ធាតុដែលប្រព្រឹត្តទៅក្នុងភូមិ ៤ មាន ២ ធាតុ” ។

ពាក្យថា “**អនេកធាតុ នានាធាតុ លោកនានត្តំ** = ភាពផ្សេងគ្នានៃលោកធាតុដែលជាអនេកធាតុ និងនានាធាតុ” ទៀតនេះ ព្រះមានព្រះភាគទ្រង់កាន់យកដើម្បីសម្តែងថា ព្រះតថាគតទ្រង់ជ្រាបសេចក្តីផ្សេងគ្នានៃលោក គឺឧបាទិន្នកសង្ខារនេះ ត្រឹមតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែនទេ, រមែងទ្រង់ជ្រាបសូម្បីសេចក្តីផ្សេងគ្នានៃលោក គឺឧបាទិន្នកសង្ខារផងនោះឯង ។

ក៏ព្រះបច្ចេកពុទ្ធទាំងឡាយ និងព្រះអគ្គសាវ័កទាំងពីរ រមែងជ្រាបសូម្បីសេចក្តីផ្សេងគ្នានៃលោក គឺឧបាទិន្នកសង្ខារដោយឯកទេស (ដោយចំណែកមួយ) ប៉ុណ្ណោះ, រមែងមិនជ្រាបសេចក្តីដោយពិស្តារ (គឺដោយមិនសេសសល់); និងមិនជ្រាបសេចក្តីផ្សេងគ្នានៃអនុបាទិន្នកសង្ខារ ។ ចំណែកព្រះសព្វញ្ញុពុទ្ធ រមែងទ្រង់ជ្រាបសេចក្តីផ្សេងគ្នានៃលោក គឺអនុបាទិន្នកសង្ខារយ៉ាងនេះថា “ដើមឈើនេះរមែងមានពណ៌សខ្លះ ព្រោះមានធាតុឈ្មោះនេះច្រើន ដើមឈើនេះមានពណ៌ខ្មៅខ្លះ...,

ដើមឈើនេះមានសម្បករលោងខ្លះ..., ដើមឈើនេះមានសម្បកក្រាស់ខ្លះ..., ដើមឈើនេះមានសម្បកស្តើងខ្លះ ព្រោះមានធាតុឈ្មោះនេះច្រើន; ស្លឹករបស់ដើមឈើនេះមានរូបយ៉ាងនេះ ដោយអំណាចនៃពណ៌ និងសណ្ឋានជាដើម ព្រោះមានធាតុឈ្មោះនេះច្រើន; ផ្កាដើមឈើនេះ មានពណ៌ខៀវ ព្រោះមានធាតុឈ្មោះនេះច្រើន, មានពណ៌លឿង... មានពណ៌ក្រហម... មានពណ៌ស... មានក្លិនក្រអូប... មានក្លិនស្អុយ...; មានផ្លែតូចៗ..., មានផ្លែធំ... មានផ្លែវែង... មានផ្លែខ្លី... មានផ្លែមូល... មានសណ្ឋានល្អ... មានសណ្ឋានអាក្រក់... មានផ្លែរលោង... មានផ្លែគ្រោតគ្រាត... មានក្លិនក្រអូប... មានក្លិនស្អុយ... មានរសផ្អែម... មានរសល្វីង... មានរសជូរ... មានរសហឹរ... មានរសចត់ ព្រោះមានធាតុឈ្មោះនេះច្រើន; ឯបន្លាដើមឈើនេះស្រួច, មានបន្លាមិនស្រួច, មានបន្លាត្រង់, មានបន្លាវៀច, មានពណ៌ក្រហម, មានពណ៌ខ្មៅ, មានពណ៌ខៀវ, មានពណ៌ស ព្រោះមានធាតុឈ្មោះនេះច្រើន" ដូច្នេះ; ព្រោះថា ញាណនេះជាកម្លាំងនៃព្រះសព្វញ្ញុពុទ្ធប៉ុណ្ណោះ, មិនជាកម្លាំងរបស់ជនទាំងឡាយដទៃឡើយ ៕

**ចប់អធិប្បាយកម្លាំងទី ៤**

## អធិប្បាយញាណជាកម្លាំងទី ៥

ពាក្យថា **"ហីនាធិមុត្តិកា"** បានដល់ អធ្យាស្រ័យដែលអាក្រក់គ្រោតគ្រាត ។ ពាក្យថា **"បណីតាធិមុត្តិកា"** បានដល់ មានអធ្យាស្រ័យល្អ ។ ពាក្យថា **"សេវន្តិ"** បានដល់ (រមែងសេពគប់ រមែងសមាគម) រមែងអាស្រ័យ រមែងជាប់

ចិត្ត ។ ពាក្យថា **"តវន្តិ"** បានដល់ ការចូលទៅជិត ។ ពាក្យថា **"បយិរុបាសន្តិ"** បានដល់ ការចូលទៅរកញយៗ; ពិតមែន បើថាលោកអាចារ្យ និងឧបជ្ឈាយ៍មិនមានសីល, សទ្ធិវិហារិក (អ្នកនៅរួម) មានសីល, សទ្ធិវិហារិកទាំងនោះ រមែងមិនចូលទៅ សូម្បីក្បែរអាចារ្យ និងឧបជ្ឈាយ៍របស់ខ្លួន, រមែងចូលទៅក្បែរភិក្ខុអ្នកសមគួរប្រហែលនឹងខ្លួនប៉ុណ្ណោះ ។ បើថា អាចារ្យ និងឧបជ្ឈាយ៍រូបណាជាអ្នកមានសីល, សទ្ធិវិហារិកមិនមានសីល ក៏រមែងមិនចូលទៅជិតអាចារ្យ និងឧបជ្ឈាយ៍, រមែងចូលទៅជិតភិក្ខុអ្នកមានអធ្យាស្រ័យអាក្រក់ដូចនឹងខ្លួនប៉ុណ្ណោះ ។ ក៏ការចូលទៅគប់រកសមាគមដោយអាការយ៉ាងនេះ មិនមានក្នុងកាលពេលនេះប៉ុណ្ណោះ, ដើម្បីសម្ដែងថា "មានហើយសូម្បីត្រឹមតែក្នុងអតីតកាល និងមានក្នុងអនាគតកាល" ដូច្នេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **"អតីតម្បិ អទ្ធានំ"** ជាដើម ។ ពាក្យនោះ មានអត្ថងាយស្រួលទាំងអស់ ។

***សួរថា*** បុគ្គលអ្នកទ្រុស្តសីលគប់រក សមាគមរកនឹងអ្នកទ្រុស្តសីលដូចគ្នា, បុគ្គលអ្នកមានសីល គប់រក សមាគមរក នឹងអ្នកមានសីលដូចគ្នា, អ្នកមានបញ្ញាថោកទាប គប់រក សមាគមរក នឹងអ្នកមានបញ្ញាថោកទាបដូចគ្នា, បុគ្គលអ្នកមានបញ្ញាល្អគប់រក សមាគមរកនឹងអ្នកមានបញ្ញាល្អដូចគ្នាប៉ុណ្ណោះ ។ អ្វីរមែងកំណត់ ?

ឆ្លើយថា អជ្ឈាសយធាតុ (សេចក្ដីពេញចិត្តដែលជាមូលហេតុខាងដើម) រមែងកំណត់ ។

បានឮថា ភិក្ខុទាំងឡាយមានចំនួនច្រើន រមែងត្រាច់ទៅកាន់ស្រុកមួយជាការទៅដើម្បីភិក្ខាជាគណៈ ។ ពួកមនុស្សនាំអាហារចំនួនច្រើន ដាក់បាត្រឱ្យពេញ

ប្រគេនហើយ ក៏បញ្ជូនទៅដោយពាក្យថា “សូមលោកទាំងឡាយ និមន្តឆាន់អាហារតាមចំណែករបស់ខ្លួនចុះ” ដូច្នេះ; សូម្បីភិក្ខុទាំងឡាយ ក៏ពោលថា “ម្នាលអ្នកមានអាយុ ពួកមនុស្សរមែងប្រកបការងារ ដែលប្រកបព្រមដោយធាតុ (សេចក្តីពេញចិត្ត)” ។ សូម្បីព្រះថេរៈ ឈ្មោះថា **ចូឡាភ័យ** ដែលទ្រទ្រង់ព្រះត្រៃបិដក កាលទៅព្រមនឹងភិក្ខុ ៥០០ រូប ដើម្បីសំពះព្រះចេតិយក្នុងនាគទីប អ្នកដែលមនុស្សទាំងឡាយ ក្នុងស្រុកមួយនិមន្តហើយ ។ ក៏ក្នុងភិក្ខុទាំងនោះ មួយរូបជាអ្នកមិនល្មមសមគួរនឹងទៅជាមួយព្រះថេរៈ សូម្បីក្នុងវិហារជិតបង្កើយ ក៏មានភិក្ខុអ្នកមិនល្មមសមគួរមួយរូប; លុះកាលភិក្ខុទាំងពីរ រូបចូលមកកាន់ស្រុក សូម្បីជនទាំងពីរនោះ គឺភិក្ខុអ្នកអាស្រ័យនៅមុន និងអាគន្តុកភិក្ខុ ដែលមិនធ្លាប់ឃើញអាគន្តុកមកមុន ទាំងអាគន្តុកភិក្ខុ ក៏មិនធ្លាប់ឃើញភិក្ខុអ្នកមកមុន, លុះកាលសូម្បីសេចក្តីជាយ៉ាងនោះ មានភិក្ខុទាំងពីររូបនោះ ក៏ចូលគ្នាបាន ក៏នាំគ្នាសើចហើយៗ បានឈរនិយាយគ្នានៅក្នុងទិសមគួរមួយចំណែក; ព្រះថេរៈឃើញហើយ ទើបពោលថា “ធាតុសំយុត្ត (សំដៅដល់ការប្រកបព្រមដោយសេចក្តីពេញចិត្តដល់គ្នានឹងគ្នា ជាមូលហេតុ) ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ជ្រាប ហើយត្រាស់ទុក” ។

គ្រាពោលថា ធាតុ គឺអធ្យាស្រ័យ (សេចក្តីពេញចិត្ត) រមែងកំណត់យ៉ាងនេះហើយ គប្បីសម្តែងសេចក្តីនេះនោះឯង ដោយធាតុសំយុត្ត ដូចតទៅនេះថា ៖

ក៏ព្រះមានព្រះភាគទ្រង់ផ្ទំលើព្រះដំណេកសម្រាប់អ្នកឈឺ ក្នុងទីជិតភ្នំគិជ្ឈកូដ ទតឃើញភិក្ខុអ្នកជាប្រធានតែមួយរូប ដែលដើរចង្ក្រមជាមួយនឹងបរិស័ទរបស់ខ្លួនៗ ក្នុងភិក្ខុទាំងឡាយ មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម អ្នកឡោម-

ព័ទ្ធ ដើម្បីប្រយោជន៍ដល់ការរក្សាព្រះអង្គ ទើបត្រាស់ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរមើលព្រះសារីបុត្ររបស់តថាគត ដែលកំពុងដើរ ចង្ក្រមជាមួយពួកភិក្ខុជាច្រើន; ភិក្ខុទាំងឡាយក្រាបទូលថា "ពិតមែនហើយព្រះអង្គ"។ បណ្ឌិតគប្បីញុំាងពាក្យទាំងពួងថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយនោះឯង មានបញ្ញាច្រើន" ជាដើម ឱ្យពិស្តារចុះ ៕

**ចប់អធិប្បាយកម្លាំងទី ៥**

## អធិប្បាយញាណជាកម្លាំងទី ៦

សត្វទាំងឡាយរមែងប្រាថ្នា រមែងអាស្រ័យក្នុងសភាវៈណា, សភាវៈនោះជាទី អាស្រ័យរបស់សត្វទាំងឡាយ គឺជាទិដ្ឋិគតៈ (សេចក្តីយល់ឃើញខុស) ក៏ដោយ ជាយថាភូតញ្ញាណ (ញាណដឹងតាមសេចក្តីពិត) ក៏ដោយ ឈ្មោះថា **អាសយៈ** ។ កិលេសដែលដេកត្រាំក្នុងខន្ធសន្តាន ដែលនៅមិនទាន់លះបាន ឈ្មោះថា **អនុស័យ** ។ កុសល និងអកុសល ដែលសង្ខារទាំងឡាយ មានកាយសង្ខារជាដើម តាក់តែងហើយ ឈ្មោះថា **ចរិត** ។ អធ្យាស្រ័យ ឈ្មោះថា **អធិមុត្តិ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា "**អប្បរជក្ខេ** = មានធូលីតិច" ជាដើម ឈ្មោះថា មានធូលី គឺកិលេសតិច ព្រោះថា ធូលី គឺរាគៈ ទោសៈ និងមោហៈ ក្នុងកែវភ្នែក គឺបញ្ញារបស់ពួកសត្វទាំងនោះមានតិច គឺបន្តិចបន្តួច ។ ឈ្មោះថា ធូលី គឺ **កិលេសមានច្រើន** ព្រោះសេចក្តីដែលបុគ្គលនោះឯង មានកិលេសក្រាស់ណែន ។ ក៏ព្រះមានជោគ រមែងទ្រង់សម្តែងនូវសេចក្តីដែលសត្វទាំងឡាយ អ្នកមានកិលេស

តិច និងមានកិលេសច្រើន ដោយបទសូម្បីទាំងពីរនោះ ។ ឥន្ទ្រិយទាំងឡាយ មានសទ្ធិន្ទ្រិយជាដើម របស់បុគ្គលណាចាស់ក្លា, បុគ្គលទាំងនោះ ឈ្មោះថា **មានឥន្ទ្រិយចាស់ក្លា** ។ ឥន្ទ្រិយទាំងនោះ របស់បុគ្គលណាទន់ខ្សោយ បុគ្គលទាំងនោះ ឈ្មោះថា **មានឥន្ទ្រិយទន់ខ្សោយ** ។ កោដ្ឋាសៈ (ពួកធម៌ទាំងនោះ) មានអាសយៈជាដើម របស់បុគ្គលណាល្អ, បុគ្គលទាំងនោះ ឈ្មោះថា **មានអាការល្អ** ។ កោដ្ឋាសៈទាំងនោះ របស់បុគ្គលណាវិបរិត (ខុសទៅចាកសេចក្ដីល្អ) បុគ្គលនោះ ឈ្មោះថា **មានអាការអាក្រក់** ។ បុគ្គលទាំងឡាយណា រមែងកំណត់ហេតុ (ការណៈ) ដែលគេពោលណែនាំហើយ, អាចដើម្បីដឹងបានដោយងាយ, បុគ្គលទាំងនោះ ឈ្មោះថា **ណែនាំឱ្យដឹងបានដោយងាយ** ។ វិបរិត (ខុសទៅអំពីនេះ) ឈ្មោះថា **ណែនាំឱ្យដឹងបានដោយលំបាក** ។ បុគ្គលណាជាអ្នកសមគួរ គឺជាអ្នកដល់ព្រមដោយធម៌ដែលជាឧបនិស្ស័យ ដើម្បីចាក់ធ្លុះមគ្គផល, បុគ្គលនោះ ឈ្មោះថា **អ្នកសមគួរដល់ការត្រាស់ដឹង**; វិបរិតទៅអំពីនេះ ឈ្មោះថា អ្នកអភព្វ គឺមិនគួរដើម្បីត្រាស់ដឹង ។

ព្រះសាស្ដាគ្រាទ្រង់តាំងមាតិកា (មេបទ) នៃញាណជាកម្លាំងទី ៦ ដោយអាការយ៉ាងនេះហើយ ពេលនេះ កាលនឹងចែកសេចក្ដីតាមលំដាប់ ទើបត្រាស់ពាក្យជាដើមថា **“កតមោ ច សត្តានំ អាសយោ** = ក៏អាសយៈ (ឆន្ទៈជាទីមកដេកនៃចិត្ត) របស់សត្វទាំងឡាយ តើដូចម្ដេច ?” ។

ក៏សេចក្ដីនៃពាក្យថា **“សស្សតោ លោកោ** = លោកទៀង” ជាដើម ខ្ញុំពោលទុកក្នុងនិក្ខេបកណ្ឌវណ្ណនា ក្នុងគ្រាក្រោយនោះឯង ។ម្យ៉ាងទៀត ពាក្យថា **“ឥតិ ភវទិដ្ឋិសន្និស្សិតា វា** = អាស្រ័យភវទិដ្ឋិ” បានដល់ សត្វទាំងឡាយអ្នក

អាស្រ័យសស្សតទិដ្ឋិ ដោយអាការយ៉ាងនេះ ។ ពិតមែន សស្សតទិដ្ឋិ ព្រះភគវា ត្រាស់ថា **“ភវទិដ្ឋិ”** ក្នុងទីនេះ, ឧច្ឆេទទិដ្ឋិត្រាស់ហៅថា **“វិភវទិដ្ឋិ”** ។ ព្រោះថា សត្វទាំងឡាយ អ្នកមានសេចក្តីយល់ឃើញខុសទាំងឡាយនេះ រមែងអាស្រ័យទិដ្ឋិទាំងពីរនេះប៉ុណ្ណោះ ព្រោះថា ទិដ្ឋិទាំងអស់ ព្រះមានព្រះភាគទ្រង់សង្គ្រោះទុកដោយសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ សូម្បីពាក្យនេះព្រះមានជោគត្រាស់ទុកថា “ម្នាលកច្ចាយនៈ ក៏ឯសត្វលោកអាស្រ័យទិដ្ឋិទាំងពីរនេះ ដោយច្រើន គឺឃើញថា (វត្ថុទាំងពួង) មាន (អត្ថិតំ) និង (វត្ថុទាំងពួង) មិនមាន (នត្ថិតំ)” [៤២] ដូច្នេះ ។ ក៏ក្នុងទិដ្ឋិទាំងពីរនោះ សេចក្តី ឃើញថា ទៀង ឈ្មោះថា **អត្ថិតា** = មាន, សេចក្តីឃើញថា ដាច់សូន្យ ឈ្មោះថា **នត្ថិតា** = មិនមាន; នេះជាអាសយៈរបស់សត្វទាំងឡាយ អ្នកជាបុថុជ្ជនដែលអាស្រ័យវដ្តៈ ៕

## សម្តែងអំពីអាសយៈរបស់សត្វដែលមិនអាស្រ័យវដ្តៈ

ឥឡូវនេះ ព្រះសាស្តាដើម្បីសម្តែងអាសយៈរបស់សត្វអ្នកបរិសុទ្ធ អ្នកមិនអាស្រ័យវដ្តៈ ទើបព្រះអង្គត្រាស់ពាក្យជាដើមថា **“ឯតេច បន ឧភោ អន្តេ អនុបគម្ម** = ក៏បើថា សត្វទាំងឡាយមិនចូលទៅអាស្រ័យចំណែកទីបំផុតទាំង ២” នេះ ។

បណ្តាពាក្យទាំងនោះ ពាក្យថា **“ឯតេ ចរា បន”** បានដល់ ក៏ឬថា សត្វទាំងនោះៗ ឯង ។ ពាក្យថា **“ឧភោ អន្តេ”** បានដល់ ចំណែកទីបំផុត ២ យ៉ាង ពោលគឺសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ ពាក្យថា **“អនុបគម្ម”** បានដល់ មិនប្រកាន់

---

[៤២] សំ. និ. ។

មាំហើយ ។ ពាក្យថា **“ឥទប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ** = ក្នុងធម៌ទាំងឡាយ ដែលជាបច្ច័យរបស់គ្នានឹងគ្នា និងអាស្រ័យគ្នានឹងគ្នាកើតឡើង” បានដល់ក្នុងធម៌ទាំងឡាយ ដែលជាបច្ច័យដល់គ្នានឹងគ្នា និងធម៌ទាំងឡាយដែលអាស្រ័យគ្នានឹងគ្នាកើតឡើង ។ ពាក្យថា **“អនុលោមិកា ខន្តិ”** បានដល់ វិបស្សនាញាណ ។ ពាក្យថា **“យថាភូតំ ញាណំ”** បានដល់ មគ្គញ្ញាណ ។ ព្រះសម្ពុទ្ធទ្រង់អធិប្បាយទុកថា ៖

វិបស្សនាដែលយោគាវចរមិនអាស្រ័យនូវចំណែកទីបំផុត ២ គឺ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិទាំងនេះ ក្នុងបដិច្ចសមុប្បាទ (គឺក្នុងការកើតឡើងនៃអវិជ្ជាជាដើម) និងក្នុងធម៌ដែលអាស្រ័យគ្នានឹងគ្នាកើតឡើង យ៉ាងណា, ឯមគ្គញ្ញាណដែលក្រៃលែងជាងវិបស្សនាញាណនោះ, នេះ ហៅថា **អាសយៈ** របស់សត្វទាំងឡាយ, ក៏សេចក្ដីនេះឯង ជាអាសយៈរបស់សត្វទាំងឡាយ សូម្បីទាំងអស់ដែលអាស្រ័យវដ្តៈ និងមិនអាស្រ័យវដ្តៈ, ទើបឈ្មោះថា នេះជាទីនៅអាស្រ័យរបស់សត្វទាំងឡាយ ។ នេះជាពាក្យដែលមានសេចក្ដីស្មើគ្នារបស់អាចារ្យទាំងឡាយ ៕

## ពាក្យរបស់អាចារ្យទាំងឡាយ

ក៏អាចារ្យវិតណ្ឌវាទី (អ្នកមានប្រក្រតីនិយាយជំទាស់) ពោលថា “ធម្មតាថា មគ្គដែលទម្លាយទីនៅ រមែងទៅ, មិនមែនឬ ? ព្រោះហេតុអ្វី ទើបលោកពោលថា មគ្គ គឺជាទីនៅអាស្រ័យរបស់សត្វទាំងឡាយ ?” ដូច្នេះ; គប្បីដេញដោលអាចារ្យនោះថា “លោកមានសូត្រ ព្រោះថាជាទីនៅដែលជារបស់ព្រះអរិយៈឬ ?”

ក៏បើថា អាចារ្យវិតណ្ឌវាទីពោលថាមាន, ក៏គប្បីពោលនឹងអាចារ្យនោះថា “លោកមិនដឹងព្រោះសូត្រនោះ លោកមិនទ្រទ្រង់ទុក” ; បើអាចារ្យវិតណ្ឌវាទីពោលថា “ខ្ញុំជាអ្នកទ្រទ្រង់សូត្រ” ដូច្នេះ, គប្បីពោលថា “សូមលោកចូរនាំសូត្រមក” ដូច្នេះ; បើអាចារ្យវិតណ្ឌវាទីនាំមក, នោះជាការល្អ, បើមិននាំមក, គប្បីនាំមកដោយខ្លួនឯងថា “**ទសយិមេ ភិក្ខវេ អរិយវាសា, យេ អរិយា អាវសឹសុ វា អាវសន្តិ វា អាវសិស្សន្តិ វា** = ម្នាលភិក្ខុទាំងឡាយ ទីនៅដែលប្រសើរ ១០ ពួកនេះ គឺព្រះអរិយៈទាំងឡាយ អាស្រ័យហើយ ឬកំពុងអាស្រ័យ ឬថា នឹងអាស្រ័យឯណា”[៤៣] ជាដើម ។ ពិតមែន សូត្រនេះ រមែងសម្តែងនូវសេចក្តីដែលមគ្គជាទីនៅអាស្រ័យ, ព្រោះហេតុដូច្នោះ ទើបពាក្យនោះ ជាពាក្យដែលព្រះមានព្រះភាគត្រាស់ទុកល្អហើយនោះឯង ។

ម្យ៉ាងទៀត ព្រះសាស្តារមែងទ្រង់ជ្រាបថា ធម៌នេះជាអាសយៈរបស់សត្វទាំងឡាយ និងរមែងទ្រង់ជ្រាបសូម្បីក្នុងខណៈ នៃបុគ្គលអ្នកមានសេចក្តីយល់ឃើញខុសប៉ុណ្ណោះថា មិនអាចដើម្បីញុំាងវិបស្សនាញាណ និងមគ្គញ្ញាណឱ្យប្រព្រឹត្តទៅផង ។ សូម្បីពាក្យនេះ ក៏ទ្រង់អធិប្បាយទុកថា “កាលបុគ្គលសេពនូវកាមនោះឯង ក៏រមែងជ្រាបថា ‘ បុគ្គលនេះ ឈ្មោះថា មានកាមជាធំ មានកាមជាអធ្យាស្រ័យ មានការបង្អោនទៅក្នុងកាម’ ដូច្នេះ; កាលសេពនូវនេក្ខម្មៈនោះឯង ក៏ជ្រាបថា ‘ បុគ្គលនេះ មាននេក្ខម្មៈជាធំ មាននេក្ខម្មៈជាអធ្យាស្រ័យ មានការបង្អោនទៅក្នុងនេក្ខម្មៈ’

---

[៤៣] អំ. ទសក. ។

ដូច្នេះ; កាលសេពព្យាបាទ ។ល ។ ការមិនព្យាបាទ ។ល ។ ថីនមិទ្ធៈ ។ល ។ កាលសេពនូវអាលោកសញ្ញានោះឯង រមែងជ្រាបថា បុគ្គលនេះមានអាលោកសញ្ញាជាធំ មានអាលោកសញ្ញាជាអធ្យាស្រ័យ មានការបង្អោនទៅក្នុងអាលោកសញ្ញា”[៤៤] ៕

## សម្តែងអំពីនិទ្ទេសនៃអនុស័យ

បណ្ឌិតគប្បីជ្រាបក្នុង **និទ្ទេសនៃអនុស័យ** ដូច្នេះ ៖

ក៏ឈ្មោះថា **កាមរាគានុស័យ** ព្រោះកាមរាគៈនោះផង អនុស័យនោះផង ជាធម៌ដេកត្រាំ ព្រោះអត្ថថា នៅមិនទាន់លះបាន ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដែរ ។ ពាក្យថា **“យំ លោកេ បិយរូបំ”** បានដល់ រូបណា ដែលឱ្យសេចក្តីស្រឡាញ់កើតឡើងក្នុងលោកនេះ ។ ពាក្យថា **“សាតរូបំ”** បានដល់ រូបដែលញុំាងសេចក្តីពេញចិត្តឱ្យកើតឡើង ជាអារម្មណ៍ដែលគួរប្រាថ្នា មានសេចក្តីពេញចិត្តជាបទដ្ឋាន ។ រាគានុស័យរបស់សត្វទាំងឡាយ **រមែងដេកត្រាំ** ក្នុងបិយរូប និងសាតរូបនេះ ព្រោះហេតុនោះ ទើបរាគានុស័យ ឈ្មោះថា អនុស័យរបស់សត្វទាំងឡាយ រមែងដេកត្រាំក្នុងអារម្មណ៍ ដែលគួរប្រាថ្នានេះ ព្រោះអត្ថថា នៅមិនទាន់បានលះ ។ ប្រៀបដូចកាលសត្វមុជចុះក្នុងទឹកហើយ ទឹកប៉ុណ្ណោះ មាននៅខាងក្រោម ខាងលើ និងខាងជុំវិញ យ៉ាងណា, ឈ្មោះថា ការកើតឡើងនៃរាគៈក្នុងអារម្មណ៍ដែលគួរប្រាថ្នាដូច្នេះនោះៗ ឯង រមែងមានដល់សត្វទាំងឡាយ ព្រោះជាអ្នកធ្លាប់សន្សំមកហើយជាញឹកញាប់ ។

---

[៤៤] ខុ. បដិ. ។

ការកើតឡើងនៃបដិឃៈ ព្រោះអារម្មណ៍ដែលមិនគួរប្រាថ្នា ក៏ដូចគ្នា ។ ពាក្យថា **“ឥតិ ឥមេសុ ទ្វីសុ ធម្មេសុ** = ក្នុងធម៌ទាំង ២ នេះ ដោយអាការយ៉ាងនេះ” បានដល់ បុគ្គលមានកាមរាគានុស័យ និងបដិឃានុស័យ ទាំងពីរនេះ មានឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ដោយអាការយ៉ាងនេះ ។ ពាក្យថា **“អវិជ្ជា អនុបតិតា** = អវិជ្ជាធ្លាក់ទៅតាមហើយ” បានដល់ អវិជ្ជាជាធម៌សម្បយុត្តដោយកាមរាគៈ និងបដិឃៈ ទើបឈ្មោះថា ជាធម៌ដែលអនុលោមតាមហើយ ដោយអំណាចនៃការធ្វើឱ្យជាអារម្មណ៍ ។ ពាក្យថា **“តទេកដ្ឋោ** = តាំងនៅក្នុងទីជាមួយគ្នា” បានដល់ ឈ្មោះថា តាំងនៅក្នុងទីជាមួយគ្នា នឹងអវិជ្ជានោះ ដោយអំណាចនៃការតាំងនៅក្នុងទីជាមួយគ្នា ដោយសេចក្ដីជាធម៌ដែលប្រកបដោយអវិជ្ជានោះ ។ ពាក្យថា **“មានោ ច ទិដ្ឋិ ច វិចិកិច្ឆា ច”** បានដល់ មានះ ៩ យ៉ាង ទិដ្ឋិ ៦២ យ៉ាង និងវិចិកិច្ឆាមានវត្ថុ ៨ ។ ក៏ក្នុងពាក្យថា **“ភវរាគានុស័យ”** នេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សង្គ្រោះទុកដោយកាមរាគានុស័យនោះឯង ៕

## សំម្ដែងអំពីនិទ្ទេសនៃចរិតជាដើម

ក្នុងនិទ្ទេសនៃចរិត បានដល់ ចេតនាដែលជា **បុញ្ញាភិសង្ខារ ១៣, អបុញ្ញាភិសង្ខារ ១២, អនេញ្ជាភិសង្ខារ ៤**; ក្នុងចេតនាទាំងនោះ កាមាវចរជា **បរិត្តភូមិ** (មានអារម្មណ៍តូច), ក្រៅពីនេះជា **មហាភូមិ** (មានអារម្មណ៍ធំ) ។

ម្យ៉ាងទៀត សូម្បីក្នុងសង្ខារទាំង ៣ នោះ សង្ខារណា មានវិបាកតិច គប្បីជ្រាបថា “ជាបរិត្តភូមិ”, មានវិបាកច្រើន គប្បីជ្រាបថា “ជាមហាភូមិ” ។

ក្នុងនិទ្ទេសនៃអធិមុត្តិ (អធ្យាស្រ័យ) ខ្ញុំបានប្រកាសទុកហើយ ក្នុងពេល

ក្រោយនោះឯង ។

*សួរថា* ក៏អធិមុត្តិ (អធ្យាស្រ័យ) នេះ សូម្បីព្រះមានព្រះភាគទ្រង់ត្រាស់ទុកក្នុងពេលក្រោយហើយ ព្រោះហេតុអ្វី ទើបទ្រង់កាន់យកម្តងទៀត ?

ឆ្លើយថា ព្រោះអធិមុត្តិ (អធ្យាស្រ័យ) នេះ ព្រះភគវាទ្រង់កាន់យកញែកចេញពេលក្រោយ ដោយអំណាចនៃការសម្តែងញាណដែលជាកម្លាំង ។ អធ្យាស្រ័យក្នុងទីនេះ ទ្រង់កាន់យកដើម្បីសម្តែងសេចក្តីដែលសត្វទាំងឡាយ ជាអ្នកមានឥន្ទ្រិយចាស់ក្លា និងឥន្ទ្រិយខ្សោយ ។

ក្នុងនិទ្ទេសនៃសត្វទាំងឡាយ អ្នកមានធូលី គឺកិលេសច្រើន ពាក្យថា **"ឧស្សន្នកតានិ** = បង្កើតឡើងឱ្យច្រើនហើយ" បានដល់ មានសេចក្តីចម្រើន; កាលពោលដោយអំណាចនៃការប្រហារជាលំដាប់ហើយ ក្នុងនិទ្ទេសនេះ ទ្រង់បានអធិប្បាយទៅតាមលំដាប់ ។ ពាក្យថា **"អនុស្សន្នកតានិ"** បានដល់ មិនចម្រើន ។

ឈ្មោះថា ឥន្ទ្រិយ គឺធម៌ដែលជាឧបនិស្ស័យ ព្រះមានព្រះភាគត្រាស់ទុកក្នុងនិទ្ទេសនៃសត្វអ្នកមានឥន្ទ្រិយចាស់ក្លា និងមានឥន្ទ្រិយខ្សោយ ។ ក៏ការប្រកបក្នុងពាក្យថា "អ្នកមានឥន្ទ្រិយចាស់ក្លា និងឥន្ទ្រិយខ្សោយ" ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងនិទ្ទេសនៃការមិនបានប្រព្រឹត្តទៅតាមលំដាប់ក្នុងខាងក្រោយនោះឯង ។

ក្នុងនិទ្ទេសនៃអាការអាក្រក់ជាដើម ក៏ដូចគ្នាដែរ ។ ពាក្យថា **"បាបាសយា** = អាសយៈអាក្រក់" បានដល់ អាសយៈ គឺអកុសល ។ ពាក្យថា **"បាបចរិតា** = មានចរិតអាក្រក់" បានដល់ បរិបូណ៌ដោយអបុញ្ញាភិសង្ខារ ។ ពាក្យថា **"បាបា-**

**ធិមុត្តិកា** = មានអធ្យាស្រ័យអាក្រក់” បានដល់ មានអធ្យាស្រ័យក្នុងវដ្តៈត្រេកអរក្រៃលែង ក្នុងសក្កាយ (គឺឧបាទានក្ខន្ធ ៥) ។

**ក្នុងនិទ្ទេសនៃអាការល្អ** អនុស័យ ឈ្មោះថា ជាសេចក្តីល្អរមែងមិនមាន ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគមិនត្រាស់ថា “អនុស័យ”; ពាក្យដ៏សេស គប្បីជ្រាបដោយន័យផ្ទុយគ្នា ៕

## សំដែងអំពីនិទ្ទេសនៃភព្វបុគ្គល និង អភព្វបុគ្គល

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនិទ្ទេសនៃសត្វអ្នកគួរត្រាស់ដឹង និងមិនគួរដល់ការត្រាស់ដឹង** ដូចតទៅ ៖

ពាក្យថា “**កម្មាវរណេន** = ដោយគ្រឿងឃាំង គឺកម្ម” បានដល់ ដោយអនន្តរិយកម្ម ៥ យ៉ាង ។ ពាក្យថា “**កិលេសាវរណេន** = ដោយគ្រឿងឃាំង គឺកិលេស” បានដល់ ដោយនិយតមិច្ឆាទិដ្ឋិ; ពាក្យថា “**វិបាកាវរណេន** = ដោយគ្រឿងឃាំង គឺវិបាក” បានដល់ បដិសន្ធិដោយអហេតុកចិត្ត ។ ក៏ព្រោះសេចក្តីចាក់ធ្លុះ រហូតដល់អរិយមគ្គ រមែងមិនមានដល់បុគ្គលអ្នកជាទុហេតុកបុគ្គល[៤៥], ព្រោះហេតុដូច្នោះ គប្បីជ្រាបថា សូម្បីទុហេតុកបដិសន្ធិ[៤៦] ក៏ឈ្មោះថា ជាគ្រឿងឃាំងគឺវិបាកដូចគ្នា ។ ពាក្យថា “**អសទ្ធា** = មិនមានសទ្ធា” បានដល់ វៀរចាកសទ្ធាក្នុងព្រះពុទ្ធជាដើម ។ ពាក្យថា “**អច្ឆន្ទិកា** = មិនមានឆន្ទៈ” បានដល់ វៀរចាកឆន្ទៈ

---

[៤៥] បុគ្គលអ្នកកើតដោយហេតុ ២ គឺ អលោភហេតុ និងអទោសហេតុ ។

[៤៦] បដិសន្ធិចិត្តដែលប្រកបដោយហេតុ ២ ។

ក្នុងកុសលរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងធ្វើ ។ មនុស្សអ្នកនៅឧត្តរកុរុទ្វីបទាំងឡាយចូលទៅកាន់ឋានរបស់អ្នកមិនមានឆន្ទៈ ។ ពាក្យថា **"ទុប្បញ្ញា** = មានបញ្ញាឱនថយ" បានដល់ ជាអ្នកវិនាសអំពីភវង្គបញ្ញា ។ សូម្បីកាលភវង្គបញ្ញា សូម្បីបរិបូណ៌ភវង្គរបស់បុគ្គលណា មិនព្យាបាទដល់លោកុត្តរ, បុគ្គលនោះ ក៏ឈ្មោះថា **មានបញ្ញាខ្សោយដែរ** ។ ពាក្យថា **"អភព្វា និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ** = មិនគួរដើម្បីធ្លាក់ចុះ កាន់សម្មត្តនិយាមក្នុងកុសលធម៌ទាំងឡាយ" បានដល់ មិនគួរឈានចុះកាន់មគ្គ ពោលគឺសម្មត្តនិយាមក្នុងកុសលធម៌ទាំងឡាយ ។ ពាក្យថា **"ន កម្មាវរណេន** = មិនប្រកបដោយគ្រឿងឃាំង គឺកម្ម" ជាដើម សេចក្ដីនេះបណ្ឌិតគប្បីញែកចេញជាពីរញាណ គឺឥន្ទ្រិយបរោបរិយត្តិញ្ញាណ និងអាសយានុសយញ្ញាណ ។ ពិតមែន ក្នុងសេចក្ដីនេះ សូម្បីឥន្ទ្រិយបរោបរិយត្តិញ្ញាណ ព្រះភគវាក៏ទ្រង់ចែកទុកដោយអាសយានុសយញ្ញាណ; ព្រោះហេតុនោះ ញាណទាំងពីរនេះ ទើបចាត់ជាញាណជាមួយគ្នា ឈ្មោះថា ជាកម្លាំងម្យ៉ាងកើតហើយ ៕

**ចប់និទ្ទេសនៃញាណជាកម្លាំងទី ៦**

## អធិប្បាយញាណជាកម្លាំងទី ៧

បុគ្គលណា រមែងសំឡឹង (ចូលឈាន) ព្រោះហេតុនោះ ទើបបុគ្គលនោះឈ្មោះថា **ឈាយី** = អ្នកចូលឈាន ។ ជន ៤ ចំពូកអ្នកចូលឈាន ព្រះភគវាត្រាស់ហៅថា **អ្នកចម្រើនឈាន ៤ ចំពូក** ។ ក្នុងជនទាំងនោះ បុគ្គល ៤ ចំពូកដំបូង បុគ្គលទី ១ បាននូវសមាបត្តិនោះឯង រមែងសម្គាល់ថា "យើងមិនបានឈាន, គឺ

សម្គាល់កម្មដ្ឋានដែលមានថា មិនមែនកម្មដ្ឋាន" ដូច្នេះ ។ បុគ្គលនេះ គប្បីជ្រាបថា ជាអ្នកបានឈាន មានប្រមាណតិច ។

**បុគ្គលទី ២** មិនបានសមាបត្តិមួយ រមែងសម្គាល់ថា "យើងបានសមាបត្តិ គឺមិនមែនកម្មដ្ឋានដែលមាន នៅសម្គាល់ថាជាកម្មដ្ឋាន" ដូច្នេះ ។ បុគ្គលនេះ គប្បីជ្រាបថា "ឈ្មោះថា **អ្នកចូលឈានបិទភ្នែក** (និទ្ទាឈាយី) លុះបិទភ្នែក (ដេកលក់) ហើយ ភ្ញាក់ឡើងមក ក៏សម្គាល់យ៉ាងនោះ" ។

**បុគ្គលទី ៣** បានសមាបត្តិ រមែងសម្គាល់ថា "យើងបានសមាបត្តិ គឺសម្គាល់ថា កម្មដ្ឋាននោះឯងថា ជាកម្មដ្ឋាននៅមាន" ដូច្នេះ បុគ្គលនេះ គប្បីជ្រាបថា បានឈានដែលស្ទាត់ជំនាញហើយ ។

**បុគ្គលទី ៤** មិនបានឈានឡើយ សម្គាល់ថា "យើងបានកម្មដ្ឋាន គឺសម្គាល់ វត្ថុដែលមិនមែនកម្មដ្ឋាននោះឯងថា ជាកម្មដ្ឋាន" ។

**ក្នុងទីនេះ ជនពីរចំពូកមិនបានឈានយ៉ាងនេះឡើយ ព្រះមានជោគត្រាស់ហៅថា "ឈាយី = អ្នកចូលឈាន" ព្រោះភាវៈដែលជនទាំងនោះចូលទៅសំឡឹងខាងក្នុង ដូចនឹងអ្នកបានឈានទាំងឡាយ ។**

**ក្នុងបុគ្គល ៤ ចំពូក** ទី ២ បុគ្គលកាលបើគ្របសង្កត់នូវធម៌ដែលជាសឹកសត្រូវដល់សមាធិ ដោយសេចក្តីខិតខំព្យាយាមដែលប្រព្រឹត្តទៅដោយសង្ខារ ឈ្មោះថា ការចូលឈានយឺតយូរ ។ អ្នកនោះតាំងនៅក្នុងឈានអស់វារៈនៃចិត្តមួយ ឬពីរហើយ ក៏ចេញដោយប្រញាប់ ឈ្មោះថា **រមែងចេញប្រញាប់** ។ ក៏បុគ្គលជម្រះធម៌ដែលជាសត្រូវ ដល់សមាធិបានដោយងាយតែម្តង ឈ្មោះថា **ចូលឈាន**

ប្រញាប់ ។ បុគ្គលមិនចេញ អំពីឈានតាមកំណត់ ឱ្យវេលាកន្លងទៅយូរ ហើយទើបចេញអំពីឈាន ឈ្មោះថា **រមែងចេញប្រញាប់** ។ សូម្បីជន ២ ចំពូកក្រៅនេះ ក៏គប្បីជ្រាបដោយន័យនេះឯង; សូម្បីជនទាំងឡាយ ៤ ចំពូកនេះ ជាអ្នកបានសមាបត្តិមែនពិត ។

**ក្នុងបុគ្គល ៤ ចំពូក** ទី ៣ បុគ្គលអ្នកឈ្លាសក្នុងការកំណត់ចែកអង្គឈានយ៉ាងនេះថា "ឈាននេះមានអង្គ ៥, ឈាននេះ មានអង្គ ៤" ដូច្នេះ ឈ្មោះថា **អ្នកឈ្លាសកំណត់សមាធិក្នុងសមាធិ** ។ បុគ្គលអ្នកមិនឈ្លាសដើម្បីនឹងទប់ស្កាត់នីវរណៈទាំងឡាយ ហើយឱ្យចិត្តតាំងនៅក្នុងធម៌ជាគ្រឿងរក្សាចិត្ត ឈ្មោះថា **អ្នកឈ្លាសកំណត់សមាបត្តិក្នុងសមាធិ** ។ សូម្បីជន ៣ ជំពូកក្រៅនេះ គប្បីជ្រាបដោយន័យនេះចុះ; សូម្បីបុគ្គល ៤ ចំពូកទាំងអស់ ជាអ្នកបានសមាបត្តិទាំងអស់ ។ ឥឡូវនេះ ឈ្មោះថា បុគ្គលអ្នកចូលឈានទាំងនេះ អាស្រ័យឈានណា, ដើម្បីសម្តែងឈានទាំងនោះ ដែលកើតឡើងហើយ ទើបព្រះភគវាត្រាស់ថា **"ចត្តារិ ឈានានិ** = ឈាន ៤" ជាដើម; បណ្តាពាក្យទាំងនោះ ឈាន ៤ វិមោក្ខ ៣ ពោលដោយអត្ថ ខ្ញុំអធិប្បាយទុកហើយ ក្នុងអដ្ឋកថានៃធម្មសង្គហៈក្នុងពេលក្រោយនោះឯង ។ សូម្បីអត្ថវិមោក្ខនៃបទដ៏សេស ក៏គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងទីនោះដូចគ្នា; ម្យ៉ាងទៀត ក្នុងទីនេះ ឈ្មោះថា **វិមោក្ខ** ព្រោះរបួតផុតវិសេស អំពីធម៌ដែលជាសឹកសត្រូវ ក្នុងខណៈចិត្តទៀងត្រង់ (អប្បនា) ហើយៗ ទាំង ៧ ខណៈដោយលំដាប់ និងការបង្អោនទៅក្នុងអារម្មណ៍ ។ ក៏វិមោក្ខទី ៨ ឈ្មោះថា អបកតវិមោក្ខ ព្រោះរបួតផុតវិសេសហើយ ដោយសញ្ញាវេទយិតនិរោធ

មានប្រការទាំងពួង ៕

## សំដែងអំពីសមាធិ ៣

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសមាធិទាំងឡាយ ដែលជាចតុក្កន័យ និងបញ្ចកន័យ ដូចតទៅ ៖

ក្នុងចតុក្កន័យ សមាធិក្នុងបឋមជ្ឈាន ឈ្មោះថា **ប្រព្រឹត្តទៅដោយវិតក្កៈ និងវិចារៈ** ។ ក្នុងបញ្ចកន័យ សមាធិក្នុងទុតិយជ្ឈាន ឈ្មោះថា **ជាសមាធិត្រឹមតែមិនមានវិតក្កៈ មានតែវិចារៈ** ។ ក្នុងចតុក្កន័យក្តី ក្នុងបញ្ចកន័យក្តី សមាធិក្នុងឈាន ៣ ខាងលើ ឈ្មោះថា **សមាធិមិនមានវិតក្កៈ មិនមានវិចារៈ** ។ ពិតមែនក្នុងសមាបត្តិទាំងឡាយ មានឈ្មោះថា “សមាធិរបស់អ្នកចូលសមាបត្តិ ៨ ដោយលំដាប់” ដូច្នេះខ្លះ ឈ្មោះថា “សមាបត្តិ” ដូច្នេះខ្លះ ។

***សួរថា*** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះការព្រមព្រៀងនៃឯកគ្គតាចិត្ត ។

សេចក្តីព្រមព្រៀងរបស់ឯកគ្គតាចិត្តដូច្នេះ ឈ្មោះថា **សមាធិរបស់និរោធ-សមាបត្តិ** ក៏មិនមែន ។ ពាក្យថា “**ហានភាគិយោ ធម្មោ** = ជាធម៌ចំណែកថយចុះ” អធិប្បាយថា កាលចេញអំពីបឋមជ្ឈានជាដើម ដែលមានគុណតិចហើយ ក៏ស្ទុះទៅរកកាមជាដើម របស់អ្នកមនសិការដោយសញ្ញា ។ ពាក្យថា “**វិសេស-ភាគិយោ ធម្មោ** = ធម៌ចំណែកល្អ គឺធម៌វិសេស” អធិប្បាយថា កាលចេញអំពីបឋមជ្ឈានជាដើម ដែលស្ទាត់ជំនាញហើយ ក៏ស្ទុះទៅតាមទុតិយជ្ឈានជាដើម របស់

អ្នកមនសិការដោយសញ្ញា ។ សេចក្ដីបរិសុទ្ធរបស់ឈាន ដែលរហ័សរហួនហើយ ឈ្មោះថា ការចេញដែលព្រះមានជោគត្រាស់ទុកដោយពាក្យថា សូម្បីសេចក្ដីបរិសុទ្ធ ក៏ឈ្មោះថាការចេញដែរ ។ ពិតមែន ឈានដែលរហ័សរហួនជាន់ទាប១ រមែងជាបទដ្ឋានដល់ឈានខាងលើ១; ព្រោះហេតុដូច្នោះ ទើបត្រាស់ថា "សូម្បីសេចក្ដីបរិសុទ្ធ ក៏ឈ្មោះថា ការចេញ" ដូច្នេះ ។ ឈ្មោះថា ការចេញអំពីភវង្គ ព្រះភគវាត្រាស់ហើយដោយបទថា **"សូម្បីការចេញអំពីសមាធិនោះ១ ក៏ឈ្មោះថា ការចេញ"** ។

**ពិតមែន ការចេញអំពីឈានទាំងអស់ រមែងមានដោយភវង្គ**, តែការចេញអំពី **និរោធ រមែងមានដោយផលសមាបត្តិតែម្យ៉ាង** ។

សេចក្ដីនេះ ឈ្មោះថា ការចេញដែលជាបាលីមុត្តកៈ (គឺក្រៅអំពីបាលី) ៕

**ចប់អធិប្បាយញាណជាកម្លាំងទី ៧**

## អធិប្បាយញាណជាកម្លាំងទី ៨

ក្នុងនិទ្ទេសនៃញាណជាកម្លាំងទី ៨ ពាក្យថា **"អនេកវិហិតំ បុព្វេនិវាសំ** = រឭកជាតិថយក្រោយមានប្រការផ្សេង១" ជាដើម ព្រះសាស្ដាត្រាស់ទុកជាអនេក ខ្ញុំឱ្យពិស្ដារហើយក្នុងវិសុទ្ធិមគ្គនុ៎ះឯង ៕

**ចប់អធិប្បាយញាណជាកម្លាំងទី ៨**

## អធិប្បាយញាណជាកម្លាំងទី ៩

សូម្បីក្នុងនិទ្ទេសនៃញាណជាកម្លាំងទី ៩ ពាក្យទាំងពួងថា **"ទិព្វេន**

**ចក្ខុនា**” ជាដើម ពិស្តារហើយក្នុងវិសុទ្ធិមគ្គនុ៎ះឯង ៕

ចប់អធិប្បាយញាណជាកម្លាំងទី ៩

## អធិប្បាយញាណជាកម្លាំងទី ១០

ពាក្យថា “**ចេតោវិមុត្តិ**” បានដល់ ផលសមាធិ ។ ពាក្យថា “**បញ្ញា-វិមុត្តិ**” បានដល់ ផលញ្ញាណ; ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយស្រួលទាំងអស់ ។ នេះជាកថាដែលស្មើគ្នារបស់អាចារ្យទាំងឡាយ ក្នុងទីនេះសិន ។ **ក៏បរវាទី** ពោលថា “ឈ្មោះថា **ទសពលញ្ញាណ** ញែកចេញជាចំណែកមួយមិនមាន, នេះជាប្រភេទរបស់ **ព្រះសព្វញ្ញុតញ្ញាណ** ប៉ុណ្ណោះ” ; សេចក្ដីនេះ មិនគប្បីឃើញយ៉ាងនោះ ។ ព្រោះថា ទសពលញ្ញាណម្យ៉ាង, សព្វញ្ញុតញ្ញាណ ក៏ជាម្យ៉ាង ។ ក៏ទសពលញ្ញាណ រមែងដឹងនូវកិច្ច (មុខនាទី) របស់ខ្លួនៗ ប៉ុណ្ណោះ, ចំណែកសព្វញ្ញុតញ្ញាណ រមែងដឹងសូម្បីនូវកិច្ចដែលទសពលញ្ញាណដឹងហើយនេះ និងរមែងដឹងនូវកិច្ច សូម្បីដ៏សេសអំពីទសពលញ្ញាណដឹងហើយនោះផង ។

ពិតមែន បណ្ដាទសពលញ្ញាណទាំងនោះ ៖

- ញាណទី ១ រមែងដឹងនូវធម៌ដែលជាហេតុ និងមិនមែនហេតុប៉ុណ្ណោះ
- ញាណទី ២ រមែងដឹងសេចក្ដីប្លែកផ្សេងគ្នានៃកម្មវិបាកប៉ុណ្ណោះ
- ញាណទី ៣ រមែងដឹងការកំណត់សេចក្ដីប្រព្រឹត្តទៅនៃកម្មប៉ុណ្ណោះ
- ញាណទី ៤ រមែងដឹងហេតុនៃសេចក្ដីផ្សេងៗ គ្នា នៃធាតុប៉ុណ្ណោះ
- ញាណទី ៥ រមែងដឹងនូវអធ្យាស្រ័យ និងសេចក្ដីបង្អោនទៅនៃ

ចិត្តប៉ុណ្ណោះ ។

-ញាណទី ៦ រមែងដឹងនូវសេចក្ដីដែលឥន្ទ្រិយទាំងឡាយ ជាធម៌ចាស់ក្លា និងទន់ខ្សោយប៉ុណ្ណោះ ។

-ញាណទី ៧ រមែងដឹងនូវភាវៈនៃសត្វទាំងឡាយ មានសេចក្ដីសៅហ្មងជាដើម ដោយឈានជាដើមប៉ុណ្ណោះ ។

-ញាណទី ៨ រមែងដឹងនូវការបន្តនៃខន្ធ ដែលធ្លាប់អាស្រ័យមកហើយក្នុងកាលមុនប៉ុណ្ណោះ ។

-ញាណទី ៩ រមែងដឹងនូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយប៉ុណ្ណោះ

-ញាណទី ១០ រមែងដឹងនូវការកំណត់សច្ចៈប៉ុណ្ណោះ ។

ចំណែកសព្វញ្ញុតញ្ញាណរមែងដឹងទូទៅ នូវធម៌ដែលទសពលញ្ញាណទាំងនោះគប្បីដឹងនូវធម៌ដ៏ក្រៃលែងផង ជាងទសពលញ្ញាណនោះផង ។ ក៏បើថា សព្វញ្ញុត-ញ្ញាណ មិនធ្វើកិច្ចទាំងអស់ របស់ទសពលញ្ញាណទាំងនោះទេ; ទុំះសព្វញ្ញុតញ្ញាណក៏ជាឈាន តែមិនអាចដើម្បីដល់កៀក, ជាឥទ្ធិ តែមិនអាចសម្ដែងឫទ្ធិ, ជាមគ្គ តែមិនអាចដើម្បីញុំាងកិលេសទាំងឡាយឱ្យអស់ទៅដូច្នេះ ។ ម្យ៉ាងទៀត បរវាទីគប្បីសួរយ៉ាងនេះថា "ឈ្មោះថា ទសពលញ្ញាណនេះ ប្រព្រឹត្តទៅដោយវិតក្កៈ និងវិចារៈ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មិនមានវិតក្កៈ មិនមានវិចារៈ ជាកាមាវចរ ជាអរូបាវចរ ជាលោកិយ ឬជាលោកុត្តរ ?" ដូច្នេះ ។ ឆ្លើយថា អ្នកដឹងក៏នឹងពោលថា "ញាណទាំង ៧ តាមលំដាប់ (គឺតាំងតែពីឋានាឋានញ្ញាណជាដើម) ប្រព្រឹត្តទៅដោយវិតក្កៈ និងវិចារៈ" ដូច្នេះ, តអំពីនោះ នឹងពោលថា "ញាណទាំង

ពីរខាងមុខ (គឺបុព្វេនិវាសានុស្សតិញ្ញាណ និងចុតូបបាតញ្ញាណ) មិនមានវិតក្កៈ និងវិចារៈ” ដូច្នេះ, តអំពីនោះ ក៏នឹងពោលថា “អាសវក្ខយញ្ញាណគប្បីប្រព្រឹត្តទៅដោយវិតក្កៈ និងវិចារៈក៏មាន, មិនមានវិតក្កៈ មានតែវិចារៈក៏មាន, ជាអវិតក្កៈ និងអវិចារៈក៏មាន” ដូច្នេះ; ដោយទំនងដូចគ្នា ញាណ ៧ តាមលំដាប់តាំងតែពីឋានា-ឋានញ្ញាណជាដើមទៅ ជាកាមាវចរ, ញាណ ២ អំពីនោះ ជារូបាវចរ, ញាណទីបំផុតខាងចុង ជាលោកុត្តរ” ដូច្នេះ, តែសព្វញ្ញុតញ្ញាណនឹងពោលថា ប្រព្រឹត្តទៅដោយវិតក្កៈ និងវិចារៈប៉ុណ្ណោះ ជាកាមាវចរនោះ[៤៧] ជាលោកិយប៉ុណ្ណោះឯង ។ ដោយប្រការដូច្នេះ **ទសពលញ្ញាណ ទើបជាម្យ៉ាង សព្វញ្ញុតញ្ញាណ ក៏ជាម្យ៉ាង** ដូចពណ៌នាមកដូច្នេះឯង ៕

## ចប់អដ្ឋកថាញាណវិភង្គ

---

[៤៧] មហាកិរិយាញាណសម្បយុត្ត ។

# ១៧. អដ្ឋកថាខុទ្ទកវត្ថុវិភង្គ

## ការកំណត់បទមាតិកា

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់តាំងបឋមមាតិកា សូម្បីក្នុង **ខុទ្ទកវត្ថុ-វិភង្គ** ដែលជាលំដាប់នៃញាណវិភង្គនោះ ហើយទ្រង់ធ្វើពាក្យអធិប្បាយដោយលំដាប់នៃបទដែលព្រះអង្គទ្រង់តាំងទុក ។ នេះជាការកំណត់មេបទ (មាតិកា) ក្នុងខុទ្ទកវិភង្គ ។

ធម៌ពួកទីមួយ (ឯកកមាតិកា) ព្រះមានព្រះភាគទ្រង់តាំងទុក ៧៣ បទ មានពាក្យថា សេចក្តីស្រវឹងក្នុងជាតិជាដើមមុន, តពីនោះទ្រង់តាំងធម៌ពួកពីរ (ទុកមាតិកា) ១៨ បទ មានពាក្យថា **សេចក្តីក្រោធ** និងការចងសេចក្តីក្រោធជាដើម, ទ្រង់តាំងធម៌ពួកបី (តិកមាតិកា) ៣៥ បទ មានពាក្យថា **អកុសលមូល ៣** ជាដើម, ទ្រង់តាំងធម៌ពួកបួន (ចតុក្កមាតិកា) ១៤ បទ មានបទថា **អាសវៈ ៤** ជាដើម, ទ្រង់តាំងធម៌ពួកប្រាំ (បញ្ចកមាតិកា) ១៥ បទ មានពាក្យថា **ឱរម្ភា-គិយសញ្ញោជនៈ ៥** ជាដើម, ទ្រង់តាំងធម៌ពួកប្រាំមួយ (ឆក្កមាតិកា) ១៤ បទ មានពាក្យថា **វិវាទមូល ៦** ជាដើម, ទ្រង់តាំងធម៌ពួកប្រាំពីរ (សត្តកមាតិកា) ៧ បទ **មានអនុស័យ ៧** ជាដើម ។ ទ្រង់តាំងធម៌ពួកប្រាំបី (អដ្ឋកមាតិកា) ៨ បទ **មានកិលេសវត្ថុ ៨** ជាដើម ។ ទ្រង់តាំងធម៌ពួកប្រាំបួន (នវកមាតិកា) ៩ បទ **មានអាឃាតវត្ថុ ៩** ជាដើម ។ ទ្រង់តាំងធម៌ពួកដប់ (ទសកមាតិកា) ៧ បទ **មានកិលេសវត្ថុ ១០** ជាដើម ។ និងគប្បីជ្រាបថា ទ្រង់តាំងតណ្ហាវិចរិត ១០៨ មានពាក្យថា “តណ្ហាចរិត * អាស្រ័យអាយតនៈខាងក្នុង ១៨ និងអាស្រ័យ

* ក្នុងបាលីនិទ្ទេសពោលថា តណ្ហាវិចរិតអាស្រ័យបញ្ចក្ខន្ធខាងក្នុង ១៨ ខាងក្រៅ ១៨ ... ។

អាយតនៈខាងក្រៅ ១៨ រួមចូលគ្នាត្រូវជា ៣៦ (តណ្ហា ៣៦ X កាល ៣ = ១០៨)" ។ នេះជាការកំណត់បទមាតិកាសិន ៕

## អដ្ឋកថាឯកកនិទ្ទេស អធិប្បាយមាតិកាពួកមួយ

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបនិទ្ទេសវារៈ ដែលព្រះមានព្រះភាគទ្រង់ប្រារព្ធ ទុកក្នុងបទមាតិកា ដែលទ្រង់តាំងទុកក្នុងឯកកមាតិកាទាំងនោះ ដោយន័យថា **"កតមោ ជាតិមទោ** = សេចក្តីស្រវឹងក្នុងជាតិ តើដូចម្តេច ?" ជាដើម ៕

## អំពីការស្រវឹងក្នុងជាតិជាដើម

ពាក្យថា **"ជាតឹ បដិច្ច"** បានដល់ ព្រោះអាស្រ័យជាតិ ។ ក៏ក្នុងឯកក-មាតិកានេះ ព្រះមានព្រះភាគត្រាស់ទុកថា ឈ្មោះថា ការអាស្រ័យមាន, ព្រោះហេតុនោះ គប្បីជ្រាបសេចក្តីក្នុងមាតិកានេះថា បានដល់ កាលបើជាតិមាន ដូច្នេះ ។ សូម្បីក្នុងពាក្យថា "ព្រោះអាស្រ័យគោត្រ" ជាដើម ក៏ន័យនេះដែរ; ឈ្មោះថា **ស្រវឹង** ដោយអំណាចនៃសេចក្តីស្រវឹង ។ អាការនៃសេចក្តីស្រវឹង **គឺកិរិយាដែលស្រវឹង** ។ កិរិយាដែលស្រវឹង **គឺសភាពដែលស្រវឹង** ។ ពាក្យថា "សេចក្តីប្រកាន់ខ្លួន (មានះ) **កិរិយាដែលប្រកាន់ខ្លួន** (មញ្ញមានា)" ជាដើម មានសេចក្តីដូចដែលពោលទុកក្នុងអដ្ឋកថានៃធម្មសង្គហៈ ក្នុងកាលមុន ។ ពាក្យថា **"អយំ ឧច្ចតិ** = បុគ្គលនេះហៅថា" បានដល់ បុគ្គលនេះនុ៎ះឯង កាលជាតិមាន អាស្រ័យជាតិនោះហើយ មានមានះ (សេចក្តីប្រកាន់ខ្លួន) ដល់នូវកិរិយាស្រវឹង ដែលកើតឡើងហើយ

នេះ ព្រះមានព្រះភាគត្រាស់ហៅថា **“ជាតិមទោ** = មានសេចក្ដីស្រវឹងក្នុងជាតិ”។ បណ្ដាវណ្ណៈសូម្បីទាំង ៤ មានក្សត្រជាដើម (ក្សត្រ ព្រាហ្មណ៍ វេស្សៈ និងសូទ្រៈ) ឈ្មោះថា សេចក្ដីស្រវឹងនោះឯង រមែងកើតឡើង ។ ពិតមែន ក្សត្រអ្នកបរិបូណ៌ដោយជាតិ រមែងធ្វើមានះ (សេចក្ដីប្រកាន់ខ្លួន) ថា “បុគ្គលដទៃដូចយើង រមែងមិនមាន ក្សត្រដ៏សេស (វៀរខ្លួនយើង) តាំងឡើងមកខាងក្រោយ ទើបបានជាក្សត្រ, ចំណែកយើងជាក្សត្របន្តសន្តិតិវង្ស” ។ សូម្បីព្រាហ្មណ៍ជាដើម ក៏មានន័យនេះដែរ ។

សូម្បីក្នុងនិទ្ទេសនៃសេចក្ដីស្រវឹងក្នុងគោត្រជាដើម ក៏គប្បីជ្រាបសេចក្ដីដោយន័យនេះដែរ; ព្រោះថា សូម្បីក្សត្រិយ៍ក៏ធ្វើមានះ (ប្រកាន់ខ្លួន) ថា “យើងជាក្សត្រិយ៍ កោណ្ឌញ្ញគោត្រ, ជាក្សត្រអាទិច្ចគោត្រ” សូម្បីព្រាហ្មណ៍ក៏ធ្វើមានះថា “យើងជាព្រាហ្មណ៍កស្សបគោត្រ, យើងជាព្រាហ្មណ៍ភារទ្វាជគោត្រ” ។ សូម្បីវេស្សៈ និងសូទ្រៈ ក៏អាស្រ័យត្រកូលរបស់ខ្លួន ហើយធ្វើមានះ; ជនទាំងឡាយជាប្រធានទាំង ១៨ គណៈ ក៏ធ្វើមានះថា “ប្រធានទាំងនោះបែកខ្ញែកគ្នា យើងមិនបែកខ្ញែកគ្នា” ជាដើម ៕

## អំពីការស្រវឹងក្នុងភាពជាអ្នកមិនមានរោគជាដើម

ក្នុងបណ្ដាសេចក្ដីស្រវឹងទាំងឡាយ មានសេចក្ដីស្រវឹងក្នុងភាពជាអ្នកមិនមានរោគជាដើម មានះដែលកើតឡើងដោយអំណាចនៃសេចក្ដីស្រវឹងថា “យើងមិនមានរោគ, ជនទាំងឡាយដ៏សេស (វៀរយើង) មានរោគច្រើន, ក៏ឈ្មោះថា ព្យាធិ

សូម្បីត្រឹមតែរោគដំណួចពិសរបស់យើង ក៏មិនមាន” ឈ្មោះថា **អារោគ្យមទោ** = ស្រវឹងក្នុងភាពមិនមានរោគ ៕

## អំពីការស្រវឹងក្នុងភាពជាកំលោះក្រមុំ

មានះដែលកើតឡើង ដោយអំណាចនៃសេចក្ដីស្រវឹងថា “យើងទើបជាកំលោះក្រមុំ, អត្តភាពរបស់សត្វទាំងឡាយដ៏សេស (វៀរយើង) ដូចជាដើមឈើតាំងនៅមាត់ជ្រោះ, ចំណែកយើងតាំងនៅក្នុងបឋមវ័យ” ឈ្មោះថា **យោព្វនមទោ** = ស្រវឹងក្នុងភាពជាកំលោះក្រមុំ ៕

## អំពីការស្រវឹងក្នុងជីវិត

មានះដែលកើតឡើង ដោយអំណាចនៃសេចក្ដីស្រវឹងថា “យើងបានរស់នៅយូរហើយ, យើងបានរស់នៅយូរ, យើងនឹងជាអ្នករស់នៅយូរ; យើងរស់នៅជាសុខហើយ, យើងរស់នៅជាសុខ, យើងនឹងរស់នៅជាសុខ” ឈ្មោះថា **ជីវិតមទោ** = ស្រវឹងក្នុងជីវិត ៕

## អំពីការស្រវឹងក្នុងលាភ

មានះដែលកើតឡើង ដោយអំណាចនៃសេចក្ដីស្រវឹងថា “យើងមានលាភច្រើន, សត្វទាំងឡាយដ៏សេស (ក្រៅអំពីយើង) មានលាភតិច, ក៏លាភទាំងឡាយ

របស់យើង ប្រមាណមិនបាន” ឈ្មោះថា **លាភមទោ** = ស្រវឹងក្នុងលាភ ៕

## អំពីការស្រវឹងក្នុងសក្ការៈ

មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា “សត្វទាំងឡាយដ៏សេស បាននូវបច្ច័យណា។, យើងប៉ុណ្ណោះដែលបាននូវបច្ច័យមានចីវរជាដើមដ៏ប្រណីត ដែលគេធ្វើល្អហើយ” ឈ្មោះថា **សក្ការមទោ** = ស្រវឹងក្នុងសក្ការៈ ៕

## អំពីសេចក្តីស្រវឹងក្នុងការគោរព

មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា “ជនទាំងឡាយដើរតាមទៅខាងក្រោយរបស់ភិក្ខុទាំងឡាយ រមែងមិនសំពះភិក្ខុនោះ ដោយគិតថា ‘អ្នកនេះជាសមណៈ’ ដូច្នេះខ្លះ, តែពួកគេទាំងនោះ ឃើញយើងហើយរមែងសំពះតែម្តង, ធ្វើសេចក្តីគោរពយើង ប្រៀបដូចជាឆត្រដែលដោតចុះជាប់នៅក្នុងថ្ម រមែងធ្វើសេចក្តីសម្គាល់យើងថា ជាអ្នកចូលទៅរក បានសំឡេងទះដៃព្រម។ គ្នា ដូចគំនរភ្លើងដូច្នោះ” ឈ្មោះថា **គរុការមទោ** = ស្រវឹងក្នុងការធ្វើសេចក្តីគោរព ៕

## អំពីការស្រវឹងក្នុងភាពជាមេដឹកនាំ

មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា “បញ្ហាដែលកើតឡើងហើយ រមែងកាត់ចិត្តសម្រេចបានដោយមាត់របស់យើងប៉ុណ្ណោះ, សូម្បីកាលទៅភិក្ខាចារ ក៏ធ្វើយើងប៉ុណ្ណោះឱ្យទៅខាងមុខ ហើយទើបហែហមទៅតាម” ឈ្មោះ

ថា **បុរេក្ខារមទោ** = ស្រវឹងក្នុងភាពជាមេដឹកនាំ ៕

## អំពីការស្រវឹងក្នុងបរិវារ

មានះដែលកើតឡើងដល់អ្នកគ្រប់គ្រងផ្ទះ អ្នកមានបរិវារច្រើន ដោយអំណាចនៃសេចក្តីស្រវឹងថា "បុរសមួយរយនាក់ខ្លះ មួយពាន់នាក់ខ្លះ រមែងនៅជុំវិញយើង" , ចំណែកមានះដែលកើតឡើង ដល់អ្នកមិនគ្រប់គ្រងផ្ទះ (គឺសមណៈ) ដោយអំណាចនៃសេចក្តីស្រវឹងថា "សមណៈមួយរយខ្លះ មួយពាន់ខ្លះ នៅជុំវិញយើង, សមណៈដ៏សេស មានបរិវារតិច, យើងមានបរិវារច្រើន មានបរិវារល្អ" ឈ្មោះថា **បរិវារមទោ** = **ស្រវឹងក្នុងបរិវារ** ៕

## អំពីការស្រវឹងក្នុងភោគសម្បត្តិ

ក៏ភោគសម្បត្តិ លោកកាន់យកដោយ **លាភ**សព្ទនោះឯង ក៏ពិតមែន, ប៉ុន្តែ លោកកាន់យកគំនរនៃភោគៈដែលតាំងទុកក្នុងទីនេះទៀត, ព្រោះហេតុដូច្នោះ មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា "សត្វទាំងឡាយដែលក្រៅពីយើងហើយ រមែងមិនបានសូម្បីតែការប្រើប្រាស់របស់ខ្លួន, ចំណែកយើងមានទ្រព្យរក្សាទុក (កំណប់ទ្រព្យ) រាប់មិនបាន" ឈ្មោះថា **ភោគមទោ** = **ស្រវឹងក្នុងភោគសម្បត្តិ** ៕

## អំពីការស្រវឹងក្នុងពណ៌សម្បុរ

ពាក្យថា **“វណ្ណំ បដិច្ច”** បានដល់ អាស្រ័យពណ៌សម្បុរ គឺសម្បុរនៃសរីរៈខ្លះ ពណ៌សម្បុរ គឺគុណសេចក្តីល្អខ្លះ; មានះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា “សត្វទាំងឡាយដ៏សេស (ក្រៅពីយើង) មានពណ៌សម្បុរមិនល្អ មានរូបមិនស្អាត, ចំណែកយើងមានរូបស្អាតគួរជ្រះថ្លា; សត្វទាំងឡាយដ៏សេសមានគុណគឺសេចក្តីល្អ មិនជាទីសរសើរ ចំណែកយើងមានកិត្តិសព្ទផ្សាយទៅក្នុងទេវតា និងមនុស្សទាំងឡាយថា សូម្បីព្រោះហេតុនេះៗ.... យើងជាព្រះថេរៈអ្នកជាពហូសូត, សូម្បីព្រោះហេតុនេះ យើងជាអ្នកមានសីល, សូម្បីព្រោះហេតុនេះ យើងជាអ្នកប្រកបដោយគុណនៃធុតង្គ” ជាដើម ឈ្មោះថា **វណ្ណមទោ = ស្រវឹងក្នុងពណ៌សម្បុរ** ៕

## អំពីការស្រវឹងក្នុងការសិក្សា

មានះដោយអំណាចនៃសេចក្តីស្រវឹងថា “សត្វទាំងឡាយដ៏សេស មានការសិក្សាតិច, ចំណែកយើងមានការសិក្សាច្រើន” ឈ្មោះថា **សុត្តមទោ = ស្រវឹងក្នុងការសិក្សា** ៕

## អំពីការស្រវឹងក្នុងបដិភាណ

មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា “សត្វទាំងឡាយដ៏សេស (វៀរយើង) ហើយ មិនមានបដិភាណ (ភាពឆ្លៀវឆ្លាស), ចំណែកយើងមាន

បដិភាណប្រមាណមិនបាន” ឈ្មោះថា **បដិភាណមទោ** = **ស្រវឹងក្នុងបដិភាណ** ។

## អំពីការស្រវឹងក្នុងរត្តញ្ញូ

មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា “យើងជាអ្នកដឹងរាត្រីយូរ យើងដឹងត្រកូលរបស់ព្រះពុទ្ធជាម្ចាស់អង្គនោះ ព្រះអង្គនោះរមែងដឹងត្រកូលព្រះរាជាអង្គនោះ ដឹងត្រកូលនៃជនបទនោះ ដឹងត្រកូលនៃស្រុកនោះ ដឹងនូវការកំណត់ ទាំងពេលយប់ ទាំងពេលថ្ងៃ ដឹងនូវការប្រកបឫក្ស និងការទាយ” ឈ្មោះថា **រត្តញ្ញូមទោ** = **ស្រវឹងក្នុងរត្តញ្ញូ** ។

## អំពីសេចក្តីស្រវឹងក្នុងការកាន់បិណ្ឌបាតជាវត្ត

មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា “ភិក្ខុទាំងឡាយកាន់បិណ្ឌបាតជាវត្តត្រឹមតែបន្តិចបន្តួច ឯយើងវិញកាន់បិណ្ឌបាតជាវត្តតាំងតែពីបួសមក” ឈ្មោះថា **បិណ្ឌបាតិកមទោ** = **ស្រវឹងក្នុងការកាន់បិណ្ឌបាតជាវត្ត** ។

## អំពីការស្រវឹងដោយមិនមាននរណាមើលងាយ

មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា “សត្វទាំងឡាយដ៏សេស ជាអ្នកត្រូវគេមើលងាយ មើលថោក ឯយើងមិនមាននរណា មើលងាយ មើលថោកឡើយ” ឈ្មោះថា **អនវញ្ញាតមទោ** = **ស្រវឹងដោយមិនមាននរណាមើលងាយ** ។

## អំពីការស្រវឹងក្នុងឥរិយាបថ

មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា "ឥរិយាបថរបស់សត្វទាំងឡាយ មិនគួរជ្រះថ្លា, ឯយើងគួរជ្រះថ្លា" ឈ្មោះថា **ឥរិយាបថមទោ** = ស្រវឹងក្នុងឥរិយាបថ ៕

## អំពីការស្រវឹងក្នុងឫទ្ធិ

មានះដែលកើតឡើង ដោយអំណាចនៃសេចក្តីស្រវឹងថា "សត្វទាំងឡាយដ៏សេស ដូចសត្វក្អែកបាក់ស្លាបហើរមិនរួច, ចំណែកយើងមានឫទ្ធិច្រើន មានអានុភាពច្រើន" ឬថា "យើងនឹងធ្វើវត្ថុណា១ ក៏សម្រេច" ឈ្មោះថា **ឫទ្ធិមទោ** = ស្រវឹងក្នុងឫទ្ធិ ៕

## អំពីការស្រវឹងក្នុងយសស័ក្តិ

**យស** លោកកាន់យកដោយ **បរិវារសម្ពទ** ក្នុងខាងក្រោយនុ៎ះឯង, តែក្នុងទីនេះ លោកកាន់យក **ភាពជាអ្នកស្រវឹងក្នុងឧបដ្ឋាក**, សេចក្តីស្រវឹងនោះ បណ្ឌិតគប្បីសម្តែងដោយបុគ្គលអ្នកគ្រប់គ្រងផ្ទះខ្លះ អ្នកមិនគ្រប់គ្រងផ្ទះខ្លះ; ក៏បណ្តាប្រជុំជន ១៨ ពួក អ្នកគ្រប់គ្រងផ្ទះមួយក្រុម ក៏មានប្រធានមួយ, មានះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា "យើងនឹងតែងតាំងមនុស្សជាអ្នកទំនុកបម្រុងយើង យើងនឹងដើរទៅ, សូម្បីអ្នកមិនគ្រប់គ្រងផ្ទះ (សមណៈ) ជាប្រធានគណៈ, ក៏មានសេចក្តីសម្គាល់ខ្លួន ដោយអំណាចនៃសេចក្តីស្រវឹងថា "យើងជាប្រធានលើ

ភិក្ខុទាំងឡាយ អ្នកប្រព្រឹត្តិនៅក្នុងឱវាទរបស់យើង” ជាដើម ឈ្មោះថា **យស~មទោ** = សេចក្ដីស្រវឹងក្នុងយសស័ក្តិ ៕

## អំពីការស្រវឹងក្នុងសីល

មានះដែលកើតឡើង ដោយអំណាចនៃសេចក្ដីស្រវឹងថា “សត្វទាំងឡាយដ៏សេស (វៀរយើង) ហើយ ជាអ្នកទ្រុស្តសីល, ឯយើងជាអ្នកមានសីល” ឈ្មោះថា **សីលមទោ** = ស្រវឹងក្នុងសីល ៕

## អំពីការស្រវឹងក្នុងសមាធិ

មានះដែលកើតឡើង ដោយអំណាចនៃសេចក្ដីស្រវឹងថា “សត្វទាំងឡាយដ៏សេស (រំលងយើង) ហើយ មិនមានឯកគ្គតាចិត្ត (សមាធិ) ក្នុងកាលសូម្បីត្រឹមតែថា ការផឹកទឹករបស់មាន់, ចំណែកយើងបានឧបចារជ្ឈាន ឬអប្បនាឈាន” ឈ្មោះថា **ឈានមទោ** = ស្រវឹងក្នុងសមាធិ ៕

## អំពីការស្រវឹងក្នុងសិប្បៈ

មានះដែលកើតឡើង ដោយអំណាចនៃការស្រវឹងថា “សត្វទាំងឡាយដ៏សេស (ក្រៅពីយើង) មិនមាន, តែយើងមានសិប្បៈ” ឈ្មោះថា **សិប្បមទោ** = ស្រវឹងក្នុងសិប្បៈ ៕

## អំពីការស្រវឹងក្នុងភាពជាអ្នកមានកម្ពស់

មានះដែលកើតឡើង ដោយអំណាចនៃការស្រវឹងថា "សត្វទាំងឡាយ (វៀរយើង) ហើយ មានទ្រង់ទ្រាយតឿ, ចំណែកយើងមានទ្រង់ទ្រាយខ្ពស់" ឈ្មោះថា **អារោហមទោ** = **ស្រវឹងព្រោះមានកម្ពស់** ៕

## អំពីការស្រវឹងក្នុងភាពជាអ្នកមានធំហំ

មានះដែលកើតឡើង ដោយអំណាចនៃការស្រវឹងថា "សត្វទាំងឡាយដ៏សេស (វៀរយើង) ហើយ មានទ្រង់ទ្រាយទាបពេក ខ្ពស់ពេក, ឯយើងមានទ្រង់ទ្រាយសមល្មម ដូចដើមនិគ្រោធ" ឈ្មោះថា **បរិណាហមទោ** = **ស្រវឹងព្រោះមានទំហំ** ៕

## អំពីការស្រវឹងក្នុងភាពជាអ្នកមានទ្រង់ទ្រាយ

មានះដែលកើតឡើង ដោយអំណាចនៃការស្រវឹងថា "អាកប្បកិរិយារបស់សត្វទាំងឡាយដ៏សេស (វៀរយើង) ហើយ មានរូបរាងប្លែក មិនគួរសរសើរ, ឯយើងវិញ មានរូបរាងគួរពេញចិត្ត គួរជាទីជ្រះថ្លា" ឈ្មោះថា **សណ្ឋានមទោ** = **ស្រវឹង ព្រោះមានទ្រង់ទ្រាយ** ៕

## អំពីការស្រវឹងក្នុងរាងកាយដែលបរិបូណ៌

មានះដែលកើតឡើង ដោយអំណាចនៃការស្រវឹងថា "រាងកាយរបស់សត្វទាំងឡាយដ៏សេស (វៀរយើង) ហើយ មានទោសច្រើន តែសរីរៈរបស់យើងមិនមាន ទោសសូម្បីត្រឹមតែប៉ុនសរសៃសក់" ឈ្មោះថា **បារិបូរិមទោ** = ស្រវឹងព្រោះមានរាងកាយបរិបូណ៌ ។

ព្រះមានព្រះភាគត្រាស់មានះ (ការប្រកាន់ខ្លួន) ដែលប្រព្រឹត្តទៅដោយវត្ថុ (សវត្ថុកៈ) ដោយប្រការមានប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងមានះមិនមានវត្ថុ (អវត្ថុកៈ) ដែលកំពុងកើតឡើងនោះឯង ទើបត្រាស់ពាក្យជាដើមថា **"តត្ថ កតមោ មទោ** = ក្នុងពាក្យទាំងនោះ ការស្រវឹង តើដូចម្តេច ?" ពាក្យនោះ មានអត្ថងាយស្រួលទាំងអស់ ៕

## បមាទនិទ្ទេស អធិប្បាយពាក្យថាសេចក្តីប្រមាទ

ពាក្យថា **"ចិត្តស្ស វោសគ្គោ** = បណ្តោយចិត្ត" បានដល់ ការបណ្តោយចិត្ត ព្រោះមិនគ្របសង្កត់ទុកដោយសតិ ក្នុងឋានទាំងឡាយដូច្នេះ មានប្រមាណប៉ុណ្ណេះ, អធិប្បាយថា វៀរចាកសតិ; ពាក្យថា **"វោសគ្គានុប្បទានំ** = ការបំពេញ (ឱ្យកម្លាំងដល់) ការបណ្តោយចិត្ត" គឺការបណ្តោយចិត្តទៅញយៗ; ពាក្យថា **អសក្កច្ចកិរិយតា** = ការធ្វើដោយមិនគោរព" បានដល់ ឈ្មោះថា ធ្វើដោយមិនគោរព ព្រោះមិនធ្វើដោយសេចក្តីគោរព គឺការចម្រើនកុសលធម៌ទាំងឡាយ មានការឱ្យទានជាដើម ឬដោយអំណាចនៃការមិនធ្វើសេចក្តីគោរពដល់បុគ្គល ឬថាចំពោះ

ទេយ្យធម៌ ។ ភាវៈនៃការធ្វើដោយទាក់ទងគ្នា ឈ្មោះថា **សាតច្ចៈ**, ការមិនធ្វើដោយទាក់ទងគ្នា ឈ្មោះថា **អសាតច្ចៈ**, អាការដែលធ្វើដោយមិនទាក់ទងគ្នា ឈ្មោះថា **អសាតច្ចកិរិយតា**; ការធ្វើដោយមិនមាំទាំ ឈ្មោះថា **អនដ្ឋិតកិរិយតា**; ក្នុងសេចក្តីនេះ ប្រៀបដូចខ្លួនសត្វបង្កួយរត់ទៅបន្តិច ហើយឈប់បន្តិច, រមែងមិនរត់ទៅជាប់តគ្នា យ៉ាងណា, សេចក្តីនេះ ក៏យ៉ាងនោះដែរ; បុគ្គលណាឱ្យទានរហូត (មួយថ្ងៃ) ឬធ្វើការបូជាមួយដង ឬថាស្តាប់ធម៌មួយដង ឬក៏ធ្វើសមណធម៌ មួយដងហើយ មិនធ្វើតទៅ មិនឱ្យកុសលនោះៗ ប្រព្រឹត្តិទៅជាប់តគ្នា ការធ្វើរបស់បុគ្គលនោះ ព្រះមានព្រះភាគត្រាស់ហៅថា "ការមិន ធ្វើឱ្យមាំទាំ" ។ ពាក្យថា "**ឱលីនវុត្តិតា** = ប្រព្រឹត្តបន្តិចបន្តួច" បានដល់ ឈ្មោះថា ប្រព្រឹត្តបន្តិចបន្តួច ព្រោះមិនប្រព្រឹត្តផ្សាយចេញទៅ ពោលគឺការធ្វើមិនឱ្យដាច់រយៈ; ពាក្យថា "**និក្ខិត្តឆន្ទតា** = ការលះបង់ឆន្ទៈ" បានដល់ វិរិយៈ និងឆន្ទៈក្នុងការធ្វើកុសល ជាសភាវៈដែលគេលះអស់ហើយ; ពាក្យថា "**និក្ខិត្តធុរំ** = ការលះបង់ធុរៈ" បានដល់ ការដាក់ធុរៈ គឺកាត់សេចក្តីព្យាយាមចេញទៅ, អធិប្បាយថា ភាវៈនៃបុគ្គលនោះ មានឆន្ទៈក្នុងចិត្តលះបង់អស់ហើយ; ពាក្យថា "**អនធិដ្ឋានំ** = ការមិនតាំងចិត្ត" បានដល់ មិនមានការតាំងចិត្តក្នុងកុសល ។

ពាក្យថា "**អននុយោគោ**" បានដល់ ការមិនប្រកបសេចក្តីព្យាយាមរឿយៗ។

ការភ្លេចសតិ ឈ្មោះថា សេចក្តីប្រមាទ; ក៏ពាក្យថា "**យោ ឯវរូបោ បមាទោ** = សេចក្តីប្រមាទឯណា មានសភាពដូច្នេះ" នេះ ជាការសម្តែងអាការ

ដោយសេចក្ដីមិនមានព្រំដែននៃបរិយាយដោយអត្ថ និងដោយព្យញ្ជនៈ; ពាក្យនេះ ព្រះមានព្រះភាគទ្រង់អធិប្បាយទុកថា សេចក្ដីប្រមាទឯណាដែលសម្ដែងហើយ តាំងអំពីដើម, សេចក្ដីប្រមាទឯណា សូម្បីដទៃទៀត ក៏មានអាការយ៉ាងនេះ មាន ជាតិយ៉ាងនេះ កិរិយាដែលប្រមាទ ដោយអំណាចនៃភាពជាអ្នកមិនចេះយកចិត្ត ទុកដាក់ក្ដី, ក៏មានអាការយ៉ាងនេះ មានជាតិយ៉ាងនេះ បុគ្គលនេះ ឈ្មោះថា មាន សេចក្ដីប្រមាទ; តែកាលពោលដោយលក្ខណៈ សេចក្ដីប្រមាទនេះ មានការមិន លះបង់សតិក្នុងកាមគុណ ៥ ជាលក្ខណៈ (ហេតុ) បណ្ឌិតគប្បីជ្រាបសេចក្ដី ប្រមាទនោះឯងថា មានអាការលះសតិដូច្នេះ ៕

## ថម្ភនិទ្ទេស អធិប្បាយការរឹងត្អឹង

ឈ្មោះថា **សេចក្ដីរឹងត្អឹង** ព្រោះអត្ថថា រឹងរុស; ភាពរឹងត្អឹងរបស់ចិត្ត ដូចជាសំពត់សាច់រឹងក្រញាង ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកក្នុងទីនេះ; អាការ នៃសេចក្ដីរឹងត្អឹង ហៅថា កិរិយារឹងចចេស, សភាពនៃការរឹងចចេស ឈ្មោះថា សេចក្ដី រឹងត្អឹង; ភាវៈនៃបុគ្គលអ្នកថោកទាប ឈ្មោះថា **កក្ខឡិយំ** = ការរឹងរូស; ភាវៈនៃបុគ្គលអ្នកគ្រោតគ្រាត ឈ្មោះថា **ផារុសិយំ** = ការបោះបោក; ភាវៈនៃចិត្ត ដែលតម្កល់ទុកត្រង់នុំះឯង ដោយអំណាចនៃការមិនធ្វើសេចក្ដីឱនលំទោនដល់បុគ្គល ដែលគួរឱនលំទោន មានការអភិវាទជាដើមនោះ ឈ្មោះថា **ឧជុចិត្តតា**; ភាពជា អ្នកមានចិត្តរឹង ភាវៈនៃការរឹងចចេស មិនជាធម្មជាតិទន់ ឈ្មោះថា **អមុទុតា** = ភាពជាអ្នកមិនទន់ភ្លន់; ពាក្យថា **“អយំ ខុច្ចតិ”** នេះ ព្រះមានព្រះភាគត្រាស់

ហៅថា **ថម្ភៈ** (ការរឹងចចេស), អធិប្បាយថា បុគ្គលប្រកបដោយសេចក្ដីរឹង-ចចេសឯណា ជាអ្នកប្រៀបដូចពស់ថ្លាន់ ដែលស៊ីនុយហើយ ក៏ដេកពត់ក្បាលដូច្នោះ, លុះឃើញព្រះចេតិយ ឬបុគ្គលអ្នកចម្រើនជាង ក៏មិនឱនលំទោន រមែងប្រព្រឹត្តិរឹងត្អឹង ដូចជាស្បូវដែលពេញដោយខ្យល់; បុគ្គលនោះ បណ្ឌិតគប្បីជ្រាបថា មានការរីកឡើងនៃចិត្តជាលក្ខណៈ ៕

## សារម្ភនិទ្ទេស អធិប្បាយការប្រណាំងប្រជែង

ឈ្មោះថា ការប្រណាំង (**សារម្ភៈ**) ដោយអំណាចនៃការខឹង; ការដែលផ្សាយចេញទៅនៃសេចក្ដីប្រណាំងប្រជែង ឈ្មោះថា ការប្រណាំងប្រជែង (**បដិ-សារម្ភៈ**); អាការដែលប្រណាំងប្រជែង ឈ្មោះថា **កិរិយាប្រណាំងប្រជែង** ។ កិរិយាដែលប្រណាំងប្រជែងផ្សាយចេញទៅ ឈ្មោះថា **កិរិយាដែលប្រណាំង-ប្រជែង**; ភាវៈនៃបុគ្គលអ្នកប្រណាំងប្រជែងផ្សាយទៅហើយ ឈ្មោះថា **សភាពនៃការប្រណាំងប្រជែង**; ពាក្យថា **"អយំ វុច្ចតិ"** នេះ ព្រះមានព្រះភាគត្រាស់ថា បុគ្គលនេះ ឈ្មោះថា មានសេចក្ដីប្រណាំងប្រជែង ពោលដោយលក្ខណៈ ព្រះមានព្រះភាគត្រាស់ហៅបុគ្គលនោះថា មានវត្ថុប្រដូចដោយការធ្វើហួសហេតុជាលក្ខណៈ, គឺថា បុគ្គលណា ប្រកបដោយវត្ថុណា បុគ្គលអ្នកប្រណាំងប្រជែងនោះ រមែងធ្វើវត្ថុនោះៗ ឱ្យជាពីរស្មើ (ទ្វេគុណ); ដូចជាអ្នកគ្រប់គ្រងផ្ទះ បុគ្គលដទៃតុបតែង ឬរៀបចំខាងក្នុងផ្ទះដោយវត្ថុត្រឹមតែម្យ៉ាងៗ បុគ្គលអ្នកប្រណាំងប្រជែង រមែងចាត់ចែងវត្ថុ ២ យ៉ាង, អ្នកចាត់ចែងដទៃទៀត រមែងចាត់ចែងវត្ថុ ៤, អ្នក

ដទៃទៀត រមែងចាត់ចែងវត្ថុ ៨; អ្នកប្រណាំងប្រជែងដទៃទៀត រមែងចាត់ចែងវត្ថុ ១៦ ។

អ្នកមិនគ្រប់គ្រងផ្ទះ (សមណៈ) មានការប្រណាំងប្រជែង កាលអ្នករៀនព្រះពុទ្ធវចនៈនិកាយមួយៗ ដោយសូត្រមួយៗ អ្នកប្រណាំងប្រជែងនឹងមនុស្សដទៃ រមែងគិតថា "យើងនឹងជាអ្នកមិននៅខាងក្រោម (ចាញ់) អ្នកនោះ" ទើបរៀន ២ និកាយ, អ្នកប្រណាំងប្រជែងដទៃទៀត រមែងរៀនយក ៣ និកាយ, អ្នកប្រណាំង-ប្រជែងដទៃផ្សេងទៀត រមែងរៀនយក ៤ និកាយ, អ្នកប្រណាំងប្រជែងមួយទៀត រមែងរៀនយកព្រះពុទ្ធវចនៈ ៥ និកាយ; ក៏ការរៀនព្រះពុទ្ធវចនៈនោះ មិនគួរដោយអំណាចនៃការប្រណាំងប្រជែង; ព្រោះថា ការប្រណាំងប្រជែងនោះ ជាក្រុម (បក្សពួក) នៃអកុសល ជាផ្លូវនាំសត្វឱ្យទៅកាន់នរក; តែថា ពោលដោយអំណាចនៃបក្សពួកក្នុងកុសល កាលបុគ្គលថ្វាយសលាកភត្តត្រឹមតែម្យ៉ាង បុគ្គលដទៃគួរឱ្យបំពេញជាពីរ កាលបុគ្គលថ្វាយពីរយ៉ាង បុគ្គលដទៃគួរថ្វាយបំពេញជា ៤ យ៉ាង យ៉ាងនេះ ទើបសមគួរ; ក៏កាលភិក្ខុរៀនព្រះពុទ្ធវចនៈនិកាយមួយ ភិក្ខុដទៃរៀនយកពីរនិកាយ ដោយគិតថា "កាលបើយើងស្វាធ្យាយព្រះពុទ្ធវចនៈសុភមង្គល (សេចក្ដីសុខ) រមែងមាន" ក៏គួរ ព្រោះហេតុនោះ ការរៀនព្រះពុទ្ធ-វចនៈឱ្យលើសពីនោះ ព្រោះនៅក្នុងក្រុមនៃកុសល ដែលជាវិវដ្ដៈក៏គួរ ៕

## អត្រិច្ឆតានិទ្ទេស អធិប្បាយការចង់បានហួសប្រមាណ

អត្ថនៃសេចក្ដីថោកទាបលាមក ដែលពោលទុកក្នុងអរិយវង្សសូត្រ យ៉ាង

ណា, អត្ថនៃសេចក្ដីប្រាថ្នាចង់បានហួសប្រមាណ ក៏ដូច្នោះដែរ; ក្នុងបណ្ដាបច្ច័យទាំងឡាយ មានចីវរប្បច្ច័យជាដើម ភិក្ខុបានវត្ថុណា១ មក ក៏មិនត្រេកអរក្នុងវត្ថុនោះ១, ឬថា ជាគ្រហស្ថ រមែងបានវត្ថុណា១ ក្នុងបណ្ដារូប សំឡេង ក្លិន រស និង ផោដ្ឋព្វៈ ក៏មិនត្រេកអរដោយវត្ថុនោះ ១; ពាក្យថា "**អភិយោភមេត្តា** = ភាពប្រាថ្នាឱ្យវិសេសឡើងទៅ" ; ឈ្មោះថា សេចក្ដីចង់បាន ព្រោះអំណាចនៃសេចក្ដីប្រាថ្នា; ឬថា អាការនៃសេចក្ដីប្រាថ្នានោះឯង ឈ្មោះថា **កិរិយាដែលប្រាថ្នា**; សភាពនៃការប្រាថ្នាហួសនឹងការចង់បានរបស់ខ្លួន ឈ្មោះថា **លោភច្រើន**; ពាក្យថា "**រាគៈ**" ជាដើម មានអត្ថតាមដែលពោលហើយ ក្នុងខាងក្រោយនោះ ឯង; ពាក្យថា "**អយំ វុច្ចតិ**" បានដល់ នេះព្រះមានព្រះភាគត្រាស់ហៅថា សេចក្ដីលោភច្រើន; សូម្បីសេចក្ដីប្រាថ្នាលើសប្រមាណនេះ ក៏ជាឈ្មោះរបស់សេចក្ដីលោភច្រើននោះឯង; តែកាលពោលដោយលក្ខណៈ សេចក្ដីប្រាថ្នាលើសប្រមាណនេះ បានដល់ សេចក្ដីមិនសន្ដោសក្នុងលាភរបស់ខ្លួន និងសេចក្ដីប្រាថ្នាក្នុងលាភរបស់អ្នកដទៃ សេចក្ដីនេះមានការប្រាថ្នាលើសប្រមាណជាលក្ខណៈ; ពិតមែន សូម្បីវត្ថុប្រណីត ដែលបុគ្គលអ្នកមានសេចក្ដីប្រាថ្នាលើសប្រមាណនោះបានហើយ រមែងប្រាកដដូចជារបស់លាមក (ថោកទាប), ក៏សូម្បីវត្ថុលាមកដែលបុគ្គលដទៃបានហើយ រមែងប្រាកដដូចជារបស់ប្រណីត, បបរដែលឆ្អិនហើយក្នុងភាជនៈមួយ ឬភត្តឬក៏នំដែល គេដាក់ទុកក្នុងបាត្ររបស់ខ្លួន ហាក់បីដូចជារបស់លាមក ក្នុងបាត្រអ្នកដទៃ រមែងប្រាកដដូចជារបស់ប្រណីត; ម្យ៉ាងទៀត សេចក្ដីប្រាថ្នាហួសប្រមាណនេះ រមែងមានសូម្បីដល់បព្វជិតទាំងឡាយ រមែងមានសូម្បីដល់គ្រហស្ថទាំងឡាយ

រមែងមានសូម្បីដល់សត្វតិរច្ឆានទាំងឡាយ; ក្នុងសេចក្ដីនេះ គប្បីជ្រាបរឿងទាំងឡាយប៉ុណ្ណេះ ជាឧទាហរណ៍តទៅ ៖

## រឿងអ្នកចង់បានហួសប្រមាណ

បានឮថា កុដុម្ពិកៈម្នាក់និមន្តភិក្ខុនី ៣០ រូប បានថ្វាយភត្តជាមួយនឹងនំ; ព្រះសង្ឃត្ថេរីញ៉ាំងនំក្នុងបាត្ររបស់ភិក្ខុនីទាំងឡាយ ឱ្យផ្លាស់ប្ដូរគ្នាហើយ (យល់ឃើញថា បំបែកនំក្នុងបាត្រដទៃ) រួចទើបឆាន់នំទាំងនោះ ដែលខ្លួនបានហើយខាងក្រោយ ។

សូម្បីព្រះបាទពារាណសី ក៏ទ្រង់ព្រះតម្រិះថា “យើងនឹងស៊ីសាច់ឆ្អិនដោយរងើកភ្លើង” ទើបទ្រង់នាំព្រះទេវីស្ដេចចូលទៅកំសាន្តព្រៃ ទ្រង់ទតឃើញកិន្នរីមួយ ទ្រង់លះចោលព្រះទេវី ស្ដេចយាងទៅតាមនាងកិន្នរីនោះទៅ ។ ទើបព្រះទេវីស្ដេចយាងទៅអាស្រមបទ (បួសជាតាបសិនី) ហើយធ្វើកសិណបរិកម្មសម្រេចបានសមាបត្តិ ៨ និងអភិញ្ញា ៥ អង្គុយហើយឃើញព្រះរាជាកំពុងស្ដេចយាងមក ទើបហោះឡើងទៅលើអាកាស ហើយយាងគេចចេញទៅ ។ ទេវតាអ្នករស់នៅត្រង់ដើមឈើ ដឹងហេតុការណ៍នោះហើយ បានពោលគាថានេះថា ៖

**“អច្ចិច្ឆំ អតិលោភេន អតិលោភមទេន ច**
**ឯវំ សោ ហាយតិត្ថានំ ចន្ទំវ អសិតាភុយា**

ព្រះអង្គនោះ ទ្រង់ប្រាថ្នានាងចន្ទកិន្នរី ទ្រង់
លះបង់ព្រះរាជធីតាអសិតាភូចោលហើយ សូម្បី
ព្រះអង្គ ក៏រមែងញ៉ាំងព្រះសរីរៈឱ្យទ្រុឌទ្រោម

ទៅ ព្រោះសេចក្ដីលោភច្រើន និងព្រោះការ
ស្រវឹងក្នុងសេចក្ដីលោភច្រើនដូច្នោះ” ។

ទេវតា បានធ្វើការចំអកចំអន់ព្រះរាជាថា “ព្រះអង្គកាលប្រាថ្នានាងចន្ទកិន្នរី ទ្រង់លះបង់ព្រះរាជធីតាអសិតាភូ ទើបសាបសូន្យចាកនាងទាំងពីរ, ការលោភច្រើន យ៉ាងនេះ រមែងធ្វើខ្លួនឱ្យវិនាសទៅ”[៥១] ៕

## រឿងបុត្រនៃសេដ្ឋី

សូម្បីក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ ព្រះនាម **កស្សបៈ** មានបុត្រសេដ្ឋីម្នាក់ ឈ្មោះថា **មិត្តវិន្ទុកៈ** មិនមានសទ្ធា, មិនជ្រះថ្លាក្នុងព្រះពុទ្ធសាសនា, មាតាអង្វរថា “កូន ! ចូរអ្នករក្សាឧបោសថសីល ចូរស្ដាប់ធម៌ក្នុងថ្ងៃនេះ រហូតដល់រាត្រីក្នុងវិហារ, ម្ដាយនឹងឱ្យទ្រព្យមួយពាន់កហាបណៈ” ព្រោះសេចក្ដីលោភក្នុងទ្រព្យ ទើបទៅវិហារ សមាទានឧបោសថសីល កាលបើទៅហើយ ក៏កំណត់ស្ថានទីថា “ទីនេះ មិនមានភ័យ (គឺមិនមាននរណាឃើញ)” ហើយដេកខាងក្រោមធម្មាសនៈ កាលបើដេករហូតដល់ ១ យប់ ក៏ក្រោកឡើងទៅផ្ទះ មាតារបស់គេដាំបាយយាគូឱ្យតាំងពីព្រឹកព្រលឹម; នាយមិត្តវិន្ទុកៈនោះ សុំទ្រព្យមួយពាន់កហាបណៈមុននោះឯងហើយទើបហុតយាគូ; លំដាប់នោះ គេមានបរិវិតក្កៈថា “ យើងនឹងរួបរួម (ប្រមូល) ទុនឱ្យបានច្រើន ដោយទ្រព្យនេះ” ទើបប្រាថ្នាឡើងទូកទៅសមុទ្រដើម្បីជួញ; លំដាប់នោះ មាតារបស់គេបានពោលហាមថា “កូន ! ក្នុងត្រកូលរបស់យើងមាន

---

[៥១] ខុ. ជា. ។

ទ្រព្យ ៤០ កោដិ, ចូរអ្នកកុំទៅអី" ; គេមិនស្តាប់បង្គាប់ពាក្យរបស់មាតាហើយ ក៏ទៅ; ទើបមាតាទៅឈររាំងខាងមុខ; ក្នុងខណៈនោះឯង គេខឹងហើយ ក៏លើកជើងប្រហារមាតាឱ្យដួល ដោយគិតថា "មេស្រីនេះ មកឈររាំងមុខយើង" , បានធ្វើមាតាឱ្យនៅក្នុងចន្លោះជើងរួច (ដើរកន្លង) ទៅ; មាតាក្រោកឡើង ហើយពោលថា "កូន ! ចូរកុំសម្គាល់យ៉ាងនេះថា 'កាលបើយើងធ្វើកម្មមានសភាពដូច្នេះ ក្នុងមាតាដូចជាយើងហើយទៅ **សេចក្តីសុខនឹងមានក្នុងទីដែលយើងទៅហើយ"** ។

កាលនាយមិត្តវិន្ទុកៈនោះ ឈានឡើងជិះទូកទៅ ទូកក៏ឿងនៅក្នុងថ្ងៃទី ៧; លំដាប់នោះ មនុស្សទាំងឡាយនោះ ពោលថា "បុរសដ៏លាមកមុខជានឹងមាននៅក្នុងទូកនេះ ពិតប្រាកដ, អ្នកទាំងឡាយចូរចាប់ស្លាក" ស្លាកដែលពួកគេឱ្យចាប់ ក៏ធ្លាក់ដល់នាយមិត្តវិន្ទុកៈនោះឯង អស់វារៈ ៣ លើក; ទើបមនុស្សទាំងនោះចាប់នាយមិត្តវិន្ទុកៈនោះ បណ្តែតក្បូនហើយ ទើបបណ្តែតទូកទៅក្នុងសមុទ្រ; ក្បូនរបស់នាយមិត្តវិន្ទុកៈនោះ អណ្តែតទៅកាន់កោះមួយ គេសោយសម្បត្តិជាមួយនឹងនាងវេមានិកប្រេតទាំងឡាយ សូម្បីនាងវេមានិកប្រេតទាំងឡាយ ពោលអង្វរថា "សូមលោកកុំទៅមុខ" កាលគេទៅហើយឃើញសម្បត្តិពីរនោះ ក៏ប្រព្រឹត្តទៅដោយលំដាប់ ក្នុងទីបំផុត បានឃើញបុរសម្នាក់មានកងចក្រខៃវិលនៅត្រង់ក្បាល, និងកាលបើប្រាកដដូចជាផ្កាឈូក, នាយមិត្តវិន្ទុកៈនោះ ទើបពោលនឹងបុរសនោះថា បពិត្រលោកដ៏ចម្រើន សូមលោកឱ្យផ្កាឈូកដែលលោកប្រដាប់ទុកនេះដល់ខ្ញុំ" ; បុរសនោះពោលថា "នៃនាយ នេះមិនមែនផ្កាឈូកទេ, នេះជាកងចក្រដែលខៃ" ; នាយមិត្តវិន្ទុកៈពោលថា "សូមលោកកុំបញ្ឆោតខ្ញុំ, ផ្កាឈូក ដូចម្តេចខ្ញុំ

មិនធ្លាប់ឃើញឬ ?” ហើយពោលថា “ក៏លោកលាបដោយចន្ទន៍ក្រហម ទើបមិនត្រូវការឱ្យផ្កាបទុម ដែលជាគ្រឿងប្រដាប់នោះដល់យើង” ។ បុរសនោះគិតថា សូម្បីជននេះនឹងជាអ្នកធ្វើកម្មដូចយើងដែរ ទើបប្រាថ្នាសោយផលរបស់កម្មនោះ” ; លំដាប់នោះ បុរសអ្នកមានកងចក្រដែលវិលព័ទ្ធនៅលើក្បាលនោះ ទើបពោលថា “ណ្ហើយចុះ យើងនឹងឱ្យ” ហើយទើបយកកងចក្រដាក់លើក្បាលរបស់នាយមិត្តវិន្ទុកៈ ហើយចៀសចេញទៅ ។

ព្រះសាស្ដាទ្រង់ជ្រាបសេចក្ដីនេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

**“ចតុព្ភិ អដ្ឋជ្ឈគមា  អដ្ឋាភិបិ ច សោឡស**
**សោឡសាភិ ច ពត្តឹស  អត្រិច្ឆំ ចក្កមាសទោ**
**ឥច្ឆាហតស្ស បោសស្ស  ចក្កំ ភមតិ មត្ថកេ**

បុរសនោះ (នាយមិត្តវិន្ទុកៈ) លះពីនាងវិមានិកប្រេត ៤ នាក់ សោយសម្បត្តិជាមួយនឹងនាងវិមានិកប្រេត ៨ នាក់ សោយសម្បត្តិជាមួយនឹងនាងវិមានិកប្រេត ១៦ នាក់ លះពីនាងវិមានិកប្រេត ១៦ នាក់ ហើយ សោយសម្បត្តិ ជាមួយនឹងនាងវិមានិកប្រេត ៣២ នាក់ ជាអ្នកមានសេចក្ដីចង់បានហួសប្រមាណ ចូលដល់កងចក្រ ចក្រនោះ រមែងវិលទៅលើក្បាលបុរសដែលមានសេចក្ដីចង់បាន នាំមកហើយ”[៥២] ៕

[៥២] ខុ. ជា. ។

## រឿងអាមាត្យ

អាមាត្យម្នាក់មានសេចក្ដីចង់បានលើសប្រមាណ សូម្បីដងទៃទៀត ឈានកន្លងខែត្រដែនរបស់ខ្លួន ចូលទៅរករបស់អ្នកដទៃ; ត្រូវគេវាយប្រហារហើយក្នុងទីនោះ ទើបជៀសចេញទៅកាន់ទីជាកន្លែងនៅរបស់តាបសម្នាក់ អធិដ្ឋានអង្គឧបោសថហើយដេក ។ អាមាត្យនោះត្រូវតាបសសួរថា "លោកធ្វើកម្មអ្វីមក" ទើបគេបានពោលគាថានេះថា "**សកំ និកេតំ អតិហេឡយានោ ឥ ល ឥ អត្រិច្ឆតា មាបុន រាគាមាសិ** = ខ្ញុំស្អប់ខ្ពើមទីនៅរបស់ខ្ញុំ បានទៅកាន់ស្ថានទីដែលជាមន្ទិល ដោយសេចក្ដីលោភច្រើន លំដាប់នោះ ជនទាំងឡាយចេញពីភូមិនាំគ្នាមកវាយខ្ញុំដោយធ្នូ, ខ្ញុំមានក្បាលបែកហើយ, មានលោហិតស្រោចខ្លួន ទើបជៀសចេញទៅ, ព្រោះហេតុដូច្នោះ ទើបខ្ញុំរក្សាឧបោសថ សូមសេចក្ដីប្រាថ្នាដ៏អាក្រក់ កុំត្រឡប់មករកខ្ញុំទៀតឡើយ" ៕

## មហិច្ឆតានិទ្ទេស

### អធិប្បាយការប្រាថ្នាច្រើន ឬ ការស្រេកឃ្លាន

បុគ្គលណាប្រាថ្នាវត្ថុទាំងឡាយហួសប្រមាណ, ឬថា សេចក្ដីចង់បានលើសប្រមាណរបស់អ្នកនោះមាន ព្រោះហេតុនោះ ទើបអ្នកនោះឈ្មោះថា ជាអ្នកមានសេចក្ដីប្រាថ្នាច្រើន (ភាពស្រេកឃ្លាន), ភាវៈនៃបុគ្គលអ្នកមានសេចក្ដីប្រាថ្នាច្រើននោះ ឈ្មោះថា **ភាពប្រាថ្នាច្រើន** ។ ក៏កាលពោលដោយលក្ខណៈបានដល់ ការមិនស្គាល់ប្រមាណក្នុងការទទួល និងក្នុងការបរិភោគ ក៏ព្រោះការ

ចម្រើនគុណដែលមិនមានហើយ នេះឈ្មោះថា មានសេចក្ដីចង់បានច្រើនជាលក្ខណៈ ។ ពិតមែន បុគ្គលអ្នកចង់បានច្រើន (ចង់ធំ) មានសេចក្ដីស្រេកឃ្លាន ប្រៀបដូចឈ្មួញរែកទំនិញ (កច្ឆបូដវាណិជ្ជោ) កាន់ទំនិញ គ្រឿងប្រដាប់ដោយដៃ និងយួរវត្ថុដែលគួរលក់ ទុកត្រង់មុខផ្លូវ ហើយពោលឃោសនាអញ្ជើញបបួលមហាជន ដែលឃើញនោះឯងថា "ម៉ែ ! ចូរកាន់យកវត្ថុឈ្មោះឯណោះ, ឈ្មោះឯណេះ" ដូច្នេះឈ្មោះថា មានឧបមាយ៉ាងណា, សេចក្ដីនេះ ក៏ដូច្នោះដែរ គុណ គឺសីល ឬការសិក្សាព្រះពុទ្ធវចនៈ ឬក៏ធុតង្គគុណ ដោយហោចទៅសូម្បីត្រឹមតែថា ការនៅព្រៃជាវត្តរបស់ខ្លួន សូម្បីមានប្រមាណតិច តែជាអ្នកប្រាថ្នាដើម្បីញុំាងមហាជនអ្នកដឹងនោះឱ្យសរសើរខ្លួន ។ ក៏ឯបុគ្គលដូច្នេះ គ្រាកាលមហាជនសរសើរខ្លួន បង្អោនបច្ច័យទាំងឡាយ សូម្បីទាំងរទេះមកឱ្យ ក៏មិនល្មម មិនពោលហាមថា "កុំឡើយ" រមែងកាន់យកមែនពិត ។ ពិតមែន នរណាៗ ក៏មិនអាចដើម្បីញុំាងវត្ថុទាំង ៣ ឱ្យឆ្អែតឱ្យពេញ គឺ ភ្លើងរមែងមិនឆ្អែតដោយឧស, សមុទ្ររមែងមិនឆ្អែត (ពេញ) ដោយទឹក, បុគ្គលអ្នកមានសេចក្ដីចង់បានច្រើន អ្នកស្រេកឃ្លាន រមែងមិនឆ្អែត (មិនគ្រប់) ដោយបច្ច័យទាំងឡាយឡើយ ។

**អគ្គិក្ខន្ធោ សមុទ្ទោ ច មហិច្ឆោ ចាបិ បុគ្គលោ**
**ពហុកេ បច្ចយេ ទេន្តេ តយោបេតេ ន បូរយេ**

វត្ថុទាំង ៣ នេះ គឺ គំនរភ្លើង ១ មហាសមុទ្រ ១
បុគ្គលអ្នកប្រាថ្នាច្រើន ១ កាលបើនរណាៗ ឱ្យបច្ច័យ

ទាំងឡាយ សូម្បីច្រើន ក៏មិនឆ្អែត មិនពេញបាន[៥៣] ។

ពិតមែន បុគ្គលអ្នកប្រាថ្នាច្រើន សូម្បីតែមាតាអ្នកឱ្យកំណើត ក៏មិនអាចដើម្បីកាន់យកចិត្តរបស់គេទុកបាន, នឹងចាំបាច់ពោលទៅថ្វីដល់បុគ្គលអ្នកជាឧបដ្ឋាក; ក្នុងសេចក្តីនេះ មានរឿងទាំងនេះ ជាឧទាហរណ៍ ៖

## រឿងភិក្ខុកំលោះ

បានឮថា ភិក្ខុកំលោះមួយរូប ជាប់ចិត្តក្នុងនំធ្វើដោយម្សៅ; លំដាប់នោះមាតារបស់ភិក្ខុនោះ កាលសាកល្បងខបដិបត្តិរបស់បុត្រមើលថា "បើថា បុត្ររបស់យើងដឹងប្រមាណក្នុងការទទួលសោត, យើងនឹងទំនុកបម្រុងឧបត្ថម្ភដោយនំទាំង-ឡាយ រហូតដល់ត្រៃមាស" ទើបផ្តើមសាកល្បងក្នុងថ្ងៃជិតរដូវភ្លៀង គ្រាដំបូងបានប្រគេននំមួយ, កាលនំនោះអស់ហើយទើបប្រគេននំដុំទី ២, កាលនំដុំទី ២ អស់ហើយ ទើបប្រគេននំដុំទី ៣; ភិក្ខុកំលោះនោះ មិនហាមថា ល្មមហើយ នៅតែទំពាឆាន់នុំះឯង; មាតាជ្រាបនូវភាវៈនៃភិក្ខុជាកូនប្រុសនោះមិនស្គាល់ប្រមាណ ទើបពោលថា "នំត្រៃមាសទាំងអស់ បុត្ររបស់យើងទំពាឆាន់អស់ហើយ ក្នុងថ្ងៃនេះឯង" ; តាំងពីថ្ងៃនោះមក មិនបានប្រគេនទៀត សូម្បីតែនំមួយដុំ ។

**សូម្បីព្រះបាទតិស្សមហារាជ** កាលថ្វាយទានដល់ភិក្ខុសង្ឃត្រង់ចេតិយ-បពីតគ្រប់៧ ថ្ងៃ ទ្រង់ដែលមហាជនក្រាបទូលថា "បពិត្រព្រះមហារាជ ព្រះអង្គសេពត្រង់កន្លែងតែមួយ (ថ្វាយទានតែកន្លែងមួយ) ប៉ុណ្ណោះឬ ?, ការថ្វាយទាន

---

[៥៣] ប. សុ. ។

ក្នុងទីដទៃ រមែងមិនគួរដល់ព្រះអង្គឬ ?” ដូច្នេះ ក្នុងថ្ងៃទី ២ ពីថ្ងៃនោះ ទើបឱ្យថ្វាយមហាទាន ក្នុងក្រុងអនុរាធបុរី ។ ក្នុងភិក្ខុទាំងនោះ សូម្បីភិក្ខុមួយរូប ក៏មិនស្គាល់ប្រមាណក្នុងការទទួល, ជនទាំងឡាយ ២-៣ នាក់ បោះចោលនូវខាទនីយៈ និងភោជនីយៈ ដែលភិក្ខុមួយរូបៗ ទទួលទៅហើយ ។ ព្រះរាជាឱ្យនិមន្តភិក្ខុសង្ឃត្រង់ចេតិយបព៌ត ក្នុងថ្ងៃទី ២ ហើយត្រាស់ថា “លោកម្ចាស់ទាំងឡាយ ចូរឱ្យបាត្រក្នុងវេលាដែលលោកម្ចាស់ទាំងឡាយ មកកាន់ព្រះរាជវាំង” ; សូម្បីភិក្ខុមួយរូប ក៏មិនឱ្យបាត្រដោយពាក្យថា “កុំឡើយ មហារាជ, ភិក្ខុទាំងឡាយ នឹងទទួលភិក្ខា ដោយប្រមាណរបស់ខ្លួនប៉ុណ្ណោះ” ។ ភិក្ខុទាំងពួងទទួលនូវភិក្ខាដ៏សមគួរដល់ប្រមាណរបស់ខ្លួនន៉ុះឯង ។ លំដាប់នោះ ព្រះរាជាត្រាស់ថា “លោកទាំងឡាយ ចូរមើលភិក្ខុទាំងនេះ សូម្បីតែមួយរូប ក៏មិនដឹងប្រមាណរបស់ខ្លួន កាលពីម្សិលមិញ វត្ថុអ្វីៗ ក៏មិនបានសល់, តែថ្ងៃនេះ កាន់យកវត្ថុតិចល្មមប្រមាណដល់ខ្លួន, ទើបវត្ថុនៅសល់ច្រើន” ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុអ្នកមានចិត្តជារបស់ខ្លួនៗ ព្រោះស្គាល់ប្រមាណ ចំណែកភិក្ខុក្រៅនេះ មិនមានចិត្តជារបស់ខ្លួនៗ ព្រោះភាពជាអ្នកមិនស្គាល់ប្រមាណ ៕

## បាបិច្ឆតានិទ្ទេស អធិប្បាយការប្រាថ្នាលាមក

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **មនុស្សខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា កាលប្រាថ្នាយ៉ាងនេះថា “សូមជនចូរដឹងថា ‘ យើងជាអ្នកមានសទ្ធា”** ជាដើម រមែងធ្វើការយ៉ាងណាមួយ គឺ ៖

បុគ្គលនោះ មិនមានសទ្ធា រមែងសម្តែងអាការថា មានសទ្ធា, អ្នកទ្រុស្ត សីលជាដើម រមែងសម្តែងអាការរបស់អ្នកមានសីលជាដើម ។

**សួរថា** រមែងសម្តែងអាការយ៉ាងណា ?

ឆ្លើយថា អ្នកមិនមានសទ្ធាសោះ ក្នុងថ្ងៃមានបុណ្យធ្លងធំៗ លោកនឹងកាន់យកអំបោសបោសសម្អាតវិហារ និងធ្វើការចាក់សំរាមក្នុងវេលាដែលពួកមនុស្សមកកាន់វិហារ, កាលជ្រាបថា ការធ្វើរបស់លោក មនុស្សទាំងឡាយដឹងហើយ ទើបទៅកាន់លានព្រះចេតិយ, បោសហើយចាក់សំរាម ឆាយដីខ្សាច់ធ្វើផ្ទៃឱ្យស្មើគ្នា ។ រមែងលាងអាសនៈទាំងឡាយ, រមែងស្រោចទឹកត្រង់ដើមពោធិ៍ ។ មនុស្សទាំង-ឡាយ ឃើញលោកហើយសម្គាល់ថា “ភិក្ខុដទៃដែលបដិបត្តិវិហារបែបនេះ នឹងមិនមាន, ភិក្ខុនេះប៉ុណ្ណោះ នឹងជាព្រះថេរៈអ្នកមានសទ្ធាបដិបត្តិវិហារនេះ” ទើបនិមន្តភិក្ខុនោះដើម្បីឆាន់អាហារ ។

សូម្បីក្នុងអ្នកទ្រុស្តសីល ក៏ចូលទៅរកព្រះវិន័យធរ រមែងសួរចំពោះមុខនៃឧបដ្ឋាកទាំងឡាយថា “បពិត្រលោកដ៏ចម្រើន កាលខ្ញុំដើរទៅ គោស្លុតចិត្ត កាលខ្ញុំបោសសម្អាត គោក៏រត់ប្រសាចទៅ, ធ្វើឱ្យស្មៅទាំងឡាយដាច់ហើយ, កាលខ្ញុំដើរចង្ក្រម សត្វទាំងឡាយរមែងងាប់, កាលខ្ញុំស្តោះទឹកមាត់ឱ្យធ្លាក់ទៅ សត្វល្អិតតូចៗ រមែងងាប់ ការឱ្យទឹកមាត់ធ្លាក់ទៅលើស្មៅដោយមិនមានសតិ ទោសអ្វីរមែងមានក្នុងទីនោះ លោកម្ចាស់” ។ កាលព្រះវិន័យធរពោលថា “ម្នាលអ្នកមានអាយុ កាលយើងមិនដឹង មិនក្លែង មិនមានចេតនាសម្លាប់សត្វ អាបត្តិរមែងមិនមាន” ហើយពោលសរសើរ ព្រះវិន័យធរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន វត្ថុនេះរមែង

ប្រាកដដល់ខ្ញុំ ហាក់បីដូចជារបស់ធ្ងន់, លោករមែងពិចារណាត្រឹមត្រូវហើយ" ។ មនុស្សទាំងឡាយស្តាប់ពាក្យនោះ ហើយជ្រះថ្លាថា "លោកម្ចាស់របស់ពួកយើង រមែងរង្កៀស សូម្បីក្នុងហេតុមានប្រមាណតិច, លោកនឹងធ្វើកម្មគ្រោតគ្រាតបានយ៉ាងណា, ភិក្ខុអ្នកមានសីលដូចភិក្ខុនេះ រមែងមិនមាន" ហើយធ្វើសក្ការៈ ។

**សូម្បីអ្នកសិក្សាតិច** ក៏នឹងអង្គុយត្រង់កណ្តាលឧបដ្ឋាក រមែងពោលថា "ភិក្ខុនុ៎ះ ទ្រទ្រង់ព្រះត្រៃបិដក ភិក្ខុនុ៎ះទ្រទ្រង់និកាយ ៤ ជាអន្តេវាសិករបស់យើង, ភិក្ខុទាំងនេះ រៀនធម៌ក្នុងសំណាក់របស់យើង" ; ពួកមនុស្សជ្រះថ្លាថា "ភិក្ខុអ្នកជាពហូសូត ដូចលោកម្ចាស់របស់យើងមិនមាន, បានឮថា ភិក្ខុរូបនុ៎ះ ៗ រៀនធម៌ក្នុងសំណាក់លោកម្ចាស់របស់យើង" ទើបធ្វើសក្ការៈ ។

**សូម្បីអ្នកត្រេកអរដោយពួកគណៈ** ក្នុងថ្ងៃដែលមានបុណ្យធ្លងធំ ៗ ញុំាងបុគ្គលឱ្យកាន់យកតាំង គឺទីអង្គុយវែង និងបង្អែកភ្ជាក់ដៃ; រមែងអង្គុយសម្រាកនៅក្នុងទីសម្រាកវេលាថ្ងៃត្រង់គល់ឈើទីបំផុតខេត្តដែននៃវិហារ; មនុស្សទាំង-ឡាយមកហើយ សួរថា "ព្រះថេរៈនិមន្តទៅណា ?" ; ឈ្មោះថា បុត្ររបស់គណ្ឋិកៈអ្នកពោលពាក្យដែលស្រពេចស្រពិលនោះឯងមាន ពោលដោយហេតុនោះឯងថា "ព្រះថេរៈមិនអង្គុយក្នុងកាលបែបនេះ, រមែងនៅក្នុងទីចង្រ្កមដែលមានផ្លូវវែងត្រង់ទីបំផុតនៃវិហារ" ។ សូម្បីភិក្ខុនោះ ក៏ញុំាងកាលឱ្យកន្លងទៅអស់កន្លះថ្ងៃ ហើយញុំាងសរសៃពីងពាងល្អិត១ ឱ្យជាប់ចុះត្រង់មុខ (ថ្ងាស) ហើយឱ្យបុគ្គលកាន់យកតាំងមកអង្គុយត្រង់ទ្វារនៃបរិវេណ ។ មនុស្សទាំងឡាយពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកទៅទីណា, ពួកខ្ញុំមកមិនឃើញលោក" ភិក្ខុនោះរមែង

ញុំាងបុគ្គលឱ្យដឹងនូវភារៈនៃខ្លួន ជាអ្នកពេញចិត្តស្ងប់ ដោយពាក្យថា "ម្នាលឧបាសក ទាំងឡាយ ខាងក្នុងវិហារនេះច្របូកច្របល់ ទីនេះជាទីត្រាច់សញ្ចរ និងឈររបស់ភិក្ខុ កំលោះ និងសាមណេរទាំងឡាយ, អាត្មាអង្គុយនៅទីសម្រាកក្នុងវេលាថ្ងៃ ដែល មានទីចង្ក្រមប្រវែង ៦០ ហត្ថ" ។

**សូម្បីអ្នកខ្ជិលច្រអូស** ក៏អង្គុយត្រង់កណ្តាលនៃឧបដ្ឋាក ពោលថា "ម្នាល ឧបាសកទាំងឡាយ ពួកលោកឃើញឧក្កាបាត (ការធ្លាក់ចុះនៃគប់ភ្លើង) ឬ ?; ត្រូវ ពួកមនុស្សសួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំមិនឃើញ, ឧក្កាបាតមានក្នុង វេលាណា លោកម្ចាស់" ទើបពោលថា "ក្នុងវេលាដើរចង្ក្រមរបស់ពួកយើង" ហើយទើបសួរថា "ពួកអ្នកបានឮសំឡេងកម្រើករបស់ផែនដីឬ" កាលគេពោលថា "ពួកខ្ញុំមិនបានឮទេ; សំឡេងរបស់ផែនដីមានក្នុងវេលាណាលោកម្ចាស់" ក៏ ពោលថា "ក្នុងវេលាមជ្ឈិមយាម គឺក្នុងវេលាដែលពួកយើងឈរផ្អែកបន្ទះក្តារ កំណត់អារម្មណ៍ ក៏មានពន្លឺធំបានកើតឡើង" , ហើយសួរថា "ឱភាសពន្លឺធំ នោះ ពួកអ្នកឃើញហើយឬ ?" កាលមនុស្សសួរថា "ពន្លឺឱភាសធំបានមានក្នុង វេលាណា លោកម្ចាស់ ?" ។ ទើបពោលថា "ក្នុងវេលាជាទីចុះអំពីការចង្ក្រម របស់អាត្មា" ។ មនុស្សទាំងឡាយជ្រះថ្លាថា "ព្រះថេរៈរបស់យើងទាំងឡាយ រមែងចង្ក្រមរហូតយាមទាំង ៣ មែនពិត, ភិក្ខុអ្នកប្រារព្ធសេចក្តីព្យាយាម ដូច លោកម្ចាស់របស់ពួកយើងមិនមានទេ" ទើបធ្វើសក្ការៈ ។

**សូម្បីអ្នកភ្លេចភ្លាំងសតិ** ក៏អង្គុយក្នុងកណ្តាលនៃឧបដ្ឋាក រមែងពោល ថា "យើងរៀនព្រះសូត្រទីឃនិកាយ ក្នុងកាលឈ្មោះឯណោះ, រៀនមជ្ឈិមនិកាយ

ក្នុងកាលឯណោះ, សំយុត្តនិកាយ និងអង្គុត្តរនិកាយក្នុងវេលាឯណោះ; ឈ្មោះថា ការក្រឡេកមើលយ៉ាងដទៃក្នុងចន្លោះ រមែងមិនមាន, បែបផែនដូចជាកើតឡើង ក្នុងមាត់របស់យើង នឹងមកក្នុងទីដែលខ្លួនប្រាថ្នាហើយៗ, ចំណែកភិក្ខុដទៃ ញ៉ាំង មាត់ឱ្យទៅមក (ដើម្បីសួរបញ្ហា) ហាក់ដូចជាពពែ" ។ មនុស្សទាំងឡាយជ្រះថ្លា ហើយ ដោយគិតថា "បុគ្គលដទៃនឹងបដិបត្តិដូចព្រះគុណម្ចាស់របស់យើងមិនមាន" ហើយធ្វើសក្ការៈ ។

**សូម្បីអ្នកមានចិត្តមិនតាំងមាំ** រមែងសួរបញ្ហានឹងអដ្ឋកថាចារ្យ (ជាដើម) ត្រង់ទីចំពោះមុខនៃឧបដ្ឋាកទាំងឡាយ, គឺរមែងសួរថា "ឈ្មោះថា កសិណរមែង ចម្រើនយ៉ាងណា ?, ឈ្មោះថា និមិត្តដែលកើតឡើងមានប្រមាណប៉ុនណា ?, ឧបចារៈ រមែងមានប្រមាណប៉ុនណា ?, អប្បនារមែងមានប្រមាណប៉ុនណា ?, អង្គរបស់បឋមជ្ឈាន មានប្រមាណប៉ុនណា ?, អង្គរបស់ទុតិយជ្ឈាន, តតិយជ្ឈាន និងចតុត្ថជ្ឈាន មានប្រមាណប៉ុនណា ?" ; កាលព្រះអដ្ឋកថាចារ្យពោលថា "ម្នាល អាវុសោ ប្រយោជន៍អ្វីដោយពាក្យប៉ុណ្ណេះ ពាក្យអ្វីៗ យ៉ាងនេះ មិនមានឬ ? និង ធ្វើការញញឹមក្នុងវេលា ដែលពោលពាក្យសំដី គួរដល់ការសិក្សារបស់ខ្លួន" ។ ទើបសម្តែងការបានសមាបត្តិរបស់ខ្លួន ដោយពាក្យថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សេចក្តីនេះត្រឹមត្រូវហើយ" ; មនុស្សទាំងឡាយជ្រះថ្លា ដោយគិតថា "លោកម្ចាស់ បានសមាបត្តិ" ទើបធ្វើសក្ការៈ ។

**សូម្បីអ្នកមានបញ្ញាខ្សោយ** ក៏នឹងអង្គុយក្នុងកណ្តាលនៃឧបដ្ឋាកទាំង ឡាយពោលថា "យើងរមែងលះបង់បរិយត្តិ" ជាដើម ដោយពាក្យថា "កាលយើង

ត្រួតមើលប្រភេទនៃធម៌ ៣ ដែលញ៉ាំងសត្វឱ្យឃើតឃូរក្នុងមជ្ឈិមនិកាយ មគ្គនោះឯង មកព្រមហើយដោយឫទ្ធិ, ឈ្មោះថា បរិយត្តិ មិនជាវត្ថុដែលធ្វើបានដោយលំបាក សម្រាប់ពួកយើង, ក៏ការរីករាយក្នុងបរិយត្តិ រមែងមិនផុតអំពីទុក្ខ” រមែងសម្តែងនូវសភាពនៃខ្លួនជាមនុស្សមានបញ្ញាច្រើន, ក៏កាលភិក្ខុនោះពោលយ៉ាងនេះ ឈ្មោះថា **រមែងទម្លាយព្រះសាសនា** ។ ឈ្មោះថា **មហាចោរដូចបុគ្គលនេះ** រមែងមិនមាន; ព្រោះថា បុគ្គលអ្នកទ្រទ្រង់ព្រះបរិយត្តិ ឈ្មោះថា មិនផុតអំពីទុក្ខ រមែងមិនមាន ។

**សូម្បីអ្នកនៅមិនទាន់អស់អាសវៈ** ឃើញទារកក្នុងស្រុក ហើយសួរថា “មាតា និងបិតារបស់ពួកអ្នកពោលថា ‘ យើងជាអ្វី” ។ ពួកទារកពោលថា “មាតា និងបិតារបស់ខ្ញុំ ពោលថា ‘ លោកជាព្រះអរហន្ត លោកម្ចាស់” ។ ភិក្ខុនោះ រមែងសម្តែងនូវភាវៈនៃខ្លួនជាអ្នកមានអាសវៈអស់ហើយ ដោយពាក្យថា “ម្នាលគហបតី អ្នកឈ្លាស នរណា១ មិនអាចដើម្បីនឹងបោកលោកបាន” ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបនូវភិក្ខុ សូម្បីដទៃទៀត ដែលសម្តែងខ្លួនជាព្រះអរហន្ត មាន**អរហន្តពាងទឹក និងអរហន្តពួរជ្រៃ** ជាដើម ៖

## **រឿងចាដិអរហន្ត** (អរហន្តពាងទឹក)

បានឮថា ភិក្ខុកុហក (អ្នកបោកបញ្ឆោត) មួយរូប គ្របពាងទឹកធំទុកខាងក្នុងបន្ទប់របស់ខ្លួន ចូលទៅក្នុងពាងក្នុងវេលាដែលពួកមនុស្សគេមករក; ទើបមនុស្សទាំងឡាយសួរថា “ព្រះថេរៈទៅណា ?”។ ក៏កាលភិក្ខុនោះពោលថា “ព្រះ

ថេរៈនៅក្នុងបន្ទប់” ពួកមនុស្សសូម្បីចូលទៅរកមើល កាលមិនឃើញទើបចេញមក ហើយពោលថា “ព្រះថេរៈមិនមាន”; ក៏កាលភិក្ខុនោះពោលថា “ព្រះថេរៈនៅខាងក្នុងបន្ទប់នោះឯង” ទើបពួកមនុស្សចូលទៅទៀត; ព្រះថេរៈនោះចេញអំពីពាងទឹក ហើយមកអង្គុយលើតាំង ។ លំដាប់នោះ កាលមនុស្សទាំងឡាយពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំមិនឃើញលោកកាលចូលមកគ្រាដំបូង ទើបចេញទៅ, លោកទៅនៅទីណា” ភិក្ខុនោះ សម្ដែងនូវភាវៈនៃខ្លួនជាអ្នកមានអាសវៈអស់ហើយ ដោយពាក្យថា “ឈ្មោះថា សមណៈទាំងឡាយ រមែងទៅកាន់ទីដែលខ្លួនប្រាថ្នាហើយៗ” ៕

## រឿងចារោហអរហន្ត (អរហន្តពូរជ្រៃ)

ភិក្ខុកុហក (អ្នកបោក) មួយរូបទៀត អាស្រ័យនៅត្រង់បណ្ណសាលាជិតភ្នំមួយ; ក៏ដើមជ្រៃមួយដើមមាននៅត្រង់មាត់ជ្រោះភ្នំ ខាងក្រោយបណ្ណសាលា, ឫសរបស់ដើមជ្រៃនោះ ទៅប្រាកដនៅត្រង់ផ្ទៃដីមួយចំណែក ។ មនុស្សទាំងឡាយដើរមកតាមផ្លូវហើយ និមន្តភិក្ខុនោះដើម្បីភត្តាហារ ។ ភិក្ខុនោះកាន់បាត្រ និងចីវរ ហើយតោងចុះមកតាមពួររបស់ដើមជ្រៃនោះ ហើយមកប្រាកដខ្លួនជិតទ្វារស្រុក ។ លំដាប់នោះ មនុស្សទាំងឡាយ អ្នកមកដល់ក្រោយសួរថា “លោកម្ចាស់ដ៏ចម្រើននិមន្តមកផ្លូវណា” ភិក្ខុនោះសម្ដែងនូវភាវៈនៃខ្លួនជាអ្នកមានអាសវៈអស់ហើយ ដោយពាក្យថា “ឈ្មោះថា ផ្លូវដែលសមណៈទាំងឡាយមកហើយ មិនសមគួរសួរ, សមណៈទាំងឡាយ រមែងមកកាន់ទីដែលខ្លួនប្រាថ្នាហើយៗ” ។ បុរសម្នាក់ស្ដាប់

រហូតដល់ថ្ងៃ ជ្រាបហើយគិតថា "យើងនឹងចាំមើលភិក្ខុនេះ" ក្នុងថ្ងៃមួយ គេឃើញទីដែលភិក្ខុនោះទៅដូច្នោះ ក្នុងថ្ងៃមួយ គេឃើញទីដែលភិក្ខុនោះ ឈានចុះតាមពួរជ្រៃ ទើបកាត់ពួរជ្រៃនោះខាងក្រោយ ទុកឱ្យសល់បន្តិច ។ ភិក្ខុអ្នកឆបោកនោះគិតថា "យើងនឹងចាប់ពួរជ្រៃឈានចុះទៅ ទើបចាប់ពួរជ្រៃនោះ លំដាប់នោះធ្លាក់ចុះទៅដីតែម្តង ក៏មានរបួសជាំ លោកជ្រាបថា នរណា១ ជ្រាបរឿងរបស់ខ្លួនហើយ ទើបគេចចេញទៅដូច្នេះ ។

ភាវៈនៃបុគ្គលអ្នកប្រាថ្នាលាមក ឈ្មោះថា សភាពលាមក ក៏កាលពោលដោយលក្ខណៈហើយ បណ្ឌិតគប្បីជ្រាបថា "ភាវៈនៃបុគ្គលនោះ ញុំាងបុគ្គលដទៃឱ្យសរសើរសេចក្ដីល្អដែលមិនមាន និងភាវៈនៃខ្លួនជាអ្នកមិនស្គាល់ប្រមាណក្នុងការទទួល, សេចក្ដីនេះ ជាលក្ខណៈរបស់បុគ្គលអ្នកមានសេចក្ដីប្រាថ្នាលាមក" ៕

## សិង្គនិទ្ទេស អធិប្បាយការនិយាយចាក់ដោត

ឈ្មោះថា **សិង្គៈ** ព្រោះអត្ថថា ជាពាក្យចាក់ដោត ។ ពាក្យចាក់ដោតនេះជាឈ្មោះរបស់ការចាក់ដោត ព្រោះកិលេស ពោលគឺសភាពនៃវាចាជាពាក្យចាក់ដោតរបស់អ្នកក្រុង ។ ភាវៈនៃវាចាជាពាក្យចាក់ដោត ឈ្មោះថា សភាពនៃវាចាចាក់ដោត; ម្យ៉ាងទៀត អាការជាពាក្យនិយាយចាក់ដោត ក៏ឈ្មោះថា សភាពដែលនិយាយចាក់ដោត ។ ភាវៈនៃបុគ្គលអ្នកនិយាយបួនជ្រុង ឈ្មោះថា **ការនិយាយបួនជ្រុង** ។ ការនិយាយ **ជ្រៀលជ្រៅ** ក៏យ៉ាងនោះដែរ ។ ភាវៈនៃបុគ្គលអ្នកនិយាយជាជ្រុងជាគូ ឈ្មោះថា ពាក្យដែលនិយាយ **មានជ្រុងមានគូ**, ពាក្យនេះ

ជាឈ្មោះរបស់ភាវៈនៃបុគ្គលអ្នកជំនាញការនិយាយចាក់ដោត ដែលត្រៀមទុកមុននោះឯង (ដូចជីកអន្លង់បញ្ឆោតត្រី); ពាក្យក្រៅពីនេះ ជាវេវចនៈរបស់ពាក្យនិយាយចាក់ដោតទាំងអស់ ។ ការនិយាយចាក់ដោតដោយអំណាចនៃកិលេស លោកពោលទុកដោយបទ សូម្បីទាំងអស់ មានអាការយ៉ាងនេះ ៕

## តិន្តិណនិទ្ទេស អធិប្បាយការនិយាយរារាំង

ពាក្យថា **តិន្តិណំ** បានដល់ ការនិយាយតិះដៀល ឬនិយាយរារាំង ។ អាការនៃការប្រព្រឹត្តរារាំង ហៅថា **ការនិយាយរារាំង** ។ ភាវៈនៃបុគ្គលអ្នកច្រើនដោយការរារាំង របស់អ្នកនិយាយដោយការរារាំង ឈ្មោះថា **សភាពដែលរារាំង** ។ ភាវៈនៃអ្នកល្មោភ ឈ្មោះថា **សភាពដែលល្មោភ**; ពាក្យក្រៅអំពីនេះ ជាពាក្យអធិប្បាយសេចក្តីនៃកិរិយាអាការរបស់ពាក្យនិយាយរារាំង ។ ពាក្យថា **"មុច្ឆញ្ចិ-កតា"** បានដល់ ភាវៈនៃចិត្តញាប់ញ័រ ព្រោះការសោយអារម្មណ៍ក្នុងឋាននៃប្រយោជន៍ដែលគួរបាន ឬមិនគួរបាន លោកហៅថា ប្រព្រឹត្តបន្ទាបខ្លួន ។ ពាក្យថា **សាធុកម្យតា** បានដល់ ប្រាថ្នានឹងបាននូវវត្ថុដែលប្រណីតក្រៃលែងឡើងទៅ ។ លោកពោលអាការរារាំងទុក ដោយអំណាចនៃកិលេសដោយបទទាំងពួង ដោយសំដៅយកថា វត្ថុរបស់អ្នកដទៃ ដូចជារបស់ខ្លួន ដូចការព្រុសរបស់សុនខដែលកំពុងផឹកទឹកបាយត្រង់ស្នូកទឹកបាយ ព្រោះឃើញសុនខដទៃមក ៕

## ចាបល្យនិទ្ទេស អធិប្បាយការពេញចិត្តតុបតែង

ការតុបតែងចីវរ ដោយវត្ថុទាំងពួង មានការធ្វើឱ្យរៀបរយជាត្របកផ្កាឈើ ស្រទាប់ឈើជាដើម ឈ្មោះថា **ការតុបតែងចីវរ** ។ ការតុបតែងបាត្រ ដោយវត្ថុទាំងឡាយ មានការធ្វើឱ្យមានសម្បុរម៉ដ្ឋ ដូចពណ៌នៃកែវមណី ឈ្មោះថា **ការតុបតែងបាត្រ** ។ ការតុបតែងសេនាសនៈ ដែលជារបស់បុគ្គលដោយចិត្រកម្មជាដើម ឈ្មោះថា **ការតុបតែងសេនាសនៈ** ។

ពាក្យថា **"ឥមស្ស វា បូតិកាយស្ស** = ការតុបតែងកាយដែលស្អុយ" បានដល់ ការតុបតែងកាយរបស់មនុស្សនេះ; ដូចយ៉ាងថា សុនខព្រៃសូម្បីកើតក្នុងថ្ងៃនោះ សូម្បីឆ្អឹងជើងនៅទន់ក៏ដោយ គេក៏ហៅថា ចចកចាស់នោះឯង និងដើមវល្លិដែលជាថ្នាំមានដើមវល្លិផោម រមែងដល់ការរាប់ថាវល្លិស្អុយនោះឯង យ៉ាងណា, កាយមនុស្ស សូម្បីមានពណ៌ដូចមាស ព្រះមានព្រះភាគត្រាស់ហៅថា កាយស្អុយនោះឯង; ដោយគ្រឿងអាភរណៈ គ្រឿងស្លៀកដណ្តប់ មានចីវរជាដើម ដែលមានពណ៌ក្រហម ពណ៌លឿងជាដើម ឈ្មោះថា **ការតុបតែង** ។ ពាក្យថា **"ពាហិរានំ វា បរិក្ខារំ** = ការតុបតែងបរិក្ខារខាងក្រៅ" បានដល់ ការតុបតែងបរិក្ខារដ៏សេសក្រៅអំពីបាត្រ និងចីវរ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងទីនោះយ៉ាងនេះថា ការតុបតែងចីវរ ការតុបតែងបាត្រនេះ យ៉ាងណា, ការតុបតែងកាយបរិក្ខារទាំងនោះ ឬថា ការតុបតែងបរិក្ខារខាងក្រៅអំពីកាយ ហៅថា ការតុបតែងដោយអំណាចនៃឈ្មោះ តាមដែលតាំងទុកសម្រាប់ហៅ ។

ក្នុងពាក្យថា **“មណ្ឌនា វិភូសនា”** នេះ គប្បីជ្រាបថា ឈ្មោះថា **មណ្ឌនា** (ការតុបតែងកាយ) ដោយអំណាចនៃការបន្ថែមនូវកន្លែងដែលខ្វះឱ្យពេញ, ឈ្មោះថា **វិភូសនា** (ការប្រដាប់) ដោយអំណាចនៃការដុសខាត់ស្បែកជាដើម ។ ពាក្យថា **“កេឡនា”** បានដល់ ការលេងដែលរីករាយ ។ ពាក្យថា **“បរិកេឡនា”** បានដល់ ការរីករាយ; ភាវៈនៃចិត្តដែលញាប់ញ័រ ឈ្មោះថា សភាពដែលញាប់ញ័រអឹមអៀន ។ ភាវៈនៃបុគ្គលដែលជាប់ស្អិត ឈ្មោះថា **សភាពដែលជាប់ស្អិត**; ពាក្យថា ភាវៈនៃចិត្តដែលជាប់ស្អិតនេះ ជាវេវចនៈនៃពាក្យថា **គិទ្ធិគតា** នោះ; ភាវៈនៃការពេញចិត្តតុបតែង ឈ្មោះថា **ចបលតា**; ភាវៈនៃបុគ្គលអ្នកពេញចិត្តតុបតែង ក៏យ៉ាងនោះដែរ ។ ពាក្យថា **“ឥទំ វុច្ចតិ”** នេះ ព្រះមានព្រះភាគត្រាស់ហៅថា ជាអ្នកញញើតអឹមអៀន ព្រោះពេញចិត្តតុបតែង ។ បុគ្គលណាប្រកបដោយការតុបតែង បុគ្គលនោះ សូម្បីមានអាយុទាំងរយឆ្នាំ ក៏ដូចជាទារកកើតក្នុងថ្ងៃនោះដែរ ៕

## អសភាគវុត្តិនិទ្ទេស អធិប្បាយការប្រព្រឹត្តមិនសមគួរ

ការមិនប្រព្រឹត្តធ្វើតាមព្រះពុទ្ធវចនៈ ឈ្មោះថា **ប្រព្រឹត្តមិនសមគួរ** ។ ផ្លូវនៃសេចក្ដីសុខដោយការធ្វើឱ្យទាស់ទែង ដែលជាសត្រូវផ្សេងៗ ឈ្មោះថា ប្រព្រឹត្តបំពាន ។ ភាវៈនៃបុគ្គលអ្នកមិនអើពើ ឈ្មោះថា **សភាពដែលមិនអើពើ**; **កិរិយាដែលមិនអើពើ** ក៏ដូចគ្នា ។ ភាវៈនៃបុគ្គលអ្នកមិនមានគារវៈ ឈ្មោះថា **សេចក្ដីមិនគោរព** ។ ការមិនធ្វើតាមពាក្យរបស់អ្នកចម្រើន (ប្រធាន) ឈ្មោះថា **សេចក្ដីមិនជឿតាម** ។ ពាក្យថា **“អយំ វុច្ចតិ”** សេចក្ដីថា បុគ្គលនេះ ព្រះមានព្រះភាគ

ត្រាស់ហៅថា អ្នកប្រព្រឹត្តមិនសមគួរ, អធិប្បាយថា “ជាអ្នកមានជីវិតដែលមិនសមគួរ” ។ បុគ្គលអ្នកប្រកបដោយភាពជាអ្នកមានជីវិតដែលមិនសមគួរ រមែងមិនបដិបត្តិរក្សាចិញ្ចឹមមាតា ឬបិតាដែលឈឺ រមែងធ្វើការឈ្លោះនឹងបិតាមាតាព្រោះទ្រព្យសម្បត្តិ, ឈ្លោះនឹងបងប្អូនប្រុស បងប្អូនស្រី ព្រោះហេតុនៃទ្រព្យរបស់មាតាបិតា, រមែងពោលវាចាឥតអៀនខ្មាស មិនធ្វើវត្ត និងវត្តដែលអាស្រ័យអាចារ្យ និងឧបជ្ឈាយ៍, មិនឧបដ្ឋាកភិក្ខុអាពាធ, បន្ទោឧច្ចារៈ និងបស្សាវៈ ក្នុងស្ថានទីដែលជាទីគោរពនៃព្រះចេតិយ របស់ព្រះមានព្រះភាគជាម្ចាស់, ស្តោះទឹកមាត់ខ្លះ, ទឹកសំបោរខ្លះ, បាំងឆត្រខ្លះ, ដើរពាក់ស្បែកជើងចូលទៅខ្លះ, មិនអៀនខ្មាស់ក្នុងសាវ័ករបស់ព្រះពុទ្ធជាម្ចាស់, មិនគោរពកោតក្រែងក្នុងសង្ឃ, មិនញុំាងហិរិ និងឳត្តប្បៈឱ្យតាំងឡើងក្នុងបុគ្គលដែលគួរគោរពទាំងឡាយ មានមាតា និងបិតាជាដើម ។ ការធ្វើយ៉ាងនេះ សូម្បីទាំងអស់ ក្នុងវត្ថុទាំងឡាយ និងក្នុងបុគ្គល មានមាតាជាដើម របស់អ្នកប្រព្រឹត្តយ៉ាងនេះ ឈ្មោះថា **ប្រព្រឹត្តមិនសមគួរ** ៕

## អរតិនិទ្ទេស អធិប្បាយការមិនត្រេកអរ

ពាក្យថា **បន្តេសុ** = ក្នុងសេនាសនៈដែលស្ងាត់, ម្យ៉ាងទៀត បានដល់សេនាសនៈស្ងាត់ ដែលនៅក្នុងទីឆ្ងាយ; ពាក្យថា **អធិកុសលេសុ** បានដល់ សមថៈ និងវិបស្សនា ។ ពាក្យថា “**អរតិ**” ជាពាក្យបដិសេធសេចក្តីត្រេកអរ ។ អាការនៃសេចក្តីមិនត្រេកអរ ឈ្មោះថា កិរិយាដែលមិនត្រេកអរ ។ ភាពជាអ្នកមិនត្រេកអរក្រៃលែង ឈ្មោះថា *សភាពដែលមិនត្រេកអរក្រៃលែង*; អាការនៃសេចក្តីមិន

ត្រេកអរក្រៃលែង ឈ្មោះថា **កិរិយាដែលមិនត្រេកអរក្រៃលែង**; អាការនៃបុគ្គលអ្នកក្រវល់ក្រវាយ ឈ្មោះថា **សេចក្តីក្រវល់ក្រវាយចិត្ត** ។ ពាក្យថា **“បរិតស្សិតា”** បានដល់ ភាពជាអ្នកតក់ស្លុតដោយអំណាចនៃភាវៈជាអ្នកក្រវល់ក្រវាយចិត្តនុ៎ះឯង ឈ្មោះថា **បរិតស្សិតា** ៕

## តន្ទីនិទ្ទេស អធិប្បាយការងោកងុយ

ការខ្ជិលច្រអូស ១ ប្រភេទ ឈ្មោះថា **តន្ទី** (គឺការងងុយដេក ឬការប្រមាទ) ។ អាការនៃអ្នកងោកងុយ ឈ្មោះថា **កិរិយាដែលងោកងុយ** ។ ពាក្យថា **“តន្ទិមនកតា”** បានដល់ ភាពជាអ្នកមានចិត្តដែលសេចក្តីខ្ជិលគ្របសង្កត់ហើយ ។ ភាវៈនៃបុគ្គលអ្នកខ្ជិលច្រអូស ឈ្មោះថា **សភាពដែលមានចិត្តងោកងុយ** ។ អាការនៃបុគ្គលអ្នកខ្ជិលច្រអូស ឈ្មោះថា **កិរិយានៃសេចក្តីងោកងុយ** ។ ភាវៈនៃបុគ្គលអ្នកខ្ជិលច្រអូសផ្លូវកាយ ដោយអំណាចនៃកិលេស ព្រះមានព្រះភាគត្រាស់ទុកដោយបទទាំងនេះ សូម្បីទាំងអស់ដូច្នេះឯង ៕

## វិជម្ភិតានិទ្ទេស អធិប្បាយការពត់កាយ

ការឱ្យកាយកម្រើកទៅ ឈ្មោះថា **ការពត់កាយ** ។ ការពត់កាយញយៗ ហៅថា **ការសណ្ដូកកាយ** ។ ពាក្យថា **“អានមនា** = ការទន់កាយ” បានដល់ ការទន់កាយទៅខាងមុខ ។ ពាក្យថា **“វិនមនា** = ការទន់កាយទៅខាងក្រោយ” បានដល់ ការអ៊ែនកាយមកខាងក្រោយ ។ ពាក្យថា **“សន្នមនា”** បានដល់ ទន់

កាយទៅជុំវិញៗ ។

ក្នុងពាក្យថា **“ការតាំងកាយឱ្យត្រង់”** នេះ ដូចយ៉ាងថា ជាងកឹតម្បាញ យកចិត្តទុកដាក់ចាប់កាន់នូវអ្វីៗ នោះឯង ពីសរសៃអំបោះ ហើយក៏តាំងកាយឱ្យត្រង់ យ៉ាងណា, ការលើកកាយឡើងខាងលើ ក៏ដូច្នោះដែរ ។ ពាក្យថា **“ព្យាធិយកំ** = សេចក្តីមិនសប្បាយកាយ” បានដល់ សភាពដែលបុគ្គលនោះមានព្យាធិកើតឡើងហើយ ។ ការពត់កាយនោះឯង ដោយអំណាចនៃកិលេស ព្រះមានព្រះភាគត្រាស់ទុកក្នុងបទ សូម្បីទាំងអស់នោះ ដោយប្រការដូច្នេះ ៕

## ភត្តសម្មទនិទ្ទេស អធិប្បាយការស្រវឹងអាហារ

ពាក្យថា **“ភុត្តាវិស្ស”** បានដល់ របស់អ្នកបរិភោគអាហារ ។ ការមិនសប្បាយជាប់ចិត្តក្នុងអាហារ ឈ្មោះថា សេចក្តីលំបាកចិត្តព្រោះអាហារ ។ ពិតមែន បុគ្គលហាក់ដូចជាដល់នូវសេចក្តីងងុយងោកងក់ ព្រោះអាហារមានកម្លាំងច្រើន ។ សេចក្តីលំបាកព្រោះអាហារ ឈ្មោះថា **ភាពជាអ្នកក្រវល់ក្រវាយព្រោះអាហារ** ។ ការក្រវល់ក្រវាយព្រោះអាហារ ឈ្មោះថា **សេចក្តីក្តៅក្រហាយ ព្រោះអាហារ** ។ ពិតមែន ក្នុងសម័យនេះ បុគ្គលនោះជាអ្នកឈ្មោះថា មានឥន្ទ្រិយដែល អាហារកម្ចាត់ហើយ ដោយឱ្យសេចក្តីក្តៅក្រហាយកើតឡើង, គឺរមែងធ្វើឱ្យរាង កាយទ្រុឌទ្រោម ។ ពាក្យថា **“កាយទុដ្ឋុល្លំ** = ភាពជាអ្នកធ្ងន់សាច់ ធ្ងន់ខ្លួន ព្រោះអាហារ” បានដល់ ភាពជាអ្នកមានកាយដែលមិនគួរដល់ការងារ (គឺមិនរហ័ស) ព្រោះអាហារ ។

និទ្ទេសនៃការរួញរាចិត្ត មានសេចក្ដីដូចពោលហើយ ក្នុងអដ្ឋកថានៃធម្ម-សង្គហៈ ក្នុងពេលមុននោះឯង; នឹងគប្បីជ្រាបអាការនៃចិត្តឈឺ ដោយអំណាចនៃកិលេសដែលព្រះមានព្រះភាគត្រាស់ទុកហើយ សូម្បីដោយបទទាំងអស់នេះ ៕

## កុហននិទ្ទេស អធិប្បាយការបោកបញ្ឆោត

ពាក្យថា **“លាភសក្ការសិលោកសន្និស្សិតស្ស** = សភាពដែលបោក-បញ្ឆោតរបស់ភិក្ខុអ្នកស្វែងរកលាភសក្ការៈ និងកេរ្ដិ៍ឈ្មោះបោះសំឡេង” អធិប្បាយថា ភិក្ខុដែលបោកបញ្ឆោតនោះ ត្រូវការលាភសក្ការៈ និងការសរសើរ ទើបប្រាថ្នាដូច្នោះ ។

ពាក្យថា **“បាបិច្ឆស្ស** = អ្នកប្រាថ្នាលាមក” បានដល់ ភិក្ខុប្រាថ្នាសម្ដែងសេចក្ដីល្អដែលខ្លួនមិនមាន ។ ពាក្យថា **“ឥច្ឆាបកតស្ស** = ត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ” អធិប្បាយថា ភិក្ខុនោះត្រូវសេចក្ដីប្រាថ្នាដែលមិនមែនធម្មតាធ្វើឱ្យក្ដៅក្រហាយហើយ ។ ខាងមុខអំពីនេះទៅ គប្បីជ្រាបកុហនវត្ថុ (រឿងការបោកបញ្ឆោត) ៣ យ៉ាង ដែលមកក្នុង **មហានិទ្ទេស** ដោយអំណាចនៃភិក្ខុអ្នកបោកបញ្ឆោត មានការតាំងចិត្តសេពបច្ច័យ ១ បោកបញ្ឆោតដោយការនិយាយខ្សឹប ១ និងការបោកបញ្ឆោត ដោយអាស្រ័យនូវឥរិយាបថ ១, ព្រោះហេតុដូច្នោះ ដើម្បីសម្ដែងការបោកបញ្ឆោត សូម្បីទាំង ៣ នោះ ទើបព្រះមានព្រះភាគផ្ដើមពាក្យថា **“បច្ចយបដិសេវនសង្ខាតេន វា** = ដោយការសេពបច្ច័យ” ជាដើម ។ ក្នុងនោះគប្បីជ្រាបរឿងការបោកបញ្ឆោត (កុហនវត្ថុ) ពោលអំពីការសេពបច្ច័យ ធ្វើឧបាយ

ជាហេតុឱ្យទាយកបង្អោនបច្ច័យ សូម្បីទាំងរទេះគោ ចាប់ផ្តើមអំពីការបដិសេធ ព្រោះអាស្រ័យការប្រាថ្នាលាមក របស់ភិក្ខុដែលសេចក្តីប្រាថ្នាគ្របសង្កត់ហើយ អ្នកដែលទាយកនិមន្តដោយចីវរជាដើម កាលទាយកនោះបង្អោនថ្វាយចីវរជាដើម ដែលប្រណីត ដោយចីវរផ្សេងៗ ថា "ឱហ្ន៎ ! លោកម្ចាស់ មានសេចក្តីប្រាថ្នាតិច, មិនត្រូវការនឹងទទួលអ្វីៗ, ក៏បើលោកគប្បីទទួលអ្វីៗ សូម្បីត្រឹមតែបន្តិច នោះជាការដែលពួកយើងបានល្អហើយហ្ន៎" , ព្រោះលោកដឹងថា ពួកគហបតីទាំងនោះ ជាអ្នកមានសទ្ធាតាំងនៅល្អហើយក្នុងខ្លួន ទើបធ្វើឱ្យជាក់ច្បាស់ ដើម្បីប្រាថ្នានឹងអនុគ្រោះគហបតីនោះ ។

សមពិតដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកក្នុង **មហានិទ្ទេស** ថា៖

រឿងការបោកបញ្ឆោត ដោយការសេពបច្ច័យ តើដូចម្តេច ?

ពួកគហបតីក្នុងលោកនេះ និមន្តភិក្ខុដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ, ភិក្ខុនោះ មានសេចក្តីប្រាថ្នាលាមក ដែលការប្រាថ្នាលាមកគ្របសង្កត់ហើយ មានសេចក្តីត្រូវការដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ អាស្រ័យនូវភាពជាអ្នកប្រាថ្នាច្រើន លោករមែងហាមឃាត់ចីវរ, បិណ្ឌបាត, សេនាសនៈ, គិលានប្បច្ច័យភេសជ្ជបរិក្ខារ; រមែងនិយាយយ៉ាងនេះថា "ប្រយោជន៍អ្វីដល់សមណៈ ដោយចីវរនេះដែលមានតម្លៃច្រើន, សមណៈគួររើសយកសំពត់ចាស់អំពីព្រៃ អំពីគំនរសម្រាម ឬអំពីរានផ្សារ ហើយធ្វើសង្ឃាដីប្រើ ដំណើរនោះ ជាការសមគួរ; ប្រយោជន៍អ្វីដល់សមណៈ ដោយបិណ្ឌបាតដែលមានតម្លៃច្រើន, សមណៈគួរសម្រេចការរស់នៅ ដោយដុំបាយដែល

បានមកដោយស្ទុងជើង ដោយប្រព្រឹត្តស្វែងរក ដំណើរនោះ ជាការសមគួរ; ប្រយោជន៍អ្វីដល់សមណៈ ដោយសេនាសនៈដែលមានតម្លៃច្រើន, សមណៈគួរនៅក្រោមដើមឈើក្នុងព្រៃស្មសាន ឬនៅក្នុងទីវាល ដំណើរនេះ ជាការសមគួរ; ប្រយោជន៍អ្វីដល់សមណៈ ដោយគិលានប្បច្ច័យភេសជ្ជបរិក្ខារ មានតម្លៃច្រើន, សមណៈគប្បីធ្វើថ្នាំដោយទឹកមូត្រស្អុយ ឬចំណិតផ្លែសម៉ ដំណើរនេះ ជាការសមគួរ; លោកអាស្រ័យនូវភាពជាអ្នកប្រាថ្នាច្រើននោះ ទើបប្រើប្រាស់នូវចីវរ ដែលសៅហ្មង, ឆាន់បិណ្ឌបាតសៅហ្មង, សេពសេនាសនៈដែលសៅហ្មង និងឆាន់គិលាន-ប្បច្ចយភេសជ្ជបរិក្ខារដែលសៅហ្មង ។ ពួកគហបតីឃើញភិក្ខុនោះហើយ រមែងជ្រាបយ៉ាងនេះថា “សមណៈនេះ មានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកស្ងប់ស្ងាត់ មិនច្រឡូកច្រឡំដោយគណៈ ប្រាថ្នាសេចក្តីព្យាយាម មានវាទៈកម្ចាត់កិលេសដ៏ក្រៃលែង” និមន្តលោក ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារដ៏ប្រណីត; លោកពោលយ៉ាងនេះថា “ព្រោះជួប (ដល់ព្រម) ដោយហេតុ ៣ ប្រការ កុលបុត្រអ្នកមានសទ្ធា មែងប្រសព្វបុណ្យច្រើន ព្រោះដល់ព្រមដោយសទ្ធា, កុលបុត្រអ្នកមានសទ្ធា ក៏ប្រសព្វបុណ្យច្រើន ព្រោះដល់ព្រមដោយទេយ្យធម៌, កុលបុត្រអ្នកមានសទ្ធា រមែងប្រសព្វបុណ្យច្រើន, ព្រោះដល់ព្រមដោយទក្ខិណេយ្យបុគ្គល កុលបុត្រអ្នកមានសទ្ធា រមែងប្រសព្វបុណ្យច្រើន, ពួកលោកអ្នកមានសទ្ធា, មានទេយ្យធម៌, ទាំងអាត្មា ក៏ជាបដិគ្គាហកៈ, បើអាត្មានឹងមិនទទួល, ពួកលោកក៏នឹងថយចុះអំពីបុណ្យទៅ, អាត្មាក៏មិនមានសេចក្តីត្រូវការដោយបច្ច័យនេះទេ តែអាត្មានឹងទទួលដោយការអនុគ្រោះពួកលោក” ; ចាប់ផ្តើម

អំពីនោះ លោកក៏ទទួលចីវរច្រើន; ទទួលសេនាសនៈច្រើន ទទួលគិលានប្បច្ចយ-ភេសជ្ជបរិក្ខារច្រើន; ភាពជាអ្នកមានមុខស្ងួត ការបោកបញ្ឆោត កិរិយាដែលបោកបញ្ឆោត ជាអ្នកបោកបញ្ឆោតមានសភាពដូច្នេះ នេះហៅថា រឿងនៃការបោកបញ្ឆោតដោយការសេពនូវបច្ច័យ ។

ក៏បុគ្គលអ្នកមានសេចក្តីប្រាថ្នាលាមកនោះឯង សូម្បីមាន បណ្ឌិតគប្បីជ្រាបថា ជារឿងបោកបញ្ឆោត ដោយការនិយាយបញ្ចិតបញ្ចៀង ដែលជាឧបាយដោយទំនងនោះៗ ដោយវាចាដែលសម្តែងដល់ការសម្រេចឧត្តរិមនុស្សធម៌ ។ ដូចយ៉ាងដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

រឿងនៃការបោកបញ្ឆោត ដោយការនិយាយបញ្ចិតបញ្ចៀង តើដូចម្តេច ?

ភិក្ខុរូបខ្លះនៅក្នុងធម្មវិន័យនេះ មានសេចក្តីប្រាថ្នាលាមក ដែលសេចក្តីប្រាថ្នាគ្របសង្កត់ហើយ មានសេចក្តីប្រាថ្នាឱ្យគេលើកសរសើរ គិតថា "ប្រជុំជននឹងលើកសរសើរយើង ដោយឧបាយយ៉ាងនេះ" ទើបពោលវាចាអាស្រ័យអរិយធម៌, គឺនិយាយថា "សមណៈណា ទ្រទ្រង់ចីវរយ៉ាងនេះ, សមណៈនោះមានអំណាចច្រើន; សមណៈណា ទ្រទ្រង់បាត្រយ៉ាងនេះ, សមណៈនោះមានអំណាចច្រើន; សមណៈណា ទ្រទ្រង់ភាជនៈលោហៈ, ទ្រទ្រង់ធម្មក្រក, ទ្រទ្រង់សំពត់សម្រាប់ត្រងទឹក, កាន់កូនសោ, ពាក់ស្បែកជើង, ប្រើវត្ថពន្ធចង្កេះ និងប្រើខ្សែយោគបាត្រយ៉ាងនេះ, សមណៈនោះមានអំណាចច្រើន" និយាយថា "សមណៈណាមានឧបជ្ឈាយ៍យ៉ាងនេះ, មានអាចារ្យយ៉ាងនេះ, មានពួករួមឧបជ្ឈាយ៍យ៉ាងនេះ, មានពួករួមអាចារ្យយ៉ាងនេះ, មានមិត្តយ៉ាងនេះ, មានមិត្តដែលធ្លាប់សេពគប់មកយ៉ាងនេះ និងមានមិត្តដែល

ស្និទ្ធស្នាលមកហើយយ៉ាងនេះ, មានសហាយ (សម្លាញ់) យ៉ាងនេះ, សមណៈនោះ មានអំណាចច្រើន" ; និយាយថា "សមណៈណានៅក្នុងវិហារដូច្នេះ, សមណៈ នោះ មានអំណាចច្រើន; សមណៈណានៅក្នុងផ្ទះមានដំបូល យ៉ាងនេះ, នៅក្នុង ប្រាសាទយ៉ាងនេះ, នៅក្នុងផ្ទះមានដំបូលត្រងិល យ៉ាងនេះ, នៅក្នុងគុហាយ៉ាងនេះ, នៅក្នុងទីពួនយ៉ាងនេះ, នៅក្នុងកុដិយ៉ាងនេះ, នៅក្នុងផ្ទះកំពូលយ៉ាងនេះ, នៅក្នុង បន្ទាយយ៉ាងនេះ, នៅក្នុងរោងមូលយ៉ាងនេះ, នៅក្នុងផ្ទះសំណាក់យ៉ាងនេះ និងនៅ ក្នុងសាលាប្រជុំយ៉ាងនេះ, នៅក្នុងមណ្ឌបយ៉ាងនេះ និងនៅក្រោមគល់ឈើយ៉ាងនេះ, សមណៈនោះ មានអំណាចច្រើន" ។

ម្យ៉ាងទៀត ភិក្ខុជាអ្នកដាក់មុខនៅ (ស្មើ) ធ្វើមុខចងចិញ្ចើមបោកបញ្ឆោត ដែលអ្នកដទៃសរសើរដោយសភាពដែលខ្លួនដាក់មុខថា "សមណៈនេះ បានវិហារ-សមាបត្តិ ដែលមានសភាពដូច្នេះ ភិក្ខុនេះរមែងពោលពាក្យដូច្នោះ ដែលបដិសំយុត្ត ដោយលោកុត្តរធម៌ និងនិព្វាន ដែលអាចឹកកំបាំងសុខុមល្អិត; ការធ្វើមុខចងចិញ្ចើម ភាពជាអ្នកមានមុខស្ងួត ការបោកបញ្ឆោត កិរិយាដែលបោកបញ្ឆោត ភាពជាអ្នក បោកបញ្ឆោត" នេះ ហៅថា រឿងនៃការបោកបញ្ឆោតដែលពោលអំពីការនិយាយ បញ្ចិតបញ្ចៀង ។ ក៏កាលភិក្ខុអ្នកមានសេចក្តីប្រាថ្នាលាមកនោះឯងមាន បណ្ឌិត គប្បីជ្រាបរឿងបោកបញ្ឆោតអាស្រ័យឥរិយាបថ ជាឧបាយដោយឥរិយាបថដែល ខ្លួននឹងធ្វើ ដើម្បីប្រាថ្នាឱ្យអ្នកដទៃសរសើរខ្លួន; ដូចយ៉ាងដែលព្រះមានព្រះភាគ ត្រាស់ទុកថា ៖

រឿងនៃការបោកបញ្ឆោត ដោយឥរិយាបថ តើដូចម្តេច ?

ភិក្ខុរូបខ្លះ ក្នុងធម្មវិន័យនេះ មានសេចក្តីប្រាថ្នាលាមក ដែលសេចក្តីប្រាថ្នាគ្របសង្កត់ហើយ មានសេចក្តីប្រាថ្នាការលើកសរសើរ គិតថា “ប្រជុំជននឹងសរសើរយើង ដោយឧបាយយ៉ាងនេះ” ទើបសង្រួមការឈរ ការអង្គុយ និងការដេក, រមែងតាំងសតិ ហើយដើរ, តាំងសតិឈរ, តាំងសតិអង្គុយ និងតាំងសតិដេក, ទៅហាក់ដូចភិក្ខុមានសមាធិដើរ, មានសមាធិឈរ, មានសមាធិអង្គុយ, មានសមាធិដេក និងធ្វើដូចភិក្ខុដែលចម្រើនអាបាថកជ្ឈាន (អ្នកចម្រើនឈានដែលប្រកបដោយមគ្គវិថិ); ការតាំងចិត្ត ធ្វើឥរិយាបថ ធ្វើមុខចងចិញ្ចើម ភាពជាអ្នកមានមុខស្ងួត ការបោកបញ្ឆោត កិរិយាបោកបញ្ឆោត ភាពជាអ្នកបោកបញ្ឆោត មានសភាពដូច្នេះ នេះហៅថា រឿងបោកបញ្ឆោត ពោលគឺឥរិយាបថ ។

ក្នុងពាក្យទាំងនោះ ពាក្យថា “**ការសេពបច្ច័យ**” ក្នុងពាក្យថា “**បច្ចយ-បដិសេវនសង្ខាតេន**” បានដល់ ដោយការសេពបច្ច័យដែលពោលយ៉ាងនេះ។ ពាក្យថា “**សាមន្តជប្បិតេន**” បានដល់ ដោយការនិយាយក្នុងទីជិត ។ ពាក្យថា “**ឥរិយាបថស្ស**” បានដល់ ឥរិយាបថ ៤; ពាក្យថា “**អដ្ឋបនា**” បានដល់ ការផ្តើមឥរិយាបថ ឬការតាំងឥរិយាបថ, ដោយសេចក្តីអើពើ (តាំងចិត្ត) ។ ពាក្យថា “**ឋបនា**” បានដល់ អាការដែលតាំងឥរិយាបថ ។ ពាក្យថា “**សណ្ឋាបនា**” បានដល់ ការត្រៀមឥរិយាបថ, ព្រះមានព្រះភាគទ្រង់អធិប្បាយពាក្យនេះទុកថា ការធ្វើឱ្យអ្នកដទៃជ្រះថ្លា ។ ពាក្យថា “**ភាកុដិកា**” បានដល់ ការចងចិញ្ចើមដោយអំណាចនៃការសម្តែងភាពជាធំ ឬភាពជាអ្នកធ្លាប់តាំងនៅមុន, ពាក្យនេះត្រាស់អធិប្បាយថា “ជាអ្នកសម្តែងសេចក្តីមិនពេញចិត្ត” ។ ក៏ឈ្មោះថា មុខចងចិញ្ចើម

ព្រោះថា ការចងចិញ្ចើមរបស់អ្នកនោះ មានជាប្រក្រតី ។ ភាវៈនៃបុគ្គលអ្នកមានមុខចងចិញ្ចើម ឈ្មោះថា **សភាពដែលចងចិញ្ចើម**; ពាក្យនិយាយដែលជាឧបាយឱ្យគេជឿ ឈ្មោះថា **ការបញ្ឆោត** ។ វិធិផ្លូវរបស់អ្នកបោកបញ្ឆោត ឈ្មោះថា **ឧបាយជាគ្រឿងបញ្ឆោត**; ភាវៈនៃបុគ្គលអ្នកបោកបញ្ឆោត ឈ្មោះថា **សភាពដែលបោកបញ្ឆោត** ៕

## លបនានិទ្ទេស អធិប្បាយការនិយាយរាក់ទាក់

ការនិយាយតាំងអំពីដើម យ៉ាងនេះថា "ម្នាលអ្នកដ៏ចម្រើន អ្នកទាំងឡាយមកដើម្បីប្រយោជន៍អ្វី ?, ឬដើម្បីនិមន្តភិក្ខុទាំងឡាយ, បើថា លោកមកដោយសេចក្តីប្រាថ្នា យ៉ាងនេះសោត, អាត្មានឹងចាត់ភិក្ខុឱ្យទៅខាងក្រោយ" ព្រោះឃើញពួកមនុស្សមកកាន់វិហារនេះ ឈ្មោះថា **ការនិយាយរាក់ទាក់** ។

ម្យ៉ាងទៀត ការនិយាយបង្អោនមកខ្លួនឯងថា "អាត្មាឈ្មោះ តិស្សៈ, ព្រះរាជាទ្រង់ជ្រះថ្លាក្នុងអាត្មា, មហាមាត្យរបស់ព្រះរាជាឯណោះៗ ក៏ជ្រះថ្លា" ព្រោះការនិយាយបង្អោនមកខ្លួនយ៉ាងនេះ ក៏ឈ្មោះថា **ការនិយាយរាក់ទាក់** ។ កាលបុគ្គលអ្នកសួរមានការនិយាយឆ្លើយឆ្លង មានប្រការតាមដែលពោលហើយនោះឯង ឈ្មោះថា **ការនិយាយសន្ទនា** ។ ការនិយាយដោយល្អ ព្រោះឱ្យឱកាសដល់អ្នកភ័យខ្លាចព្រោះការនិយាយមិនរហ័សរហួនរបស់គហបតីទាំងឡាយ ឈ្មោះថា **ការនិយាយលួងលោមចិត្ត** ។ ការនិយាយលើកខ្លួនឱ្យខ្ពស់ យ៉ាងនេះថា "អ្នកជាកុដុម្ពិកៈស្តុកស្តម្ភ ជាមហានាវិក ជាមហាទានបតី" ឈ្មោះថា **ការនិយាយលើកសរ**

**សើរ** ។ ការនិយាយដោយធ្វើឱ្យខ្ពស់ ដោយចំណែកទាំងពួង ឈ្មោះថា **ការនិយាយលើកសរសើរ** ។ ការនិយាយធ្វើឱ្យពេញចិត្តថា "ម្នាលឧបាសកទាំងឡាយក្នុងគ្រាមុន លោករមែងថ្វាយទានក្នុងកាលដូច្នេះ, ឥឡូវនេះ លោកមិនថ្វាយទានឬ" ។ គេឆ្លើយថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំនៅមិនទាន់មានឱកាស" ជាដើម ហើយធ្វើឱ្យក្រៃលែងៗ ឡើងទៅ ឈ្មោះថា **ការនិយាយបញ្ឆិតបញ្ឆៀង** ។ អធិប្បាយថា បានដល់ ការនិយាយបញ្ចុះបញ្ចូល ។

ម្យ៉ាងវិញទៀត ភិក្ខុឃើញបុគ្គលកាន់ទឹកអំពៅមកទើបសួរថា "ម្នាលឧបាសក លោកបានទឹកអំពៅមកអំពីណា ?" ឆ្លើយថា "អំពីចំការ លោកម្ចាស់" ។ ភិក្ខុសួរថា "អំពៅក្នុងចំការនោះ មានរសជាតិផ្អែមទេ ?" ។ ឧបាសកពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកទំពាឆាន់ហើយគប្បីជ្រាបបាន" ភិក្ខុពោលថា "ម្នាលឧបាសក បើអាត្មានិយាយថា 'សូមអ្នកទាំងឡាយ ប្រគេនទឹកអំពៅដល់ភិក្ខុ" ដូច្នេះ រមែងមិនគួរ ការនិយាយលើកសរសើររបស់ភិក្ខុអ្នកអែបអបមានសភាពដូច្នេះ សូម្បីយ៉ាងណា, ការនិយាយបញ្ឆិតបញ្ឆៀងនោះ ឈ្មោះថា **ខន្លហនា**, ការនិយាយបញ្ឆិតបញ្ឆៀងញយៗ ដោយចំណែកទាំងពួង ឈ្មោះថា **ការនិយាយអែបអប** ។ ពាក្យថា **ការនិយាយលើកសរសើរ** បានដល់ វាចាជាគ្រឿងញុំាងចិត្តឱ្យញាប់ញ័រ ដែលលើកឡើងយ៉ាងនេះថា "ត្រកូលនេះរមែងដឹងថាយើងល្អមែនពិត, បើគេនឹងប្រគេនទេយ្យធម៌សោត នឹងប្រគេនដល់យើងប៉ុណ្ណោះ" ឈ្មោះថា ការសរសើរ គឺការលើកសរសើរ ។ ក្នុងសេចក្ដីនោះ គប្បីពោលដល់រឿងឧបដ្ឋាកអ្នកទំនុកបម្រុងភិក្ខុ ដូច្នេះ ៖

បានឮថា ភិក្ខុ ២ រូប ចូលទៅកាន់ស្រុកមួយ អង្គុយត្រង់រោងភត្តាហារ ឃើញកុមារីម្នាក់ ទើបហៅមក ។ លំដាប់នោះ ភិក្ខុមួយរូប ទើបសួរភិក្ខុមួយរូបទៀតថា “លោកម្ចាស់ កុមារីនេះជាកូនអ្នកណា ?” ទើបភិក្ខុនោះលើកសរសើរដោយពាក្យថា “ម្នាលអ្នកមានអាយុ ជាកូនស្រីឧបដ្ឋាកអ្នកទំនុកបម្រុងខ្ញុំករុណា មាតារបស់ក្មេងស្រីនេះ កាលខ្ញុំករុណាទៅផ្ទះហើយ កាលនឹងប្រគេនយទឹកដោះថ្លាវរមែងប្រគេនទាំងអស់តែម្តង, សូម្បីកុមារីនេះ ក៏ប្រគេនទឹកដោះទាំងអស់ដូចមាតានោះដែរ ។

ការនិយាយសរសើរញយៗ ឈ្មោះថា ការនិយាយសរសើរញឹកញាប់ ។ ពាក្យថា **“អនុប្បិយភាណិតា”** បានដល់ ការពោលវាចាដែលជាទីស្រឡាញ់ញយៗ មិនអាស្រ័យសច្ចៈ ឬសមគួរនឹងធម៌ឡើយ ។ ពាក្យថា **“ចាតុកម្យតា”** បានដល់ **ប្រព្រឹត្តតាំងខ្លួនឱ្យទាបទៅ** ។ ពាក្យថា **“មុគ្គសូប្យតា”** បានដល់ វាចាដូចនឹងសម្លសណ្តែកបាយ ។ ដូចយ៉ាងថា កាលសណ្តែកបាយ ដែលបុគ្គលស្ងោរ សណ្តែកបាយខ្លះ មិនឆ្អិន, សណ្តែកបាយដែលនៅសល់ឆ្អិន យ៉ាងណា, ពាក្យថានិយាយសច្ចៈអ្វីៗ ក៏មាន ពាក្យនិយាយដែលមិនឱ្យជឿបានក៏មាន ក្នុងពាក្យសម្តីរបស់បុគ្គលនោះៗ ឯង, បុគ្គលនេះ ព្រះមានព្រះភាគត្រាស់ហៅថា **“អ្នកមានវាចា ដូចសម្លសណ្តែកបាយ”** ។ ភាវៈនៃបុគ្គលអ្នកមានវាចាលេងខ្លះ ពិតខ្លះ ដូចសម្ល សណ្តែកបាយនោះ ឈ្មោះថា សភាពនៃវាចាដូចសម្លសណ្តែកបាយ ។ ភាវៈនៃ បុគ្គលអ្នកពេញចិត្តថៃរក្សាក្មេង ឈ្មោះថា សភាពជាអ្នកថៃរក្សាក្មេង; ពិតមែន បុគ្គលណារក្សាទារកក្នុងត្រកូលដោយចង្កេះ ឬដោយស្មាដូចមេដោះ,

អធិប្បាយថា រមែងរក្សាក្មេងក្នុងត្រកូលដោយឱ្យរស់នៅ ការងាររបស់អ្នករក្សាក្មេង នោះ ឈ្មោះថា ការទទួលរក្សាក្មេង ។ ភារៈនៃបុគ្គលអ្នករក្សាក្មេង ឈ្មោះថា សភាពនៃការទទួលរក្សាក្មេង ៕

## នេមិត្តិកតានិទ្ទេស អធិប្បាយការធ្វើនិមិត្ត

ពាក្យថា **“និមិត្តំ”** បានដល់ កាយកម្ម និងវចីកម្ម ដែលប្រកបព្រមដោយការឱ្យបច្ច័យយ៉ាងណាមួយដល់ពួកជនដទៃ ។ ពាក្យថា **“និមិត្តកម្មំ”** បានដល់ ភាពជាអ្នកឈ្លាសក្នុងការធ្វើនិមិត្ត, ក្នុងសេចក្តីនេះ មានរឿងដូច្នេះ ៖

បានឮថា ភិក្ខុមួយរូបកាន់បិណ្ឌបាតជាវត្តទៅដល់ទ្វារស្រុកនាយជាងមាស ដែលជាឧបដ្ឋាក ។ ជាងមាសក៏សួរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន លោកត្រូវការអ្វី” ទើបលោកយកដៃចេញតាមចន្លោះចីវរ ហើយបានសម្តែងអាការ គឺការនាំកាំបិតទៅ ។ ជាងមាសជ្រាបលក្ខណៈអាការនោះ ហើយពោលថា “លោកម្ចាស់ដ៏ចម្រើន នោះកាំបិតរបស់ខ្ញុំ” ហើយក៏ប្រគេនកាំបិតទៅ ។ ពាក្យថា **“ឱភាសោ”** បានដល់ ពោលពាក្យដែលទាក់ទងដោយបច្ច័យ ។ ពាក្យថា **“ឱភាសកម្មំ”** អធិប្បាយថា ភិក្ខុឃើញបុគ្គលចិញ្ចឹមកូនគោ ទើបសួរថា “កូនគោនោះ ជាកូនគោទឹកដោះស្រស់ ឬជាកូនគោទឹកដោះជូរ កាលក្មេងទាំងនោះពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ជាកូនគោទឹកដោះស្រស់” លោកក៏និយាយដោយន័យដែលមាតាបិតារបស់ក្មេងចិញ្ចឹមគោនោះឱ្យជ្រាប ដែលជាហេតុឱ្យគេប្រគេនទឹកដោះជាដើម ដោយន័យថា “ប្រសិនបើថា គប្បីជាកូនគោ ទឹកដោះស្រស់សោត, សូម្បី

ភិក្ខុទាំងឡាយ ក៏គប្បីបានទឹកដោះស្រស់” ។ ពាក្យថា **“សាមន្តជប្បា”** បានដល់ការខ្សឹប គឺនិយាយជិត ។ ក្នុងសេចក្ដីនេះ បណ្ឌិតគប្បីពោល ដល់រឿងព្រះថេរៈអ្នករៀនជាតក ៖

បានឮថា ព្រះថេរៈអ្នករៀនជាតកមួយរូប ជាអ្នកប្រាថ្នាឆាន់អាហារ ចូលកាន់ផ្ទះឧបដ្ឋាយិកា ហើយអង្គុយ ។ ឧបដ្ឋាយិកានោះ មិនប្រាថ្នាប្រគេនអ្វីៗ ទើបពោលថា “អង្ករមិនមាន” ហើយទៅផ្ទះរបស់មិត្តភក្តិ ហាក់បីដូចជាត្រូវការនាំអង្ករមក ។ ពេលនោះ ភិក្ខុនោះ ក៏ចូលទៅខាងក្នុងបន្ទប់ហើយមើលឃើញដើមអំពៅផ្អែមនោះ នៅត្រង់កៀនទ្វារ, ឃើញទឹកអំពៅក្នុងភាជនៈ, ឃើញត្រីងៀតក្នុងកញ្ច្រែង, ឃើញអង្ករ ក្នុងឆ្នាំងធំ, ឃើញខ្លាញ់ក្នុងឆ្នាំងខ្លាញ់ ហើយអង្គុយ ។

ស្ត្រីមេផ្ទះមកហើយពោលថា “យើងមិនបានអង្ករទេ” ដូច្នេះ ។ ព្រះថេរៈពោលថា “ម្នាលឧបាសិកា ថ្ងៃនេះ ភិក្ខាប្រហែលនឹងមិនមានទេ” ហើយពោលថា “អាត្មាបានឃើញនិមិត្តច្បាស់ណាស់” ។ ស្រីនោះសួរថា “លោកម្ចាស់ ឃើញនិមិត្តដូចម្ដេច ?” ។

ព្រះថេរៈពោលថា “អាត្មាមើលដោយគិតថា ‘យើងនឹងប្រហារពស់ដែលឃើញហើយនោះ ហាក់ដូចជាដើមអំពៅដែលដាក់ទុកត្រង់កន្លៀតទ្វារ, ឃើញដុំថ្ម ហាក់ដូចជាដុំស្ករអំពៅដែលដាក់លើភាជនៈ ឃើញពស់បើកពពារចេញហើយព្រោះត្រូវចោល ដោយដុំដីដូចនឹងត្រីងៀតដាក់ទុកក្នុងកញ្ច្រែង, ឃើញធ្មេញរបស់ពស់នោះ ដេញតាមខាំដុំដីនោះ ដូចអង្ករក្នុងឆ្នាំង, លំដាប់នោះ ឃើញទឹកមាត់ដែលលាយពិស ចេញទៅអំពីមាត់ដែលក្រោធហើយនោះ ដូចនឹងខ្លាញ់ដែលនៅក្នុងឆ្នាំង

ខ្លាញ់” ។ ស្ត្រីមេផ្ទះប្រគេនទឹកអំពៅ ដោយគិតថា “យើងមិនអាចដើម្បីនឹងបោកបញ្ឆោតសមណៈត្រងោលបានទេ” ហើយដាំបាយប្រគេនព្រមគ្នានឹងខ្លាញ់ស្ករអំពៅក្នុងឆ្នាំង និងត្រី ។

បណ្ឌិតគប្បីជ្រាបការនិយាយ ដោយអាការយ៉ាងនេះថា “ជាការនិយាយជិត១” , ពាក្យថា **ការនិយាយព័ទ្ធជុំវិញ** បានដល់ ឡោមព័ទ្ធដោយប្រការដែលខ្លួននឹងបានយ៉ាងនោះឯង ៕

## និទ្ទេសិកតានិទ្ទេស អធិប្បាយការនិយាយតិះដៀល

ពាក្យថា “**ការជេរ**” បានដល់ ការជេរដោយអក្កោសវត្ថុ ១០ ប្រការ ។ ពាក្យថា **ការដាក់បណ្តាសា** បានដល់ ការពោលដាក់ទំនាយ ។ ពាក្យថា “**ការនិន្ទា**” បានដល់ ការនិយាយលើកទោសឡើងដោយន័យថា “គេមិនមានសទ្ធា មិនគួរជ្រះថ្លា” ។ ពាក្យថា “**ការនិយាយលើកទោស**” បានដល់ ការលើកវាចាឡើងថា “លោកកុំពោលវាចាដូច្នេះ ក្នុងទីនេះ” ។ ការនិយាយលើកទោសដែលប្រព្រឹត្តទៅដោយវត្ថុ ប្រព្រឹត្តទៅដោយហេតុ ដោយចំណែកទាំងពួង ហៅថា **ការនិយាយមើលងាយ** ។

ម្យ៉ាងទៀត ការនិយាយលើកទោសឡើងយ៉ាងនេះថា “ឱ ! លោកម្ចាស់ទាន (ទានបតី) ឃើញហើយម្តេចក៏មិនឱ្យអ្វី១” ឈ្មោះថា **តិះដៀល** ។ ការនិយាយដោយល្អ យ៉ាងនេះថា “**លោកទានបតីធំ**” ហៅថា **ការនិយាយមើលងាយ** ។ ពាក្យថា “**ការនិយាយមើលងាយ**” បានដល់ ការនិយាយចំអក

ចំអន់យ៉ាងនេះថា "ជីវិត (ការរស់នៅ) របស់លោកនេះ ស៊ីរុក្ខជាតិជាអាហារ មិនមែនឬ ?" ឈ្មោះថា ការនិយាយចំអកឡកឡាយ ។ រមែងនិយាយឱ្យក្រៃលែងជាងនេះថា "លោកទាំងឡាយ រមែងពោលយ៉ាងនេះថា 'បុគ្គលនេះមិនមែនទាយក' ដូច្នេះជាដើម, បុគ្គលណា រមែងឱ្យវាចាដល់បុគ្គលទាំងពួង រហូតអស់កាលជានិច្ចថា 'មិនមាន' ដូច្នេះ បុគ្គលនោះ ឈ្មោះថា និយាយចំអកចំអន់, ឬមើលងាយឱ្យចេញឈ្មោះសំឡេង ។ ការនិយាយថា "លោកទានបតីមិនឱ្យ" ឬតិះដៀលឱ្យចេញឈ្មោះសំឡេងដោយ អាការទាំងពួង ឈ្មោះថា ការនិយាយឱ្យចេញឈ្មោះសំឡេងយ៉ាងខ្លាំង ។ ការនាំរឿងទៅតិះដៀលអំពីស្រុកនេះ ទៅកាន់ស្រុកនោះអំពីជនបទនេះ ទៅកាន់ជនបទនោះថា "បុគ្គលរមែងប្រសព្វសូម្បីសេចក្ដីខ្លាចអំពីការតិះដៀលរបស់យើង" យ៉ាងនេះ ឈ្មោះថា ការនាំរឿងទៅតិះដៀល ។ ការនិយាយវាចាពីរោះចំពោះមុខ ខាងក្រោយនិយាយនិន្ទា ឈ្មោះថា ការនិយាយពីរោះតែចំពោះមុខ ខាងក្រោយនិយាយនិន្ទា ។ ពិតមែន បុគ្គលអ្នកនិយាយយ៉ាងនេះ កាលមិនអាចមើលចំពោះមុខ រមែងដូចជាការកកេរសាច់ស៊ីក្នុងទីកំបាំងមុខ, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគជាម្ចាស់ ហៅបុគ្គលនេះថា "**និយាយពីរោះចំពោះមុខ ក្រោយខ្នងនិន្ទា**" ។ ពាក្យថា "**អរិយំ ទុច្ចតិ និច្ចេស ភតា**" បានដល់ បុគ្គលនេះ រមែងមិននាំ គឺរមែងមិនពោលគុណរបស់អ្នកដទៃដែលមាននៅខាងក្នុង ហាក់ដូចជាបុគ្គលឈ្លេចឈ្លី គន្ធជាតិ គឺឈ្លេចឈ្លីគុណរបស់អ្នកដទៃឱ្យអស់ទៅ រមែងហាក់ដូចជាការស្វែងរក គន្ធជាតិនោះ វាចាដូច្នេះ ជាវាចាស្វែងរកលាភ, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅថា

“និយាយតិះដៀល (ឧបាយកោង)” ៕

## លាភេន លាភំ និជិគីសនតានិទ្ទេស
## អធិប្បាយការទាក់លាភ ដោយលាភ

ការស្វែងរក (ដោយឧបាយនៃសេចក្តីប៉ុនប៉ង) ឈ្មោះថា ការប្រាថ្នា លាភសក្ការៈ និងឈ្មោះសំឡេង ។ ពាក្យថា **“ឥតោ លទ្ធំ”** បានដល់ លាភ-សក្ការៈ ឈ្មោះសំឡេងដែលខ្លួនបានហើយអំពីស្រុកនេះ ។ ពាក្យថា **“អមុត្រ”** បានដល់ ក្នុងផ្ទះឈ្មោះឯណោះ ។ ពាក្យថា **“ឯដ្ឋិ”** បានដល់ ការប្រាថ្នា ។ ពាក្យថា **“គវេដ្ឋិ”** បានដល់ ការស្វែងរក ។ ពាក្យថា **“មិយេដ្ឋិ”** បានដល់ ការស្វែងរកញយៗ ។ ក៏ក្នុងរឿងនេះ បណ្ឌិតគប្បីជ្រាបរឿងរបស់ភិក្ខុអ្នកឱ្យភិក្ខាដែលខ្លួនបានហើយ ចាប់ផ្តើមអំពីដើម ដល់ទារកក្នុងត្រកូល ក្នុងទីនោះៗ ហើយទើបបានទឹកដោះស្រស់ និងយាគូក្នុងទីបំផុតរួចទៅ ។ ពាក្យថា **“ឯសនា”** ជាដើម ជាពាក្យវេវចនៈរបស់ពាក្យថា **សេចក្តីប្រាថ្នា**ជាដើម ។ ព្រោះហេតុដូច្នោះ ក្នុងទីនេះគប្បីជ្រាបការប្រកបយ៉ាងនេះថា ពាក្យថា **“ឯដ្ឋិ”** បានដល់ កិរិយាដែលស្វែងរក, ពាក្យថា **“គវេដ្ឋិ”** បានដល់ កិរិយាដែលស្វែងរក, ពាក្យថា **“បរិយេដ្ឋិ”** បានដល់ កិរិយាដែលត្រាច់ស្វែងរក ៕

## សេយ្យមាននិទ្ទេស

## អធិប្បាយការសម្គាល់ថាខ្លួនលើសគេ

ពាក្យថា **“ជាតិយា** = ដោយជាតិ” បានដល់ ដល់ព្រមដោយជាតិមានភាពជាក្សត្រិយ៍ជាដើម ។ ពាក្យថា **“គោត្តេន** = ដោយគោត្រ” បានដល់ ដោយគោត្រដែលខ្ពស់បំផុត មានគោតមគោត្រជាដើម ។ ពាក្យថា **“កោលបុត្តិយេន** = ដោយសេចក្តីជាអ្នកមានត្រកូល” បានដល់ ដោយភាវៈជាត្រកូលធំ ។ ពាក្យថា **“វណ្ណបោក្ខរតាយ** = ដោយភាពជាអ្នកមានរូបស្អាត” បានដល់ ដោយភាពជាអ្នកមានសរីរៈដែលដល់ព្រមដោយវណ្ណៈ, ពិតមែន សរីរៈព្រះមានព្រះភាគជាម្ចាស់រមែងត្រាស់ហៅថា បោក្ខរៈ, អធិប្បាយថា ព្រោះភាវៈនៃបុគ្គលនោះជាអ្នកមានរូបស្អាតដោយវណ្ណសម្បត្តិ ។ ពាក្យថា **“ធនេន”** ជាដើម (គឺដោយទ្រព្យ ដោយភាពជាធំ ដោយមុខនាទីការងារ ដោយសិល្បៈ និងដោយវិជ្ជាស្ថានជាដើម) មានសេចក្តីងាយស្រួលទាំងអស់ ។ ក្នុងពាក្យថា **“មានំ ជប្បេតិ** = រមែងដល់ខ្លួន គឺរមែងញ៉ាំងមានះឱ្យកើត” ទាំងនោះ អធិប្បាយថា ក្នុងបណ្តាវត្ថុទាំងនេះ រមែងឱ្យមានះប្រព្រឹត្តទៅថា “យើងលើសគេ គឺរមែងធ្វើដោយវត្ថុយ៉ាងណាមួយ” ៕

## សទិសមាននិទ្ទេស

## អធិប្បាយការសម្គាល់ថា ខ្លួនស្មើគេ

ក្នុងពាក្យថា **“មានំ ជប្បេតិ”** នេះឯង បណ្ឌិតគប្បីជ្រាបថា រមែងឱ្យមានះ (សេចក្តីសម្គាល់ខ្លួន) ថា “យើងជាអ្នកដូចនឹងគេដោយវត្ថុ (ហេតុ) យ៉ាង

ណាមួយ"។ ម្យ៉ាងទៀត ក្នុងនិទ្ទេសនៃសេចក្ដីសម្គាល់ថា **ស្មើគេនេះ** មានសេចក្ដីប្លែកគ្នាដោយអត្ថ តែព្រះបាលីមិនមានការប្លែកផ្សេងគ្នាឡើយ ៕

## ហីនមាននិទ្ទេស

## អធិប្បាយការសម្គាល់ថា ខ្លួនអន់ជាងគេ

ពាក្យថា **"ឱមានំ ជប្បេតិ"** បានដល់ ញុំាងមានះឱ្យប្រព្រឹត្តទៅក្នុងចំណែកទាប ។ មានះដ៏លាមក ដ៏លាមកបំផុត ឈ្មោះថា ឱមានះ ។ ពាក្យថា **"ឱមញ្ញនា ឱមញ្ញិតត្តំ"** បានដល់ ការសម្ដែងសេចក្ដីប្រព្រឹត្តទៅនៃអាការ ។ ពាក្យថា **"ហីឡនា"** បានដល់ ការខ្ពើមខ្លួនឯង (ការរង្កៀសខ្លួនឯង) ដោយឋានៈទាំងឡាយ មានដោយជាតិជាដើម ។ ពាក្យថា **"ឱហីឡនា"** បានដល់ ការខ្ពើមយ៉ាងក្រៃលែង ។ ពាក្យថា **"ឱហីឡិតត្តំ"** បានដល់ ជាការសម្ដែងចេញនូវសេចក្ដីប្រព្រឹត្តទៅរបស់បុគ្គលនោះៗ ឯង ។ ពាក្យថា **"អត្តុញ្ញា"** បានដល់ ការយល់ខ្លួនឯងថា ថោកទាប (មើលងាយខ្លួនឯង) ។ ពាក្យថា **"អត្តាវញ្ញា"** បានដល់ ការមើលងាយខ្លួន ។ ពាក្យថា **"អត្តបរិភវោ"** បានដល់ សេចក្ដីចំអកខ្លួន (ការមើលថាខ្វះខាត)" ដោយសម្គាល់ថា "ពួកយើងទាបជាងគេ ដោយសម្បត្តិមានជាតិជាដើម" ។ មានះទាំង ៣ នេះ ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃវត្ថុមានជាតិជាដើម មិនបានអាស្រ័យបុគ្គល ដូចពណ៌នាមកដូច្នេះ ។

ក្នុងមានះទាំង ៣ នេះ មានះមួយៗ រមែងកើតឡើងដល់បុគ្គលអ្នកមានសេចក្ដីសម្គាល់ថា ខ្លួនល្អជាងគេ ស្មើគេ ទាបជាងគេ សូម្បីទាំង ៣ ។ ក្នុងមានះទាំង

នោះ មានះថា **យើងល្អលើសគេ** ជាមានះពិត១ របស់បុគ្គលអ្នកលើសជាងគេ, ចំណែកមានះដ៏សេសមិនមែន ។ មានះថា **យើងស្មើគេ** ជាមានះពិត១ របស់បុគ្គលអ្នកស្មើនឹងអ្នកដទៃនោះឯង, មានះដ៏សេសមិនមែន ។ មានះថា **យើងជាអ្នកអាក្រក់ជាងគេ** ជាមានះរបស់បុគ្គលអ្នកអាក្រក់នោះឯង, មានះដ៏សេសមិនមែន ។

បណ្តាមានះទាំងនោះ ពាក្យថា "**តត្ថ កតមោ សេយ្យស្សសេយ្យោ-ហមស្មិ** = អ្នកលើសជាងគេ សម្គាល់ថាលើសជាងគេ តើដូចម្តេច ?" ជាដើម ព្រះមានព្រះភាគត្រាស់មានះ ៩ យ៉ាង ដោយអាស្រ័យបុគ្គល ។ ក្នុងមានះទាំងនោះ មានះមានបី ៗ រមែងកើតឡើងដល់បុគ្គលម្នាក់ៗ ។ បណ្តាពាក្យទាំងនោះ ពាក្យថា "**ឧបាតិ** = រមែងប្រកាន់ខ្លួន" បានដល់ រមែងតាំងទុក ។ ពាក្យថា "**តំ និស្សាយ**" បានដល់ អាស្រ័យការប្រកាន់ខ្លួន ដោយភាពជាអ្នកលើសជាងគេនោះ ។

មានះក្នុងខថា "**អ្នកលើសគេ សម្គាល់ថា លើសគេ**" មានះនេះរមែងកើតដល់ព្រះរាជា និងបព្វជិតទាំងឡាយ ។ ពិតមែន ព្រះរាជារមែងធ្វើមានះនេះថា "អ្នកណា១ ស្មើយើង ដោយតំបន់ទឹកដីព្រំដែន ឬដោយទ្រព្យ ឬដោយពាហនៈមានឬ ?" ។ សូម្បីបព្វជិតរមែងធ្វើមានះនេះថា "នរណា១ ដូចជាយើងដោយសីល និងធុតង្គជាដើម មានឬ ?" ។

សូម្បីមានះថា "**អ្នកលើសគេ សម្គាល់ថា ស្មើគេ**" ក៏រមែងកើតឡើងដល់បុគ្គលនោះ១ ឯង ។ ពិតមែន ព្រះរាជារមែងធ្វើមានះនេះថា "អ្វី១ ជាការធ្វើដែលផ្សេងពីយើង ដោយព្រះរាជាដទៃ ដោយខេត្តខណ្ឌ ឬដោយទ្រព្យ ឬក៏

ដោយពាហនៈមានឬ ?” ។ សូម្បីបព្វជិត ក៏ធ្វើមានះនេះថា “អ្វី១ ជាការផ្សេងគ្នារបស់យើងនឹងភិក្ខុដទៃ ដោយគុណទាំងឡាយមានសីល និងធុតង្គជាដើមមានឬ ?”។

សូម្បីមានះក្នុងខថា **“អ្នកលើសជាងគេ សម្គាល់ថា ទាបជាងគេ”** ក៏រមែងកើតដល់បុគ្គលនោះ១ ។ ពិតមែន ខេត្តខណ្ឌ ឬទ្រព្យ ឬក៏ពាហនៈជាដើម រមែងមិនសម្បូណ៌ដល់ព្រះរាជាណា ព្រះរាជានោះ រមែងធ្វើហេតុត្រឹមតែថា អាស្រ័យសេចក្ដីសុខ ដែលជាវោហារថា “អ្នកនោះជាព្រះរាជារបស់យើង” ឱ្យជាមានះថា “យើងឈ្មោះថា ជាព្រះរាជាបានយ៉ាងណា” សូម្បីបព្វជិតអ្នកមានលាភ-សក្ការៈតិច រមែងធ្វើមានះដែលដូចនឹងពាក្យថា “យើងជាធម្មកថិក ជាពហូសូត ជាមហាថេរនោះឯង ឱ្យជាមានះថា យើងឈ្មោះថា ជាធម្មកថិក ឬពហូសូត ឬក៏ជាមហាថេរ ដូចម្ដេច ព្រោះលាភសក្ការៈ មិនមានដល់យើង” ។

មានះថា **“អ្នកស្មើគេ សម្គាល់ថា លើសគេ”** ជាដើម រមែងកើតឡើងដល់បុគ្គលទាំងឡាយ មានអាមាត្យជាដើម ។ ពិតមែន អាមាត្យរមែងធ្វើមានះ ទាំងឡាយនេះថា “រាជបុរស (អាមាត្យ)ដទៃ ដូចយើង ដោយខេត្តដែន ឬដោយ ភោគៈ យាន ពាហនៈជាដើម មានឬ ?” ឬធ្វើមានះថា “ការធ្វើផ្សេងគ្នារបស់យើង និងអាមាត្យដទៃ មានឬ ?” ឬក៏ធ្វើមានះថា “ត្រឹមតែឈ្មោះថា អាមាត្យនោះឯង សូម្បីថាព្រោះនិយមក្នុងការទំពាស៊ីអាហារ រមែងមិនមានដល់យើង ឬថា យើង ឈ្មោះថា ជាអាមាត្យបានយ៉ាងណា” ។

មានះក្នុងពាក្យថា **“យើងអាក្រក់ជាងគេ សម្គាល់ថា លើសគេ”** ជាដើម រមែងកើតឡើងដល់ទាសៈទាំងឡាយជាដើម ។ ពិតមែន ទាសៈរមែងធ្វើ

មានះទាំងឡាយយ៉ាងនេះថា "យើងជាទាសៈព្រោះមាតាបិតា ឈ្មោះថា ទាសៈដទៃ ស្មើយើងមានឬ ? មនុស្សដទៃមិនអាចដើម្បីរស់នៅព្រោះអាស្រ័យផ្ទៃជាហេតុ ទើបជាទាសៈ ចំណែកយើង ឈ្មោះថា ជាអ្នកប្រសើរជាង ព្រោះមកតាមប្រពៃណី" ឬធ្វើមានះថា "ការធ្វើដែលប្លែកផ្សេងគ្នារបស់យើង និងទាសៈឯណោះ ជាទាសៈតាមប្រពៃណី ជាទាសៈ ដែលបរិសុទ្ធដោយចំណែកពីរ" ឬថា ធ្វើមានះថា "យើងចូលដល់ភាពជាទាសៈ ដោយអំណាចនៃផ្ទៃ, តែតំណែងជាទាសៈរបស់យើង មិនមានតាំងអំពីមាតាបិតា, យើងឈ្មោះថា ជាទាសៈបានដូចម្ដេចទៅ" ។ ក៏ទាសៈរមែងធ្វើមានះ យ៉ាងណា, សូម្បីមនុស្សចោលសម្រាម និងមនុស្សចណ្ឌាលជាដើម ក៏រមែងធ្វើមានះទាំងឡាយនេះដែរ ។

ម្យ៉ាងទៀត មានះដែលកើតឡើងតាមសេចក្ដីពិត ក្នុងខថា "អ្នកលើសជាងគេ សម្គាល់ថា លើសជាងគេ" ជាបុគ្គលអ្នកលើសគេនោះ, មានះ ២ ក្រៅនេះមិនមែន ។ មានះថា "យើងស្មើគេ មានសេចក្ដីសម្គាល់ថាស្មើគេ" ក៏ដូចគ្នា, មានះថា "យើងអាក្រក់ជាងគេ" ក៏កើតដល់បុគ្គលអ្នកអាក្រក់នោះ៧ ឯង, មានះក្រៅពីនេះ មិនមែនទេ ។

**ក្នុងមានះទាំងនោះ មានះដែលកើតឡើងតាមសេចក្ដីពិត ជាធម៌ដែលអរហត្តមគ្គគប្បីសម្លាប់, មានះដែលមិនកើតឡើងតាមសេចក្ដីពិត ជាធម៌ដែលសោតាបត្តិមគ្គគប្បីសម្លាប់ ។**

ព្រះសាស្ដាត្រាស់មានះទាំងឡាយ ដែលប្រព្រឹត្តទៅដោយវត្ថុយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងសម្ដែងមានះដែលកើតឡើងមិនមានវត្ថុ ទើបត្រាស់

ពាក្យជាដើមថា **“តត្ថ កតមោ មានោ** = បណ្តាពាក្យទាំងនោះ មានះ តើដូចម្តេច ?” ជាដើម ។

ក្នុងនិទ្ទេសនៃអតិមានះ (ការមើលងាយ) ព្រះមានព្រះភាគជាម្ចាស់ ទ្រង់មិនកាន់យកបុគ្គលដោយអំណាចនៃការដឹងថាជាអ្នកលើសគេជាដើម តែទ្រង់ពន្យល់ដោយអំណាចនៃវត្ថុមានជាតិជាដើមនោះឯង ។ បណ្តាពាក្យទាំងនោះ ពាក្យថា **“អតិមញ្ញតិ** = រមែងមើលងាយ” បានដល់ រមែងសម្គាល់ខ្លួនថា “អ្នកដទៃដូចយើងដោយជាតិជាដើម រមែងមិនមាន” ៕

## មានាតិមាននិទ្ទេស

## អធិប្បាយការប្រកាន់ខ្លួន និងការឆ្មើងឆ្មៃ

ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **“យោ ឯវរូបោ”** យ៉ាងនេះ ដើម្បីសម្តែងថា មានះដែលកើតឡើងខាងដើមថា “បុគ្គលណាដូចយើង, តែឥឡូវនេះយើងជាអ្នកប្រសើរជាង, អ្នកនេះទាបជាង” , ឈ្មោះថា ការប្រកាន់ខ្លួន និងការឆ្មើងឆ្មៃ ដោយអាស្រ័យមានះថា “អ្នកដទៃដូចនឹងខ្លួនក្នុងកាលមុននោះ បុគ្គលនោះរមែងដូចជាបុគ្គល មានភារៈធ្ងន់ក្រៃលែងជាងភារៈធ្ងន់” ។

**និទ្ទេសនៃឱមានះ** (មានះដ៏លាមក) ដូចនឹងនិទ្ទេសនៃមានះដែលអាក្រក់ (ហីនមានះ) នោះឯង ។ តែកាលពោលដោយអំណាចនៃវេនេយ្យសត្វ (សត្វដែលគួរណែនាំបាន) ឈ្មោះរបស់មានះនោះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា អ្នកមានសេចក្តីសម្គាល់ថា “យើងអាក្រក់” , មានះនេះ ឈ្មោះថា **ឱមានះ** ដោយអំណាច

នៃការប្រព្រឹត្តទៅដោយកំណត់ខ្លួនយ៉ាងទាបដូច្នេះ ។ម្យ៉ាងទៀត ក្នុងមានះនេះ បណ្ឌិតគប្បីជ្រាបថា មានះនេះ ឈ្មោះថា ឱមានះ ដោយអំណាចនៃការប្រព្រឹត្តទៅ ព្រោះធ្វើខ្លួនឱ្យទាបយ៉ាងនេះថា “មានជាតិ, តែជាតិរបស់លោកដូចជាតិរបស់ក្អែក; មានគោត្រ, តែគោត្ររបស់លោក ដូចគោត្ររបស់ចណ្ឌាល; សំឡេងរបស់លោក មាន, តែសំឡេងរបស់លោកដូចសំឡេងសត្វក្អែក” ៕

## អធិមាននិទ្ទេស

## អធិប្បាយការសម្គាល់ថា បានពន្លុះធម៌វិសេស

ពាក្យថា “**អប្បត្តេ បត្តសញ្ញិតា** = ការសម្គាល់ថា ដល់ហើយក្នុងធម៌ដែលខ្លួននៅមិនទាន់បានដល់” បានដល់ មានការសម្គាល់ដល់សច្ចៈ ៤ ដែលខ្លួននៅមិនទាន់បានពន្លុះ ថាពន្លុះហើយ ។ ពាក្យថា “**អកតេ** = ក្នុងកិច្ចដែលនៅមិនទាន់បានធ្វើ” បានដល់ មានសេចក្ដីសម្គាល់ក្នុងកិច្ចដែលខ្លួនគប្បីធ្វើ ដែលមគ្គ ៤ នៅមិនទាន់បានធ្វើ ។ ពាក្យថា “**អនធិគតេ** = ក្នុងធម៌ដែលខ្លួននៅមិនទាន់បានពន្លុះ” បានដល់ នៅមិនទាន់ពន្លុះសច្ចធម៌ទាំង ៤ ។ ពាក្យថា “**អសច្ឆិកតេ** = ក្នុងធម៌ដែលខ្លួននៅមិនទាន់បានធ្វើឱ្យជាក់ច្បាស់” បានដល់ ធម៌ដែលអរហត្តមគ្គនៅមិនទាន់បានធ្វើឱ្យជាក់ច្បាស់ ។ ពាក្យថា “**អយំ វុច្ចតិ អធិមានោ**” បានដល់ បុគ្គលនេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ ហៅថា អ្នកមានសេចក្ដីសម្គាល់ថា ខ្លួនបានពន្លុះធម៌វិសេស ។

***សួរថា*** ក៏សេចក្ដីសម្គាល់ថា ខ្លួនបានពន្លុះធម៌វិសេសនោះ រមែងកើតដល់

អ្នកណា, រមែងកើតដល់បុគ្គលណា ?

ឆ្លើយថា រមែងមិនកើតឡើងដល់ព្រះអរិយសាវ័កឡើយ ។

ពិតមែន ព្រះអរិយសាវ័កនោះ មានសោមនស្ស (សេចក្ដីពេញចិត្ត) ដែលកើតឡើងល្អហើយ ក្នុងខណៈដែលពិចារណាមគ្គ ផល និព្វាន និងកិលេសដែលលោកលះហើយ នឹងនៅមិនទាន់បានលះនុ៎ះឯង មិនមានការសង្ស័យក្នុងការចាក់ធ្លុះនូវគុណរហូត (ក្នុងបដិវេធ) ដែលជាអរិយគុណ, ព្រោះហេតុដូច្នេះ ព្រះសោតាបន្នជាដើម ដោយអំណាចនៃសេចក្ដីសម្គាល់ថា "យើងជាព្រះសកទាគាមី" ជាដើម ។

**សេចក្ដីសម្គាល់ខ្លួនថា បានពន្លុះធម៌វិសេស** មិនកើតឡើងសូម្បីដល់បុគ្គលអ្នកទ្រុស្តសីល ។ ពិតមែន បុគ្គលអ្នកទ្រុស្តសីលនោះ មិនមានសេចក្ដីប្រាថ្នាក្នុងការពន្លុះអរិយគុណឡើយ ។ សេចក្ដីសម្គាល់ខ្លួន រមែងមិនកើតឡើង សូម្បីដល់បុគ្គលអ្នកមានសីល អ្នកមានកម្មដ្ឋានលះហើយ អ្នកប្រកបរឿយៗ **នូវភាពជាអ្នកត្រេកអរក្នុងការដេកជាដើម** ។

ក៏បើសេចក្ដីសម្គាល់ថា ខ្លួនបានពន្លុះធម៌វិសេសនោះ រមែងកើតឡើងដល់អ្នកមានសីលបរិសុទ្ធ អ្នកមិនប្រមាទក្នុងកម្មដ្ឋាន អ្នកកំណត់នាមរូប ឆ្លងកាត់សេចក្ដីសង្ស័យ បានដោយការកំណត់បច្ច័យ អ្នកលើកនាមរូបឡើងកាន់ត្រៃ-លក្ខណ៍ហើយ ពិចារណាសង្ខារទាំងឡាយ អ្នកមានសេចក្ដីឃើញច្បាស់ មានសេចក្ដីព្យាយាម ។

ម្យ៉ាងទៀត កាលមានសេចក្ដីសម្គាល់ថា បានពន្លុះធម៌វិសេស កើតឡើងហើយ បុគ្គលអ្នកបានសមថៈម្យ៉ាង (សុទ្ធសមថលាភី) ឬអ្នកបានវិបស្សនាម្យ៉ាង

(វិបស្សនាលាភី) រមែងបញ្ឈប់កម្មដ្ឋានទុកក្នុងចន្លោះ; ព្រោះថា កាលបុគ្គលនោះមិនឃើញ សេចក្ដីប្រាកដកើតឡើងនៃកិលេស អស់វេលា ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ទើបកើតសេចក្ដីសម្គាល់ថា "ខ្លួនយើងជាព្រះសោតាបន្ន ឬព្រះសកទាគាមី ឬក៏ ព្រះអនាគាមី" ។ ចំណែកព្រះយោគីអ្នកបានសមថៈ និងវិបស្សនា កាលមានសេចក្ដីសម្គាល់ថាបានពន្លះព្រះអរហត្តនោះ ទើបបញ្ឈប់កម្មដ្ឋាន; ព្រោះថា កិលេសទាំងឡាយដែលបុគ្គលនោះសង្កត់ទុកហើយ ដោយកម្លាំងនៃសមាធិ, សង្ខារទាំងឡាយ ដែលលោកកំណត់ល្អហើយដោយកម្លាំងនៃវិបស្សនា, ព្រោះហេតុដូច្នោះ កិលេសទាំងឡាយ រមែងមិនកើតឡើងអស់ ៦០ ឆ្នាំខ្លះ ៨០ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ ។ សេចក្ដីមិនសង្ស័យ (គឺមិនមានសេចក្ដីសម្គាល់ខ្លួន) រមែងមានដល់ព្រះ-ខីណាស្រពប៉ុណ្ណោះ ។ ព្រះយោគីអ្នកបានទាំងសមថៈ ទាំងវិបស្សនានោះ កាលមិនឃើញការកើតឡើងនៃកិលេសអស់កាលយូរយ៉ាងនេះ ទើបបញ្ឈប់កម្មដ្ឋានទុកក្នុងចន្លោះនុ៎ះឯង រមែងសម្គាល់ថា "យើងពន្លុះជាព្រះអរហន្ត" ដូចព្រះ**មហានាគ-ត្ថេរ** អ្នកនៅក្នុង **ឧច្ចតលង្កៈ** ដូចព្រះ**មហាទត្តត្ថេរ** អ្នកនៅក្នុង**ហង្កមកៈ** និងដូចព្រះ**ចូឡសុមត្ថេរ** អ្នកនៅក្នុងកុដិដែលជាទីធ្វើនូវសេចក្ដីព្យាយាម ឈ្មោះថា **និង្កបោណៈ** ជិតភ្នំឈ្មោះ **ចិត្តលបព៌ត** ។ ក្នុងសេចក្ដីនោះ គប្បីជ្រាបការពន្យល់បង្ហាញរឿងមួយ ដូច្នេះថា ៖

## រឿងព្រះមហានាគត្ថេរ

បានឮថា **ព្រះធម្មទិន្នត្ថេរ** អ្នកអាស្រ័យនៅតលង្កៈមួយរូប ជាព្រះខីណា-

ស្រព មានបញ្ញាក្នុងបដិសម្ភិទា បានជាអ្នកឱ្យឱវាទដល់ភិក្ខុសង្ឃ, ក្នុងថ្ងៃមួយ លោកអង្គុយសម្រាក ក្នុងទីសម្រាកវេលាថ្ងៃរបស់ខ្លួន រឭកដល់អាចារ្យរបស់លោកថា "កិច្ចនៃសមណៈរបស់ព្រះមហានាគត្ថេរ ក្នុងឧច្ចតលង្កៈ អាចារ្យរបស់យើងដល់ទីបំផុតហើយ ឬមិនទាន់ដល់ហ្ន៎" ឃើញហើយនូវសភាពដែលអាចារ្យរបស់ខ្លួននោះ នៅជាបុថុជ្ជន និងជ្រាបថា "កាលយើងមិនទៅ អាចារ្យរបស់យើងនឹងធ្វើកាលកិរិយា ដោយទាំងនៅជាបុថុជ្ជននោះឯង" ទើបហោះទៅកាន់វេហាស៏ដោយឫទ្ធិ ចុះហើយជិតព្រះមហានាគត្ថេរ ដែលអង្គុយសម្រាកក្នុងទីសម្រាកវេលាថ្ងៃ សំពះថ្វាយបង្គំ ហើយសម្តែងវត្ត អង្គុយក្នុងទីដ៏សមគួរ ។ ក៏កាលអាចារ្យសួរថា "ម្នាលធម្មទិន្នមានអាយុ ព្រោះហេតុអ្វី ទើបលោកមកក្នុងវេលាដែលមិនសមគួរ ?" ទើបលោកពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំមកដើម្បីសួរបញ្ហានឹងលោកម្ចាស់" ។ លំដាប់នោះ កាលអាចារ្យពោលថា "ម្នាលអ្នកមានអាយុ អ្នកចូរសួរមកចុះ កាលខ្ញុំព្រះករុណាជ្រាប ក៏នឹងឆ្លើយ" ទើបសួរបញ្ហារាប់ពាន់ខ ។ ព្រះថេរៈជាអាចារ្យមិនទាក់ទើនឹងបញ្ហា ដែលព្រះធម្មទិន្នសួរហើយៗ ក៏ពោលឆ្លើយហើយៗ ។ លំដាប់នោះ គ្រាកាលដែលព្រះធម្មទិន្នពោលថា "បពិត្រលោកម្ចាស់ ញាណរបស់លោកក្រៃលែង, ធម៌នេះលោកពន្លុះក្នុងកាលណា ?" លោកក៏ពោលថា "អ្នកមានអាយុ ក្នុងកាលនៃវស្សា ៦០ អំពីកាលនេះ" ។ ព្រះធម្មទិន្នពោលថា "បពិត្រលោកម្ចាស់ លោកនៅតែប្រើសមាធិឬ ?" ; លោកអាចារ្យឆ្លើយថា "ខនេះ មិនធ្ងន់ចិត្តឡើយ" ។

ព្រះធម្មទិន្នទើបពោលថា "បពិត្រលោកម្ចាស់ បើយ៉ាងនេះ សូមលោក

និម្មិតដំរីមួយ” ។ លោកក៏បាននិម្មិតដំរីសសុទ្ធ ។ ព្រះធម្មទិន្នពោលថា “បពិត្រលោកម្ចាស់ ឥឡូវដំរីនេះមានត្រចៀកបើក (កាង) ចេញហើយ មានកន្ទុយសណ្ដូកចេញហើយ យកប្រមោយដាក់ក្នុងមាត់ បញ្ចេញសំឡេងកោញ្ចនាទ (សំឡេងគឹកកង) គួរឱ្យខ្លាច បែរមុខមករកលោក, ដោយអាការដែលលោកនិម្មិតនោះឡើងមកយ៉ាងនោះ” ។ ព្រះថេរៈជាអាចារ្យ កាលឃើញនិម្មិតយ៉ាងនេះហើយ ឃើញនូវអាការកិរិយាសំឡេងគួរខ្លាចរបស់ដំរី មកដោយលឿន លោកក៏ក្រោកឡើងដើម្បីគេចចេញទៅ ។ ព្រះធម្មទិន្នជាព្រះខីណាស្រព ទើបលាដៃចេញចាប់ជាយចីវររបស់លោកអាចារ្យ ហើយពោលថា “បពិត្រលោកម្ចាស់ សេចក្ដីភ័យខ្លាចរមែងមានដល់ព្រះខីណាស្រពដែរឬ ?” ។ លោកអាចារ្យជ្រាបសភាពដែលខ្លួននៅជាបុថុជ្ជន ក្នុងកាលនោះ ទើបពោលថា “ម្នាលធម្មទិន្នមានអាយុ លោកចូរជាទីពឹងដល់ខ្ញុំ” ហើយអង្គុយច្រហោងក្បែរជើងរបស់ព្រះធម្មទិន្ន ។ ព្រះធម្មទិន្នពោលថា “បពិត្រលោកម្ចាស់ ខ្ញុំមកដោយប្រាថ្នាថា នឹងជាទីពឹងដល់លោកម្ចាស់ សូមលោកកុំមានវិតក្កៈ” ដូច្នេះ ហើយប្រាប់កម្មដ្ឋាន ។ ព្រះថេរៈជាអាចារ្យរៀនកម្មដ្ឋានហើយ ក៏ក្រោកឡើងកាន់ទីចង្ក្រម ក្នុងជំហានទី ៣ ក៏ពន្លុះព្រះអរហត្តផលដ៏លើស; បានឮថា ព្រះថេរៈនេះ ដើមឡើយជាអ្នកមានទោសចរិត ៕

## អស្មិមាននិទ្ទេស អធិប្បាយការសម្គាល់ថាមានអត្តា

ពាក្យថា “**រូបេ អស្មីតិ មានោ** = ការសម្គាល់ក្នុងរូបថា ជាខ្លួនយើង” បានដល់ មានការសម្គាល់កើតឡើងថា “រូបជាយើង” ។ ពាក្យថា “**ឆន្ទោ** =

ការពេញចិត្ត” បានដល់ ជាអ្នកមានឆន្ទៈទៅតាមមានះ (មានះ គឺការសម្គាល់ថាមានអត្តា) នោះឯង ។ សេចក្តីចូលចិត្ត ពេញចិត្ត ដែលដេកត្រាំនៅក្នុងរូបថា ជាខ្លួនយើង ក៏ដូចគ្នា; សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដែរ ៕

## មិច្ឆាមាននិទ្ទេស អធិប្បាយការប្រកាន់ខ្លួនខុស

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **“ឆាចកេន ខា កម្មាយតនេន”** ជាដើម ការងាររបស់ព្រានប្រមង់ និងអ្នកសម្លាប់សត្វជាដើម ឈ្មោះថា **ការងារដ៏លាមក**។ ភាពឈ្លាសវាងវៃក្នុងការធ្វើសំណាញ់ ប្រដាប់ដាក់ត្រី និងធ្វើស្នរលំពែងចាក់ត្រីជាដើម ឈ្មោះថា **សិប្បៈដ៏លាមក** ។ វិជ្ជាបៀតបៀនយ៉ាងណាមួយ ឈ្មោះថា **វិជ្ជាស្ថានដ៏លាមក** ។ ការប្រកបព្រមដោយចំពោះនូវរឿងនិទាន មានរឿងភារតយុទ្ធ និងរឿងចាប់យកនាងសិតាជាដើម ឈ្មោះថា **ការសិក្សាដ៏លាមក** ។ ភាពឈ្លាស វាងវៃក្នុងពាក្យកាព្យ ការពត់ពេន រាំច្រៀង និងរៀបរាប់ពិពណ៌នាជាដើម ដែលប្រកបដោយទុព្ភាសិត ឈ្មោះថា **បដិភាណដ៏លាមក** ។ អជសីល (ប្រព្រឹត្តិដូចពពែ) គោសីល (ប្រព្រឹត្តិដូចគោ) ឈ្មោះថា **សីលដ៏លាមក** ។ **សូម្បីវត្ត** ក៏គឺអជវត្ត និងគោវត្ត ដូចគ្នា; ទិដ្ឋិ ៦២ យ៉ាងណាមួយ ឈ្មោះថា **ទិដ្ឋិដ៏លាមក** ។

**ក្នុងនិទ្ទេសនៃសេចក្តីវិតក្កៈដល់ញាតិ** (ការគិតដល់ញាតិ) ជាដើម ឈ្មោះថា គិតដល់ញាតិ គឺវិតក្កៈដែលកើតឡើង ប្រារព្ធញាតិទាំងឡាយ ដោយសេចក្តីស្រឡាញ់អាស្រ័យផ្ទះ ដែលដាក់ប្រដាប់ក្នុងស្រុក អាស្រ័យទាក់ទងដោយកាមគុណ ៥ យ៉ាងនេះថា “ញាតិរបស់យើងទាំងឡាយ ជាអ្នកសប្បាយ មានទ្រព្យសម្បត្តិ” ។

តែបុគ្គលនោះ មានសេចក្តីត្រិះរិះនឹកគិតប្រព្រឹត្តទៅយ៉ាងនេះថា "ញាតិទាំងឡាយរបស់យើងមានសទ្ធា មានសេចក្តីជ្រះថ្លា មានសេចក្តីអស់ទៅ ដល់សេចក្តីអន់ថយហើយ" **មិនឈ្មោះថា ត្រិះរិះដល់ញាតិ** ។

សេចក្តីត្រិះរិះ ដែលកើតឡើងដល់អ្នកត្រេកអរថា "ជនបទរបស់យើងទាំងឡាយ មានភិក្ខាហាររកបានដោយងាយ មានបាយសម្បូណ៌" ដោយអំណាចនៃសេចក្តីស្រឡាញ់ ដែលអាស្រ័យផ្ទះ (គេហសិតបេមំ) ឈ្មោះថា **ការត្រិះរិះដល់ជនបទ** ។ តែថាបុគ្គលមានសេចក្តីត្រិះរិះប្រព្រឹត្តទៅ យ៉ាងនេះថា "មនុស្សទាំងឡាយក្នុងជនបទរបស់ពួកយើង មានសទ្ធា មានសេចក្តីជ្រះថ្លា ដល់សេចក្តីអស់ទៅ និងដល់សេចក្តីសូន្យទៅហើយ" រមែងមិនបាន ឈ្មោះថា **ការត្រិះរិះដល់ជនបទ** ។

សេចក្តីត្រិះរិះដើម្បីត្រូវការមិនឱ្យស្លាប់, ឬថា ការត្រិះរិះដែលមិនស្លាប់ ឈ្មោះថា **អបរវិតក្កៈ** (សេចក្តីត្រិះរិះដែលមិនសម្លាប់ខ្លួន) ។ ក្នុងសេចក្តីនេះ ការត្រិះរិះដែលជាប់ដោយសេចក្តីពេញចិត្ត ក្នុងការធ្វើវត្ថុដែលធ្វើបានដោយលំបាករបស់អ្នកធ្វើទុក្ករកិរិយា ដោយត្រិះរិះថា "កាលសេចក្តីទុក្ខកើតឡើងដោយការព្យាយាម មានការអង្គុយច្រហោងជាដើម ដែលធ្វើទាល់តែអស់កម្លាំង, អត្តារមែងនៅជាសុខ រមែងមិនស្លាប់ក្នុងភពខាងមុខ" ឈ្មោះថា **ការត្រិះរិះដើម្បីសេចក្តីត្រូវការមិនសម្លាប់ខ្លួន** ។ ក៏បុគ្គលអ្នកមានទិដ្ឋិយ៉ាងនេះ ត្រូវអ្នកដទៃសួរបញ្ហាថា "លោករមែងពោលថា 'អត្តា និងលោកទៀង' ដូច្នេះជាដើម លោកនឹងពោលវាចាដ៏ងាយ មិនស្លាប់ខ្លួនថា 'វត្ថុនេះ រមែងប្រាកដដល់យើងថា៖

**ឯវន្តិបិ មេ នោ** = សូម្បីយ៉ាងនេះ ក៏មិនមែន

**តថាតិបិ មេ នោ** = សូម្បីយ៉ាងនោះ ក៏មិនមែន

**អញ្ញថាតិបិ មេ នោ** = សូម្បីយ៉ាងដទៃ ក៏មិនមែន

**នោតិបិ មេ នោ** = សូម្បីវត្ថុដែលមិនមែន ក៏មិនមែន

**នោ នោតិបិ មេ នោ** = សូម្បីវត្ថុដែលមិនមែនៗ ក៏មិនមែន"[៥៤] ។

រមែងដល់នូវការច្របូកច្របល់, សេចក្តីត្រិះរិះដែលប្រកបដោយទិដ្ឋិគតៈរបស់បុគ្គលនោះ ប្រៀបដូចជាត្រីលោតចុះទឹកទៅហើយ នរណាៗ ក៏មិនអាចទៅចាប់ សម្លាប់បានយ៉ាងណា, សេចក្តីនេះក៏ដូច្នោះដែរ **ឈ្មោះថា ការត្រិះរិះមិនស្លាប់ខ្លួន** ព្រោះអត្ថថា មិនជាក់ច្បាស់ និងព្រោះមិនតាំងនៅក្នុងចំណែកមួយ ។ ព្រះមានព្រះភាគត្រាស់ការត្រិះរិះដែលមិនស្លាប់ខ្លួននេះ ដោយរួមយកការត្រិះរិះសូម្បីទាំងពីរប្រភេទនេះ ។

ពាក្យថា "**បរានុទ្ទយតា បដិសំយុត្តោ** = សេចក្តីគិតទាក់ទងដល់ការអាណិតអ្នកដទៃ" បានដល់ សេចក្តីត្រិះរិះប្រកបដោយសេចក្តីស្រឡាញ់ អាស្រ័យផ្ទះដែលសមគ្នានឹងសេចក្តីអាណិត ។ ពាក្យថា "**សហនន្ទី** = មានសេចក្តីរីករាយរួមគ្នា" ជាដើម បានដល់ ពេលឧបដ្ឋាកទាំងឡាយមានសេចក្តីរីករាយ ឬមានសេចក្តីទុក្ខសោក លោក ក៏រមែងរីករាយជាទ្វេគុណ ឬសោកទ្វេគុណរួមនឹងឧបដ្ឋាកទាំងនោះ, កាលឧបដ្ឋាកទាំងនោះ មានសេចក្តីសុខ ឬទុក្ខ លោកក៏ជាអ្នកមានសេចក្តីសុខ ឬទុក្ខទ្វេគុណជាមួយ នឹងឧបដ្ឋាកទាំងនោះ ។ ពាក្យថា "**ឧប្បន្នេសុ**

---

[៥៤] ទី. សី. ។

**កិច្ចករណីយេសុ** = កាលកិច្ចដែលគប្បី ធ្វើកើតឡើង” បានដល់ កាលបុគ្គលដទៃទាំងនោះ មានការងារធំតូចកើតឡើង ។ ពាក្យថា “**អត្តនា វា យោគំ អាបជ្ជតិ** = មានព្យាយាមធ្វើដោយខ្លួនឯង” បានដល់ កាលភិក្ខុញ៉ាំងកិច្ចទាំងនោះៗ ឱ្យសម្រេច រមែងឈានកន្លងព្រះបញ្ញត្តិ (វិន័យ), រមែងល្មើសធម៌ដែលជាគ្រឿងលះកិលេស ។ ពាក្យថា “**យោ តត្ថ** = ក្នុងការស្និទ្ធស្នាលនឹងបុទ្គិទាំងនោះ” បានដល់ សេចក្តីត្រិះរិះណា ដែលជាគេហសិតៈមានការស្និទ្ធស្នាលនឹងគ្នានោះ ក្នុងវិហារ ឬថា ក្នុងការកន្លងសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។ សេចក្តីត្រិះរិះនេះ ឈ្មោះថា គិតជាប់ដោយការអាណិតអ្នកដទៃ ។

ពាក្យថា “**លាភសក្ការសិលោកបដិសំយុត្តោ** = គិតជាប់ដោយលាភសក្ការៈ និងឈ្មោះ” បានដល់ សេចក្តីត្រិះរិះដែលប្រកបដោយការធ្វើឱ្យជាអារម្មណ៍ និងការបានបច្ច័យ ៤ បានដល់ការបានចីវរជាដើម ដោយសក្ការៈ និងដោយកិត្តិសព្ទ (កេរ្តិ៍ឈ្មោះ) ។

ពាក្យថា “**អនវញ្ញត្តិបដិសំយុត្តោ** = ការគិតដោយមិនចង់ឱ្យនរណាមើលងាយ” បានដល់ ការត្រិះរិះដែលកើតឡើងព្រមគ្នានឹងសេចក្តីប្រាថ្នា មិនឱ្យនរណាមើលងាយយ៉ាងនេះថា “ឱហ្ន ! បុគ្គលដទៃៗ មិនគប្បីមើលងាយយើង, មិនពោលអាក្រក់ពីយើង មិនគប្បីនិយាយបៀតបៀនយើង” ។ ពាក្យថា “**យោ តត្ថ គេហសិតោ**” បានដល់ កាលបើចិត្តកើតឡើងថា “បុគ្គលពួកដទៃ កុំមើល (ស្ងាន) យើងត្រូវឡើយ” រមែងជាអ្នកអាស្រ័យផ្ទះ ពោលគឺកាមគុណ ៥ ឈ្មោះថា មានវិតក្កៈកើតឡើង យ៉ាងនេះហើយ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ប្រាកដ

ជាក់ច្បាស់ហើយមែនពិត ៕

ចប់ឯកកនិទ្ទេស

## អដ្ឋកថាទុកនិទ្ទេស អធិប្បាយមាតិកា ២ ប្រភេទ

ក្នុងទុកមាតិកាទាំងឡាយ បណ្ឌិតគប្បីជ្រាប **និទ្ទេសនៃសេចក្តីក្រោធជាដើម** ដោយន័យដែលពោលទុកហើយក្នុងពេលក្រោយនោះឯង ។ **ក៏ក្នុងនិទ្ទេសនៃការចងនូវសេចក្តីក្រោធជាដើម** ដែលជាអនាគត គឺបុគ្គលណាវមែងចងសេចក្តី ក្រោធទុកក្នុងកាលមុន ខាងក្រោយសេចក្តីក្រោធកើតឡើងទៀត ។ ក៏ឈ្មោះថា **ឧបនាហៈ** ការចងសេចក្តីក្រោធ; អាការនៃការចងនូវសេចក្តីក្រោធ ឈ្មោះថា **កិរិយាដែលចងនូវសេចក្តីក្រោធ** ។ ភាវៈនៃបុគ្គលអ្នកចងសេចក្តីក្រោធ ឈ្មោះថា **សភាពដែលចងសេចក្តីក្រោធ**; ពាក្យថា **“អដ្ឋបនា =** សេចក្តីតាំងទុក” បានដល់ ការតាំងសេចក្តីក្រោធទុក ជាប់តគ្នារបស់សេចក្តីក្រោធដែលកើតឡើង ។ ម្យ៉ាងទៀត បានដល់ ការតាំងទុកនូវខេត្តដែនរបស់សេចក្តីក្រោធដែលកើតឡើងពេលមុន; ការតាំងសេចក្តីក្រោធទុកតាមប្រក្រតី ហៅថា **តាំងទុកនូវសេចក្តីក្រោធ**; ការតាំងអាឃាតញយ១ ដោយចំណែកទាំងពួង ឈ្មោះថា **ចងនូវសេចក្តីក្រោធទុក** ។ ការមិនសម្តែងសេចក្តីប្លែកផ្សេងគ្នានៃសេចក្តីក្រោធខាងក្រោយ និងសេចក្តីក្រោធដែលកើតឡើងមុន ហើយធ្វើទុកដោយភាពជាមួយគ្នា ឈ្មោះថា **សន្សំសេចក្តីក្រោធទុក** ។ ការបន្តអំពីសេចក្តីក្រោធពេលក្រោយ និងដោយសេចក្តីក្រោធពេលដំបូង ឈ្មោះថា **ចងព័ន្ធសេចក្តីក្រោធទុក** ។

ពាក្យថា **“ប្រកាន់ខ្ជាប់នូវសេចក្ដីក្រោធ”** បានដល់ ការធ្វើសេចក្ដីក្រោធឱ្យមាំ ។ ពាក្យថា **“អយំ ទុច្ចតិ”** សេចក្ដីថា លក្ខណៈនេះមានការចូលទៅចងទុកជាលក្ខណៈ មានការមិនលះបង់នូវពៀរជារស ព្រះមានព្រះភាគជាម្ចាស់ត្រាស់ ហៅលក្ខណៈនេះថា **“ឧបនាហៈ** = ការចងសេចក្ដីក្រោធ” អធិប្បាយថា បុគ្គលអ្នកប្រកបដោយសេចក្ដីក្រោធដោយលក្ខណៈណា រមែងមិនអាចដើម្បីលះពៀរ មានសភាពដូច្នេះ, បុគ្គលនេះរមែងជាប់តាមនូវសេចក្ដីក្រោធដទៃៗ ទៀតដោយលក្ខណៈថា “បុគ្គលនេះ មិនសមគួរពោលនឹងយើងយ៉ាងនេះ” សេចក្ដីក្រោធរបស់គេ រមែងឆេះសន្ធោសន្ធៅតែម្ដង ហាក់ដូចជាឧសងាប់ដែលភ្លើងឆេះទូទៅហើយ, សេចក្ដីក្រោធនោះរមែងមិនស្អាត ហាក់ដូចជាស្បែកខ្លាឃ្មុំដែលបុគ្គលធ្វើឱ្យស្អាតហើយ និងហាក់ដូចជាសំពត់ចាស់ ដែលប្រឡាក់ដោយខ្លាញ់ ឬប្រេង ។

ឈ្មោះថា **មក្ខៈការមើលងាយគុណគេ** (បំបាត់គុណគេ) ដោយអំណាចនៃភាវៈជារបស់ប្រឡាក់ គឺថា បុគ្គលសូម្បីប្រព្រឹត្តទៅដោយអំណាចនៃការមើលងាយគុណ របស់អ្នកដទៃនោះ រមែងប្រឡាក់ទោសនោះមុន ដូចជាលាមកដែលជារបស់ខ្លួនឯង រមែងប្រឡាក់ខ្លួនឯង ។ ពីរបទអំពីនោះ ជាពាក្យអធិប្បាយសភាពនៃកិរិយា អាការ ។ ភាវៈនៃបុគ្គលអ្នករឹងចចេសគ្រោតគ្រាត ឈ្មោះថា **សភាពដែលមើលងាយ** ។ អធិប្បាយថា គុណសូម្បីមានប្រមាណតិច រមែងមិនមានព្រោះអាស្រ័យការមើលងាយ មើលថោក ព្រោះហេតុដូច្នោះ ទើបសភាវៈនោះឈ្មោះថា ជាការពោលខ្ជាក់ទឹកមាត់; ការធ្វើនៃបុគ្គលអ្នកមើលងាយគុណរបស់អ្នកដទៃ ឈ្មោះថា **ធ្វើសេចក្ដីលុបបំបាត់គុណ** (មើលងាយ) ។

ពិតមែន ជាគ្រហស្ថក៏ដោយ ជាភិក្ខុក៏ដោយ កាលអាស្រ័យនូវសេចក្តីក្រោធហើយ ដោយហេតុមានប្រមាណតិចប៉ុណ្ណោះ រមែងមើលងាយគុណ គឺភារៈនៃបុគ្គលនោះ អាស្រ័យអ្នកដទៃ រមែងមិនមានដល់គេ ព្រោះហេតុនៃសេចក្តីក្រោធនោះ, ព្រោះហេតុដូច្នោះ ទើបមានឈ្មោះថា និយាយទៅឱ្យបង្ហិនទឹកមាត់ (និយាយឱ្យទឹកមាត់អស់ទៅទទេៗ) ទើបឈ្មោះថា ជាការធ្វើនូវភាពជាអ្នកមើលងាយ និងហាក់ដូចជាជាន់ញាំញីសេចក្តីល្អរបស់អ្នកដទៃទុកដោយជើង ។ ការធ្វើរបស់អ្នកនោះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ហៅថា **មក្ខៈ** (សេចក្តីលុបគុណគេ) ។ ក៏កាលពោលដោយលក្ខណៈ **មក្ខៈ** នេះមានការលុបគុណរបស់អ្នកដទៃជាលក្ខណៈ, មានការញុំាងគុណរបស់អ្នកដទៃឱ្យវិនាសទៅជាកិច្ច, មានការកាត់រំលាយកិរិយាអាការដែលបុគ្គលដទៃធ្វើល្អហើយជាបច្ចុប្បដ្ឋាន (ជាហេតុជិតឱ្យកើតឡើង *) ។

បុគ្គលណារមែងវាយឫកស្មើនឹងគេ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **បលាសៈ** (វាយឫកស្មើគេ), អធិប្បាយថា សម្តែងគុណរបស់អ្នកដទៃ រមែងធ្វើគុណទាំងឡាយ ស្រដៀងនឹងគុណរបស់ខ្លួន; វិថីផ្លូវរបស់បុគ្គលអ្នកវាយឫក ស្មើនឹងអ្នកដទៃ ឈ្មោះថា **បលាសាយបនា**; បលាសៈការវាយឫកស្មើនោះផង ជាអាហារព្រោះនាំមកនូវការឈ្នះរបស់ខ្លួនផង ឈ្មោះថា **បលាសាហារ**; ពាក្យថា **វិវាទដ្ឋានំ** បានដល់ ហេតុនៃការវិវាទគ្នា; ការកាន់យកធុរៈ (មុខងារ) ស្មើគ្នា ឈ្មោះថា **ការប្រណាំងប្រជែង** ។ ការមិនដាក់ធុរៈដែលខ្លួនកាន់យកហើយ ឈ្មោះថា **ការមិនលះបង់** ។ ក៏កាលពោលដោយលក្ខណៈជាដើម

---

* បានដល់ ផល ។

បលាសៈនោះមានការ ប្រណាំងប្រជែងជាលក្ខណៈ, មានការធ្វើគុណទាំងឡាយរបស់ខ្លួនឱ្យស្មើគ្នានឹងគុណ របស់បុគ្គលដទៃជារស, មានការយកចិត្តទុកដាក់ ដោយកំណត់កាន់យកគុណរបស់ អ្នកដទៃជាបច្ចុប្បដ្ឋាន ។

**ពិតមែន** បុគ្គលអ្នកវាយឫកស្មើ រមែងមិនឱ្យធុរៈ (ការងារ) ដល់បុគ្គលទីពីរ, រមែងញ៉ាំងគុណរបស់ខ្លួនឱ្យរីកចេញទៅស្មើៗ គឺថា កាលព្រះសូត្រទាំងឡាយ ឬការណៈទាំងឡាយចំនួនច្រើន ដែលភិក្ខុដទៃសូម្បីនាំមកហើយ ក្នុងរោងសន្ទនាធម៌ នឹងពោលពង្រីកសេចក្ដីចេញទៅ នូវគុណរបស់ខ្លួនឱ្យស្មើៗ នឹងអ្នកដទៃថា "ក្នុងវាទៈរបស់លោក នឹងវាទៈរបស់យើង ហេតុដែលប្លែកផ្សេងគ្នា ឈ្មោះថាមានឬ ?, ពាក្យរបស់ពួកយើង ក៏ដូចជាមួយនឹងលោកនោះឯង ប្រៀបដូចមាសដែលបុគ្គលបំបែកចេញហើយ ក៏ជាមាសនោះឯង មិនមែនឬ ?" ។

**និទ្ទេសនៃឥស្សា** សេចក្ដីឫស្យា និងមច្ឆរិយៈ សេចក្ដីកំណាញ់ មានសេចក្ដីដូចដែលខ្ញុំពោលហើយនោះឯង ៕

## មាយានិទ្ទេស អធិប្បាយការបោកប្រាស់

ពាក្យថា **"ទាចំ ភាសតិ"** បានដល់ ភិក្ខុអ្នកឈានកន្លងព្រះបញ្ញត្តិដែលដឹងនោះឯង ធ្វើឱ្យជាភារៈធ្ងន់, រមែងនិយាយហាក់ដូចជាថា ខ្លួនជាអ្នកចូលទៅស្ងប់ដោយប្រាថ្នានឹងឱ្យអ្នកដទៃដឹងថា "ឈ្មោះថា ឋានៈ គឺការកន្លងព្រះបញ្ញត្តិ រមែងមិនមានដល់ខ្លួនឯង" ។ ពាក្យថា **"ភារយេន បរក្កមតិ"** បានដល់ ភិក្ខុនោះ

រមែងធ្វើវត្តបដិបត្តិដោយផ្លូវកាយ ដោយគិតថា "នរណា១ កុំបានដឹងនូវបាបកម្ម នេះ ដែលយើងធ្វើហើយ" ។ លក្ខណៈនេះ ឈ្មោះថា **មាយា** ការលាក់ពុតហាក់ដូច ជាលេងកល (និងលួចមាយា) ព្រោះការបិទទោសដែលខ្លួនដឹង ។ សភាពដែល បុគ្គលអ្នកមានមាយា ឈ្មោះថា **មាយាវិតា** ។ សត្វទាំងឡាយធ្វើបាបហើយ ក៏នៅ កន្លងល្មើស គឺធ្វើបាបទៀត ព្រោះភាពជាអ្នកបិទបាំងទុកដោយសភាវៈណា សភាវៈ នោះ ឈ្មោះថា **ការលាក់ពុត**; ឈ្មោះថា កន្លង ព្រោះកន្លងដោយឱ្យឃើញការ ប្រព្រឹត្តទៅដោយអាការដទៃ ដោយការធ្វើផ្លូវកាយ និងវាចា ។ សត្វទាំងឡាយ រមែងធ្វើនូវការឆបោក ដោយសភាពណា សភាពនោះ ឈ្មោះថា **បោកបញ្ឆោត** ។ អធិប្បាយថា រមែងធ្វើឱ្យទទេ ចាកប្រយោជន៏; ឈ្មោះថា បង្កប់ ព្រោះញុំាងបាប ទាំងឡាយ ឱ្យកើតច្របូកច្របល់គ្នា ទៅដោយពាក្យថា "យើងរមែងមិនធ្វើយ៉ាង នេះ" ។ ឈ្មោះថា បំពួន ព្រោះការមិនសម្រួមដោយកាយជាដើម ។

ការបិទបាំងដោយចំណែកទាំងពួង ឈ្មោះថា លាក់បាំង ។ ឈ្មោះថា ការ បិទបាំង ព្រោះរមែងបិទបាំងបាបដោយកាយកម្ម និងវចីកម្ម ហាក់ដូចជាលាមក ដែលបុគ្គលបិទបាំងទុកដោយស្មៅ និងស្លឹកឈើទាំងឡាយ ។ ការបិទបាំងដោយ ចំណែកទាំងពួង ឈ្មោះថា **ការបិទបាំង** ។ ឈ្មោះថា ការមិនបើកចំហ ព្រោះ មិនធ្វើឱ្យជាក់ច្បាស់ ។ ឈ្មោះថា ការបិទបាំងជិត ព្រោះមិនសម្តែងឱ្យប្រាកដ ។ ការបិទបាំងដោយល្អ ឈ្មោះថា សេចក្តីបិទជិតស្លុង; ឈ្មោះថា **ការធ្វើដោយទូទៅ** ព្រោះធ្វើបាបសូម្បីដទៃ ដោយអំណាចនៃការបិទបាំងដែលខ្លួនបានធ្វើហើយ ។ ពាក្យថា **"អយំ វុច្ចតិ"** សេចក្តីថា លក្ខណៈនេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់

ហៅថា **មាយា** ដែលមានការលាក់បាំងទុក ដែលខ្លួនធ្វើហើយជាលក្ខណៈ ។ បុគ្គលប្រកបដោយលក្ខណៈណា រមែងហាក់ដូចជារងើកភ្លើង ដែលបិទទុកដោយផេះ រមែងដូចជាដង្កត់ឈើដែលទឹកបិទបាំងទុក ដូចសស្ត្រាដែលបុគ្គលរុំទុកដោយកម្ទេចក្រណាត់ដូច្នោះ ៕

## សាឋេយ្យនិទ្ទេស អធិប្បាយការអួតអាង

ការមិនពោលដោយពេញចិត្ត ព្រោះសម្តែងគុណដែលខ្លួនមិនមាន ឈ្មោះថា ជា អ្នកអួត ។ ការអួតដោយចំណែកទាំងពួង ឈ្មោះថា **ជាអ្នកអួតច្រើន** ។ ពាក្យថា **“យំ តត្ថ”** បានដល់ សេចក្តីអួតឯណា ក្នុងបុគ្គលនោះ ។ ភាពកោង គឺការសម្តែង គុណដែលមិនមាន ឈ្មោះថា **ការអួត** ។ អាការនៃការអួត ឈ្មោះថា **ភាវៈនៃ បុគ្គលអ្នកអួត** ។ ពាក្យថា **“កក្ខឡតា”** បានដល់ ភាវៈនៃសេចក្តីរឹងប៉ឹងមាន សេចក្តីមិនអត់ធន់ចំពោះវត្ថុដែលមិនជាភ័យ ហាក់ដូចជាសេចក្តីកម្រើករឹងប៉ឹងរបស់ទងបទុម ។ សូម្បីពាក្យថា **សភាពដែលរឹងប៉ឹង** ក៏ជាវេវចនៈរបស់សេចក្តីអួតនោះៗ ឯង ។ សេចក្តីកោងនោះដូចជាសសរខឿន ដែលបុគ្គលជីករណ្តៅកប់តាំងទុក ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកដោយបទទាំងពីរ គឺការនិយាយជាល្បិច ជាគូ និងសភាពដែលនិយាយជាល្បិចជាគូ ។ ពាក្យថា **“ឥទំ វុច្ចតិ”** សេចក្តីថា ការអួតមានការប្រកាសគុណដែលមិនមានក្នុងខ្លួន ជាលក្ខណៈនេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅថា **សាឋេយ្យៈ** (ការអួត) ។ ការអួត

នោះ ដែលអ្នកណាៗ មិនអាចដើម្បីដឹងនូវការពោលកន្លងរបស់អ្នកប្រកប ដោយអាការណា អាការនោះ រមែងដូចនឹង *សូករយក្ស* ដែលពោលទុកដូច្នេះ ៖

“យក្សនោះរមែងក្លែងភេទជាសូករៈ (ជ្រូក)
នៅខាងឆ្វេងពពៃ នៅខាងស្តាំគោចាស់មាន
ស្នែងវែង អង្គុយបញ្ចេញសំឡេង” ។

**និទ្ទេសនៃអវិជ្ជាជាដើម** មានសេចក្ដីដូចដែលបានពោលហើយនោះឯង ។

## អនជ្ជវនិទ្ទេស អធិប្បាយការមិនស្មោះត្រង់

អាការនៃបុគ្គលអ្នកកោង ឈ្មោះថា អនជ្ជវៈ គឺការមិនស្មោះត្រង់ ។ ភាវៈនៃបុគ្គលមិនស្មោះត្រង់ ឈ្មោះថា **ភាពមិនស្មោះត្រង់** ។ ការកោងនៃដួងចន្ទ ឈ្មោះថា **ជិម្ហតា** គឺភាពមិនត្រង់ ។

ពាក្យថា **“វង្កតា”** បានដល់ វៀចដូចទឹកនោមគោ ( គោមូត្រ ) ។ ពាក្យថា **“កុដិលតា** = ភាពង” បានដល់ ភាពងដូចដងនង្គ័ល ។ ការវៀចវេរនៃកាយវាចា និងចិត្តនោះឯង ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកដោយបទសូម្បីទាំងអស់នេះ ។

## អមទ្ទវនិទ្ទេស អធិប្បាយការមិនទន់ភ្លន់

ភាវៈនៃបុគ្គលអ្នកមិនទន់ភ្លន់ ឈ្មោះថា អមុទុតា ។ អាការនៃសេចក្ដីមិនទន់ភ្លន់ ឈ្មោះថា **អមទ្ទវតា** ។ ភាវៈនៃបុគ្គលអ្នករឹងប៉ឹង ឈ្មោះថា **កក្ខឡិយៈ** ។

ភាវៈនៃបុគ្គលអ្នកទ្រគោះបោះបោក ឈ្មោះថា **ផារុសិយៈ** ព្រោះមិនមានសេចក្ដីស្នេហា (ជាប់ចិត្ត) ដល់ការធ្វើទន់ភ្លន់; ភាវៈនៃចិត្តដែលចចេសរឹងរូស ព្រោះមិនប្រព្រឹត្តឱនលំទោន ឈ្មោះថា **ខជ្ជុចិត្តតា** ។ សព្ទថា **“អមុទុតា”** លោកសម្ដែងភាវៈនៃអ្នកមិនទន់ភ្លន់នោះ ឱ្យវិសេសឡើងទៀត ។ ពាក្យថា **“ខជ្ជុចិត្តតា”** ភាពជាអ្នកមានចិត្តប្រកាន់រឹងត្អឹង មិនមែនជាចិត្តស្មោះត្រង់ ។ **និទ្ទេសនៃអក្ខន្តិ** សេចក្ដីមិនអត់ធន់ជាដើម បណ្ឌិតគប្បីជ្រាបសេចក្ដីផ្ទុយគ្នានឹងនិទ្ទេសនៃខន្តិ សេចក្ដីអត់ធន់ជាដើម ៕

## សញ្ញោជននិទ្ទេស អធិប្បាយកិលេសជាគ្រឿងចងទុក

កាមភព ឈ្មោះថា (សញ្ញោជនៈ) ខាងក្នុង ។ រូបភព និងអរូបភព ឈ្មោះថា (សញ្ញោជនៈ) ខាងក្រៅ ។ ពិតមែន សត្វទាំងឡាយរមែងអាស្រ័យ នៅក្នុងកាមភព អស់កាលបន្តិចបន្តួច គឺអាស្រ័យនៅអស់កាលដែលជាចំណែកទី ៤ (មួយភាគបួន) នៃកប្បប៉ុណ្ណោះ; ក្នុងចំណែកនៃកប្បទាំង ៣ ដែលនៅសល់នេះ កាមភព រមែងទទេ ។

សត្វទាំងឡាយ រមែងអាស្រ័យនៅក្នុងរូបភព និងអរូបភព រហូតអស់កាលច្រើន ក៏ពិតមែន, ប៉ុន្តែថា ព្រោះចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយនោះ មានច្រើនក្នុងកាមភព, ចំណែកក្នុងរូបភព និងអរូបភពមានតិច; ក៏ចុតិ និងបដិសន្ធិក្នុងទីណាមានច្រើន, សេចក្ដីអាល័យក្ដីសេចក្ដីប្រាថ្នាក្ដី និងសេចក្ដីចង់បានក្ដី រមែងមានច្រើនក្នុងទីនោះ; ចុតិ

និងបដិសន្ធិក្នុងទីណាមានតិច, ក្នុងទីនោះ ក៏មានកិលេសគ្រឿងចងតិច; ព្រោះហេតុដូច្នោះ ទើបកាមភព ឈ្មោះថា ជាអជ្ឈត្តៈខាងក្នុង; ចំណែករូបភព និងអរូបភព ឈ្មោះថា ជាពហិទ្ធាខាងក្រៅ ។ គ្រឿងចងក្នុងកាមភព ពោលគឺខាងក្នុង ឈ្មោះថា សញ្ញោជនៈខាងក្នុង, គ្រឿងចងក្នុងរូបភព និងអរូបភព ពោលគឺខាងក្រៅ ឈ្មោះថា សញ្ញោជនៈខាងក្រៅ។

បណ្តាសញ្ញោជនៈទាំងនោះ ខាងក្នុង និងខាងក្រៅ មានម្យ៉ាងៗ ៥; ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **“សញ្ញោជនៈ** ដែលជាចំណែកខាងក្រោមមាន ៥, **សញ្ញោជនៈ** ដែលជាចំណែកខាងលើមាន ៥” ។

## ក្នុងសេចក្តីនេះ គប្បីជ្រាបវចនត្ថៈដូច្នេះ ៖

កាមធាតុ ព្រះមានព្រះភាគជាម្ចាស់ឱ្យឈ្មោះថា **ឱរំ** = ខាងក្រោម, សញ្ញោជនៈណា រមែងសេពនូវធម៌ខាងក្រោមនោះ ដោយអាស្រ័យការកើតឡើង និងការ សម្រេចក្នុងកាមធាតុនោះ ព្រោះហេតុនោះ សញ្ញោជនៈនោះ ទើបឈ្មោះថា **ឱរម្ភាគិយៈ** ដែលប្រព្រឹត្តទៅក្នុងចំណែកខាងក្រោម ។ រូបធាតុ និងអរូបធាតុ ព្រះមានព្រះភាគឱ្យឈ្មោះថា **ឧទ្ធំ** = ខាងលើ, សញ្ញោជនៈណា រមែងសេពនូវធម៌ខាងលើនោះ ដោយការកើតឡើង និងសេចក្តីសម្រេចក្នុងរូបធាតុ និងអរូបធាតុនោះ ព្រោះហេតុនោះ សញ្ញោជនៈនោះ ទើបឈ្មោះថា **ឧទ្ធម្ភាគិយៈ** ដែលប្រព្រឹត្តទៅចំណែកខាងលើ ៕

ចប់ទុកនិទ្ទេស

## អដ្ឋកថាតិកនិទ្ទេស អធិប្បាយមាតិកាពួក ៣

សេចក្ដីប្រាកដនៃវដ្ដមូល ៣ ព្រះមានព្រះភាគត្រាស់ទុកដោយអកុសល-មូល ៣ ។ **វិតក្កៈ**ក្នុងធម៌ទាំងឡាយ មានអកុសលវិតក្កៈជាដើម គប្បីជ្រាបថា ត្រាស់ទុកដោយអំណាចនៃការត្រិះរិះ ។ **សញ្ញា** គប្បីជ្រាបថា ត្រាស់ទុកដោយអំណាចនៃសញ្ជាននៈ = ការចងចាំ ។ គប្បីជ្រាបថា ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ជាសភាវៈ ៕

## ទុច្ចរិតនិទ្ទេស អធិប្បាយទុច្ចរិត

ទុច្ចរិតន័យទីមួយ ព្រះមានព្រះភាគទ្រង់ចែកទុកដោយអំណាចនៃកម្មបថ ។ ន័យទីពីរទ្រង់ចែកទុកដោយអំណាចនៃកម្ម ដែលសង្គ្រោះក្នុងអកុសលទាំងអស់; ន័យទី ៣ ទ្រង់ចែកទុកដោយអំណាចនៃចេតនា ដែលកើតឡើងហើយ ។

ក្នុងនិទ្ទេសនៃអាសវៈ ដោយបរិយាយនៃសុត្តន្តៈ ព្រះមានព្រះភាគត្រាស់អាសវៈ ៣ ប៉ុណ្ណោះ ៕

## ឯសនានិទ្ទេស អធិប្បាយការស្វែងរក

ក្នុង **ឯសនានិទ្ទេស** នោះ ពោលដោយសង្ខេប ៖

សេចក្ដីត្រេកអរដោយការស្វែងរកកាម ព្រះមានព្រះភាគត្រាស់ទុកដោយន័យថា **“បណ្ដាឯសនា ៣ នោះ កាមេសនា តើដូចម្ដេច ?”** ជាដើម

គប្បីជ្រាបថា ឈ្មោះថា **កាមេសនា**។ សេចក្តីត្រេកអរដោយការស្វែងរកភព ដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យថា **"សេចក្តីពេញចិត្តក្នុងភព ៣ ណា"** ជាដើម គប្បីជ្រាបថា **ភវេសនា** ។ សេចក្តីឃើញខុស ដែលស្វែងរកព្រហ្មចរិយៈ ដែលឃើញប្រពៃតាមអធ្យាស្រ័យនៃទិដ្ឋិ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ដោយន័យថា **"លោកទៀង"** ជាដើម គប្បីជ្រាបថា **ព្រហ្មចរិយេសនា** ។ ក៏ព្រោះរាគៈ និងទិដ្ឋិហ្នឹងឯង មិនបានឈ្មោះថា ឯសនាតែម្យ៉ាងប៉ុណ្ណោះ, សូម្បីកម្ម ដែលតាំងនៅក្នុងឋានតែមួយជាមួយគ្នានឹងរាគៈ និងទិដ្ឋិនោះ ក៏ឈ្មោះថា **ឯសនា** (ការស្វែងរក) មែនពិត; ព្រោះហេតុដូច្នោះ ដើម្បីសម្តែងនូវឯសនា ការស្វែងរកទាំងនោះ ទើបព្រះមានព្រះភាគជាម្ចាស់ទ្រង់ចែកន័យទី ២ ទុក ។ បណ្តាពាក្យទាំងនោះ ពាក្យថា **"តទេកដ្ឋំ** = តាំងនៅក្នុងឋានតែមួយជាមួយគ្នា" គប្បីជ្រាបថា ជាធម៌ដែលតាំងនៅក្នុងឋានតែមួយជាមួយគ្នា; ឯធម៌ដែលសម្បយុត្តដោយរាគៈ និងទិដ្ឋិនោះ គឺធម៌ដែលតាំងនៅក្នុងឋានតែមួយជាមួយនឹងកាមរាគៈ រមែងប្រព្រឹត្តទៅដល់សត្វទាំងឡាយ អ្នកត្រាច់ទៅក្នុងកាមភពទាំងឡាយប៉ុណ្ណោះ, ចំណែកធម៌ដែលតាំងនៅក្នុង ឋានតែមួយជាមួយគ្នានឹងភវរាគៈ រមែងប្រព្រឹត្តទៅដល់មហាព្រហ្មទាំងឡាយ ។ ក្នុងកាលព្រះយោគាវចរចេញហើយពីសមាបត្តិ ត្រេកអរនូវអង្គឈានចង្រ្កម (ត្រេកអរបណ្តើរចង្រ្កមបណ្តើរ) អកុសលកាយកម្ម រមែងកើត ។ ក្នុងការត្រេកអរ ព្រោះថ្លែងវាចាថា "ឱ ! សុខពិត ឱ ! សុខពិត" អកុសលវចីកម្មរមែងកើត, ក្នុងកាលត្រេកអរដោយចិត្តប៉ុណ្ណោះ ព្រោះមិនធ្វើអង្គនៃកាយ និងអង្គនៃវាចាឱ្យញ័រ ឱ្យកម្រើកទៅ អកុសលមនោកម្មរមែងកើត ។

អកុសលកម្មទាំងនោះ រមែងកើតដល់បុគ្គលអ្នកទៅតាមទិដ្ឋិសូម្បីទាំងអស់ ដោយអំណាចនៃ **អន្តគ្គាហិកទិដ្ឋិ** ប៉ុណ្ណោះ ព្រោះអំណាចនៃការដើរចង្ក្រមជាដើម ៕

## **វិធានិទ្ទេស**

## **អធិប្បាយវិធា[៥៦] គឺការប្រកាន់ខ្លួន**

ការតាំងនៅនៃអាការៈ ក្នុងពាក្យថា "ជនទាំងឡាយ រមែងពោលសរសើរលើកខ្លួនថា 'មានសីលប្រភេទណា, មានបញ្ញាប្រភេទណា"[៥៧] ជាដើម ឈ្មោះថា **វិធា** ។ ការតាំងនៅនៃអាការៈ ក្នុងពាក្យថា "ញាណវត្ថុមានម្យ៉ាង (គឺមិនមានប្លែកគ្នា)"[៥៨] ជាដើម ឈ្មោះថា **កោដ្ឋាសៈ** ។ ការតាំងនៅនៃអាការៈ ក្នុងពាក្យថា "បុគ្គលរមែងមិនកំណត់ក្នុងវិធា គឺការប្រកាន់ខ្លួនជាដើម"[៥៩] ឈ្មោះថា **មានះ** ។ សូម្បីក្នុងទីនេះ មានះនោះឯង ឈ្មោះថា **វិធា** ។ ពិតមែន មានះនោះ ព្រះមានព្រះភាគត្រាស់ហៅថា **វិធា** ព្រោះការតាក់តែងចាត់ចែង ដោយអំ-ណាចនៃការប្រកាន់ខ្លួនថា "**ជាអ្នកប្រសើរ**" ជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា **វិធា** ព្រោះអត្ថថា ការតាំងទុកនូវការប្រកាន់ខ្លួន ។ ព្រោះហេតុដូច្នោះ ពាក្យថា

---

[៥៦] ពាក្យថា **វិធា** សំដៅដល់កិលេសមានច្រើនប្រការ គឺមានះ និងអហង្ការ ឬប្រកាន់ជាចំណែកៗ ហៅថា កោដ្ឋាសៈ ។

[៥៧] សំ. ស.។

[៥៨] អភិ.។

[៥៩] ខុ. ថេរ.។

**“សេយ្យោ ហមស្មី”** នេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា **វិធា** ព្រោះតាំងទុកនូវមានះដែលមានប្រការយ៉ាងច្រើន ដែលកើតឡើងយ៉ាងនេះថា “យើងជាអ្នកប្រ-សើរជាងគេ” ជាដើម ។ សូម្បីក្នុងពីរបទដែលនៅសល់ ក៏ន័យនេះដែរ ៕

## ភយនិទ្ទេស

## អធិប្បាយភយៈ គឺការខ្លាច

ពាក្យថា **“ជាតឹ បដិច្ច ភយំ”** បានដល់ ភ័យដែលកើតឡើង ព្រោះអាស្រ័យការកើត (ជាតិ) ជាបច្ច័យ ។ ពាក្យថា **“ភយានកំ** = ភ័យដែលគួរខ្លាច” នេះ ជានិទ្ទេសនៃអាការៈ ។ ពាក្យថា **“ឆម្ភិតត្តំ** = ភាពតក់ស្លុតនៃចិត្ត” បានដល់សេចក្តីញាប់ញ័រនៃខ្លួន ព្រោះអំណាចនៃភ័យ ។ ពាក្យថា **“លោមហំសោ** = សេចក្តីព្រឺព្រួចនៃរោម” បានដល់ សភាពនៃរោមទាំងឡាយ ជារបស់បះឡើងទៅខាងលើ ។ ព្រះមានព្រះភាគគ្រាទ្រង់សម្តែងសេចក្តីខ្លាចដោយកិច្ច ដោយបទទាំងពីរនេះហើយ ក៏ទ្រង់សម្តែងសេចក្តីខ្លាចដោយសភាវៈ **គឺការភ័យខ្លាចតក់ស្លុតនៃចិត្តទៀត** ៕

## តមនិទ្ទេស អធិប្បាយតមៈ គឺអវិជ្ជា

**អវិជ្ជា** ព្រះមានព្រះភាគត្រាស់ទុកដោយការមាន **វិចិកិច្ឆាជាសីសៈ** ។ ពិតមែន ព្រោះព្រះបាលីថា "សេចក្តីងងឹត សេចក្តីវង្វេង, ឱឃៈ គឺអវិជ្ជា ជាភ័យធំ" ព្រោះហេតុនោះ **អវិជ្ជា** ទើបឈ្មោះថា **តមៈ** ។ តមៈ ព្រះមានព្រះភាគត្រាស់ថា មានវិចិកិច្ឆា (សេចក្តីសង្ស័យ) ជាសីសៈ ជាការសម្តែងដោយងាយតាមអំណាចនៃកាលវែងទាំង ៣ (គឺអតីតអទ្ធានៈ អនាគតអទ្ធានៈ និងបច្ចុប្បន្នអទ្ធានៈ) ។ ក្នុងកាលទាំងនេះ កាលបុគ្គលសង្ស័យថា "ក្នុងអតីតកាលយើងបានជាក្សត្របុហ្ន៎ ឬថា ជាព្រាហ្មណ៍, ជាវេស្សៈ, ជាសូទ្រៈ, ជាមនុស្សខ្មៅ, ជាមនុស្សស,

ជាមនុស្សតឿ និងជាមនុស្សខ្ពស់" ឈ្មោះថា **រមែងសង្ស័យប្រារព្ធអតីតអទ្ធានៈ** (អតីតកាលដ៏យូរអង្វែង) ។ កាលសង្ស័យថា "ក្នុងអនាគតកាល យើងនឹងជាក្សត្រ ឬហ្ន៎, ឬថា នឹងជាព្រាហ្មណ៍, ជាវេស្សៈ, ជាសូទ្រៈ ។ល។ ជាមនុស្សខ្ពស់" ឈ្មោះថា **រមែងសង្ស័យប្រារព្ធអនាគតអទ្ធានៈ** (អនាគតដ៏យូរអង្វែង) ។ កាលសង្ស័យ ថា "ក្នុងពេលឥឡូវនេះ យើងជាក្សត្របុហ្ន៎ ឬថា ជាព្រាហ្មណ៍, ជាវេស្សៈ, ជាសូទ្រៈ" ឬសង្ស័យថា "យើងមានរូបយ៉ាងណា, ឬថា មានវេទនា សញ្ញា សង្ខារ វិញ្ញាណយ៉ាងណា" ឈ្មោះថា **រមែងសង្ស័យប្រារព្ធបច្ចុប្បន្នអទ្ធានៈ** (បច្ចុប្បន្នកាលដ៏យូរអង្វែង) ។

**ក្នុងតមនិទ្ទេសនោះ** បុគ្គលអ្នកជាក្សត្រ ។ល។ ឬថា ជាសូទ្រៈ រមែងមិនមានសូម្បីក៏ពិតមែន, ប៉ុន្តែអ្នកកាន់លទ្ធិថា ជីវៈមានដោយប្រការទាំងពួង ស្តាប់ការបែងចែកវណ្ណៈនៃជីវៈរបស់ក្សត្រជាដើម កាលសង្ស័យ ឈ្មោះថា រមែង

សង្ស័យ យ៉ាងនេះថា "ជីវៈក្នុងខាងក្នុងរបស់យើងយ៉ាងណាហ្ន៎, ជាពណ៌ខៀវឬហ្ន៎ ឬថា ពណ៌លឿង ពណ៌ក្រហម ពណ៌ស, ឬជា ៤ ចំណែក, ឬថាជា ៦ ចំណែក ជា ៨ ចំណែកយ៉ាងណាហ្ន៎" ។

**តិត្ថាយតនានិ** បានដល់ អាយតនៈ គឺពាក្យទូន្មានដែលជាលទ្ធិផ្សេងៗ ។ ម្យ៉ាងទៀត បានដល់ អាយតនៈ គឺពាក្យទូន្មានរបស់តិរ្ថិយទាំងឡាយ ។ ក្នុងអាយតនៈទាំងនោះ **ទិដ្ឋិ ៦២ ឈ្មោះថា តិត្ថៈ គឺកំពង់ជាទីឆ្លង** ។ ទិដ្ឋិទាំងនោះ រមែងគួរ រមែងពេញចិត្ត ដល់ជនទាំងឡាយណា, ជនទាំងឡាយនោះ ឈ្មោះថា ជាតិរ្ថិយ ។ អត្ថនៃអាយតនៈលោកពោលទុកហើយ ក្នុងកាលក្រោយនោះឯង ។ ក៏ព្រោះអាយតនៈទាំងនោះ ជាគតិនៃទិដ្ឋិទាំងពួង កាលកើតឡើង រមែងកើតឡើងក្នុងឋានទាំង ៣ នេះប៉ុណ្ណោះ [៦០], សូម្បីកាលប្រជុំ ក៏រមែងប្រជុំប្រមូលមកក្នុងឋានទាំងនេះនោះឯង, ព្រោះថាអាយតនៈ គឺពាក្យទូន្មានរបស់តិរ្ថិយទាំងនោះប៉ុណ្ណោះ ជាមូលហេតុ ក្នុងសេចក្តីជាផ្លូវដំណើរទៅនៃទិដ្ឋិ, ព្រោះហេតុដូច្នោះ **តិត្ថៈ** ដែលជាហេតុទាំងនោះ ទើបឈ្មោះថា **អាយតនៈ** និងព្រោះអត្ថមានពាក្យថា ទិដ្ឋិទាំងនោះ ជាសភាវៈកើតឡើងឯងផង ទើបឈ្មោះថា **តិត្ថាយតនៈ**, ដោយអត្ថនោះឯង សូម្បីពាក្យថា អាយតនៈរបស់តិរ្ថិយទាំងឡាយ ក៏ឈ្មោះថា តិត្ថាយតនៈ ។ ពាក្យថា **បុរិសបុគ្គលោ** បានដល់ សត្វ ។ ម្យ៉ាងទៀត សូម្បីនរកណាៗ ហៅថា បុរសក្តី

[៦០] ពាក្យថា **ឋានទាំង ៣** គឺ ១. វាទៈថា ព្រោះបានធ្វើហេតុទុកក្នុងកាលមុន ២. វាទៈថា ព្រោះហេតុ គឺអ្នកជាធំសាងឱ្យ ៣. វាទៈថា ដោយមិនមានហេតុ មិនមានបច្ច័យ ។

បុគ្គលក្តី រមែងពោលបានថា ជាសត្វនោះឯង ដោយពិត ។ កថានេះ ឈ្មោះថា **សម្មុតិកថា** ។ បុគ្គលណារមែងដឹងសម្មុតិកថានេះបាន ដោយប្រការណា, ព្រះមានព្រះភាគរមែងត្រាស់ពាក្យនោះ ដោយប្រការនោះ ។ ពាក្យថា **“បដិសំវេទេតិ** = រមែងសោយវេទនា” បានដល់ រមែងដឹងវត្ថុដែលកើតឡើងក្នុងសន្តានរបស់ខ្លួន ទាំងរមែងធ្វើ ឬរមែងសោយវេទនា ដែលខ្លួនដឹងហើយនោះ ។ ពាក្យថា **“បុព្វេ កតហេតុ** = ព្រោះធ្វើហេតុទុកក្នុងកាលមុន” បានដល់ ព្រោះហេតុដែលខ្លួនធ្វើ ហើយក្នុងកាលមុន អធិប្បាយថា គេរមែងសោយវេទនា ដោយកម្មប្បច្ច័យដែលខ្លួនធ្វើហើយក្នុងកាលមុននោះ ៕

## និគណ្ឋសម័យ លទ្ធិនៃនិគ្រន្ថ ឬ ជីអាក្រាត

ក៏ពួកនិគ្រន្ថទាំងនោះ មានប្រក្រតីពោលយ៉ាងនេះ គឺពោលបដិសេធការសោយកម្ម និងការសោយកិរិយា តែរមែងទទួលការសោយវិបាក ( ផលរបស់កម្ម) តែម្យ៉ាងប៉ុណ្ណោះ ។ ទាំងក្នុងបណ្តាអាពាធ ៨ យ៉ាង [៦១] មានអាពាធដែលកើតពីទឹក

---

[៦១] អាពាធ ៨ យ៉ាង គឺ

១.បិត្តិសមុដ្ឋានា អាពាធា អាពាធកើតពីទឹកប្រមាត់ជាសមុដ្ឋាន

២.វាតសមុដ្ឋានា អាពាធា អាពាធកើតពីខ្យល់ជាសមុដ្ឋាន

៣.សេម្ហសមុដ្ឋានា អាពាធា អាពាធកើតពីស្លេស្មជាសមុដ្ឋាន

៤.សន្និបាតសមុដ្ឋានា អាពាធា អាពាធកើតពីសន្និបាត( ប្រជុំ) ជាសមុដ្ឋាន

ប្រមាត់ជាសមុដ្ឋានជាដើម គេបដិសេធអាពាធ ៧ យ៉ាង រមែងទទួល (អាពាធ) តែមួយ គឺអាពាធទី ៨ ប៉ុណ្ណោះ ។ ក្នុងកម្ម ៣ [៦២] មានទិដ្ឋធម្មវេទនីយកម្មជាដើម បដិសេធកម្ម ២ យ៉ាង រមែងទទួលអបរាបរវេទនីយកម្មតែម្យ៉ាងប៉ុណ្ណោះ ។ ក្នុងចេតនា ៤ យ៉ាង ពោលគឺកុសល អកុសល វិបាក និងកិរិយា រមែងទទួលចំពោះតែចេតនាដែលជាវិបាកប៉ុណ្ណោះ ។

ពាក្យថា **"ឥស្សរនិម្មានហេតុ"** បានដល់ ឈ្មោះថា មានព្រះជាធំសាងឱ្យជាហេតុ, អធិប្បាយថា អ្នកជាធំ គឺព្រះព្រហ្ម ឬបជាបតី និមិត្តវត្ថុនោះឡើង ទើបសោយបាន ៕

## ព្រាហ្មណសម័យ លទ្ធិនៃព្រាហ្មណ៍

ពិតមែន លទ្ធិនៃព្រាហ្មណ៍នេះ ជាការប្រកបអធិប្បាយ (ឋាន) ទាំង ៣ នេះ ថាដូច្នេះ ៖

វេទនាទាំង ៣ នេះ ដែលអ្នកណា។ ឈ្មោះថា មិនអាចដើម្បីសោយវេទនាបាន ព្រោះហេតុដែលខ្លួនឯងធ្វើទុកហើយ ឬព្រោះហេតុដែលបុគ្គលដទៃធ្វើឱ្យក្នុង

---

**៥.ឧតុបរិណាមជា អាពាធា** អាពាធកើតពីការប្រែប្រួលរដូវជាសមុដ្ឋាន

**៦.វិសមបរិហារជា អាពាធា** អាពាធកើតពីការរក្សារាងកាយមិនសមគួរជាសមុដ្ឋាន

**៧.ឱបក្កមិកា អាពាធា** អាពាធកើតពីការធ្វើសេចក្ដីព្យាយាមខ្លាំងក្លា ជាសមុដ្ឋាន

**៨.កម្មវិបាកជា អាពាធា** អាពាធកើតពីផលរបស់កម្មជាសមុដ្ឋាន ។

[៦២] **កម្ម ៣ យ៉ាង** គឺ ទិដ្ឋធម្មវេទនីយកម្ម ឧបបជ្ជវេទនីយកម្ម និងអបរាបរវេទនីយកម្ម ។

បច្ចុប្បន្ន ឬថា ព្រោះហេតុដែលខ្លួនធ្វើទុកហើយក្នុងកាលមុន ឬក៏ព្រោះមិនមានហេតុ មិនមានបច្ច័យ, តែថា បុគ្គលរមែងសោយវេទនាទាំងនេះបាន ព្រោះហេតុដែលអ្នកជាធំនិមិត្តឱ្យប៉ុណ្ណោះ ។

ម្យ៉ាងទៀត ពួកព្រាហ្មណ៍ទាំងនោះ មានប្រក្រតីពោលយ៉ាងនេះ គឺមិនពោលទទួលក្នុងអាពាធ ៨ យ៉ាង ដែលពោលមកហើយសូម្បីត្រឹមតែមួយទេ ទាំងរមែងពោលហាម សូម្បីអាពាធទាំងអស់ ។ ក្នុងកោដ្ឋាសៈ (គឺធម៌ជាចំណែកមួយៗ) សូម្បីទាំងអស់ មានទិដ្ឋធម្មវេទនីយកម្មជាដើម ក៏ដូចគ្នា មិនពោលទទួលសូម្បីតែម្យ៉ាងទេ រមែងបដិសេធសូម្បីទាំងអស់ ។

ពាក្យថា **"អហេតុអប្បច្ចយា"** អធិប្បាយថា ព្រោះវៀរហេតុ និងបច្ច័យ រមែងសោយវេទនាដោយបដិសេធហេតុ ៕

## អាជីវកសម័យ លទ្ធិនៃអាជីវក

សូម្បីអាជីវកទាំងនេះ មានប្រក្រតីពោលយ៉ាងនេះ គឺមិនពោលទទួលហេតុទាំងឡាយតាមដែលពោលហើយ និងក្នុងអាពាធទាំងឡាយមានព្យាធិជាដើម សូម្បីត្រឹមតែម្យ៉ាង រមែងបដិសេធទាំងអស់មែនពិត ។

បលិពោធទាំងឡាយ ឈ្មោះថា **ធម៌ជាគ្រឿងកង្វល់** ។ ពាក្យថា **"កិលេសជាគ្រឿងកង្វល់ គឺរាគៈ"** បានដល់ រាគៈកំពុងកើតឡើង រមែងចងព័ន្ធ រមែងឱ្យសត្វកង្វល់, ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ហៅរាគៈថា កិលេសជាគ្រឿងកង្វល់; សូម្បីក្នុងទោសៈ និងមោហៈ ក៏ន័យនេះដែរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **“អង្គណានិ** = ទីទួល” ដូច្នេះ ៖

ភូមិប្រទេសណា ក្នុងព្រះបាលីដែលមានមកហើយយ៉ាងនេះថា “បុគ្គលរមែងមិនជួបទឹក ក្នុងទីដែលជាទួលនោះ ទីនោះទើបឈ្មោះថា ទួល” [៦៣] ។ កិលេសណាៗ មានមកក្នុងព្រះបាលីថា “បុគ្គលរមែងព្យាយាមលះកិលេសនុ៎ះឯង ដែលត្រឹមតែដូចជាធូលី ឬថា ត្រឹមតែដូចជាទួល” [៦៤] ព្រោះហេតុនោះ **កិលេសនោះៗ ទើបឈ្មោះថា ទឹកភក់ ឬភក់ស្អិត** ។ កិលេសមានប្រការផ្សេងៗ ក្នុងអាគតស្ថានថា **“សង្គណោ សមានោ”** [៦៥] កិលេសនោះ ឈ្មោះថា **តិព្វកិលេស** គឺកិលេសដែលមានកម្លាំងខ្លាំង ។ សូម្បីក្នុងទីនោះ ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុងពាក្យថា កិលេសដូចទីទួល; ដោយហេតុនោះនុ៎ះឯង ទើបត្រាស់ថា **“កិលេសដូចទីទួល គឺរាគៈ”** ជាដើម ។

ពាក្យថា **“មលានិ”** បានដល់ កិលេសជាហេតុនៃសេចក្ដីសៅហ្មង ។ ពាក្យថា **“មលំ** = គឺរាគៈ” អធិប្បាយថា រាគៈកាលកើតឡើង រមែងធ្វើចិត្តឱ្យសៅហ្មង, រមែងធ្វើចិត្តឱ្យកាន់យកនូវសេចក្ដីមួហ្មង, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហៅរាគៈថា **“មលំ”** ។ សូម្បីកិលេសទាំងពីរដែលនៅសល់ក្រៅពីនេះ ក៏ន័យនេះដែរ ៕

---

[៦៣] ខុ. ជា. ។

[៦៤] ម. មូ., អំ. ទសក. ។

[៦៥] ម. មូ. ។

## ទិសមនិទ្ទេស អធិប្បាយការធ្វើមិនឱ្យស្មើ គឺកិលេស

ក៏ព្រោះសត្វទាំងឡាយ រមែងតក់ស្លុតក្នុងកិលេសទាំងឡាយ មានរាគៈជាដើម និងក្នុងទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម, ក៏ឯសត្វទាំងឡាយជំពប់ភ្លាត់ដួលហើយ រមែងធ្លាក់ (ឃ្លាត) ទៅពីព្រះពុទ្ធសាសនាខ្លះ ពីសុគតិខ្លះ, ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា "**សេចក្តីមិនស្មើ គឺរាគៈ**" ជាដើម ព្រោះការជំពប់ហើយ ក៏ធ្លាក់ទៅជាហេតុ ៕

## អគ្គិនិទ្ទេស អធិប្បាយអគ្គិ គឺភ្លើង

ពាក្យថា "**អគ្គិ** គឺភ្លើង" ឈ្មោះថា អគ្គិ ព្រោះអត្ថថា ដុតបំផ្លាញ ។

ពាក្យថា "**រាគគ្គិ** = ភ្លើង គឺរាគៈ" អធិប្បាយថា រាគៈកាលកើតឡើង រមែងដុតបំផ្លាញ គឺញុំាងសត្វឱ្យឆេះ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **អគ្គិ** (ភ្លើង គឺរាគៈ); សូម្បីទោសៈ និងមោហៈ ក៏ន័យនេះដែរ ។ ក្នុងអគ្គិនិទ្ទេសនោះ មានរឿងជាឧទាហរណ៍ដូច្នេះ ៖

## រឿងការដុតបំផ្លាញរបស់ភ្លើង គឺរាគៈ

បានឮថា ភិក្ខុនីក្រមុំមួយរូប ទៅកាន់រោងឧបោសថក្នុងវិហារ ឈ្មោះថា **ចិត្តលបព៌ត** ហើយឈរមើលអ្នករក្សាទ្វារ, លំដាប់នោះ រាគៈ គឺសេចក្តីត្រេកអរខាងក្នុងរបស់នាងកើតឡើង, នាងត្រូវភ្លើង គឺរាគៈនោះឯង ឆេះហើយ ក៏ធ្វើកាលៈ (ស្លាប់) ទៅ ។ ពួកភិក្ខុនីទាំងឡាយដើរទៅ ពោលថា "ភិក្ខុនីក្រមុំនេះឈរ,

លោកចូរហៅមក” ; ភិក្ខុនីមួយរូបដើរទៅចាប់ដៃរបស់ភិក្ខុនីក្រមុំនោះ ព្រមនឹងការពោលថា “ព្រោះហេតុអ្វី ទើបនាងឈរ” ; ភិក្ខុនីក្រមុំនោះ គ្រាន់តែដៃរបស់ភិក្ខុនីក្រមុំម្យ៉ាងទៀត ពាល់ត្រូវហើយប៉ុណ្ណោះ ក៏ដួលចុះទៅ ។

នេះជារឿងនៃការដុតបំផ្លាញរបស់រាគៈជាមុនសិន ។

**ចំណែកភ្លើង គឺទោសៈ** បណ្ឌិតគប្បីជ្រាបដូចទេពមួយពួកដែលឈ្មោះថា **មនោបទោសិកៈ** ព្រោះការដុតបំផ្លាញរបស់ទោសៈ ទើបត្រូវចុតិ ។ ឯភ្លើង គឺមោហៈនោះ គប្បីជ្រាបដូចទេពមួយពួក ដែលឈ្មោះថា **ខិឌ្ឌាបទោសិកៈ** ព្រោះការដុត បំផ្លាញរបស់មោហៈ ក៏ត្រូវចុតិ ។ ពិតមែន សេចក្ដីវង្វេងភ្លេចសតិ រមែងមានដល់ ទេពឈ្មោះថា ខិឌ្ឌាបទោសិកៈ ដោយអំណាចនៃមោហៈ, ព្រោះហេតុដូច្នោះ កាលទេពទាំងនោះ ញុំាងវេលាបរិភោគអាហារឱ្យហួសទៅហើយ លោកក៏រមែងធ្វើកាលៈ; ដោយអំណាចនៃសេចក្ដីរីករាយនោះ ។

ពាក្យថា **“ទឹកអម្ចត់”** បានដល់ ទឹកដែលឥតតម្លៃមិនមានរស ។ ធម៌ដែលប្រណីតដែលមានឱជៈ សូម្បីត្រឹមតែម្យ៉ាង ក្នុងកិលេសទាំងឡាយមានរាគៈជាដើមផង ក្នុងទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើមផង មិនមានទេ, ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា **ទឹកចត់ គឺរាគៈជាដើម** ។ ទិដ្ឋិ (ការឃើញ ខុស) ដែលសម្បយុត្តដោយសេចក្ដីត្រេកអរ ឈ្មោះថា **អស្សាទទិដ្ឋិ** ។ ពាក្យថា **“កាមទាំងឡាយមិនមានទោស”** បានដល់ សមណព្រាហ្មណ៍ខាងក្រៅរមែងពោលថា “ទោសក្នុងការសេពវត្ថុកាមទាំងឡាយ រមែងមិនមានដោយកិលេសកាម” ។ ពាក្យថា **“ធាតព្យត្តំ”** បានដល់ ការបរិភោគ ការផឹក គឺការលេបចូល

ទៅ; ពិតមែន សមណព្រាហ្មណ៍នោះមានប្រក្រតីពោលយ៉ាងនេះ ទើបបរិភោគកិលេសកាម ក្នុងវត្ថុកាមទាំងឡាយ ដូចបុគ្គលបរិភោគ (នូវអាហារ) ។ ការឃើញខុសថា មានអត្តា (សេចក្តីឃើញខុសដែលប្រព្រឹត្តទៅតាមអត្តា) ឈ្មោះថា **អត្តានុទិដ្ឋិ** (ដូចឃើញរូបជាខ្លួន ឬឃើញខ្លួនមានរូប ឃើញរូបក្នុងខ្លួន ឃើញខ្លួនក្នុងរូបជាដើម) ។

ទិដ្ឋិដ៏លាមក ឈ្មោះថា **មិច្ឆាទិដ្ឋិ** (ដូចយល់ឃើញថា ទានដែលបុគ្គលឱ្យហើយ មិនមានផល ការបូជាមិនមានផលជាដើម) ។

ឥឡូវនេះ ដើម្បីសម្តែងសេចក្តីក្នុង**អស្សាទនិទ្ទេសនោះ** តាមលំដាប់ទើបព្រះមានព្រះភាគត្រាស់ថា ព្រោះសស្សតទិដ្ឋិជាទី ១ គឺជាអស្សាទទិដ្ឋិ, សក្កាយទិដ្ឋិជាទី ២ គឺជាអត្តានុទិដ្ឋិ និងឧច្ឆេទទិដ្ឋិជាទី ៣ គឺមិច្ឆាទិដ្ឋិ, ព្រោះហេតុដូច្នោះទើបត្រាស់ពាក្យថា **សស្សតទិដ្ឋិ អស្សាទទិដ្ឋិ** ជាដើម ដើម្បីសម្តែងនូវសេចក្តីនោះ ។

**និទ្ទេសនៃអរតិ** គឺសេចក្តីមិនត្រេកអរ និងនិទ្ទេសនៃវិហេសា គឺសេចក្តីបៀតបៀន មានអត្ថាធិប្បាយតាមដែលពោលហើយនោះឯង ។

ការប្រព្រឹត្តមិនជាធម៌ ឈ្មោះថា **អធម្មចរិយា**, អធិប្បាយថា ការធ្វើខុស; ការប្រព្រឹត្តមិនស្មើ ឈ្មោះថា **វិសមចរិយា**, ម្យ៉ាងទៀត ឈ្មោះថា **វិសមចរិយា** ព្រោះប្រព្រឹត្តធ្វើកម្មដែលមិនស្មើ ។

**និទ្ទេសនៃភាពជាអ្នកប្រដៅលំបាក និងនិទ្ទេសនៃភាពជាអ្នកមានមិត្តអាក្រក់** មានអត្ថាធិប្បាយតាមដែលពោលមកហើយ ។ សញ្ញាទាំងឡាយដែល

ប្រព្រឹត្តទៅក្នុងសេចក្តីផ្សេងគ្នា ឈ្មោះថា **នានត្តសញ្ញា** ព្រោះការប្រព្រឹត្តទៅក្នុងនិមិត្តារម្មណ៍នៃបុថុជ្ជន ។ ម្យ៉ាងទៀត ព្រោះកាមសញ្ញាតែម្យ៉ាង, ទាំងព្យាបាទ-សញ្ញាជាដើម ក៏ម្យ៉ាង, ព្រោះហេតុដូច្នោះ សូម្បីពាក្យថា "សញ្ញាដែលជាសភាវៈផ្សេងៗ គ្នា" ទើបឈ្មោះថា **នានត្តសញ្ញា** ៕

## កោសជ្ជនិទ្ទេស អធិប្បាយការខ្ជិល

ការប្រព្រឹត្តទន់ខ្សោយ ការមិនអាចប្រកបសេចក្តីព្យាយាម ដោយការចម្រើនកុសលធម៌របស់អ្នកមានចិត្តធ្លាប់ស្និទ្ធស្នាលក្នុងកាមគុណទាំង ៥ ឈ្មោះថា **កោសជ្ជៈ** (គឺសេចក្តីខ្ជិលច្រអូស), បណ្ឌិតគប្បីជ្រាបភាពដែលបុគ្គលជាអ្នកប្រមាទហើយ ដោយអំណាចនៃសេចក្តីស្រវឹង ឈ្មោះថា **បមាទៈ** (គឺសេចក្តីប្រមាទ) ។

**និទ្ទេសនៃអសន្តុដ្ឋិ** (គឺមិនសន្តោស) មានសេចក្តីតាមដែលពោលហើយ ។

## អនាទរិយនិទ្ទេស អធិប្បាយការមិនអើពើ

ភាវៈនៃបុគ្គលជាអ្នកមិនអើពើ ដោយអំណាចនៃសេចក្តីមិនអើពើ ចំពោះឱវាទ (ការទូន្មាន) ឈ្មោះថា **អានាទរិយៈ** (គឺសេចក្តីមិនអើពើ) ។ អាការនៃសេចក្តីមិនអើពើ ឈ្មោះថា **សភាពដែលមិនអើពើ** ។ ភាពជាអ្នកមិនគោរពឈ្មោះ ថា **អគារវតា** ព្រោះអត្ថថា មិនអាស្រ័យរួមនឹងអ្នកគួរគោរព ។ ឈ្មោះថា **សេចក្តី មិនជឿស្តាប់** ព្រោះអត្ថថា មិននៅអាស្រ័យនឹងអ្នកជាប្រធាន ។ ពាក្យថា "**អនទ្ធា** = សេចក្តីមិនកាន់យក" បានដល់ ការមិនទទួលឱវាទ ។ ពាក្យថា

**"អនន្វាយនា"** បានដល់ អាការដែលមិនអើពើ ។ ភាវៈនៃបុគ្គលជាអ្នកដំណើរទៅដោយសេចក្ដីមិនអើពើ ឈ្មោះថា **អនន្វាយិតត្តំ** = សេចក្ដីពេញចិត្តផ្លូវជំទាស់ ។ ភាវៈនៃបុគ្គល អ្នកមិនមានសីល ឈ្មោះថា **អសីល្យំ** = ទ្រុស្ដសីល ។ ពាក្យថា **"អចិត្តិការោ"** បានដល់ ការមិនធ្វើសេចក្ដីកោតក្រែង ។ ភាវៈនៃបុគ្គលជាអ្នកមិនមានសទ្ធា ឈ្មោះថា **ការមិនមានសទ្ធា** ។ អាការនៃភាពជាអ្នកមិនមានសទ្ធា ឈ្មោះថា **កិរិយាមិនជឿស្ដាប់** ។ ការមិនកាន់យក ព្រោះមិនទុកចិត្ត មិនចូលទៅជិត ឈ្មោះថា **កិរិយាដែលមិនដាក់ចិត្តជឿ** ។ ឈ្មោះថា **សេចក្ដីមិនជ្រះថ្លាក្រៃលែង** ព្រោះអត្ថថា មិនជ្រះថ្លា ។

ពាក្យថា **"អវទញ្ញុតា** = សេចក្ដីមិនឧបត្ថម្ភ" បានដល់ អ្នកមិនដឹងដល់ពាក្យថា "សូមលោកចូរឱ្យទាន លោកចូរធ្វើបុណ្យ" ព្រោះអំណាចនៃសេចក្ដីកំណាញ់ដ៏ស្វិត ។

ក្នុងសេចក្ដីថា **"ពុទ្ធា ច ពុទ្ធសាវកា ច** = ព្រះពុទ្ធ និងសាវ័ករបស់ព្រះពុទ្ធ" នោះ សូម្បីព្រះបច្ចេកពុទ្ធ លោកក៏កាន់យកសព្ទថា **ពុទ្ធៈ** នុ៎ះឯង ។ ភាពជាអ្នកមិនត្រូវការទៅកាន់ទីជិតនៃព្រះអរិយៈទាំងនោះ ឈ្មោះថា **អសមេតុកម្យតា** = សេចក្ដីមិនត្រូវការសមាគមនឹងព្រះអរិយៈទាំងឡាយ ។ ពាក្យថា **សេចក្ដីមិនត្រូវការនឹងស្ដាប់... នូវព្រះសទ្ធម្ម"** បានដល់ ពោធិបក្ខិយធម៌ ៣៧ ឈ្មោះថា **ព្រះសទ្ធម្ម**, ភាពជាអ្នកមិនត្រូវការ ដើម្បីស្ដាប់នូវព្រះធម៌នោះ ភាពជាអ្នកមិនសិក្សាព្រះធម៌ ឈ្មោះថា **អនុគ្គហេតុកាម្យតា** = សេចក្ដីមិនត្រូវការនឹងរៀន ។ ភាពជាអ្នកគិត ប្រណាំងប្រជែងឈ្មោះថា **ភាពជាអ្នកមិនត្រូវការទ្រទ្រង់ធម៌**

ទុក ក៏កាលពោលដោយអត្ថ ភាពជាអ្នកមានចិត្តគិតប្រណាំងប្រជែង រមែងមាន ព្រោះហេតុណា ព្រោះហេតុនោះ ដើម្បីសម្ដែងអត្ថនោះ ព្រះមានព្រះភាគទើប ត្រាស់ថា "បណ្ដាបទ ទាំងនោះ ការគិតប្រណាំងប្រជែង តើដូចម្ដេច ?" ជាដើម ។ ក្នុងសេចក្ដីនោះ ការប្រណាំងប្រជែងរមែងមាន ដោយអំណាចនៃការតិះដៀល; ការប្រណាំងប្រជែង កើតឡើងញយៗ ឈ្មោះថា **ការគិតប្រណាំងប្រជែង រឿយៗ**; អាការនៃការ ប្រណាំងប្រជែងឈ្មោះថា ការគិតប្រណាំងប្រជែង ។ កិរិយាប្រណាំងប្រជែងរឿយៗ ឈ្មោះថា អាការប្រណាំងប្រជែងរឿយៗ; ភាវៈ នៃបុគ្គលជាអ្នកគិតប្រណាំង ប្រជែងរឿយៗ ឈ្មោះថា សភាពដែលគិតប្រណាំង ប្រជែងរឿយៗ ។

ពាក្យថា **"សេចក្ដីមើលងាយ"** បានដល់ ការបង្ខូចកេរ្តិ៍ឈ្មោះ ។ ពាក្យ ថា **"សេចក្ដីប្រមាថ"** បានដល់ ការសំឡឹងឃើញទោសដែលអាក្រក់ ។ ការ សម្ដែងកិរិយាឱ្យកើតសេចក្ដីអៀនខ្មាស (បញ្ឈឺចិត្ត) ឈ្មោះថា សេចក្ដីពេបជ្រាយ ។ ភាព ជាអ្នកស្វែងរកសេចក្ដីខ្វះខាត ឈ្មោះថា ការចាំស្វែងរកទោស ។ម្យ៉ាងទៀត បុគ្គលណា រមែងស្វែងរកនូវកំហុស ព្រោះហេតុនោះ បុគ្គលនោះទើបឈ្មោះថា អ្នក ចាំស្វែងរកទោស ។ ភាវៈនៃបុគ្គលអ្នកចាំស្វែងរកទោសនោះ ឈ្មោះថា ការចាំ ស្វែងរកទោស ។ ពាក្យថា **"អយំ វុច្ចតិ"** សេចក្ដីថា ក៏ភាពជាអ្នកមានចិត្តគិត ប្រណាំងប្រជែងនេះ មានការតាមមើលទោសរបស់បុគ្គលដទៃ ជាលក្ខណៈ ទើបព្រះ មានព្រះភាគត្រាស់ហៅថា ភាពជាអ្នកមានចិត្តគិតប្រណាំងប្រជែង ។ បុគ្គលណា ប្រកបហើយ ដោយលក្ខណៈ គឺតាមមើលទោសរបស់អ្នកដទៃណានោះ ប្រៀបដូច

ជាងដេរសំពត់ លាសំពត់ចេញហើយ ក៏ត្រូវតមើលសំពត់ធ្លុះនោះឯង យ៉ាងណា, បុគ្គលមានចិត្តគិតប្រណាំងប្រជែង ក៏ដូច្នោះដែរ; ការលុបគុណសម្បត្តិទាំងពួង របស់អ្នកដទៃ ហើយតាំងនៅក្នុងវត្ថុដែលមិនជាគុណទាំងឡាយប៉ុណ្ណោះ ។

ពាក្យថា **“អយោនិសោមនសិការោ”** បានដល់ ការធ្វើទុកក្នុងចិត្តដោយឧបាយដែលមិនប្រពៃ ។ ពាក្យថា **“អនិច្ចេ និច្ចំ”** អធិប្បាយថា មនសិការយ៉ាងនេះ គឺមនសិការក្នុងវត្ថុដែលមិនទៀងថា “វត្ថុនេះជារបស់ទៀង” ។ សូម្បីក្នុងពាក្យថា **“ទុក្ខេ សុខំ”** ជាដើម ក៏ន័យនេះដែរ ។ ពាក្យថា **“សច្ចវិប្បដិកូលេនវា”** បានដល់ មិនមនសិការអនុលោមតាមសច្ចៈទាំង ៤ ។ ពាក្យថា **“ចិត្តស្សអាវដ្ដនា”** ជាដើម សូម្បីទាំងអស់ជាវេវចនៈរបស់អាវជ្ជនចិត្តនុ៎ះឯង ។ ពិតមែន អាវជ្ជនៈ ឈ្មោះថា **អាវដ្ដនា**នៃចិត្ត ព្រោះញ៉ាំងភវង្គចិត្តឱ្យឃ្លាតទៅ ។ ឈ្មោះថា **ការផ្លាស់ទៅ** ព្រោះរមែងត្រឡប់ទៅក្នុងខាងក្រោយ (ភវង្គ) ។ ចិត្តណា រមែងនឹកដល់អារម្មណ៍ ព្រោះហេតុនោះ ចិត្តនោះ ឈ្មោះថា **អាភោគៈ** ។ ចិត្តណា រមែងប្រមូលមកនូវអារម្មណ៍ដទៃ ក្រៅពីអារម្មណ៍របស់ភវង្គ ព្រោះហេតុនោះ ចិត្តនោះទើបឈ្មោះថា **សមន្នាហារៈ** ។

កាលអាវជ្ជនចិត្តកើតឡើង ធ្វើខ្លួនឱ្យចងព័ន្ធហើយ ៗ នូវអារម្មណ៍នោះនុ៎ះឯង ទុកក្នុងចិត្ត ព្រោះហេតុនោះ អាវជ្ជនចិត្តនោះ ទើបឈ្មោះថា **មនសិការ** ។ ពាក្យថា **“រមែងធ្វើទុកក្នុងចិត្ត”** បានដល់ រមែងតាំងទុកក្នុងចិត្ត ។ ពាក្យថា **“អយំ វុច្ចតិ”** អធិប្បាយថា ធ្វើទុកក្នុងចិត្តដោយឧបាយដែលមិនប្រពៃ គឺមនសិការខុសផ្លូវ ជាលក្ខណៈនេះ ព្រះមានព្រះភាគត្រាស់ហៅថា **អយោនិសោមន-**

សិការ ។ បុគ្គលរមែងមិនអាចដើម្បីពិចារណាសច្ចៈទាំងឡាយ មានទុក្ខសច្ចជាដើម តាមសេចក្តីពិត បានដោយអយោនិសោមនសិការនោះ ៕

## ខុម្មគ្គសេវនានិទ្ទេស អធិប្បាយការសេពផ្លូវខុស

ឈ្មោះថា **ការសេព** ដោយអំណាចនៃការសេពផ្លូវដែលខុសយ៉ាងណា ព្រះមានព្រះភាគត្រាស់ថា ការសេពផ្លូវខុសដូច្នេះ ដើម្បីសម្តែងផ្លូវខុសនោះ ទើបទ្រង់ធ្វើទុតិយបុច្ឆាថា “**បណ្តាបទទាំងនោះ ផ្លូវខុស តើដូចម្តេច ?**” ។ ពាក្យដែលនៅសល់ក្នុងបទទាំងពួង មានអត្ថងាយទាំងអស់នុ៎ះឯង ៕

**ចប់តិកនិទ្ទេស**

## អដ្ឋកថាចតុក្កនិទ្ទេស អធិប្បាយមាតិកាពួក ៤

ពាក្យថា “*តណ្ហាកាលនឹងកើត រមែងកើតព្រោះហេតុនៃចីវរ*” ជាដើម អធិប្បាយថា តណ្ហារមែងកើតឡើង ព្រោះចីវរជាហេតុយ៉ាងនេះថា “យើងនឹងបាន ចីវរដែលពេញចិត្ត ក្នុងទីណា១ ” ជាដើម ។ ឥតិសព្ទ ក្នុងពាក្យថា “**ឥតិភវាភវហេតុ**” នេះ ជានិបាតចុះក្នុងអត្ថនៃនិទស្សនៈ (គឺឧទាហរណ៍), អធិប្បាយថា តណ្ហាកាលនឹងកើត រមែងកើតព្រោះចីវរជាហេតុ យ៉ាងណា, តណ្ហានោះ សូម្បីកាលនឹងកើត ក៏រមែងកើតព្រោះវត្ថុដទៃដែលប្រណីត និងប្រណីតក្រៃលែងជាងហេតុដូច្នោះ ។ ក៏វត្ថុទាំងឡាយ មានប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើម ដែលប្រណីតនិងប្រណីតក្រៃលែងជាង ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុងពាក្យថា “**ភវា**

**ភវោ"** នេះ; ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងអរិយវង្ស ៤ តាមលំដាប់ ដើម្បីប្រយោជន៍ដល់ការលះនូវការកើតឡើងនៃតណ្ហា ( តណ្ហុប្បាទា ៤) ទាំងនេះ ៕

## អគតិគមនៈ = លំអៀង

ពាក្យថា **"ឆន្ទាគតឹ គច្ឆតិ"** អធិប្បាយថា បុគ្គលរមែងលំអៀង គឺរមែងធ្វើវត្ថុដែលមិនគួរធ្វើ ព្រោះឆន្ទៈ គឺព្រោះសេចក្ដីស្រឡាញ់ ។ សូម្បីក្នុងបទដទៃៗក៏ន័យនេះដែរ ។ ក្នុងអគតិទាំងនោះ បុគ្គលណារមែងធ្វើវត្ថុដែលមិនមែនម្ចាស់របស់ឱ្យជាម្ចាស់ ដោយអំណាចនៃសេចក្ដីស្រឡាញ់ពេញចិត្តថា "បុគ្គលនេះជាមិត្តរបស់ខ្ញុំ ឬជាសម្លាញ់ (សន្ទិដ្ឋោ) ឬថាជាអ្នករួមស៊ីរួមដេក (សម្ភត្តៈ) ឬក៏ជាញាតិរបស់ខ្ញុំ ឬក៏ថា បុគ្គលនេះរមែងឱ្យតម្លៃ (សំណូក) លើសនេះដល់ខ្ញុំ", បុគ្គលនេះ ឈ្មោះថា រមែងលំអៀងព្រោះស្រឡាញ់ (ឆន្ទាគតិ) ។

បុគ្គលណា រមែងធ្វើវត្ថុដែលជារបស់មានម្ចាស់ ឱ្យជារបស់មិនមានម្ចាស់របស់ដោយអំណាចនៃបកតិវេរា (គឺការមិនពេញចិត្តគ្នាមកពីមុន) ឬថា ដោយអំណាចនៃសេចក្ដីក្រោធ ដែលកើតឡើងក្នុងខណៈនោះនុ៎ះឯងថា "អ្នកជាសត្រូវរបស់យើង" បុគ្គលនេះឈ្មោះថា **រមែងលំអៀងព្រោះសេចក្ដីមិនពេញចិត្តគ្នា** (ទោសាគតិ) ។

បុគ្គលណា ពោលពាក្យណា រមែងធ្វើវត្ថុដែលមានម្ចាស់ ឱ្យទៅជាវត្ថុមិនមានម្ចាស់ ព្រោះសេចក្ដីល្ងង់ខ្លៅ ព្រោះជាមនុស្សរងងឹត, បុគ្គលនេះ ឈ្មោះថា

**មោហាគតិ** = **រមែងលំអៀងព្រោះវង្វេង** ។ បុគ្គលណា មានសេចក្ដីខ្លាចថា "អ្នកនេះ ជារាជវល្លភៈ ឬអ្នកនេះប្រព្រឹត្តមិនត្រឹមត្រូវ ឬថា បុគ្គលនេះនឹងគប្បីធ្វើសេចក្ដីវិនាសឱ្យដល់យើង" , រមែងធ្វើបុគ្គលអ្នកមិនមែនម្ចាស់ទ្រព្យ ឱ្យជាម្ចាស់ទ្រព្យ, អ្នកនេះ ឈ្មោះថា **រមែងលំអៀងព្រោះសេចក្ដីខ្លាច** (ភយាគតិ) ។ ក៏ម្យ៉ាងទៀត បុគ្គលណា កាលចែកវត្ថុណាមួយ ក្នុងឋានៈដែលគួរចែក រមែងឱ្យច្រើនជាងបុគ្គលដទៃ ដោយអំណាចនៃសេចក្ដីស្រឡាញ់ថា "អ្នកនេះជាមិត្តរបស់យើង ឬក៏ជា សម្លាញ់របស់យើង ឬថា ជាអ្នករួមស៊ីរួមដេក" ។ រមែងឱ្យតិចដោយអំណាចនៃទោសៈថា "អ្នកនេះជាសត្រូវរបស់យើង" , កាលមិនដឹងថា "វត្ថុនេះដែលយើងឱ្យហើយ ឬថា នៅមិនទាន់ឱ្យ ព្រោះភាវៈនៃខ្លួនជាមនុស្សខ្លៅ រមែងឱ្យរបស់របរ ច្រើនដល់មនុស្សខ្លះ រមែងឱ្យតិចដល់មនុស្សខ្លះ" ជាអ្នកខ្លាចថា "កាលយើងមិនឱ្យវត្ថុនេះ អ្នកនេះគប្បីធ្វើសេចក្ដីវិនាស សូម្បីដល់យើង" រមែងឱ្យរបស់របរដល់មនុស្សខ្លះ ។ សូម្បីបុគ្គលទាំង ៤ ជំពូកនេះ ឈ្មោះថា រមែងដំណើរទៅកាន់ឆន្ទាគតិជាដើម តាមលំដាប់ ។ ព្រះអរិយៈទាំងឡាយ រមែងមិនដំណើរទៅ ព្រោះធម៌មានឆន្ទៈ ជាដើមនេះ ព្រោះហេតុនោះ ធម៌នេះ ទើបឈ្មោះថា **អគតិ** ។ ជនទាំងឡាយ មិនមែនព្រះអរិយៈ រមែងដំណើរទៅកាន់អគតិដោយធម៌មានឆន្ទៈជាដើមនេះ ព្រោះហេតុនោះ អគតិនេះទើបឈ្មោះថា **អគតិគមនៈ** ។ បទទាំងពីរនៃធម៌ទាំង ៤ មានឆន្ទៈជាដើមនេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកដោយអំណាចនៃសេចក្ដីជាធម៌ សាធារណៈ ។ ការលំអៀង (**គមនំ** សំដៅដល់ការប្រព្រឹត្តទៅ) ព្រោះឆន្ទៈ ឈ្មោះថា **ឆន្ទាគមនំ** = ការលំអៀងព្រោះសេចក្ដីស្រឡាញ់ ។ ឆន្ទា

គមនៈនេះ ព្រះមានព្រះភាគត្រាស់ទុក ដោយមិនសាធារណៈដល់ធម៌ទាំងឡាយមានទោសៈជាដើម ។ ការលំអៀងព្រោះធ្វើភាគៈដែលជាផ្នែកនៃខ្លួន និងទោសៈដែលជាផ្នែករបស់អ្នកដទៃ ទុកចំពោះមុខដោយសេចក្ដីជាអ្នកមិនរួមជាពួកតែមួយជាមួយគ្នា ឈ្មោះថា សេចក្ដីលំអៀង **ព្រោះជាពួកត្រូវគ្នា**, សេចក្ដីលំអៀងនេះត្រាស់ទុកដោយសាធារណៈដល់ឆន្ទៈ និងទោសៈ ។ ឈ្មោះថា សេចក្ដីលំអៀងព្រោះត្រឡប់ទៅដូច ទឹកហូរ ក៏ព្រោះដូចជាទឹកដែលហូរទៅកាន់ទីទាបដូច្នោះការលំអៀងនេះ ត្រាស់ទុកដោយអំណាចនៃធម៌ជាសាធារណៈ សូម្បីដល់ការលំអៀងទាំង ៤ ៕

## **វិបរិយេសៈ - ការយល់ខុស**

សភាវៈណា រមែងស្វែងរកវត្ថុដែលផ្ទុយ ដោយន័យថា វត្ថុទាំងឡាយមានសេចក្ដីមិនទៀងជាដើម ថាជារបស់ទៀងជាដើម សភាវៈនោះ ទើបឈ្មោះថា **វិបរិយេសៈ** (សេចក្ដីចូលចិត្តខុស) ។ សេចក្ដីចូលចិត្តខុសព្រោះសញ្ញា ឈ្មោះថា **សញ្ញាវិបរិយេសៈ** ។ ក្នុងវិបរិយេសៈទាំងពីរសូម្បីក្រៅពីនេះ ក៏ន័យនេះដែរ ។ វិបរិយេសៈទាំង ៤ នេះ រមែងមានដោយអំណាចនៃវត្ថុ ៤ (គឺ **អនិច្ចៈ ទុក្ខៈ អនត្តៈ** និង **អសុភៈ**) ទើបជាវិបរិយេសៈ ១២ ដោយអំណាចនៃសញ្ញាជាដើម ។ ក្នុងវត្ថុទាំងឡាយណា វិបរិយេសៈ ៨ ក្នុងវិបរិយេសៈទាំងនោះ រមែងលះបានដោយ សោតាបត្តិមគ្គ ។ ក្នុងពាក្យថា **"អសុភំ សុភេ"** នេះ បណ្ឌិតគប្បីជ្រាបថា សញ្ញា និងចិត្តវិបល្លាស រមែងស្រាលទៅខ្លះ ដោយសកទាគាមិមគ្គ, និងរមែងលះ

បានដោយអនាគាមិមគ្គ ។ ក្នុងពាក្យថា **“ឧក្កេ សុខំ”** នេះ គប្បីជ្រាបថា រមែងលះបានដោយអរហត្តមគ្គ ៕

## អនរិយវោហារ

ពាក្យថា **“អនរិយវោហារា”** បានដល់ វោហារ គឺពាក្យទាំងឡាយដែលមិនមែនរបស់ព្រះអរិយៈ ជាពាក្យលាមក ។ ពាក្យថា **“ទិដ្ឋវាទិតា** = និយាយថាឃើញ” បានដល់ ជាអ្នកមានប្រក្រតីពោលយ៉ាងនេះថា វត្ថុនេះខ្ញុំឃើញហើយ ។ ក៏ក្នុងពាក្យនេះ បណ្ឌិតគប្បីជ្រាបសេចក្ដីដោយអំណាចនៃចេតនា ដែលញ៉ាំងវាចានោះៗ ឱ្យតាំងឡើង ។ សូម្បីពាក្យថា “ចេតនាដែលបុគ្គលនោះ ពោលព្រមនឹងសំឡេង” ព្រះមានព្រះភាគក៏ត្រាស់ទុកហើយនុ៎ះឯង ។ សូម្បីក្នុងពួក ៤ នៃអនរិយវោហារទី ២ ក៏ន័យនេះដែរ ។ ពិតមែន ក៏ឈ្មោះថា ព្រះអរិយៈមិនឃើញហើយ ពោលថា “យើងឃើញហើយ” ឬថាឃើញហើយ ពោលថា “មិនឃើញ” រមែងមិនមាន ។ បុគ្គលអ្នកមិនមែនព្រះអរិយៈប៉ុណ្ណោះ រមែងពោលយ៉ាងនេះ ។ ព្រោះហេតុដូច្នោះ កាលបុគ្គលពោលយ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា ចេតនា ៨ ជាមួយនឹងអនរិយវោហារ ៨ ទាំងនេះ កើតព្រមនឹងសំឡេង ។

ពួក ៤ ទីមួយក្នុងទុច្ចរិតទាំងឡាយ ព្រះមានព្រះភាគត្រាស់ទុក ដោយអំណាចនៃចេតនាដែលជាបាប (ជាពៀរ) ពួក ៤ ទីពីរ ត្រាស់ទុកដោយអំណាចនៃវចីទុច្ចរិត ។

ក្នុងភ័យទាំងឡាយ ភ័យដែលកើតឡើង ព្រោះអាស្រ័យការកើត (ជាតិ)

ឈ្មោះថា **ជាតិភ័យ** ក្នុងពួក ៤ ទីមួយ ។ សូម្បីក្នុងភ័យដែលនៅសល់ ក៏ន័យនេះដែរ; ភ័យដែលកើតឡើង ព្រោះព្រះរាជា ឈ្មោះថា **រាជភ័យ** ក្នុងពួក ៤ ទីពីរ ។ សូម្បីក្នុងភ័យដែលនៅសល់ ក៏ន័យនេះដែរ ។ ភ័យ ៤ ក្នុងពួក ៤ ទីបី កាលបុគ្គលធ្លាក់ចុះកាន់ទឹកក្នុងមហាសមុទ្រ ទើបឈ្មោះថា ជាភ័យតាមដែលព្រះមានព្រះភាគត្រាស់នោះ ។

បានឮថា ក្នុងមហាសមុទ្ររលកឈ្មោះថា **មហិន្ទវីចិ** តាំងឡើងទៅខាងលើ ៦០ យោជន៍ ។ រលកឈ្មោះថា **គង្គាវីចិ** តាំងឡើងទៅខាងលើ ៥០ យោជន៍ ។ រលកឈ្មោះថា **រោហនវីចិ** តាំងឡើងទៅខាងលើ ៤០ យោជន៍; ភ័យដែលកើតឡើង ព្រោះអាស្រ័យកូនរលកទាំងឡាយ ឈ្មោះថា **ឩមិភ័យ** ភ័យកើតឡើងពីរលក ។ ភ័យកើតពីក្រពើ ឈ្មោះថា **កុម្ភីលភ័យ** ។ ភ័យដែលកើតពីអន្លង់ទឹកកួចឈ្មោះថា **អាវដ្តភ័យ ។ សុំសុកា** ព្រះមានព្រះភាគត្រាស់ថា ត្រីកាច, ភ័យកើតពីត្រីកាចនោះឈ្មោះថា **សុង្សុកាភ័យ**; ពាក្យថា **"ភ័យកើតពីការតិះដៀលខ្លួនឯង"** ក្នុងពួក ៤ ទីបួន បានដល់ ភ័យដែលកើតឡើងដល់បុគ្គល អ្នកមានបាបកម្មតិះដៀលខ្លួនឯង ។ ពាក្យថា **"ភ័យកើតអំពីការតិះដៀលពីអ្នកដទៃ"** បានដល់ភ័យដែល កើតឡើងអំពីការតិះដៀលរបស់បុគ្គលដទៃ ។ ពាក្យថា **"ភ័យកើតអំពីអាជ្ញា"** បានដល់ ភ័យដែលកើតឡើងព្រោះអាស្រ័យអាជ្ញា ដែលព្រះរាជាឱ្យប្រព្រឹត្តទៅដល់ បុគ្គលអ្នកគ្រប់គ្រងផ្ទះ (អាគារិកបុគ្គល) និងព្រោះអាជ្ញា គឺព្រះវិន័យរបស់អ្នកមិន នៅគ្រប់គ្រងផ្ទះ ។ ពាក្យថា **"ភ័យកើតអំពីអបាយ"** បានដល់ ភ័យដែលកើតឡើង ព្រោះអាស្រ័យអបាយភូមិ ៤ ។ ឈ្មោះថា មហាភ័យ

១៦ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ហើយដោយភ័យ ៤ ពួក មួយពួកៗ បួនៗ ទាំងនេះ ដោយប្រការដូច្នេះ ។ ឈ្មោះថា **តិម្ពរុសកទិដ្ឋិ**[៦៦] ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកក្នុងទិដ្ឋិ ចតុក្កៈ; បណ្ដាទិដ្ឋិទាំងនោះ ពាក្យថា **"សុខទុក្ខខ្លួនឯងធ្វើឱ្យ"**[៦៧] បានដល់ កាលបុគ្គលឃើញវេទនា ដោយភាវៈជាអត្តា តួខ្លួន ការឃើញខុសក៏កើតឡើងថា "វេទនាដែលវេទនានោះឯង ធ្វើទុកហើយ" ។ កាលបើដូច្នោះ ក៏នឹងប្រាកដថាវេទនាដែល កើតឡើងក្នុងកាលមុននោះមាន ព្រោះហេតុដូច្នោះ ទិដ្ឋិគឺការឃើញខុសនេះ ទើប ឈ្មោះថា **សស្សតទិដ្ឋិ**; ពាក្យថា **"សច្ចតោ ថេតតោ"** បានដល់ ទិដ្ឋិកើតឡើង ដោយសច្ចៈ ដោយថាវរៈ ។ ពាក្យថា **"សុខទុក្ខដែលមនុស្សដទៃធ្វើឱ្យ"**[៦៨] អធិប្បាយថា កាលសោយវេទនាដែលកើតឡើងចំពោះមុខ ក៏ឃើញថា "ខ្លួនមាន វេទនា គឺមានវេទនាដទៃធ្វើឱ្យ ទិដ្ឋិការយល់ឃើញខុសក៏នឹងកើតឡើងថា 'វេទនានេះ ដែលវេទនាដទៃធ្វើឱ្យ" ។ កាលបើយ៉ាងនេះ ភាពដាច់សូន្យនៃវេទនា ដែលកើតឡើងមុន រមែងប្រាកដថា "ព្រោះវេទនាជា

---

[៦៦] **តិម្ពរុសកទិដ្ឋិ** បានដល់ ទិដ្ឋិដែលប្រជុំហើយដោយភាគៈ បណ្ឌិតទាំងឡាយឱ្យពាក្យអធិប្បាយថា ជាទិដ្ឋិដែលកើតឡើងពីការរៀនច្រើន ហើយមានមានះថា ខ្ញុំជាអ្នកប្រាជ្ញ (សស្សតទិដ្ឋិ ឧច្ឆេទទិដ្ឋិ និង អហេតុកទិដ្ឋិ) ។

[៦៧] ក្នុងសក្កាយទិដ្ឋិថា **វេទនំ អត្តតោ សមនុបស្សតិ** = ឃើញវេទនាដោយសេចក្ដី ជាខ្លួន ដោយយល់ថា វេទនាជាមួយនឹងខ្លួន។

[៦៨] ក្នុងសក្កាយទិដ្ឋិថា **វេទនាវន្តំ វា អត្តានំ** = ម្យ៉ាងទៀត ឃើញខ្លួនថា មានវេទនា ដោយយល់ថា ខ្លួន និងវេទនា ជាមនុស្សតែមួយ ។

អ្នកធ្វើវេទនា” ទិដ្ឋិនេះ ទើបឈ្មោះថា (ឧច្ឆេទទិដ្ឋិ) ពាក្យថា “សុខទុក្ខខ្លួនឯងធ្វើឱ្យផង មនុស្សដទៃធ្វើឱ្យផង” បានដល់ ទិដ្ឋិការឃើញខុស ដែលកើតឡើងដល់ អ្នកប្រកាន់ថា “សុខទុក្ខខ្លួនឯងធ្វើពាក់កណ្ដាល អ្នកដទៃធ្វើឱ្យពាក់កណ្ដាល” ដោយអត្ថតាមដែលពោលហើយនោះឯង ។ នេះឈ្មោះថា **សស្សតុច្ឆេទទិដ្ឋិ** ។

ទិដ្ឋិការឃើញខុស ខទី ៤ កើតឡើងដល់អ្នកប្រកាន់ថា “សុខទុក្ខមិនមានហេតុឡើយ” ; កាលបើមានសេចក្ដីយ៉ាងនេះ ទិដ្ឋិនេះ ទើបឈ្មោះថា **អហេតុកទិដ្ឋិ** ។ បទដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលទាំងអស់ ព្រោះមានន័យ ដូចដែលពោលហើយក្នុងពេលមុននោះឯង ៕

**ចប់ចតុក្កនិទ្ទេស**

## អដ្ឋកថាបញ្ចកនិទ្ទេស អធិប្បាយមាតិកាពួក ៥

សញ្ញោជនៈទាំងឡាយ មានសក្កាយទិដ្ឋិជាដើម ដែលបុគ្គលណានៅមិនបានលះ, សញ្ញោជនៈទាំងនេះ ក៏នឹងទាញបុគ្គលនោះ អ្នកកើតសូម្បីក្នុងភវគ្គភូមិ (ភូមិខ្ពស់) ឱ្យទៅក្នុងកាមភពនោះឯង, ព្រោះហេតុនោះ សញ្ញោជនៈទាំងនេះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅថា **ឱរម្ភាគិយៈ** [៦៩] (សញ្ញោជនៈខាងក្រោម) ។ ដោយហេតុនេះ សញ្ញោជនៈទាំង ៥ នេះ ទើបមិនបានហាមអ្នកទៅកាន់ភវគ្គភូមិ, ប៉ុន្តែរមែងនាំអ្នកទៅហើយនោះ ឱ្យត្រឡប់មកកាន់ភពនេះទៀត ។ សញ្ញោជនៈ

---

[៦៩] **សញ្ញោជនៈខាងក្រោម ៥** គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ កាមច្ឆន្ទៈ និងព្យាបាទៈ ។

ខាងលើ [៧០] មានរូបរាគៈជាដើម ឈ្មោះថា **សង្គៈ** ព្រោះអត្ថថា ជាគ្រឿងចង, និង ឈ្មោះថា **សល្លៈ** (កូនសរ) ព្រោះអត្ថថា ចាក់ដោត ។

ពាក្យថា **“ចេតោខិលា”** បានដល់ សភាពនៃចិត្តជាធម្មជាតិរឹងត្អឹង សភាពនៃចិត្តដូចគំនរសំរាម សភាពនៃចិត្តដូចជាដង្គត់ឈើ ។ ពាក្យថា **“សត្ថរិ កង្ខតិ”** បានដល់ សេចក្តីសង្ស័យក្នុងព្រះសរីរៈរាងកាយរបស់ព្រះសាស្តា ឬក្នុងព្រះគុណរបស់ព្រះសាស្តា; គឺថា កាលបុគ្គលសង្ស័យក្នុងព្រះសរីរៈរបស់ព្រះសាស្តា រមែងសង្ស័យថា “ព្រះសរីរៈរបស់ព្រះសាស្តា ឈ្មោះថា ប្រដាប់ដោយលក្ខណៈដ៏ប្រសើរ ៣២ ប្រការនោះ មានពិត ឬក៏មិនមាន” ; កាលសង្ស័យក្នុងព្រះគុណរបស់ព្រះសាស្តា រមែងសង្ស័យថា “ព្រះសព្វញ្ញុតញ្ញាណដែលអាចដឹងអតីតៈ អនាគត និងបច្ចុប្បន្ន មាន ឬមិនមាន” ។ ពាក្យថា **“វិចិកិច្ឆតិ”** បានដល់ កាលបុគ្គលគិតរមែងលំបាក, រមែងប្រសព្វសេចក្តីទុក្ខ, រមែងមិនអាចកាត់ក្តីបាន ។ ពាក្យថា **“នាធិមុច្ចតិ”** បានដល់ រមែងមិនបានចំពោះ ដល់ការបង្អោនចិត្តជឿថា “ព្រះគុណរបស់ព្រះសាស្តានោះ ជាយ៉ាងនេះ” ។ ពាក្យថា **“នសម្បសីទតិ”** បានដល់ បុគ្គលស្ទាបស្ទង់ចុះកាន់ព្រះគុណរបស់ព្រះសាស្តាហើយ រមែងមិនអាចដើម្បីជាអ្នកមិនសៅហ្មង ព្រោះសេចក្តីត្រេកអរ និងព្រោះភាពជាអ្នកអស់សេចក្តីសង្ស័យ ។ ពាក្យថា **“ធម្មេ”** បានដល់ រមែងសង្ស័យក្នុង**ព្រះបរិយត្តិធម៌** និងក្នុង**ព្រះបដិវេធធម៌** ។ អធិប្បាយថា កាលសង្ស័យក្នុងព្រះបរិយត្តិធម៌ រមែងសង្ស័យថា “ជនទាំងឡាយរមែងពោលថា ‘ព្រះត្រៃបិដក គឺព្រះពុទ្ធវចនៈ ៨៤.០០០ ព្រះធម្មក្ខន្ធនោះ មានឬ ?” ; កាល

---

[៧០] **ឧទ្ធម្ភាគិយសញ្ញោជនៈ ៥** គឺ រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ និងអវិជ្ជា។

សង្ស័យក្នុងព្រះបដិវេធធម៌ រមែងសង្ស័យថា "ជនទាំងឡាយ រមែងពោលថា 'ឈ្មោះថា មគ្គ ព្រោះការហូរចេញនៃវិបស្សនា, ឈ្មោះថា ផល ព្រោះការហូរចេញនៃមគ្គ, និងឈ្មោះថា **ព្រះនិព្វាន** ព្រោះជាការលះ គឺចោលនូវសង្ខារទាំងឡាយ' ដូច្នេះ នោះមានមែន ឬមិនមាន ?" ។ ពាក្យថា **"សង្ឃេ កង្ខតិ"** បានដល់ រមែងសង្ស័យថា "បុគ្គលអ្នកតាំងនៅក្នុងមគ្គ ៤ និងផល ៤ អ្នកដំណើរទៅកាន់បដិបទាដោយអំណាចនៃការដើរទៅ មានពាក្យថា '**ឧជុប្បដិបន្នោ**' ដូច្នេះជាដើម មានសភាពដូច្នេះ ឈ្មោះថា សង្ឃជាព្រះអរិយបុគ្គល ៨ មាន ឬមិនមាន" កាលសង្ស័យក្នុងសិក្ខា រមែងសង្ស័យថា "បុគ្គលទាំងឡាយ រមែងពោលថា 'អធិសីលសិក្ខា អធិចិត្តសិក្ខា និងអធិបញ្ញាសិក្ខា" ដូច្នេះ ពាក្យនេះមាន ឬមិនមាន" ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"ចេតោ វិនិពន្ធា"** ឈ្មោះថា ចេតោវិនិពន្ធៈ (គ្រឿងចងព័ន្ធចិត្ត) ព្រោះគ្រឿងចងទាំងឡាយរមែងចងចិត្តទុក ដូចបុគ្គលក្ដាប់វត្ថុដោយដៃហើយ ក៏កាន់យក ។ ពាក្យថា **"កាមេ"** បានដល់ ក្នុងវត្ថុកាមខ្លះ ក្នុងកិលេសកាមខ្លះ ។ ពាក្យថា **"កាយេ"** បានដល់ ក្នុងកាយរបស់ខ្លួន ។ ពាក្យថា **"រូបេ"** បានដល់ ក្នុងរូបខាងក្រៅ ។ ពាក្យថា **"យាវទត្ថំ** = តាមសេចក្ដីត្រូវការ" ។ ពាក្យថា **"ឧទរាវទេហកំ"** បានដល់ ក្រពេញអាហារ; ពិតមែន អាហារពេញក្រពះនោះ ព្រះមានព្រះភាគត្រាស់ហៅថា ឧទរាវទេហកៈ ព្រោះការបរិភោគអាហាររហូតឆ្អែត ។ ពាក្យថា **"សេយ្យសុខំ"** បានដល់ រកសេចក្ដីសុខលើគ្រែ និងតាំង ឬថា សេចក្ដីសុខជាប់ទាក់ទងនឹងឧណ្ហភូមិ ។

ពាក្យថា **"បស្សសុខំ"** បានដល់ សេចក្ដីសុខរបស់បុគ្គលអ្នកដេកត្រឡប់

ទៅ មកខាងស្តាំ ឬខាងឆ្វេង យ៉ាងណា, សេចក្តីសុខដែលកើតឡើងហើយក្នុងទីនេះ ក៏ដូច្នោះដែរ ។

ពាក្យថា **“មិទ្ធសុខំ”** បានដល់ សេចក្តីសុខក្នុងការលក់ ។ ពាក្យថា **“អនុ-យុត្តោ”** បានដល់ ប្រកបហើយ ខ្វល់ខ្វាយហើយជាប្រក្រតី; ពាក្យថា **“តាំងចិត្ត”** បានដល់ ប្រាថ្នាហើយ ។ ពាក្យថា **“ដោយសីល”** ក្នុងពាក្យថា **សីលេន** ជាដើម បានដល់ **ចតុប្បារិសុទ្ធិសីល** ។ ពាក្យថា **“វត្តំ”** បានដល់ សមាទានវត្ត គឺប្រព្រឹត្ត ។ ពាក្យថា **“តបោ”** បានដល់ ប្រព្រឹត្តបំពេញតបៈ ។ ពាក្យថា **“ព្រហ្ម-ចរិយំ”** បានដល់ វៀរមេថុនធម្ម ។ ពាក្យថា **“ទេវោ វា តវិស្សាមិ** = យើងនឹងជាទេវតា អ្នកមានអំណាចធំ” ។ ពាក្យថា **“ទេវញ្ញតរោ វា”** បានដល់ ឬថា ជាទេវតាអ្នកមានយសស័ក្តិតូចរូបណាមួយ ។

ធម៌ទាំងឡាយដែលឈ្មោះថា **នីវរណៈ** ព្រោះរមែងបិទ រមែងរាំងកុសល-ធម៌ទាំងឡាយ ។ ពាក្យថា **“មាតា ជីវិតា វោរោបិតា ហោតិ”** បានដល់ **មនុស្សប៉ុណ្ណោះ** សម្លាប់មាតារបស់ខ្លួនដែលជាមនុស្ស **សូម្បីបិតា** ក៏ជាមនុស្សយ៉ាងនោះឯង ។ **ព្រះអរហន្ត** ក៏ជាព្រះអរហន្តមនុស្សនោះឯង ។ ពាក្យថា **“ដោយចិត្តដែលប្រទូសរ៉ាយ”** បានដល់ ចិត្តគិតនឹងសម្លាប់ ។

ពាក្យថា **“សញ្ញី”** បានដល់ ព្រមព្រៀងដោយសញ្ញា ។ ពាក្យថា **“អរោ-គោ”** បានដល់ ទៀងពិតមិនប្រែប្រួលឡប់ ។ ពាក្យថា **“ឥត្ថេកេ អភិវទន្តិ”** បានដល់ សមណព្រាហ្មណ៍ពួកមួយ រមែងពោលយ៉ាងនេះ, គឺរមែងពោលដោយប្រការដូច្នេះ ។ **សញ្ញីវាទៈ ១៦** ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកដោយពាក្យមាន

ប្រមាណប៉ុណ្ណោះ ។ ពាក្យថា **"អសញ្ញី"** បានដល់ វៀរអំពីសញ្ញា ។ **អសញ្ញីវាទៈ ៨** ព្រះមានព្រះភាគជាអង្គម្ចាស់ ត្រាស់ទុកដោយបទថា **អសញ្ញី** នេះ ។ **នេវសញ្ញីនាសញ្ញីវាទៈ ៨** ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកដោយបទទី ៣ ។ ពាក្យថា **"សតោ វា បន សត្តស្ស"** បានដល់ ម្យ៉ាងទៀត កាលសត្វមាននោះឯង ។ ពាក្យថា **"ឧច្ឆេទំ"** បានដល់ ការដាច់សូន្យ ។ ពាក្យថា **"វិនាសំ"** បានដល់ សេចក្ដីវិនាស ។ ពាក្យថា **"វិភវំ"** បានដល់ មិនមានភព ។ ពាក្យទាំងអស់នេះ ជាវេវចនៈរបស់គ្នានឹងគ្នា ។

**ក្នុងសេចក្ដីនេះ មនុស្ស ២ នាក់ គឺអ្នកបានឈានម្នាក់ មិនបានឈាន ម្នាក់ រមែងកាន់យកឧច្ឆេទទិដ្ឋិ ។**

**ក្នុងពីរនាក់នោះ ឈានលាភីបុគ្គលឃើញសត្វកំពុងចុតិ ដោយចក្ខុទិព្វ តាមសេចក្ដីសមគួរ មិនឃើញការកើតឡើង ឬថាបុគ្គលណា រមែងមិនអាចដើម្បីឃើញនូវចុតិនោះផង មិនអាចដើម្បីនឹងឃើញនូវការកើតឡើងផង បុគ្គលនោះ ក៏រមែងកាន់យកនូវឧច្ឆេទទិដ្ឋិ ។**

អ្នកមិនបានឈាន ព្រោះសេចក្ដីប្រាថ្នាច្រើនក្នុងកាមគុណ រមែងគិតថា "អ្នកណាហ្ន៎ នឹងដឹងនូវបរលោក" , ម្យ៉ាងទៀត ប្រៀបដូចស្លឹកឈើជ្រុះទៅអំពីដើមឈើហើយ រមែងមិនដុះឡើងយ៉ាងណា, បុគ្គលអ្នកមិនបានឈាន កាន់យកនូវឧច្ឆេទទិដ្ឋិ ព្រោះវិតក្កៈជាដើមថា "សត្វទាំងឡាយក៏យ៉ាងនោះ" ។ ឧច្ឆេទវាទៈ ៧ ដែលកើតឡើងហើយ ព្រោះការកំណត់ដូច្នោះផង ដោយប្រការដទៃផង ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃតណ្ហា និងទិដ្ឋិទាំងឡាយ ។ ពិតមែន ទិដ្ឋិនេះជាពាក្យសង្គ្រោះរបស់តណ្ហា និងទិដ្ឋិទាំងនោះ ។ បច្ចក្ខធម្ម (ធម៌ដែលប្រចក្ស) ព្រះមាន-

ព្រះភាគត្រាស់ហៅថា **ទិដ្ឋធម្ម** ក្នុងពាក្យថា **“ទិដ្ឋធម្មនិព្វានំ វា បនេកេ** = ឬថា សមណព្រាហ្មណ៍ពួកមួយ រមែងពោលអះអាងទិដ្ឋធម្មនិព្វាន” ។

ពាក្យដែលពោលមកនេះ ជាឈ្មោះរបស់បុគ្គលអ្នកបាននូវធម៌នោះៗ ។ និព្វានក្នុងទិដ្ឋធម្ម ឈ្មោះថា ទិដ្ឋធម្មនិព្វាន ។ អធិប្បាយថា ការចូលទៅស្ងប់នៃទុក្ខក្នុងអត្តភាពនេះប៉ុណ្ណោះ ។ នេះជាពាក្យសង្គ្រោះវាទៈថា ទិដ្ឋធម្មនិព្វាន ។

ពាក្យថា **“វេរា** = ពៀរ ៥” បានដល់ ចេតនាដែលជាបាប ។

ពាក្យថា **“ព្យសនា”** បានដល់ សេចក្តីវិនាសទាំងឡាយ ៕

## ទោសនៃការមិនអត់ធន់ ៥ យ៉ាង គឺ

១-មិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត

២-មានវេរា (ពៀរ) ច្រើន

៣-មានទោសច្រើន

៤-ស្លាប់ដោយការភ្លេចភ្លាំងសតិ

៥-ស្លាប់ហើយ ចូលដល់អបាយភូមិ ៤ ភូមិណាមួយ ។

ពាក្យថា **“អក្ខន្តិយា”** បានដល់ នៃការមិនអត់ធន់ ។ ពាក្យថា **“អប្បិយោ”** បានដល់ មិនគប្បីជាទីស្រឡាញ់ ព្រោះជាវត្ថុបដិកូលក្នុងការឃើញ និងក្នុងការស្តាប់ ។ ឈ្មោះថា **មិនជាទីពេញចិត្ត** ព្រោះសូម្បីការគិត ចិត្តរមែងមិនក្បែកណែន ។ ពាក្យថា **“វេរពហុលោ”** បានដល់ មានវេរាច្រើន ។ ពាក្យថា **“វជ្ជពហុលោ”** បានដល់ មានទោសច្រើន ។

ភ័យដែលកើតឡើង ព្រោះអាស្រ័យអាជីវៈដែលញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅ ឈ្មោះថា **អាជីវកភ័យ**, អាជីវកភ័យនោះរមែងមានដល់អ្នកគ្រប់គ្រងផ្ទះខ្លះ; ក្នុងបុគ្គលទាំងនោះ អ្នកគ្រប់គ្រងផ្ទះ រមែងធ្វើកម្មដែលជាអកុសលច្រើន ព្រោះហេតុនៃអាជីវៈមុន; និងតអំពីនោះ ភ័យនោះ ក៏កើតដល់គេរហូតដល់មរណសម័យ ឬរហូតនរកប្រាកដ ។ សូម្បីអ្នកមិនគ្រប់គ្រងផ្ទះទេ កាលធ្វើអនេសនៈ គឺការស្វែងរកចិញ្ចឹមជីវិតក្នុងផ្លូវដែលមិនគួរជាច្រើន ភ័យនោះរមែងកើតឡើងដល់គេរហូតដល់មរណសម័យ ឬនរកប្រាកដ; នេះឈ្មោះថា អាជីវកភ័យ; ពាក្យថា **"អសិលោកភយំ"** បានដល់ ភ័យ គឺការតិះដៀល; ពាក្យថា **បរិសសារជ្ជភយំ** បានដល់ភ័យ ពោលគឺសេចក្ដីត្រេកអរ រមែងកើតឡើងដល់បុគ្គលអ្នកមានបាបដែលធ្វើទុកហើយ និងចូលទៅកាន់ទីប្រជុំនៃបរិស័ទនេះ ឈ្មោះថា ភ័យកើតពីការតក់ស្លុត កាលបើចូលទៅកាន់ទីប្រជុំភ័យទាំងពីរក្រៅនេះ គឺមរណភ័យ និងអបាយភ័យ ប្រាកដជាក់ច្បាស់ហើយនោះឯង ។

ក្នុងទិដ្ឋធម្មនិព្វានវាទ ពាក្យថា **"បញ្ចហិ កាមគុណេហិ"** បានដល់ដោយសេចក្ដីចងព័ន្ធ ដែលជាចំណែកនៃកាមគុណ ៥ មានរូបជាទីពេញចិត្តជាដើម; ពាក្យថា **"សម្បិតោ"** បានដល់ ជាប់ណែនហើយ នៃបនិត្យហើយដោយល្អ; ពាក្យថា **"សមង្គីភូតោ"** បានដល់ ប្រកបហើយ; ពាក្យថា **"បរិចារេតិ** = រមែងបម្រើ" បានដល់ ញ៉ាំងឥន្ទ្រិយទាំងឡាយឱ្យប្រព្រឹត្តទៅព្រម រមែងបង្អោនចូលទៅខាងនេះផង ខាងនោះផង តាមសេចក្ដីសុខក្នុងកាមគុណទាំងឡាយនោះ; ម្យ៉ាងទៀត រមែងសមាគម រមែងរីករាយ រមែងលេងក្នុងកាមទាំងនោះ; ក៏កាមគុណទាំង

ពីរក្នុងទីនេះ លោកប្រាថ្នាយកកាមគុណដែលជារបស់មនុស្ស បណ្ឌិតគប្បីជ្រាបដូចនឹងកាមគុណរបស់ព្រះបាទមន្ធាតុ, កាមគុណដែលជាទិព្វ គប្បីជ្រាបដូចនឹងកាម-គុណរបស់ទេវរាជក្នុងសួគ៌ជាន់បរនិម្មិតវសវត្តី។ ក៏សមណព្រាហ្មណ៍ទាំងនោះ រមែងពោលនឹងបុគ្គលអ្នកចូលដល់កាម មានសភាពបែបនេះថា "ជាអ្នកពន្លះទិដ្ឋធម្ម-និព្វានដ៏កំពូល ដ៏ល្អដាច់គេ" ; បណ្តាពាក្យទាំងនោះ ពាក្យថា **"បរមទិដ្ឋធម្ម-និព្វានំ"** បានដល់ ទិដ្ឋធម្មនិព្វានក៏ល្អដាច់គេ, គឺខ្ពង់ខ្ពស់ ។

ក្នុងវារៈទី ២ កាមទាំងឡាយដែលឈ្មោះថា **មិនទៀង** ព្រោះអត្ថថា មានហើយត្រឡប់ជាមិនមានវិញ, ឈ្មោះថា **ជាទុក្ខ** ព្រោះអត្ថថា បៀតបៀន, និងគប្បីជ្រាបថា ឈ្មោះថា **មានសេចក្តីប្រែប្រួលទៅជាធម្មតា** ព្រោះអត្ថថា លះប្រក្រតី; ពាក្យថា **"តេសំ វិបរិណាមញ្ញថាភាវា** = ព្រោះភាវៈប្រែប្រួលជាយ៉ាងដទៃ" អធិប្បាយថា ព្រោះកាមទាំងនោះជាយ៉ាងដទៃ ពោលគឺមានសេចក្តីប្រែ-ប្រួលទៅ; **សោកៈ គឺការសោកសៅ, បរិទេវៈ គឺសេចក្តីខ្សឹកខ្សួល, ទុក្ខៈ គឺសេចក្តីទុក្ខ, ទោមនស្សៈ គឺការអន់ចិត្ត និងឧបាយាសៈ គឺសេចក្តីចង្អៀត-ចង្អល់ក្នុងចិត្ត** រមែងកើតឡើងដោយន័យដែលពោលទុកថា **"យម្បិមេ អហោសិ, តម្បិ មេ នត្ថិ** = សូម្បីយើងមានវត្ថុណាហើយ, សូម្បីវត្ថុនោះ ក៏ត្រឡប់មិនមាន" ; បណ្តាពាក្យទាំងនោះ **សេចក្តីសោកសៅ** មានការដុតបំផ្លាញខាងក្នុងជាលក្ខណៈ, **សេចក្តីខ្សឹកខ្សួល** មានការរៀបរាប់អណ្តឺតអណ្តក អាស្រ័យនូវសេចក្តីក្រោធនោះ ជាលក្ខណៈ, **ទុក្ខៈ** មានការបៀតបៀនកាយជាលក្ខណៈ, **ទោមនស្សៈ** មានការពិឃាតចិត្តជាលក្ខណៈ, **សេចក្តីចង្អៀតចង្អល់ចិត្ត** មានការសៅហ្មងចិត្ត

ជាលក្ខណៈ; ពាក្យថា **"ទិតិក្កិតំ"** បានដល់ វិតក្កៈដែលប្រព្រឹត្តទៅដោយអំណាចនៃការលើកឡើង ។ ពាក្យថា **ទិចារិតំ** បានដល់ វិចារៈដែលប្រព្រឹត្តទៅដោយអំណាចនៃការផ្គងឡើង; ពាក្យថា **"ឯតេន ឯតំ"** បានដល់ បឋមជ្ឈាននេះ រមែងប្រាកដ ដូចជាបន្ទាដ៏ធំ ដោយវិតក្កៈ និងវិចារៈនេះ ។ ពាក្យថា **"បីតិគតំ"** បានដល់ បីតិនោះឯង ។ ពាក្យថា **"ចេតសោ ឧព្ពិលាទិតំ** = ការភ្លើតភ្លើនចិត្ត" បានដល់ ការធ្វើចិត្តឱ្យរីករាយ ។

ពាក្យថា **"ចេតសោ អាតោគោ"** បានដល់ ចេញអំពីឈានហើយ ក៏មនសិការឱ្យចិត្តត្រឡប់រឮកដល់សេចក្ដីខុសញយៗ ។ បទដ៏សេសក្នុងទីទាំងពួងមានអត្ថងាយស្រួលទាំងអស់នោះឯង ៕

ចប់បញ្ចកនិទ្ទេស

## អដ្ឋកថាឆក្កនិទ្ទេស អធិប្បាយមាតិកាពួក ៦

បុគ្គលអ្នកក្រោធហើយរមែងដល់ការឈ្លោះ វិវាទ និងការឈ្លោះប្រកែកគ្នា ដោយអំណាចនៃសេចក្ដីក្រោធ ឬថា បុគ្គលអ្នកប្រកាន់ខ្ជាប់តែសេចក្ដីយល់ឃើញរបស់ខ្លួន ក៏រមែងដល់ការឈ្លោះ ការវិវាទ ការឈ្លោះប្រកែកគ្នា ព្រោះសេចក្ដីប្រកាន់ខ្ជាប់តែសេចក្ដីយល់ឃើញរបស់ខ្លួន, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា " វិវាទមូល មានសេចក្ដីក្រោធ" ជាដើម ៕

## ឆន្ទរាគនិទ្ទេស អធិប្បាយឆន្ទរាគៈ

ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកដោយសង្ខេបថា **ធម៌ទាំងឡាយអាស្រ័យផ្ទះ** ឈ្មោះថា ឆន្ទរាគៈ ព្រោះអាស្រ័យផ្ទះ គឺកាមដូច្នេះហើយ ដើម្បីនឹងទ្រង់សម្ដែងធម៌នោះដោយប្រភេទឯទៀត ទើបត្រាស់ថា **"មនាបិយេសុ រូបេសុ"** ជាដើម ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **"មនាបិយេសុ"** បានដល់ សេចក្ដីពេញចិត្តដែលញ៉ាំងចិត្តឱ្យចម្រើន ។

**វិរោធវត្ថុ** គឺរឿងពិរោធ (អាឃាត) ។ ពាក្យថា **អមនាបិយេសុ** បានដល់ ក្នុងវត្ថុដែលញ៉ាំងចិត្តមិនឱ្យចម្រើន ។ ពាក្យថា **"អគារវោ** = ក្នុងអគារវៈទាំងឡាយ" បានដល់ វៀរចាកសេចក្ដីគោរព ។

ពាក្យថា **"អប្បតិស្សោ"** បានដល់ អ្នកមិនជឿស្ដាប់ មិនប្រព្រឹត្តតាម ។ ក៏សេចក្ដីនេះ កាលព្រះសាស្ដាទ្រង់ព្រះជន្មនៅ ភិក្ខុណា មិនទៅកាន់ទីបម្រើ ក្នុងកាលទាំង ៣, កាលព្រះសាស្ដាមិនស៊ករងព្រះបាទ (ស្បែកជើង) ចង្ក្រម ភិក្ខុណាស៊កស្បែកជើងចង្ក្រម, កាលព្រះសាស្ដាចង្ក្រមនៅក្នុងទីទាប ភិក្ខុណាចង្ក្រមក្នុងទីចង្ក្រមខ្ពស់, កាលព្រះសាស្ដាប្រថាប់នៅលើទីទាប ភិក្ខុណានៅលើទីខ្ពស់, ភិក្ខុណាដណ្ដប់ក្រសោបស្មាទាំង ២, បាំងឆត្រ, ស៊កស្បែកជើង, ងូតទឹក និងបន្ទោបង់ឧច្ចារបស្សាវៈ ក្នុងកន្លែងជាទីឃើញនៃព្រះសាស្ដា, ឬថា កាលព្រះសាស្ដាបរិនិព្វានហើយ ភិក្ខុណាមិនទៅដើម្បីសំពះព្រះចេតិយ, រមែងធ្វើការងារទាំងពួង ដែលពោលហើយក្នុងកន្លែងជាទីប្រាកដនៃចេតិយ គឺក្នុងកន្លែងជាទីឃើញនៃព្រះសាស្ដា, ភិក្ខុនេះ ឈ្មោះថា **មិនគោរពក្នុងព្រះសាស្ដា។**

ក៏ភិក្ខុណា មិនទៅស្តាប់ធម៌ដែលសង្ឃប្រកាសហើយ **ដោយគោរព**, រមែងមិនស្តាប់ដោយគោរព, រមែងអង្គុយសន្ទនាគ្នា, រមែងរៀនដោយមិនគោរព, រមែងពោលបង្រៀនដោយមិនគោរព, ភិក្ខុនេះឈ្មោះថា **ជាអ្នកមិនគោរពក្នុងព្រះធម៌** ។

ក៏ភិក្ខុណា មិនបានទទួលការនិមន្តអំពីភិក្ខុជាព្រះថេរៈឱ្យសម្តែងធម៌ រមែងសម្តែងធម៌, ឆ្លើយបញ្ហា, ដើរ ឈរ និងអង្គុយ ប៉ះទង្គិចភិក្ខុដែលចាស់ជាង, ឬថាអង្គុយយកសំពត់រឹតជង្គង់ យកដៃរឹតជង្គង់, រមែងដណ្តប់ក្រសោបស្មាទាំងពីរ ត្រង់កណ្តាលជំនុំសង្ឃ, រមែងបាំងឆត្រ និងពាក់ស្បែកជើង, ភិក្ខុនេះ ឈ្មោះថា **មិនគោរពក្នុងសង្ឃ**; ពិតមែន ភិក្ខុសូម្បីធ្វើសេចក្តីមិនគោរព ក្នុងរឿងដែលពោលហើយត្រឹមតែម្យ៉ាងក្នុងសង្ឃ ក៏ឈ្មោះថា **មិនគោរពក្នុងសង្ឃដូចគ្នា** ។

ក៏ភិក្ខុណា មិនធ្វើសិក្ខា ៣ ឱ្យបរិបូណ៌ ភិក្ខុនោះ ឈ្មោះថា **មិនគោរពក្នុងសិក្ខា** ។

កាលភិក្ខុណា មិនចម្រើនលក្ខណៈនៃសេចក្តីមិនប្រមាទរឿយៗ ភិក្ខុនោះឈ្មោះថា **មិនគោរពក្នុងសេចក្តីមិនប្រមាទ** ។ កាលមិនធ្វើបដិសណ្ឋារ ២ យ៉ាង[៧១] ឈ្មោះថា មិនគោរពក្នុងបដិសណ្ឋារ ។

ពាក្យថា **“បរិហានិយា ធម្មា”** បានដល់ ធម៌ទាំងឡាយដែលធ្វើនូវសេចក្តីសាបសូន្យ ។ ពាក្យថា **“កម្មារាមតា”** បានដល់ ជាអ្នកប្រកបហើយ ខ្វល់ខ្វាយហើយ ដោយសេចក្តីត្រេកអរក្រៃលែងក្នុងនវកម្ម (ការកសាងថ្មី) ឬថា ក្នុងការងារ

---

[៧១] **បដិសណ្ឋារ ២ យ៉ាង** គឺ អាមិសបដិសណ្ឋារ និងធម្មបដិសណ្ឋារ ។

ទាំងឡាយ មានការពិចារណាគិត (ចាត់ចែង) ដល់ចីវរជាដើម ។ ពាក្យថា **"ភស្សារាមតា"** បានដល់ ប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងការសន្ទនា ដោយអំណាចនៃពាក្យដែលជាតិរច្ឆានកថា ។ ពាក្យថា **"និទ្ទារាមតា"** បានដល់ ប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងការដេកលក់ ។ ពាក្យថា **"សង្គណិការាមតា"** បានដល់ ប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងការសេពគប់ដោយពួកគណៈ ។ ពាក្យថា **"សំសគ្គារាមតា"** បានដល់ ប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងការនៅរួមគ្នា ៥ យ៉ាង គឺក្នុងការនៅរួមគ្នាដោយការស្តាប់, នៅរួមគ្នាដោយការមើល, នៅរួមគ្នាដោយការសន្ទនា, នៅរួមគ្នាដោយការបរិភោគ និងនៅរួមគ្នាដោយកាយ ។ ពាក្យថា **"បបញ្ចារាមតា"** បានដល់ ប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងធម៌ដែលញ៉ាំងសត្វឱ្យយឺតយូរ គឺតណ្ហា មានះ និងទិដ្ឋិ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"សោមនស្សុបវិចារៈ"** ជាដើម ។ ធម៌ទាំងឡាយ ឈ្មោះថា សោមនស្សុបវិចារៈ ព្រោះអត្ថថា រមែងជញ្ជឹងគិតដល់ការកើតឡើងរួមជាមួយ **សោមនស្ស** ។

ពាក្យថា **"ចក្ខុនា រូបំ ទិស្វា"** បានដល់ ឃើញរូបដោយចក្ខុវិញ្ញាណ ។ ពាក្យថា **"សោមនស្សដ្ឋានិយំ"** បានដល់ ជាហេតុនៃសោមនស្ស ដោយអំណាចនៃអារម្មណ៍ ។ ក្នុងពាក្យថា **"ឧបវិចរតិ"** នោះ បានដល់ រមែងជញ្ជឹងគិតដល់ដោយការប្រព្រឹត្តទៅនៃវិចារៈ ។ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងពួក ៦ សូម្បីទាំង ៣ គឺ សោមនស្សុបវិចារៈ ទោមនស្សុបវិចារៈ និងឧបេក្ខុបវិចារៈ ដោយន័យនេះថា **"វិតក្កោ បន តំ សម្បយុត្តោ ចារ** = វិតក្កៈជាធម៌សម្បយុត្តដោយវិចារៈនោះ" ។

ពាក្យថា **“គេហសិតានិ”** បានដល់ អាស្រ័យនូវកាមគុណទាំងឡាយ ។ ពាក្យថា **“សោមនស្សានិ”** បានដល់ សេចក្ដីសុខផ្លូវចិត្ត ។ ពាក្យថា **“ទោមន-ស្សានិ”** បានដល់ សេចក្ដីទុក្ខផ្លូវចិត្ត ។ ពាក្យថា **“ឧបេក្ខា”** បានដល់ ឧបេក្ខា-វេទនា ដែលសម្បយុត្តដោយអញ្ញាណ (គឺមោហៈ) ។ សូម្បីពាក្យថា **“អញ្ញា-ណុបេក្ខា”** ក៏ជាឈ្មោះរបស់ឧបេក្ខាដែលសម្បយុត្តដោយអញ្ញាណនោះឯង ៕

## ទិដ្ឋិ ៦

វាសព្ទ ក្នុងបទទាំងពួង ក្នុងពាក្យថា **“អត្ថិ មេ អត្តាតិ វា”** នេះ ជានិបាតកំណត់សេចក្ដី ។ ព្រះមានព្រះភាគទ្រង់អធិប្បាយថា ការយល់ឃើញខុសរមែងកើតឡើងយ៉ាងនេះក្ដី ។ ក៏សស្សតទិដ្ឋិរមែងកាន់យកនូវភាវៈនៃខ្លួនមានក្នុងកាលទាំងពួងក្នុងពាក្យថា **“អត្ថិ មេ អត្តា”** នេះ ។ ពាក្យថា **“សច្ចតោ ថេត-តោ”** បានដល់ ដោយពិត ដោយមាំមួន ។ ពាក្យថា **“ឥទំ សច្ចំ”** ព្រះមាន-ព្រះភាគជាម្ចាស់ ត្រាស់អធិប្បាយថា ដោយភាវៈជាវត្ថុមាំមួនដោយល្អ ។ ពាក្យថា **“នត្ថិ មេ អត្តា** = អត្តារបស់យើងមិនមាន” អធិប្បាយថា ទិដ្ឋិនេះ ឈ្មោះថាឧច្ឆេទទិដ្ឋិ, ព្រោះកាន់យកសេចក្ដីមិនមាននៃសត្វអ្នកប្រាកដនៅក្នុងទីនោះៗ ។

ម្យ៉ាងទៀត ទិដ្ឋិនេះ ឈ្មោះថា **សស្សតទិដ្ឋិ** ព្រោះកាន់យកអត្តាក្នុងកាលទាំង ៣ សូម្បីកើតមុនថា មាន ។ **ឧច្ឆេទទិដ្ឋិ** កាន់យកអត្តាដែលជាបច្ចុប្បន្នប៉ុណ្ណោះថា មិនមាន ។ គឺថា ឈ្មោះថា **ឧច្ឆេទទិដ្ឋិ** ព្រោះការប្រកាន់ថា អត្តាក្នុងអតីតៈ និងអនាគត សូម្បីកើតខាងក្រោយថា “មិនមាន” ដូចជាឧច្ឆេទទិដ្ឋិរបស់

បុគ្គលអ្នកមានសេចក្ដីយល់ឃើញថា “របស់បូជាយញ្ញ គឺជាផេះធូលី” ។ សស្សតទិដ្ឋិរបស់បុគ្គលអ្នកមានសេចក្ដីយល់ឃើញថា អត្តាកើតឡើង អណ្ដែត១ ត្រាច់ទៅ ទើបប្រកាន់ខ្ជាប់ថា “អត្តាក្នុងអតីតៈប៉ុណ្ណោះមិនមាន” ។ ពាក្យថា “**អត្តនា វា អត្តានំ សញ្ជានាមិ** = រមែងដឹងនូវអត្តាដោយអត្តាដូច្នេះក្ដី” អធិប្បាយថា លោកពោលទុកយ៉ាងនេះថា “យើងឈ្មោះថារមែងដឹងនូវអត្តានេះ ដោយអត្តានេះ ព្រោះប្រកាន់ថា ‘ អត្តាក្នុងខន្ធដោយមានសញ្ញាខន្ធជាសីសៈ ហើយដឹងខន្ធដ៏សេស ដោយសញ្ញា” ។ ពាក្យថា “**អត្តនា វា អនត្តានំ** = ដឹងនូវអនត្តាដោយអត្តា” អធិប្បាយថា លោកពោលទុកយ៉ាងនេះថា ព្រោះដឹងអត្តាទាំងនោះ ដោយកាន់យកសញ្ញាខន្ធនោះឯងថាជាអត្តា ហើយក៏កាន់យកខន្ធ ៤ ដ៏សេសថាជាអនត្តា ។ ពាក្យថា “**អនត្តនា វា អត្តានំ** = ដឹងនូវអត្តាដោយអនត្តា” បានដល់ លោកពោលទុកយ៉ាងនេះថា ព្រោះកាន់យកសញ្ញាខន្ធ ពោលថាជាអនត្តា ហើយប្រកាន់ យកខន្ធ ៤ ក្រៅពីនេះថាជាអត្តា ព្រោះដឹងអត្តាទាំងនោះ ដោយសញ្ញា សូម្បីការប្រកាន់ខ្ជាប់អត្តាទាំងអស់ ជាសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ដូចពោលមកហើយនោះឯង ។ ក៏ពាក្យថា “**វទោ វេទេយ្យោ** = អ្នកពោល អ្នកសោយ” នេះ ជាពាក្យធ្វើសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ឱ្យមាំមួនមែនពិត ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យទាំងនោះដូច្នេះ ក៏ឈ្មោះថា **វទោ** = អ្នកពោល ព្រោះរមែងពោល, អធិប្បាយថា អ្នកធ្វើ **វចីកម្ម** ។ ឈ្មោះថា **វេទេយ្យោ** ព្រោះបុគ្គលគប្បីសោយ, អធិប្បាយថា អត្តារមែងដឹង ទើបឈ្មោះថា រមែងសោយ ។ ឥឡូវនេះ អត្តានោះ រមែងដឹងនូវធម៌ឯណា, ដើម្បីសម្ដែងនូវធម៌នោះ ព្រះមានព្រះភាគក៏ត្រាស់ថា “**តត្រ តត្រ**

**ទីឃរត្តំ កល្យាណបាបកានំ"** ជាដើម; បណ្ដាពាក្យទាំងនោះ ពាក្យថា **"តត្រ តត្រ"** បានដល់ ក្នុងយោនិ (កំណើត) ក្នុងគតិ ក្នុងឋិតិ ក្នុងនិវាស និងនិកាយទាំងឡាយ ឬថា ក្នុងអារម្មណ៍ទាំងឡាយនោះៗ ។ ពាក្យថា **"ទីឃរត្តំ"** បានដល់ អស់កាលយូរ ។ ពាក្យថា **"បច្ចនុភោតិ"** បានដល់ រមែងសោយ ។ ពាក្យថា **"ន សោ ជាតោ នាហោសិ"** បានដល់ អត្តានោះ ឈ្មោះថា មិនកើត ព្រោះការមិនកើតជាធម្មតា, អធិប្បាយថា អត្តានោះមាននៅក្នុងកាល គ្រប់ពេលមែនពិត ។ ដោយហេតុនោះៗ ឯង ទើបថា អត្តាមិនបានមានហើយក្នុងអតីតៈ និងមិនមានហើយក្នុងអនាគត; ឈ្មោះថា អត្តាណាកើតឡើងហើយ, អត្តានោះមានហើយ ។ តែអត្តាណានឹងកើត, អត្តានោះ ក៏នឹងមាន ។

ម្យ៉ាងទៀត ពាក្យថា **"ន សោ ជាតោ នាហោសិ"** អធិប្បាយថា អត្តានោះ មិនកើត មិនមានហើយ សូម្បីក្នុងអតីតៈ សូម្បីក្នុងអនាគត ក៏នឹងមិនកើត នឹងមិនមាន ព្រោះសេចក្ដីដែលអត្តានោះ មាននៅក្នុងកាលគ្រប់ពេល ។ ពាក្យថា **"និច្ចោ"** បានដល់ វៀរចាកការកើត និងការរលត់ ។ ពាក្យថា **"ធុវោ** = យូរយារ" បានដល់ ជាសភាវៈមាំមួន ជាវត្ថុមានសារៈ ។ ពាក្យថា **"សស្សតោ"** បានដល់ ប្រកបដោយកាលទាំងពួង ។ ពាក្យថា **"អវិបរិណាមធម្មោ** = មិនប្រែត្រឡប់" បានដល់ ធម៌ដែលលះភាវៈជាប្រក្រតីរបស់ខ្លួន គឺរមែងមិនដល់នូវការប្រព្រឹត្តទៅដទៃ ដូចសត្វបង្គួយ មិនលះនូវភាវៈជាប្រក្រតីរបស់ខ្លួនដូច្នោះ ។ ឈ្មោះថា ទិដ្ឋិ ដែលប្រព្រឹត្តទៅជាមួយអាសវៈទាំងអស់នេះ ព្រះមានព្រះភាគត្រាស់ហើយដោយប្រការដូច្នេះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថប្រាកដច្បាស់ហើយ ។

**ចប់ឆក្កនិទ្ទេស**

## អដ្ឋកថាសត្តកនិទ្ទេស អធិប្បាយមាតិកាពួក ៧

សភាវធម៌ណា ឈ្មោះថា រមែងដេករឿយៗ ព្រោះអត្ថថា ជាសភាវៈដ៏មានកម្លាំង និងព្រោះអត្ថថា ជាសភាវៈដែលនៅមិនទាន់លះបាន ព្រោះហេតុនេះ សភាវធម៌ទាំងនោះ ទើបឈ្មោះថា **អនុស័យ** គឺកិលេសដែលដេករឿយៗ ក្នុងសន្តាន[៧២] ។

សភាវធម៌ណា រមែងប្រកបសត្វទុក រមែងឱ្យសត្វបន្តនៅក្នុងវដ្តៈ ព្រោះហេតុនោះ សភាវធម៌ទាំងនោះ ទើបឈ្មោះថា **សញ្ញោជនៈ** គឺកិលេសគ្រឿងប្រកបសត្វទុកក្នុងវដ្តៈ ។

សភាវធម៌ណា រមែងកើតរុំព័ទ្ធចិត្ត ដោយអំណាចនៃការប្រាកដឡើង ព្រោះហេតុនោះ សភាវធម៌ទាំងនោះ ទើបឈ្មោះថា **បរិយុដ្ឋាន** គឺកិលេសដែលប្រទូសរ៉ាយចិត្ត ។ បរិយុដ្ឋាន គឺ **កាមរាគៈ** ហ្នឹងឯង ឈ្មោះថា **កាមរាគបរិយុដ្ឋាន** ។ សូម្បីពាក្យដែលនៅសល់ ក៏ន័យនេះដែរ ។

ធម៌ទាំងឡាយដែលមិនមែនជារបស់សប្បុរស, ឬថា ធម៌ទាំងឡាយដែលមិនស្ងប់ ព្រោះអត្ថថា ជាធម៌លាមក ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា

---

[៧២] អង្គធម៌របស់អនុសយកិលេស សញ្ញោជនៈ និងបរិយុដ្ឋានតែម្យ៉ាងដូចគ្នា គឺកាមរាគៈ បដិឃៈ មានះ ទិដ្ឋិ វិចិកិច្ឆា ភវរាគៈ និងអវិជ្ជា, ចំណែកដែលផ្សេងគ្នានោះ គឺអនុស័យ ចាត់ជាកិលេសយ៉ាងល្អិត បានបច្ច័យហើយទើបកើតឡើង សញ្ញោជនៈ និងបរិយុដ្ឋាន ចាត់ជាកិលេសយ៉ាងកណ្តាល ព្រោះកើតឡើង សម្បយុត្តជាមួយចិត្ត កិលេសទាំងអស់កន្លងមនោទ្វារ ទៅកាន់កាយទ្វារ និងវចីទ្វារ ហៅថា កិលេសយ៉ាងគ្រោតគ្រាត ។

**អសទ្ធម្ម** ។

ចរិតទាំងឡាយ ដែលទោសទាំងឡាយមានរាគៈជាដើម ប្រទូសរ៉ាយហើយ ព្រោះហេតុនោះ ចរិតទាំងនោះ ទើបឈ្មោះថា **ទុច្ចរិត** ។ ធម៌ទាំងឡាយណា រមែងសម្គាល់ដោយអាការនោះៗ ព្រោះហេតុនោះ ធម៌ទាំងនោះទើបឈ្មោះថា **មានះ**។

## ទិដ្ឋិនិទ្ទេស

ពាក្យថា **"រូបី"** បានដល់ មានរូប ។ ពាក្យថា **"ចាតុម្មហាភូតិកោ"** សេចក្តីថា ការសម្រេចដោយមហាភូតរូប ៤ ។ ពាក្យថា **"មាតាបិត្តំ"** បានដល់ រូបដែលជារបស់មាតា និងបិតា ។ **សួរថា** រូបអ្វី ? ឆ្លើយថា រូប គឺទឹកសុក្កៈ និងលោហិត (ទឹកសុក្កៈដែលជារបស់បិតា និងលោហិតរបស់មាតា) ឈ្មោះថា **មាតាបេត្តិកសម្ភវៈ** ព្រោះកើតឡើងពីទឹកសម្ភពរបស់មាតា និងបិតា ។ សមណ-ព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ រមែងពោលនូវការកើតនៃមនុស្ស ដោយរូបកាយដែលជាប្រធាននោះថា "នេះជាអត្តា" ។ ក្នុងវារៈទី ២ សមណព្រាហ្មណ៍ខ្លះ បដិ-សេធរូបកាយដែលកើតពីមាតាបិតានោះ តែរមែងពោលទទួលនូវភាវៈជាអត្តាដែលជាទិព្វ ។ ពាក្យថា **"ទិព្វោ"** បានដល់ អត្តាដែលកើតឡើងក្នុងទេវលោក ។ ពាក្យថា **"កាមាវចរោ"** បានដល់ អត្តាដែលរាប់បញ្ចូលក្នុងសួគ៌ ៦ ជាន់ ។ ពាក្យថា **"កពឡិង្ការំ ភក្ខយតិ** * **"** បានដល់ មានដុំបាយជាអាហារ (កពឡិង្ការភក្ខោ) ។

---

* បាលីដើមថា ភក្ខោ។

ពាក្យថា **“មនោមយោ”** បានដល់ អត្តាដែលកើតឡើងហើយ ដោយចិត្ត ដែលកើតពីឈាន ។ ពាក្យថា **“សព្វង្គបច្ចង្គី”** បានដល់ ប្រកបដោយអវយវៈតូចធំទាំងពួង ។ ពាក្យថា **“អហីនិន្ទ្រិយោ”** បានដល់ មានឥន្ទ្រិយបរិបូណ៌ មិនខ្វះខាត ។ រូបណាមានក្នុងព្រហ្មលោក, ព្រះមានព្រះភាគត្រាស់នូវរូបនោះ ដោយអំណាចនៃរូបរបស់ព្រហ្មផង និងដោយអំណាចនៃសណ្ឋានរបស់រូបក្រៅពីនោះផង ។ ពាក្យថា **“អាកាសានញ្ចាយតនូបគោ”** បានដល់ ជាអ្នកចូលដល់នូវការកើតក្នុងអាកាសានញ្ចាយតនៈ ។ ក្នុងពាក្យទាំងឡាយសូម្បីក្រៅអំពីនេះ ក៏ន័យនេះដែរ ។ បទដែលនៅសល់ក្នុងទីទាំងពួង មានអត្ថងាយស្រួលទាំងអស់នោះឯង ៕

ចប់សត្តកនិទ្ទេស

## អដ្ឋកថាអដ្ឋកនិទ្ទេស អធិប្បាយមាតិកាពួក ៨

ក៏កិលេសវត្ថុ [៧៣] គឺកិលេសទាំងឡាយនោះឯង ។ ពាក្យថា **“កុសីតវត្ថូនិ”** បានដល់ វត្ថុដែលជាទីតាំងនៃសេចក្តីខ្ជិល គឺការកៀចក្រាញ, អធិប្បាយថា ជាហេតុនៃសេចក្តីខ្ជិលច្រអូស ។ ពាក្យថា **“កម្មំ កត្តព្វំ ហោតិ** = យើងនឹងធ្វើការងារ” បានដល់ ការងារដែលត្រូវធ្វើ មានការពិចារណា (ចាត់ចែង) បច្ច័យបួន មានចីវរជាដើម ។ ពាក្យថា **“ន វីរិយំ អារព្ភតិ** = មិនប្រារព្ធសេចក្តីព្យាយាម” បានដល់ មិនប្រារព្ធសេចក្តីព្យាយាមសូម្បីទាំងពីរយ៉ាង ។ ពាក្យថា **“អប្បត្តស្ស”** បានដល់ ដើម្បីបានធម៌ដែលនៅមិនទាន់បាន មានឈាន វិបស្សនា មគ្គ និងផល ។

---

[៧៣] កិលេស ៨ គឺ លោភៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ និងឧទ្ធច្ចៈ ។

ពាក្យថា **"អនធិគតស្ស"** បានដល់ ដើម្បីធ្វើឱ្យច្បាស់នូវឈាន វិបស្សនា មគ្គ និង ផល ។ ពាក្យថា **"អសច្ឆិកតស្ស"** បានដល់ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវឈាន វិបស្សនា មគ្គ និងផលនោះនុ៎ះឯង ដែលនៅមិនបានធ្វើឱ្យជាក់ច្បាស់ ។ ពាក្យថា **"ឥធំ បចមំ"** អធិប្បាយថា ការលិចចុះយ៉ាងនេះថា "លោកអញ្ជើញចុះ យើងនឹង ដេក" នេះ ជាកុសីតវត្ថុទី ១ ។ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួង ដោយន័យនេះ ។

ពាក្យថា **"មាសាចិតំ មញ្ញេ** = ដូចសណ្តែកធ្ងន់" បានដល់ សណ្តែក ដែលបុគ្គលឱ្យសើមដោយទឹក ឈ្មោះថា **សណ្តែកធ្ងន់** ។ អធិប្បាយថា សណ្តែក ធ្ងន់សើមហើយ រមែងជារបស់ធ្ងន់ យ៉ាងណា, កាយរបស់អ្នកខ្ជិលច្រអូសនោះ រមែងធ្ងន់ ក៏យ៉ាងនោះដែរ ។

ពាក្យថា **"គិលានា វុដ្ឋិតោ ហោតិ"** បានដល់ ភិក្ខុត្រឹមតែបាត់ឈឺ ៕

## ចិត្តបដិឃាតក្នុងលោកធម៌

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"អដ្ឋសុ លោកធម្មេសុ"** ក៏ឈ្មោះ ថា **លោកធម៌** ព្រោះជាធម៌របស់លោក ។ សត្វលោកទាំងឡាយ ឈ្មោះថា ផុតពី លោកធម៌នេះ រមែងមិនមានឡើយ, លោកធម៌ទាំងនេះ រមែងមានសូម្បីដល់ព្រះ ពុទ្ធទាំងឡាយមែនពិត ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា **"លោកធម៌"** ។ បទថា **"បដិឃាតោ"** បានដល់ អាការៈ គឺការថ្នាំងថ្នាក់ចិត្ត ។ ពាក្យថា **"លាភេ សារាគោ** = ត្រេកអរក្នុងលាភ" បានដល់ សេចក្តីត្រេកអរ ដែលកើតឡើង ដោយអំណាចនៃសោមនស្សដែលអាស្រ័យផ្ទះយ៉ាងនេះថា "យើង

រមែងបានលាភ” សេចក្តីត្រេកអរនោះ ទើបឈ្មោះថា ខ្ចប់ចិត្ត ។ ពាក្យថា **“អលាភេន បដិវិរោធោ** = ការប្រទូសរ៉ាយក្នុងសេចក្តីសាបសូន្យលាភ” បានដល់ សេចក្តីប្រទូសរ៉ាយដែលកើតឡើង ដោយអំណាចនៃទោមនស្សថា “យើងរមែងមិន បានលាភ” សូម្បីសេចក្តីត្រេកអរប្រទូសរ៉ាយនោះ រមែងខ្ចប់ចិត្ត, ព្រោះហេតុ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា **បដិឃាត** ។ សូម្បីក្នុងពាក្យថា “សេចក្តីត្រេកអរក្នុង **យស**” ជាដើម បណ្ឌិតគប្បីជ្រាបការកើតឡើងនៃធម៌ទាំង នោះ យ៉ាងនេះថា “យើងមានបរិវារច្រើន, យើងមានបរិវារតិច, យើងបានទទួល ការសរសើរ, យើងបានទទួលការនិន្ទា, យើងដល់សុខ, យើងដល់ទុក្ខ” ។ ពាក្យថា **“អនរិយវោហារា”** បានដល់ វោហារ (ពាក្យនិយាយ) របស់បុគ្គលមិនមែនព្រះ អរិយៈ ។

ទោសទាំងឡាយរបស់បុរស ឈ្មោះថា **បុរិសទោសា** ។ ពាក្យថា **“ន សរាមិ”** បានដល់ រមែងកែខ្លួន រមែងឱ្យខ្លួនរួចផុតដោយភាវៈជាអ្នកមិនមានសតិ យ៉ាងនេះថា “យើងរឭកមិនបាន កំណត់មិនបាន នូវឋាននៃកម្មនេះ ដែលយើងធ្វើ ហើយ” ។ ពាក្យថា **“ចោទកំយេវ បដិប្ផរតិ”** បានដល់ ជាអ្នកជំទាស់គ្នាផ្សាយ ទៅ គឺរមែងតាំងនៅដោយភាពជាអ្នកចោទតមាត់គ្នា ។ ពាក្យថា **“កិន្នុ ខោ តុយ្ហំ”** សេចក្តីថា ប្រយោជន៍អ្វីហ្ន៎ ដោយការពោលរបស់លោកអ្នកល្ងង់ មិនឈ្លាស គឺរមែងសម្តែងថា “លោករមែងមិនដឹងរឿងវត្ថុនៃអាបត្តិ រមែងមិនស្គាល់ការ តិះដៀល” ។ អធិប្បាយថា សូម្បីលោកឯង ក៏មិនស្គាល់អាបត្តិ ទើបលោកសម្គាល់ ពាក្យអ្វីៗ ដែលបុគ្គលគប្បីពោលយ៉ាងនេះដូច្នោះ ទោសនោះ រមែងគ្របសង្កត់

លោក ។ ពាក្យថា **"ចោទេតិ"** សេចក្តីថា រមែងពោលលើកអាបត្តិឡើងថា "លោកនោះឯង ត្រូវអាបត្តិ" ជាដើម ។ ពាក្យថា **"បដិករោហិ"** បានដល់ រមែងសម្តែងថា លោកចូរសម្តែងទេសនាគាមិនី (គឺសម្តែងអាបត្តិតាំងពីថុល្លច្ច័យ ដរាបដល់អាបត្តិទាបបំផុត), ចូរចេញចាកវុដ្ឋានគាមិនី (គឺចេញចាក) អាបត្តិសង្ឃាទិសេស; កាលបើតាំងមាំនៅក្នុងសេចក្តីបរិសុទ្ធចាកអាបត្តិទាំងនោះ ទើបគួរជំទាស់អ្នកដទៃ ។ ពាក្យថា **"អញ្ញេន អញ្ញំ បដិចរតិ"** បានដល់ រមែងបិទបាំងហេតុដទៃដោយហេតុដទៃ ឬថា បិទបាំងនូវពាក្យដោយពាក្យ ។ ពាក្យថា **"អាបត្តី អាបន្នោសិ"** បានដល់ រមែងពោលថា "អ្នកនិយាយថាយើងត្រូវអាបត្តិ, យើងត្រូវអាបត្តិអ្វី ? ត្រូវអាបត្តិយ៉ាងណា ? ត្រូវអាបត្តិទីណា ? រមែងនិយាយអ្វីៗ យ៉ាងនេះ" ។ ម្យ៉ាងទៀត កាលសង្ឃពោលថា "អាបត្តិអ្វីៗ ប្រាកដដូច្នេះ លោកឃើញឬ ?" ភិក្ខុនោះ រមែងមិនស្តាប់ រមែងមិនបង្អោនសោតៈចូលទៅ ។ ពាក្យថា **"ពហិទ្ធា កថំ អបនាមេតិ"** បានដល់ ត្រូវសង្ឃសួរថា "លោកត្រូវអាបត្តិឈ្មោះនេះឬ ?" ភិក្ខុអ្នកត្រូវសង្ឃសួរនោះ ក៏នឹងនិយាយជាយ៉ាងដទៃថា "ខ្ញុំទៅក្រុងបាតលិបុត្រ" ។ កាលសង្ឃសួរទៀតថា "ពួកយើងរមែងមិនសួរការទៅក្រុងបាតលិបុត្រ" ។ ភិក្ខុនោះ ក៏នឹងនិយាយតទៅថា "យើងទៅកាន់ក្រុងរាជគ្រឹះ" ។ សង្ឃពោលថា "លោកនឹងទៅក្រុងរាជគ្រឹះ ឬទៅផ្ទះព្រាហ្មណ៍ក៏ដោយ លោកក៏ត្រូវអាបត្តិ" ។ បណ្តាពាក្យនិយាយក្រៅរឿងទាំងនោះ កាលភិក្ខុពោលពាក្យថា "សាច់ជ្រូកដែលយើងបានហើយ" ជាដើម ឈ្មោះថា រមែងនិយាយប្រទាក់គ្នា ។ ពាក្យថា **"កោបំ"** បានដល់ ភាពជាអ្នកក្រោធហើយ ។ ពាក្យថា

**“ទោសំ”** បានដល់ ជាអ្នកប្រទូសរ៉ាយហើយ ។ សូម្បីពាក្យទាំងពីរនេះ ក៏ជាឈ្មោះរបស់សេចក្ដីក្រោធនោះឯង ។ ពាក្យថា **“អប្បច្ចយំ”** បានដល់ កិរិយាដែលមិនសន្ដោស ។ ពាក្យនេះ ជាឈ្មោះរបស់ទោមនស្ស ។ ពាក្យថា **“ឃាតិករោតិ”** បានដល់ រមែងសម្ដែង រមែងប្រកាស ។ ពាក្យថា **“ពាហាវិក្ខេបកំ ភណតិ”** បានដល់ វាសដៃនិយាយពាក្យដែលមិនមានខ្មាស ។ ពាក្យថា **“វិហេសេតិ”** បានដល់ រមែងបៀតបៀន រមែងចាក់ដោត ។ ពាក្យថា **“អនាទយិត្វា”** បានដល់ មិនកាន់យកដោយសេចក្ដីគោរពកោតក្រែង, គឺមើលងាយ និងមិនអើពើ ។ ពាក្យថា **“អតិពាឡំ”** បានដល់ ការខ្វល់ខ្វាយក្រៃលែងហួសប្រមាណ ។ ពាក្យថា **“មយិ-ព្យាវដា”** បានដល់ ការខ្វល់ខ្វាយក្នុងយើង ។ ពាក្យថា **“ហីនាយាវត្តិត្វា”** អធិប្បាយថា លាភេទមកជាគ្រហស្ថ ដើម្បីត្រូវការជាមនុស្សអាក្រក់ ។ ពាក្យថា **“អត្តមនា ហោថ”** បានដល់ រមែងពោលដោយប្រាថ្នាថា “លោកទាំងឡាយ ចូរមានចិត្តត្រេកអរ ចូរបានវត្ថុដែលយើងគប្បីបាន ចូរនៅក្នុងទីដែលយើងគប្បីនៅ, ចូរនៅយ៉ាងសប្បាយ ដែលយើងធ្វើហើយដល់លោកទាំងឡាយ” ។

វាទៈ ដែលប្រព្រឹត្តទៅ ក្នុងពាក្យថា **“អត្តាមិនមានសញ្ញា”** ឈ្មោះថា អសញ្ញីវាទ ។ អសញ្ញីវាទនោះ មានដល់បុគ្គលទាំងនោះ ព្រោះហេតុនោះ បុគ្គលទាំងនោះ ទើបឈ្មោះថា អសញ្ញីវាទ ។ សេចក្ដីយល់ឃើញខុសថា **“អត្តាមានរូប”** ក្នុងពាក្យថា **“រូបី អត្តា”** ជាដើម សេចក្ដីថា ទិដ្ឋិថា “អត្តាមានរូប” រមែងកើតដល់បុគ្គលបានឈាន ព្រោះប្រកាន់កសិណរូបថាជាអត្តា ។ ចំណែកសេចក្ដីយល់ឃើញរបស់អ្នកមិនបានឈាន រមែងមានដោយត្រឹមតែថា ការត្រិះរិះប៉ុណ្ណោះ ដូច

ការយល់ឃើញខុសរបស់អាជីវកទាំងឡាយ ។ ក៏ឯសេចក្ដីយល់ឃើញខុសថា “អត្តាមិនមានរូប” រមែងកើតឡើងដល់អ្នកដែលបានឈានប៉ុណ្ណោះ ។ ព្រោះកាន់យកនិមិត្តក្នុងអរូបសមាបត្តិថាជាអត្តា ។ ការយល់ឃើញខុស របស់អ្នកមិនបានឈានរមែងមានត្រឹមតែសេចក្ដីត្រិះរិះតែម្យ៉ាង ដូចការយល់ឃើញខុសរបស់ពួកនិគ្រន្ថ ក៏ក្នុងទីនេះ បណ្ឌិតគប្បីផ្ទៀងផ្ទាត់ដល់ហេតុ ឱ្យពិតប្រាកដក្នុងភាវៈជាអត្តាដែលមិនមានសញ្ញាមែនពិត ។ ព្រោះថា បុគ្គលអ្នកមានសេចក្ដីយល់ឃើញខុស កាន់យកវត្ថុណាមួយនោះ រមែងដូចជាមនុស្សឆ្កួត ។ ពាក្យថា **“អត្តាទាំងដែលមានរូប និងទាំងមិនមានរូប”** បានដល់ ការយល់ខុស ដែលលោកពោលទុកដោយអំណាចនៃបុគ្គលអ្នកប្រកាន់យករូបជ្ឈាន និងអរូបជ្ឈានលាយគ្នា ។ ទិដ្ឋិនេះ រមែងកើតដល់បុគ្គលអ្នកបានរូបាវចរសមាបត្តិ និងអរូបាវចរសមាបត្តិខ្លះ ដល់អ្នកត្រិះរិះយកដោយខ្លួនឯងខ្លះ ។

ក៏ពាក្យថា **“អត្តាមានរូបក៏មិនមែន មិនមានរូបក៏មិនមែន”** ជាទិដ្ឋិរបស់អ្នកចូលចិត្តត្រិះរិះដោយចំណែកតែមួយប៉ុណ្ណោះ ។ ពាក្យថា “**អន្តវា** = អត្តាមានទីបំផុត” បានដល់ ទិដ្ឋិរបស់បុគ្គលអ្នកប្រកាន់បរិត្តកសិណ (កសិណមានអារម្មណ៍ល្អិតតូច) ដោយសេចក្ដីជាអត្តា ។ ពាក្យថា **“អនន្តវា”** បានដល់ ទិដ្ឋិរបស់អ្នកប្រកាន់កសិណមានអារម្មណ៍ មិនមានប្រមាណ ។ ពាក្យថា “**អន្តវា ច អនន្តវា ច** = អត្តាទាំងឡាយមានទីបំផុត និងរកទីបំផុតមិនបាន” បានដល់ ទិដ្ឋិដែលកើតឡើង ព្រោះកសិណខាងលើ និងខាងក្រោមមានទីបំផុត និងប្រកាន់យកកសិណខាង ទទឹងដែលមិនមានទីបំផុតថាជាអត្តា ។ ពាក្យថា “**នេវន្តវា នានន្ត**

**ទា** = អត្តា មានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន” បានដល់ ទិដ្ឋិរបស់ពួកអ្នកចូលចិត្តគិតប៉ុណ្ណោះ ។ បទដែលនៅសល់ក្នុងទីទាំងពួង មានអត្ថងាយមែនពិត ៕

ចប់អដ្ឋកថាអដ្ឋកនិទ្ទេស

## អដ្ឋកថានវកនិទ្ទេស អធិប្បាយមាតិកាពួក ៩

ពាក្យថា “**អាឃាតវត្ថុ ៩**” នេះ ព្រះមានព្រះភាគត្រាស់ហើយដោយអំណាចនៃធម៌ដែលកើតឡើងក្នុងសត្វទាំងឡាយប៉ុណ្ណោះ ។ ធម៌ទាំងឡាយដែលឈ្មោះថា **បុរិសមលៈ** ព្រោះជាមន្ទិលរបស់បុរស ។ ពាក្យថា “**នវវិធា**” បានដល់ មន្ទិល ៩ ឬថា ៩ ប្រភេទ ៕

## តណ្ហាមូលកធម៌

ពាក្យថា “**តណ្ហំ បដិច្ច**” បានដល់ ព្រោះអាស្រ័យតណ្ហា ។ ពាក្យថា “**បរិយេសនា**” បានដល់ ការស្វែងរកអារម្មណ៍មានរូបារម្មណ៍ជាដើម ។ ពិតមែនកាលតណ្ហាមាន អារម្មណ៍មានរូបារម្មណ៍ជាដើមនេះ ក៏មាន ។ ពាក្យថា “**លាភោ**” បានដល់ ការបានអារម្មណ៍មានរូបារម្មណ៍ជាដើម ។ ពិតមែន កាលបើការស្វែងរកមាន អារម្មណ៍ មានរូបារម្មណ៍ជាដើម ក៏មាន ។

**ក៏វិនិច្ឆ័យមាន ៤** ដោយអំណាចនៃញាណ តណ្ហា ទិដ្ឋិ និងវិតក្កៈ ។

ក្នុងពាក្យទាំង ៤ នោះ បញ្ញាណាដែលគប្បីដឹងការវិនិច្ឆ័យ (កាត់សេចក្តី)

បានដោយងាយ, កាលដឹងការវិនិច្ឆ័យល្អហើយ ក៏ប្រកបសេចក្ដីសុខរឿយៗ ខាងក្នុង (នៃកម្មសុខ) នេះ ឈ្មោះថា **ញាណវិនិច្ឆ័យ**[៧៤] ។ **វិនិច្ឆ័យ ២ យ៉ាងគឺ តណ្ហាវិនិច្ឆ័យ និងទិដ្ឋិវិនិច្ឆ័យ** ដែលមានមកហើយក្នុងព្រះបាលីនោះ តណ្ហាចរិត ១៨ ឈ្មោះថា **តណ្ហាវិនិច្ឆ័យ**[៧៥] ។ ទិដ្ឋិ ៦២ ឈ្មោះថា **ទិដ្ឋិវិនិច្ឆ័យ** ។ **ក៏សេចក្ដីត្រិះរិះនោះឯង ព្រះមានព្រះភាគត្រាស់ហៅថា វិនិច្ឆ័យក្នុងវិភង្គនេះ** មកក្នុងព្រះសូត្រនេះថា "ម្នាលស្ដេចទេព ឆន្ទៈ (សេចក្ដីពេញចិត្ត) នោះឯង ជាហេតុនៃសេចក្ដីត្រិះរិះ"[៧៦] ។

ពិតមែន បុគ្គលណាបានលាភ ហើយរមែងវិនិច្ឆ័យនូវវត្ថុនោះៗ ថា "វត្ថុនេះជារបស់ពេញចិត្ត វត្ថុនេះមិនពេញចិត្ត ឬថា វត្ថុនេះល្អ វត្ថុនេះមិនល្អ ដោយសេចក្ដីត្រិះរិះនោះឯង គឺដោយត្រិះរិះថា 'វត្ថុនេះមានប្រមាណប៉ុណ្ណោះ នឹងមានដល់យើង, ដើម្បីសេចក្ដីចម្រើននៃរូបារម្មណ៍ វត្ថុរបស់មានប្រមាណប៉ុណ្ណោះ សមគួរដល់យើងដើម្បីសេចក្ដីចម្រើនសទ្ទារម្មណ៍ជាដើម វត្ថុរបស់មានប្រមាណប៉ុណ្ណោះ សមគួរដល់យើង, វត្ថុរបស់មានប្រមាណប៉ុណ្ណោះ សមគួរដល់អ្នកដទៃ, យើងនឹងបរិភោគមានប្រមាណប៉ុណ្ណោះ នឹងរក្សាទុកមានប្រមាណប៉ុណ្ណោះ", ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ព្រោះអាស្រ័យការបាន ទើបកើតការវិនិច្ឆ័យ" ។

ពាក្យថា **"ឆន្ទរាគោ"** បានដល់ រាគៈ គឺសេចក្ដីត្រេកអរ ដែលមាន

---

[៧៤] ម. ឧ.។

[៧៥] ខុ. មហា.។

[៧៦] ទី. ម.។

កម្លាំងខ្សោយផង ដែលមានកម្លាំងច្រើនផង រមែងកើតក្នុងវត្ថុដែលត្រិះរិះដោយអកុសលវិតក្កៈយ៉ាងនេះ ។ ក៏ពាក្យថា “**ឆន្ទោ**” ក្នុងវិភង្គនេះ ជាឈ្មោះរបស់រាគៈមានកម្លាំងខ្សោយ ។ ពាក្យថា “**អជ្ឈោសានំ**” បានដល់ សេចក្តីប្រកាន់ដែលមានកម្លាំងថា “ជាយើង ជារបស់យើង” ។ ពាក្យថា “**បរិគ្គហោ** = សេចក្តីហួងហែង ” បានដល់ ការធ្វើសេចក្តីហួងហែង ដោយអំណាចនៃតណ្ហា និងទិដ្ឋិ ។ ពាក្យថា “**មច្ឆរិយំ** = សេចក្តីកំណាញ់” បានដល់ សេចក្តីមិនអត់ធន់ដើម្បីឱ្យជារបស់សាធារណៈដល់ជនពួកដទៃ ។ ដោយហេតុនោះនុ៎ះឯង អាចារ្យក្នុងកាលមុន ទើបពោលសំដៅដល់តណ្ហា និងទិដ្ឋិនោះ ទុកយ៉ាងនេះថា “សេចក្តីអស្ចារ្យនេះ ចូរមានដល់យើងប៉ុណ្ណោះ, ចូរកុំមានដល់បុគ្គលដទៃ” ជាដើម ព្រោះការប្រព្រឹត្តទៅនៃតណ្ហា និងទិដ្ឋិនោះ ទើបព្រះមានព្រះភាគត្រាស់ហៅធម៌នេះថា “សេចក្តីកំណាញ់” ។ ពាក្យថា “**អារក្ខោ** = ការរក្សា” បានដល់ ការរក្សាដោយល្អ ដោយអំណាចនៃការឃុំគ្រង ការពាររបស់នោះៗ ដោយការបិទទ្វារ និងរក្សាទុកក្នុងហិបជាដើម ។ ពាក្យថា “**អធិករោ**” បានដល់ អធិករណ៍ គឺរឿងដែលកើតឡើង ។ ពាក្យថា អធិករណ៍នេះ ជាឈ្មោះរបស់ហេតុ [៧៧] ។ ពាក្យថា “**អារក្ខាធិករណំ**” នេះជាសព្ទនបុំសកលិង្គ, ក្នុងសេចក្តីថា កើត មាន ជា, អធិប្បាយថា ជាហេតុនៃការរក្សា ។

ក៏ព្រះមានព្រះភាគត្រាស់តណ្ហាមូលកធម៌ ៩ ដើម្បីហាមអកុសលធម៌ដទៃៗ ព្រោះការបៀតបៀនសត្វមានការចាប់កំណាត់ឈើជាដើម ។ ការចាប់កាន់កំណាត់ឈើលោកហៅថា **ទណ្ឌាទាន** ។ ការចាប់កាន់សស្ត្រាមានមុខតែម្ខាងជាដើម ឈ្មោះ

---

[៧៧] សំដៅដល់ការនិយាយឿនៗ ថា លោកៗ ។

ថា **សត្ថាទាន** ។ ការឈ្លោះដោយកាយក៏ដោយ ការឈ្លោះដោយវាចាក៏ដោយ ឈ្មោះថា **ការឈ្លោះ** ។ សេចក្តីពិរោធកើតឡើងមុន ឈ្មោះថា **ការប្រកែកគ្នា**; ការពិរោធកើតឡើងក្រោយ ឈ្មោះថា **ការវិវាទគ្នា** ។ ពាក្យថា **"តុវំ តុវំ"** [៧៨] ជាពាក្យដែលមិនគោរព លោកកែសព្ទនេះថាជា **"ត្វំ ត្វំ"** ។

ការចលាចល ការញាប់ញ័រ ឈ្មោះថា **ឥញ្ជិតំ** ។ ព្រះមានព្រះភាគត្រាស់មានះនោះឯង ទុកក្នុងពាក្យថា **"អស្មិ** = ជាយើង" ទុកដោយបទទាំងឡាយដែលមានពាក្យថា **"ឥញ្ជិតមេតំ"** ជាដើម ។ ពិតមែន សូម្បីមានះដែលប្រព្រឹត្តទៅហើយ ក្នុងពាក្យថា **"ជាយើង"** ក៏ឈ្មោះថា **ឥញ្ជិតំ** នោះឯង ។ **នេវសញ្ញីនាសញ្ញី** [៧៩] ដែលប្រព្រឹត្តទៅក្នុងពាក្យថា "នេះជាយើង" ក្តី ឬថា "យើងនឹងប្រព្រឹត្តទៅ" ក្តី ក៏ឈ្មោះថា **ឥញ្ជិតំ** ។ មានះនោះឯង ព្រះមានព្រះភាគត្រាស់ទុកសូម្បីដោយពួក ៩ ដែលនៅសល់ ។

ក៏ព្រះមានព្រះភាគទ្រង់ត្រាស់ថា ឈ្មោះថា **មានះ** ព្រោះសេចក្តីញាប់ញ័រ ។ ឈ្មោះថា សេចក្តីញាប់ញ័រ ព្រោះសេចក្តីសម្គាល់ខ្លួន (ប្រកាន់ខ្លួន) ។ ឈ្មោះថា សេចក្តីសម្គាល់ខ្លួន ព្រោះសេចក្តីក្តៅក្រហាយ ។ ឈ្មោះថា សេចក្តីក្តៅក្រហាយ ព្រោះជាធម៌ញុំាងសត្វឱ្យយឺតយូរ ។ ធម៌ដែលញុំាងសត្វឱ្យយឺតយូរ ឈ្មោះថា

---

[៧៨] សំដៅដល់ការនិយាយឡើន១ ថា លោក១ ។

[៧៩] យើងនឹងជាសត្វមានសញ្ញា ក៏មិនមែន, មិនមានសញ្ញា ក៏មិនមែន ។

**សង្ខត:** ព្រោះការតាក់តែងដោយហេតុនោះៗ ដោយប្រការដូច្នេះ ។ បទដែលនៅសល់ក្នុងទីទាំងពួង មានអត្ថងាយស្រួលមែនពិត ៕

ចប់នវកនិទ្ទេស

## អដ្ឋកថាទសកនិទ្ទេស អធិប្បាយមាតិកាពួក ១០

**កិលេសវត្ថុ ១០** គឺកិលេស ១០ នោះឯង ។ ក៏ក្នុងនិទ្ទេសនេះ **អាឃាតវត្ថុ** ព្រះមានព្រះភាគត្រាស់រឿងនេះ មួយអន្លើដោយអាឃាតដែលកើតឡើងក្នុងអដ្ឋានៈ ដូចជាជំពប់គល់ឈើ និងមុតបន្លាជាដើម ដែលបុគ្គលមិនគប្បីឱ្យកម្រើក ដោយអំណាចនៃបទទាំងឡាយ មានពាក្យថា **"អនត្ថំ មេ អចរតិ** = អ្នកនេះ បានធ្វើសេចក្ដីសាបសូន្យ (វិនាស) ដល់យើង" ជាដើម ។ ពាក្យថា **"មិច្ឆាញាណំ"** ក្នុងមិច្ឆត្តៈ ១០ បានដល់ មោហៈដែលកើតឡើង ដោយកិរិយាពិចារណាថា "បណ្ដាការធ្វើបាបទាំងឡាយ យើងកម្ចាត់បានហើយ កម្ចាត់ល្អហើយ ដោយអំណាចនៃការគិតតាមឧបាយ ។ ពាក្យថា **"មិច្ឆាវិមុត្តិ"** បានដល់ ធម៌ដែលជា ឈ្មោះរបស់វិមុត្តិរបស់បុគ្គលអ្នកមិនទាន់រួចផុតនោះឯង ។ បទដែលនៅសល់ក្នុងទីទាំងពួង មានអត្ថងាយស្រួលមែនពិត ៕

ចប់ទសកនិទ្ទេស

## អដ្ឋកថាតណ្ហាវិចរិតនិទ្ទេស អធិប្បាយតណ្ហាវិចរិត

ពាក្យថា **"តណ្ហាវិចរិតានិ"** បានដល់ ការប្រាកដនៃតណ្ហា ការប្រព្រឹត្ត

ទៅសព្វនៃតណ្ហា ។ ពាក្យថា **“អជ្ឈត្តិកស្ស ឧបាទាយ** = អាស្រ័យបញ្ចក្ខន្ធខាងក្នុង” ។ ពាក្យថា **“អជ្ឈត្តិកស្ស”** នេះជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ ពាក្យថា **“អស្មីតិ ហោតិ** = តណ្ហាថា យើងមាន” ដូច្នេះក៏មាន បានដល់ ពាក្យថា យើងមានដូច្នេះ ក៏មាន ព្រោះអាស្រ័យបញ្ចក្ខន្ធខាងក្នុងនេះឯង ហើយកាន់យកការប្រជុំនៃបញ្ចក្ខន្ធនោះ ដោយអំណាចនៃតណ្ហា មានះ និងទិដ្ឋិ ។ អធិប្បាយថា កាលការប្រជុំនៃខន្ធនោះ នៅមានការប្រកាន់ថាយើងមាន ទើបមាន ។ ក្នុងពាក្យថា **“ឥត្ថស្មីតិ ហោតិ** = យើងមានដោយប្រការនេះ” ជាដើម ដូច្នេះក៏មាន គប្បីជ្រាបថា ការប្រកាន់យកដោយការប្រជុំគ្នាថា យើងមានយ៉ាងនេះ មានការប្រកាន់ ២ យ៉ាង គឺសេចក្តីប្រកាន់យក ដោយការមិនប្រៀបធៀប (អនុបនិធាយ) និងការកាន់យកដោយការប្រៀបធៀប (ឧបនិធាយ) ។ ក្នុង ២ នោះ ពាក្យថា **“អនុបនិធាយ”** បានដល់ ការមិនអាស្រ័យអាការយ៉ាងដទៃថា “យើងមានដោយប្រការនេះ ព្រោះធ្វើភារៈរបស់ខ្លួនប៉ុណ្ណោះ ឱ្យជាអារម្មណ៍” ។ អធិប្បាយថា ការកាន់យកដោយអំណាចនៃតណ្ហា មានះ និងទិដ្ឋិយ៉ាងនេះថា “បណ្តាជនទាំងឡាយ មានក្សត្រជាដើម យើងជាយ៉ាងនេះ” ហៅថា **ការកាន់យកដោយអនុបនិធាយ** សិន ។

ចំណែកការប្រកាន់យកដោយឧបនិធាយ មាន ២ យ៉ាង គឺ ដោយសេចក្តីប្រៀបធៀបស្មើគ្នានឹងខ្លួន និងមិនស្មើនឹងខ្លួន ។ ដើម្បីសម្តែងការប្រកាន់នោះ ទើបព្រះមានព្រះភាគត្រាស់ថា **“ឯវស្មិ”** និងថា **“អញ្ញថស្មិ”** ផង ។ បណ្តាពាក្យទាំងនោះ ពាក្យថា **“ឯវស្មិ”** នេះ ជាការប្រកាន់ដោយប្រៀបធៀបស្មើនឹងខ្លួន ។

អធិប្បាយថា ក្សត្រនេះយ៉ាងណា, ព្រាហ្មណ៍នេះយ៉ាងណា សូម្បីខ្លួនយើង ក៏យ៉ាងនោះ ។ ពាក្យថា **"អញ្ញថស្មិ"** នេះ ជាការប្រកាន់ប្រៀបធៀបដោយសេចក្ដីមិនស្មើនឹងខ្លួន អធិប្បាយថា ក្សត្រនេះយ៉ាងណា, ព្រាហ្មណ៍នេះយ៉ាងណា យើងជាយ៉ាងដទៃ គឺអាក្រក់ជាង ឬថា ក្រៃលែងជាងជនទាំងនោះ ។ តណ្ហាវិចរិតទាំង ៤ នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃបច្ចុប្បន្នមុននោះឯង ។ ចំណែកតណ្ហាវិចរិតទាំង ៤ នេះ ដែលនឹងកើតមានជាដើម ត្រាស់ទុកដោយអំណាចនៃអនាគត ។ បណ្ឌិតគប្បីជ្រាប សេចក្ដីនៃតណ្ហាទាំងនោះ ដោយន័យដែលពោលហើយក្នុងពួក ៤ ដូចបានពោល ទុកមុននោះឯង ។

ពាក្យថា **"អស្មិ"** បានដល់ យើងទៀង ។ ពាក្យថា **"សាតស្មិ"** បានដល់ យើងមិនទៀង ។ ម្យ៉ាងទៀត ព្រះបាលីថា **"អស្មិ សតស្មិ"** ដូច្នេះក៏មាន ។ បណ្ដាបទទាំងនោះ បទថា **"អត្ថិ"** ជាអសធាតុ ។ ពាក្យថា **"អត្ថិ"** នេះ ជាឈ្មោះរបស់ពាក្យថា ទៀង ។ ពាក្យថា **"សីឧតិ"** ជាសតធាតុ ។ ពាក្យថា **"សីឧតិ"** នេះ ជាឈ្មោះរបស់ពាក្យថា មិនទៀង ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបបទទាំងពីរនេះ ដែលព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃសស្សតៈ និងឧច្ឆេទៈ ។ បទទាំង ៤ ខាងមុខពីនេះ មានពាក្យថា **"សិយំ"** [៨០] ជាដើម គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃសេចក្ដីសង្ស័យ និងការខ្វល់ចិត្ត ។ បទទាំងនោះ គប្បីជ្រាបសេចក្ដីដោយន័យដែលពោលទុកក្នុងពួក ៤ ដំបូងនោះឯង ។ ក៏បទទាំង ៤ មានពាក្យថា **"អបាហំ សិយំ"** ជាដើម ព្រះមានព្រះភាគត្រាស់ទុក

---

[៨០] យើងគប្បីជា...ដោយប្រការនេះ យើងគប្បីជា... យ៉ាងនោះ គប្បីជ្រាបដោយប្រការដទៃ ។

ដោយអំណាចនៃអាការប្រាថ្នាយ៉ាងនេះថា "ឈ្មោះថា យើងគប្បីមានដោយប្រការនោះៗ ខ្លះ ។ បទទាំង ៤ នោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងពួក ៤ ដំបូងនោះឯង ។

ក្នុងបទទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះ ៖

**"ទ្វេ ទិដ្ឋិសីសា ចត្តារោ សុទ្ធសីសា សីសមូលកា**
**តយោ តយោតិ ឯតានិ អដ្ឋារស វិភាវយេ**

បណ្ឌិតគប្បីយល់ច្បាស់តណ្ហាវិចរិតធម៌ទាំង ១៨ នេះ គឺ ២ បទ ឈ្មោះថា ទិដ្ឋិសីសៈ (មានទិដ្ឋិជាប្រធាន) ៤ បទ ជាសុទ្ធសីសៈ បទនីមួយៗ ៣ រួម ១២ បទ ជាសីសមូលកៈ" ។

ពិតមែន ក្នុងបទទាំងនោះ ២ បទ ដែលព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃ **សស្សត** និង **ឧច្ឆេទ** ឈ្មោះថា **ទិដ្ឋិសីសៈ** ។ ៤ បទទាំងនេះ គឺ **អស្មិ** = តណ្ហាថាយើងមាន, **ភវិស្សំ** = តណ្ហាថា យើងនឹងមាន, **សិយំ** = តណ្ហាថា យើងគប្បីមាន, **អបាហំ សិយំ** = តណ្ហាថា យើងគប្បីមាន, ឈ្មោះថា **សុទ្ធសីសៈ** ប៉ុណ្ណោះ ។ ១២ បទ គឺម្យ៉ាងៗ ៣ មានពាក្យថា "**អថស្មិ** = តណ្ហាថា យើងមានដោយប្រការដូច្នេះ" ជាដើម ឈ្មោះថា **សីសមូលកៈ** ព្រោះហេតុដូច្នោះ គប្បីជ្រាបតណ្ហាវិចរិតធម៌ទាំងនោះ យ៉ាងនេះថា "២ បទ ឈ្មោះថា ទិដ្ឋិសីសៈ, ៤ បទ ឈ្មោះថា សុទ្ធសីសៈ, ១២ បទ ឈ្មោះថា សីសមូលកៈ" ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់ចែកសម្តែងធម៌ទាំងនោះ (តណ្ហា-

វិចរិត) ដោយលំដាប់តែម្តង ទើបផ្តើមពាក្យថា “**កថញ្ច អស្មីតិ ហោតិ** = ក៏តណ្ហា ថា យើងមាន គឺយ៉ាងណា” ជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យថា “ **កិញ្ចិធម្មំ អនវការី ករិត្វា** = មិនធ្វើការវែញកធម៌យ៉ាងណាមួយ” អធិប្បាយថា មិនធ្វើការ ចែកធម៌អ្វីៗ សូម្បីត្រឹមតែម្យ៉ាង គឺមិនកាន់យកតែមួយៗ ក្នុងបណ្តាធម៌ទាំងឡាយ មានរូប និងវេទនាជាដើម ដោយកាន់យករួមគ្នានោះឯង ។ ពាក្យថា “**អស្មីតិ ឆន្ទំ បដិលភតិ** = រមែងបានឆន្ទៈ គឺសេចក្តីពេញចិត្តថា យើងមានដូច្នេះ” អធិប្បាយថា កាន់យកបញ្ចក្ខន្ធរួមគ្នាទាំងអស់ហើយ រមែងបានតណ្ហាថា “យើង” ។ សូម្បីក្នុង ពាក្យថា **មានះ ទិដ្ឋិ** ក៏ន័យនេះដែរ ។ ក្នុងធម៌ទាំងនោះ (គឺតណ្ហា មានះ ទិដ្ឋិ) និទ្ទេសនេះ ជាតណ្ហាវិចរិតនិទ្ទេស ក៏ពិតមែន, ប៉ុន្តែ មានះ និងទិដ្ឋិ ក៏មិនវៀរចាក តណ្ហា ។ ព្រោះហេតុដូច្នោះ ក្នុងតណ្ហាវិចរិតនិទ្ទេស ទើបព្រះមានព្រះភាគត្រាស់ មានះ និងទិដ្ឋិទុក ដោយអំណាចនៃអត្ថតែមួយ ជាមួយនឹងតណ្ហាវិចរិតនោះ។ ម្យ៉ាងទៀត សូម្បីធម៌ទាំង ៣ គឺ តណ្ហា មានះ និងទិដ្ឋិ ដែលជាធម៌ធ្វើសត្វឱ្យយឺត-យូរ ព្រះមានព្រះភាគទ្រង់លើកឡើងសម្តែងដោយតណ្ហាសីសៈ (តណ្ហាជាប្រធាន) ចំណែកមានះ និងទិដ្ឋិ ព្រះមានព្រះភាគទ្រង់កាន់យកដើម្បីអធិប្បាយតណ្ហានោះ ដោយសមគួរដល់ធម៌ ដែលលើកឡើងសម្តែងប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត ព្រះមាន-ព្រះភាគកាលទ្រង់សម្តែងធម៌ ជាគ្រឿងយឺតយូរ គឺតណ្ហា ទើបត្រាស់ទុកយ៉ាងនេះ ដើម្បីសម្តែងសូម្បីធម៌ជាគ្រឿង យឺតយូរដែលនៅសល់ (គឺមានះ ទិដ្ឋិ) និងតណ្ហា នោះឯង ។ ពាក្យថា “**តស្មិំ សតិ ឥមានិ បបញ្ចិតានិ** = កាលធម៌ទាំង ៣ មាន ធម៌ជាគ្រឿងយឺតយូរទាំងនេះ” , អធិប្បាយថា កាលធម៌ជាគ្រឿងយឺតយូរ ៣

យ៉ាង ដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យថា **“តស្មិំ អស្មីតិ ឆន្ទំ បដិ-លភតិ”** ជាដើមមាន ធម៌ទាំងនេះ មានពាក្យថា **“ឥត្ថិស្មីតិ វា** = យើងប្រព្រឹត្តទៅដោយប្រការនោះ” ជាដើម រមែងជាធម៌ជាគ្រឿងឱ្យយឺតយូរហើយ ។

ក្នុងពាក្យទាំងឡាយមានពាក្យថា **“ខត្តិយោស្មិ** = តណ្ហាថា យើងជាក្សត្រ” ជាដើម បណ្ឌិតគប្បីជ្រាបសេចក្តីដោយន័យនេះថា “យើងឈ្មោះថា ជាក្សត្រ ដោយសេនាមាត្យជាដើម អភិសេក (តែងតាំង) យើងឈ្មោះថា ជាព្រាហ្មណ៍ ដោយភាពជាបុរោហិត ដោយការរៀនមន្តជាដើម, យើងឈ្មោះថា វេស្សៈ ដោយការរក្សាស្រែនិងគោជាដើម, យើងឈ្មោះថា ដូចជាជាតិសូទ្រៈ ដោយភាពជាអ្នកស្វែងរកអាហារ, យើងឈ្មោះថា ជាអ្នកគ្រប់គ្រងផ្ទះ ដោយលក្ខណៈរបស់គ្រហស្ថ” ។ ពាក្យថា **“ឯវំ ឥត្ថស្មីតិ ហោតិ** = តណ្ហាថា យើងជាយ៉ាងនោះ” អធិប្បាយថា តណ្ហារមែងញុំាងពិធីការនៃក្សត្រជាដើម ក្នុងជនទាំងឡាយមានក្សត្រជាដើម ឱ្យកើតឡើងក្នុងខ្លួនយ៉ាងនេះហើយ ទើបពេញចិត្តវិធីការ ដោយប្រការយ៉ាងនេះថា “ជាយើង” ។ ក្នុងពាក្យថា **“យថា សោ ខត្តិយោ”** ជាដើម គប្បីជ្រាបសេចក្តី ដោយន័យនេះថា “ជននោះ ជាក្សត្រដោយសេនាមាត្យជាដើម អភិសេកយ៉ាងណា, សូម្បីយើង ក៏ជាក្សត្រ” ។ ក្នុងន័យទី ២ គប្បីជ្រាបសេចក្តីដោយន័យនេះថា “បុគ្គលនោះ ជាក្សត្រដោយសេនាមាត្យជាដើម អភិសេកយ៉ាងណា, តែយើងមិនជាក្សត្រដូច្នោះទេ, គឺថាជាអ្នកអាក្រក់ជាងអ្នកនោះ, ឬថា ប្រសើរជាង” ។ សូម្បីក្នុងនិទ្ទេសនៃពាក្យថា

**“តទិស្សំ”** ជាដើម ក៏ន័យនេះដែរ ។

ព្រះមានព្រះភាគ ត្រាទ្រង់ចែកតណ្ហាវិចរិតអាស្រ័យបញ្ចក្ខន្ធខាងក្នុង យ៉ាងនេះហើយ ឥឡូវនេះ គប្បីទ្រង់ចែកតណ្ហាវិចរិតអាស្រ័យបញ្ចក្ខន្ធខាងក្រៅ ទើបត្រាស់ពាក្យថា **“តត្ថ កតមានិ”** ជាដើម ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **“ពាហិរស្ស ឧបាទាយ”** បានដល់ អាស្រ័យបញ្ចក្ខន្ធខាងក្រៅ ។ ពិតមែន សូម្បីពាក្យថា **“ពាហិរស្ស ឧបាទាយ”** នេះ ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ ពាក្យថា **“ឥមិនា”** បានដល់ ដោយរូបនេះ ។ ល ។ ឬថា ដោយវិញ្ញាណនេះ ក៏ពាក្យដែលនៅសល់ បណ្ឌិតគប្បីជ្រាបសេចក្ដីដោយន័យដែលពោលហើយ ក្នុងនិទ្ទេសវារៈមុននោះឯង ។ ក្នុងនិទ្ទេសវារៈ ពាក្យថា **“អវករិំ ករិត្វា”** បានដល់ ធ្វើការញែកបញ្ចក្ខន្ធ ។ ក្នុងពាក្យទាំងឡាយ មានពាក្យថា **“ឥមិនា អស្មីតិ ឆន្ទំ បដិលភតិ”** ជាដើម បណ្ឌិតគួរជ្រាបសេចក្ដីយ៉ាងនេះថា បុគ្គលកាន់យកបញ្ចក្ខន្ធយ៉ាងនេះថា **“ឥមិនា រូបេន វា ។ ល ។ វិញ្ញាណេន វា”** ដោយឯកទេស រមែងបានឆន្ទៈថា យើងមានដោយរូបនេះជាដើម ។

ក្នុងពាក្យទាំងឡាយមានពាក្យថា **“ឥមិនា ខត្តិយោស្មិ”** ជាដើម គប្បីជ្រាបសេចក្ដីដោយន័យមុននោះឯង យ៉ាងនេះថា “យើងជាក្សត្រដោយឆត្រ ឬថា ដោយព្រះខ័ន្គ ឬថា ដោយសេនាមាត្យអភិសេក” ។ ពិតមែន បទថា **“ឥមិនា”** ត្រឹមតែជាបទប៉ុណ្ណោះ គឺជាពាក្យវិសេសក្នុងសេចក្ដីនេះ ។ បទដែលលោកពោលថា

**"ឥមិនា"** នោះឯង សូម្បីក្នុងពាក្យថា **"យថា សោ ខត្តិយោ"** ជាដើម ក៏ជាបទវិសេស ។ ព្រោះហេតុដូច្នោះ បណ្ឌិតគ្រាប្រកបបទយ៉ាងនេះថា "ជាក្សត្រដោយអំណាចនៃរូបនោះ យ៉ាងណា, សូម្បីយើងក៏យ៉ាងនោះ ឬជាក្សត្រ ដោយព្រះខ័ន្ឌ ឬថា ដោយឆត្រ ឬក៏ដោយសេនាមាត្យអភិសេកនេះ យ៉ាងណា យើងក៏ដូច្នោះ" គប្បីជ្រាបសេចក្តីក្នុងបទទាំងឡាយដោយន័យនេះ ។ ពាក្យថា **"ឥមិនា និច្ចោស្មិ** = យើងទៀង ដោយរូបនេះ" អធិប្បាយថា គ្រាធ្វើការចែកបញ្ចក្ខន្ធហើយក៏កាន់យកធម៌ម្យ៉ាង ក្នុងរូបជាដើមនុ៎ះឯងថា "ជាយើង" ហើយ រមែងសម្គាល់ថា "យើងទៀង យើងនៅយឺនយូរ ដោយព្រះខន្ឌនេះ ឬថា ដោយឆត្រនេះ" ។ សូម្បីក្នុងពាក្យថា **ឱច្ឆេទនិដ្ឋិ** នេះ ក៏ន័យនេះដែរ ។ ពាក្យដែលនៅសល់ក្នុងបទទាំងពួងគប្បីជ្រាបដោយន័យដែលពោលហើយ ។

ពាក្យថា **"ឥតិ ឯវរូបានិ អតីតានិ ឆត្តឹស"** បានដល់ តណ្ហាវិចរិតក្នុងអតីតៈរបស់បុគ្គលតែម្នាក់ៗ មាន ៣៦ ។ ពាក្យថា **"អនាគតានិ ឆត្តឹស"** បានដល់ តណ្ហាវិចរិតក្នុងអនាគតរបស់បុគ្គលម្នាក់ៗ នុ៎ះឯង មាន ៣៦ ។ ពាក្យថា **"បច្ចុប្បន្នានិ ឆត្តឹស"** តណ្ហាវិចរិតក្នុងបច្ចុប្បន្ន ៣៦ របស់បុគ្គលមួយៗ ឬថាច្រើននាក់ដោយអំណាចនៃតណ្ហា តាមដែលបាន ។ ក៏បណ្ឌិតគប្បីជ្រាបតណ្ហាវិចរិតរបស់សត្វទាំងឡាយក្នុងអតីតៈ ដោយចំណែកតែមួយប៉ុណ្ណោះ មាន ៣៦, ក្នុងអនាគត ៣៦, ក្នុងបច្ចុប្បន្ន ៣៦ ។ ពិតមែន សត្វទាំងឡាយ ប្រភេទដែលមានតណ្ហា មានះ និងទិដ្ឋិ មិនដូចគ្នា **មានច្រើនរកទីបំផុតមិនបាន** ។ ម្យ៉ាងទៀត

ក្នុងខថា “**អដ្ឋសតំ តណ្ហាវិចរិតំ ហោតិ**” នេះ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងទីនេះយ៉ាងនេះថា “តណ្ហាវិចរិត ពោលគឺតណ្ហា ១០៨” នោះឯង ។ បទដែលនៅសល់ក្នុងទីទាំងពួង មានអត្ថងាយស្រួលទាំងអស់នោះឯង ៕

ចប់តណ្ហាវិចរិតនិទ្ទេស

## ទិដ្ឋិគតនិទ្ទេស

ពាក្យថា “**ព្រហ្មជាលេ វេយ្យាករណេ**” បានដល់ ព្រះសូត្រទីមួយនៃគម្ពីរទីឃនិកាយ ដែលជាពាក្យវេយ្យាករណ៍ ឈ្មោះថា **ព្រហ្មជាលៈ** ។ ពាក្យថា “**វុត្តានិ ភគវតា**” បានដល់ ភាសិតដែលព្រះសាស្តាត្រាស់ដោយព្រះអង្គឯង ។ ក្នុងពាក្យថា “**ចត្តារោ សស្សតវាទា**” ជាដើម បណ្ឌិតគប្បីជ្រាបប្រភេទ និងសេចក្តីនៃទិដ្ឋិ ដោយន័យដែលពោលហើយក្នុងព្រហ្មជាលសូត្រ មានពាក្យថា “**តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញាបេន្តិ ចតូហិ វត្ថូហិ** = ក៏សមណព្រាហ្មណ៍ដ៏ចម្រើនដែលមានវាទៈថាទៀងទាំងនោះ អាស្រ័យនូវអ្វី ? ប្រារព្ធអ្វី ? ទើបបញ្ញត្តថា អត្តា និងលោកទៀង ដោយហេតុ ៤ ប្រការ”[៨១] ជាដើមនោះឯង ។

## ចប់អដ្ឋកថាខុទ្ទកវត្ថុវិភង្គ

[៨១] ទី. សី. ។

# ១៨.អដ្ឋកថាធម្មហទយវិភង្គ

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបការកំណត់ព្រះបាលីក្នុង **ធម្មហទយវិភង្គ** ដែលជាលំដាប់តអំពី **ខុទ្ទកវត្ថុវិភង្គ** ដូចតទៅយ៉ាងនេះជាមុនសិន ៖

ក៏ក្នុងវារៈនេះ ឈ្មោះថា **សព្វសង្គាហិកវារៈ** គឺវារៈពោលអំពីការរួបរួមធម៌ទាំងឡាយ ដែលព្រះមានព្រះភាគត្រាស់ទុក ដោយអំណាចនៃពួកធម៌ទាំងឡាយ ១២ ពួក ផ្តើមតាំងអំពីខន្ធជាដើមទៅ ។

**វារៈទី ២** ឈ្មោះថា **ឧប្បត្តានុប្បត្តិទស្សនវារៈ** គឺវារៈពោលអំពីការសម្តែង ការកើតឡើង និងការមិនកើតឡើងនៃធម៌ទាំងឡាយនោះឯង ក្នុងកាមធាតុជាដើម ។

**វារៈទី ៣** ឈ្មោះថា **បរិយាបន្នាបរិយាបន្នទស្សនវារៈ** គឺវារៈពោលអំពីការ សម្តែងធម៌ដែលរាប់បញ្ចូលគ្នា និងមិនរាប់បញ្ចូលគ្នា ក្នុងកាមធាតុទាំងនោះឯង ។

**វារៈទី ៤** ឈ្មោះថា **វិជ្ជមានាវិជ្ជមានធម្មទស្សនវារៈ** គឺវារៈពោលអំពីការសម្តែងធម៌ដែលមាន និងមិនមាន ក្នុងខណៈនៃការកើតឡើងក្នុងភូមិទាំង ៣ ។

**វារៈទី ៥** ឈ្មោះថា **ទស្សនវារៈ** គឺវារៈពោលអំពីការសម្តែងធម៌ទាំងនោះដោយអំណាចនៃការប្រព្រឹត្តទៅក្នុងចន្លោះភូមិ ។

**វារៈទី ៦** ឈ្មោះថា **ឧប្បាទកម្មាយុប្បមាណទស្សនវារៈ** គឺវារៈពោលអំពីការសម្តែងប្រមាណនៃអាយុ ដែលកើតឡើងព្រោះកម្មនោះក្នុងគតិទាំងឡាយ ។

**វារៈទី ៧** ឈ្មោះថា **អភិញ្ញេយ្យាទិវារៈ** គឺវារៈពោលអំពីធម៌ដែលគប្បីដឹងក្រៃលែងជាដើម ។

**វារៈទី ៨ ឈ្មោះថា សារម្មណានារម្មណាទិវារៈ** គឺវារៈពោលអំពីសារម្មណធម៌ អនារម្មណធម៌ជាដើម ។

**វារៈទី ៩ ឈ្មោះថា ទស្សនវារៈ** ព្រោះសង្គ្រោះធម៌មានខន្ធជាដើមនោះ ដោយអំណាចនៃទិដ្ឋិ និងសុតៈជាដើម ។

**វារៈទី ១០ ឈ្មោះថា ទស្សនវារៈ** ព្រោះសង្គ្រោះធម៌ទាំងនោះ ដោយអំណាចនៃតិកមាតិកា មានកុសលត្តិកៈជាដើម ៕

## អធិប្បាយសព្វសង្គាហិកវារៈទី ១

បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងវារៈទី ១ ឈ្មោះថា **សព្វសង្គាហិកវារៈ** សិនដោយព្រះបាលីដែលព្រះមានព្រះភាគទ្រង់កំណត់ទុកដោយវារៈទាំង ១០ យ៉ាងនេះ គឺ កាលត្រាស់មិនបានត្រាស់ថា ខន្ធ ១ ។ល ។ ឬខន្ធ ៤ ឬថា ខន្ធ ៦ (ខន្ធទាំង ៦ ពួកតិរ្ថិយបញ្ញត្តឡើង) តែត្រាស់ថា ខន្ធទាំងឡាយមានប៉ុន្មាន ក្នុងការប្រព្រឹត្តទៅក្នុងរវាងនៃភូមិ ចាប់ផ្ដើមតាំងពីអវីចិមហានរក ដរាបដល់ភវគ្គភូមិ អ្នកដទៃឈ្មោះថា អាចដើម្បីនឹងពោលថា "ខន្ធ ៥" មិនបាន ព្រោះហេតុដូច្នោះ ដើម្បីសម្ដែងកម្លាំងនៃព្រះតថាគតរបស់ព្រះអង្គ ទើបត្រាស់ពាក្យវិស្សជ្ជនា ដែលសមគួរដល់ពាក្យសួរ ក្នុងកម្លាំងនៃព្រះញាណនេះថា ឈ្មោះថា សព្វញ្ញុព្យាករណ៍ ។ សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា **អាយតនៈ ១២** ជាដើម ក៏ន័យនេះដែរ ។ បណ្ឌិត

គប្បីជ្រាបប្រភេទនៃធម៌ទាំងឡាយ មាន **រូបក្ខន្ធ** ជាដើម ដោយន័យដូចពោល ហើយក្នុងខន្ធវិភង្គជាដើម ៕

## អធិប្បាយឧប្បត្តានុប្បត្តិឧស្សនវារៈទី ២

**ក្នុងវារៈទី ២** ពួកធម៌ណា រមែងកើតដល់សត្វទាំងឡាយ អ្នកកើតហើយក្នុងកាមធាតុ ក្នុងកាមភព ព្រះមានព្រះភាគទ្រង់សង្គ្រោះធម៌ទាំងឡាយ ដែលរាប់បញ្ចូលគ្នា និងមិនរាប់បញ្ចូលគ្នា ក្នុងកាមធាតុទាំងនោះ ហើយត្រាស់ពាក្យថា **"កាមធាតុយា បញ្ចក្ខន្ធា"** ជាដើម ។ សូម្បីក្នុងរូបធាតុជាដើម ក៏ន័យនេះដែរ ។ ក៏ព្រោះអាយតនៈជាដើម រមែងមិនធ្វើកិច្ចនៃអាយតនៈជាដើម ព្រោះការមិនមាន **ឃានាយតនៈ** ជាដើម របស់ព្រហ្មទាំងឡាយ អ្នករាប់បញ្ចូលក្នុងរូបធាតុ, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **"រូបធាតុយា ឆ អាយតនានិ, នវ ធាតុយោ"** ជាដើម ។ ម្យ៉ាងទៀត ក៏ឈ្មោះថា ធាតុដែលមិនរាប់បញ្ចូល ដោយអំណាចនៃឱកាស ឬថា ដោយអំណាចនៃការកើតឡើងរបស់សត្វ រមែងមិនមាន ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគមិនត្រាស់ពាក្យថា **"អបរិយាបន្នធាតុយា"** ជាដើម សម្ដែងនូវធាតុណាៗ ដែលមិនរាប់បញ្ចូល ហើយនុ៎ះឯង ទើបត្រាស់ថា **"អបរិយាបន្នេ ភតិ ខន្ធា** = ខន្ធណា មិនរាប់បញ្ចូល" ជាដើម ៕

## អធិប្បាយបរិយាបន្នាបរិយាបន្នទស្សនវារៈទី ៣

ក្នុងវារៈទី ៣ ពាក្យថា **"កាមធាតុយា បរិយាបន្នា"** អធិប្បាយថា **បរិយាបន្នា** ព្រោះអត្ថថា កាលសេពនូវកាមធាតុ អាស្រ័យនូវកាមធាតុ នៅខាងក្នុង កាមធាតុនោះ ធ្លាក់ចុះកាន់កាមធាតុនោះ ទើបដល់ការរាប់ថា ជាកាមធាតុនោះឯង ។ សូម្បីបទដែលនៅសល់ ក៏ន័យនេះដែរ ។ ពាក្យថា **"បរិយាបន្នា"** បានដល់ ជាពាក្យកំណត់ធម៌ទាំងនោះ ដោយអំណាចនៃភព និងដោយអំណាចនៃឱកាស ឬថា ដោយអាស្រ័យការកើតឡើងនៃសត្វ ។ ពាក្យថា **"អបរិយាបន្នា"** បានដល់ ជាពាក្យមិនកំណត់យ៉ាងនោះ ៕

## អធិប្បាយវិជ្ជមានាវិជ្ជមានធម្មទស្សនវារៈទី ៤

ក្នុងវារៈទី ៤ ពាក្យថា **"ឯកាទសាយតនានិ"** បានដល់ អាយតនៈ ១១ វៀរសទ្ទាយតនៈ ។ ពិតមែន សទ្ទាយតនៈនោះរមែងមិនកើតក្នុងខណៈបដិសន្ធិពិតប្រាកដ ។ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងបទទាំងពួង ដោយន័យនេះ ។ ក្នុងទីនេះ ព្រះមានព្រះភាគទ្រង់មិនបានត្រាស់គតិនៃទេព និងអសុរក្នុងពួកទាំង ៧ ក្នុងវារៈនេះ តែត្រាស់គតិនៃ **គព្ភសេយ្យកៈ**ទាំងឡាយទុកដោយមិនប្លែកគ្នា ។ ព្រោះហេតុដូច្នោះ គប្បីជ្រាបថា គព្ភសេយ្យកៈទាំងឡាយ រមែងកើតក្នុងទីណាៗ, អាយតនៈរបស់ទេព និងអសុរទាំងឡាយនោះ រមែងកើតក្នុងទីនោះៗ ។ ធាតុទាំងឡាយក៏យ៉ាងនោះដែរ ។ ពាក្យដែលនៅសល់ក្នុងទីនេះ មានអត្ថងាយទាំងអស់ ៕

## អធិប្បាយឧស្សទវារៈទី ៥

ពាក្យណាដែលនឹងពោល ក្នុងវារៈទី ៥, ពាក្យនោះ ខ្ញុំពោលហើយក្នុងអដ្ឋកថានៃធម្មសង្គហៈនុ៎ះឯង ៕

## អធិប្បាយឧប្បាទកម្មាយុប្បមាណឧស្សទវារៈទី ៦

ក្នុងវារៈទី ៦ ឈ្មោះថា **ទេវតា** (ទេព) ព្រោះរមែងរីករាយដោយបញ្ច-កាមគុណមានប្រការផ្សេងៗ ដែលពិសេសដោយឫទ្ធិ ។ ពាក្យថា **"សម្មតិ-ទេវោ"** បានដល់ ទេវៈដោយសន្មតរបស់មនុស្សលោកយ៉ាងនេះ គឺព្រះរាជា ព្រះទេវី ។ ពាក្យថា **"ឧប្បត្តិទេវា"** បានដល់ ជាទេវតាដោយឧប្បត្តិ ព្រោះការកើតឡើងក្នុងទេវលោក ។ ពាក្យថា **"វិសុទ្ធិទេព"** បានដល់ ជាទេវតាដោយសេចក្តីបរិសុទ្ធចាកកិលេសទាំងឡាយ គួរដល់ការបូជារបស់ទេវតាទាំងអស់ ។ ពាក្យថា **"រាជា"** នោះ បានដល់ ក្សត្រដែលមុទ្ធាភិសេកហើយ ។ ពាក្យថា **"ទេវិយោ"** បានដល់ ជាមហេសីរបស់ព្រះរាជាទាំងនោះ; ពាក្យថា **"ឧបោសថកម្មំ ករិត្វា"** បានដល់ ចូរធ្វើឧបោសថដែលប្រកបដោយអង្គ ៨ ក្នុងថ្ងៃទី ១៤ ជាដើម ។ តឡូវនេះ ព្រោះបុញ្ញកម្មមានការឱ្យទានបន្តិចបន្តួចៗ ជាដើម រមែងជាបច្ច័យដល់ភាពជាមនុស្សមានរូបល្អ, គឺថា បុញ្ញកម្មដែលធ្វើច្រើនក្រៃលែង ក៏រមែងជាបច្ច័យដល់ភាពជាខត្តិយមហាសាលជាដើម មានប្រការផ្សេងៗ ដែលជាចំណែកច្រើនប្រ-ការ ក្នុងបុញ្ញកម្មដ៏ក្រៃលែង, ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទ្រង់សំ-ដែងសេចក្តីផ្សេងគ្នា នៃការកើតឡើងដោយអំណាចនៃបុញ្ញកម្មនោះ ទើបត្រាស់

ពាក្យថា **“អប្បេកច្ចេ គហបតិ មហាសលានំ** = មនុស្សខ្លះ ចូលដល់ភាពជាគហបតីមហាសាល” ជាដើម ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **“មហន្តោ សារោ ឯតេសំ”** គប្បីជ្រាបវិនិច្ឆ័យថា សារៈ (ភាពមាំទាំ) ដ៏ធំ របស់បុគ្គលទាំងនេះមាន ព្រោះហេតុនោះ បុគ្គលទាំងនោះ ទើបឈ្មោះថា **មហាសារៈ** (អ្នកមាំទាំ), ក៏ពាក្យថា **“មហាសារៈ”** នេះ លោកផ្លាស់អក្សរ **រ** ឱ្យជាអក្សរ **ល** ទើបជាមហាសាល ។ ម្យ៉ាងទៀត គហបតីទាំងឡាយនោះឯង ជាអ្នកមហាសាល, ឬថា ភារៈនៃមហាសាលទាំងឡាយ មានដល់គហបតីទាំងឡាយ ព្រោះហេតុនោះ គហបតីនោះ ទើបឈ្មោះថា **គហបតីមហាសាល** ។ សូម្បីពាក្យដែលនៅសល់ទាំងពួង ក៏ន័យនេះដែរ ៕

## គហបតីមហាសាល

ក្នុងបុគ្គលទាំងនោះ ក្នុងភូមិរបស់បុគ្គលទាំងឡាយណា មានទ្រព្យរក្សាទុកយ៉ាងតិច ៤០ កោដិ និងរមែងចាយកហាបណៈទាំងឡាយ គាក់តែងអាហារប្រចាំថ្ងៃ ៥ អម្ពណៈ ក្នុងមួយថ្ងៃៗ អ្នកនេះឈ្មោះថា **គហបតីមហាសាល** ៕

## ព្រាហ្មណមហាសាល

ក៏ក្នុងផ្ទះរបស់បុគ្គលណា មានទ្រព្យយ៉ាងតិចបំផុត ៨០ កោដិ និងរមែងចាយកហាបណៈទាំងឡាយ គាក់តែងអាហារ ១០ អម្ពណៈ ក្នុងមួយថ្ងៃៗ បុគ្គលនេះ ឈ្មោះថា **ព្រាហ្មណមហាសាល** ៕

## ខត្តិយមហាសាល

ក្នុងព្រះរាជមណ្ឌបរបស់ព្រះរាជាអង្គណា មានព្រះរាជទ្រព្យតម្កល់នៅក្នុងឃ្លាំង យ៉ាងតិចបំផុត ១០០ កោដិ និងរមែងចាយកហាបណៈទាំងឡាយ គាក់តែងអាហារ ២០ អម្ពណៈ ក្នុងមួយថ្ងៃៗ ព្រះរាជានេះឈ្មោះថា **ខត្តិយមហាសាល** ។

ពាក្យថា **"សមាគន្តិ"** បានដល់ ភាពជាអ្នកនៅរួមគ្នា (ជាសម្លាញ់នឹងគ្នា) អធិប្បាយថា កើតស្មើគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"ចាតុម្មហារាជិកានំ"** ជាដើម ទេវតាទាំងឡាយ ឈ្មោះថា **ចាតុម្មហារាជិកា** រមែងមាននៅត្រង់កណ្តាលនៃភ្នំឈ្មោះសិនេរុ ។ ក្នុងទេវតាទាំងនោះ ពួកខ្លះតាំងនៅត្រង់ភ្នំ, ពួកខ្លះតាំងនៅលើអាកាស, លំដាប់នៃទេវតាទាំងនោះ ដល់ភ្នំចក្កវាឡ ទេវតាទាំងនេះ គឺឈ្មោះថា ខិឌ្ឌាបទោសិកៈ, ឈ្មោះថា មនោបទោសិកៈ, ឈ្មោះថា សីតវលាហកៈ, ឈ្មោះថា ឧណ្ហវលាហកៈ, ឈ្មោះថា ចន្ទិមទេវបុត្រ, ឈ្មោះថា សុរិយទេវបុត្រ, សូម្បីទាំងអស់តាំងនៅក្នុងទេវលោកជាន់ចាតុម្មហារាជិកាប៉ុណ្ណោះ ។ ជនទាំងឡាយ ៣៣ នាក់កើតឡើងហើយ ក្នុងទេវលោកនោះ ព្រោះហេតុនោះ ទេវលោកនោះ ទើបឈ្មោះថា **តាវត្តិង្ស** (ទេវលោកជាទីនៅរបស់ទេវតា ៣៣ នាក់) ក៏សូម្បីទេវតាទាំងនោះតាំងនៅត្រង់ភ្នំ ក៏មាន, តាំងនៅលើអាកាស ក៏មាន ។ លំដាប់នៃទេវតាទាំងនោះក៏ដល់ភ្នំចក្កវាឡ ។ ក៏លំដាប់របស់ទេវតាយាមាជាដើម ក៏ដូចគ្នា; ពិតមែន សូម្បីក្នុងទេវលោកមួយ លំដាប់របស់ទេវតាទាំងឡាយ ឈ្មោះថា មិនដល់ភ្នំចក្កវាឡរមែងមិនមាន ។ ក្នុងទេវតាទាំងនោះ ទេវតាទាំងឡាយណា ញ៉ាំងជីវិតឱ្យប្រព្រឹត្ត

ទៅ ញុំាងជីវិតឱ្យដល់ព្រមនូវសេចក្ដីសុខដែលជាទិព្វ ព្រោះហេតុនោះ ទេវតាទាំងនោះ ទើបឈ្មោះថា **យាមា** ។

ទេវតាទាំងឡាយណា ជាអ្នកត្រេកអរហើយ រីករាយហើយ ព្រោះហេតុ-នោះ ទេវតាទាំងនោះ ទើបឈ្មោះថា **តុសិត** ។

ទេវតាទាំងឡាយណា និម្មិតហើយៗ រមែងត្រេកអរក្នុងការបរិភោគកាម (កាមភោគៈ) តាមពេញចិត្តក្នុងវេលាដែលប្រាថ្នាដើម្បីត្រេកអរក្រៃលែង ដោយភាពជាអារម្មណ៍ដែលតាក់តែងតាមប្រក្រតី ព្រោះហេតុនោះ ទេវតានោះ ទើបឈ្មោះថា **និម្មានរតី** ។

ទេវតាទាំងឡាយណា ជ្រាបនូវអាចារៈនៃចិត្តហើយ ញុំាងអំណាចឱ្យប្រ-ព្រឹត្តទៅក្នុងភោគៈទាំងឡាយ ដែលអ្នកដទៃនិម្មិតឱ្យហើយ, ព្រោះហេតុនោះ ទេវ-តាទាំងនោះ ទើបឈ្មោះថា **បរនិម្មិតវសវត្តី** ៕

## អធិប្បាយអាយុរបស់មនុស្ស និងទេវតា

ពាក្យថា **“អប្បំ វា ភិយ្យោ”** អធិប្បាយអាយុរបស់ពួកមនុស្សនោះមិនដល់ ២០០ ឆ្នាំ គឺថា មានអាយុ ១០០ ឆ្នាំ លើស ២០ ឆ្នាំ ឬ ៣០ ឆ្នាំ, ៤០, ៥០ ឆ្នាំ ឬថា ៦០ ឆ្នាំ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **“អប្បំ** = អាយុតិច” ព្រោះមិនដល់ ២០០ ឆ្នាំ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **ព្រហ្មបារិសជ្ជា** ជាដើម ព្រហ្មទាំងឡាយជាអ្នកហែហម គឺព្រោះជាបរិវារអ្នកបម្រើមហាព្រហ្ម ព្រោះហេតុនោះ ទើបឈ្មោះថា

**ព្រហ្មបារិសជ្ជា** ។ ឈ្មោះថា **ព្រហ្មបុរោហិតា** ព្រោះតាំងនៅក្នុងភាពជាបុរោហិត (អាចារ្យ) របស់ព្រហ្មទាំងនោះ ។ ឈ្មោះថា **មហាព្រហ្ម** ព្រោះជាព្រហ្មធំដោយភាពជាអ្នកមានវណ្ណៈល្អ និងភាពជាអ្នកមានអាយុវែង ។ សូម្បីព្រហ្មទាំង ៣ នេះ រមែងនៅក្នុងបឋមជ្ឈានភូមិដែលជាផ្ទៃតែមួយ ។ តែថា អាយុនៃព្រហ្មទាំងនោះផ្សេងគ្នា ។ **ព្រហ្ម** ឈ្មោះថា **បរិត្តាភា** ព្រោះមានរស្មីតិច ។ ឈ្មោះថា **អប្បមាណាភា** ព្រោះមានរស្មីរកប្រមាណមិនបាន ។ ក៏ឈ្មោះថា **អាភស្សរា** ព្រោះរស្មីចេញចាកសរីរៈរបស់ព្រហ្មទាំងនោះ ដូចជាអណ្តាតភ្លើងចេញពីប្រទីបមានពន្លឺឆ្វាចៗ ដូចដល់ការ ចោះទម្លុះទៅ ។ សូម្បីជនទាំង ៣ នោះ រមែងនៅក្នុងលំដាប់ជាមួយគ្នាក្នុងទុតិយជ្ឈានភូមិ ។ ក៏ប៉ុន្តែ ការកំណត់អាយុរបស់ព្រហ្មទាំងនោះផ្សេងគ្នា ។ ព្រហ្មដែលឈ្មោះថា **បរិត្តសុភា** ព្រោះសេចក្តីល្អរបស់ព្រហ្មទាំងនោះតិច ។ ឈ្មោះថា **អប្បមាណសុភា** ព្រោះសេចក្តីល្អរបស់ព្រហ្មទាំងនោះ មិនមានប្រមាណ ។ ឈ្មោះថា **សុភកិណ្ហា** ព្រោះព្រហ្មទាំងនោះ មានសេចក្តីល្អដេរដាសទូលំទូលាយ មានរស្មីនៃសរីរៈល្អ មានពណ៌នៃកាយដូចគ្នា មានសិរីដូចផ្ទាំងមាសរុងរឿងឆ្អិនឆ្អៅតាំងនៅក្នុងហិបមាស ។ សូម្បីជនទាំង ៣ នេះ រមែងរស់នៅក្នុងតតិយជ្ឈានភូមិដែលជាលំដាប់ជាមួយគ្នា ។ តែថា ការកំណត់អាយុរបស់ព្រហ្មទាំងនោះផ្សេងគ្នា ។

ពាក្យថា **"អារម្មណនានត្តតា** = អារម្មណ៍ដែលផ្សេងគ្នា" បានដល់ ភាពជាអ្នកមានអារម្មណ៍ផ្សេងគ្នា ក្នុងពាក្យថា **"មនសិការនានត្តតា** = ព្រោះមនសិ-ការដែលផ្សេងគ្នា" ជាដើម ក៏ន័យនេះដែរ ។ បណ្ឌិតគប្បីជ្រាបក្នុងការផ្សេងគ្នានៃអារម្មណ៍នោះ ដូច្នេះ គឺ បឋវីកសិណ រមែងជាអារម្មណ៍របស់បុគ្គលម្នាក់ៗ

។ល។ ឱទាតកសិណ ជាអារម្មណ៍របស់បុគ្គលម្នាក់ ឈ្មោះថា **អារម្មណនានត្តៈ** ដែលប្រែថា មានអារម្មណ៍ផ្សេងគ្នា; ពាក្យថា បុគ្គលម្នាក់រមែងមនសិការនូវបឋវីកសិណ ។ល។ បុគ្គលម្នាក់រមែងមនសិការនូវឱទាតកសិណ នេះឈ្មោះថា មនសិការនានត្តៈ ។ ពាក្យថា បុគ្គលម្នាក់មានឆន្ទៈក្នុងបឋវីកសិណ ។ល។ បុគ្គលម្នាក់មានឆន្ទៈក្នុងឱទាតកសិណនេះ ឈ្មោះថា **ភាពជាអ្នកមានឆន្ទៈផ្សេងគ្នា** ។ ពាក្យថា ម្នាក់រមែងបង្អោនចិត្តទៅដោយអំណាចនៃបឋវីកសិណ ។ល។ ម្នាក់បង្អោនចិត្តទៅក្នុងឱទាតកសិណនេះ ឈ្មោះថា **ភាពជាអ្នកមានបណីធិផ្សេងគ្នា** ។ ពាក្យថា ម្នាក់រមែងបង្អោនចិត្តទៅដោយអំណាចនៃបឋវីកសិណ ។ល។ ម្នាក់បង្អោនចិត្តទៅក្នុងឱទាតកសិណ នេះឈ្មោះថា **ភាពជាអ្នកមានការបង្អោនចិត្តជឿផ្សេងគ្នា** ។ ពាក្យថា បុគ្គលម្នាក់រមែងញុំាងចិត្តឱ្យប្រាថ្នាទៅ ដោយអំណាចនៃបឋវីកសិណ ។ល។ ម្នាក់រមែងឱ្យចិត្តប្រាថ្នាទៅដោយអំណាចនៃឱទាតកសិណនេះឈ្មោះថា **ភាពជាអ្នកមានអភិនីហារផ្សេងគ្នា** ។ ពាក្យថា បុគ្គលម្នាក់មានបញ្ញាអាចកំណត់បឋវីកសិណ ។ល។ ម្នាក់មានបញ្ញាអាចកំណត់ឱទាតកសិណ នេះឈ្មោះថា **ភាពជាអ្នកមានបញ្ញាផ្សេងគ្នា**; ក្នុងអធិការនោះ ព្រះមានព្រះភាគទ្រង់ត្រាស់អារម្មណ៍ និងមនសិការទុកដោយចំណែកខាងដើម ។ ឆន្ទបណីធិ ការបង្អោនចិត្តជឿ និងអភិនីហារ រមែងប្រព្រឹត្តទៅក្នុងអប្បនាខ្លះ ក្នុងឧបចារៈខ្លះ ។ ចំណែកបញ្ញាព្រះមានព្រះភាគត្រាស់ទុកថា ជាមិស្សកៈ គឺទាំងជាលោកិយ និងទាំងជាលោកុត្តរ ។ ពាក្យថា **"អសញ្ញសត្តានំ"** បានដល់ សត្វដែលវៀរចាកសញ្ញា ។ ពិតមែន សមណព្រាហ្មណ៍ពួកខ្លះ បួសក្នុងលទ្ធិផ្សេងៗ ឃើញទោសក្នុងចិត្តថា

“ព្រោះអាស្រ័យចិត្ត ឈ្មោះថា សេចក្ដីត្រេកអរ សេចក្ដីមិនត្រេកអរ និងសេចក្ដីវង្វេង ទើបមាន” ហើយញ៉ាំងសញ្ញាវិរាគៈ (ការអស់នូវសេចក្ដីត្រេកអរក្នុងសញ្ញា) ឱ្យកើតមនសិការថា “ឈ្មោះថា ភាពជាអ្នកមិនមានចិត្តជាវត្ថុដែលពេញចិត្ត និងនោះជាទិដ្ឋធម្មនិព្វាន” ហើយចម្រើនសមាបត្តិ ចូលដល់សញ្ញាវិរាគៈនោះ ទើបកើតឡើងក្នុងភពដែលមិនមានសញ្ញានោះ ។ ក្នុងខណៈនៃការកើតរបស់អសញ្ញសត្តព្រហ្មទាំងនោះ រូបក្ខន្ធតែម្យ៉ាងប៉ុណ្ណោះ រមែងកើតឡើង ។ ព្រហ្មទាំងនោះ កាលឈរកើត ក៏រមែងឈរហើយនុ៎ះឯង, កាលអង្គុយកើត ក៏រមែងអង្គុយហើយនុ៎ះឯង, កាលដេកកើត ក៏រមែងដេកនុ៎ះឯង; ដូចជារូបវិចិត្រ (រូបគំនូរ) តាំងនៅក្នុងភពនោះ រហូតដល់ ៥០០ កប្ប; ក្នុងទីបំផុតនៃព្រហ្មទាំងនោះ រូបកាយនោះ រមែងអន្តរធានទៅ, កាមាវចរសញ្ញារមែងកើតឡើង ។ ដោយហេតុនោះ ទេវតាទាំងនោះរមែងប្រាកដថា “ឃ្លាតហើយចាកកាយនោះ ព្រោះការកើតឡើងនៃសញ្ញា ក្នុងលោកនេះ” ។

ព្រហ្មទាំងនោះ ក៏ឈ្មោះថា **វេហប្ផលា** ព្រោះផលរបស់គេទាំងនោះបរិបូណ៌; ឈ្មោះថា **អវិហា** ព្រោះរមែងមិនសាបសូន្យ មិនសូន្យទៅចាកសមាបត្តិរបស់ខ្លួន ។ ឈ្មោះថា **អតប្បា** ព្រោះរមែងមិនញ៉ាំងសត្វអ្វីៗ ឱ្យក្ដៅក្រហាយ ។ ឈ្មោះថា **សុទស្សា** ព្រោះអត្ថថា ឃើញល្អ មានរូបគួរជ្រះថ្លា ។ ឈ្មោះថា **សុទស្សី** ព្រោះទេវតាទាំងនោះ រមែងឃើញដោយល្អ ឬថា ការឃើញរបស់ទេវតាទាំងនោះល្អ ។ ឈ្មោះថា **អកនិដ្ឋា** ព្រោះជាអ្នកចម្រើនបំផុត ដោយគុណទាំងអស់មែនពិត និងដោយភវសម្បត្តិ សម្រាប់អ្នកមានគុណធម៌តិច រមែងមិនមានក្នុងទីនេះ ។

ពាក្យថា “**អាកាសានញ្ចាយតនំ ឧបគតា**” បានដល់ ចូលដល់អាកាសា-

នញ្ចាយតនៈ ។ សូម្បីក្នុងពាក្យក្រៅអំពីនេះ ក៏ន័យនេះដែរ ។ ភូមិ គឺកាមាវចរ ៦, ព្រហ្មលោក ៩, សុទ្ធាវាស ៥, អរូប ៤, អសញ្ញសត្តា ១ និងវេហប្ផលា ១ រួមជាទេវលោក ២៦ ភូមិ និងមនុស្សលោក ១ ទៀត ទើបជា ២៧ ភូមិ ដោយប្រការដូច្នេះ បណ្ដាភូមិទាំងឡាយ ព្រះសម្មាសម្ពុទ្ធទ្រង់កំណត់អាយុរបស់មនុស្ស និងទេវ-តា ទ្រង់មិនកំណត់អាយុសត្វក្នុងអបាយភូមិ ៤ និងភុម្មទេវតាទាំងឡាយ ។

**សួរថា** ព្រោះហេតុអ្វី ទើបទ្រង់មិនកំណត់អាយុក្នុងអបាយ ៤ និងភុម្មទេវតាទាំងនោះ ?

ឆ្លើយថា ក្នុងនរក កម្មប៉ុណ្ណោះជាប្រមាណ; គឺថា កម្មនៅមិនទាន់អស់ដរាបណា, ក៏រមែងឆេះក្នុងនរកដរាបនោះ, ក្នុងអបាយដ៏សេស ក៏ដូចគ្នា ។ កម្មនោះឯង ជាប្រមាណសូម្បីជារបស់ភុម្មទេវតាទាំងឡាយ ។ ពិតមែន ទេវតារូបខ្លះ កើតហើយក្នុងភូមិនោះ រមែងតាំងនៅបានត្រឹមតែ ៧ ថ្ងៃ, រូបខ្លះតាំងនៅបាន ១ ខែ, **សូម្បីតាំងនៅដល់ ១ កប្ប ក៏មាន** ។ ក្នុងទេវតា និងមនុស្សទាំងនោះ ព្រះសោតាបន្នអ្នកតាំងនៅក្នុងភាពជាគ្រហស្ថក្នុងមនុស្សទាំងឡាយ រមែងសម្រេចនូវសកទាគាមិផលខ្លះ អនាគាមិផលខ្លះ អរហត្តផលខ្លះ ។ បណ្ដាព្រះអរិយៈទាំងនោះ ព្រះសោតាបន្នជាដើម រមែងតាំងនៅរហូតដល់អស់ជីវិត, តែព្រះខីណាស្រពទាំងឡាយប៉ុណ្ណោះ រមែងបរិនិព្វាន ឬថា រមែងបួស ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះធម្មតាថា ព្រះអរហន្តមានគុណប្រសើរបំផុត, តែភេទគ្រហស្ថជាភេទថោកទាប, ភេទនៃគ្រហស្ថទើបមិនអាចទ្រទ្រង់គុណ ដ៏ខ្ពង់ខ្ពស់បំផុតនោះបាន ព្រោះភាវៈជាភេទថោកទាប ។ ព្រោះហេតុដូច្នោះ ព្រះខីណាស្រពទាំងនោះ ទើបប្រាថ្នាដើម្បី

បរិនិព្វាន ឬថា ដើម្បីនឹងបួស ។ ចំណែកភុម្មទេវតា សូម្បីសម្រេចអរហត្ត ហើយ រមែងតាំងនៅរហូតដល់អស់ជីវិត, ព្រះសោតាបន្ន និងព្រះសកទាគាមីនោះឯង ក្នុងទេវតាកាមាវចរ ៦ ជាន់ រមែងតាំងនៅរហូតអស់កាលនៃជីវិត ។ ព្រះអនាគាមី គួរទៅកាន់រូបភព, តែព្រះខីណាស្រព គួរដើម្បីបរិនិព្វាន ។ **សួរថា** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះការមិនមានឱកាស (ទីទំនេរ) ដើម្បីបួសសម្ភ ។ សូម្បីព្រះអរិយបុគ្គលទាំងអស់ ក្នុងរូបាវចរ និងអរូបាវចរ រមែងតាំងនៅរហូតអស់ជីវិត ។ ព្រះសោតាបន្ន និងព្រះសកទាគាមី អ្នកកើត ក្នុងរូបាវចរនោះ រមែងមិនត្រឡប់មកក្នុងលោកនេះទៀត រមែងបរិនិព្វានក្នុងភពនោះឯង ។ ព្រោះថា ព្រះសោតាបន្ន និងសកទាគាមីទាំងនោះ ឈ្មោះថា ជាអ្នកមិនត្រឡប់មកព្រោះឈានលាភី (សំដៅដល់ព្រះសោតាបន្ន និងព្រះសកទាគាមីក្នុងរូបភព មានឈ្មោះថា ឈានលាភី អនាគាមី អ្នកមិនត្រឡប់មកព្រោះបានឈាន) **សួរថា ក៏អ្វីរមែងកំណត់ការបានសមាបត្តិ ៨ ?** ឆ្លើយថា ឈានដែលស្ទាត់ជំនាញនោះ សមាបត្តិ ៨ ទើបកើតឡើង ។ **សួរថា ក៏អ្វីរមែងកំណត់ឈានទាំងឡាយ ដែលស្ទាត់ជំនាញ?** ឆ្លើយថា សេចក្តីប្រាថ្នារមែងកំណត់; គឺបុគ្គលណារមែងប្រាថ្នាការកើតឡើងក្នុងទីណា រមែងធ្វើឈានឱ្យកើតឡើងក្នុងទីនោះៗ ឯង ។

**សួរថា កាលសេចក្តីប្រាថ្នាមិនមាន អ្វីរមែងកំណត់ ?** ឆ្លើយថា សមាបត្តិដែលបុគ្គលនោះចូលដល់ហើយក្នុងសម័យជិតស្លាប់ រមែងកំណត់ ។ **សួរថា សមាបត្តិដែលដល់ព្រមហើយ ក្នុងសម័យជិតស្លាប់មិនមាន អ្វីរមែងកំណត់?** ឆ្លើយថា នេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ ពិតមែន បុគ្គលនោះរមែងកើតឡើង

ក្នុងនេវសញ្ញានាសញ្ញាយតនភព ដោយចំណែកតែមួយ ។ ការកើតក្នុងភពនោះនុ៎ះឯងក្តី ការកើតឡើងក្នុងខាងលើក្តី រមែងមានដល់ព្រះអរិយសាវ័ក អ្នកកើតក្នុងព្រហ្មលោក ៩, មិនមានការកើតឡើងក្នុងភពខាងក្រោមទេ ។ ចំណែកការកើតក្នុងភពនោះក្តី ការកើតឡើងក្នុងភពដែលខ្ពស់ទៅក្តី ការកើតឡើងក្នុងភពខាងទាបក្តី រមែងមានដល់បុថុជ្ជនទាំងឡាយ ។ ការកើតឡើងក្នុងភពនោះក្តី ការកើតឡើងក្នុងភពដែលខ្ពស់ឡើងទៅក្តី រមែងមានដល់ព្រះអរិយសាវ័កក្នុងសុទ្ធាវាស ៥ និងក្នុងអរូបភព ៤ ។ ព្រះអនាគាមីអ្នកកើតក្នុងបឋមជ្ឈានភូមិ ជម្រះព្រហ្មលោក ៩ តាំងនៅក្នុងព្រហ្មលោកជាន់ខ្ពស់បំផុតហើយ ទើបបរិនិព្វាន ។ ក្នុងទេវលោកទាំង ៣ នេះ គឺវេហប្ផលា អកនិដ្ឋា និងនេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា **ភពដ៏ប្រ-សើរបំផុត** ព្រោះអនាគាមីក្នុងភពទាំង ៣ នេះ រមែងមិនទៅកាន់ភពខាងលើ និងមិនចុះទៅកាន់ភពខាងក្រោម, រមែងបរិនិព្វានក្នុងភពនោះៗ ឯង នេះជាបកិណ្ណកៈក្នុងវារៈទី ៦ ដូច្នេះឯង ៕

## អធិប្បាយអភិញ្ញេយ្យាទិវារៈទី ៧

**ក្នុងវារៈទី ៧** បណ្ឌិតគប្បីជ្រាបសេចក្តីនៃ**អភិញ្ញេយ្យៈ** (ធម៌គប្បីដឹងក្រៃ-លែង ឬធម៌ដែលគួរដឹងក្រៃលែង) ដោយអំណាចនៃការដឹងក្រៃលែងនូវការកំណត់ធម៌ដែលប្រព្រឹត្តទៅជាមួយលក្ខណៈ ។ សេចក្តីនៃបរិញ្ញេយ្យៈ (ធម៌គួរកំណត់ដឹង) គប្បីជ្រាបដឹងដោយអំណាចនៃបរិញ្ញាទាំងឡាយ គឺញាតបរិញ្ញា តីរណបរិញ្ញា និងបហានបរិញ្ញា ។ ក៏ក្នុងសេចក្តីនោះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃញាតបរិញ្ញា

និងតីរណបរិញ្ញាប៉ុណ្ណោះ ។

ក្នុងពាក្យថា **"រូបក្ខន្ធ"** ជាអភិញ្ញេយ្យៈ ជាបរិញ្ញេយ្យៈ មិនមែន បហាតព្វៈ ជាដើមនោះឯង ។ **សមុទយសច្ច** បណ្ឌិតគប្បីជ្រាបដោយអំណាចនៃ**បហានបរិញ្ញា** ក្នុងពាក្យថា **"សមុទយសច្ចំ"** ជាអភិញ្ញេយ្យៈ ជាបរិញ្ញេយ្យៈ **និងជាបហាតព្វៈ** ជាដើម ៕

## អធិប្បាយសារម្មណានារម្មណាទិវារៈទី ៨

**ក្នុងវារៈទី ៨** បណ្ឌិតគប្បីជ្រាបការមិនមានអារម្មណ៍ (អនារម្មណៈ) និងមានអារម្មណ៍ (អារម្មណៈ) ដោយអំណាចនៃអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម និងដោយអំណាចនៃវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើម ៕

**ក្នុងវារៈទី ៩** មានសេចក្ដីងាយទាំងអស់ ។ សូម្បីក្នុង **វារៈទី ១០** ពាក្យណាដែលខ្ញុំគប្បីពោល, ពាក្យទាំងអស់នោះ ខ្ញុំពោលហើយក្នុងវារៈ សម្ដែងអំពីបញ្ហាបុច្ឆកៈនោះឯង ។

**ចប់អដ្ឋកថា**

**ធម្មហទយវិភង្គ**

# និគមគាថា

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់គោរពធម៌ ទ្រង់មានទេវតារាប់ពាន់ហែហមហើយ ទ្រង់សម្តែងព្រះអភិធម្មដល់ទេពទាំងឡាយ អ្នកគោរពធម៌ក្នុងទេពនគរ ។

ទ្រង់ជាទីពឹងតែមួយគត់ មិនមានបុរសជាគម្រប់ពីរ ត្រាស់វិភង្គប្បករណ៍ ដែលជាបករណ៍ទី ២ មានគុណបរិសុទ្ធ ប្រដាប់ដោយវិភង្គ ១៨ វិភង្គឯណាទុក ។

ដើម្បីប្រកាសអត្ថនៃបករណ៍នោះ ខ្ញុំឈ្មោះថា **ពុទ្ធឃោសៈ** ដែលព្រះសង្ឃត្ថេរនិមន្តហើយ ដោយគុណដែលមាននៅក្នុងខ្លួន គឺមានឥន្ទ្រិយដែលសង្រួមហើយ មានគតិ (បញ្ញា) មិនស្តឹក មានសេចក្តីដឹងល្អ ដោយហេតុនេះ ទើបខ្ញុំកាន់យកអដ្ឋកថា ផ្តើមរចនាក្នុងអត្ថ ដ៏ល្អិតសុខុមដោយល្អឈ្មោះថា សម្មោហវិនោទនី ដើម្បីបន្ទោបង់មោហៈសេចក្តីវង្វេង មកអធិប្បាយសម្មោហវិនោទនីនេះ រួបរួមយកសារៈនៃអដ្ឋកថារបស់អាចារ្យ ក្នុងពេលមុនទុក ឥឡូវនេះ បករណ៍នេះដល់ទីបំផុតហើយ ដោយព្រះបាលី ៤០ ភាណវារៈ ប្រាសចាកអន្តរាយហើយ យ៉ាងណា សូមមនោរថរបស់សត្វទាំងឡាយ ចូរប្រាសចាកមន្ទិលទាំងឡាយ ចូរសម្រេចសមតាមប្រណិធានសេចក្តីប្រាថ្នាយ៉ាងនោះចុះ ។

ក៏បុណ្យឯណា ដែលខ្ញុំរចនាបករណ៍នេះ ឱ្យសម្រេចហើយ ដើម្បីការតាំងនៅមាំនៃព្រះសទ្ធម្ម ដោយអានុភាពនៃបុណ្យនោះ សូមសត្វលោក ព្រមទាំងទេវលោក ចូរបានទទួលបុណ្យនោះផង។

សូមព្រះសទ្ធម្មចូរតាំងនៅដោយល្អ អស់កាលដ៏យូរ សូមសត្វលោកអ្នកត្រេកអរក្រៃលែងក្នុងព្រះធម៌ ចូរចម្រើនគ្រប់កាល និងសូមជនបទទាំងឡាយ ចូរដល់ព្រមដោយសេចក្តីសុខ មានសេចក្តីក្សេមក្សាន្ត មានភិក្ខារកបានដោយងាយជាដើម អស់កាលជានិច្ចចុះ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ **អដ្ឋកថា វិភង្គប្បករណ៍** ឈ្មោះថា **សម្មោហវិនោទនី** នេះ ព្រះថេរៈដែលគ្រូទាំងឡាយហៅថា **ពុទ្ធឃោសៈ** ប្រដាប់ដោយ សទ្ធាពុទ្ធិ (ការចេះដឹង) និងវីរិយៈដ៏បរិសុទ្ធក្រៃលែង បានញុំាងហេតុនៃសីលអាចារៈ អជ្ជវៈ (សេចក្តីស្មោះត្រង់) និងមទ្ទវៈ (ភាពទន់ភ្លន់) ជាដើម ឱ្យតាំងឡើងហើយ អាចក្នុងការដោះស្រាយសេចក្តីសាំញ៉ាំ (គឺវិនិច្ឆ័យខសេចក្តីដែលស្មុគស្មាញ) ក្នុងសេចក្តីផ្សេងគ្នានៃលទ្ធិរបស់ខ្លួន និងអ្នកដទៃ ប្រកបដោយភាពភ្លឺស្វាងនៃបញ្ញា មានកម្លាំងនៃញាណ ដែលមិនទើសទាក់ក្នុងសត្ថុសាសន៍ អាចវែកញែកការសិក្សាព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា ជាមហាវេយ្យាករណ៍ (គឺជាអ្នកអធិប្បាយដ៏ទូលាយ) ប្រកបដោយលម្អនៃពាក្យពេចន៍ដ៏ពីរោះឯក ទាំងពោលចេញទៅបានស្រួល ដែលកើតអំពីករណសម្បត្តិ ជាអ្នកនិយាយថ្នាក់កំពូល (វាគ្មិន) ដោយនិយាយបាន ទាំងចង និងស្រាយ (សួរឆ្លើយ) ជាកវីថ្មី ជាអលង្ការនៃវង្សរបស់ព្រះថេរៈទាំងឡាយអ្នកនៅក្នុងមហាវិហារ ដែលជាប្រទីបនៃថេរវង្ស * មាន

---

* តាំងពីពាក្យថា ដែលជាប្រទីបនៃថេរវង្ស...។ ល ។... បដិសម្ភិទាឈ្លាស ជាពាក្យពង្រីកសេចក្តីនៃការសំដែងគុណសម្បត្តិរបស់ព្រះថេរៈអ្នកនៅក្នុងមហាវិហារ មិនមែនរបស់អ្នករចនាគម្ពីរនេះទេ ។

សេចក្តីដឹងមុតមាំល្អ ក្នុងឧត្តរិមនុស្សធម៌ដែលប្រដាប់ដោយគុណ មានអភិញ្ញា ៦ ជាដើម មានបដិសម្ភិទា ដែលខ្លួនចាក់ធ្លុះហើយ ជាបរិវារ មានសេចក្តីដឹងបរិសុទ្ធទូលំទូលាយ ជាអ្នកធ្វើបករណ៍នេះទុក ។

សូមបករណ៍ដែលសម្តែងន័យរបស់បញ្ញាវិសុទ្ធិនេះ ចូរតាំងនៅក្នុងលោក ដើម្បីកុលបុត្រទាំងឡាយ អ្នកស្វែងរកធម៌ ជាគ្រឿងរលាស់ខ្លួនចេញចាកលោក ដរាបដល់ព្រះនាមថា **ពុទ្ធោ** របស់អង្គព្រះលោកជេដ្ឋ មហាឥសីដែលមានចិត្តបរិសុទ្ធ ជាអ្នកនឹងធឹង ដែលប្រព្រឹត្តទៅក្នុងលោកចុះ ។

ភ្នំធំតាំងនៅ ដរាបណា ព្រះចន្ទនៅមានពន្លឺ ដរាបណា
សូមព្រះសទ្ធម្ម របស់ព្រះគោតម ដែលមានយសធំ ចូរ
តាំងនៅដរាបនោះចុះ ៕

# សម្មោហវិនោទនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ វិភង្គបករណ៍

## តតិយភាគ ៤

## ចប់ដោយបរិបូណ៌

បោះពុម្ពលើកទី ២

រក្សាសិទ្ធិ ( ហាមថតចម្លង)